

ឯកសារគម្ពីរព្រះត្រៃបិដកស្កេននេះ
ត្រូវបានថតចេញពីច្បាប់គម្ពីរព្រះត្រៃបិដកដប៉ុន ៗ

ឯកសារគម្ពីរព្រះត្រៃបិដកនេះ ចាប់ពីភាគ១ ដល់ ភាគ៥០
គឺជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងបុត្រធីតា,
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត-សាវង្ស ៗ និងទុកក្នុង
គេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ៗ

កែសម្រួលតាមកុំព្យូទ័រ តម្រូវឧបករណ៍អានអេឡិចត្រូនិច
ដោយខ្ញុំព្រះករុណា ខ្ញុំបាទ ស្រុង-ចាន់ណា ៗ៕

www.5000-years.org

# ព្រះ
# ត្រៃបិដកបាលី
## និង
# សេចក្ដីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
# សំយុត្តនិកាយ ខន្ធវារវគ្គ
# បញ្ចមភាគ
# ៣៣

បោះពុម្ពលើកទី ២

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព.ស. ២៥០៦

# សុត្តន្តបិដកេ

# សំយុត្តនិកាយស្ស ខន្ធវារវគ្គោ

## បញ្ចមោ ភាគោ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## ខន្ធសំយុត្តំ

### មូលបណ្ណាសកេ នកុលបិតវគ្គោ

(១) ឯវំមេ សុតំ ។ ឯកំ សមយំ ភគវា ភគ្គេសុ វិហរតិ សុំសុមារគិរេ ភេសកឡាវនេ មិគទាយេ ។ បេ ។ អថខោ នកុលបិតា គហបតិ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ នកុលបិតា គហបតិ ភគវន្តំ ឯតទវោច អហមស្មិ ភន្តេ ជិណ្ណោ វុឌ្ឍោ មហល្លកោ

# សុត្តន្តបិដក

# សំយុត្តនិកាយ ខន្ធវារវគ្គ

## បញ្ចមភាគ

---

*សូមក្រាបថ្វាយបង្គំចំពោះព្រះមានព្រះភាគ*

*ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ។*

## ខន្ធសំយុត្ត

### មូលបណ្ណាសកៈ នកុលបិតវគ្គ

(១) ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងភេសកឡាវ័ន ជាទីឲ្យនូវអភ័យដល់សត្វម្រឹគ ជិតក្រុងសុំសុមារគិរៈ ក្នុងដែនភគ្គៈ ។ បេ ។ គ្រានោះឯង គហបតី ឈ្មោះនកុលបិតា (ជាបិតារបស់កុមារឈ្មោះនកុលៈ) ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះនកុលបិតាគហបតី អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជរាហើយ មានវ័យចម្រើនហើយ ចាស់ហើយ

អទ្ធគតោ វយោអនុប្បត្តោ អាតុរកាយោ អភិក្ខណា-
តង្កោ អនិច្ចទស្សាវី ខោ បនាហំ ភន្តេ ភគវតោ ម-
នោភាវនីយានញ្ច ភិក្ខូនំ ឱវទតុ មំ ភន្តេ ភគវា អនុ-
សាសតុ មំ ភន្តេ ភគវា យំ មមស្ស ទីឃរត្តំ ហិតា-
យ សុខាយាតិ ។ ឯវមេតំ គហបតិ ឯវមេតំ គហបតិ
អាតុរោ ហាយំ គហបតិ កាយោ អណ្ឌភូតោ បរិ-
យោនទ្ធោ យោ ហិ គហបតិ ឥមំ កាយំ បរិហរន្តោ
មុហុត្តំបិ អារោគ្យំ បដិជានេយ្យ កិមញ្ញត្រ ពាល្យា
តស្មាតិហ តេ គហបតិ ឯវំ សិក្ខិតព្វំ អាតុរកាយស្ស
មេ សតោ ចិត្តំ អនាតុរំ ភវិស្សតីតិ ឯវំ ហិ តេ គហបតិ
សិក្ខិតព្វន្តិ ។

មានវ័យកន្លងហើយ ចូលក្នុងបច្ឆិមវ័យហើយ មានកាយសោប់សេល់ មានជម្ងឺរឿយ ៗ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនបានឃើញព្រះមានព្រះភាគ និងពួកភិក្ខុគួរដល់ការចម្រើននៃចិត្ត អស់កាលជានិច្ចទេ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគទូន្មានខ្ញុំព្រះអង្គ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគប្រៀនប្រដៅខ្ញុំព្រះអង្គ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ខ្ញុំព្រះអង្គ អស់កាលជាយូរអង្វែង ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលគហបតី ការណ៍នុ៎ះយ៉ាងហ្នឹងហើយ ម្នាលគហបតី ការណ៍នុ៎ះយ៉ាងហ្នឹងហើយ ម្នាលគហបតី ព្រោះថា កាយនេះតែងសោប់សេល់ (មិនមាំមួន) ដូចជាស៊ុតសត្វ គ្រាន់តែមានសម្បកពាសព័ទ្ធជុំវិញ ម្នាលគហបតី អ្នកណាដែលរក្សាកាយនេះ សំគាល់ថាគ្មានរោគ សូម្បីមួយរំពេច អ្នកនោះឯង មិនមានអ្វីក្រៅពីសេចក្តីល្ងង់ទេ ម្នាលគហបតី ព្រោះហេតុនោះ គួរអ្នកសិក្សាយ៉ាងនេះថា កាលបើអាត្មាអញ មានកាយសោប់សេល់ ចិត្តនឹងមិនសោប់សេល់ទេ ម្នាលគហបតី គួរអ្នកសិក្សា យ៉ាងនេះចុះ ។

(២) អថខោ នកុលបិតា គហបតិ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា យេនាយស្មា សារីបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ សារីបុត្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ នកុលបិតរំ គហបតឹ អាយស្មា សារីបុត្តោ ឯតទវោច វិប្បសន្នានិ ខោ តេ គហបតិ ឥន្ទ្រិយានិ បរិសុទ្ធោ មុខវណ្ណោ បរិយោទាតោ អលត្ថ នោ អជ្ជ ភគវតោ សម្មុខា ធម្មឹ កថំ សវនាយាតិ ។ កិញ្ហិ នោ សិយា ភន្តេ ឥទានាហំ ភន្តេ ភគវតា ធម្មិយា កថាយ អមតេន អភិសិត្តោតិ ។ យថាកថំ បន ត្វំ គហបតិ ភគវតា ធម្មិយា កថាយ អមតេន អភិសិត្តោតិ ។ ឥធាហំ ភន្តេ យេន ភគវា តេនុបសង្កមឹ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹ ។ ឯកមន្តំ និសិន្នោ ខោហំ ភន្តេ ភគវន្តំ ឯតទវោចំ អហមស្មិ ភន្តេ ជិណ្ណោ វុឌ្ឍោ មហល្លកោ

[២] លំដាប់នោះ នកុលបិតាគហបតី ត្រេកអរ រីករាយ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ហើយក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណ ហើយចូលទៅរកព្រះសារីបុត្តមានអាយុ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះសារីបុត្តមានអាយុ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះនកុលបិតាគហបតី អង្គុយក្នុងទីដ៏សមគួរហើយ ទើបព្រះសារីបុត្តមានអាយុ និយាយយ៉ាងនេះថា ម្នាលគហបតី ឥន្ទ្រិយរបស់អ្នកស្រស់បស់ សម្បុរមុខក៏ស្អាតផូរផង់ ចំនងជាបានស្តាប់ធម្មីកថា ក្នុងទីចំពោះព្រះភក្ត្ររបស់ព្រះមានព្រះភាគ ក្នុងថ្ងៃនេះហើយទេដឹង ។ បពិត្រលោកដ៏ចម្រើន ថ្វីក៏ខ្ញុំព្រះករុណាមិនបានស្តាប់ បពិត្រលោកដ៏ចម្រើន អម្បាញ់មិញ ព្រះមានព្រះភាគបានស្រោចស្រព់ទឹកអម្រឹតគឺធម្មីកថា ដល់ខ្ញុំព្រះករុណា ។ ម្នាលគហបតី ចុះព្រះមានព្រះភាគស្រោចស្រព់ទឹកអម្រឹតគឺធម្មីកថាដល់អ្នក ដូចម្តេចខ្លះ ។ បពិត្រលោកដ៏ចម្រើន ក្នុងអម្បាញ់មិញនេះ ខ្ញុំព្រះករុណាបានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគហើយអង្គុយក្នុងទីដ៏សមគួរ ។ បពិត្រលោកដ៏ចម្រើន លុះខ្ញុំអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជរាហើយ មានវ័យចម្រើនហើយ ចាស់ហើយ

អទ្ធគតោ វយោអនុប្បត្តោ អាតុរកាយោ អភិក្ខណា-
តង្កោ អចិរទស្សាវី ខោ បនាហំ ភន្តេ ភគវតោ មនោ-
ភាវនីយានញ្ច ភិក្ខូនំ ឱវទតុ មំ ភន្តេ ភគវា អនុសា-
សតុ មំ ភន្តេ ភគវា យំ មម អស្ស ទីឃរត្តំ ហិតាយ
សុខាយាតិ ។ ឯវំ វុត្តេ មំ ភន្តេ ភគវា ឯតទវោច
ឯវមេតំ គហបតិ ឯវមេតំ គហបតិ អាតុរោ ហាយំ
គហបតិ កាយោ អណ្ឌភូតោ បរិយោនទ្ធោ យោ ហិ
គហបតិ ឥមំ កាយំ បរិហរន្តោ មុហុត្តម្បិ អារោគ្យំ
បដិជានេយ្យ កិមញ្ញត្រ ពាល្យា តស្មាតិហ តេ គហ-
បតិ ឯវំ សិក្ខិតព្វំ អាតុរកាយស្ស មេ សតោ ចិត្តំ
អនាតុរំ ភវិស្សតីតិ ឯវំ ហិ តេ គហបតិ សិក្ខិតព្វន្តិ ។
ឯវំ ខ្វាហំ ភន្តេ ភគវតា ធម្មិយា កថាយ អមតេន
អភិសិត្តោតិ ។

មានវ័យកន្លងហើយ ចូលមកកាន់បច្ឆិមវ័យហើយ មានកាយរសាប់រសល់ មានជម្ងឺរឿយៗ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនបានឃើញព្រះមានព្រះភាគ និងពួកភិក្ខុគួរដល់ការចម្រើននៃចិត្ត អស់កាលជានិច្ចទេ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទូន្មានខ្ញុំព្រះអង្គ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ប្រៀនប្រដៅខ្ញុំព្រះអង្គ ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់ខ្ញុំព្រះអង្គ អស់កាលជាយូរអង្វែង ។ បពិត្រលោកដ៏ចម្រើន កាលបើខ្ញុំព្រះករុណា ក្រាបទូលយ៉ាងនេះហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់ចំពោះខ្ញុំករុណា យ៉ាងនេះថា ម្នាលគហបតី ការណ៍នុ៎ះយ៉ាងហ្នឹងហើយ ម្នាលគហបតី ការណ៍នុ៎ះយ៉ាងហ្នឹងហើយ ម្នាលគហបតី ព្រោះថាកាយនេះ តែងរសាប់រសល់ (មិនមាំមួន) ដូចស៊ុតសត្វ មានសម្បកពាសព័ទ្ធជុំវិញ ម្នាលគហបតី អ្នកណាដែលរក្សាកាយនេះ សំគាល់ថាគ្មានរោគ សូម្បីមួយរំពេច អ្នកនោះឯងមិនមានអ្វីក្រៅពីសេចក្ដីល្ងង់ទេ ម្នាលគហបតី ព្រោះហេតុនោះ គួរអ្នកសិក្សាយ៉ាងនេះថា កាលបើអាត្មាអញមានកាយរសាប់រសល់ តែចិត្តនឹងមិនរសាប់រសល់ទេ ម្នាលគហបតី អ្នកគួរសិក្សាយ៉ាងនេះចុះ ។ បពិត្រលោកដ៏ចម្រើន ព្រះមានព្រះភាគ ស្រោចស្រប់ទឹកអម្រឹតគឺធម៌កថា ដល់ខ្ញុំព្រះករុណា យ៉ាងនេះឯង ។

(៣) ន ហិ បន តំ គហបតិ បដិភាសិ ភគវន្តំ ឧត្តរឹ បដិបុច្ឆិតុំ កិត្តាវតា នុ ខោ ភន្តេ អាតុរកាយោ ចេវ ហោតិ អាតុរចិត្តោ ច កិត្តាវតា ច បន អាតុរ-កាយោ ហិ ខោ ហោតិ នោ ច អាតុរចិត្តោតិ ។ ទូរតោបិ ខោ មយំ ភន្តេ អាគច្ឆេយ្យាម អាយស្មតោ សារីបុត្តស្ស សន្តិកេ ឯតស្ស ភាសិតស្ស អត្ថមញ្ញាតុំ សាធុ វតា-យស្មន្តំយេវ សារីបុត្តំ បដិភាតុ ឯតស្ស ភាសិតស្ស អត្ថោតិ ។ តេនហិ គហបតិ សុណាហិ សាធុកំ មន-សិករោហិ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ នកុល-បិតា គហបតិ អាយស្មតោ សារីបុត្តស្ស បច្ចស្សោសិ ។ អាយស្មា សារីបុត្តោ ឯតទវោច

[៣] ម្នាលគហបតី ចុះអ្នកមិនអាចសួរបញ្ជាក់ ចំពោះព្រះមានព្រះភាគតទៅទៀតថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលមានកាយក្រសាប់ក្រសល់ផង មានចិត្តក្រសាប់ក្រសល់ផង ដោយហេតុដូចម្ដេចខ្លះ មួយទៀត បុគ្គលមានកាយក្រសាប់ក្រសល់ តែមានចិត្តក្រសាប់ក្រសល់ ដូចម្ដេចខ្លះទេឬ ។ បពិត្រលោកដ៏ចម្រើន យើងខ្ញុំមកពីចម្ងាយដើម្បីដឹងសេចក្ដីនៃភាសិតនុ៎ះ ក្នុងសំណាក់ព្រះសារីបុត្តមានអាយុ (ឯណោះវិញ) ខ្ញុំព្រះករុណាសូមអង្វរ សូមព្រះសារីបុត្តមានអាយុ បំភ្លឺសេចក្ដីនៃភាសិតនេះឲ្យបាន ។ ម្នាលគហបតី បើដូច្នោះ ចូរអ្នកប្រុងស្ដាប់ យកចិត្តទុកដាក់ឲ្យប្រពៃចុះ អាត្មានឹងសំដែងជូន ។ នកុលបិតាគហបតី ទទួលពាក្យព្រះសារីបុត្តមានអាយុថា ព្រះករុណា លោកម្ចាស់ ។ ព្រះសារីបុត្តមានអាយុ សំដែងយ៉ាងនេះថា

[៤] កថញ្ច គហបតិ អាតុរកាយោ ចេវ ហោតិ អាតុរចិត្តោ ច ។ ឥធ គហបតិ អស្សុតវា បុថុជ្ជនោ អរិយានំ អទស្សាវី អរិយធម្មស្ស អកោវិទោ អរិយធម្មេ អវិនីតោ សប្បុរិសានំ អទស្សាវី សប្បុរិសធម្មស្ស អកោវិទោ សប្បុរិសធម្មេ អវិនីតោ រូបំ អត្តតោ សមនុបស្សតិ រូបវន្តំ វា អត្តានំ អត្តនិ វា រូបំ រូបស្មឹ វា អត្តានំ អហំ រូបំ មម រូបន្តិ បរិយុដ្ឋដ្ឋាយី ហោតិ ។ តស្ស អហំ រូបំ មម រូបន្តិ បរិយុដ្ឋដ្ឋាយិនោ តំ រូបំ វិបរិណាមតិ អញ្ញថា ហោតិ តស្ស រូបវិបរិណាមញ្ញថាភាវា ឧប្បជ្ជន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសា ។ វេទនំ អត្តតោ សមនុបស្សតិ វេទនាវន្តំ វា អត្តានំ អត្តនិ វា វេទនំ វេទនាយ វា អត្តានំ អហំ វេទនា មម វេទនាតិ បរិយុដ្ឋដ្ឋាយី ហោតិ ។ តស្ស អហំ វេទនា មម វេទនាតិ បរិយុដ្ឋដ្ឋាយិនោ សា វេទនា វិបរិណាមតិ

(៤) ម្នាលគហបតី បុគ្គលមានកាយសៅហ្មងផង មានចិត្តសៅហ្មងផង តើដូចម្តេច ។ ម្នាលគហបតី បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង ជាអ្នកមិនឃើញពួកព្រះអរិយៈ មិនឈ្លាសវៃក្នុងធម៌ព្រះអរិយៈ មិនបានសិក្សាក្នុងធម៌ព្រះអរិយៈ មិនបានឃើញពួកសប្បុរស មិនឈ្លាសវៃក្នុងធម៌សប្បុរស មិនបានសិក្សាក្នុងធម៌របស់សប្បុរស រមែងពិចារណាឃើញច្បាស់នូវរូបថាជាខ្លួន នូវខ្លួនថាមានរូបខ្លះ នូវរូបថាមានក្នុងខ្លួនខ្លះ នូវខ្លួនថាមានក្នុងរូបខ្លះ រមែងប្រកាន់ថារូបគឺអញ រូបរបស់អាត្មាអញ ។ កាលបើបុគ្គលនោះ មានចិត្តប្រកាន់ថារូបគឺអញ រូបរបស់អាត្មាអញ លុះដល់រូបនោះប្រែប្រួលទៅ ប្លែកទៅ សេចក្តីសោក សេចក្តីខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត រមែងកើតឡើងដល់បុគ្គលនោះ ព្រោះតែរូបប្រែប្រួល ប្លែកទៅ ។ បុគ្គលនោះ ពិចារណាឃើញនូវវេទនាថាជាខ្លួន នូវខ្លួនថាមានវេទនាខ្លះ នូវវេទនាថាមានក្នុងខ្លួនខ្លះ នូវខ្លួនថាមានក្នុងវេទនាខ្លះ មានសេចក្តីប្រកាន់ថាវេទនាគឺអញ វេទនារបស់អាត្មាអញ ។ កាលបុគ្គលនោះ មានសេចក្តីប្រកាន់ថា វេទនាគឺអញ វេទនារបស់អាត្មាអញដូច្នេះ លុះដល់វេទនានោះប្រែប្រួលទៅ

អញ្ញថា ហោតិ តស្ស វេទនាវិបរិណាមញ្ញថាភាវា ឧប្បជ្ជន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសា ។ សញ្ញំ អត្តតោ សមនុបស្សតិ សញ្ញាវន្តំ វា អត្តានំ អត្តនិ វា សញ្ញំ សញ្ញាយ វា អត្តានំ អហំ សញ្ញា មម សញ្ញាតិ បរិយុដ្ឋដ្ឋាយី ហោតិ ។ តស្ស អហំ សញ្ញា មម សញ្ញាតិ បរិយុដ្ឋដ្ឋាយិនោ សា សញ្ញា វិបរិណមតិ អញ្ញថា ហោតិ តស្ស សញ្ញាវិបរិណាមញ្ញថាភាវា ឧប្បជ្ជន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសា ។ សង្ខារេ អត្តតោ សមនុបស្សតិ សង្ខារវន្តំ វា អត្តានំ អត្តនិ វា សង្ខារេ សង្ខារេសុ វា អត្តានំ អហំ សង្ខារា មម សង្ខារាតិ បរិយុដ្ឋដ្ឋាយី ហោតិ ។ តស្ស អហំ សង្ខារា មម សង្ខារាតិ បរិយុដ្ឋដ្ឋាយិនោ តេ សង្ខារា វិបរិណមន្តិ អញ្ញថា ហោតិ តស្ស សង្ខារវិបរិណាមញ្ញថាភាវា ឧប្បជ្ជន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសា ។

ប្រែទៅ សេចក្ដីសោក សេចក្ដីខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្ដីចង្អៀតចង្អល់ចិត្ត តែងកើតឡើងដល់បុគ្គលនោះ ព្រោះតែវេទនាប្រែប្រួលទៅ ប្រែទៅ ។ បុគ្គលពិចារណាឃើញ នូវសញ្ញាថាជាខ្លួនខ្លះ នូវខ្លួនថាមានសញ្ញាខ្លះ នូវសញ្ញាថាមានក្នុងខ្លួនខ្លះ នូវខ្លួនថាមានក្នុងសញ្ញាខ្លះ ក៏ប្រកាន់ថាសញ្ញាគឺអញ សញ្ញារបស់អាត្មាអញ ។ កាលបើបុគ្គលនោះមានសេចក្ដីប្រកាន់ថា សញ្ញាគឺអញ សញ្ញារបស់អាត្មាអញ លុះដល់សញ្ញានោះប្រែប្រួលទៅ ប្រែទៅ សេចក្ដីសោក សេចក្ដីខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្ដីចង្អៀតចង្អល់ចិត្ត តែងកើតឡើងដល់បុគ្គលនោះ ព្រោះតែសញ្ញាប្រែប្រួលទៅ ប្រែទៅ ។ បុគ្គលពិចារណាឃើញនូវសង្ខារទាំងឡាយថាជាខ្លួនខ្លះ នូវខ្លួនថាមានសង្ខារខ្លះ នូវសង្ខារទាំងឡាយថាមានក្នុងខ្លួនខ្លះ នូវខ្លួនថាមានក្នុងសង្ខារទាំងឡាយខ្លះ តែងប្រកាន់ថាសង្ខារទាំងឡាយគឺអញ សង្ខារទាំងឡាយរបស់អាត្មាអញ ។ កាលបុគ្គលនោះមានសេចក្ដីប្រកាន់ថា សង្ខារទាំងឡាយគឺអញ សង្ខារទាំងឡាយរបស់អាត្មាអញ លុះដល់សង្ខារទាំងនោះប្រែប្រួលទៅ ប្រែទៅ សេចក្ដីសោក សេចក្ដីខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្ដីចង្អៀតចង្អល់ចិត្ត តែងកើតឡើងដល់បុគ្គលនោះ ព្រោះតែសង្ខារទាំងឡាយប្រែប្រួលទៅ ប្រែទៅ ។

វិញ្ញាណំ អត្តតោ សមនុបស្សតិ វិញ្ញាណវន្តំ វា អត្តានំ អត្តនិ វា វិញ្ញាណំ វិញ្ញាណស្មឹ វា អត្តានំ អហំ វិញ្ញាណំ មម វិញ្ញាណន្តិ បរិយុដ្ឋដ្ឋាយី ហោតិ ។ តស្ស អហំ វិញ្ញាណំ មម វិញ្ញាណន្តិ បរិយុដ្ឋដ្ឋាយិនោ តំ វិញ្ញាណំ វិបរិណមតិ អញ្ញថា ហោតិ តស្ស វិញ្ញាណវិបរិណាមញ្ញថាភាវា ឧប្បជ្ជន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសា ។ ឯវំ ខោ គហបតិ អាតុរកាយោ ចេវ ហោតិ អាតុរចិត្តោ ច ។

(៩) កថញ្ច គហបតិ អាតុរកាយោ ហិ ខោ ហោតិ នោ ច អាតុរចិត្តោ ។ ឥធ គហបតិ សុតវា អរិយសាវកោ អរិយានំ ទស្សាវី អរិយធម្មស្ស កោវិទោ

បុគ្គលពិចារណាឃើញ នូវវិញ្ញាណថាជាខ្លួនខ្លះ នូវខ្លួនថាមានវិញ្ញាណខ្លះ នូវវិញ្ញាណថាមានក្នុងខ្លួនខ្លះ នូវខ្លួនថាមានក្នុងវិញ្ញាណខ្លះ តែងប្រកាន់ថា វិញ្ញាណគឺអញ វិញ្ញាណរបស់អាត្មាអញ ។ កាលបុគ្គលនោះ មានសេចក្តីប្រកាន់ថា វិញ្ញាណគឺអញ វិញ្ញាណរបស់អាត្មាអញ លុះដល់វិញ្ញាណនោះប្រែប្រួលទៅ ប្លែកទៅ សេចក្តីសោក សេចក្តីខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត តែងកើតឡើងដល់បុគ្គលនោះ ព្រោះតែវិញ្ញាណប្រែប្រួលទៅ ប្លែកទៅ ។ ម្នាលគហបតី បុគ្គលមានកាយសោប់សេល់ផង មានចិត្តសោប់សេល់ផង យ៉ាងនេះឯង ។

[៤] ម្នាលគហបតី ចុះបុគ្គលមានកាយសោប់សេល់ តែចិត្តមិនសោប់សេល់ តើដូចម្តេច ។ ម្នាលគហបតី អរិយសាវ័កក្នុងលោកនេះ ជាអ្នកចេះដឹង បានឃើញពួកព្រះអរិយៈឈ្លាសវៃក្នុងធម៌ព្រះអរិយៈ

អរិយធម្មេ សុវិនីតោ សប្បុរិសានំ ទស្សាវី សប្បុរិសធម្មស្ស កោវិទោ សប្បុរិសធម្មេ សុវិនីតោ ន រូបំ អត្តតោ សមនុបស្សតិ ន រូបវន្តំ វា អត្តានំ ន អត្តនិ វា រូបំ ន រូបស្មឹ វា អត្តានំ អហំ រូបំ មម រូបន្តិ ន បរិយុដ្ឋដ្ឋាយី ហោតិ ។ តស្ស អហំ រូបំ មម រូបន្តិ អបរិយុដ្ឋដ្ឋាយិនោ តំ រូបំ វិបរិណមតិ អញ្ញថា ហោតិ តស្ស រូបវិបរិណាមញ្ញថាភាវា នុប្បជ្ជន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសា ។ ន វេទនំ អត្តតោ សមនុបស្សតិ ន វេទនាវន្តំ វា អត្តានំ ន អត្តនិ វា វេទនំ ន វេទនាយ វា អត្តានំ អហំ វេទនា មម វេទនាតិ ន បរិយុដ្ឋដ្ឋាយី ហោតិ ។ តស្ស អហំ វេទនា មម វេទនាតិ អបរិយុដ្ឋដ្ឋាយិនោ សា វេទនា វិបរិណមតិ អញ្ញថា ហោតិ តស្ស វេទនាវិបរិណាមញ្ញថាភាវា នុប្បជ្ជន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសា ។ ន សញ្ញំ អត្តតោ សមនុបស្សតិ

បានសិក្សាចំពោះធម៌ព្រះអរិយៈ ឃើញពួកសប្បុរស ឈ្លាសវៃក្នុងធម៌សប្បុរស បានសិក្សាចំពោះធម៌សប្បុរស រមែងមិនពិចារណាឃើញនូវរូបថាជាខ្លួនខ្លះ មិនឃើញនូវខ្លួនថាមានរូបខ្លះ មិនឃើញនូវរូបថាមានក្នុងខ្លួនខ្លះ មិនឃើញនូវខ្លួនថាមានក្នុងរូបខ្លះ មិនប្រកាន់ថារូបគឺអញ រូបរបស់អាត្មាអញទេ ។ កាលបុគ្គលនោះ មិនប្រកាន់ថា រូបគឺអញ រូបរបស់អាត្មាអញទេ លុះរូបនោះប្រែប្រួលទៅ ប្លែកទៅ សេចក្តីសោក សេចក្តីខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត ក៏មិនបានកើតឡើងដល់បុគ្គលនោះ ព្រោះតែរូបប្រែប្រួលទៅ ប្លែកទៅឡើយ ។ មិនពិចារណាឃើញនូវវេទនាថាជាខ្លួនខ្លះ មិនឃើញនូវខ្លួនថាមានវេទនាខ្លះ មិនឃើញនូវវេទនាថាមានក្នុងខ្លួនខ្លះ មិនឃើញនូវខ្លួនថាមានក្នុងវេទនាខ្លះ មិនប្រកាន់ថាវេ-ទនាគឺអញ វេទនារបស់អាត្មាអញទេ ។ កាលបុគ្គលនោះ មិនប្រកាន់ថា វេទនាគឺអញ វេទនារបស់អាត្មាអញទេ លុះវេទនានោះប្រែប្រួលទៅ ប្លែកទៅ សេចក្តីសោក សេចក្តីខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត មិនកើតឡើងដល់បុគ្គលនោះ ព្រោះតែវេទនាប្រែប្រួលទៅ ប្លែកទៅឡើយ ។ មិនពិចារណាឃើញនូវសញ្ញាថាជាខ្លួនខ្លះ

ន សញ្ញាវន្តំ វា អត្តានំ ន អត្តនិ វា សញ្ញំ ន សញ្ញាយ វា អត្តានំ អហំ សញ្ញា មម សញ្ញាតិ ន បរិយុដ្ឋដ្ឋាយី ហោតិ ។ តស្ស អហំ សញ្ញា មម សញ្ញាតិ អបរិយុដ្ឋដ្ឋាយិនោ សា សញ្ញា វិបរិណមតិ អញ្ញថា ហោតិ តស្ស សញ្ញាវិបរិណាមញ្ញថាភាវា នុប្បជ្ជន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសា ។ ន សង្ខារេ អត្តតោ សមនុបស្សតិ ន សង្ខារវន្តំ វា អត្តានំ ន អត្តនិ វា សង្ខារេ ន សង្ខារេសុ វា អត្តានំ អហំ សង្ខារា មម សង្ខារាតិ ន បរិយុដ្ឋដ្ឋាយី ហោតិ ។ តស្ស អហំ សង្ខារា មម សង្ខារាតិ អបរិយុដ្ឋដ្ឋាយិនោ តេ សង្ខារា វិបរិណមន្តិ អញ្ញថា ហោន្តិ តស្ស សង្ខារវិបរិណាមញ្ញថាភាវា នុប្បជ្ជន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសា ។ ន វិញ្ញាណំ អត្តតោ សមនុបស្សតិ ន វិញ្ញាណវន្តំ វា អត្តានំ ន អត្តនិ វា វិញ្ញាណំ ន វិញ្ញាណស្មឹ វា អត្តានំ អហំ វិញ្ញាណំ មម វិញ្ញាណន្តិ ន បរិយុដ្ឋដ្ឋាយី ហោតិ ។ តស្ស

មិនឃើញនូវខ្លួនថាមានសញ្ញាខ្លះ មិនឃើញនូវសញ្ញាថាមានក្នុងខ្លួនខ្លះ មិនឃើញនូវខ្លួនថាមានក្នុងសញ្ញាខ្លះ មិនប្រកាន់ថាសញ្ញាគឺអញ សញ្ញារបស់អាត្មាអញទេ ។ កាលបុគ្គលនោះ មិនប្រកាន់ថាសញ្ញាគឺអញ សញ្ញារបស់អាត្មាអញទេ លុះសញ្ញានោះប្រែប្រួលទៅ ប្លែកទៅ សេចក្តីសោក សេចក្តីខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត ក៏មិនកើតឡើងដល់បុគ្គលនោះ ព្រោះតែសញ្ញាប្រែប្រួលទៅ ប្លែកទៅឡើយ ។ មិនពិចារណាឃើញនូវសង្ខារទាំងឡាយថាជាខ្លួនខ្លះ មិនឃើញនូវខ្លួនថាមានសង្ខារខ្លះ មិនឃើញនូវសង្ខារទាំងឡាយថាមានក្នុងខ្លួនខ្លះ មិនឃើញនូវខ្លួនថាមានក្នុងសង្ខារទាំងឡាយខ្លះ មិនប្រកាន់ថាសង្ខារទាំងឡាយគឺអញសង្ខារទាំងឡាយរបស់អាត្មាអញទេ ។ កាលបុគ្គលនោះមិនប្រកាន់ថាសង្ខារទាំងឡាយគឺអញ សង្ខារទាំងឡាយរបស់អាត្មាអញទេ លុះសង្ខារទាំងនោះប្រែប្រួលទៅ ប្លែកទៅ សេចក្តីសោក សេចក្តីខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត មិនកើតឡើងដល់បុគ្គលនោះ ព្រោះតែសង្ខារទាំងឡាយប្រែប្រួលទៅ ប្លែកទៅឡើយ ។ មិនពិចារណាឃើញនូវវិញ្ញាណថាជាខ្លួនខ្លះ មិនឃើញនូវខ្លួនថាមានវិញ្ញាណខ្លះ មិនឃើញនូវវិញ្ញាណថាមានក្នុងខ្លួនខ្លះ មិនឃើញនូវខ្លួនថាមានក្នុងវិញ្ញាណខ្លះ មិនបានប្រកាន់ថាវិញ្ញាណគឺអញ វិញ្ញាណរបស់អាត្មាអញទេ ។ កាលបុគ្គលនោះ

អហំ វិញ្ញាណំ មម វិញ្ញាណន្តិ អបរិយុដ្ឋដ្ឋាយិនោ តំ វិញ្ញាណំ វិបរិណមតិ អញ្ញថា ហោតិ តស្ស វិញ្ញាណវិបរិណាមញ្ញថាភាវា នុប្បជ្ជន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសា ។ ឯវំ ខោ គហបតិ អាតុរកាយោបិ ខោ ហោតិ នោ ច អាតុរចិត្តោតិ ។ ឥទមវោច អាយស្មា សារីបុត្តោ អត្តមនោ នកុលបិតា គហបតិ អាយស្មតោ សារីបុត្តស្ស ភាសិតំ អភិនន្ទីតិ ។

[២] ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា សក្កេសុ វិហរតិ ទេវទហំ នាម សក្យានំ និគមោ ។ អថ ខោ សម្ពហុលា បច្ឆាភូមគមិកា ភិក្ខូ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ ឥច្ឆាម មយំ ភន្តេ បច្ឆាភូមំ ជនបទំ គន្តុំ បច្ឆាភូមេ ជនបទេ និវាសំ កប្បេតុន្តិ ។

មិនប្រកាន់ថាវិញ្ញាណគឺអញ វិញ្ញាណរបស់អាត្មាអញទេ លុះវិញ្ញាណនោះប្រែប្រួលទៅ ប្លែកទៅ សេចក្តីសោក សេចក្តីខ្សឹកខ្សួល ទុក្ខទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត ក៏មិនកើតឡើងដល់បុគ្គលនោះ ព្រោះតែវិញ្ញាណប្រែប្រួលទៅ ប្លែកទៅឡើយ ។ ម្នាលគហបតី បុគ្គលមានកាយសោប់សេល់ តែចិត្តមិនបានសោប់សេល់ យ៉ាងនេះឯង ។ លុះព្រះសារីបុត្តមានអាយុ បាននិយាយពាក្យនេះហើយ នកុលបិតា-គហបតី ជាអ្នកមានសេចក្តីត្រេកអរ បានត្រេកអរនឹងភាសិតរបស់ព្រះសារីបុត្តមានអាយុ ។

(២) ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងនិគមឈ្មោះទេវទហៈ របស់ពួកសក្យៈ ក្នុងដែនសក្កៈ ។ គ្រានោះឯង ពួកភិក្ខុច្រើនរូប ដែលមានដំណើរត្រូវទៅបច្ឆាភូមិ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយ ក្នុងទីដ៏សមគួរ ។ លុះពួកភិក្ខុទាំងនោះ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំប្រាថ្នានឹងទៅកាន់ជនបទឈ្មោះបច្ឆាភូមិ នឹងសម្រេចការនៅអាស្រ័យ ក្នុងបច្ឆាភូមជនបទ ។

អបលោកិតោ បន វោ ភិក្ខវេ សារីបុត្តោតិ ។ ន ខោ នោ ភន្តេ អបលោកិតោ អាយស្មា សារីបុត្តោតិ ។ អប-លោកេថ ភិក្ខវេ សារីបុត្តំ សារីបុត្តោ ភិក្ខវេ បណ្ឌិតោ ភិក្ខូនំ អនុគ្គាហកោ សព្រហ្មចារីនន្តិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

(៧) តេន ខោ បន សមយេន អាយស្មា សា-រីបុត្តោ ភគវតោ អវិទូរេ អញ្ញតរស្មឹ ឯលគលាគុម្ពេ និសិន្នោ ហោតិ ។ អថ ខោ តេ ភិក្ខូ ភគវតោ ភា-សិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា យេនាយស្មា សារីបុត្តោ តេនុបសង្កមឹសុ ឧបសង្កមិត្វា អាយស្មតា សារីបុត្តេន សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និ-សិន្នា ខោ តេ ភិក្ខូ អាយស្មន្តំ សារីបុត្តំ ឯតទវោចុំ

ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ បានលាសារីបុត្តហើយឬ ។ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំមិនបានលាព្រះសារីបុត្តមានអាយុទេ ។ ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយលាសារីបុត្តផង ម្នាលភិក្ខុទាំងឡាយ (ព្រោះ) សារីបុត្តជាបណ្ឌិត ជាអ្នកអនុគ្រោះពួកភិក្ខុជាសព្រហ្មចារី ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[៧] សម័យនោះឯង ព្រះសារីបុត្តមានអាយុ អង្គុយនៅក្បែរគុម្ពរទឹកមួយ មិនឆ្ងាយអំពីព្រះមានព្រះភាគ ។ គ្រានោះឯង ភិក្ខុទាំងនោះក្រោកអំពីអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយចូលទៅរកព្រះសារីបុត្តមានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះសារីបុត្តមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួររឭកហើយ អង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុទាំងនោះអង្គុយក្នុងទីដ៏សមគួរហើយ ក៏និយាយនឹងព្រះសារីបុត្តមានអាយុ

ឥច្ឆាម មយំ អាវុសោ សារីបុត្ត បច្ចន្តិមំ ជនបទំ គន្តុំ បច្ចន្តិមេ ជនបទេ និវាសំ កប្បេតុន្តិ ។ អបលោកិតោ នោ សត្ថាតិ ។ សន្តិ ហាវុសោ នានាវេរជ្ជគតំ ភិក្ខុំ បញ្ហំ បុច្ឆិតារោ ខត្តិយបណ្ឌិតាបិ ព្រាហ្មណបណ្ឌិតាបិ គហបតិបណ្ឌិតាបិ សមណបណ្ឌិតាបិ បណ្ឌិតា ហាវុសោ មនុស្សា វីមំសកា កឹវាទាយស្មន្តានំ សត្ថា កិមក្ខាយីតិ ។ កច្ចិ វោ អាយស្មន្តានំ ធម្មា សុស្សុតា សុគ្គហិតា សុមនសិកតា សូបធារិតា សុប្បដិវិទ្ធា បញ្ញាយ យថា ព្យាករមានា អាយស្មន្តោ វុត្តវាទិនោ ចេវ ភគវតោ អស្សថ ន ច ភគវន្តំ អភូតេន អព្ភាចិក្ខេយ្យាថ ធម្មស្ស ចានុធម្មំ ព្យាករេយ្យាថ ន ច កោចិ សហធម្មិកោ វាទានុបាតោ(១) គារយ្ហំ ឋានំ អាគច្ឆេយ្យាតិ ។ ទូរតោបិ ខោ មយំ អាវុសោ អាគច្ឆេយ្យាម អាយស្មតោ សារីបុត្តស្ស សន្តិកេ ឯតស្ស ភាសិតស្ស អត្ថមញ្ញាតុំ សាធុ វតាយស្មន្តំយេវ សារីបុត្តំ បដិភាតុ ឯតស្ស ភាសិតស្ស អត្ថោតិ ។

១ វាទានុវាទោតិបិ បាឋោ ។

យ៉ាងនេះថា ម្នាលអាវុសោ សារីបុត្ត យើងប្រាថ្នានឹងទៅកាន់បច្ឆាភូម-ជនបទ នឹងសម្រេចការនៅអាស្រ័យ ក្នុងបច្ឆាភូមជនបទ ។ ពួកលោកបានលាព្រះសាស្តាហើយឬ ។ ម្នាលអាវុសោ គង់មានពួកខត្តិយ-បណ្ឌិតខ្លះ ព្រាហ្មណបណ្ឌិតខ្លះ គហបតិបណ្ឌិតខ្លះ សមណបណ្ឌិតខ្លះ ជាអ្នកសួរប្រស្នាចំពោះភិក្ខុដែលទៅកាន់ដែនដទៃផ្សេង ៗ ព្រោះថា ពួកមនុស្សជាបណ្ឌិត ជាអ្នកពិចារណារកប្រយោជន៍ (តែងសួរថា) ព្រះសាស្តារបស់ពួកលោកមានអាយុនោះ តើមានលទ្ធិដូចម្តេច ប្រៀនប្រដៅដូចម្តេច ។ លោកមានអាយុទាំងឡាយ លោកបានស្តាប់ដោយប្រពៃ រៀនដោយប្រពៃ យកចិត្តទុកដាក់ដោយប្រពៃ ចាំជាក់លាក់ ចាក់ធ្លុះដោយប្រពៃដោយប្រាជ្ញា នូវធម៌ទាំងឡាយដែរឬ ពួកលោកមានអាយុ កាលនឹងដោះស្រាយ យ៉ាងណា ដែលឈ្មោះថាសម្តែងតាមធម៌ ដែលព្រះមានព្រះភាគត្រាស់ហើយផង កុំពោលបង្កាច់ព្រះមានព្រះភាគ ដោយពាក្យមិនពិតផង ព្យាករនូវធម៌ដ៏សមគួរដល់ធម៌ផង លំអាននៃពាក្យបន្តិចបន្តួច ដែលប្រកបដោយធម៌ មិនគប្បីដល់នូវហេតុដែលគួរតិះដៀលផង ។ ម្នាលអាវុសោ ពួកយើងខ្ញុំមកអំពីទីឆ្ងាយបម្រុងឲ្យដឹងសេចក្តីនៃភាសិតនេះ ក្នុងសំណាក់ព្រះសារីបុត្តមានអាយុ សូមអង្វរ សូមព្រះសារីបុត្តមានអាយុ បំភ្លឺសេចក្តីនៃភាសិតនេះឲ្យទាន ។

(៨) តេនហាវុសោ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវមាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ សារីបុត្តស្ស បច្ចស្សោសុំ ។ អាយស្មា សារីបុត្តោ ឯតទវោច សន្តិ ហាវុសោ នានាវេរជ្ជគតំ ភិក្ខុំ បញ្ហំ បុច្ឆិតារោ ខត្តិយបណ្ឌិតាបិ ព្រាហ្មណបណ្ឌិតាបិ គហបតិបណ្ឌិតាបិ សមណបណ្ឌិតាបិ បណ្ឌិតា ហាវុសោ មនុស្សា វីមំសកា កឹវាទាយស្មន្តានំ សត្ថា កិមក្ខាយីតិ ។ ឯវំ បុដ្ឋា តុម្ហេ អាវុសោ ឯវំ ព្យាករេយ្យាថ ឆន្ទរាគវិនយក្ខាយី ខោ នោ អាវុសោ សត្ថាតិ ។ ឯវំ ព្យាកតេបិ ខោ អាវុសោ អស្សុយេវ ឧត្តរឹ បញ្ហំ បុច្ឆិតារោ ខត្តិយបណ្ឌិតាបិ ព្រាហ្មណបណ្ឌិតាបិ គហបតិបណ្ឌិតាបិ សមណបណ្ឌិតាបិ បណ្ឌិតា ហាវុសោ មនុស្សា វីមំសកា កិស្មឹ បនាយស្មន្តានំ ឆន្ទរាគវិនយក្ខាយី សត្ថាតិ ។ ឯវំ បុដ្ឋា តុម្ហេ អាវុសោ

(៨) ម្នាលអាវុសោ បើដូច្នោះ ចូរលោកទាំងឡាយស្តាប់ ចូរយកចិត្តទុកដាក់ឲ្យប្រពៃចុះ ខ្ញុំនឹងសំដែងប្រាប់ ។ ភិក្ខុទាំងនោះក៏ទទួលពាក្យព្រះសារីបុត្តមានអាយុថា ករុណា អាវុសោ ។ ព្រះសារីបុត្តមានអាយុ បាននិយាយយ៉ាងនេះថា ម្នាលអាវុសោ គង់មានពួកខត្តិយបណ្ឌិតខ្លះ ព្រាហ្មណបណ្ឌិតខ្លះ គហបតិបណ្ឌិតខ្លះ សមណបណ្ឌិតខ្លះ ជាអ្នកសួរប្រស្នាចំពោះភិក្ខុដែលទៅកាន់ដែនដទៃផ្សេង ៗ មិនខាន ម្នាលអាវុសោ ព្រោះពួកមនុស្សជាបណ្ឌិត ជាអ្នកពិចារណាកេប្រយោជន៍ (តែងសួរថា) ព្រះសាស្តារបស់លោកមានអាយុនោះ តើមានលទ្ធិដូចម្តេច ប្រដៅធម៌អ្វី ។ ម្នាលអាវុសោ ពួកលោកត្រូវគេសួរយ៉ាងនេះហើយ ត្រូវដោះស្រាយយ៉ាងនេះថា ម្នាលអាវុសោ ព្រះសាស្តារបស់យើង ជាអ្នកប្រដៅឲ្យកំចាត់បង់នូវឆន្ទរាគ ។ ម្នាលអាវុសោ កាលបើពួកលោកដោះស្រាយយ៉ាងនេះហើយ ពួកខត្តិយបណ្ឌិតក្តី ព្រាហ្មណបណ្ឌិតក្តី គហបតិបណ្ឌិតក្តី សមណបណ្ឌិតក្តី គង់នឹងសួរប្រស្នាតទៅទៀត ម្នាលអាវុសោ ព្រោះពួកមនុស្សជាបណ្ឌិត ជាអ្នកពិចារណាកេប្រយោជន៍ (សមជានឹងសួរថា) ព្រះសាស្តារបស់លោកមានអាយុប្រដៅឲ្យកំចាត់បង់ នូវឆន្ទរាគ តើក្នុងវត្ថុអ្វី ។ ម្នាលអាវុសោ

ឯវំ ព្យាករេយ្យាថ រូបេ ខោ អាវុសោ ឆន្ទរាគវិន-
យក្ខាយី សត្ថា ។ វេទនាយ ។ សញ្ញាយ ។ សង្ខារេសុ ។
វិញ្ញាណេ ឆន្ទរាគវិនយក្ខាយី សត្ថាតិ ។ ឯវំ ព្យាកតេបិ
ខោ អាវុសោ អស្សុយេវ ឧត្តរឹ បញ្ហំ បុច្ឆិតារោ ខត្តិយ-
បណ្ឌិតាបិ ព្រាហ្មណបណ្ឌិតាបិ គហបតិបណ្ឌិតាបិ ស-
មណបណ្ឌិតាបិ បណ្ឌិតា ហាវុសោ មនុស្សា វីមំសកា
កឹ បនាយស្មន្តានំ អាទីនវំ ទិស្វា រូបេ ឆន្ទរាគវិន-
យក្ខាយី សត្ថា ។ វេទនាយ ។ សញ្ញាយ ។ សង្ខា-
រេសុ ។ វិញ្ញាណេ ឆន្ទរាគវិនយក្ខាយី សត្ថាតិ ។ ឯវំ
បុដ្ឋា តុម្ហេ អាវុសោ ឯវំ ព្យាករេយ្យាថ រូបេ ខោ អាវុសោ

ពួកលោកត្រូវគេសួរយ៉ាងនេះ គួរដោះស្រាយយ៉ាងនេះថា ម្នាលអាវុសោ ព្រះសាស្តាទ្រង់ប្រដៅឧបាយឲ្យកំចាត់បង់ នូវឆន្ទរាគ[១] ក្នុងរូប ។ ក្នុងវេទនា ។ ក្នុងសញ្ញា ។ ក្នុងសង្ខារទាំងឡាយ ។ ព្រះសាស្តាទ្រង់ប្រដៅឧបាយកំចាត់បង់នូវឆន្ទរាគក្នុងវិញ្ញាណ ។ ម្នាលអាវុសោ កាលបើពួកលោកដោះស្រាយយ៉ាងនេះហើយ ពួកខត្តិយបណ្ឌិតក្តី ព្រាហ្មណបណ្ឌិតក្តី គហបតិបណ្ឌិតក្តី សមណបណ្ឌិតក្តី សមជានឹងសួរប្រស្នាតទៅទៀត ម្នាលអាវុសោ ព្រោះពួកមនុស្សជាបណ្ឌិត តែងពិចារណារកប្រយោជន៍ (តែងសួរថា) ព្រះសាស្តារបស់លោកមានអាយុ ទ្រង់ឃើញទោសដូចម្តេច បានជាប្រដៅឧបាយកំចាត់បង់នូវឆន្ទរាគក្នុងរូប ។ ក្នុងវេទនា ។ ក្នុងសញ្ញា ។ ក្នុងសង្ខារទាំងឡាយ ។ ព្រះសាស្តាទ្រង់ប្រដៅឧបាយកំចាត់បង់នូវឆន្ទរាគក្នុងវិញ្ញាណ ។ ម្នាលអាវុសោ ពួកលោកត្រូវគេសួរយ៉ាងនេះហើយ គួរដោះស្រាយយ៉ាងនេះថា ម្នាលអាវុសោ

---

១ សេចក្តីត្រេកត្រអាលក្នុងរូប ។

អវីតរាគស្ស អវីតច្ឆន្ទស្ស អវីតបេមស្ស អវីតបិបាសស្ស អវីតបរិឡាហស្ស អវីតតណ្ហស្ស តស្ស រូបស្ស វិបរិណាមញ្ញថាភាវា ឧប្បជ្ជន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសា ។ វេទនាយ ។ សញ្ញាយ ។ សង្ខារេសុ អវីតរាគស្ស ។ បេ ។ អវីតតណ្ហស្ស តេសំ សង្ខារានំ វិបរិណាមញ្ញថាភាវា ឧប្បជ្ជន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសា ។ វិញ្ញាណេ អវីតរាគស្ស អវីតច្ឆន្ទស្ស អវីតបេមស្ស អវីតបិបាសស្ស អវីតបរិឡាហស្ស អវីតតណ្ហស្ស តស្ស វិញ្ញាណស្ស វិបរិណាមញ្ញថាភាវា ឧប្បជ្ជន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសា ។

សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត រមែងកើតឡើង ដល់បុគ្គលដែលមិនទាន់ប្រាសចាកកាមៈ មិនទាន់ប្រាសចាកឆន្ទៈ មិនទាន់ប្រាសចាកសេចក្តីស្រឡាញ់ មិនទាន់ប្រាសចាកសេចក្តីស្រេកឃ្លាន មិនទាន់ប្រាសចាកសេចក្តីក្តៅក្រហាយ មិនទាន់ប្រាសចាកតណ្ហា ក្នុងរូប ព្រោះតែរូបនោះ ប្រែប្រួលទៅ ប្លែកទៅ ។ ក្នុងវេទនា ។ ក្នុងសញ្ញា ។ មិនទាន់ប្រាសចាកកាមៈក្នុងសង្ខារទាំង-ឡាយ ។បេ។ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត រមែងកើតឡើងដល់បុគ្គល ដែលមិនទាន់ប្រាសចាកតណ្ហា ព្រោះតែសង្ខារទាំងឡាយនោះ ប្រែប្រួលទៅ ប្លែកទៅ ។ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត រមែងកើតឡើងដល់បុគ្គលដែលមិនទាន់ប្រាសចាកកាមៈ មិនទាន់ប្រាសចាកឆន្ទៈ មិនទាន់ប្រាសចាកសេចក្តីស្រឡាញ់ មិនទាន់ប្រាសចាកសេចក្តីស្រេកឃ្លាន មិនទាន់ប្រាសចាកសេចក្តីក្តៅក្រហាយ មិនទាន់ប្រាសចាកតណ្ហាក្នុងវិញ្ញាណ ព្រោះតែវិញ្ញាណនោះប្រែប្រួលទៅ ប្លែកទៅ ។

ឥទំ ខោ នោ អាវុសោ អាទីនវំ ទិស្វា រូបេ ឆន្ទ-
រាគវិនយក្ខាយី សត្ថា ។ វេទនាយ ។ សញ្ញាយ ។
សង្ខារេសុ ។ វិញ្ញាណេ ឆន្ទរាគវិនយក្ខាយី សត្ថាតិ ។
ឯវំ ព្យាកតេបិ ខោ អាវុសោ អស្សុយេវ ឧត្តរី បញ្ហំ
បុច្ឆិតារោ ខត្តិយបណ្ឌិតាបិ ព្រាហ្មណបណ្ឌិតាបិ គ-
ហបតិបណ្ឌិតាបិ សមណបណ្ឌិតាបិ បណ្ឌិតា ហាវុសោ
មនុស្សា វីមំសកា កឹ បនាយស្មន្តានំ អានិសំសំ
ទិស្វា រូបេ ឆន្ទរាគវិនយក្ខាយី សត្ថា ។ វេទនាយ ។
សញ្ញាយ ។ សង្ខារេសុ ។ វិញ្ញាណេ ឆន្ទរាគវិនយក្ខា-
យី សត្ថាតិ ។ ឯវំ បុដ្ឋា តុម្ហេ អាវុសោ ឯវំ
ព្យាករេយ្យាថ រូបេ ខោ អាវុសោ វីតរាគស្ស វី-
តច្ឆន្ទស្ស វីតបេមស្ស វីតបិបាសស្ស វីតបរិឡា-
ហស្ស វីតតណ្ហស្ស តស្ស រូបស្ស វិបរិណាមញ្ញថាភា-
វា នុប្បជ្ជន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសា ។

ម្នាលអាវុសោ ព្រះសាស្តារបស់យើងទាំងឡាយ ទ្រង់ឃើញទោសនេះឯង បានជាទ្រង់ប្រដៅឲ្យកំចាត់បង់នូវឆន្ទរាគក្នុងរូប ។ ក្នុងវេទនា ។ ក្នុងសញ្ញា ។ ក្នុងសង្ខារទាំងឡាយ ។ ព្រះសាស្តាទ្រង់ប្រដៅឲ្យកំចាត់បង់នូវឆន្ទរាគក្នុងវិញ្ញាណ ។ ម្នាលអាវុសោ កាលបើពួកលោកដោះស្រាយយ៉ាងនេះហើយ ពួកខត្តិយបណ្ឌិតក្តី ព្រាហ្មណបណ្ឌិតក្តី គហបតិបណ្ឌិតក្តី សមណបណ្ឌិតក្តី សមជាសួរប្រស្នាតទៅទៀត ម្នាលអាវុសោ ព្រោះពួកមនុស្សជាបណ្ឌិត តែងពិចារណារកប្រយោជន៍ (តែងសួរថា) ព្រះសាស្តារបស់លោកមានអាយុ ទ្រង់ឃើញអានិសង្សដូចម្តេច បានជាប្រដៅឲ្យកំចាត់បង់នូវឆន្ទរាគ ក្នុងរូប ។ ក្នុងវេទនា ។ ក្នុងសញ្ញា ។ ក្នុងសង្ខារទាំងឡាយ ។ ព្រះសាស្តាទ្រង់ប្រដៅឲ្យកំចាត់បង់នូវឆន្ទរាគក្នុងវិញ្ញាណ ។ ម្នាលអាវុសោ ពួកលោកត្រូវគេសួរយ៉ាងនេះហើយ គួរព្យាករយ៉ាងនេះថា ម្នាលអាវុសោ សេចក្តីសោក ខ្សឹក-ខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត រមែងមិនកើតឡើងដល់បុគ្គលដែលប្រាសចាករាគ: ប្រាសចាកឆន្ទ: ប្រាសចាកសេចក្តីស្រ-ឡាញ់ ប្រាសចាកសេចក្តីស្រេកឃ្លាន ប្រាសចាកសេចក្តីក្តៅក្រហាយ ប្រាសចាកតណ្ហា ក្នុងរូប ព្រោះតែរូបនោះប្រែប្រួលទៅ ប្លែកទៅ ។

វេទនាយ ។ សញ្ញាយ ។ សង្ខារេសុ វិគតរាគស្ស វិគតច្ឆន្ទស្ស វិគតបេមស្ស វិគតបិបាសស្ស វិគតបរិឡាហស្ស វិគតតណ្ហស្ស តេសំ សង្ខារានំ វិបរិណាមញ្ញថាភាវា នុប្បជ្ជន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសា ។ វិញ្ញាណេ វិគតរាគស្ស វិគតច្ឆន្ទស្ស វិគតបេមស្ស វិគតបិបាសស្ស វិគតបរិឡាហស្ស វិគតតណ្ហស្ស តស្ស វិញ្ញាណស្ស វិបរិណាមញ្ញថាភាវា នុប្បជ្ជន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសា ។ ឥទំ ខោ អាវុសោ អានិសំសំ ទិស្វា រូបេ ឆន្ទរាគវិនយក្ខាយី សត្ថា ។ វេទនាយ ។ សញ្ញាយ ។ សង្ខារេសុ ។ វិញ្ញាណេ ឆន្ទរាគវិនយក្ខាយី សត្ថាតិ ។

ក្នុងវេទនា ១ ក្នុងសញ្ញា ១ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត រមែងមិនកើតឡើង ដល់បុគ្គលដែលប្រាសចាករាគៈ ប្រាសចាកឆន្ទៈ ប្រាសចាកសេចក្តីស្រឡាញ់ ប្រាសចាកសេចក្តីស្រេកឃ្លាន ប្រាសចាកសេចក្តីក្តៅក្រហាយ ប្រាសចាកតណ្ហា ក្នុងសង្ខារទាំងឡាយ ព្រោះតែសង្ខារទាំងឡាយនោះ ប្រែប្រួលទៅ ប្លែកទៅ ។ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត រមែងមិនកើតឡើង ដល់បុគ្គលដែលប្រាសចាករាគៈ ប្រាសចាកឆន្ទៈ ប្រាសចាកសេចក្តីស្រឡាញ់ ប្រាសចាកសេចក្តីស្រេកឃ្លាន ប្រាសចាកសេចក្តីក្តៅក្រហាយ ប្រាសចាកតណ្ហា ក្នុងវិញ្ញាណ ព្រោះតែវិញ្ញាណនោះ ប្រែប្រួលទៅ ប្លែកទៅ ។ ម្នាលអាវុសោ ព្រះសាស្តារបស់យើងទាំងឡាយ ទ្រង់ឃើញអានិសង្សនេះឯង បានជាទ្រង់ប្រដៅឲ្យបាយកំចាត់បង់នូវឆន្ទរាគ ក្នុងរូប ១ ក្នុងវេទនា ១ ក្នុងសញ្ញា ១ ក្នុងសង្ខារទាំងឡាយ ១ ព្រះសាស្តាទ្រង់ប្រដៅឲ្យបាយកំចាត់បង់ នូវឆន្ទរាគ ក្នុងវិញ្ញាណ ១

(៩) អកុសលេ អាវុសោ ធម្មេ ឧបសម្បជ្ជ វិហរតោ ទិដ្ឋេ ចេវ ធម្មេ សុខោ វិហារោ អភវិស្ស អវិឃាតោ អនុបាយាសោ អបរិឡាហោ កាយស្ស ច ភេទា បរំ មរណា សុគតិ បាដិកង្ខា ន យិទំ ភគវា អកុសលានំ ធម្មានំ បហានំ វណ្ណេយ្យ ។ យស្មា ច ខោ អាវុសោ អកុសលេ ធម្មេ ឧបសម្បជ្ជ វិហរតោ ទិដ្ឋេ ចេវ ធម្មេ ទុក្ខោ វិហារោ សវិឃាតោ សឧបាយាសោ សបរិឡាហោ កាយស្ស ច ភេទា បរំ មរណា ទុគ្គតិ បាដិកង្ខា តស្មា ភគវា អកុសលានំ ធម្មានំ បហានំ វណ្ណេតិ ។

(១០) កុសលេ អាវុសោ ធម្មេ ឧបសម្បជ្ជ វិហរតោ ទិដ្ឋេ ចេវ ធម្មេ ទុក្ខោ វិហារោ អភវិស្ស សវិឃាតោ សឧបាយាសោ សបរិឡាហោ កាយស្ស ច ភេទា បរំ មរណា ទុគ្គតិ បាដិកង្ខា ន យិទំ ភគវា កុសលានំ ធម្មានំ ឧបសម្បទំ វណ្ណេយ្យ ។ យស្មា ច ខោ អាវុសោ កុសលេ ធម្មេ ឧបសម្បជ្ជ វិហរតោ ទិដ្ឋេ ចេវ ធម្មេ សុខោ វិហារោ អវិឃាតោ អនុបាយាសោ

(៩) ម្នាលអាវុសោ មួយទៀត កាលបើបុគ្គលបាននូវអកុសលធម៌ទាំងឡាយហើយ ការនៅជាសុខ ឥតទុក្ខ មិនចង្អៀតចង្អល់ចិត្ត មិនក្តៅក្រហាយក្នុងបច្ចុប្បន្ននឹងមានផង លុះទំលាយរាងកាយស្លាប់ទៅ ត្រូវទៅកើតក្នុងឋានសុគតិជាប្រាកដផង សមជាព្រះមានព្រះភាគមិនសរសើរការលះបង់នូវអកុសលធម៌នេះទេ ។ ម្នាលអាវុសោ ព្រោះហេតុតែបុគ្គលបាននូវអកុសលធម៌ទាំងឡាយហើយ ការនៅជាទុក្ខ ប្រកបដោយសេចក្តីលំបាក ប្រកបដោយសេចក្តីចង្អៀតចង្អល់ចិត្ត ប្រកបដោយសេចក្តីក្តៅក្រហាយក្នុងបច្ចុប្បន្នក៏មានផង លុះទំលាយរាងកាយស្លាប់ទៅ ត្រូវទៅកើតក្នុងទុគ្គតិជាប្រាកដផង បានជាព្រះមានព្រះភាគទ្រង់សរសើរការលះបង់នូវអកុសលធម៌ទាំងឡាយ ។

(១០) ម្នាលអាវុសោ មួយទៀត កាលបើបុគ្គលបាននូវអកុសលធម៌ទាំងឡាយហើយ ការនៅជាទុក្ខ ប្រកបដោយសេចក្តីលំបាក ប្រកបដោយសេចក្តីចង្អៀតចង្អល់ចិត្ត ប្រកបដោយសេចក្តីក្តៅក្រហាយ ក្នុងបច្ចុប្បន្ននឹងមានផង លុះទំលាយរាងកាយស្លាប់ទៅ ត្រូវទៅកើតក្នុងទុគ្គតិជាប្រាកដផង សមជាព្រះមានព្រះភាគទ្រង់មិនសរសើរ នូវការបំពេញកុសលធម៌ទាំងឡាយនេះទេ ។ ម្នាលអាវុសោ ព្រោះហេតុតែបុគ្គលបាន នូវកុសលធម៌ទាំងឡាយហើយ ការនៅជាសុខ ឥតទុក្ខ មិនចង្អៀតចង្អល់ចិត្ត

អបរិឡាហោ កាយស្ស ច ភេទា បរំ មរណា សុគតិ បាដិកង្ខា តស្មា ភគវា កុសលានំ ធម្មានំ ឧបសម្បទំ វណ្ណេតីតិ ។ ឥទមវោច អាយស្មា សារីបុត្តោ ។ អត្តមនា តេ ភិក្ខូ អាយស្មតោ សារីបុត្តស្ស ភាសិតំ អភិនន្ទុន្តិ ។

(១១) ឯវម្មេ សុតំ ។ ឯកំ សមយំ អាយស្មា មហាកច្ចានោ អវន្តីសុ វិហរតិ កុររឃរេ បបាតេ បព្វតេ ។ អថខោ ហាលិទ្ទិកានិ គហបតិ យេនាយស្មា មហាកច្ចានោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ មហាកច្ចានំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ហាលិទ្ទិកានិ គហបតិ អាយស្មន្តំ មហាកច្ចានំ ឯតទវោច វុត្តមិទំ ភន្តេ ភគវតា អដ្ឋកវគ្គិយេ មាគណ្ឌិយបញ្ហេ

មិនក្តៅក្រហាយ ក្នុងបច្ចុប្បន្នក៏មានផង លុះទំលាយរាងកាយស្លាប់ទៅ ត្រូវបានសុគតិជាប្រាកដផង បានជាព្រះមានព្រះភាគ ទ្រង់សរសើរ នូវការបំពេញកុសលធម៌ទាំងឡាយ ។ ព្រះសារីបុត្តមានអាយុ សំដែងភាសិតនេះចប់ហើយ ។ ភិក្ខុទាំងនោះ ជាអ្នកមានសេចក្តីត្រេកអរ បានត្រេកអរ នឹងភាសិត របស់ព្រះសារីបុត្ត មានអាយុ ។

(១១) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមហាកច្ចានៈ មានអាយុ គង់នៅលើភ្នំមានជ្រោះ (ម្ខាង) ទៀបក្រុងឈ្មោះកុររឃរៈ ក្នុងអវន្តីជនបទ ។ គ្រានោះឯង គហបតីឈ្មោះហាលិទ្ទិកានិ បានចូលទៅរកព្រះមហាកច្ចានៈមានអាយុ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមហាកច្ចានៈមានអាយុ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះហាលិទ្ទិកានិគហបតីអង្គុយក្នុងទីដ៏សមគួរហើយ ក៏បាននិយាយនឹងព្រះមហាកច្ចានៈមានអាយុ យ៉ាងនេះថា បពិត្រលោកម្ចាស់ដ៏ចំរើន សុភាសិតនេះ ព្រះមានព្រះភាគ បានសំដែងទុក ក្នុងមាគណ្ឌិយបញ្ហា ដែលកប់បញ្ចូលក្នុងអដ្ឋកវគ្គថា

ឱកំ បហាយ អនិកេតសារី
កាមេ អកុព្វំ មុនិ សន្ថវានិ
កាមេហិ រិត្តោ អបុរក្ខរានោ
កថំ ន វិគ្គយ្ហ ជនេន កយិរាតិ ។

ឥមស្ស នុ ខោ ភន្តេ ភគវតា សង្ខិត្តេន ភាសិតស្ស កថំ វិត្ថារេន អត្ថោ ទដ្ឋព្វោតិ ។

(១២) រូបធាតុ ខោ គហបតិ វិញ្ញាណស្ស ឱកោ រូបធាតុរាគវិនិពទ្ធញ្ច បន វិញ្ញាណំ ឱកសារីតិ វុច្ចតិ ។ វេទនាធាតុ ខោ គហបតិ វិញ្ញាណស្ស ឱកោ វេទនាធាតុរាគវិនិពទ្ធញ្ច បន វិញ្ញាណំ ឱកសារីតិ វុច្ចតិ ។ សញ្ញាធាតុ ខោ គហបតិ វិញ្ញាណស្ស ឱកោ សញ្ញាធាតុរាគវិនិពទ្ធញ្ច បន វិញ្ញាណំ ឱកសារីតិ វុច្ចតិ ។ សង្ខារធាតុ ខោ គហបតិ វិញ្ញាណស្ស ឱកោ សង្ខារធាតុរាគវិនិពទ្ធញ្ច បន វិញ្ញាណំ ឱកសារីតិ វុច្ចតិ ។ ឯវំ ខោ គហបតិ ឱកសារី ហោតិ ។

ព្រះតថាគតលះបង់នូវផ្ទះ (បញ្ចក្ខន្ធ) ជាអ្នកមិនមានការអន្ទោលទៅរកកន្លែងស្នាក់ (អារម្មណ៍ទាំង ៦) ជាអ្នកប្រាជ្ញមិនបានធ្វើនូវសេចក្ដីស្និទ្ធស្នាល ក្នុងស្រុក ជាអ្នកទំនេរចាកកាមទាំងឡាយ មិនមានប្រាថ្នាទៅក្នុងអនាគតកាល មិនគប្បីធ្វើនូវពាក្យទាស់ទែងជាមួយនឹងជន ។

បពិត្រលោកដ៏ចម្រើន សេចក្ដីនៃធម៌ដែលព្រះមានព្រះភាគត្រាស់ដោយសង្ខេបនេះ តើត្រូវយល់ដោយពិស្ដារដូចម្ដេច ។

[ ១២ ] ម្នាលគហបតី រូបធាតុ ឈ្មោះថាជាផ្ទះរបស់វិញ្ញាណ ឯកម្មវិញ្ញាណ ដែលជាប់ចំពាក់ដោយតម្រេកក្នុងរូបធាតុ ហៅថាការអន្ទោលទៅរកផ្ទះ ។ ម្នាលគហបតី វេទនាធាតុ ឈ្មោះថាជាផ្ទះរបស់វិញ្ញាណ ឯកម្មវិញ្ញាណ ដែលជាប់ចំពាក់ដោយតម្រេកក្នុងវេទនាធាតុ ហៅថាការអន្ទោលទៅរកផ្ទះ ។ ម្នាលគហបតី សញ្ញាធាតុ ឈ្មោះថាជាផ្ទះរបស់វិញ្ញាណ ឯកម្មវិញ្ញាណ ដែលជាប់ចំពាក់ដោយតម្រេកក្នុងសញ្ញាធាតុ ហៅថាការអន្ទោលទៅរកផ្ទះ ។ ម្នាលគហបតី សង្ខារធាតុ ឈ្មោះថាជាផ្ទះរបស់វិញ្ញាណ ឯកម្មវិញ្ញាណ ដែលជាប់ចំពាក់ដោយតម្រេក ក្នុងសង្ខារធាតុ ហៅថាការអន្ទោលទៅរកផ្ទះ ។ ម្នាលគហបតី បុគ្គលជាអ្នកអន្ទោលទៅរកផ្ទះ យ៉ាងនេះឯង ។

(១៣) កថញ្ច គហបតិ អនោកសារី ហោតិ ។ រូបធាតុយា ខោ គហបតិ យោ ឆន្ទោ យោ រាគោ យា នន្ទិ យា តណ្ហា យេ ឧបាយុបាទានា ចេតសោ អធិដ្ឋានាភិនិវេសានុសយា តេ តថាគតស្ស បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ អនុប្បាទធម្មា តស្មា តថាគតោ អនោកសារីតិ វុច្ចតិ ។ វេទនាធាតុយា ខោ គហបតិ ។ សញ្ញាធាតុយា ខោ គហបតិ ។ សង្ខារធាតុយា ខោ គហបតិ ។ វិញ្ញាណធាតុយា ខោ គហបតិ យោ ឆន្ទោ យោ រាគោ យា នន្ទិ យា តណ្ហា យេ ឧបាយុបាទានា ចេតសោ អធិដ្ឋានាភិនិវេសានុសយា តេ តថាគតស្ស បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ អនុប្បាទធម្មា តស្មា តថាគតោ

(១៣) ម្នាលគហបតី ចុះព្រះតថាគតមិនមានការអន្ទោលទៅរកផ្ទះ តើដូចម្តេច ។ ម្នាលគហបតី សេចក្តីប៉ុនប៉ង តម្រេក សេចក្តីរីករាយ សេចក្តីប្រាថ្នាណា ក្នុងរូបធាតុ មួយទៀត ឧបាយ(១)និងឧបាទាន(២)ណា ដែលជាទីឈរ ជាទីអង្គុយ ជាទីដេក របស់អកុសលចិត្ត ធម៌ទាំងនោះ ព្រះតថាគតបានលះបង់ហើយ បានគាស់រំលើងគល់អស់ហើយ បានធ្វើឲ្យសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត បានធ្វើឲ្យលែងមានបែបភាព ជាសភាពមិនកើតតទៅ ព្រោះហេតុនោះ បានជាគេហៅថា ព្រះតថាគត មិនមានការអន្ទោលទៅរកផ្ទះ ។ ម្នាលគហបតី ក្នុងវេទនាធាតុ ។ ម្នាលគហបតី ក្នុងសញ្ញាធាតុ ។ ម្នាលគហបតី ក្នុងសង្ខារធាតុ ។ ម្នាលគហបតី សេចក្តីប៉ុនប៉ង តម្រេក សេចក្តីរីករាយ សេចក្តីប្រាថ្នាណា ក្នុងវិញ្ញាណធាតុ មួយទៀត ឧបាយ និងឧបាទានណា ដែលជាទីឈរ ជាទីអង្គុយ ជាទីដេក របស់អកុសលចិត្ត ធម៌ទាំងនោះ ព្រះតថាគតបានលះបង់ចោលហើយ បានគាស់រំលើងគល់អស់ហើយ បានធ្វើឲ្យសល់តែទីនៅដូចជាទីនៅនៃដើមត្នោត បានធ្វើឲ្យលែងមានបែបភាព ជាសភាពមិនកើតតទៅ ព្រោះហេតុនោះ បានជាគេហៅថា ព្រះតថាគត

---

១ ឧបាយពីរគឺ តណ្ហា ១ ទិដ្ឋិ ១ ។ ២ ឧបាទាន ៤ មានកាមុបាទានជាដើម (អដ្ឋកថា) ។

អនោកសារីតិ វុច្ចតិ ។ ឯវំ ខោ គហបតិ អនោកសារី ហោតិ ។

(១៤) កថញ្ច គហបតិ និកេតសារី ហោតិ ។ រូប-និមិត្តនិកេតវិសារវិនិពន្ធា ខោ គហបតិ និកេតសារីតិ វុច្ចតិ ។ សទ្ទនិមិត្ត ។ បេ ។ គន្ធនិមិត្ត ... រសនិមិត្ត... ផោដ្ឋព្វនិមិត្ត... ធម្មនិមិត្តនិកេតវិសារវិនិពន្ធា ខោ គហ-បតិ និកេតសារីតិ វុច្ចតិ ។ ឯវំ ខោ គហបតិ និកេ-តសារី ហោតិ ។

(១៥) កថញ្ច គហបតិ អនិកេតសារី ហោតិ ។ រូបនិមិត្តនិកេតវិសារវិនិពន្ធា ខោ គហបតិ តថាគតស្ស បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា

មិនមានការអន្ទោលទៅរកផ្ទះ ។ ម្នាលគហបតី ព្រះតថាគតមិនមានការអន្ទោលទៅរកផ្ទះ យ៉ាងនេះឯង ។

[១៤] ម្នាលគហបតី ចុះបុគ្គលដែលមានការអន្ទោលទៅរកកន្លែងស្នាក់ (អារម្មណ៍ទាំង ៦) តើដូចម្តេច ។ ម្នាលគហបតី បុគ្គលដែលហៅថាមានការអន្ទោលទៅរកកន្លែងស្នាក់ ព្រោះការផ្សាយទៅ និងការជាប់ចំពាក់នៃកិលេសដែលកើតឡើងក្នុងកន្លែងស្នាក់ គឺរូបនិមិត្ត ។ សទ្ទ-និមិត្ត ។ បេ ។ គន្ធនិមិត្ត ... រសនិមិត្ត ... ផោដ្ឋព្វនិមិត្ត ... ម្នាលគហបតី បុគ្គលដែលហៅថា មានការអន្ទោលទៅរកកន្លែងស្នាក់ ព្រោះការផ្សាយទៅ និងការជាប់ចំពាក់នៃកិលេសដែលកើតឡើងក្នុងកន្លែងស្នាក់ គឺធម្ម-និមិត្ត ។ ម្នាលគហបតី បុគ្គលដែលមានការអន្ទោលទៅរកកន្លែងស្នាក់ យ៉ាងនេះឯង ។

[១៥] ម្នាលគហបតី ចុះព្រះតថាគតដែលមិនមានការអន្ទោលទៅរកកន្លែងស្នាក់ តើដូចម្តេច ។ ម្នាលគហបតី សេចក្តីផ្សាយទៅ និងការជាប់ចំពាក់នៃកិលេសដែលកើតឡើងក្នុងកន្លែងស្នាក់ គឺរូបនិមិត្ត ព្រះតថាគតបានលះបង់ចោលហើយ បានកាត់រំលើងគល់អស់ហើយ បានធ្វើឲ្យសល់តែទីនៅដូចជាទីនៅនៃដើមត្នោត បានធ្វើឲ្យលែងមានបែបភាព

អាយតឹ អនុប្បាទធម្មា តស្មា តថាគតោ អនិកេតសារីតិ វុច្ចតិ ។ សទ្ទនិមិត្ត ។ បេ ។ គន្ធនិមិត្ត ... រសនិមិត្ត ... ផោដ្ឋព្វនិមិត្ត ... ធម្មនិមិត្តនិកេតវិសារវិនិពន្ធា ខោ គហបតិ តថាគតស្ស បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ អនុប្បាទធម្មា តស្មា តថាគតោ អនិកេតសារីតិ វុច្ចតិ ។ ឯវំ ខោ គហបតិ អនិកេតសារី ហោតិ ។

(១៦) កថញ្ច គហបតិ ឱកេ សន្ធវជាតោ ហោតិ ។ ឥធ គហបតិ ឯកច្ចោ គិហីហិ សំសដ្ឋោ វិហរតិ សហនន្ទី សហសោកី សុខិតេសុ សុខិតោ

ជាសភាពមិនកើតតទៅ ព្រោះហេតុនោះ បានជាគេហៅថា ព្រះតថាគត មិនមានការអន្ទោលទៅរកកន្ទន្ទស្នាក់ (អារម្មណ៍ទាំង ៦) ។ សទ្ទនិមិត្ត ។ បេ ។ គន្ធនិមិត្ត ... រសនិមិត្ត ... ផោដ្ឋព្វនិមិត្ត ... ម្នាលគហបតី សេចក្តីផ្សាយទៅ និងការជាប់ចំពាក់នៃកិលេសដែលកើតឡើងក្នុងកន្ទន្ទស្នាក់គឺធម្មនិមិត្ត ព្រះតថាគតបានលះបង់ហើយ បានកាត់រំលើងគល់អស់ហើយ បានធ្វើឲ្យសល់តែទីនៅដូចជាទីនៅនៃដើមត្នោត បានធ្វើឲ្យលែងមានបែបភាព ជាសភាពមិនកើតតទៅ ព្រោះហេតុនោះ បានជាគេហៅថា ព្រះតថាគត មិនមានការអន្ទោលទៅរកកន្ទន្ទស្នាក់ ។ ម្នាលគហបតី ព្រះតថាគតមិនមានការអន្ទោលទៅរកកន្ទន្ទស្នាក់ យ៉ាងនេះឯង ។

[១៦] ម្នាលគហបតី ភិក្ខុដែលមានសេចក្តីស្និទ្ធស្នាលក្នុងស្រុក តើដូចម្តេច ។ ម្នាលគហបតី ភិក្ខុខ្លះក្នុងសាសនានេះ ជាអ្នកប្រឡូកប្រឡំដោយពួកគ្រហស្ថ មានសេចក្តីរីករាយជាមួយគ្នា មានសេចក្តីសោកជាមួយគ្នា កាលបើពួកគ្រហស្ថបានសេចក្តីសុខ ក៏បានសេចក្តីសុខផង

ទុក្ខិតេសុ ទុក្ខិតោ ឧប្បន្នេសុ កិច្ចករណីយេសុ អត្ត-នា តេសុ យោគំ អាបជ្ជតិ ។ ឯវំ ខោ គហបតិ កាមេ សន្ថវជាតោ ហោតិ ។

(១៧) កថញ្ច គហបតិ កាមេ ន សន្ថវជាតោ ហោតិ ។ ឥធ គហបតិ ភិក្ខុ គិហីហិ អសំសដ្ឋោ វិហរតិ ន សហនន្ទី ន សហសោកី ន សុខិតេសុ សុខិតោ ន ទុក្ខិតេសុ ទុក្ខិតោ ឧប្បន្នេសុ កិច្ចក-រណីយេសុ ន អត្តនា តេសុ យោគំ អាបជ្ជតិ ។ ឯវំ ខោ គហបតិ កាមេ ន សន្ថវជាតោ ហោតិ ។

កាលបើពួកគ្រហស្ថបានសេចក្តីទុក្ខ ក៏បានសេចក្តីទុក្ខផង កាលបើពួកគ្រហស្ថទាំងនោះ មានកិច្ចការដែលត្រូវធ្វើកើតឡើង ជួយខ្វល់ខ្វាយក្នុងកិច្ចទាំងនោះដោយខ្លួនឯង ៗ ម្នាលគហបតី ភិក្ខុមានសេចក្តីស្និទ្ធស្នាលក្នុងស្រុក យ៉ាងនេះឯង ៗ

(១៧) ម្នាលគហបតី ចុះភិក្ខុដែលមិនស្និទ្ធស្នាលក្នុងស្រុក តើដូចម្តេច ៗ ម្នាលគហបតី ភិក្ខុក្នុងសាសនានេះ មិនប្រឡូកប្រឡំដោយពួកគ្រហស្ថ មិនត្រេកអរជាមួយគ្នា មិនមានសេចក្តីសោកជាមួយគ្នា កាលបើពួកគ្រហស្ថ បានសេចក្តីសុខ ក៏មិនបានសេចក្តីសុខជាមួយផង កាលបើពួកគ្រហស្ថ បានសេចក្តីទុក្ខ ក៏មិនបានសេចក្តីទុក្ខជាមួយផង កាលបើពួកគ្រហស្ថ មានកិច្ចការដែលត្រូវធ្វើកើតឡើង ក៏មិនជួយខ្វល់ខ្វាយក្នុងកិច្ចការទាំងនោះដោយខ្លួនឯង ៗ ម្នាលគហបតី ភិក្ខុដែលមិនស្និទ្ធស្នាលក្នុងស្រុក យ៉ាងនេះឯង ៗ

(១៨) កថញ្ច គហបតិ កាមេហិ ន រិត្តោ ហោតិ ។ ឥធ គហបតិ ឯកច្ចោ កាមេសុ អវីតរាគោ ហោតិ អវីតច្ឆន្ទោ អវីតប្បេមោ អវីតបិបាសោ អវីតបរិឡាហោ អវីតតណ្ហោ ។ ឯវំ ខោ គហបតិ កាមេហិ ន រិត្តោ ហោតិ ។

(១៩) កថញ្ច គហបតិ កាមេហិ រិត្តោ ហោតិ ។ ឥធ គហបតិ ឯកច្ចោ កាមេសុ វីតរាគោ ហោតិ វីតច្ឆន្ទោ វីតប្បេមោ វីតបិបាសោ វីតបរិឡាហោ វីតតណ្ហោ ។ ឯវំ ខោ គហបតិ កាមេហិ រិត្តោ ហោតិ ។

(១៨) ម្នាលគហបតី ចុះភិក្ខុដែលមិនស្ងាត់ចាកកាម តើដូចម្តេច ។ ម្នាលគហបតី ភិក្ខុក្នុងសាសនានេះ មិនទាន់ប្រាសចាកតម្រេក មិនទាន់ប្រាសចាកសេចក្តីប៉ុនប៉ង មិនទាន់ប្រាសចាកសេចក្តីស្រឡាញ់ មិនទាន់ប្រាសចាកសេចក្តីស្រេកឃ្លាន មិនទាន់ប្រាសចាកសេចក្តីក្តៅក្រហាយ មិនទាន់ប្រាសចាកសេចក្តីប្រាថ្នាក្នុងកាមទាំងឡាយនៅឡើយ ។ ម្នាលគហបតី ភិក្ខុដែលមិនស្ងាត់ចាកកាមទាំងឡាយ យ៉ាងនេះឯង ។

(១៩) ម្នាលគហបតី ចុះភិក្ខុដែលស្ងាត់ចាកកាម តើដូចម្តេច ។ ម្នាលគហបតី ភិក្ខុក្នុងសាសនានេះ ប្រាសចាកតម្រេក ប្រាសចាកសេចក្តីប៉ុនប៉ង ប្រាសចាកសេចក្តីស្រឡាញ់ ប្រាសចាកសេចក្តីស្រេកឃ្លាន ប្រាសចាកសេចក្តីក្តៅក្រហាយ ប្រាសចាកសេចក្តីប្រាថ្នាក្នុងកាមទាំងឡាយ ។ ម្នាលគហបតី ភិក្ខុដែលស្ងាត់ចាកកាមទាំងឡាយ យ៉ាងនេះឯង ។

(២០) កថញ្ច គហបតិ បុរក្ខរោ ហោតិ ។ ឥធ គហបតិ ឯកច្ចស្ស ឯវំ ហោតិ ឯវំរូបោ សិយំ អនាគតមទ្ធានំ ឯវំវេទនោ សិយំ អនាគតមទ្ធានំ ឯវំសញ្ញោ សិយំ អនាគតមទ្ធានំ ឯវំសង្ខារោ សិយំ អនាគតមទ្ធានំ ឯវំវិញ្ញាណោ សិយំ អនាគតមទ្ធានន្តិ ។ ឯវំ ខោ គហបតិ បុរក្ខរោ ហោតិ ។

(២១) កថញ្ច គហបតិ អបុរក្ខរោ ហោតិ ។ ឥធ គហបតិ ឯកច្ចស្ស ន ឯវំ ហោតិ ឯវំរូបោ សិយំ អនាគតមទ្ធានំ ឯវំវេទនោ សិយំ អនាគតមទ្ធានំ ឯវំសញ្ញោ សិយំ អនាគតមទ្ធានំ ឯវំសង្ខារោ សិយំ អនាគតមទ្ធានំ ឯវំវិញ្ញាណោ សិយំ អនាគតមទ្ធានន្តិ ។ ឯវំ ខោ គហបតិ អបុរក្ខរោ ហោតិ ។

[ ៦០ ] ម្នាលគហបតី ចុះភិក្ខុជាអ្នកប្រាថ្នាទៅក្នុងអនាគតកាល តើដូចម្តេច ។ ម្នាលគហបតី ភិក្ខុក្នុងសាសនានេះ មានសេចក្តីប្រាថ្នាយ៉ាងនេះថា សូមឲ្យអាត្មាអញមានរូបយ៉ាងនេះ ក្នុងកាលជាអនាគត សូមឲ្យមានវេទនាយ៉ាងនេះ ក្នុងកាលជាអនាគត សូមឲ្យមានសញ្ញាយ៉ាងនេះ ក្នុងកាលជាអនាគត សូមឲ្យមានសង្ខារយ៉ាងនេះ ក្នុងកាលជាអនាគត សូមឲ្យមានវិញ្ញាណយ៉ាងនេះ ក្នុងកាលជាអនាគត ។ ម្នាលគហបតី ភិក្ខុជាអ្នកប្រាថ្នាទៅក្នុងអនាគតកាល យ៉ាងនេះឯង ។

[ ៦១ ] ម្នាលគហបតី ចុះភិក្ខុជាអ្នកមិនប្រាថ្នាទៅក្នុងអនាគតកាល តើដូចម្តេច ។ ម្នាលគហបតី ភិក្ខុក្នុងសាសនានេះ មិនមានសេចក្តីប្រាថ្នាយ៉ាងនេះ សូមឲ្យអាត្មាអញមានរូបយ៉ាងនេះ ក្នុងកាលជាអនាគត សូមឲ្យមានវេទនាយ៉ាងនេះ ក្នុងកាលជាអនាគត សូមឲ្យមានសញ្ញាយ៉ាងនេះ ក្នុងកាលជាអនាគត សូមឲ្យមានសង្ខារយ៉ាងនេះ ក្នុងកាលជាអនាគត សូនឲ្យមានវិញ្ញាណយ៉ាងនេះ ក្នុងកាលជាអនាគត ។ ម្នាលគហបតី ភិក្ខុជាអ្នកមិនប្រាថ្នាទៅក្នុងអនាគតកាល យ៉ាងនេះឯង ។

[២២] កថញ្ច គហបតិ កថំ វិគ្គយ្ហ ជនេន កត្តា ហោតិ ។ ឥធ គហបតិ ឯកច្ចោ ឯវរូបឹ កថំ កត្តា ហោតិ ន ត្វំ ឥមំ ធម្មវិនយំ អាជានាសិ អហំ ឥមំ ធម្មវិនយំ អាជានាមិ កឹ ត្វំ ឥមំ ធម្មវិនយំ អាជានិស្សសិ មិច្ឆាបដិបន្នោ ត្វមសិ អហមស្មិ សម្មាបដិបន្នោ បុរេ វចនីយំ បច្ឆា អវច បច្ឆា វចនីយំ បុរេ អវច សហិតម្មេ អសហិតន្តេ អធិចិណ្ណន្តេ វិបរាវត្តំ អារោបិតោ តេ វាទោ ចរ វាទប្បមោក្ខាយ និគ្គហិតោសិ និព្វេឋេហិ វា សចេ បហោសីតិ ។ ឯវំ ខោ គហបតិ កថំ វិគ្គយ្ហ ជនេន កត្តា ហោតិ ។

(២២) ម្នាលគហបតី ចុះកិច្ចធ្វើនូវពាក្យទាស់ទែងជាមួយនឹងជន តើដូចម្តេច ។ ម្នាលគហបតី ភិក្ខុខ្លះក្នុងសាសនានេះ និយាយពាក្យមានសភាពយ៉ាងនេះថា អ្នកមិនស្គាល់ច្បាស់នូវធម៌វិន័យនេះទេ ខ្ញុំទើបស្គាល់ច្បាស់ធម៌វិន័យនេះ អ្នកនឹងស្គាល់ធម៌វិន័យនេះដូចម្តេចបាន អ្នកជាអ្នកប្រតិបត្តិខុស ខ្ញុំទើបប្រតិបត្តិត្រូវ ពាក្យដែលគេគួរនិយាយមុន អ្នកទៅជានិយាយក្រោយ ពាក្យដែលគេគួរនិយាយក្រោយ អ្នកទៅជានិយាយមុន ពាក្យរបស់ខ្ញុំទើបមានប្រយោជន៍ ពាក្យរបស់អ្នកមិនមានប្រយោជន៍ទេ វត្ថុដែលអ្នកសន្សំមកយូរហើយ ដល់មកត្រូវសំដីខ្ញុំក៏វិបរិតទៅ ខ្ញុំលើកទោសអ្នកហើយ ចូរអ្នកទៅរកដោះទោស (ឲ្យរួចចុះ) ខ្ញុំសង្កត់សង្កិនអ្នកហើយ បើអ្នកគ្រាន់បើ អ្នកដោះស្រាយមកចុះ ។ ម្នាលគហបតី កិច្ចធ្វើនូវពាក្យទាស់ទែងជាមួយនឹងជន យ៉ាងនេះឯង ។

( ២៣ ) កថញ្ច គហបតិ កថំ ន វិគ្គយ្ហ ជនេន កត្តា ហោតិ ។ ឥធ គហបតិ ភិក្ខុ ឯវរូបឹ កថំ កត្តា ហោតិ ន ត្វំ ឥមំ ធម្មវិនយំ អាជានាសិ អហំ ឥមំ ធម្មវិនយំ អាជានាមិ កឹ ត្វំ ឥមំ ធម្មវិនយំ អាជានិស្សសិ មិច្ឆាបដិបន្នោ ត្វមសិ អហមស្មិ សម្មាបដិបន្នោ បុរេ វចនីយំ បច្ឆា អវច បច្ឆា វចនីយំ បុរេ អវច សហិតម្មេ អសហិតន្តេ អធិចិណ្ណន្តេ វិបរាវត្តំ អារោបិតោ តេ វាទោ ចរ វាទប្បមោក្ខាយ និគ្គហិតោសិ និព្វេឋេហិ វា សចេ បហោសីតិ ។ ឯវំ ខោ គហបតិ កថំ ន វិគ្គយ្ហ ជនេន កត្តា ហោតិ ។

( ២៤ ) ឥតិ ខោ គហបតិ យន្តំ វុត្តំ ភគវតា អដ្ឋកវគ្គិយេ មាគណ្ឌិយបញ្ហេ

(២៣) ចុះភិក្ខុមិនធ្វើនូវពាក្យទាស់ទែងជាមួយនឹងជន តើដូចម្តេច ។ ម្នាលគហបតី ភិក្ខុក្នុងសាសនានេះ មិននិយាយពាក្យមានសភាពយ៉ាងនេះថា អ្នកមិនស្គាល់ច្បាស់នូវធម្មវិន័យនេះទេ ខ្ញុំទើបស្គាល់ច្បាស់នូវធម្មវិន័យនេះ អ្នកនឹងស្គាល់ធម្មវិន័យនេះដូចម្តេចបាន អ្នកជាអ្នកប្រតិបត្តិខុស ខ្ញុំទើបប្រតិបត្តិត្រូវ ពាក្យដែលគេគួរនិយាយមុន អ្នកទៅជានិយាយក្រោយ ពាក្យដែលគេគួរនិយាយក្រោយ អ្នកទៅជានិយាយមុន ពាក្យរបស់ខ្ញុំទើបមានប្រយោជន៍ ពាក្យអ្នកមិនមានប្រយោជន៍ទេ វត្ថុដែលអ្នកសន្សំមកយូរហើយ ដល់មកត្រូវសំដីខ្ញុំក៏វិបរិតទៅ ខ្ញុំលើកទោសអ្នកហើយ ចូរអ្នកទៅរកដោះទោស (ឲ្យរួចចុះ) ខ្ញុំសង្កត់សង្កិនអ្នកហើយ បើអ្នកគ្រាន់បើ អ្នកដោះស្រាយមកចុះ ។ ម្នាលគហបតី ភិក្ខុមិនធ្វើនូវពាក្យទាស់ទែងជាមួយនឹងជន យ៉ាងនេះឯង ។

(២៤) ម្នាលគហបតី ភាសិតដែលព្រះមានព្រះភាគបានត្រាស់ហើយ ក្នុងមាគណ្ឌិយបញ្ហា ដែលកប់ចូលក្នុងអដ្ឋកវគ្គថា

ឱកំ បហាយ អនិកេតសារី
គាមេ អកុព្វំ មុនិ សន្ថវានិ
កាមេហិ រិត្តោ អបុរេក្ខរានោ
កថំ ន វិគ្គយ្ហ ជនេន កយិរាតិ ។

ឥមស្ស ខោ គហបតិ ភគវតា សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថោ ទដ្ឋព្វោតិ ។

(២៥) ឯវម្មេ សុតំ ។ ឯកំ សមយំ អាយស្មា មហាកច្ចានោ អវន្តីសុ វិហរតិ កុររឃរេ បបាតេ បព្វតេ ។ អថខោ ហាលិទ្ទិកានិ គហបតិ យេនាយស្មា មហាកច្ចានោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ មហាកច្ចានំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ហាលិទ្ទិកានិ គហបតិ អាយស្មន្តំ មហាកច្ចានំ ឯតទវោច វុត្តមិទំ ភន្តេ ភគវតា សក្កបញ្ហេ យេ តេ សមណព្រាហ្មណា

ព្រះតថាគត លះបង់ផ្ទះគឺបញ្ចក្ខន្ធហើយ ជាអ្នកមិនមានការអន្ទោលទៅរកកន្លែងស្នាក់ (គឺអារម្មណ៍ទាំង ៦) ជាអ្នកប្រាជ្ញមិនធ្វើសេចក្តីស្និទ្ធស្នាលក្នុងស្រុក ជាអ្នកទំនេរចាកកាមទាំង-ឡាយ មិនមានសេចក្តីប្រាថ្នាទៅក្នុងអនាគតកាល មិនគប្បីធ្វើនូវពាក្យទាស់ទែងជាមួយនឹងជន ដូច្នេះឯង ។

ម្នាលគហបតី សេចក្តីនៃព្រះពុទ្ធដីកា ដែលព្រះមានព្រះភាគត្រាស់ហើយ ដោយសង្ខេបនេះឯង អ្នកត្រូវយល់សេចក្តីដោយពិស្តារយ៉ាងនេះចុះ ។

(២៤) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមហាកច្ចានៈមានអាយុ គង់នៅលើភ្នំដែលមានជ្រោះខ្វាង ទៀបក្រុង ឈ្មោះកុររ-ឃរៈ ក្នុងដែនអវន្តី ។ គ្រានោះឯង គហបតីឈ្មោះហលិទ្ទិកានិ ចូលទៅរកព្រះមហាកច្ចានៈមានអាយុ លុះចូលទៅដល់ ថ្វាយបង្គំព្រះមហាកច្ចានៈមានអាយុ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះហលិទ្ទិកា-និគហបតី អង្គុយក្នុងទីដ៏សមគួរហើយ ទើបនិយាយនឹងព្រះមហាកច្ចានៈមានអាយុយ៉ាងនេះថា បពិត្រលោកដ៏ចំរើន ពាក្យនេះ ព្រះមានព្រះភាគ បានត្រាស់ទុកក្នុងសក្កប្បញ្ហាថា ពួកសមណព្រាហ្មណ៍ណា

តណ្ហាសង្ខយវិមុត្តា តេ អច្ចន្តនិដ្ឋា អច្ចន្តយោគក្ខេមិនោ អច្ចន្តព្រហ្មចារិនោ អច្ចន្តបរិយោសានា សេដ្ឋា ទេវមនុស្សានន្តិ ។ ឥមស្ស នុ ខោ ភន្តេ ភគវតា សង្ខិត្តេន ភាសិតស្ស កថំ វិត្ថារេន អត្ថោ ទដ្ឋព្វោតិ ។

(២៦) រូបធាតុយា ខោ គហបតិ យោ ឆន្ទោ យោ រាគោ យា នន្ទី យា តណ្ហា យេ ឧបាយុបាទានា ចេតសោ អធិដ្ឋានាភិនិវេសានុសយា តេសំ ខយា វិរាគា និរោធា ចាគា បដិនិស្សគ្គា ចិត្តំ សុវិមុត្តន្តិ វុច្ចតិ ។ វេទនាធាតុយា ខោ គហបតិ ។ បេ ។ សញ្ញាធាតុយា ខោ គហបតិ ។ សង្ខារធាតុយា ខោ គហបតិ ។ វិញ្ញាណធាតុយា ខោ យោ ឆន្ទោ យោ រាគោ យា នន្ទី យា តណ្ហា យេ ឧបាយុ-

មានចិត្តរួចស្រឡះហើយ ព្រោះអស់ទៅនៃតណ្ហា ពួកសមណ-ព្រាហ្មណ៍ទាំងនោះ ទើបពេញជាអ្នកមានកិច្ចការស្រេចហើយ ពេញជាអ្នកមានធម៌ក្សេមចាកយោគៈ ពេញជាអ្នកប្រព្រឹត្តព្រហ្មចរិយៈ ពេញជាអ្នកមានទីបំផុតដោយជុំវិញ ប្រសើរបំផុតជាងទេវតានិងមនុស្សទាំងឡាយ ។ បពិត្រលោកដ៏ចម្រើន សេចក្តីនៃធម៌ដែលព្រះមានព្រះភាគត្រាស់ហើយ ដោយសង្ខេបនេះឯង តើត្រូវយល់សេចក្តីដោយពិស្តារដូចម្តេច ។

[២៦] ម្នាលគហបតី សេចក្តីប៉ុនប៉ង តម្រេក រីករាយ ប្រាថ្នា ឧបាយ និងឧបាទាន ដែលជាទីឈរ ជាទីអង្គុយ ជាទីដេក របស់ចិត្តណា ក្នុងរូបធាតុ ចិត្តដែលហៅថារួចស្រឡះហើយ ព្រោះអស់ទៅ ព្រោះគ្មានតម្រេក ព្រោះរលត់ ព្រោះលះបង់ ព្រោះដម្រុះបោល នូវសេចក្តីប៉ុនប៉ងជាដើមនោះ ។ ម្នាលគហបតី ក្នុងវេទនាធាតុ ។បេ។ ម្នាលគហបតី ក្នុងសញ្ញាធាតុ ។ ម្នាលគហបតី ក្នុងសង្ខារធាតុ ។ ម្នាលគហបតី សេចក្តីប៉ុនប៉ង តម្រេក រីករាយ ប្រាថ្នា ឧបាយ

បាទានា ចេតសោ អធិដ្ឋានាភិនិវេសានុសយា តេសំ ខយា វិរាគា និរោធា ចាគា បដិនិស្សគ្គា ចិត្តំ សុវិមុត្តន្តិ វុច្ចតិ ។ ឥតិ ខោ គហបតិ យន្តំ វុត្តំ ភគវតា សក្កបញ្ហេ យេ តេ សមណព្រាហ្មណា តណ្ហាសង្ខយវិមុត្តា តេ អច្ចន្តនិដ្ឋា អច្ចន្តយោគក្ខេមិនោ អច្ចន្តព្រហ្មចារិនោ អច្ចន្តបរិយោសានា សេដ្ឋា ទេវមនុស្សានន្តិ ។ ឥមស្ស ខោ គហបតិ ភគវតា សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថោ ទដ្ឋព្វោតិ ។

(២៧) ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា

និងឧបាទាន ដែលជាទីឈរ ជាទីអង្គុយ ជាទីដេក របស់ចិត្តណា ក្នុងវិញ្ញាណធាតុ ចិត្តដែលហៅថារួចស្រឡះហើយ ព្រោះអស់ទៅ ព្រោះគ្មានតម្រេក ព្រោះរលត់ ព្រោះលះបង់ ព្រោះដម្រុះចោល នូវសេចក្តីប៉ុនប៉ងជាដើមនោះ ។ ម្នាលគហបតី ពាក្យដែលព្រះមានព្រះភាគទ្រង់ត្រាស់ក្នុងសក្កបញ្ហាថា ពួកសមណព្រាហ្មណ៍ណា ដែលមានចិត្តរួចស្រឡះហើយ ព្រោះអស់ទៅនៃតណ្ហា ពួកសមណព្រាហ្មណ៍ទាំងនោះ ទើបពេញជាអ្នកមានកិច្ចការស្រេចហើយ ពេញជាអ្នកមានសេចក្តីក្សេមក្សាន្តចាកយោគៈ ពេញជាអ្នកប្រព្រឹត្តព្រហ្មចរិយៈ ពេញជាអ្នកមានទីបំផុតដោយជុំវិញ ប្រសើរបំផុតជាងទេវតានិងមនុស្សទាំងឡាយ ដូច្នេះឯង ។ ម្នាលគហបតី សេចក្តីនៃធម៌ដែលព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ដោយសង្ខេបនេះឯង អ្នកត្រូវយល់សេចក្តីដោយពិស្តារ យ៉ាងនេះចុះ ។

(២៧) ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក្នុងទីនោះឯង ព្រះមានព្រះភាគ ត្រាស់ហៅពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ បានទទួលព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ទើបព្រះមានព្រះភាគ

ឋតនេវច សមាធឹ ភិក្ខវេ ភាវេថ ។ សមាហិតោ ភិក្ខវេ ភិក្ខុ យថាភូតំ បជានាតិ ។ កិញ្ច យថាភូតំ បជានាតិ ។ រូបស្ស សមុទយញ្ច អត្ថង្គមញ្ច វេទនាយ សមុទយញ្ច អត្ថង្គមញ្ច សញ្ញាយ សមុទយញ្ច អត្ថង្គមញ្ច សង្ខារានំ សមុទយញ្ច អត្ថង្គមញ្ច វិញ្ញាណស្ស សមុទយញ្ច អត្ថង្គមញ្ច ។

(២៨) កោ ច ភិក្ខវេ រូបស្ស សមុទយោ កោ វេទនាយ សមុទយោ កោ សញ្ញាយ សមុទយោ កោ សង្ខារានំ សមុទយោ កោ វិញ្ញាណស្ស សមុទយោ ។ ឥធ ភិក្ខវេ អភិនន្ទតិ អភិវទតិ អជ្ឈោសាយ តិដ្ឋតិ ។ កិញ្ច អភិនន្ទតិ អភិវទតិ អជ្ឈោសាយ តិដ្ឋតិ ។ រូបំ អភិនន្ទតិ អភិវទតិ អជ្ឈោសាយ តិដ្ឋតិ តស្ស រូបំ អភិនន្ទតោ អភិវទតោ អជ្ឈោសាយ តិដ្ឋតោ ឧប្បជ្ជតិ នន្ទិ យា រូបេ នន្ទិ តទុបាទានំ

ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយចម្រើននូវសមាធិ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានចិត្តតំកល់មាំហើយ រមែងដឹងច្បាស់តាមសេចក្ដីពិត ។ ចុះដឹងច្បាស់នូវអ្វី តាមសេចក្ដីពិត ។ ដឹងច្បាស់ នូវការកើតឡើងនិងសេចក្ដីវិនាសនៃរូប នូវការកើតឡើងនិងសេចក្ដីវិនាសនៃវេទនា នូវការកើតឡើងនិងសេចក្ដីវិនាសនៃសញ្ញា នូវការកើតឡើងនិងសេចក្ដីវិនាស នៃសង្ខារទាំងឡាយ នូវការកើតឡើងនិងសេចក្ដីវិនាសនៃវិញ្ញាណ ។

[ ២៨ ] ម្នាលភិក្ខុទាំងឡាយ ចុះការកើតឡើងនៃរូប តើដូចម្ដេច ការកើតឡើងនៃវេទនា តើដូចម្ដេច ការកើតឡើងនៃសញ្ញា តើដូចម្ដេច ការកើតឡើងនៃសង្ខារទាំងឡាយ តើដូចម្ដេច ការកើតឡើងនៃវិញ្ញាណ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលក្នុងលោកនេះ តែងត្រេកអរ សរសើរ ក្រសោបក្រសាយក ។ ចុះបុគ្គលនោះ តែងត្រេកអរ សរសើរ ក្រសោបក្រសាយកអ្វី ។ បុគ្គលនោះ តែងត្រេកអរ សរសើរ ក្រសោបក្រសាយកនូវរូប កាលបុគ្គលនោះ កំពុងត្រេកអរ សរសើរ ក្រសោបក្រសាយកនូវរូប សេចក្ដីត្រេកអរតែងកើតឡើង សេចក្ដីត្រេកអរណាក្នុងរូប សេចក្ដីត្រេកអរនោះ ហៅថាឧបាទាន (សេចក្ដីប្រកាន់)

តស្សុបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។ វេទនំ អភិនន្ទតិ ។ បេ ។ សញ្ញំ អភិនន្ទតិ ។ បេ ។ សង្ខារេ អភិនន្ទតិ ។ បេ ។ វិញ្ញាណំ អភិនន្ទតិ អភិវទតិ អជ្ឈោសាយ តិដ្ឋតិ តស្ស វិញ្ញាណំ អភិនន្ទតោ អភិវទតោ អជ្ឈោសាយ តិដ្ឋតោ ឧប្បជ្ជតិ នន្ទិ យា វិញ្ញាណេ នន្ទិ តទុបាទានំ តស្សុបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។ អយំ ភិក្ខវេ រូបស្ស សមុទយោ អយំ វេទនា សមុទយោ អយំ សញ្ញាយ សមុទយោ អយំ សង្ខារានំ សមុទយោ អយំ វិញ្ញាណស្ស សមុទយោ ។

ភពកើតឡើង ព្រោះសេចក្តីប្រកាន់នូវរូបនោះជាបច្ច័យ ជាតិកើតឡើង ព្រោះភពជាបច្ច័យ ជរាមរណៈ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត កើតឡើង ព្រោះជាតិជាបច្ច័យដែរ ។ សេចក្តីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ យ៉ាងនេះឯង ។ ត្រេកអរនឹងវេទនា ។បេ។ ត្រេកអរនឹងសញ្ញា ។បេ។ ត្រេកអរនឹងសង្ខារទាំងឡាយ ។បេ។ ត្រេកអរ សរសើរ ក្រសោបក្រសាវយកនូវវិញ្ញាណ កាលបើបុគ្គលនោះ កំពុងត្រេកអរ សរសើរ ក្រសោបក្រសាវយកនូវវិញ្ញាណ សេចក្តីត្រេកអររមែងកើតឡើង សេចក្តីត្រេកអរណា ក្នុងវិញ្ញាណ សេចក្តីត្រេកអរនោះ ហៅថាឧបាទាន (សេចក្តីប្រកាន់) ភពកើតឡើង ព្រោះសេចក្តីប្រកាន់នូវវិញ្ញាណនោះជាបច្ច័យ ជាតិកើតឡើង ព្រោះភពជាបច្ច័យ ។បេ។ សេចក្តីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះឈ្មោះថាហេតុឲ្យកើតរូប នេះឈ្មោះថាហេតុឲ្យកើតវេទនា នេះឈ្មោះថាហេតុឲ្យកើតសញ្ញា នេះឈ្មោះថាហេតុឲ្យកើតសង្ខារទាំងឡាយ នេះឈ្មោះថាហេតុឲ្យកើតវិញ្ញាណ ។

(២៩) កោ ច ភិក្ខវេ រូបស្ស អត្ថង្គមោ ។ កោ វេទនាយ ។ កោ សញ្ញាយ ។ កោ សង្ខារានំ ។ កោ វិញ្ញាណស្ស អត្ថង្គមោ ។ ឥធ ភិក្ខវេ នាភិនន្ទតិ នាភិវទតិ នាជ្ឈោសាយ តិដ្ឋតិ ។ កិញ្ច នាភិនន្ទតិ នាភិវទតិ នាជ្ឈោសាយ តិដ្ឋតិ ។ រូបំ នាភិនន្ទតិ នា-ភិវទតិ នាជ្ឈោសាយ តិដ្ឋតិ តស្ស រូបំ អនភិនន្ទតោ អនភិវទតោ អនជ្ឈោសាយ តិដ្ឋតោ យា រូបេ នន្ទិ សា និរុជ្ឈតិ តស្ស នន្ទិនិរោធា ឧបាទាននិរោធោ ឧបាទាន-និរោធា ភវនិរោធោ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ ។ វេទនំ នាភិនន្ទតិ នា-ភិវទតិ នាជ្ឈោសាយ តិដ្ឋតិ តស្ស វេទនំ អនភិនន្ទតោ អនភិវទតោ អនជ្ឈោសាយ តិដ្ឋតោ យា វេទនាយ នន្ទិ សា និរុជ្ឈតិ តស្ស នន្ទិនិរោធា ឧបាទាននិរោធោ

[៤៩] ម្នាលភិក្ខុទាំងឡាយ សេចក្តីវិនាសទៅវិញនៃរូប តើដូចម្តេច ៗ នៃវេទនា តើដូចម្តេច ៗ នៃសញ្ញា តើដូចម្តេច ៗ នៃសង្ខារទាំងឡាយ តើដូចម្តេច ៗ សេចក្តីវិនាសនៃវិញ្ញាណ តើដូចម្តេច ៗ ម្នាលភិក្ខុទាំងឡាយ បុគ្គលក្នុងលោកនេះ មិនត្រេកអរ មិនសរសើរ មិនក្រសោបក្រសាវយក ៗ ចុះបុគ្គលនោះ មិនត្រេកអរ មិនសរសើរ មិនក្រសោបក្រសាវយកអ្វី ៗ មិនត្រេកអរ មិនសរសើរ មិនក្រសោបក្រសាវយកនូវរូប កាលបុគ្គលនោះ មិនត្រេកអរ មិនសរសើរ មិនក្រសោបក្រសាវយកនូវរូប សេចក្តីត្រេកអរណា ក្នុងរូប សេចក្តីត្រេកអរនោះ ក៏រលត់បាត់បង់ ការរលត់ឧបាទាន ព្រោះរលត់សេចក្តីត្រេកអររបស់បុគ្គលនោះ ការរលត់ភព ព្រោះរលត់ឧបាទាន ។ បេ ។ ការរលត់ទៅនៃកងទុក្ខទាំងអស់នុ៎ះ យ៉ាងនេះឯង ៗ បុគ្គលនោះ មិនត្រេកអរ មិនសរសើរ មិនក្រសោបក្រសាវយកនូវវេទនា កាលបុគ្គលនោះ មិនត្រេកអរ មិនសរសើរ មិនក្រសោបក្រសាវយកនូវវេទនាទេ សេចក្តីត្រេកអរណា ក្នុងវេទនា សេចក្តីត្រេកអរនោះ ក៏រលត់ទៅ ការរលត់ឧបាទាន ព្រោះរលត់សេចក្តីត្រេកអររបស់បុគ្គលនោះ

ឧបាទាននិរោធា ភវនិរោធោ ភវនិរោធា ជាតិនិរោធោ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ ។ សញ្ញំ នាភិនន្ទតិ ។ បេ ។ សង្ខារេ នាភិនន្ទតិ នាភិវទតិ នាជ្ឈោសាយ តិដ្ឋតិ តស្ស សង្ខារេ អនភិនន្ទតោ អនភិវទតោ អនជ្ឈោសាយ តិដ្ឋតោ យា សង្ខារេសុ នន្ទិ សា និរុជ្ឈតិ តស្ស នន្ទិនិរោធា ឧបាទាននិរោធោ ឧបាទាននិរោធា ភវនិរោធោ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ ។ វិញ្ញាណំ នាភិនន្ទតិ នាភិវទតិ នាជ្ឈោសាយ តិដ្ឋតិ តស្ស វិញ្ញាណំ អនភិនន្ទតោ អនភិវទតោ អនជ្ឈោសាយ តិដ្ឋតោ យា វិញ្ញាណេ នន្ទិ សា និរុជ្ឈតិ តស្ស នន្ទិនិរោធា ឧបាទាននិរោធោ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ ។ អយំ ភិក្ខវេ រូបស្ស អត្ថង្គមោ អយំ វេទនាយ អត្ថង្គមោ អយំ សញ្ញាយ អត្ថង្គមោ អយំ សង្ខារានំ អត្ថង្គមោ អយំ វិញ្ញាណស្ស អត្ថង្គមោតិ ។

ការរលត់ភព ព្រោះរលត់ឧបាទាន ការរលត់ជាតិ ព្រោះរលត់ភព ។ បេ ។ ការរលត់ទៅនៃកងទុក្ខទាំងអស់នុ៎ះ យ៉ាងនេះឯង ។ មិនត្រេកអរនឹងសញ្ញា ។ បេ ។ មិនត្រេកអរ មិនសរសើរ មិនក្រសោបក្រសាវយកនូវសង្ខារទាំងឡាយ កាលបុគ្គលនោះ មិនត្រេកអរ មិនសរសើរ មិនក្រសោបក្រសាវយកនូវសង្ខារទាំងឡាយទេ សេចក្តីត្រេកអរណាក្នុងសង្ខារទាំងឡាយ សេចក្តីត្រេកអរនោះរលត់ទៅ ការរលត់ឧបាទាន ព្រោះរលត់សេចក្តីត្រេកអររបស់បុគ្គលនោះ ការរលត់ភព ព្រោះរលត់ឧបាទាន ។ បេ ។ ការរលត់ទៅនៃកងទុក្ខទាំងអស់នុ៎ះ យ៉ាងនេះឯង ។ មិនត្រេកអរ មិនសរសើរ មិនក្រសោបក្រសាវយកនូវវិញ្ញាណ កាលបើបុគ្គលនោះ មិនត្រេកអរ មិនសរសើរ មិនក្រសោបក្រសាវយកនូវវិញ្ញាណទេ សេចក្តីត្រេកអរណា ក្នុងវិញ្ញាណ សេចក្តីត្រេកអរនោះរលត់ទៅ ការរលត់ឧបាទាន ព្រោះរលត់សេចក្តីត្រេកអររបស់បុគ្គលនោះ ។ បេ ។ ការរលត់ទៅនៃកងទុក្ខទាំងអស់នុ៎ះ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះឈ្មោះថាសេចក្តីវិនាសរូប នេះឈ្មោះថាសេចក្តីវិនាសវេទនា នេះឈ្មោះថាសេចក្តីវិនាសសញ្ញា នេះឈ្មោះថាសេចក្តីវិនាសសង្ខារទាំងឡាយ នេះឈ្មោះថាសេចក្តីវិនាសវិញ្ញាណ ។

(៣០) សាវត្ថិយំ ។ តត្រ ខោ ។ បេ ។ បដិសល្លាណេ ភិក្ខវេ យោគមាបជ្ជថ ។ បដិសល្លីនោ ភិក្ខវេ ភិក្ខុ យថាភូតំ បជានាតិ ។ កិញ្ច យថាភូតំ បជានាតិ ។ រូបស្ស សមុទយញ្ច អត្ថង្គមញ្ច វេទនាយ សមុទយញ្ច អត្ថង្គមញ្ច សញ្ញាយ សមុទយញ្ច អត្ថង្គមញ្ច សង្ខារានំ សមុទយញ្ច អត្ថង្គមញ្ច វិញ្ញាណស្ស សមុទយញ្ច អត្ថង្គមញ្ច ។ (យថា បឋមសុត្តេ វិត្ថារោ តថា វិត្ថារេតព្វំ ។)

(៣១) សាវត្ថិយំ ។ តត្រ ខោ ។ បេ ។ ឧបាទានបរិតស្សនញ្ច វោ ភិក្ខវេ ទេសិស្សាមិ អនុបាទានអបរិតស្សនញ្ច តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច

[៣០] ទៀបក្រុងសាវត្ថី ។ កន្លែងនោះឯង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយប្រកបព្យាយាម ក្នុងការស្ងប់ស្ងាត់កាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលស្ងប់ស្ងាត់កាយ រមែងដឹងច្បាស់ តាមសេចក្តីពិត ។ ចុះដឹងច្បាស់នូវអ្វី តាមសេចក្តីពិត ។ ដឹងច្បាស់នូវសេចក្តីកើតឡើងនិងសេចក្តីវិនាសនៃរូប នូវសេចក្តីកើតឡើងនិងសេចក្តីវិនាសនៃវេទនា នូវសេចក្តីកើតឡើងនិងសេចក្តីវិនាសនៃសញ្ញា នូវសេចក្តីកើតឡើងនិងសេចក្តីវិនាសនៃសង្ខារទាំងឡាយ នូវសេចក្តីកើតឡើងនិងសេចក្តីវិនាសនៃវិញ្ញាណ ។ (សេចក្តីពិស្តារក្នុងសូត្រទី ១ យ៉ាងណា បណ្ឌិតត្រូវធ្វើឲ្យពិស្តារយ៉ាងនោះចុះ ។)

[៣១] ទៀបក្រុងសាវត្ថី ។ កន្លែងនោះឯង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវសេចក្តីតក់ស្លុតដែលកើតឡើង ព្រោះសេចក្តីប្រកាន់ផង នូវសេចក្តីមិនតក់ស្លុត ព្រោះសេចក្តីមិនប្រកាន់ផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់ធម៌នោះចុះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែងប្រាប់ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា

(៣៦) កថញ្ច ភិក្ខវេ ឧបាទាបរិតស្សនា ហោតិ ។ ឥធ ភិក្ខវេ អស្សុតវា បុថុជ្ជនោ អរិយានំ អទស្សាវី អរិយធម្មស្ស អកោវិទោ អរិយធម្មេ អវិនីតោ សប្បុរិសានំ អទស្សាវី សប្បុរិសធម្មស្ស អកោវិទោ សប្បុរិសធម្មេ អវិនីតោ រូបំ អត្តតោ សមនុបស្សតិ រូបវន្តំ វា អត្តានំ អត្តនិ វា រូបំ រូបស្មឹ វា អត្តានំ តស្ស តំ រូបំ វិបរិណមតិ អញ្ញថា ហោតិ តស្ស រូបវិបរិណាមញ្ញថាភាវា រូបវិបរិណាមានុបរិវត្តិវិញ្ញាណំ ហោតិ តស្ស រូបវិបរិណាមានុបរិវត្តិជា បរិតស្សនាធម្មសមុប្បាទា ចិត្តំ បរិយាទាយ តិដ្ឋន្តិ ចេតសោ បរិយាទានា ឧត្តាសវា ច ហោតិ វិឃាតវា ច អបេក្ខវា ច ឧបាទាយ ច បរិតស្សតិ ។ វេទនំ អត្តតោ សមនុបស្សតិ វេទនាវន្តំ វា អត្តានំ អត្តនិ វា វេទនំ វេទនាយ វា អត្តានំ តស្ស សា វេទនា វិបរិណមតិ

[ ៣៦ ] ម្នាលភិក្ខុទាំងឡាយ សេចក្តីតក់ស្លុត ព្រោះសេចក្តីប្រកាន់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង ជាអ្នកមិនឃើញពួកព្រះអរិយៈ មិនឈ្លាសវៃក្នុងធម៌ព្រះអរិយៈ មិនបានសិក្សាក្នុងធម៌ព្រះអរិយៈ មិនបានឃើញពួកសប្បុរស មិនឈ្លាសវៃក្នុងធម៌សប្បុរស មិនបានទូន្មានខ្លួនក្នុងធម៌សប្បុរស រមែងពិចារណាឃើញច្បាស់ នូវរូបថាជាខ្លួនខ្លះ ឃើញនូវខ្លួនថាមានរូបខ្លះ ឃើញនូវរូបថាមានក្នុងខ្លួនខ្លះ ឃើញនូវខ្លួនថាមានក្នុងរូបខ្លះ លុះដល់រូបនោះនៃបុគ្គលនោះ ប្រែប្រួលទៅ ប្លែកទៅ កម្មវិញ្ញាណដែលវិលតាមការប្រែប្រួលរបស់រូប រមែងមានដល់បុគ្គលនោះ ព្រោះតែរូបប្រែប្រួលទៅប្លែកទៅ សេចក្តីតក់ស្លុតនិងការកើតឡើងនៃអកុសលធម៌ ដែលកើតអំពីការវិលតាមនូវសេចក្តីប្រែប្រួលនៃរូប ក៏គ្របសង្កត់កុសលចិត្តរបស់បុគ្គលនោះ ព្រោះតែការគ្របសង្កត់ចិត្ត ទើបបុគ្គលនោះ មានសេចក្តីតក់ស្លុតផង មានសេចក្តីទុក្ខផង មានសេចក្តីអាឡោះអាល័យផង តែងតក់ស្លុត ព្រោះប្រកាន់ផង ។ ពិចារណាឃើញច្បាស់នូវវេទនាថាជាខ្លួនខ្លះ ឃើញនូវខ្លួនថាមានវេទនាខ្លះ ឃើញនូវវេទនាថាមានក្នុងខ្លួនខ្លះ ឃើញនូវខ្លួនថាមានក្នុងវេទនាខ្លះ លុះដល់វេទនានោះ របស់បុគ្គលនោះ ប្រែប្រួលទៅ

អញ្ញថា ហោតិ តស្ស វេទនាវិបរិណាមញ្ញថាភាវា វេទនាវិបរិណាមានុបរិវត្តិវិញ្ញាណំ ហោតិ តស្ស វេទនាវិបរិណាមានុបរិវត្តិជា បរិតស្សនាធម្មសមុប្បាទា ចិត្តំ បរិយាទាយ តិដ្ឋន្តិ ចេតសោ បរិយាទានា ឧត្តាសវា ច ហោតិ វិឃាតវា ច អបេក្ខវា ច ឧបាទាយ ច បរិតស្សតិ ។ សញ្ញំ អត្តតោ សមនុបស្សតិ ។ បេ ។ សង្ខារេ អត្តតោ សមនុបស្សតិ សង្ខារវន្តំ វា អត្តានំ អត្តនិ វា សង្ខារេ សង្ខារេសុ វា អត្តានំ តស្ស តេ សង្ខារា វិបរិណាមន្តិ អញ្ញថា ហោន្តិ តស្ស សង្ខារានំ វិបរិណាមញ្ញថាភាវា សង្ខារវិបរិណាមានុបរិវត្តិវិញ្ញាណំ ហោតិ តស្ស សង្ខារវិបរិណាមានុបរិវត្តិជា បរិតស្សនាធម្មសមុប្បាទា ចិត្តំ បរិយាទាយ តិដ្ឋន្តិ ចេតសោ បរិយាទានា ឧត្តាសវា ច ហោតិ វិឃាតវា ច អបេក្ខវា ច ឧបាទាយ ច បរិតស្សតិ ។ វិញ្ញាណំ អត្តតោ សមនុបស្សតិ វិញ្ញាណវន្តំ វា អត្តានំ អត្តនិ វា វិញ្ញាណំ វិញ្ញាណស្មឹ វា អត្តានំ

ប្រែទៅ កម្មវិញ្ញាណដែលវិលទៅតាមការប្រែប្រួលនៃវេទនា រមែងមានដល់បុគ្គលនោះ ព្រោះតែវេទនាប្រែប្រួលទៅ ប្រែទៅ សេចក្តីតក់ស្លុតនិងការកើតឡើង នៃអកុសលធម៌ ដែលកើតអំពីការវិលតាមនូវសេចក្តីប្រែប្រួលនៃវេទនា រមែងគ្របសង្កត់កុសលចិត្តរបស់បុគ្គលនោះ ព្រោះតែការគ្របសង្កត់ចិត្ត បុគ្គលនោះមានសេចក្តីតក់ស្លុតផង មានសេចក្តីទុក្ខផង មានសេចក្តីអាឡោះអាល័យផង តែងតក់ស្លុត ព្រោះប្រកាន់ផង ។ ពិចារណា ឃើញច្បាស់នូវសញ្ញាថាជាខ្លួន ។បេ។ ពិចារណាឃើញច្បាស់នូវសង្ខារថាជាខ្លួន ឃើញនូវខ្លួនថាមានសង្ខារខ្លះ ឃើញនូវសង្ខារថាមានក្នុងខ្លួនខ្លះ ឃើញនូវខ្លួនថាមានក្នុងសង្ខារខ្លះ លុះដល់សង្ខារនោះ របស់បុគ្គលនោះ ប្រែប្រួលទៅ ប្រែទៅ កម្មវិញ្ញាណដែលវិលតាមការប្រែប្រួលនៃសង្ខារ រមែងមានដល់បុគ្គលនោះ ព្រោះតែសង្ខារប្រែប្រួលទៅ ប្រែទៅ សេចក្តីតក់ស្លុតនិងការកើតឡើងនៃអកុសលធម៌ ដែលកើតអំពីការវិលតាមនូវសេចក្តីប្រែប្រួលនៃសង្ខារ រមែងគ្របសង្កត់ចិត្តបុគ្គលនោះ ព្រោះតែការគ្របសង្កត់ចិត្ត ទើបបុគ្គលនោះរមែងតក់ស្លុតផង ប្រកបដោយសេចក្តីទុក្ខផង មានសេចក្តីអាល័យផង តែងតក់ស្លុត ព្រោះប្រកាន់ផង ។ ពិចារណាឃើញច្បាស់នូវវិញ្ញាណថាជាខ្លួនខ្លះ ឃើញនូវខ្លួនថាមានវិញ្ញាណខ្លះ ឃើញនូវវិញ្ញាណថាមានក្នុងខ្លួនខ្លះ ឃើញនូវខ្លួនថាមានក្នុងវិញ្ញាណខ្លះ

តស្ស តំ វិញ្ញាណំ វិបរិណមតិ អញ្ញថា ហោតិ តស្ស វិញ្ញាណវិបរិណាមញ្ញថាភាវា វិញ្ញាណវិបរិណាមានុបរិវត្តិវិញ្ញាណំ ហោតិ តស្ស វិញ្ញាណវិបរិណាមានុបរិវត្តិជា បរិតស្សនាធម្មសមុប្បាទា ចិត្តំ បរិយាទាយ តិដ្ឋន្តិ ចេតសោ បរិយាទានា ឧត្តាសវា ច ហោតិ វិឃាតវា ច អបេក្ខវា ច ឧបាទាយ ច បរិតស្សតិ ។ ឯវំ ខោ ភិក្ខវេ ឧបាទានបរិតស្សនា ហោតិ ។

(៣៣) កថញ្ច ភិក្ខវេ អនុបាទានអបរិតស្សនា ហោតិ ។ ឥធ ភិក្ខវេ សុតវា អរិយសាវកោ អរិយានំ ទស្សាវី អរិយធម្មស្ស កោវិទោ អរិយធម្មេ សុវិនីតោ សប្បុរិសានំ ទស្សាវី សប្បុរិសធម្មស្ស កោវិទោ សប្បុរិសធម្មេ សុវិនីតោ ន រូបំ អត្តតោ សមនុបស្សតិ ន រូបវន្តំ វា អត្តានំ ន អត្តនិ វា រូបំ ន រូបស្មឹ វា អត្តានំ តស្ស តំ រូបំ វិបរិណមតិ អញ្ញថា ហោតិ តស្ស រូបវិបរិណាមញ្ញ-

លុះដល់វិញ្ញាណនោះរបស់បុគ្គលនោះ ប្រែប្រួលទៅ ប្លែកទៅ កម្មវិញ្ញាណដែលវិលតាមការប្រែប្រួលនៃវិញ្ញាណ រមែងមានដល់បុគ្គលនោះ ព្រោះតែវិញ្ញាណ ប្រែប្រួលទៅ ប្លែកទៅ សេចក្តីតក់ស្លុតនិងការកើតឡើងនៃអកុសលធម៌ ដែលកើតអំពីការវិលតាម នូវសេចក្តីប្រែប្រួលនៃវិញ្ញាណ រមែងគ្របសង្កត់ចិត្តរបស់បុគ្គលនោះ ព្រោះតែការគ្របសង្កត់ ទើបបុគ្គលនោះមានសេចក្តីតក់ស្លុតផង មានសេចក្តីទុក្ខផង មានសេចក្តីការឡោះអាល័យផង តែងតក់ស្លុត ព្រោះប្រកាន់ផង ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីតក់ស្លុត ព្រោះសេចក្តីប្រកាន់ យ៉ាងនេះឯង ។

(៣៣) ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីមិនតក់ស្លុត ព្រោះការមិនប្រកាន់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កក្នុងសាសនានេះ ជាអ្នកចេះដឹង ជាអ្នកឃើញពួកព្រះអរិយៈ ជាអ្នកឈ្លាសវៃក្នុងធម៌ព្រះអរិយៈ បានសិក្សាខ្លួន ក្នុងធម៌ព្រះអរិយៈ ជាអ្នកឃើញពួកសប្បុរស ជាអ្នកឈ្លាសវៃក្នុងធម៌សប្បុរស បានទូន្មានខ្លួនក្នុងធម៌សប្បុរស មិនពិចារណាឃើញច្បាស់នូវរូបថាជាខ្លួនខ្លះ មិនឃើញនូវខ្លួនថាមានរូបខ្លះ មិនឃើញនូវរូបថាមានក្នុងខ្លួនខ្លះ មិនឃើញនូវខ្លួនថាមានក្នុងរូបខ្លះ លុះដល់រូបរបស់អរិយសាវ័កនោះប្រែប្រួលទៅ ប្លែកទៅ កម្មវិញ្ញាណដែលវិល

ថាភាវា ន រូបវិបរិណាមានុបរិវត្តិវិញ្ញាណំ ហោតិ តស្ស ន រូបវិបរិណាមានុបរិវត្តជា បរិតស្សនាធម្មសមុប្បាទា ចិត្តំ បរិយាទាយ តិដ្ឋន្តិ ចេតសោ អបរិយាទានា ន ចេវ ឧត្តាសវា ហោតិ ន វិឃាតវា ន អបេក្ខវា អនុបាទាយ ច ន បរិតស្សតិ ។ ន វេទនំ អត្តតោ សមនុបស្សតិ ន វេទនាវន្តំ វា អត្តានំ ន អត្តនិ វា វេទនំ ន វេទនាយ វា អត្តានំ តស្ស សា វេទនា វិបរិណាមតិ អញ្ញថា ហោតិ តស្ស វេទនាវិបរិណាមញ្ញថាភាវា ន វេទនាវិបរិណាមានុបរិវត្តិវិញ្ញាណំ ហោតិ តស្ស ន វេទនាវិបរិណាមានុបរិវត្តជា បរិតស្សនាធម្មសមុប្បាទា ចិត្តំ បរិយាទាយ តិដ្ឋន្តិ ចេតសោ អបរិយាទានា ន ចេវ ឧត្តាសវា ហោតិ ន វិឃាតវា ន អបេក្ខវា

តាមការប្រែប្រួលនៃរូប រមែងមិនមាន ដល់អរិយសាវ័កនោះ ព្រោះតែរូបប្រែប្រួលទៅ ប្លែកទៅទេ សេចក្តីតក់ស្លុតនិងការកើតឡើង នៃអកុសលធម៌ ដែលកើតអំពីការវិល តាមនូវសេចក្តីប្រែប្រួលនៃរូប ក៏មិនគ្របសង្កត់ចិត្តនៃអរិយសាវ័កនោះទេ ព្រោះតែការមិនគ្របសង្កត់ចិត្ត ទើបអរិយសាវ័កនោះ មិនមានសេចក្តីតក់ស្លុតផង មិនមានសេចក្តីទុក្ខផង មិនមានសេចក្តីអាឡោះអាល័យផង មិនតក់ស្លុតព្រោះមិនប្រកាន់ផង ។ មិនពិចារណាឃើញច្បាស់ នូវវេទនាជាខ្លួនខ្លះ មិនឃើញនូវខ្លួនថាមានវេទនាខ្លះ មិនឃើញនូវវេទនាថាមានក្នុងខ្លួនខ្លះ មិនឃើញនូវខ្លួនថាមានក្នុងវេទនាខ្លះ (លុះដល់) វេទនានោះ របស់អរិយសាវ័កនោះ ប្រែប្រួលទៅ ប្លែកទៅ កម្មវិញ្ញាណដែលវិលតាមការប្រែប្រួលនៃវេទនា រមែងមិនមាន ដល់អរិយសាវ័កនោះ ព្រោះតែវេទនាប្រែប្រួលទៅ ប្លែកទៅទេ សេចក្តីតក់ស្លុតនិងការកើតឡើងនៃអកុសលធម៌ ដែលកើតអំពីការវិលតាមសេចក្តីប្រែប្រួលនៃវេទនា ក៏មិនគ្របសង្កត់ចិត្ត នៃអរិយសាវ័កនោះបានឡើយ ព្រោះតែការមិនគ្របសង្កត់ចិត្ត ទើបអរិយសាវ័កនោះ មិនមានសេចក្តីតក់ស្លុតផង មិនមានសេចក្តីទុក្ខផង មិនមានសេចក្តីអាឡោះអាល័យផង

អនុបាទាយ ច ន បរិតស្សតិ ។ ន សញ្ញំ ។បេ។ ន សង្ខារេ អត្តតោ សមនុបស្សតិ ន សង្ខារវន្តំ វា អត្តានំ ន អត្តនិ វា សង្ខារេ ន សង្ខារេសុ វា អត្តានំ តស្ស តេ សង្ខារា វិបរិណមន្តិ អញ្ញថា ហោន្តិ តស្ស សង្ខារវិបរិណាមញ្ញថាភាវា ន សង្ខារវិបរិណាមានុបរិវត្តិវិញ្ញាណំ ហោតិ តស្ស ន សង្ខារវិបរិណាមានុបរិវត្តិជា បរិតស្សនាធម្មសមុប្បាទា ចិត្តំ បរិយាទាយ តិដ្ឋន្តិ ចេតសោ អបរិយាទានា ន ចេវ ឧត្តាសវា ហោតិ ន វិឃាតវា ន អបេក្ខវា អនុបាទាយ ច ន បរិតស្សតិ ។ ន វិញ្ញាណំ អត្តតោ សមនុបស្សតិ ន វិញ្ញាណវន្តំ វា អត្តានំ ន អត្តនិ វា វិញ្ញាណំ ន វិញ្ញាណស្មឹ វា អត្តានំ តស្ស តំ វិញ្ញាណំ វិបរិណមតិ អញ្ញថា ហោតិ តស្ស វិញ្ញាណវិបរិណាមញ្ញថាភាវា ន វិញ្ញាណវិបរិណាមានុបរិវត្តិវិញ្ញាណំ ហោតិ តស្ស ន វិញ្ញាណវិបរិណាមានុបរិវត្តិជា បរិតស្សនាធម្មសមុប្បាទា

មិនតក់ស្លុតព្រោះមិនប្រកាន់ផង ។ មិនពិចារណាឃើញច្បាស់នូវសញ្ញា ។ បេ ។ មិនពិចារណាឃើញច្បាស់នូវសង្ខារទាំងឡាយថាជាខ្លួនខ្លះ មិនឃើញនូវខ្លួនថាមានសង្ខារខ្លះ មិនឃើញនូវសង្ខារថាមានក្នុងខ្លួនខ្លះ មិនឃើញនូវខ្លួនថាមានក្នុងសង្ខារខ្លះ លុះដល់សង្ខារនោះរបស់អរិយសាវ័កនោះ ប្រែប្រួលទៅ ប្លែកទៅ កម្មវិញ្ញាណដែលវិលតាមការប្រែប្រួលនៃសង្ខារ រមែងមិនមានដល់អរិយសាវ័កនោះ ព្រោះសង្ខារប្រែប្រួលទៅ ប្លែកទៅទេ សេចក្តីតក់ស្លុតនិងការកើតឡើងនៃអកុសលធម៌ ដែលកើតអំពីការវិលតាមសេចក្តីប្រែប្រួលនៃសង្ខារ ក៏មិនគ្របសង្កត់ចិត្តអរិយសាវ័កនោះឡើយ ព្រោះតែការមិនគ្របសង្កត់ចិត្ត ទើបអរិយសាវ័កនោះ មិនមានសេចក្តីតក់ស្លុតផង មិនមានសេចក្តីទុក្ខផង មិនមានសេចក្តីអាឡោះអាល័យផង មិនតក់ស្លុតព្រោះមិនប្រកាន់ផង ។ មិនពិចារណាឃើញច្បាស់នូវវិញ្ញាណថាជាខ្លួនខ្លះ មិនឃើញនូវខ្លួនថាមានវិញ្ញាណខ្លះ មិនឃើញនូវវិញ្ញាណថាមានក្នុងខ្លួនខ្លះ មិនឃើញនូវខ្លួនថាមានក្នុងវិញ្ញាណខ្លះ លុះដល់វិញ្ញាណនោះ របស់អរិយសាវ័កនោះ ប្រែប្រួលទៅ ប្លែកទៅ កម្មវិញ្ញាណដែលវិលតាមការប្រែប្រួលនៃវិញ្ញាណ រមែងមិនមានដល់អរិយសាវ័កនោះ ព្រោះតែវិញ្ញាណ ប្រែប្រួលទៅ ប្លែកទៅទេ សេចក្តីតក់ស្លុតនិងការកើតឡើងនៃអកុសលធម៌ ដែលកើតអំពីការវិលតាម សេចក្តីប្រែប្រួលនៃវិញ្ញាណ

ចិត្តំ បរិយាទាយ តិដ្ឋន្តិ ចេតសោ អបរិយាទានា ន ចេវ ឧត្តាសវា ហោតិ ន វិឃាតវា ន អបេក្ខវា អនុបាទាយ ច ន បរិតស្សតិ ។ ឯវំ ខោ ភិក្ខវេ អនុបាទានអបរិតស្សនា ហោតីតិ ។

(៣៦) សាវត្ថិយំ ។ តត្រ ខោ ។ បេ ។ ឧបាទានបរិតស្សនញ្ច វោ ភិក្ខវេ ទេសិស្សាមិ អនុបាទានអបរិតស្សនញ្ច តំ សុណាថ ។ បេ ។ កថញ្ច ភិក្ខវេ ឧបាទានបរិតស្សនា ហោតិ ។ ឥធ ភិក្ខវេ អស្សុតវា បុថុជ្ជនោ រូបំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ សមនុបស្សតិ តស្ស តំ រូបំ វិបរិណមតិ អញ្ញថា ហោតិ តស្ស រូបវិបរិណាមញ្ញថាភាវា ឧប្បជ្ជន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសា ។ វេទនំ ឯតំ មម ។ បេ ។ សញ្ញំ ឯតំ មម ។ បេ ។ សង្ខារេ ឯតំ មម ។ បេ ។ វិញ្ញាណំ ឯតំ មម ឯសោហមស្មិ

ក៏មិនគ្រប់សង្កត់ចិត្ត នៃអរិយសាវ័កនោះឡើយ ព្រោះការមិនគ្រប់សង្កត់ចិត្ត ទើបអរិយសាវ័កនោះ មិនមានសេចក្ដីតក់ស្លុតផង មិនមានសេចក្ដីទុក្ខផង មិនមានសេចក្ដីអាឡោះអាល័យផង មិនតក់ស្លុត ព្រោះមិនប្រកាន់ផង ៗ ម្នាលភិក្ខុទាំងឡាយ ការមិនតក់ស្លុត ព្រោះមិនប្រកាន់យ៉ាងនេះឯង ៗ

(៣៤) ទៀបក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវសេចក្ដីតក់ស្លុត ព្រោះសេចក្ដីប្រកាន់ផង សេចក្ដីមិនតក់ស្លុតព្រោះសេចក្ដីមិនប្រកាន់ផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្ដាប់ធម៌នោះចុះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីតក់ស្លុត ព្រោះសេចក្ដីប្រកាន់ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង រមែងពិចារណាឃើញនូវរូបថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ លុះដល់រូបនោះ របស់បុគ្គលនោះ ប្រែប្រួលទៅ ប្លែកទៅ សេចក្ដីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្ដីចង្អៀតចង្អល់ចិត្ត រមែងកើតឡើងដល់បុគ្គលនោះ ព្រោះតែរូបប្រែប្រួលទៅ ប្លែកទៅ ។ នូវវេទនាថា នុ៎ះរបស់អញ ។បេ។ នូវសញ្ញាថា នុ៎ះរបស់អញ ។ បេ ។ នូវសង្ខារទាំងឡាយថា នុ៎ះរបស់អញ ។ បេ ។ ពិចារណាឃើញនូវវិញ្ញាណថា នុ៎ះរបស់អញ នុ៎ះជាអញ

ឯសោ មេ អត្តាតិ សមនុបស្សតិ តស្ស តំ វិញ្ញាណំ វិបរិណាមតិ អញ្ញថា ហោតិ តស្ស វិញ្ញាណវិបរិណាមញ្ញថាភាវា ឧប្បជ្ជន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសា ។ ឯវំ ខោ ភិក្ខវេ ឧបាទាបរិតស្សនា ហោតិ ។

(៣៨) កថញ្ច ភិក្ខវេ អនុបាទាអបរិតស្សនា ហោតិ ។ ឥធ ភិក្ខវេ សុតវា អរិយសាវកោ រូបំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ សមនុបស្សតិ តស្ស តំ រូបំ វិបរិណាមតិ អញ្ញថា ហោតិ តស្ស រូបវិបរិណាមញ្ញថាភាវា នុប្បជ្ជន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសា ។ វេទនំ នេតំ មម ។

នុះជាខ្លួនរបស់អញ លុះដល់វិញ្ញាណនោះ របស់បុគ្គលនោះ ប្រែប្រួលទៅ ប្លែកទៅ សេចក្ដីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្ដីចង្អៀតចង្អល់ចិត្ត រមែងកើតឡើងដល់បុគ្គលនោះ ព្រោះតែវិញ្ញាណប្រែប្រួលទៅ ប្លែកទៅ ។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីតក់ស្លុត ព្រោះសេចក្ដីប្រកាន់ យ៉ាងនេះឯង ។

(៣៤) ម្នាលភិក្ខុទាំងឡាយ ចុះការមិនតក់ស្លុតព្រោះសេចក្ដីមិនប្រកាន់ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងលោកនេះ ជាអ្នកចេះដឹង រមែងពិចារណាឃើញនូវរូបថា នុះមិនមែនរបស់អញ នុះមិនមែនជាអញ នុះមិនមែនជាខ្លួនអញទេ លុះដល់រូបនោះ របស់អរិយសាវកនោះ ប្រែប្រួលទៅ ប្លែកទៅ សេចក្ដីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្ដីចង្អៀតចង្អល់ចិត្ត រមែងមិនកើតឡើងដល់អរិយសាវកនោះ ព្រោះតែរូបប្រែប្រួលទៅ ប្លែកទៅឡើយ ។ នូវវេទនាថា នុះមិនមែនរបស់អញ ។

សញ្ញំ នេតំ មម ។ សង្ខារេ នេតំ មម ។ វិញ្ញាណំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ សមនុបស្សតិ តស្ស តំ វិញ្ញាណំ វិបរិណាមតិ អញ្ញថា ហោតិ តស្ស វិញ្ញាណវិបរិណាមញ្ញថាភាវា ឧប្បជ្ជន្តិ សោកបរិទេវ-ទុក្ខទោមនស្សុបាយាសា ។ ឯវំ ខោ ភិក្ខវេ អនុបាទា-នអបរិតស្សនា ហោតីតិ ។

(៣៦) សាវត្ថិយំ ។ តត្រ ខោ ។ បេ ។ រូបំ ភិក្ខវេ អនិច្ចំ អតីតានាគតំ កោ បន វាទោ បច្ចុប្បន្នស្ស ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ អតីតស្មឹ រូបស្មឹ អនបេក្ខោ ហោតិ អនាគតំ រូបំ នាភិនន្ទតិ បច្ចុប្បន្នស្ស រូបស្ស និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតិ ។ វេទនា អនិច្ចា ។ បេ ។ សញ្ញា អនិច្ចា ។ បេ ។ សង្ខារា អនិច្ចា អតីតានាគតា កោ បន

នូវសញ្ញាថា នុ៎ះមិនមែនរបស់អញ ។ នូវសង្ខារទាំងឡាយថា នុ៎ះមិនមែនរបស់អញ ។ ពិចារណាឃើញនូវវិញ្ញាណថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញទេ លុះដល់វិញ្ញាណនោះរបស់អរិយសាវ័កនោះ ប្រែប្រួលទៅ ប្លែកទៅ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត រមែងមិនកើតឡើងដល់អរិយសាវ័កនោះ ព្រោះតែវិញ្ញាណប្រែប្រួលទៅ ប្លែកទៅឡើយ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីមិនតក់ស្លុត ព្រោះការមិនប្រកាន់ យ៉ាងនេះឯង ។

[៣៦] ទៀបក្រុងសាវត្ថី ។ កន្លែងនោះឯង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ រូបជាអតីត អនាគត មិនទៀងទៅហើយ ចាំបាច់និយាយថ្វីដល់រូបជាបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័ក ជាអ្នកចេះដឹង កាលបើឃើញយ៉ាងនេះ ជាអ្នកឥតមានអាឡោះអាល័យ ក្នុងរូបជាអតីត មិនត្រេកអរចំពោះរូបជាអនាគត ជាអ្នកប្រតិបត្តិដើម្បីនឿយណាយរំសាយ រំលត់រូបជាបច្ចុប្បន្ន ។ វេទនាមិនទៀង ។ បេ ។ សញ្ញាមិនទៀង ។ បេ ។ សង្ខារជាអតីត អនាគត មិនទៀងទៅហើយ ចាំបាច់

វាទោ បច្ចុប្បន្នានំ ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ អតីតេសុ សង្ខារេសុ អនបេក្ខោ ហោតិ អនាគតេ សង្ខារេ នាភិនន្ទតិ បច្ចុប្បន្នានំ សង្ខារានំ និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតិ ។ វិញ្ញាណំ អនិច្ចំ អតីតានាគតំ កោ បន វាទោ បច្ចុប្បន្នស្ស ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ អតីតស្មឹ វិញ្ញាណស្មឹ អនបេក្ខោ ហោតិ អនាគតំ វិញ្ញាណំ នាភិនន្ទតិ បច្ចុប្បន្នស្ស វិញ្ញាណស្ស និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតីតិ ។

(៣៧) សាវត្ថិយំ ។ តត្រ ខោ ។ បេ ។ រូបំ ភិក្ខវេ ទុក្ខំ អតីតានាគតំ កោ បន វាទោ បច្ចុប្បន្នស្ស ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ អតីតស្មឹ រូបស្មឹ អនបេក្ខោ ហោតិ អនាគតំ រូបំ នាភិនន្ទតិ បច្ចុប្បន្នស្ស រូបស្ស និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតិ ។ វេទនា ទុក្ខា ។ សញ្ញា ទុក្ខា ។ សង្ខារា ទុក្ខា ។ វិញ្ញាណំ ទុក្ខំ អតីតានាគតំ

និយាយថ្មីដល់សង្ខារជាបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័ក ជាអ្នកចេះដឹង កាលបើឃើញយ៉ាងនេះ ជាអ្នកមិនអាឡោះអាល័យក្នុងសង្ខារជាអតីត មិនត្រេកអរចំពោះសង្ខារ ជាអនាគត ប្រតិបត្តិដើម្បីនឿយណាយ រំសាយ រំលត់សង្ខារជាបច្ចុប្បន្ន ។ វិញ្ញាណជាអតីត អនាគត មិនទៀងទៅហើយ ចាំបាច់និយាយថ្មីដល់វិញ្ញាណជាបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័ក ជាអ្នកចេះដឹង កាលបើឃើញយ៉ាងនេះ ជាអ្នកមិនអាឡោះអាល័យក្នុងវិញ្ញាណជាអតីត មិនត្រេកអរចំពោះវិញ្ញាណជាអនាគត ជាអ្នកប្រតិបត្តិដើម្បីនឿយណាយ រំសាយ រំលត់វិញ្ញាណជាបច្ចុប្បន្ន ។

(៣៧) ទៀបក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ រូបជាអតីត និងអនាគត ជាទុក្ខទៅហើយ ចាំបាច់និយាយថ្មីដល់រូបជាបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័ក ជាអ្នកចេះដឹង កាលបើឃើញយ៉ាងនេះ ជាអ្នកមិនអាឡោះអាល័យក្នុងរូបជាអតីត មិនត្រេកអរចំពោះរូបជាអនាគត ជាអ្នកប្រតិបត្តិដើម្បីនឿយ-ណាយ រំសាយ រំលត់រូបជាបច្ចុប្បន្ន ។ វេទនាជាទុក្ខ ។ សញ្ញាជាទុក្ខ ។ សង្ខារជាទុក្ខ ។ វិញ្ញាណជាអតីតនិងអនាគត ជាទុក្ខទៅហើយ

កោ បន វាទោ បច្ចុប្បន្នស្ស ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ អតីតស្មឹ វិញ្ញាណស្មឹ អនបេក្ខោ ហោតិ អនាគតំ វិញ្ញាណំ នាភិនន្ទតិ បច្ចុប្បន្នស្ស វិញ្ញាណស្ស និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតីតិ ។

(៣៨) សាវត្ថិយំ ។ តត្រ ខោ ។ បេ ។ រូបំ ភិក្ខវេ អនត្តា អតីតានាគតំ កោ បន វាទោ បច្ចុប្បន្នស្ស ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ អតីតស្មឹ រូបស្មឹ អនបេក្ខោ ហោតិ អនាគតំ រូបំ នាភិនន្ទតិ បច្ចុប្បន្នស្ស រូបស្ស និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតិ ។ វេទនា អនត្តា ។ សញ្ញា អនត្តា ។ សង្ខារា អនត្តា ។ វិញ្ញាណំ អនត្តា អតីតានាគតំ កោ បន វាទោ បច្ចុប្បន្នស្ស ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ អតីតស្មឹ វិញ្ញាណស្មឹ អនបេក្ខោ ហោតិ អនាគតំ វិញ្ញាណំ នាភិនន្ទតិ

ចាំបាច់និយាយថ្វីដល់វិញ្ញាណជាបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័ក ជាអ្នកចេះដឹង កាលបើឃើញយ៉ាងនេះ ជាអ្នកមិនអាឡោះអាល័យក្នុងវិញ្ញាណ ជាអតីត មិនត្រេកអរចំពោះវិញ្ញាណជាអនាគត ជាអ្នកប្រតិបត្តិដើម្បីនឿយណាយ រំសាយ រំលត់វិញ្ញាណ ជាបច្ចុប្បន្ន ។

[ ៣៨ ] ទៀបក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ រូបជាអតីតនិងអនាគត ជាអនត្តាទៅហើយ ចាំបាច់និយាយថ្វីដល់រូបជាបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវ័កជាអ្នកចេះដឹង ឃើញយ៉ាងនេះ ជាអ្នកមិនអាឡោះអាល័យក្នុងរូបជាអតីត មិនត្រេកអរ ចំពោះរូបជាអនាគត ជាអ្នកប្រតិបត្តិដើម្បីនឿយណាយ រំសាយ រំលត់រូបជាបច្ចុប្បន្ន ។ វេទនាជាអនត្តា ។ សញ្ញាជាអនត្តា ។ សង្ខារជាអនត្តា ។ វិញ្ញាណជាអតីតនិងអនាគត ជាអនត្តាទៅហើយ ចាំបាច់និយាយថ្វីដល់វិញ្ញាណជាបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កជាអ្នកចេះដឹង កាលបើឃើញយ៉ាងនេះ ជាអ្នកមិនអាឡោះអាល័យក្នុងវិញ្ញាណជាអតីត មិនត្រេកអរចំពោះវិញ្ញាណ

បច្ចុប្បន្នស្ស វិញ្ញាណស្ស និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតីតិ ។

នកុលបិតវគ្គោ បឋមោ ។

តស្សុទ្ទានំ

នកុលបិតា ទេវទហា
ទ្វេបិ ហាលិទ្ទិកានិ ច
សមាធិប្បដិសល្លានំ
ឧបាទាបរិតស្សនា ទុវេ
អតីតានាគតប្បច្ចុប្បន្នា
វគ្គោ តេន បវុច្ចតិ ។

ជាអនាគត ជាអ្នកប្រតិបត្តិដើម្បីនឿយណាយ រសាយ រលត់វិញ្ញាណ ជាបច្ចុប្បន្ន ។

ចប់ នកុលបិតវគ្គ ទី ១ ។

## ឧទ្ទាននៃនកុលបិតវគ្គនោះ គឺ

រឿងនកុលបិតាគហបតី ១ រឿងកន្លទេវទហនិគម ១ រឿងហលិទ្ទិកានិគហបតី ២ លើក រឿងសមាធិ ១ រឿងកាយ-វិវេក ១ រឿងសេចក្តីតក់ស្លុតព្រោះសេចក្តីប្រកាន់ ២ លើក រឿងខន្ធជាអតីត ១ អនាគត ១ បច្ចុប្បន្ន ១ ហេតុនោះបានជាហត់ជា ១ វគ្គ ។

# អនិច្ចវគ្គោ

(៣៩) ឯវម្មេ សុតំ ។ សាវត្ថិយំ ។ តត្រ ខោ ។ រូបំ ភិក្ខវេ អនិច្ចំ វេទនា អនិច្ចា សញ្ញា អនិច្ចា សង្ខារា អនិច្ចា វិញ្ញាណំ អនិច្ចំ ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ រូបស្មឹបិ និព្វិន្ទតិ វេទនាយបិ និព្វិន្ទតិ សញ្ញាយបិ និព្វិន្ទតិ សង្ខារេសុបិ និព្វិន្ទតិ វិញ្ញាណស្មឹបិ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ ។ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ។ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

(៤០) សាវត្ថិយំ ។ តត្រ ខោ ។ រូបំ ភិក្ខវេ ទុក្ខំ វេទនា ទុក្ខា សញ្ញា ទុក្ខា សង្ខារា ទុក្ខា

# អនិច្ចវគ្គ

[៣៩] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ ទៀបក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ រូបមិនទៀង វេទនាមិនទៀង សញ្ញាមិនទៀង សង្ខារមិនទៀង វិញ្ញាណមិនទៀង ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវ័កជាអ្នកចេះដឹង ឃើញយ៉ាងនេះ រមែងនឿយណាយនឹងរូបផង នឿយណាយនឹងវេទនាផង នឿយណាយនឹងសញ្ញាផង នឿយណាយនឹងសង្ខារផង នឿយណាយនឹងវិញ្ញាណផង កាលបើនឿយណាយ ក៏រមែងស្អប់ខ្ពើម ព្រោះតែស្អប់ខ្ពើម ទើបចិត្តរួចស្រឡះ (ចាកកិលេស) ។ កាលបើចិត្តរួចស្រឡះហើយ ញាណក៏កើតឡើងថា ចិត្តរួចស្រឡះហើយ ។ អរិយសាវ័កនោះ រមែងដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈអាត្មាអញបាននៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

[៤០] ទៀបក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ រូបជាទុក្ខ វេទនាជាទុក្ខ សញ្ញាជាទុក្ខ សង្ខារជាទុក្ខ

វិញ្ញាណំ ទុក្ខំ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

[៤១] សាវត្ថិយំ ។ តត្រ ខោ ។ រូបំ ភិក្ខវេ អនត្តា វេទនា អនត្តា សញ្ញា អនត្តា សង្ខារា អនត្តា វិញ្ញាណំ អនត្តា ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ រូបស្មឹបិ និព្វិន្ទតិ វេទនាយបិ និព្វិន្ទតិ សញ្ញាយបិ និព្វិន្ទតិ សង្ខារេសុបិ និព្វិន្ទតិ វិញ្ញាណស្មឹបិ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ ។ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ។ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

វិញ្ញាណជាទុក្ខ ។ កាលបើអរិយសាវ័ក ឃើញយ៉ាងនេះ ។ បេ ។ រមែងដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះ ទៀត មិនមានឡើយ ។

( ៤១ ) ទៀបក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ រូបជាអនត្តា វេទនាជាអនត្តា សញ្ញាជាអនត្តា សង្ខារជាអនត្តា វិញ្ញាណជាអនត្តា ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវ័កជាអ្នកចេះដឹងឃើញយ៉ាងនេះ រមែងនឿយណាយនឹងរូបផង នឿយណាយនឹងវេទនាផង នឿយណាយនឹងសញ្ញាផង នឿយណាយនឹងសង្ខារផង នឿយណាយនឹងវិញ្ញាណផង កាលបើនឿយណាយ ក៏រមែងស្អប់ខ្ពើម ព្រោះតែស្អប់ខ្ពើម ទើបចិត្តរួចស្រឡះ ។ កាលបើចិត្តផុតស្រឡះហើយ ញាណ រមែងកើតឡើងថា ចិត្តរួចស្រឡះហើយ ។ រមែងដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈអាត្មាអញបាននៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

[៤២] សាវត្ថិយំ ។ តត្រ ខោ ។ រូបំ ភិក្ខវេ អនិច្ចំ យទនិច្ចំ តំ ទុក្ខំ យំ ទុក្ខំ តទនត្តា យទនត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ វេទនា អនិច្ចា យទនិច្ចំ តំ ទុក្ខំ យំ ទុក្ខំ តទនត្តា យទនត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ សញ្ញា អនិច្ចា ។ បេ ។ សង្ខារា អនិច្ចា ។ បេ ។ វិញ្ញាណំ អនិច្ចំ យទនិច្ចំ តំ ទុក្ខំ យំ ទុក្ខំ តទនត្តា យទនត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

[៥២] ទៀបក្រុងសាវត្ថី ។ គង់ទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ រូបមិនទៀង របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ របស់នោះជាអនត្តា របស់ណាជាអនត្តា របស់នោះបណ្ឌិតត្រូវយល់តាមសេចក្តីពិត ដោយប្រាជ្ញាដ៏ប្រពៃ យ៉ាងនេះថា នុ៎ះមិនមែនរបស់អញទេ នុ៎ះមិនមែនជាអញទេ នុ៎ះមិនមែនជាខ្លួនអញទេ ។ វេទនាមិនទៀង របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ របស់នោះជាអនត្តា របស់ណា ជាអនត្តា របស់នោះបណ្ឌិតត្រូវយល់តាមសេចក្តីពិត ដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនរបស់អញទេ នុ៎ះមិនមែនជាអញទេ នុ៎ះមិនមែនជាខ្លួនអញទេ ។ សញ្ញាមិនទៀង ។ បេ ។ សង្ខារមិនទៀង ។ បេ ។ វិញ្ញាណមិនទៀង របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ របស់នោះជាអនត្តា របស់ណាជាអនត្តា របស់នោះបណ្ឌិតត្រូវយល់តាមសេចក្តីពិត ដោយប្រាជ្ញាដ៏ប្រពៃ យ៉ាងនេះថា នុ៎ះមិនមែនរបស់អញទេ នុ៎ះមិនមែនជាអញទេ នុ៎ះមិនមែនជាខ្លួនអញទេ ។ កាលបើឃើញយ៉ាងនេះ ។ បេ ។ ក៏ដឹងច្បាស់ថា មគ្គ-ភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

(៤៣) សាវត្ថិយំ ។ តត្រ ខោ ។ រូបំ ភិក្ខវេ ទុក្ខំ យំ ទុក្ខំ តទនត្តា យទនត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ វេទនា ទុក្ខា ។ សញ្ញា ទុក្ខា ។ សង្ខារា ទុក្ខា ។ វិញ្ញាណំ ទុក្ខំ យំ ទុក្ខំ តទនត្តា យទនត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

(៤៤) សាវត្ថិយំ ។ តត្រ ខោ ។ រូបំ ភិក្ខវេ អនត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ បេ ។ ឯវំ បស្សំ ភិក្ខវេ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

(៩៣) ទៀបក្រុងសាវត្ថី ។ កន្លែងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ រូបជាទុក្ខ របស់ណាជាទុក្ខ របស់នោះជាអនត្តា របស់ណាជាអនត្តា របស់នោះបណ្ឌិតត្រូវយល់តាមសេចក្តីពិត ដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនរបស់អញទេ នុ៎ះមិនមែនជាអញទេ នុ៎ះមិនមែនជាខ្លួនអញទេ ។ វេទនាជាទុក្ខ ។ សញ្ញាជាទុក្ខ ។ សង្ខារជាទុក្ខ ។ វិញ្ញាណជាទុក្ខ របស់ណាជាទុក្ខ របស់នោះជាអនត្តា របស់ណាជាអនត្តា របស់នោះបណ្ឌិតត្រូវយល់តាមសេចក្តីពិត ដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនរបស់អញទេ នុ៎ះមិនមែនជាអញទេ នុ៎ះមិនមែនជាខ្លួនអញទេ ។ កាលបើឃើញយ៉ាងនេះ ។ បេ ។ ក៏ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

(៩៤) ទៀបក្រុងសាវត្ថី ។ កន្លែងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ រូបជាអនត្តា (ឥតខ្លឹមសារ) រូបនោះបណ្ឌិតត្រូវយល់តាមសេចក្តីពិត ដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនរបស់អញទេ នុ៎ះមិនមែនជាអញទេ នុ៎ះមិនមែនជាខ្លួនអញទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ កាលបើឃើញយ៉ាងនេះ ។ បេ ។ ក៏ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

(៤៥) សាវត្ថិយំ ។ តត្រ ខោ ។ រូបំ ភិក្ខវេ អនិច្ចំ យោបិ ហេតុ យោបិ បច្ចយោ រូបស្ស ឧប្បាទាយ សោបិ អនិច្ចោ ។ អនិច្ចសម្ភូតំ ភិក្ខវេ រូបំ កុតោ និច្ចំ ភវិស្សតិ ។ វេទនា អនិច្ចា យោបិ ហេតុ យោបិ បច្ចយោ វេទនាយ ឧប្បាទាយ សោបិ អនិច្ចោ ។ អនិច្ចសម្ភូតា ភិក្ខវេ វេទនា កុតោ និច្ចា ភវិស្សតិ ។ សញ្ញា អនិច្ចា ។ សង្ខារា អនិច្ចា យោបិ ហេតុ យោបិ បច្ចយោ សង្ខារានំ ឧប្បាទាយ សោបិ អនិច្ចោ ។ អនិច្ចសម្ភូតា ភិក្ខវេ សង្ខារា កុតោ និច្ចា ភវិស្សន្តិ ។ វិញ្ញាណំ អនិច្ចំ យោបិ ហេតុ យោបិ បច្ចយោ វិញ្ញាណស្ស ឧប្បាទាយ សោបិ អនិច្ចោ ។ អនិច្ចសម្ភូតំ ភិក្ខវេ វិញ្ញាណំ កុតោ និច្ចំ ភវិស្សតិ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

(៤៥) ទៀបក្រុងសាវត្ថី ។ គង់ទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ រូបមិនទៀង ហេតុណាក្តី បច្ច័យណាក្តី ដែលនាំរូបឲ្យកើតឡើង ហេតុប្បច្ច័យនោះក៏មិនទៀងដែរ ។ ម្នាលភិក្ខុទាំងឡាយ រូបដែលកើតអំពីហេតុប្បច្ច័យ មិនទៀងទៅហើយ តើនឹងបានទៀងទាត់មកពីណា ។ វេទនាមិនទៀង ហេតុណាក្តី បច្ច័យណាក្តី ដែលនាំឲ្យវេទនាកើតឡើង ហេតុប្បច្ច័យនោះក៏មិនទៀងដែរ ។ ម្នាលភិក្ខុទាំងឡាយ វេទនាដែលកើតអំពីហេតុប្បច្ច័យមិនទៀងទៅហើយ តើនឹងបានទៀងទាត់មកពីណា ។ សញ្ញាមិនទៀង ។ សង្ខារមិនទៀង ហេតុណាក្តី បច្ច័យណាក្តី ដែលនាំឲ្យសង្ខារកើតឡើង ហេតុប្បច្ច័យនោះក៏មិនទៀងដែរ ។ ម្នាលភិក្ខុទាំងឡាយ សង្ខារដែលកើតអំពីហេតុប្បច្ច័យមិនទៀងហើយ តើនឹងបានទៀងទាត់មកពីណា ។ វិញ្ញាណមិនទៀង ហេតុណាក្តី បច្ច័យណាក្តី ដែលនាំឲ្យវិញ្ញាណកើតឡើង ហេតុប្បច្ច័យនោះក៏មិនទៀងដែរ ។ ម្នាលភិក្ខុទាំងឡាយ វិញ្ញាណកើតអំពីហេតុប្បច្ច័យមិនទៀងទៅហើយ តើនឹងបានទៀងទាត់មកពីណា ។ កាលបើឃើញយ៉ាងនេះ ។ បេ ។ ក៏ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

(៤៦) សាវត្ថិយំ ។ តត្រ ខោ ។ រូបំ ភិក្ខវេ ទុក្ខំ យោបិ ហេតុ យោបិ បច្ចយោ រូបស្ស ឧប្បាទាយ សោបិ ទុក្ខោ ។ ទុក្ខសម្ភូតំ ភិក្ខវេ រូបំ កុតោ សុខំ ភវិស្សតិ វេទនា ទុក្ខា សញ្ញា ទុក្ខា ។ សង្ខារា ទុក្ខា ។ វិញ្ញាណំ ទុក្ខំ យោបិ ហេតុ យោបិ បច្ចយោ វិញ្ញាណស្ស ឧប្បាទាយ សោបិ ទុក្ខោ ។ ទុក្ខសម្ភូតំ ភិក្ខវេ វិញ្ញាណំ កុតោ សុខំ ភវិស្សតិ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

(៤៧) សាវត្ថិយំ ។ តត្រ ខោ ។ រូបំ ភិក្ខវេ អនត្តា យោបិ ហេតុ យោបិ បច្ចយោ រូបស្ស ឧប្បាទាយ សោបិ អនត្តា ។ អនត្តសម្ភូតំ ភិក្ខវេ រូបំ កុតោ អត្តា ភវិស្សតិ ។ វេទនា អនត្តា ។ សញ្ញា អនត្តា ។ សង្ខារា

(៤៦) ទៀបក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ រូបជាទុក្ខ ហេតុណាក្តី បច្ច័យណាក្តី ដែលនាំឲ្យរូបកើតឡើង ហេតុប្បច្ច័យនោះក៏ជាទុក្ខដែរ ។ ម្នាលភិក្ខុទាំងឡាយ រូបដែលកើតអំពីហេតុប្បច្ច័យជាទុក្ខ តើនឹងបានសុខមកពីណា ។ វេទនាជាទុក្ខ ។ សញ្ញាជាទុក្ខ ។ សង្ខារជាទុក្ខ ។ វិញ្ញាណជាទុក្ខ ហេតុណាក្តី បច្ច័យណាក្តី ដែលនាំឲ្យវិញ្ញាណ កើតឡើង ហេតុប្បច្ច័យនោះក៏ជាទុក្ខដែរ ។ ម្នាលភិក្ខុទាំងឡាយ វិញ្ញាណដែលកើតអំពីហេតុប្បច្ច័យជាទុក្ខ តើនឹងបានសុខមកពីណា ។ កាលបើឃើញយ៉ាងនេះ ។ បេ ។ រមែងដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃ ដែលប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

(៤៧) ទៀបក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ រូបជាអនត្តា ហេតុណាក្តី បច្ច័យណាក្តី ដែលនាំឲ្យរូបកើតឡើង ហេតុប្បច្ច័យនោះក៏ជាអនត្តាដែរ ។ ម្នាលភិក្ខុទាំងឡាយ រូបដែលកើតអំពីហេតុប្បច្ច័យជាអនត្តា តើនឹងបានជាអត្តា (មានខ្លឹមសារ) មកពីណា ។ វេទនាជាអនត្តា ។ សញ្ញាជាអនត្តា ។ សង្ខារ

អនត្តា ។ វិញ្ញាណំ អនត្តា យោបិ ហេតុ យោបិ បច្ចយោ វិញ្ញាណស្ស ឧប្បាទាយ សោបិ អនត្តា ។ អនត្តសម្ភូតំ ភិក្ខវេ វិញ្ញាណំ កុតោ អត្តា ភវិស្សតិ ។ ឯវំ បស្សំ ។បេ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

(៤៨) សាវត្ថិយំ ។ អារាមេ ។ អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច និរោធោ និរោធោតិ ភន្តេ វុច្ចតិ កតមេសានំ ខោ ភន្តេ ធម្មានំ និរោធោ និរោធោតិ វុច្ចតីតិ ។ រូបំ ខោ អានន្ទ អនិច្ចំ សង្ខតំ បដិច្ចសមុប្បន្នំ ខយធម្មំ វយធម្មំ វិរាគធម្មំ និរោធធម្មំ តស្ស និរោធោ និរោធោតិ វុច្ចតិ ។ វេទនា អនិច្ចា សង្ខតា បដិច្ចសមុប្បន្នា

ជាអនត្តា ៗ វិញ្ញាណ ជាអនត្តា ហេតុណាក្តី បច្ច័យណាក្តី ដែលនាំឲ្យវិញ្ញាណកើតឡើង ហេតុប្បច្ច័យនោះ ក៏ជាអនត្តាដែរ ៗ ម្នាលភិក្ខុទាំងឡាយ វិញ្ញាណដែលកើតអំពីហេតុប្បច្ច័យ ជាអនត្តា តើនឹងបានជាអនត្តាមកពីណា ៗ កាលបើឃើញយ៉ាងនេះ ៗ បេ ៗ ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃ ដែលប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ៗ

(៤៨) ទៀបក្រុងសាវត្ថី ៗ ក្នុងវត្ត ៗ គ្រានោះឯង ព្រះអានន្ទ មានអាយុ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ៗ លុះព្រះអានន្ទមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យដែលហៅថា សេចក្តីរលត់ ៗ បពិត្រព្រះអង្គដ៏ចម្រើន តើសេចក្តីរលត់ធម៌ណា បានជាហៅថារលត់ ៗ ម្នាលអានន្ទ រូបមិនទៀង ជារបស់ដែលបច្ច័យតាក់តែងហើយ ដែលកើតឡើង ព្រោះអាស្រ័យហេតុប្បច្ច័យ មានកិរិយាអស់ទៅ សូន្យទៅ ប្រាសទៅ រលត់ទៅ ជាធម្មតា សេចក្តីរលត់នៃរូបនោះ ហៅថារលត់ ៗ វេទនាមិនទៀង ជាធម្មជាតិដែលបច្ច័យតាក់តែងហើយ ដែលកើតឡើង ព្រោះអាស្រ័យហេតុប្បច្ច័យ

ខយធម្មា វយធម្មា វិរាគធម្មា និរោធធម្មា តស្មា និរោធោ និរោធោតិ វុច្ចតិ ។ សញ្ញា អនិច្ចា ។ សង្ខារា អនិច្ចា សង្ខតា បដិច្ចសមុប្បន្នា ខយធម្មា វយធម្មា វិរាគធម្មា និរោធធម្មា តេសំ និរោធោ និរោធោតិ វុច្ចតិ ។ វិញ្ញាណំ អនិច្ចំ សង្ខតំ បដិច្ចសមុប្បន្នំ ខយធម្មំ វយធម្មំ វិរាគធម្មំ និរោធធម្មំ តស្ស និរោធោ និរោធោតិ វុច្ចតិ ។ ឥមេសំ ខោ អានន្ទ ធម្មានំ និរោធោ និរោធោតិ វុច្ចតីតិ ។

អនិច្ចវគ្គោ ទុតិយោ ។

## តស្សុទ្ទានំ

អនិច្ចំ ទុក្ខំ អនត្តា
យទនិច្ចាបរេ តយោ
ហេតុនាបិ តយោ វុត្តា
អានន្ទេន ច តេ នវាតិ ។

មានកិរិយាអស់ទៅ សូន្យទៅ ប្រាសទៅ រលត់ទៅ ជាធម្មតា សេចក្តីរលត់នៃវេទនានោះ ហៅថារលត់ ។ សញ្ញាមិនទៀង ។ សង្ខារមិនទៀង ជាសភាវៈដែលបច្ច័យតាក់តែងហើយ ដែលកើតឡើង ព្រោះអាស្រ័យហេតុប្បច្ច័យ មានកិរិយាអស់ទៅ សូន្យទៅ ប្រាសទៅ រលត់ទៅ ជាធម្មតា សេចក្តីរលត់នៃសង្ខារទាំងនោះ ហៅថារលត់ ។ វិញ្ញាណមិនទៀង ជាធម្មជាតដែលបច្ច័យតាក់តែងហើយ ដែលកើតឡើង ព្រោះអាស្រ័យហេតុប្បច្ច័យ មានកិរិយាអស់ទៅ សូន្យទៅ ប្រាសទៅ រលត់ទៅ ជាធម្មតា សេចក្តីរលត់នៃវិញ្ញាណនោះ ហៅថារលត់ ។ ម្នាលអានន្ទ សេចក្តីរលត់នៃធម៌ទាំងនេះឯង ហៅថារលត់ ។

ចប់ អនិច្ចវគ្គ ទី ២ ។

## ឧទ្ទានក្នុងអនិច្ចវគ្គនោះ គឺ

ខន្ធមិនទៀង ១ ជាទុក្ខ ១ ជាអនត្តា ១ និងខន្ធមិនទៀងដទៃទៀត ៣ និងខន្ធ ៣ ទ្រង់ត្រាស់ដោយហេតុផង ជាគំរប់ ១០ នឹងរឿងព្រះអានន្ទ ។

## ភារវគ្គោ

(៤៩) សាវត្ថិយំ ។ តត្រ ខោ ។ ភារញ្ច វោ ភិក្ខវេ ទេសិស្សាមិ ភារហារញ្ច ភារាទានញ្ច ភារនិក្ខេបនញ្ច តំ សុណាថ ។ បេ ។ ឯតទវោច កតមោ ច ភិក្ខវេ ភារោ ។ បញ្ចុបាទានក្ខន្ធាតិស្ស វចនីយំ ។ កតមេ បញ្ច ។ (១)រូបុបាទានក្ខន្ធោ វេទនុបាទានក្ខន្ធោ សញ្ញុបាទានក្ខន្ធោ សង្ខារុបាទានក្ខន្ធោ វិញ្ញាណុបាទានក្ខន្ធោ ។ អយំ វុច្ចតិ ភិក្ខវេ ភារោ ។

(៥០) កតមោ ច ភិក្ខវេ ភារហារោ ។ បុគ្គលោតិស្ស វចនីយំ ។ ស្វាយំ អាយស្មា ឯវំនាមោ ឯវំគោត្តោ ។ អយំ វុច្ចតិ ភិក្ខវេ ភារហារោ ។

---

១ កត្ថចិ បោត្ថកេ សេយ្យថីទំ ។

# ភារវគ្គ

[៤៩] ក្នុងក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវភារៈ(១)ផង នូវអ្នកដែលនាំភារៈផង នូវការប្រកាន់មាំនូវភារៈផង នូវការដាក់ចុះនូវភារៈផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះចុះ ។ បេ ។ ទើបមានព្រះបន្ទូលសួរដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេច ឈ្មោះថាភារៈ ។ គប្បីឆ្លើយថា ឧបាទានក្ខន្ធទាំង ៥ ។ ចុះឧបាទានក្ខន្ធទាំង ៥ តើដូចម្តេចខ្លះ ។ គឺរូបូបាទានក្ខន្ធ ១ វេទនូបាទានក្ខន្ធ ១ សញ្ញូបាទានក្ខន្ធ ១ សង្ខារូបាទានក្ខន្ធ ១ វិញ្ញាណូបាទានក្ខន្ធ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាភារៈ ។

[៥០] ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេច ឈ្មោះថាអ្នកនាំនូវភារៈ ។ គប្បីឆ្លើយថា បុគ្គល ។ គឺអ្នកមានអាយុនោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ នេះឈ្មោះថាអ្នកនាំនូវភារៈ ។

---

១ ប្រែថា ធ្ងន់ គឺលំបាកនឹងរក្សា មានឲ្យដើរ អង្គុយ ដេក ផ្ងូត ប្រដាប់ ស៊ី ផឹក ជាដើម (អដ្ឋកថា) ។

(៩១) កតមញ្ច ភិក្ខវេ ភារាទានំ ។ យាយំ តណ្ហា បោនោព្ភវិកា នន្ទិរាគសហគតា តត្រតត្រាភិនន្ទិនី ។ សេយ្យថីទំ ។ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា ។ ឥទំ វុច្ចតិ ភិក្ខវេ ភារាទានំ ។

(៩២) កតមញ្ច ភិក្ខវេ ភារនិក្ខេបនំ ។ យោ តស្សាយេវ តណ្ហាយ អសេសវិរាគនិរោធោ ចាគោ បដិនិស្សគ្គោ មុត្តិ អនាលយោ ។ ឥទំ វុច្ចតិ ភិក្ខវេ ភារនិក្ខេបនន្តិ ។ ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា

(៥១) ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេច ឈ្មោះថាការប្រកាន់មាំនូវភារៈ ។ តណ្ហាដែលនាំឲ្យកើតក្នុងភពថ្មី ប្រកបដោយតម្រេក ដោយអំណាចនៃសេចក្តីត្រេកត្រអាល មានកិរិយារីករាយក្នុងអារម្មណ៍នោះ ៗ ជាប្រក្រតី ។ តណ្ហានោះ ដូចម្តេចខ្លះ ។ គឺកាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាការប្រកាន់មាំនូវភារៈ ។

(៥២) ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេច ឈ្មោះថាការដាក់ចុះនូវភារៈ ។ សេចក្តីវិនាសនៃសេចក្តីរលត់ មិនមានសេសសល់ កិរិយាលះបង់ កិរិយាលោសចោល កិរិយារួចស្រឡះ ការមិនមានអាល័យក្នុងតណ្ហានោះ ឯណា ម្នាលភិក្ខុទាំងឡាយ នេះ ហៅថាការដាក់ចុះនូវភារៈ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់នូវព្រះពុទ្ធដីកានេះហើយ លុះព្រះសុគត ត្រាស់នូវព្រះពុទ្ធដីកានេះរួចហើយ បន្ទាប់ពីនោះមក ព្រះសាស្តាទ្រង់ត្រាស់នូវព្រះគាថានេះថា

(៨៣) ភារា ហវេ បញ្ចក្ខន្ធា
ភារហារោ ច បុគ្គលោ
ភារាទានំ ទុក្ខំ លោកេ
ភារនិក្ខេបនំ សុខំ
និក្ខិបិត្វា គរុំ ភារំ
អញ្ញំ ភារំ អនាទិយ
សមូលំ តណ្ហំ អព្ពុយ្ហ
និច្ឆាតោ បរិនិព្វុតោតិ ។

(៨៤) សាវត្ថិយំ ។ តត្រ ខោ ។ បរិញ្ញេយ្យេ ច ភិក្ខវេ ធម្មេ ទេសេស្សាមិ បរិញ្ញញ្ច តំ សុណាថ ។ កតមេ ច ភិក្ខវេ បរិញ្ញេយ្យា ធម្មា ។ រូបំ ភិក្ខវេ បរិញ្ញេយ្យោ ធម្មោ វេទនា បរិញ្ញេយ្យោ ធម្មោ សញ្ញា បរិញ្ញេយ្យោ ធម្មោ សង្ខារា បរិញ្ញេយ្យោ ធម្មោ វិញ្ញាណំ បរិញ្ញេយ្យោ ធម្មោ ។ ឥមេ វុច្ចន្តិ ភិក្ខវេ បរិញ្ញេយ្យា ធម្មា ។

[៤៣] បញ្ចក្ខន្ធជារបស់ធ្ងន់ដោយពិត បុគ្គលអ្នកនាំនូវភារៈគឺបញ្ចក្ខន្ធក្តី ការប្រកាន់យកនូវភារៈគឺបញ្ចក្ខន្ធក្តី តែងនាំមកនូវទុក្ខក្នុងលោក ការដាក់ចុះនូវភារៈជាហេតុនាំមកនូវសុខ លុះតែបុគ្គលដាក់ចុះនូវភារៈដ៏ធ្ងន់គឺបញ្ចក្ខន្ធចេញ មិនក្តោបកាន់នូវភារៈដទៃទៀត បានដកឡើងនូវតណ្ហាព្រមទាំងឫស ទើបជាអ្នកមិនមានសេចក្តីប្រាថ្នា ហើយបរិនិព្វាន ។

[៤៤] ក្នុងក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែង នូវធម៌ដែលត្រូវកំណត់ដឹងផង នូវកិរិយាកំណត់ដឹងផង អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថាធម៌ដែលត្រូវកំណត់ដឹង ។ ម្នាលភិក្ខុទាំងឡាយ រូបជាធម៌ដែលត្រូវកំណត់ដឹង វេទនាជាធម៌ដែលត្រូវកំណត់ដឹង សញ្ញាជាធម៌ដែលត្រូវកំណត់ដឹង សង្ខារជាធម៌ដែលត្រូវកំណត់ដឹង វិញ្ញាណជាធម៌ដែលត្រូវកំណត់ដឹង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាធម៌ដែលត្រូវកំណត់ដឹង ។

[៥៥] កតមា ច ភិក្ខវេ បរិញ្ញា ។ យោ ភិក្ខវេ រាគក្ខយោ ទោសក្ខយោ មោហក្ខយោ ។ អយំ វុច្ចតិ ភិក្ខវេ បរិញ្ញាតិ ។

[៥៦] សាវត្ថិយំ ។ តត្រ ខោ ។ រូបំ ភិក្ខវេ អនភិជានំ អបរិជានំ អវិរាជយំ អប្បជហំ អភព្វោ ទុក្ខក្ខយាយ វេទនំ អនភិជានំ អបរិជានំ អវិរាជយំ អប្បជហំ អភព្វោ ទុក្ខក្ខយាយ សញ្ញំ អនភិជានំ ។ បេ ។ សង្ខារេ អនភិជានំ អបរិជានំ អវិរាជយំ អប្បជហំ អភព្វោ ទុក្ខក្ខយាយ វិញ្ញាណំ អនភិជានំ អបរិជានំ អវិរាជយំ អប្បជហំ អភព្វោ ទុក្ខក្ខយាយ ។

[៥៥] ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថាការកំណត់ដឹង ។ ម្នាលភិក្ខុទាំងឡាយ កិរិយាអស់រាគៈ កិរិយាអស់ទោសៈ កិរិយាអស់មោហៈណា ម្នាលភិក្ខុទាំងឡាយ នេះហៅថាការកំណត់ដឹង ។

[៥៦] គង់ក្រុងសាវត្ថី ។ គង់ទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនដឹងច្បាស់ មិនកំណត់ដឹង មិននឿយណាយ មិនលះបង់នូវរូប មិនគួរដើម្បីអស់ទុក្ខបានទេ បុគ្គលកាលមិនដឹងច្បាស់ មិនកំណត់ដឹង មិននឿយណាយ មិនលះបង់នូវវេទនា មិនគួរដើម្បីអស់ទុក្ខបានទេ បុគ្គលកាលមិនដឹងច្បាស់ ។ បេ ។ នូវសញ្ញា បុគ្គលកាលមិនដឹងច្បាស់ មិនកំណត់ដឹង មិននឿយណាយ មិនលះបង់នូវសង្ខារ មិនគួរដើម្បីអស់ទុក្ខបានទេ បុគ្គលកាលមិនដឹងច្បាស់ មិនកំណត់ដឹង មិននឿយណាយ មិនលះបង់នូវវិញ្ញាណ មិនគួរដើម្បីអស់ទុក្ខបានទេ ។

[៨៧] រូបញ្ច ខោ ភិក្ខវេ អភិជានំ បរិជានំ វិរាជ-
យំ បជហំ ភព្វោ ទុក្ខក្ខយាយ ។ វេទនំ អភិជានំ ។
សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ អភិជានំ បរិជានំ វិរាជ-
យំ បជហំ ភព្វោ ទុក្ខក្ខយាយាតិ ។

[៨៨] សាវត្ថិយំ ។ តត្រ ខោ ។ យោ ភិក្ខវេ
រូបស្មឹ ឆន្ទរាគោ តំ បជហថ ឯវំ តំ រូបំ បហីនំ
ភវិស្សតិ ឧច្ឆិន្នមូលំ តាលាវត្ថុកតំ អនភាវង្កតំ អា-
យតឹ អនុប្បាទធម្មំ ។ យោ វេទនាយ ឆន្ទរាគោ តំ
បជហថ ឯវំ សា វេទនា បហីនា ភវិស្សតិ ឧច្ឆិន្ន-
មូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ អនុប្បា-
ទធម្មា ។ យោ សញ្ញាយ ឆន្ទរាគោ តំ បជហថ ឯវំ
សា សញ្ញា បហីនា ភវិស្សតិ ឧច្ឆិន្នមូលា តាលាវត្ថុ-

(៩៧) ម្នាលភិក្ខុទាំងឡាយ លុះតែបុគ្គលដឹងច្បាស់ កំណត់ដឹង នឿយណាយ លះបង់ នូវរូប ទើបគួរដើម្បីអស់ទុក្ខបាន ។ បុគ្គលកាលដឹងច្បាស់នូវវេទនា ។ នូវសញ្ញា ។ នូវសង្ខារ ។ លុះតែបុគ្គលដឹងច្បាស់ កំណត់ដឹង នឿយណាយ លះបង់ នូវវិញ្ញាណ ទើបគួរដើម្បីអស់ទុក្ខបាន ។

(៩៨) កើតក្រុងសាវត្ថី ។ កើតទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ឆន្ទរាគណា មានក្នុងរូប អ្នកទាំងឡាយចូរលះបង់នូវឆន្ទរាគនោះចេញ កាលបើយ៉ាងនេះ រូបនោះឯង នឹងឈ្មោះថាអ្នកទាំងឡាយបានលះបង់ រំលើងឫសគល់ ធ្វើមិនឲ្យមានទីកើតដូចជាត្នោតកំបុតក ធ្វើឲ្យតាំងនៅមិនបាន មិនឲ្យកើតឡើងតទៅទៀតជាធម្មតា ។ ឆន្ទរាគណា មានក្នុងវេទនា អ្នកទាំងឡាយចូរលះបង់នូវឆន្ទរាគនោះចេញ កាលបើយ៉ាងនេះ វេទនានោះឯង នឹងឈ្មោះថាអ្នកទាំងឡាយបានលះបង់ រំលើងឫសគល់ ធ្វើមិនឲ្យមានទីកើតដូចជាត្នោតកំបុតក ធ្វើឲ្យតាំងនៅមិនបាន មិនឲ្យកើតឡើងតទៅទៀតជាធម្មតា ។ ឆន្ទរាគណា មានក្នុងសញ្ញា អ្នកទាំង-ឡាយចូរលះបង់នូវឆន្ទរាគនោះចេញ កាលបើយ៉ាងនេះ សញ្ញានោះឯង នឹងឈ្មោះថាអ្នកទាំងឡាយបានលះបង់ រំលើងឫសគល់ ធ្វើមិនឲ្យមាន

កតា អនភាវង្កតា អាយតឹ អនុប្បាទធម្មា ។ យោ សង្ខារេសុ ឆន្ទរាគោ តំ បជហថ ឯវំ តេ សង្ខារា បហីនា ភវិស្សន្តិ ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ អនុប្បាទធម្មា ។ យោ វិញ្ញាណស្មឹ ឆន្ទរាគោ តំ បជហថ ឯវំ តំ វិញ្ញាណំ បហីនំ ភវិស្សតិ ឧច្ឆិន្នមូលំ តាលាវត្ថុកតំ អនភាវង្កតំ អាយតឹ អនុប្បាទធម្មន្តិ ។

(៥៩) សាវត្ថិយំ ។ តត្រ ខោ ។ បុព្វេវ មេ ភិក្ខវេ សម្ពោធា អនភិសម្ពុទ្ធស្ស ពោធិសត្តស្សេវ សតោ ឯតទហោសិ កោ នុ ខោ រូបស្ស អស្សាទោ កោ អាទីនវោ កឹ និស្សរណំ ។ កោ វេទនាយ អស្សាទោ កោ អាទីនវោ កឹ និស្សរណំ ។ កោ សញ្ញាយ អស្សាទោ កោ អាទីនវោ កឹ និស្សរណំ ។ កោ សង្ខារានំ អស្សាទោ កោ អាទីនវោ កឹ និស្សរណំ ។ កោ វិញ្ញាណស្ស អស្សាទោ កោ អាទីនវោ កឹ និស្សរណន្តិ ។ តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ

ទីកើតដូចជាត្នោតកំបុតក ធ្វើឲ្យតាំងនៅមិនបាន មិនឲ្យកើតឡើងតទៅទៀតជាធម្មតា ។ ឆន្ទរាគណា មានក្នុងសង្ខារ អ្នកទាំងឡាយចូរលះបង់នូវឆន្ទរាគនោះចេញ កាលបើយ៉ាងនេះ សង្ខារទាំងនោះឯង ទឹងឈ្មោះថាអ្នកទាំងឡាយបានលះបង់ រំលើងឫសគល់ ធ្វើមិនឲ្យមានទីកើតដូចជាត្នោតកំបុតក ធ្វើឲ្យតាំងនៅមិនបាន មិនឲ្យកើតឡើងតទៅទៀតជាធម្មតា ។ ឆន្ទរាគណា មានក្នុងវិញ្ញាណ អ្នកទាំងឡាយចូរលះបង់នូវឆន្ទរាគនោះចេញ កាលបើយ៉ាងនេះ វិញ្ញាណនោះឯង ទឹងឈ្មោះថាអ្នកទាំងឡាយបានលះបង់ រំលើងឫសគល់ ធ្វើមិនឲ្យមានទីកើតដូចជាត្នោតកំបុតក ធ្វើឲ្យតាំងនៅមិនបាន មិនឲ្យកើតឡើងតទៅទៀតជាធម្មតា ។

(៤៩) ក្នុងក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ កាលតថាគតនៅជាពោធិសត្វមិនទាន់ត្រាស់ដឹង មុនអំពីសម្ពោធិញាណនៅឡើយ មានសេចក្តីត្រិះរិះដូច្នេះថា អ្វីហ្ន៎ជាអានិសង្ស អ្វីជាទោស អ្វីជាការរលាស់ចេញ នៃរូប ។ អ្វីជាអានិសង្ស អ្វីជាទោស អ្វីជាការរលាស់ចេញ នៃវេទនា ។ អ្វីជាអានិសង្ស អ្វីជាទោស អ្វីជាការរលាស់ចេញ នៃសញ្ញា ។ អ្វីជាអានិសង្ស អ្វីជាទោស អ្វីជាការរលាស់ចេញ នៃសង្ខារ ។ អ្វីជាអានិសង្ស អ្វីជាទោស អ្វីជាការរលាស់ចេញ នៃវិញ្ញាណ ។ ម្នាលភិក្ខុទាំងឡាយ តថាគតមានសេចក្តីត្រិះរិះ

យំ ខោ រូបំ បដិច្ច ឧប្បជ្ជតិ សុខំ សោមនស្សំ អយំ
រូបស្ស អស្សាទោ យំ រូបំ អនិច្ចំ ទុក្ខំ វិបរិណា-
មធម្មំ អយំ រូបស្ស អាទីនវោ យោ រូបស្មឹ ឆន្ទរាគវិ-
នយោ ឆន្ទរាគប្បហានំ ឥទំ រូបស្ស និស្សរណំ ។
យំ វេទនំ បដិច្ច ឧប្បជ្ជតិ សុខំ សោមនស្សំ អយំ វេ-
ទនាយ អស្សាទោ យា វេទនា អនិច្ចា ទុក្ខា វិបរិណា-
មធម្មា អយំ វេទនាយ អាទីនវោ យោ វេទនាយ
ឆន្ទរាគវិនយោ ឆន្ទរាគប្បហានំ ឥទំ វេទនាយ និស្សរ-
ណំ ។ យំ សញ្ញំ បដិច្ច ឧប្បជ្ជតិ ។ យំ សង្ខារេ
បដិច្ច ឧប្បជ្ជតិ សុខំ សោមនស្សំ អយំ សង្ខារានំ
អស្សាទោ យេ សង្ខារា អនិច្ចា ទុក្ខា វិបរិណាមធម្មា
អយំ សង្ខារានំ អាទីនវោ យោ សង្ខារេសុ ឆន្ទរាគវិ-
នយោ ឆន្ទរាគប្បហានំ ឥទំ សង្ខារានំ និស្សរណំ ។
យំ វិញ្ញាណំ បដិច្ច ឧប្បជ្ជតិ សុខំ សោមនស្សំ

ដូច្នេះថា សេចក្ដីសុខ សោមនស្សណា កើតឡើងព្រោះអាស្រ័យរូប នេះជាអានិសង្សរបស់រូប រូបណា មិនទៀង ជាទុក្ខ មានកិរិយាប្រែប្រួលជាធម្មតា នេះជាទោសរបស់រូប ការបន្ទោបង់នូវឆន្ទរាគ ការលះបង់នូវឆន្ទរាគណា ក្នុងរូប នេះជាការរលាស់ចេញ នូវរូប ៗ សេចក្ដីសុខ សោមនស្សណា កើតឡើងព្រោះអាស្រ័យវេទនា នេះជាអានិសង្សរបស់វេទនា វេទនាណា មិនទៀង ជាទុក្ខ មានកិរិយាប្រែ-ប្រួលជាធម្មតា នេះជាទោសរបស់វេទនា ការបន្ទោបង់នូវឆន្ទរាគ ការលះបង់នូវឆន្ទរាគណា ក្នុងវេទនា នេះជាការរលាស់ចេញនូវវេទនា ៗ សេចក្ដីសុខ សោមនស្សណា កើតឡើងព្រោះអាស្រ័យសញ្ញា ៗ សេចក្ដីសុខ សោមនស្សណា កើតឡើងព្រោះអាស្រ័យសង្ខារ នេះជាអានិសង្សរបស់សង្ខារ សង្ខារណា មិនទៀង ជាទុក្ខ មានកិរិយាប្រែប្រួលជាធម្មតា នេះជាទោសរបស់សង្ខារ ការបន្ទោបង់ នូវឆន្ទរាគ ការលះបង់ នូវឆន្ទរាគណា ក្នុងសង្ខារ នេះជាការរលាស់ចេញ នូវសង្ខារ ៗ សេចក្ដីសុខ សោមនស្សណា កើតឡើងព្រោះអាស្រ័យវិញ្ញាណ

អយំ វិញ្ញាណស្ស អស្សាទោ យំ វិញ្ញាណំ អនិច្ចំ ទុក្ខំ វិបរិណាមធម្មំ អយំ វិញ្ញាណស្ស អាទីនវោ យោ វិញ្ញាណស្មឹ ឆន្ទរាគវិនយោ ឆន្ទរាគប្បហានំ ឥទំ វិញ្ញាណស្ស និស្សរណំ ។

[២០] យាវកីវញ្ចាហំ ភិក្ខវេ ឥមេសំ បញ្ចន្នំ ឧបាទានក្ខន្ធានំ ឯវំ អស្សាទញ្ច អស្សាទតោ អាទីនវញ្ច អាទីនវតោ និស្សរណញ្ច និស្សរណតោ យថាភូតំ ន អព្ភញ្ញាសឹ នេវ តាវាហំ ភិក្ខវេ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោ[១] បច្ចញ្ញាសឹ ។ យតោ ច ខោហំ ភិក្ខវេ ឥមេសំ បញ្ចន្នំ ឧបាទានក្ខន្ធានំ ឯវំ អស្សាទញ្ច អស្សាទតោ អាទីនវញ្ច អាទីនវតោ និស្សរណញ្ច និស្សរណតោ យថាភូតំ អព្ភញ្ញាសឹ អថាហំ ភិក្ខវេ

---

១ ឱ. ម. អភិសម្ពុទ្ធោតិ ។

នេះជាអានិសង្សរបស់វិញ្ញាណ វិញ្ញាណណា មិនទៀង ជាទុក្ខ មានកិរិយាប្រែប្រួលជាធម្មតា នេះជាទោសរបស់វិញ្ញាណ ការបន្ទោបង់នូវឆន្ទរាគ ការលះបង់នូវឆន្ទរាគណា ក្នុងវិញ្ញាណ នេះជាការរលាស់ចេញ នូវវិញ្ញាណ ។

(៦០) ម្នាលភិក្ខុទាំងឡាយ តថាគតមិនទាន់ដឹងច្បាស់តាមពិត នូវអានិសង្សថាជាអានិសង្សផង នូវទោសថាជាទោសផង នូវការរលាស់ចេញថាជាការរលាស់ចេញផង របស់ឧបាទានក្ខន្ធទាំង ៥ នេះ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ តថាគតក៏មិនទាន់ប្តេជ្ញាខ្លួនថាជាអ្នកត្រាស់ដឹងនូវសម្មាសម្ពោធិញាណ ជាគុណជាតដ៏ប្រសើរ ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស អស់កាលត្រឹមនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ លុះតថាគតបានដឹងច្បាស់តាមពិត នូវអានិសង្សថាជាអានិសង្សផង នូវទោសថាជាទោសផង នូវការរលាស់ចេញថាជាការរលាស់ចេញផង របស់ឧបាទានក្ខន្ធទាំង៥នេះ ក្នុងកាលណា ម្នាលភិក្ខុទាំងឡាយ តថាគតទើបប្តេជ្ញាខ្លួន

សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោ បច្ចញ្ញាសឹ ។ ញាណញ្ច បន មេ ទស្សនំ ឧទបាទិ អកុប្បា មេ វិមុត្តិ អយមន្តិមា ជាតិ នត្ថិទានិ បុនព្ភវោតិ ។

[៦១] សាវត្ថិយំ ។ តត្រ ខោ ។ រូបស្សាហំ ភិក្ខវេ អស្សាទបរិយេសនំ អចរឹ យោ រូបស្ស អស្សាទោ តទជ្ឈគមំ យាវតា រូបស្ស អស្សាទោ បញ្ញាយ មេ សោ សុទិដ្ឋោ ។ រូបស្សាហំ ភិក្ខវេ អាទីនវបរិយេសនំ អចរឹ យោ រូបស្ស អាទីនវោ តទជ្ឈ-

ថាជាអ្នកត្រាស់ដឹង នូវសម្មាសម្ពោធិញ្ញាណ ជាគុណជាតដ៏ប្រសើរក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ក្នុងកាលនោះឯង ។ ការដឹងច្បាស់ ឃើញច្បាស់ ក៏កើតឡើងហើយដល់តថាគតដូច្នេះថា សេចក្ដីរួចស្រឡះ (ចាកអាសវៈ) របស់តថាគតមិនកម្រើកបានឡើយ ជាតិនេះ ជាទីបំផុតត្រឹមនេះហើយ ឥឡូវនេះ ភពថ្មី គឺការត្រឡប់កើតតទៅទៀត មិនមានឡើយ ។

[៦១] ក្នុងក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ តថាគតបានប្រព្រឹត្តស្វះស្វែងរក នូវអានិសង្សរបស់រូប អានិសង្សរបស់រូបណា តថាគតក៏បានជួបប្រទះនូវអានិសង្សនោះហើយ អានិសង្សរបស់រូបទាំងប៉ុន្មាន អានិសង្សនោះតថាគតបានឃើញច្បាស់ដោយបញ្ញាហើយ ។ ម្នាលភិក្ខុទាំងឡាយ តថាគតបានប្រព្រឹត្តស្វះស្វែងរកនូវទោសរបស់រូប ទោសរបស់រូបណា តថាគតក៏បានជួបប្រទះនូវទោស

គមំ យាវតា រូបស្ស អាទីនវោ បញ្ញាយ មេ សោ សុទិដ្ឋោ ។ រូបស្សាហំ ភិក្ខវេ និស្សរណបរិយេសនំ អចរឹ យំ រូបស្ស និស្សរណំ តទជ្ឈគមំ យាវតា រូបស្ស និស្សរណំ បញ្ញាយ មេ តំ សុទិដ្ឋំ ។ វេទនាយាហំ ភិក្ខវេ ។ សញ្ញាយាហំ ភិក្ខវេ ។ សង្ខារានាហំ ភិក្ខវេ ។ វិញ្ញាណស្សាហំ ភិក្ខវេ អស្សាទបរិយេសនំ អចរឹ យោ វិញ្ញាណស្ស អស្សាទោ តទជ្ឈគមំ យាវតា វិញ្ញាណស្ស អស្សាទោ បញ្ញាយ មេ សោ សុទិដ្ឋោ ។ វិញ្ញាណស្សាហំ ភិក្ខវេ អាទីនវបរិយេសនំ អចរឹ យោ វិញ្ញាណស្ស អាទីនវោ តទជ្ឈគមំ យាវតា វិញ្ញាណស្ស អាទីនវោ បញ្ញាយ មេ សោ សុទិដ្ឋោ ។

នោះហើយ ទោសរបស់រូបទាំងប៉ុន្មាន ទោសនោះតថាគតបានឃើញច្បាស់ដោយបញ្ញាហើយ ។ ម្នាលភិក្ខុទាំងឡាយ តថាគតបានប្រព្រឹត្តស្វះស្វែងរកការរលាស់ចេញនូវរូប ការរលាស់ចេញនូវរូបណា តថាគតក៏បានជួបប្រទះ នូវការរលាស់ចេញនូវរូបនោះ ការរលាស់ចេញនូវរូបទាំងប៉ុន្មាន ការរលាស់ចេញនូវរូបនោះ តថាគតបានឃើញច្បាស់ដោយបញ្ញាហើយ ។ ម្នាលភិក្ខុទាំងឡាយ តថាគត (បានប្រព្រឹត្តស្វះស្វែងរកអានិសង្ស) របស់វេទនា ។ ម្នាលភិក្ខុទាំងឡាយ តថាគត (បានប្រព្រឹត្តស្វះស្វែងរកអានិសង្ស) របស់សញ្ញា ។ ម្នាលភិក្ខុទាំងឡាយ តថាគត (បានប្រព្រឹត្តស្វះស្វែងរកអានិសង្ស) របស់សង្ខារ ។ ម្នាលភិក្ខុទាំងឡាយ តថាគតបានប្រព្រឹត្តស្វះស្វែងរកអានិសង្ស របស់វិញ្ញាណ អានិសង្សរបស់វិញ្ញាណណា តថាគតក៏បានជួបប្រទះ នូវអានិសង្សរបស់វិញ្ញាណនោះហើយ អានិសង្សរបស់វិញ្ញាណទាំងប៉ុន្មាន អានិសង្សរបស់វិញ្ញាណនោះ តថាគតបានឃើញច្បាស់ ដោយបញ្ញាហើយ ។ ម្នាលភិក្ខុទាំងឡាយ តថាគតបានប្រព្រឹត្តស្វះស្វែងរកទោសរបស់វិញ្ញាណ ទោសរបស់វិញ្ញាណណា តថាគតក៏បានជួបប្រទះ នូវទោសរបស់វិញ្ញាណនោះហើយ ទោសរបស់វិញ្ញាណទាំងប៉ុន្មាន ទោសរបស់វិញ្ញាណនោះ តថាគតបានឃើញច្បាស់ ដោយបញ្ញាហើយ ។

វិញ្ញាណស្សាហំ ភិក្ខវេ និស្សរណបរិយេសនំ អចរឹ យំ វិញ្ញាណស្ស និស្សរណំ តទជ្ឈគមំ យាវតា វិញ្ញាណស្ស និស្សរណំ បញ្ញាយ មេ តំ សុទិដ្ឋំ ។ យាវកីវញ្ចាហំ ភិក្ខវេ ឥមេសំ បញ្ចន្នំ ឧបាទានក្ខន្ធានំ អស្សាទញ្ច អស្សាទតោ អាទីនវញ្ច អាទីនវតោ និស្សរណញ្ច និស្ស-រណតោ យថាភូតំ ន អព្ភញ្ញាសឹ ។ បេ ។ បច្ចញ្ញាសឹ ។ ញាណញ្ច បន មេ ទស្សនំ ឧទបាទិ អកុប្បា មេ វិមុត្តិ(១) អយមន្តិមា ជាតិ នត្ថិ ទានិ បុនព្ភវោតិ ។

---

១ ឱ. ម. ចេតោវិមុត្តិ ។

ម្នាលភិក្ខុទាំងឡាយ តថាគតបានប្រព្រឹត្តស្វះស្វែងរកការរលាស់ចេញនូវវិញ្ញាណ ការរលាស់ចេញនូវវិញ្ញាណណា តថាគតក៏បានជួបប្រទះនូវការរលាស់ចេញនូវវិញ្ញាណនោះហើយ ការរលាស់ចេញនូវវិញ្ញាណទាំងប៉ុន្មាន ការរលាស់ចេញនូវវិញ្ញាណនោះ តថាគតបានឃើញច្បាស់ដោយបញ្ញាហើយ ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនទាន់ដឹងច្បាស់តាមពិត នូវអានិសង្សថាជាអានិសង្សផង នូវទោសថាជាទោសផង នូវការរលាស់ចេញថាជាការរលាស់ចេញផង របស់ឧបាទានក្ខន្ធទាំង ៥ នេះ អស់កាលត្រឹមណា ។ បេ ។ ក៏មិនបានប្តេជ្ញាខ្លួន ។ ឯការដឹងច្បាស់ ឃើញច្បាស់ ក៏កើតឡើងហើយដល់តថាគតដូច្នេះថា សេចក្តីរួចស្រឡះ (ចាកអាសវៈ) របស់តថាគតមិនកម្រើកទៀតឡើយ ជាតិនេះ ជាទីបំផុតត្រឹមនេះហើយ ឥឡូវនេះ ភពថ្មី គឺការត្រឡប់កើតទៀត មិនមានឡើយ ។

(៦២) សាវត្ថិយំ ។ តត្រ ខោ ។ នោ ចេទំ ភិក្ខវេ រូបស្ស អស្សាទោ អភវិស្ស ន យិទំ សត្តា រូបស្មឹ សារជ្ជេយ្យុំ ។ យស្មា ច ខោ ភិក្ខវេ អត្ថិ រូបស្ស អស្សាទោ តស្មា រូបស្មឹ សារជ្ជន្តិ ។ នោ ចេទំ ភិក្ខវេ រូបស្ស អាទីនវោ អភវិស្ស ន យិទំ សត្តា រូបស្មឹ និព្វិន្ទេយ្យុំ ។ យស្មា ច ខោ ភិក្ខវេ អត្ថិ រូបស្ស អាទីនវោ តស្មា សត្តា រូបស្មឹ និព្វិន្ទន្តិ ។ នោ ចេទំ ភិក្ខវេ រូបស្ស និស្សរណំ អភវិស្ស ន យិទំ សត្តា រូបស្មា និស្សរេយ្យុំ ។ យស្មា ច ខោ ភិក្ខវេ អត្ថិ រូបស្ស និស្សរណំ តស្មា សត្តា រូបស្មា និស្សរន្តិ ។ នោ ចេទំ ភិក្ខវេ វេទនាយ អស្សាទោ អភវិស្ស ។ បេ ។ នោ ចេទំ ភិក្ខវេ សញ្ញាយ ។ នោ ចេទំ ភិក្ខវេ សង្ខារានំ អស្សាទោ អភវិស្ស ន យិទំ សត្តា សង្ខារេសុ សារជ្ជេយ្យុំ ។ យស្មា ច ខោ ភិក្ខវេ អត្ថិ សង្ខារានំ អស្សាទោ តស្មា សត្តា សង្ខារេសុ សារជ្ជន្តិ ។ នោ ចេទំ ភិក្ខវេ សង្ខារានំ អាទីនវោ អភវិស្ស ន យិទំ សត្តា សង្ខារេសុ និព្វិន្ទេយ្យុំ ។ យស្មា ច ខោ ភិក្ខវេ អត្ថិ សង្ខារានំ អាទីនវោ តស្មា សត្តា

[៦២] ក្នុងក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ បើអានិសង្សរបស់រូបមិនមានទេ សត្វទាំងឡាយក៏មិនត្រេកអរក្នុងរូបឡើយ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សរបស់រូបមាន បានជាសត្វទាំងឡាយត្រេកអរក្នុងរូប ។ ម្នាលភិក្ខុទាំងឡាយ បើទោសរបស់រូបមិនមានទេ សត្វទាំងឡាយនេះ ក៏មិននឿយណាយក្នុងរូបឡើយ ។ ម្នាលភិក្ខុទាំងឡាយ ទោសរបស់រូបមាន បានជាសត្វទាំងឡាយតែងនឿយណាយ ក្នុងរូប ។ ម្នាលភិក្ខុទាំងឡាយ បើការរលាស់ចេញនូវរូបមិនមានទេ សត្វទាំងឡាយ ក៏មិនរលាស់ចេញចាករូបឡើយ ។ ម្នាលភិក្ខុទាំងឡាយ ការរលាស់ចេញនូវរូបមាន បានជាសត្វទាំងឡាយ តែងរលាស់ចេញចាករូប ។ ម្នាលភិក្ខុទាំងឡាយ បើអានិសង្សរបស់វេទនាមិនមានទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ បើ(អានិសង្ស)របស់សញ្ញា មិនមានទេ ។ ម្នាលភិក្ខុទាំងឡាយ បើអានិសង្សរបស់សង្ខារ មិនមានទេ សត្វទាំងឡាយក៏មិនត្រេកអរក្នុងសង្ខារឡើយ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សរបស់សង្ខារមាន បានជាសត្វទាំងឡាយត្រេកអរ ក្នុងសង្ខារ ។ ម្នាលភិក្ខុទាំងឡាយ បើទោសរបស់សង្ខារមិនមានទេ សត្វទាំងឡាយក៏មិននឿយណាយ ក្នុងសង្ខារឡើយ ។ ម្នាលភិក្ខុទាំងឡាយ ទោសរបស់សង្ខារមាន បានជាសត្វទាំងឡាយ

សង្ខារេសុ និព្វិន្ទន្តិ ។ នោ ចេទំ ភិក្ខវេ សង្ខារានំ និស្សរណំ អភវិស្ស ន យិទំ សត្តា សង្ខារេហិ និស្សរេយ្យុំ ។ យស្មា ច ខោ ភិក្ខវេ អត្ថិ សង្ខារានំ និស្សរណំ តស្មា សត្តា សង្ខារេហិ និស្សរន្តិ ។ នោ ចេទំ ភិក្ខវេ វិញ្ញាណស្ស អស្សាទោ អភវិស្ស ន យិទំ សត្តា វិញ្ញាណស្មឹ សារជ្ជេយ្យុំ ។ យស្មា ច ខោ ភិក្ខវេ អត្ថិ វិញ្ញាណស្ស អស្សាទោ តស្មា សត្តា វិញ្ញាណស្មឹ សារជ្ជន្តិ ។ នោ ចេទំ ភិក្ខវេ វិញ្ញាណស្ស អាទីនវោ អភវិស្ស ន យិទំ សត្តា វិញ្ញាណស្មឹ និព្វិន្ទេយ្យុំ ។ យស្មា ច ខោ ភិក្ខវេ អត្ថិ វិញ្ញាណស្ស អាទីនវោ តស្មា សត្តា វិញ្ញាណស្មឹ និព្វិន្ទន្តិ ។ នោ ចេទំ ភិក្ខវេ វិញ្ញាណស្ស និស្សរណំ អភវិស្ស ន យិទំ សត្តា វិញ្ញាណស្មា និស្សរេយ្យុំ ។ យស្មា ច ខោ ភិក្ខវេ អត្ថិ វិញ្ញាណស្ស និស្សរណំ តស្មា សត្តា វិញ្ញាណស្មា និស្សរន្តិ ។

តែងនឿយណាយក្នុងសង្ខារ ។ ម្នាលភិក្ខុទាំងឡាយ បើការរលាស់ចេញនូវសង្ខារនេះមិនមានទេ សត្វទាំងឡាយនេះ ក៏មិនរលាស់ចេញចាកសង្ខារឡើយ ។ ម្នាលភិក្ខុទាំងឡាយ ការរលាស់ចេញនូវសង្ខារមាន បានជាសត្វទាំងឡាយតែងរលាស់ចេញចាកសង្ខារ ។ ម្នាលភិក្ខុទាំង-ឡាយ បើអានិសង្សរបស់វិញ្ញាណនេះមិនមានទេ សត្វទាំងឡាយក៏មិនត្រេកអរក្នុងវិញ្ញាណឡើយ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សរបស់វិញ្ញាណមាន បានជាសត្វទាំងឡាយត្រេកអរក្នុងវិញ្ញាណ ។ ម្នាលភិក្ខុទាំងឡាយ បើទោសរបស់វិញ្ញាណមិនមានទេ សត្វទាំងឡាយក៏មិននឿយណាយក្នុងវិញ្ញាណឡើយ ។ ម្នាលភិក្ខុទាំងឡាយ ទោសរបស់វិញ្ញាណមាន បានជាសត្វទាំងឡាយតែងនឿយណាយក្នុងវិញ្ញាណ ។ ម្នាលភិក្ខុទាំងឡាយ បើការរលាស់ចេញនូវវិញ្ញាណមិនមានទេ សត្វទាំងឡាយ ក៏មិនរលាស់ចេញចាកវិញ្ញាណឡើយ ។ ម្នាលភិក្ខុទាំងឡាយ ការរលាស់ចេញ នូវវិញ្ញាណមាន បានជាសត្វទាំងឡាយតែងរលាស់ចេញចាកវិញ្ញាណ ។

(៦៣) យាវកីវញ្ច ភិក្ខវេ សត្តា ឥមេសំ បញ្ចន្នំ ឧបាទានក្ខន្ធានំ អស្សាទញ្ច អស្សាទតោ អាទីនវញ្ច អាទីនវតោ និស្សរណញ្ច និស្សរណតោ យថាភូតំ ន អព្ភញ្ញឹសុ នេវ តាវ ភិក្ខវេ សត្តា សទេវកេ[1] លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ និស្សដា វិសញ្ញុត្តា វិប្បមុត្តា វិមរិយាទិកតេន ចេតសា វិហរឹសុ ។ យតោ ច ខោ ភិក្ខវេ សត្តា ឥមេសំ បញ្ចន្នំ ឧបាទានក្ខន្ធានំ អស្សាទញ្ច អស្សាទតោ អាទីនវញ្ច អាទីនវតោ និស្សរណញ្ច និស្សរណតោ យថាភូតំ អព្ភញ្ញឹសុ អថ ភិក្ខវេ សត្តា សទេវកា លោកា សមារកា សព្រហ្មកា សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ និស្សដា វិសញ្ញុត្តា វិប្បមុត្តា វិមរិយាទិកតេន ចេតសា វិហរន្តីតិ ។

---

១ ឱ. ម. សទេវកា លោកា សមារកា សព្រហ្មកាតិ ភិ ជាយោ ។

( ៦៣ ) ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយមិនបានដឹងច្បាស់តាមពិត នូវអានិសង្សថាជាអានិសង្សផង នូវទោសថាជាទោសផង នូវការរលាស់ចេញថាជាការរលាស់ចេញផង របស់ឧបាទានក្ខន្ធទាំង៥ នេះ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយក្នុងលោកព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស រមែងមិនរលាស់ចេញ មិនបានប្រាសចេញ មិនបានរួចស្រឡះ មានចិត្តមិនបានធ្វើឲ្យប្រាសចាកដែន គឺកិលេសនិងវដ្ដៈ អស់កាលត្រឹមណោះដែរ ។ ម្នាលភិក្ខុទាំងឡាយ លុះតែសត្វទាំងឡាយដឹងច្បាស់តាមពិត នូវអានិសង្សថាជាអានិសង្សផង នូវទោសថាជាទោសផង នូវការរលាស់ចេញថាជាការរលាស់ចេញផង របស់ឧបាទានក្ខន្ធទាំង ៥ នេះ ក្នុងកាលណា ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ ក្នុងលោកព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ទើបបានរលាស់ចេញ ប្រាសចេញ រួចស្រឡះ មានចិត្តធ្វើឲ្យប្រាសចាកដែន គឺកិលេសនិងវដ្ដៈ ក្នុងកាលនោះ ។

(៦៨) សាវត្ថិយំ ។ តត្រ ខោ ។ យោ ភិក្ខវេ រូបំ អភិនន្ទតិ ទុក្ខំ សោ អភិនន្ទតិ យោ ទុក្ខំ អភិនន្ទតិ អបរិមុត្តោ សោ ទុក្ខស្មាតិ វទាមិ ។ យោ វេទនំ អភិនន្ទតិ ។ យោ សញ្ញំ អភិនន្ទតិ ។ យោ សង្ខារេ អភិនន្ទតិ ។ យោ វិញ្ញាណំ អភិនន្ទតិ ទុក្ខំ សោ អភិនន្ទតិ យោ ទុក្ខំ អភិនន្ទតិ អបរិមុត្តោ សោ ទុក្ខស្មាតិ វទាមិ ។

(៦៩) យោ ច ខោ ភិក្ខវេ រូបំ នាភិនន្ទតិ ទុក្ខំ សោ នាភិនន្ទតិ យោ ទុក្ខំ នាភិនន្ទតិ បរិមុត្តោ សោ ទុក្ខស្មាតិ វទាមិ ។ យោ វេទនំ នាភិនន្ទតិ ។ យោ សញ្ញំ នាភិនន្ទតិ ។ យោ សង្ខារេ នាភិនន្ទតិ ។ យោ វិញ្ញាណំ នាភិនន្ទតិ ទុក្ខំ សោ នាភិនន្ទតិ យោ ទុក្ខំ នាភិនន្ទតិ បរិមុត្តោ សោ ទុក្ខស្មាតិ វទាមីតិ ។

[៦៤] ក្នុងក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលណា ត្រេកអរនឹងរូប បុគ្គលនោះ ឈ្មោះថាត្រេកអរនឹងទុក្ខ បុគ្គលណា ត្រេកអរនឹងទុក្ខ តថាគតហៅថា បុគ្គលនោះ មិនរួចស្រឡះចាកទុក្ខបានឡើយ ។ បុគ្គលណា ត្រេកអរនឹងវេទនា ។ បុគ្គលណា ត្រេកអរនឹងសញ្ញា ។ បុគ្គលណា ត្រេកអរនឹងសង្ខារទាំងឡាយ ។ បុគ្គលណា ត្រេកអរនឹងវិញ្ញាណ បុគ្គលនោះ ឈ្មោះថាត្រេកអរនឹងទុក្ខ បុគ្គលណា ត្រេកអរនឹងទុក្ខ តថាគតហៅថា បុគ្គលនោះ មិនរួចស្រឡះចាកទុក្ខបានឡើយ ។

[៦៥] ម្នាលភិក្ខុទាំងឡាយ បុគ្គលណា មិនត្រេកអរនឹងរូប បុគ្គលនោះ ឈ្មោះថាមិនត្រេកអរនឹងទុក្ខ បុគ្គលណា មិនត្រេកអរនឹងទុក្ខ តថាគតហៅថា បុគ្គលនោះ រួចស្រឡះចាកទុក្ខបាន ។ បុគ្គលណា មិនត្រេកអរនឹងវេទនា ។ បុគ្គលណា មិនត្រេកអរនឹងសញ្ញា ។ បុគ្គលណា មិនត្រេកអរនឹងសង្ខារទាំងឡាយ ។ បុគ្គលណា មិនត្រេកអរនឹងវិញ្ញាណ បុគ្គលនោះ ឈ្មោះថាមិនត្រេកអរនឹងទុក្ខ បុគ្គលណាមិនត្រេកអរនឹងទុក្ខ តថាគតហៅថា បុគ្គលនោះ រួចស្រឡះចាកទុក្ខបាន ។

(៦៦) សាវត្ថិយំ ។ តត្រ ខោ ។ យោ ភិក្ខវេ រូបស្ស ឧប្បាទោ ឋិតិ អភិនិព្វត្តិ បាតុភាវោ ទុក្ខស្សេ-សោ ឧប្បាទោ រោគានំ ឋិតិ ជរាមរណស្ស បាតុភាវោ ។ យោ វេទនាយ ។ យោ សញ្ញាយ ។ យោ សង្ខារានំ ។ យោ វិញ្ញាណស្ស ឧប្បាទោ ឋិតិ អភិនិព្វត្តិ បាតុភាវោ ទុក្ខស្សេសោ ឧប្បាទោ រោគានំ ឋិតិ ជរាមរណស្ស បាតុភាវោ ។

(៦៧) យោ ច ភិក្ខវេ រូបស្ស និរោធោ វូបសមោ អត្ថង្គមោ ទុក្ខស្សេសោ និរោធោ រោគានំ វូបសមោ ជរាមរណស្ស អត្ថង្គមោ ។ យោ វេទនាយ ។ យោ សញ្ញាយ ។ យោ សង្ខារានំ ។ យោ វិញ្ញាណស្ស និ-រោធោ វូបសមោ អត្ថង្គមោ ទុក្ខស្សេសោ និរោធោ រោគានំ វូបសមោ ជរាមរណស្ស អត្ថង្គមោតិ ។

(៦៦) ក្នុងក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ការកើតឡើង ការតាំងនៅ ការកើតចំពោះ ការកើតប្រាកដ ណា នៃរូប នុ៎ះឯង ឈ្មោះថាការកើតឡើងនៃទុក្ខ ការតាំងនៅនៃរោគ ការកើតប្រាកដ នៃជរាមរណៈ ។ ការកើតឡើង ណា នៃវេទនា ។ នៃសញ្ញា ។ នៃសង្ខារទាំងឡាយ ។ ការកើតឡើង ការតាំងនៅ ការកើតចំពោះ ការកើតប្រាកដ ណា នៃវិញ្ញាណ នុ៎ះឯង ឈ្មោះថាការកើតឡើងនៃទុក្ខ ការតាំងនៅនៃរោគ ការកើតប្រាកដ នៃជរាមរណៈ ។

(៦៧) ម្នាលភិក្ខុទាំងឡាយ សេចក្តីរលត់ សេចក្តីស្ងប់រម្ងាប់ សេចក្តីវិនាស ណា នៃរូប នុ៎ះឯង ឈ្មោះថាសេចក្តីរលត់នៃទុក្ខ សេចក្តីស្ងប់រម្ងាប់នៃរោគ សេចក្តីវិនាសនៃជរាមរណៈ ។ សេចក្តីរលត់ ណា នៃវេទនា ។ នៃសញ្ញា ។ នៃសង្ខារទាំងឡាយ ។ សេចក្តីរលត់ សេចក្តីស្ងប់រម្ងាប់ សេចក្តីវិនាស ណា នៃវិញ្ញាណ នុ៎ះឯង ឈ្មោះថា សេចក្តីរលត់នៃទុក្ខ សេចក្តីស្ងប់រម្ងាប់នៃរោគ សេចក្តីវិនាសនៃជរាមរណៈ ។

(៦៨) សាវត្ថិយំ ។ តត្រ ខោ ។ អឃញ្ច វោ ភិក្ខវេ ទេសេស្សាមិ អឃមូលញ្ច តំ សុណាថ ។ កតមញ្ច ភិក្ខវេ អឃំ ។ រូបំ ភិក្ខវេ អឃំ វេទនា អឃំ សញ្ញា អឃំ សង្ខារា អឃំ វិញ្ញាណំ អឃំ ។ ឥទំ វុច្ចតិ ភិក្ខវេ អឃំ ។

(៦៩) កតមញ្ច ភិក្ខវេ អឃមូលំ ។ យាយំ តណ្ហា ពោនោព្ភវិកា នន្ទិរាគសហគតា តត្រតត្រាភិនន្ទិនី ។ សេយ្យថីទំ ។ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា ។ ឥទំ វុច្ចតិ ភិក្ខវេ អឃមូលន្តិ ។

(៧០) សាវត្ថិយំ ។ តត្រ ខោ ។ បភង្គុញ្ច ភិក្ខវេ ទេសេស្សាមិ អប្បភង្គុញ្ច តំ សុណាថ ។ កិញ្ច ភិក្ខវេ បភង្គុ កឹ អប្បភង្គុ ។ រូបំ ភិក្ខវេ បភង្គុ យោ តស្ស និរោធោ វូបសមោ អត្ថង្គមោ ឥទំ អប្បភង្គុ ។

( ៦៨ ) ក្នុងក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវទុក្ខផង នូវឫសគល់នៃទុក្ខផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចខ្លះ ហៅថា ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ រូបជាទុក្ខ វេទនាជាទុក្ខ សញ្ញាជាទុក្ខ សង្ខារទាំងឡាយជាទុក្ខ វិញ្ញាណជាទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ នេះ ហៅថា ទុក្ខ ។

( ៦៩ ) ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេច ហៅថា ឫសគល់នៃទុក្ខ ។ តណ្ហា ណា ដែលនាំឲ្យកើតក្នុងភពថ្មី ប្រកបដោយតម្រេក ដោយអំណាចនៃសេចក្តីត្រេកត្រអាល មានកិរិយារីករាយក្នុងអារម្មណ៍នោះ ៗ ជាប្រក្រតី ។ ចុះតណ្ហានោះ ដូចម្តេចខ្លះ ។ គឺកាមតណ្ហា ភវតណ្ហា វិភវតណ្ហា ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ឫសគល់នៃទុក្ខ ។

( ៧០ ) ក្នុងក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ តថាគត នឹងសំដែង នូវរបស់បែកធ្លាយផង នូវរបស់មិនបែកធ្លាយផង ( ដល់អ្នកទាំងឡាយ ) ចូរអ្នកទាំងឡាយស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ចុះអ្វីជារបស់បែកធ្លាយ អ្វីជារបស់មិនបែកធ្លាយ ។ ម្នាលភិក្ខុទាំងឡាយ រូបជារបស់បែកធ្លាយ សេចក្តីរលត់ សេចក្តីស្ងប់-ម្ងាប់ សេចក្តីវិនាស ណា នៃរូបនោះ នេះ ជារបស់មិនបែកធ្លាយ ។

វេទនា បភង្គុ យោ តស្សា និរោធោ វូបសមោ អត្ថង្គមោ ឥទំ អប្បភង្គុ ។ សញ្ញា បភង្គុ ។ សង្ខារា បភង្គុ យោ តេសំ និរោធោ វូបសមោ អត្ថង្គមោ ឥទំ អប្បភង្គុ ។ វិញ្ញាណំ បភង្គុ យោ តស្ស និរោធោ វូបសមោ អត្ថង្គមោ ឥទំ អប្បភង្គុន្តិ ។

ភារវគ្គោ តតិយោ ។

## តស្សុទ្ទានំ

ភារំ បរិញ្ញំ បរិជានំ
ឆន្ទរាគំ ចតុត្ថកំ
អស្សាទា ច តយោ វុត្តា
អភិនន្ទនមដ្ឋមំ
ឧប្បាទំ អឃមូលំ ច
ឯកាទសមោ បភង្គុន្តិ ។

---

វេទនាជារបស់ប្រែប្រួល សេចក្តីរលត់ សេចក្តីស្ងប់រម្ងាប់ សេចក្តីវិនាស ណា នៃវេទនានោះ នេះជារបស់មិនប្រែប្រួល ។ សញ្ញាជារបស់ប្រែប្រួល ។ សង្ខារទាំងឡាយជារបស់ប្រែប្រួល សេចក្តីរលត់ សេចក្តីស្ងប់រម្ងាប់ សេចក្តីវិនាស ណា នៃសង្ខារទាំងនោះ នេះ ជារបស់មិនប្រែប្រួល ។ វិញ្ញាណជារបស់ប្រែប្រួល សេចក្តីរលត់ សេចក្តីស្ងប់រម្ងាប់ សេចក្តីវិនាស ណា នៃវិញ្ញាណនោះ នេះ ជារបស់មិនប្រែប្រួល ។

ចប់ ភារវគ្គ ទី ៣ ។

## ឧទ្ទានក្នុងភារវគ្គនោះ គឺ

និយាយអំពីរបស់ធ្ងន់ ១ ការកំណត់ដឹង ១ កិត្តកាលដឹង ១ លះបង់ឆន្ទរាគ ១ ជាគំរប់ ៤ អំពីអានិសង្ស ៣ លើក សេចក្តីត្រេកអរ ១ ជាគំរប់ ៨ អំពីការកើត ១ ឫសគល់នៃទុក្ខ ១ របស់ប្រែប្រួល ១ ជាគំរប់ ១១ ។

# នតុម្ហាកវគ្គោ

(៧១) សាវត្ថិយំ ។ តត្រ ខោ ។ យំ ភិក្ខវេ ន តុម្ហាកំ តំ បជហថ តំ វោ បហីនំ ហិតាយ សុខាយ ភវិស្សតិ ។ កិញ្ច ភិក្ខវេ ន តុម្ហាកំ ។ រូបំ ភិក្ខវេ ន តុម្ហាកំ តំ បជហថ តំ វោ បហីនំ ហិតាយ សុខាយ ភវិស្សតិ ។ វេទនា ន តុម្ហាកំ តំ បជហថ សា វោ បហីនា ហិតាយ សុខាយ ភវិស្សតិ ។ សញ្ញា ន តុម្ហាកំ ។ សង្ខារា ន តុម្ហាកំ តេ បជហថ

## នតុម្ហាកវគ្គ

(៧១) ក្នុងក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ របស់ណា មិនមែនរបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយ ចូរលះបង់របស់នេះចេញ របស់នោះ បើអ្នកទាំងឡាយ លះបង់ហើយ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ។ ម្នាលភិក្ខុទាំងឡាយ ចុះរបស់ដូចម្តេច ដែលមិនមែនរបស់អ្នកទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ រូបមិនមែនរបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយ ចូរលះបង់នូវរូបនោះចេញ រូបនោះ បើអ្នកទាំងឡាយ លះបង់ហើយ នឹងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ។ វេទនាមិនមែនរបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយចូរលះបង់វេទនានោះចេញ វេទនានោះ បើអ្នកទាំងឡាយលះបង់ហើយ នឹងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ។ សញ្ញាមិនមែនរបស់អ្នកទាំងឡាយទេ ។ សង្ខារទាំងឡាយមិនមែនរបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយចូរលះបង់សង្ខារនោះចេញ

តេ វោ បហីនា ហិតាយ សុខាយ ភវិស្សន្តិ ។ វិញ្ញាណំ ន តុម្ហាកំ តំ បជហថ តំ វោ បហីនំ ហិតាយ សុខាយ ភវិស្សតិ ។

(៧២) សេយ្យថាបិ ភិក្ខវេ យំ ឥមស្មឹ ជេតវនេ តិណកដ្ឋសាខាបលាសំ តំ ជនោ ហរេយ្យ វា ឌហេយ្យ វា យថាបច្ចយំ វា ករេយ្យ អបិ នុ តុម្ហាកំ ឯវមស្ស អម្ហេ ជនោ ហរតិ វា ឌហតិ វា យថាបច្ចយំ វា ករោតីតិ ។ នោ ហេតំ ភន្តេ ។ តំ កិស្ស ហេតុ ។ ន ហិ នោ ឯតំ ភន្តេ អត្តា វា អត្តនិយំ វាតិ ។ ឯវមេវ ខោ ភិក្ខវេ រូបំ ន តុម្ហាកំ តំ បជហថ តំ វោ បហីនំ ហិតាយ សុខាយ ភវិស្សតិ ។ វេទនា ន តុម្ហាកំ

សញ្ញាទាំងនោះ បើអ្នកទាំងឡាយលះបង់ហើយ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ។ វិញ្ញាណមិនមែនរបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយចូរលះបង់វិញ្ញាណនោះចេញ វិញ្ញាណនោះ បើអ្នកទាំងឡាយ លះបង់ហើយ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ។

[៧២] ម្នាលភិក្ខុទាំងឡាយ ដូចស្មៅ ឬឈើ មែកឈើ និងស្លឹកឈើណា ក្នុងវត្តជេតពននេះ អ្នកផងនាំយកចេញ ឬដុតចោល ឬក៏ធ្វើឲ្យសមគួរដល់ហេតុ នូវស្មៅ ឬឈើ មែកឈើ និងស្លឹកឈើនោះ ចុះអ្នកទាំងឡាយនឹងមានសេចក្តីត្រិះរិះយ៉ាងនេះថា អ្នកផងឈ្មោះថានាំយកចេញ ឬដុតចោល ឬក៏ធ្វើឲ្យសមគួរដល់ហេតុ នូវយើងទាំងឡាយដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនដូច្នោះទេ ។ ដំណើរនោះ ព្រោះហេតុដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះវត្ថុនោះ មិនមែនជាខ្លួនផង មិនមែនជារបស់អាស្រ័យនៅក្នុងខ្លួនផង នៃយើងទាំងឡាយទេ ។ ម្នាលភិក្ខុទាំងឡាយ រូបមិនមែនរបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយចូរលះបង់នូវរូបនោះចេញ រូបនោះបើអ្នកទាំងឡាយលះបង់ហើយ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ។ វេទនាមិនមែនរបស់

តំ បជហថ សា វោ បហីនា ហិតាយ សុខាយ ភវិស្ស-តិ ។ សញ្ញា ន តុម្ហាកំ ។ សង្ខារា ន តុម្ហាកំ ។ វិញ្ញា-ណំ ន តុម្ហាកំ តំ បជហថ តំ វោ បហីនំ ហិតាយ សុខាយ ភវិស្សតីតិ ។

(៧៣) សាវត្ថិយំ ។ តត្រ ខោ ។ យំ ភិក្ខវេ ន តុម្ហាកំ តំ បជហថ តំ វោ បហីនំ ហិតាយ សុខាយ ភវិស្សតិ ។ កិញ្ច ភិក្ខវេ ន តុម្ហាកំ ។ រូបំ ភិក្ខវេ ន តុម្ហាកំ តំ បជហថ តំ វោ បហីនំ ហិតាយ សុ-ខាយ ភវិស្សតិ ។ វេទនា ន តុម្ហាកំ ។ សញ្ញា ន តុម្ហាកំ ។ សង្ខារា ន តុម្ហាកំ ។ វិញ្ញាណំ ន តុម្ហាកំ

អ្នកទាំងឡាយទេ អ្នកទាំងឡាយចូរលះបង់ នូវវេទនានោះចេញ វេទនានោះ បើអ្នកទាំងឡាយលះបង់ហើយ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ។ សញ្ញាមិនមែនរបស់អ្នកទាំងឡាយទេ ។ សង្ខារទាំងឡាយមិនមែនរបស់អ្នកទាំងឡាយទេ ។ វិញ្ញាណមិនមែនរបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយចូរលះបង់ នូវវិញ្ញាណនោះចេញ វិញ្ញាណនោះបើអ្នកទាំងឡាយ លះបង់ហើយ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ក៏មានឧបមេយ្យយ៉ាងនោះឯង ។

(៧៣) ក្នុងក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ របស់ណាមិនមែនរបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយចូរលះបង់របស់នោះចេញ របស់នោះ បើអ្នកទាំងឡាយលះបង់ហើយ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ។ ម្នាលភិក្ខុទាំងឡាយ ចុះរបស់ដូចម្តេច ដែលមិនមែនរបស់អ្នកទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ រូបមិនមែនរបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយចូរលះបង់នូវរូបនោះចេញ រូបនោះបើអ្នកទាំងឡាយលះបង់ហើយ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ។ វេទនាមិនមែនរបស់អ្នកទាំងឡាយទេ ។ សញ្ញាមិនមែនរបស់អ្នកទាំងឡាយទេ ។ សង្ខារទាំងឡាយមិនមែនរបស់អ្នកទាំងឡាយទេ ។ វិញ្ញាណមិនមែនរបស់អ្នកទាំងឡាយទេ

តំ បជហាថ តំ វោ បហីនំ ហិតាយ សុខាយ ភវិស្សតិ ។ យំ ភិក្ខវេ ន តុម្ហាកំ តំ បជហាថ តំ វោ បហីនំ ហិតាយ សុខាយ ភវិស្សតីតិ ។

(៧៤) សាវត្ថិយំ ។ អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ យមហំ ភគវតោ ធម្មំ សុត្វា ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរេយ្យន្តិ ។ យំ ខោ ភិក្ខុ អនុសេតិ តេន សង្ខំ គច្ឆតិ យំ នានុសេតិ

អ្នកទាំងឡាយចូរលះបង់ នូវវិញ្ញាណនោះចេញ វិញ្ញាណនោះ បើអ្នកទាំងឡាយលះបង់ហើយ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ។ ម្នាលភិក្ខុទាំងឡាយ របស់ណាមិនមែនរបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយចូរលះបង់របស់នោះចេញ របស់នោះ បើអ្នកទាំងឡាយលះបង់ហើយ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ។

[៧៦] ក្នុងក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុមួយរូប ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគហើយអង្គុយ ក្នុងទីដ៏សមគួរ ។ លុះភិក្ខុនោះ អង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គស្តាប់ធម៌ណា របស់ព្រះមានព្រះភាគហើយ គប្បីជាបុគ្គលម្នាក់ឯង ចៀសចេញចាកពួក មិនប្រមាទ មានព្យាយាមជាគ្រឿងដុតកំដៅនូវកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន សូមព្រះមានព្រះភាគសំដែងធម៌នោះ ដោយសង្ខេប ដល់ខ្ញុំព្រះអង្គឲ្យបាន ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ បុគ្គលដេកផ្ទិតនឹងអនុស័យណា រមែងដល់នូវការរាប់ដោយអនុស័យនោះ បុគ្គលមិនដេកផ្ទិតនឹងអនុស័យណា

ន តេន សង្ខំ គច្ឆតីតិ ។ អញ្ញាតំ ភគវា អញ្ញាតំ សុគ-
តាតិ ។ យថាកថំ បន ត្វំ ភិក្ខុ មយា សង្ខិត្តេន
ភាសិតស្ស វិត្ថារេន អត្ថំ អាជានាសីតិ ។ រូបញ្ចេ ភន្តេ
អនុសេតិ តេន សង្ខំ គច្ឆតិ ។ វេទនញ្ចេ អនុសេតិ ។
សញ្ញាញ្ចេ អនុសេតិ ។ សង្ខារេ ចេ អនុសេតិ ។
វិញ្ញាណញ្ចេ អនុសេតិ តេន សង្ខំ គច្ឆតិ ។ រូបញ្ចេ
ភន្តេ នានុសេតិ ន តេន សង្ខំ គច្ឆតិ ។ វេទនញ្ចេ
នានុសេតិ ន តេន សង្ខំ គច្ឆតិ ។ សញ្ញាញ្ចេ ។ សង្ខារេ
ចេ ។ វិញ្ញាណញ្ចេ នានុសេតិ ន តេន សង្ខំ គច្ឆតិ ។
ឥមស្ស ខ្វាហំ ភន្តេ ភគវតា សង្ខិត្តេន ភាសិតស្ស
ឯវំ វិត្ថារេន អត្ថំ អាជានាមីតិ ។

រមែងមិនដល់នូវការកើតដោយអនុស័យនោះ ។ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គយល់ហើយ បពិត្រព្រះសុគត ខ្ញុំព្រះអង្គយល់ហើយ ។ មាលក្យបុត្តភិក្ខុ ចុះពាក្យដែលតថាគតសំដែងសង្ខេប អ្នកយល់សេចក្តីដោយពិស្តារបាន តើដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន បើបុគ្គលផ្គងផ្គិតនឹងរូប រមែងដល់នូវការកើត (ជាជាអ្នកត្រេកអរ អ្នកប្រទូស្ត អ្នកវង្វេង) ដោយការផ្គងផ្គិតនោះ ។ បើបុគ្គលផ្គងផ្គិតនឹងវេទនា ។ បើបុគ្គលផ្គងផ្គិតនឹងសញ្ញា ។ បើបុគ្គលផ្គងផ្គិតនឹងសង្ខារ ។ បើបុគ្គលផ្គងផ្គិតនឹងវិញ្ញាណ រមែងដល់នូវការកើតដោយការផ្គងផ្គិតនោះ ។ បពិត្រព្រះអង្គដ៏ចម្រើន បើបុគ្គលផ្គងផ្គិតនឹងរូប រមែងមិនដល់នូវការកើត (ជាជាអ្នកត្រេកអរ អ្នកប្រទូស្ត អ្នកវង្វេង) ដោយការផ្គងផ្គិតនោះ ។ បើបុគ្គលមិនផ្គងផ្គិតនឹងវេទនា រមែងមិនដល់នូវការកើតដោយការផ្គងផ្គិតនោះ ។ បើបុគ្គល (មិនផ្គងផ្គិត) នឹងសញ្ញា ។ នឹងសង្ខារ ។ បើបុគ្គលមិនផ្គងផ្គិតនឹងវិញ្ញាណ រមែងមិនដល់នូវការកើតដោយការផ្គងផ្គិតនោះ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះពុទ្ធដីកាដែលព្រះមានព្រះភាគសំដែងសង្ខេបនេះ ខ្ញុំព្រះអង្គយល់សេចក្តីដោយពិស្តារបាន យ៉ាងនេះឯង ។

(៧៥) សាធុ សាធុ ភិក្ខុ សាធុ ខោ ត្វំ ភិក្ខុ មយា សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ អាជានាសិ ។ រូបញ្ចេ ភិក្ខុ អនុសេតិ តេន សង្ខំ គច្ឆតិ ។ វេទនញ្ចេ ។ សញ្ញញ្ចេ ។ សង្ខារេ ចេ ។ វិញ្ញាណញ្ចេ អនុសេតិ តេន សង្ខំ គច្ឆតិ ។ រូបញ្ចេ ភិក្ខុ នានុសេតិ ន តេន សង្ខំ គច្ឆតិ ។ វេទនញ្ចេ ។ សញ្ញញ្ចេ ។ សង្ខារេ ចេ ។ វិញ្ញាណញ្ចេ នានុសេតិ ន តេន សង្ខំ គច្ឆតិ ។ ឥមស្ស ខោ ភិក្ខុ មយា សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថោ ទដ្ឋព្វោតិ ។

(៧៦) អថខោ សោ ភិក្ខុ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ សោ ភិក្ខុ ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ

(៧៥) ម្នាលភិក្ខុ ត្រូវហើយ ៗ ម្នាលភិក្ខុ ពាក្យដែលតថាគតសំដែងសង្ខេប អ្នកយល់សេចក្តីដោយពិស្តារបាន នេះជាការប្រពៃណាស់ ៗ ម្នាលភិក្ខុ បើបុគ្គលផ្តេកផ្តិតនឹងរូប រមែងដល់នូវការរាប់ (ថាជាអ្នកត្រេកអរ អ្នកប្រទូស្ត អ្នកវង្វេង) ដោយការផ្តេកផ្តិតនោះ ៗ បើបុគ្គលផ្តេកផ្តិតនឹងវេទនា ៗ នឹងសញ្ញា ៗ នឹងសង្ខារ ៗ បើបុគ្គលផ្តេកផ្តិតនឹងវិញ្ញាណ រមែងដល់នូវការរាប់ដោយការផ្តេកផ្តិតនោះ ៗ ម្នាលភិក្ខុ បើបុគ្គលមិនផ្តេកផ្តិតនឹងរូប មិនដល់នូវការរាប់ដោយការផ្តេកផ្តិតនោះ ៗ បើបុគ្គលមិនផ្តេកផ្តិតនឹងវេទនា ៗ នឹងសញ្ញា ៗ នឹងសង្ខារ ៗ បើបុគ្គលមិនផ្តេកផ្តិតនឹងវិញ្ញាណ រមែងមិនដល់នូវការរាប់ដោយការផ្តេកផ្តិតនោះ ៗ ម្នាលភិក្ខុ ពាក្យដែលតថាគតសំដែងសង្ខេបនេះឯង បណ្ឌិតគប្បីយល់សេចក្តីដោយពិស្តារ យ៉ាងនេះឯង ៗ

(៧៦) គ្រានោះឯង ភិក្ខុនោះ ត្រេកអរ រីករាយ នឹងភាសិតរបស់ព្រះមានព្រះភាគហើយ ក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណ រួចចៀសចេញទៅ ៗ លំដាប់នោះ ភិក្ខុនោះ ជាបុគ្គលតែម្នាក់ឯង ចៀសចេញ (ចាកពួក) ជាអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកំដៅនូវកិលេស មានចិត្តបញ្ជូនទៅកាន់

នចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសិ ។ អញ្ញតរោ ច បន សោ ភិក្ខុ អរហតំ អហោសីតិ ។

(៧៧) សាវត្ថិយំ ។ អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា ។ បេ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច សាធុ មេ ភន្តេ ភគវា សំខិត្តេន ធម្មំ ទេសេតុ យមហំ ភគវតោ ធម្មំ សុត្វា ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរេយ្យន្តិ ។

ព្រះនិព្វាន កុលបុត្តទាំងឡាយចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់គុណវិសេសណា មិនយូរប៉ុន្មាន ក៏បានធ្វើឲ្យជាក់ច្បាស់នូវគុណវិសេសដ៏ប្រសើរ ជាទីបំផុតនៃព្រហ្មចរិយធម៌នោះ ដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ហើយសម្រេចនៅ ក៏បានដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយធម៌ អាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ បណ្តាព្រះអរហន្តទាំងឡាយ ភិក្ខុនោះបានជាព្រះអរហន្តមួយអង្គដែរ ។

(៧៧) ក្នុងក្រុងសាវត្ថី ។ គ្រានោះ ភិក្ខុមួយរូប ចូលទៅគាល់ព្រះមានព្រះភាគ ។ បេ ។ លុះភិក្ខុនោះអង្គុយ ក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គស្តាប់ធម៌ណា របស់ព្រះមានព្រះភាគហើយ គប្បីជាបុគ្គលម្នាក់ឯង ចៀសចេញ (ចាកពួក) ជាអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន សូមព្រះមានព្រះភាគសំដែងធម៌នោះ ដោយសង្ខេប ដល់ខ្ញុំព្រះអង្គឲ្យបាន ។

យំ ខោ ភិក្ខុ អនុសេតិ តំ អនុមិយ្យតិ យំ អនុមិយ្យតិ តេន សង្ខំ គច្ឆតិ យំ នានុសេតិ ន តំ អនុមិយ្យតិ យំ នានុមិយ្យតិ ន តេន សង្ខំ គច្ឆតីតិ ។ អញ្ញាតំ ភគវា អញ្ញាតំ សុគតាតិ ។ យថាកថំ បន ត្វំ ភិក្ខុ មយា សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ អាជានាសី-តិ ។ រូបញ្ចេ ភន្តេ អនុសេតិ តំ អនុមិយ្យតិ យំ អនុ-មិយ្យតិ តេន សង្ខំ គច្ឆតិ ។ វេទនញ្ចេ អនុសេតិ ។ សញ្ញញ្ចេ អនុសេតិ ។ សង្ខារេ ចេ អនុសេតិ ។ វិញ្ញា-ណញ្ចេ អនុសេតិ តំ អនុមិយ្យតិ យំ អនុមិយ្យតិ តេន សង្ខំ គច្ឆតិ ។ រូបញ្ចេ ភន្តេ នានុសេតិ

ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ បុគ្គលផ្ដេកផ្ដិតនឹងអនុស័យណា រមែងស្លាប់នឹងអនុស័យនោះ បុគ្គលស្លាប់នឹងអនុស័យណា រមែងដល់នូវកិរិយាកប់ដោយអនុស័យនោះ បុគ្គលមិនផ្ដេកផ្ដិតនឹងអនុស័យណា រមែងមិនស្លាប់នឹងអនុស័យនោះ បុគ្គលមិនស្លាប់នឹងអនុស័យណា រមែងមិនដល់នូវការកប់ ដោយអនុស័យនោះ ។ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គយល់ហើយ បពិត្រព្រះសុគត ខ្ញុំព្រះអង្គយល់ហើយ ។ ម្នាលភិក្ខុ ចុះពាក្យដែលតថាគតសំដែងដោយសង្ខេប អ្នកយល់សេចក្ដីដោយពិស្ដារបាន តើដូចម្ដេច ។ បពិត្រព្រះអង្គដ៏ចំរើន បើបុគ្គលផ្ដេក-ផ្ដិតនឹងរូប រមែងស្លាប់នឹងរូបនោះ បុគ្គលស្លាប់នឹងរូបណា រមែងដល់នូវការកប់ (ថាជាអ្នកត្រេកអរ អ្នកប្រទូស្ដ អ្នកវង្វេង) ដោយរូបនោះ ។ បើបុគ្គលផ្ដេកផ្ដិតនឹងវេទនា ។ បើបុគ្គលផ្ដេកផ្ដិតនឹងសញ្ញា ។ បើបុគ្គលផ្ដេកផ្ដិតនឹងសង្ខារ ។ បើបុគ្គលផ្ដេកផ្ដិតនឹងវិញ្ញាណ រមែងស្លាប់នឹងវិញ្ញាណនោះ បុគ្គលស្លាប់នឹងវិញ្ញាណណា រមែងដល់នូវការកប់ដោយវិញ្ញាណនោះ ។ បពិត្រព្រះអង្គដ៏ចំរើន បើបុគ្គលមិនផ្ដេកផ្ដិតនឹងរូប

ន តំ អនុមិយ្យតិ យំ នានុមិយ្យតិ ន តេន សង្ខំ គច្ឆតិ ។ វេទនញ្ចេ នានុសេតិ ។ សញ្ញញ្ចេ នានុសេតិ ។ សង្ខារេ ចេ នានុសេតិ ។ វិញ្ញាណញ្ចេ នានុសេតិ ន តំ អនុមិយ្យតិ យំ នានុមិយ្យតិ ន តេន សង្ខំ គច្ឆតិ ។ ឥមស្ស ខ្វាហំ ភន្តេ ភគវតា សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថំ អាជានាមីតិ ។

(៧៨) សាធុ សាធុ ភិក្ខុ សាធុ ខោ ត្វំ ភិក្ខុ មយា សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ អាជានាសិ ។ រូបញ្ចេ ភិក្ខុ អនុសេតិ តំ អនុមិយ្យតិ យំ អនុមិយ្យតិ តេន សង្ខំ គច្ឆតិ ។ វេទនញ្ចេ ។ សញ្ញញ្ចេ ។ សង្ខារេ ចេ ។ វិញ្ញាណញ្ចេ អនុសេតិ តំ អនុមិយ្យតិ យំ អនុមិយ្យតិ តេន សង្ខំ គច្ឆតិ ។ រូបញ្ចេ ភិក្ខុ នានុ-

រមែងមិនស្លាប់ទឹងរូបនោះ បុគ្គលមិនស្លាប់ទឹងរូបណា រមែងមិនដល់នូវការកាប់ដោយរូបនោះ ។ បើបុគ្គលមិនផ្តេកផ្តិតទឹងវេទនា ។ បើបុគ្គលមិនផ្តេកផ្តិតទឹងសញ្ញា ។ បើបុគ្គលមិនផ្តេកផ្តិតទឹងសង្ខារ ។ បើបុគ្គលមិនផ្តេកផ្តិតទឹងវិញ្ញាណ រមែងមិនស្លាប់ទឹងវិញ្ញាណនោះ បុគ្គលមិនស្លាប់ទឹងវិញ្ញាណណា រមែងមិនដល់នូវការកាប់ដោយវិញ្ញាណនោះ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះពុទ្ធដីកាដែលព្រះមានព្រះភាគ សំដែងដោយសង្ខេបនេះឯង ខ្ញុំព្រះអង្គយល់សេចក្តីដោយពិស្តារបាន យ៉ាងនេះឯង ។

(៧៨) ម្នាលភិក្ខុ ត្រូវហើយ ។ ម្នាលភិក្ខុ ពាក្យដែលតថាគតសំដែងដោយសង្ខេប អ្នកយល់សេចក្តីដោយពិស្តារបាន ជាការប្រពៃណាស់ ។ ម្នាលភិក្ខុ បើបុគ្គលផ្តេកផ្តិតទឹងរូប រមែងស្លាប់ទឹងរូបនោះ បុគ្គលស្លាប់ទឹងរូបណា រមែងដល់នូវការកាប់ដោយរូបនោះ ។ បើបុគ្គលផ្តេកផ្តិតទឹងវេទនា ។ ទឹងសញ្ញា ។ ទឹងសង្ខារ ។ បើបុគ្គលផ្តេកផ្តិតទឹងវិញ្ញាណ រមែងស្លាប់ទឹងវិញ្ញាណនោះ បុគ្គលស្លាប់ទឹងវិញ្ញាណណា រមែងដល់នូវការកាប់ ដោយវិញ្ញាណនោះ ។ ម្នាលភិក្ខុ បើបុគ្គលមិន

សេតិ ន តំ អនុមិយ្យតិ យំ នានុមិយ្យតិ ន តេន សង្ខំ គច្ឆតិ ។ វេទនញ្ចេ នានុសេតិ ។ សញ្ញញ្ចេ នានុសេតិ ។ សង្ខារេ ចេ នានុសេតិ ។ វិញ្ញាណញ្ចេ នានុសេតិ ន តំ អនុមិយ្យតិ យំ នានុមិយ្យតិ ន តេន សង្ខំ គច្ឆតិ ។ ឥមស្ស ខោ ភិក្ខុ មយា សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថោ ទដ្ឋព្វោតិ ។ បេ ។ អញ្ញតរោ ច បន សោ ភិក្ខុ អរហតំ អហោសីតិ ។

(៧៩) សាវត្ថិយំ ។ អថខោ អាយស្មា អានន្ទោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ អានន្ទំ ភគវា ឯតទវោច សចេ តំ អានន្ទ ឯវំ បុច្ឆេយ្យុំ

ផ្តេកផ្តិតនឹងរូប រមែងមិនស្ងាប់នឹងរូបនោះ បុគ្គលមិនស្ងាប់នឹងរូបណា រមែងមិនដល់នូវការពេបដោយរូបនោះ ។ បើបុគ្គលមិនផ្តេកផ្តិតនឹងវេទនា ។ បើបុគ្គលមិនផ្តេកផ្តិតនឹងសញ្ញា ។ បើបុគ្គលមិនផ្តេកផ្តិតនឹងសញ្ញា ។ បើបុគ្គលមិនផ្តេកផ្តិតនឹងវិញ្ញាណ រមែងមិនស្ងាប់នឹងវិញ្ញាណនោះ បុគ្គលមិនស្ងាប់នឹងវិញ្ញាណណា រមែងមិនដល់នូវការពេបដោយវិញ្ញាណនោះ ។ ម្នាលភិក្ខុ ពាក្យដែលតថាគតសំដែង ដោយសង្ខេបនេះឯង បណ្ឌិតគួរយល់សេចក្តី ដោយពិស្តារ យ៉ាងនេះ ។ បេ ។ បណ្តាព្រះអរហន្តទាំងឡាយ ភិក្ខុនោះបានជាព្រះអរហន្តមួយអង្គដែរ ។

(៧៩) ក្នុងក្រុងសាវត្ថី ។ គ្រានោះ ព្រះអានន្ទមានអាយុ ចេញចាកទីពួនសម្ងំ ក្នុងសាយណ្ហសម័យ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទមានអាយុ អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលអានន្ទ បើគេសួរអ្នក

កតមេសំ អាវុសោ អានន្ទ ធម្មានំ ឧប្បាទោ បញ្ញាយតិ វយោ បញ្ញាយតិ ឋិតានំ អញ្ញថត្តំ បញ្ញាយតីតិ ។ ឯវំ បុដ្ឋោ ត្វំ អានន្ទ កិន្តិ ព្យាករេយ្យាសីតិ ។ សចេ មំ ភន្តេ ឯវំ បុច្ឆេយ្យុំ កតមេសំ អាវុសោ អានន្ទ ធម្មានំ ឧប្បាទោ បញ្ញាយតិ វយោ បញ្ញាយតិ ឋិតានំ អញ្ញថត្តំ បញ្ញាយតីតិ ។ ឯវំ បុដ្ឋោ អហំ ភន្តេ ឯវំ ព្យាករេយ្យំ រូបស្ស ខោ អាវុសោ ឧប្បាទោ បញ្ញាយតិ វយោ បញ្ញាយតិ ឋិតស្ស អញ្ញថត្តំ បញ្ញាយតិ ។ វេទនាយ ។ សញ្ញាយ ។ សង្ខារានំ ។ វិញ្ញាណស្ស ឧប្បាទោ បញ្ញាយតិ វយោ បញ្ញាយតិ ឋិតស្ស អញ្ញថត្តំ បញ្ញាយតិ ។ ឥមេសំ ខោ អាវុសោ ធម្មានំ ឧប្បាទោ បញ្ញាយតិ វយោ បញ្ញាយតិ ឋិតានំ អញ្ញថត្តំ បញ្ញាយតីតិ ។ ឯវំ បុដ្ឋោ អហំ ភន្តេ ឯវំ ព្យាករេយ្យន្តិ ។

យ៉ាងនេះថា នែអានន្ទមានអាយុ ធម៌ទាំងឡាយដូចម្ដេចខ្លះ ដែលកើតប្រាកដ វិនាសទៅប្រាកដ កាលតាំងនៅហើយប្រែប្រួលទៅវិញ(១) ក៏ប្រាកដ ។ ម្នាលអានន្ទ កាលបើគេសួរយ៉ាងនេះ តើអ្នកគប្បីដោះស្រាយដូចម្ដេច ។ បពិត្រព្រះអង្គដ៏ចម្រើន បើគេសួរខ្ញុំព្រះអង្គយ៉ាងនេះថា នែអានន្ទមានអាយុ ធម៌ទាំងឡាយដូចម្ដេចខ្លះ ដែលកើតប្រាកដ វិនាសទៅប្រាកដ កាលតាំងនៅហើយប្រែប្រួលទៅវិញ ក៏ប្រាកដ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើគេសួរយ៉ាងនេះ ខ្ញុំព្រះអង្គគប្បីដោះស្រាយយ៉ាងនេះថា ម្នាលអាវុសោ រូបរមែងកើតប្រាកដ វិនាសទៅប្រាកដ កាលតាំងនៅហើយប្រែប្រួលទៅវិញក៏ប្រាកដ ។ វេទនា ។ សញ្ញា ។ សង្ខារ ។ វិញ្ញាណរមែងកើតប្រាកដ វិនាសទៅប្រាកដ កាលតាំងនៅហើយប្រែប្រួលទៅវិញក៏ប្រាកដ ។ ម្នាលអាវុសោ ធម៌ទាំងនេះឯង រមែងកើតប្រាកដ វិនាសទៅប្រាកដ កាលតាំងនៅហើយប្រែប្រួលទៅវិញក៏ប្រាកដ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើគេសួរយ៉ាងនេះ ខ្ញុំព្រះអង្គគប្បីដោះស្រាយ យ៉ាងនេះឯង ។

---

១ សំដៅយកធម៌ គឺរូប, វេទនា, សញ្ញា, វិញ្ញាណ របស់សត្វ កំពុងរស់នៅ ហើយចាស់គ្រាំគ្រា (អដ្ឋកថា) ។

(៨០) សាធុ សាធុ អានន្ទ រូបស្ស ខោ អានន្ទ ឧប្បាទោ បញ្ញាយតិ វយោ បញ្ញាយតិ ឋិតស្ស អញ្ញថត្តំ បញ្ញាយតិ ។ វេទនាយ ។ សញ្ញាយ ។ សង្ខារានំ ។ វិញ្ញាណស្ស ឧប្បាទោ បញ្ញាយតិ វយោ បញ្ញាយតិ ឋិតស្ស អញ្ញថត្តំ បញ្ញាយតិ ។ ឥមេសំ ខោ អានន្ទ ធម្មានំ ឧប្បាទោ បញ្ញាយតិ វយោ បញ្ញាយតិ ឋិតានំ អញ្ញថត្តំ បញ្ញាយតីតិ ។ ឯវំ បុដ្ឋោ ត្វំ អានន្ទ ឯវំ ព្យាករេយ្យាសីតិ ។

(៨១) សាវត្ថិយំ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ អានន្ទំ ភគវា ឯតទវោច សចេ តំ អានន្ទ ឯវំ បុច្ឆេយ្យុំ កតមេសំ អាវុសោ អានន្ទ ធម្មានំ ឧប្បាទោ បញ្ញាយិត្ថ វយោ បញ្ញាយិត្ថ ឋិតានំ អញ្ញថត្តំ បញ្ញាយិត្ថ ។ កតមេសំ ធម្មានំ ឧប្បាទោ បញ្ញាយិស្សតិ វយោ បញ្ញាយិស្សតិ ឋិតានំ អញ្ញថត្តំ បញ្ញាយិស្សតិ ។ កតមេសំ ធម្មានំ ឧប្បាទោ បញ្ញាយតិ វយោ បញ្ញាយតិ ឋិតានំ អញ្ញថត្តំ បញ្ញាយតីតិ ។

(៨០) ម្នាលអានន្ទ ត្រូវហើយៗ ម្នាលអានន្ទ រូបពិតជាកើតប្រាកដ វិនាសទៅប្រាកដ កាលតាំងនៅ ហើយប្រែប្រួលទៅវិញក៏ប្រាកដ ។ វេទនា ។ សញ្ញា ។ សង្ខារ ។ វិញ្ញាណពិតជាកើតប្រាកដ វិនាសទៅប្រាកដ កាលតាំងនៅហើយប្រែប្រួលទៅវិញ ក៏ប្រាកដ ។ ម្នាលអានន្ទ ធម៌ទាំងឡាយនេះឯង រមែងកើតប្រាកដ វិនាសទៅប្រាកដ កាលតាំងនៅហើយប្រែប្រួលទៅវិញ ក៏ប្រាកដ ។ ម្នាលអានន្ទ កាលបើគេសួរយ៉ាងនេះ អ្នកគប្បីដោះស្រាយយ៉ាងនេះចុះ ។

(៨១) ក្នុងក្រុងសាវត្ថី ។ លុះព្រះអានន្ទមានអាយុ អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលអានន្ទ បើគេសួរយ៉ាងនេះថា នែអានន្ទមានអាយុ ធម៌ទាំងឡាយដូចម្តេចខ្លះ ដែលកើតប្រាកដហើយ វិនាសទៅប្រាកដហើយ កាលតាំងនៅហើយប្រែប្រួលទៅវិញក៏ប្រាកដហើយ ។ ធម៌ទាំងឡាយដូចម្តេចខ្លះ នឹងកើតប្រាកដ នឹងវិនាសទៅប្រាកដ កាលតាំងនៅហើយប្រែប្រួលទៅវិញក៏នឹងប្រាកដ ។ ធម៌ទាំងឡាយដូចម្តេចខ្លះ កំពុងកើតប្រាកដ កំពុងវិនាសទៅប្រាកដ កំពុងតាំងនៅហើយប្រែប្រួលទៅវិញក៏ប្រាកដ ។

ឯវំ បុដ្ឋោ ត្វំ អានន្ទ កិន្តិ ព្យាករេយ្យាសីតិ ។ សចេ មំ ភន្តេ ឯវំ បុច្ឆេយ្យុំ កតមេសំ អាវុសោ អានន្ទ ធម្មានំ ឧប្បាទោ បញ្ញាយិត្ថ វយោ បញ្ញាយិត្ថ ឋិតានំ អញ្ញថត្តំ បញ្ញាយិត្ថ ។ កតមេសំ ធម្មានំ ឧប្បាទោ បញ្ញាយិស្សតិ វយោ បញ្ញាយិស្សតិ ឋិតានំ អញ្ញថត្តំ បញ្ញាយិស្សតិ ។ កតមេសំ ធម្មានំ ឧប្បាទោ បញ្ញាយតិ វយោ បញ្ញាយតិ ឋិតានំ អញ្ញថត្តំ បញ្ញាយតីតិ ។ ឯវំ បុដ្ឋោ អហំ ភន្តេ ឯវំ ព្យាករេយ្យំ យំ ខោ អាវុសោ រូបំ អតីតំ និរុទ្ធំ វិបរិណតំ តស្ស ឧប្បាទោ បញ្ញាយិត្ថ វយោ បញ្ញាយិត្ថ ឋិតស្ស អញ្ញថត្តំ បញ្ញាយិត្ថ ។ យា វេទនា អតីតា និរុទ្ធា វិបរិណតា តស្សា ឧប្បាទោ បញ្ញាយិត្ថ វយោ បញ្ញាយិត្ថ ឋិតាយ អញ្ញថត្តំ បញ្ញាយិត្ថ ។ យា សញ្ញា ។ យេ សង្ខារា អតីតា

ម្នាលអានន្ទ កាលបើគេសួរយ៉ាងនេះ តើអ្នកគប្បីដោះស្រាយដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន បើគេសួរខ្ញុំព្រះអង្គយ៉ាងនេះថា នែអានន្ទមានអាយុ ធម៌ទាំងឡាយដូចម្តេចខ្លះ ដែលកើតប្រាកដហើយ វិនាសទៅប្រាកដហើយ កាលតាំងនៅហើយប្រែប្រួលទៅវិញក៏ប្រាកដហើយ ។ ធម៌ទាំងឡាយដូចម្តេចខ្លះ ទើងកើតប្រាកដ ទើងវិនាសទៅប្រាកដ កាលតាំងនៅហើយប្រែប្រួលទៅវិញក៏ទើងប្រាកដ ។ ធម៌ទាំងឡាយដូចម្តេចខ្លះ កំពុងកើតប្រាកដ កំពុងវិនាសទៅប្រាកដ កំពុងតាំងនៅហើយប្រែប្រួលទៅវិញក៏ប្រាកដ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើគេសួរយ៉ាងនេះ ខ្ញុំព្រះអង្គគប្បីដោះស្រាយយ៉ាងនេះថា ម្នាលអាវុសោ ទាំងឡាយ រូបណា ដែលកន្លងទៅហើយ រលត់ហើយ ប្រែប្រួលហើយ រូបនោះឈ្មោះថាកើតប្រាកដហើយ វិនាសទៅប្រាកដហើយ កាលតាំងនៅហើយប្រែប្រួលទៅវិញក៏ប្រាកដហើយ ។ វេទនាណា ដែលកន្លងទៅហើយ រលត់ហើយ ប្រែប្រួលហើយ វេទនានោះ ឈ្មោះថាកើតប្រាកដហើយ វិនាសទៅប្រាកដហើយ កាលតាំងនៅហើយប្រែប្រួលទៅវិញក៏ប្រាកដហើយ ។ សញ្ញាណា ។ សង្ខារណា ដែលកន្លងទៅហើយ

និរុទ្ធា វិបរិណតា តេសំ ឧប្បាទោ បញ្ញាយិត្ថ វយោ បញ្ញាយិត្ថ ឋិតានំ អញ្ញថត្តំ បញ្ញាយិត្ថ ។ យំ វិញ្ញាណំ អតីតំ និរុទ្ធំ វិបរិណតំ តស្ស ឧប្បាទោ បញ្ញាយិត្ថ វយោ បញ្ញាយិត្ថ ឋិតស្ស អញ្ញថត្តំ បញ្ញាយិត្ថ ។ ឥមេសំ ខោ អាវុសោ ធម្មានំ ឧប្បាទោ បញ្ញាយិត្ថ វយោ បញ្ញាយិត្ថ ឋិតានំ អញ្ញថត្តំ បញ្ញាយិត្ថ ។ យំ ខោ អាវុសោ រូបំ អជាតំ អប្បាតុភូតំ តស្ស ឧប្បាទោ បញ្ញាយិស្សតិ វយោ បញ្ញាយិស្សតិ ឋិតស្ស អញ្ញថត្តំ បញ្ញាយិស្សតិ ។ យា វេទនា អជាតា អប្បាតុភូតា តស្សា ឧប្បាទោ បញ្ញាយិស្សតិ វយោ បញ្ញាយិស្សតិ ឋិតាយ អញ្ញថត្តំ បញ្ញាយិស្សតិ ។ យា សញ្ញា ។ យេ សង្ខារា អជាតា អប្បាតុភូតា តេសំ ឧប្បាទោ បញ្ញាយិស្សតិ វយោ បញ្ញាយិស្សតិ ឋិតានំ អញ្ញថត្តំ បញ្ញាយិស្សតិ ។

រលត់ហើយ ប្រែប្រួលហើយ សង្ខារទាំងនោះ ឈ្មោះថាកើតប្រាកដហើយ វិនាសទៅប្រាកដហើយ កាលតាំងនៅហើយប្រែប្រួលទៅវិញក៏ប្រាកដហើយ ។ វិញ្ញាណណា ដែលកន្លងទៅហើយ រលត់ហើយ ប្រែប្រួលហើយ វិញ្ញាណនោះ ឈ្មោះថាកើតប្រាកដហើយ វិនាសទៅប្រាកដហើយ កាលតាំងនៅហើយប្រែប្រួលទៅវិញក៏ប្រាកដហើយ ។ ម្នាលអាវុសោទាំងឡាយ ធម៌ទាំងនេះឯង ដែលកើតប្រាកដហើយ វិនាសទៅប្រាកដហើយ កាលតាំងនៅហើយប្រែប្រួលទៅវិញក៏ប្រាកដហើយ ។ ម្នាលអាវុសោទាំងឡាយ រូបណា ដែលមិនទាន់កើត មិនទាន់មានប្រាកដ រូបនោះ ឈ្មោះថានឹងកើតប្រាកដ នឹងវិនាសទៅប្រាកដ កាលតាំងនៅហើយប្រែប្រួលទៅវិញក៏នឹងប្រាកដ ។ វេទនាណា ដែលមិនទាន់កើត មិនទាន់មានប្រាកដ វេទនានោះ ឈ្មោះថានឹងកើតប្រាកដ នឹងវិនាសទៅប្រាកដ កាលតាំងនៅហើយប្រែប្រួលទៅវិញក៏នឹងប្រាកដ ។ សញ្ញាណា ។ សង្ខារណា ដែលមិនទាន់កើត មិនទាន់មានប្រាកដ សង្ខារទាំងនោះ ឈ្មោះថានឹងកើតប្រាកដ នឹងវិនាសទៅប្រាកដ កាលតាំងនៅហើយប្រែប្រួលទៅវិញក៏នឹងប្រាកដ ។

យំ វិញ្ញាណំ អជាតំ អបាតុភូតំ តស្ស ឧប្បាទោ បញ្ញា-
យិស្សតិ វយោ បញ្ញាយិស្សតិ ឋិតស្ស អញ្ញថត្តំ បញ្ញា-
យិស្សតិ ។ ឥមេសំ ខោ អាវុសោ ធម្មានំ ឧប្បាទោ
បញ្ញាយិស្សតិ វយោ បញ្ញាយិស្សតិ ឋិតានំ អញ្ញថត្តំ
បញ្ញាយិស្សតិ ។ យំ ខោ អាវុសោ រូបំ ជាតំ បា-
តុភូតំ តស្ស ឧប្បាទោ បញ្ញាយតិ វយោ បញ្ញាយតិ
ឋិតស្ស អញ្ញថត្តំ បញ្ញាយតិ ។ យា វេទនា ជាតា
បាតុភូតា ។ បេ ។ យា សញ្ញា ។ យេ សង្ខារា ជាតា
បាតុភូតា តេសំ ឧប្បាទោ បញ្ញាយតិ វយោ បញ្ញា-
យតិ ឋិតានំ អញ្ញថត្តំ បញ្ញាយតិ ។ យំ វិញ្ញាណំ ជាតំ
បាតុភូតំ តស្ស ឧប្បាទោ បញ្ញាយតិ វយោ បញ្ញាយតិ
ឋិតស្ស អញ្ញថត្តំ បញ្ញាយតិ ។ ឥមេសំ ខោ អាវុសោ
ធម្មានំ ឧប្បាទោ បញ្ញាយតិ វយោ បញ្ញាយតិ ឋិតានំ
អញ្ញថត្តំ បញ្ញាយតីតិ ។ ឯវំ បុដ្ឋោ អហំ ភន្តេ ឯវំ
ព្យាករេយ្យន្តិ ។

វិញ្ញាណណា ដែលមិនទាន់កើត មិនទាន់មានប្រាកដ វិញ្ញាណនោះ ឈ្មោះថាទឹងកើតប្រាកដ ទឹងវិនាសទៅប្រាកដ កាលតាំងនៅហើយ ប្រែប្រួលទៅវិញក៏ទឹងប្រាកដ ។ ម្នាលអាវុសោទាំងឡាយ ធម៌ទាំងនេះឯង ទឹងកើតប្រាកដ ទឹងវិនាសទៅប្រាកដ កាលតាំងនៅហើយ ប្រែប្រួលទៅវិញក៏ទឹងប្រាកដ ។ ម្នាលអាវុសោទាំងឡាយ រូបណា ដែលកំពុងកើត កំពុងមានប្រាកដ រូបនោះ ឈ្មោះថាកំពុងកើតប្រាកដ កំពុងវិនាសទៅប្រាកដ កំពុងតាំងនៅហើយប្រែប្រួលទៅវិញប្រាកដ ។ វេទនាណា ដែលកំពុងកើត កំពុងមានប្រាកដ ។ បេ ។ សញ្ញាណា ។ សង្ខារណា ដែលកំពុងកើត កំពុងមានប្រាកដ សង្ខារទាំងនោះ ឈ្មោះថាកំពុងកើតប្រាកដ កំពុងវិនាសទៅប្រាកដ កំពុងតាំងនៅហើយប្រែប្រួលទៅវិញប្រាកដ ។ វិញ្ញាណណា ដែលកំពុងកើត កំពុងមានប្រាកដ វិញ្ញាណនោះ ឈ្មោះថាកំពុងកើតប្រាកដ កំពុងវិនាសទៅប្រាកដ កំពុងតាំងនៅហើយប្រែប្រួលទៅវិញប្រាកដ ។ ម្នាលអាវុសោទាំងឡាយ ធម៌ទាំងនេះឯង ដែលកំពុងកើតប្រាកដ កំពុងវិនាសទៅប្រាកដ កំពុងតាំងនៅហើយប្រែប្រួលទៅវិញប្រាកដ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើគេសួរ យ៉ាងនេះ ខ្ញុំព្រះអង្គគប្បីដោះស្រាយ យ៉ាងនេះឯង ។

[៨៤] សាធុ សាធុ អានន្ទ យំ ខោ អានន្ទ រូបំ អតីតំ និរុទ្ធំ វិបរិណតំ តស្ស ឧប្បាទោ បញ្ញាយិត្ថ វយោ បញ្ញាយិត្ថ ឋិតស្ស អញ្ញថត្តំ បញ្ញាយិត្ថ យា វេទនា ។ យា សញ្ញា ។ យេ សង្ខារា ។ យំ វិញ្ញាណំ អតីតំ និរុទ្ធំ វិបរិណតំ តស្ស ឧប្បាទោ បញ្ញាយិត្ថ ។ វយោ បញ្ញាយិត្ថ ឋិតស្ស អញ្ញថត្តំ បញ្ញាយិត្ថ ។ ឥមេសំ ខោ អានន្ទ ធម្មានំ ឧប្បាទោ បញ្ញាយិត្ថ វយោ បញ្ញាយិត្ថ ឋិតានំ អញ្ញថត្តំ បញ្ញាយិត្ថ ។ យំ ខោ អានន្ទ រូបំ អជាតំ អបាតុភូតំ តស្ស ឧប្បាទោ បញ្ញាយិស្សតិ វយោ បញ្ញាយិស្សតិ ឋិតស្ស អញ្ញថត្តំ បញ្ញាយិស្សតិ ។ យា វេទនា ។ យា សញ្ញា ។ យេ សង្ខារា ។ យំ វិញ្ញាណំ អជាតំ អបាតុភូតំ តស្ស ឧប្បាទោ បញ្ញាយិស្សតិ វយោ បញ្ញាយិស្សតិ ឋិតស្ស អញ្ញថត្តំ បញ្ញាយិស្សតិ ។ ឥមេសំ ខោ អានន្ទ ធម្មានំ

[៨២] ម្នាលអានន្ទ ត្រូវហើយៗ ម្នាលអានន្ទ រូបណា កន្លងទៅហើយ រលត់ហើយ ប្រែប្រួលហើយ រូបនោះ ឈ្មោះថាកើតប្រាកដហើយ វិនាសប្រាកដហើយ កាលតាំងនៅហើយប្រែប្រួលទៅវិញក៏ប្រាកដហើយ ។ វេទនាណា ។ សញ្ញាណា ។ សង្ខារណា ។ វិញ្ញាណណា កន្លងទៅហើយ រលត់ហើយ ប្រែប្រួលហើយ វិញ្ញាណនោះ ឈ្មោះថាកើតប្រាកដហើយ វិនាសទៅប្រាកដហើយ កាលតាំងនៅហើយប្រែប្រួលទៅវិញក៏ប្រាកដហើយ ។ ម្នាលអានន្ទ ធម៌ទាំងនេះឯង ដែលកើតប្រាកដហើយ វិនាសទៅប្រាកដហើយ កាលតាំងនៅហើយប្រែប្រួលទៅវិញក៏ប្រាកដហើយ ។ ម្នាលអានន្ទ រូបណាដែលមិនទាន់កើត មិនទាន់មានប្រាកដទេ រូបនោះ ឈ្មោះថានឹងកើតប្រាកដ នឹងវិនាសប្រាកដ កាលតាំងនៅហើយប្រែប្រួលទៅវិញក៏នឹងប្រាកដ ។ វេទនាណា ។ សញ្ញាណា ។ សង្ខារណា ។ វិញ្ញាណណា ដែលមិនទាន់កើត មិនទាន់មានប្រាកដទេ វិញ្ញាណនោះ ឈ្មោះថានឹងកើតប្រាកដ នឹងវិនាសប្រាកដ កាលតាំងនៅហើយប្រែប្រួលទៅវិញក៏នឹងប្រាកដ ។ ម្នាលអានន្ទ ធម៌ទាំងនេះឯង

ឧប្បាទោ បញ្ញាយិស្សតិ វយោ បញ្ញាយិស្សតិ ឋិតានំ អញ្ញថត្តំ បញ្ញាយិស្សតិ ។ យំ ខោ អានន្ទ រូបំ ជាតំ ភូតំ តស្ស ឧប្បាទោ បញ្ញាយតិ វយោ បញ្ញាយតិ ឋិតស្ស អញ្ញថត្តំ បញ្ញាយតិ ។ យា វេទនា ជាតា ភូតា ។ បេ ។ យា សញ្ញា ។ យេ សង្ខារា ។ យំ វិញ្ញាណំ ជាតំ ភូតំ តស្ស ឧប្បាទោ បញ្ញាយតិ វយោ បញ្ញាយតិ ឋិតស្ស អញ្ញថត្តំ បញ្ញាយតិ ។ ឥមេសំ ខោ អានន្ទ ធម្មានំ ឧប្បាទោ បញ្ញាយតិ វយោ បញ្ញាយតិ ឋិតានំ អញ្ញថត្តំ បញ្ញាយតីតិ ។ ឯវំ បុដ្ឋោ ត្វំ អានន្ទ ឯវំ ព្យាករេយ្យាសីតិ ។

(៨៣) សាវត្ថិយំ ។ តត្រ ខោ ។ ធម្មានុធម្មប្បដិបន្នស្ស ភិក្ខវេ ភិក្ខុនោ អយមនុធម្មោ ហោតិ យំ រូបេ និព្វិទាពហុលោ(១) វិហរេយ្យ វេទនាយ និព្វិទាពហុលោ វិហរេយ្យ សញ្ញាយ និព្វិទាពហុលោ វិហរេយ្យ

---

១ ឱ. ម. និព្វិទាពហុលំ ។

ដែលនឹងកើតប្រាកដ នឹងវិនាសប្រាកដ កាលតាំងនៅហើយប្រែប្រួលទៅវិញក៏នឹងប្រាកដ ។ ម្នាលអានន្ទ រូបណា ដែលកំពុងកើត កំពុងមានប្រាកដ រូបនោះ ឈ្មោះថាកំពុងកើតប្រាកដ កំពុងវិនាសប្រាកដ កាលតាំងនៅហើយប្រែប្រួលទៅវិញក៏ប្រាកដ ។ វេទនាណា ដែលកំពុងកើត កំពុងមានប្រាកដ ។ បេ ។ សញ្ញាណា ។ សង្ខារណា ។ វិញ្ញាណណា ដែលកំពុងកើត កំពុងមានប្រាកដ វិញ្ញាណនោះ ឈ្មោះថាកំពុងកើតប្រាកដ កំពុងវិនាសប្រាកដ កាលតាំងនៅហើយប្រែប្រួលទៅវិញក៏ប្រាកដ ។ ម្នាលអានន្ទ ធម៌ទាំងនេះឯង ដែលកំពុងកើតប្រាកដ កំពុងវិនាសប្រាកដ កាលតាំងនៅហើយប្រែប្រួលទៅវិញក៏ប្រាកដ ។ ម្នាលអានន្ទ កាលបើគេសួរយ៉ាងនេះ អ្នកគប្បីដោះស្រាយយ៉ាងនេះចុះ ។

(៨៣) ក្នុងក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ រមែងមានអនុធម៌នេះ គឺជាអ្នកច្រើនដោយសេចក្តីនឿយណាយ ក្នុងរូប ច្រើនដោយសេចក្តីនឿយណាយ ក្នុងវេទនា ច្រើនដោយសេចក្តីនឿយណាយ ក្នុងសញ្ញា

សង្ខារេសុ និព្វិទាពហុលោ វិហរេយ្យ វិញ្ញាណេ និព្វិទាពហុលោ វិហរេយ្យ ។ សោ រូបេ និព្វិទាពហុលោ វិហរន្តោ ។ វេទនាយ ។ សញ្ញាយ ។ សង្ខារេសុ ។ វិញ្ញាណេ និព្វិទាពហុលោ វិហរន្តោ រូបំ បរិជានាតិ ។ វេទនំ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ បរិជានាតិ ។ សោ រូបំ បរិជានំ ។ វេទនំ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ បរិជានំ បរិមុច្ចតិ រូបម្ហា បរិមុច្ចតិ វេទនាយ បរិមុច្ចតិ សញ្ញាយ បរិមុច្ចតិ សង្ខារេហិ បរិមុច្ចតិ វិញ្ញាណម្ហា បរិមុច្ចតិ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ បរិមុច្ចតិ ទុក្ខស្មាតិ វទាមីតិ ។

(៨៤) សាវត្ថិយំ ។ តត្រ ខោ ។ ធម្មានុធម្មប្បដិបន្នស្ស ភិក្ខវេ ភិក្ខុនោ អយមនុធម្មោ ហោតិ យំ រូបេ អនិច្ចានុបស្សី វិហរេយ្យ ។ វេទនាយ ។ សញ្ញាយ ។

ប្រើនដោយសេចក្តីទៀយណាយ កន្លសង្ខារ ប្រើនដោយសេចក្តីទៀយណាយ កន្លវិញ្ញាណ ។ កាលបើភិក្ខុនោះ ប្រើនដោយសេចក្តីទៀយណាយ កន្លរូប ។ កន្លវេទនា ។ កន្លសញ្ញា ។ កន្លសង្ខារ ។ កាលបើភិក្ខុនោះ ប្រើនដោយសេចក្តីទៀយណាយកន្លវិញ្ញាណ ក៏រមែងកំណត់ដឹងនូវរូប ។ នូវវេទនា ។ នូវសញ្ញា ។ នូវសង្ខារ ។ រមែងកំណត់ដឹងនូវវិញ្ញាណ ។ កាលបើភិក្ខុនោះ កំណត់ដឹងនូវរូប ។ នូវវេទនា ។ នូវសញ្ញា ។ នូវសង្ខារ ។ កាលបើភិក្ខុនោះ កំណត់ដឹងនូវវិញ្ញាណ រមែងរួចស្រឡះចាករូប រួចស្រឡះចាកវេទនា រួចស្រឡះចាកសញ្ញា រួចស្រឡះចាកសង្ខារ រួចស្រឡះចាកវិញ្ញាណ រួចស្រឡះចាកជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត តថាគតពោលថា បុគ្គលនោះ រួចស្រឡះចាកវដ្តទុក្ខ ។

[ ៩៦ ] កន្លក្រុងសាវត្ថី ។ កន្លទីនោះឯង ។ មាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ រមែងមានអនុធម៌នេះ គឺជាអ្នកពិចារណាឃើញថាមិនទៀង កន្លរូប ។ កន្លវេទនា ។ កន្លសញ្ញា ។

សង្ខារេសុ ។ វិញ្ញាណេ អនិច្ចានុបស្សី វិហរេយ្យ ។ សោ រូបេ អនិច្ចានុបស្សី វិហរន្តោ ។ វេទនាយ ។ សញ្ញាយ ។ សង្ខារេសុ ។ វិញ្ញាណេ អនិច្ចានុបស្សី វិហរន្តោ រូបំ បរិជានាតិ ។ វេទនំ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ បរិជានាតិ ។ សោ រូបំ បរិជានំ ។ វេទនំ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ បរិជានំ បរិមុច្ចតិ រូបម្ហា បរិមុច្ចតិ វេទនាយ បរិមុច្ចតិ សញ្ញាយ បរិមុច្ចតិ សង្ខារេហិ បរិមុច្ចតិ វិញ្ញាណម្ហា បរិមុច្ចតិ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ បរិមុច្ចតិ ទុក្ខស្មាតិ វទាមីតិ ។

(៨៥) សាវត្ថិយំ ។ តត្រ ខោ ។ ធម្មានុធម្មប្បដិបន្នស្ស ភិក្ខវេ ភិក្ខុនោ អយមនុធម្មោ ហោតិ យំ រូបេ ទុក្ខានុបស្សី វិហរេយ្យ ។ វេទនាយ ។ សញ្ញាយ ។ សង្ខារេសុ ។ វិញ្ញាណេ ទុក្ខានុបស្សី វិហរេយ្យ ។ សោ រូបេ ទុក្ខានុបស្សី វិហរន្តោ ។ វេទនាយ ។ សញ្ញាយ ។

កងសង្ខារ ។ ជាអ្នកពិចារណាឃើញថាមិនទៀង កងវិញ្ញាណ ។ កាលបើភិក្ខុនោះ ពិចារណាឃើញថាមិនទៀង កងរូប ។ កងវេទនា ។ កងសញ្ញា ។ កងសង្ខារ ។ កាលបើភិក្ខុនោះ ពិចារណាឃើញថាមិនទៀងកងវិញ្ញាណ ក៏រមែងកំណត់ដឹងនូវរូប ។ នូវវេទនា ។ នូវសញ្ញា ។ នូវសង្ខារ ។ រមែងកំណត់ដឹងនូវវិញ្ញាណ ។ កាលបើភិក្ខុនោះ កំណត់ដឹងនូវរូប ។ នូវវេទនា ។ នូវសញ្ញា ។ នូវសង្ខារ ។ កាលបើភិក្ខុនោះ កំណត់ដឹងនូវវិញ្ញាណ រមែងរួចស្រឡះចាករូប រួចស្រឡះចាកវេទនា រួចស្រឡះចាកសញ្ញា រួចស្រឡះចាកសង្ខារ រួចស្រឡះចាកវិញ្ញាណ រួចស្រឡះចាកជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត តថាគតពោលថា បុគ្គលនោះរួចស្រឡះចាកវដ្តទុក្ខ ។

(៩៥) កងក្រុងសាវត្ថី ។ កងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រព្រឹត្តធម៌សមគួរដល់ធម៌ រមែងមានអនុធម៌នេះ គឺជាអ្នកពិចារណាឃើញថាជាទុក្ខកងរូប ។ កងវេទនា ។ កងសញ្ញា ។ កងសង្ខារ ។ ជាអ្នកពិចារណាឃើញថាជាទុក្ខកងវិញ្ញាណ ។ កាលបើភិក្ខុនោះ ពិចារណាឃើញថាជាទុក្ខកងរូប ។ កងវេទនា ។ កងសញ្ញា ។

សង្ខារេសុ ។ វិញ្ញាណេ ទុក្ខានុបស្សី វិហរន្តោ រូបំ បរិ-
ជានាតិ ។ វេទនំ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ
បរិជានាតិ ។ សោ រូបំ បរិជានំ ។ វេទនំ ។ សញ្ញំ ។
សង្ខារេ ។ វិញ្ញាណំ បរិជានំ បរិមុច្ចតិ រូបម្ហា បរិមុច្ចតិ
វេទនាយ បរិមុច្ចតិ សញ្ញាយ បរិមុច្ចតិ សង្ខារេហិ ប-
រិមុច្ចតិ វិញ្ញាណម្ហា បរិមុច្ចតិ ជាតិយា ជរាយ មរណេន
សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបា-
យាសេហិ បរិមុច្ចតិ ទុក្ខស្មាតិ វទាមីតិ ។

(៨៦) សាវត្ថិយំ ។ តត្រ ខោ ។ ធម្មានុធម្មប្បដិ-
បន្នស្ស ភិក្ខវេ ភិក្ខុនោ អយមនុធម្មោ ហោតិ យំ រូបេ
អនត្តានុបស្សី វិហរេយ្យ ។ វេទនាយ ។ សញ្ញាយ ។
សង្ខារេសុ ។ វិញ្ញាណេ អនត្តានុបស្សី វិហរេយ្យ ។ សោ
រូបេ អនត្តានុបស្សី វិហរន្តោ ។ វេទនាយ ។ សញ្ញា-
យ ។ សង្ខារេសុ ។ វិញ្ញាណេ អនត្តានុបស្សី វិហរន្តោ
រូបំ បរិជានាតិ ។ វេទនំ ។ សញ្ញំ ។ សង្ខារេ ។

ក្នុងសង្ខារ ៗ ពិចារណាឃើញថាជាទុក្ខក្នុងវិញ្ញាណ រមែងកំណត់ដឹងច្បាស់នូវរូប ៗ នូវវេទនា ៗ នូវសញ្ញា ៗ នូវសង្ខារ ៗ រមែងកំណត់ដឹងច្បាស់នូវវិញ្ញាណ ៗ កាលបើភិក្ខុនោះ កំណត់ដឹងច្បាស់នូវរូប ៗ នូវវេទនា ៗ នូវសញ្ញា ៗ នូវសង្ខារ ៗ កំណត់ដឹងច្បាស់នូវវិញ្ញាណ រមែងរួចស្រឡះចាករូប រួចស្រឡះចាកវេទនា រួចស្រឡះចាកសញ្ញា រួចស្រឡះចាកសង្ខារ រួចស្រឡះចាកវិញ្ញាណ រួចស្រឡះចាកជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស នឹងសេចក្តីចង្អៀតចង្អល់ចិត្ត តថាគតពោលថា បុគ្គលនោះរួចស្រឡះចាកវដ្តទុក្ខ ៗ

(៨៦) ក្នុងក្រុងសាវត្ថី ៗ ក្នុងទីនោះឯង ៗ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ រមែងមានអនុធម៌នេះ គឺជាអ្នកពិចារណាឃើញថាមិនមែនជារបស់ខ្លួន ក្នុងរូប ៗ ក្នុងវេទនា ៗ ក្នុងសញ្ញា ៗ ក្នុងសង្ខារ ៗ ជាអ្នកពិចារណាឃើញថាមិនមែនជារបស់ខ្លួនក្នុងវិញ្ញាណ ៗ កាលបើភិក្ខុនោះ ពិចារណាឃើញថាមិនមែនជារបស់ខ្លួនក្នុងរូប ៗ ក្នុងវេទនា ៗ ក្នុងសញ្ញា ៗ ក្នុងសង្ខារ ៗ កាលបើភិក្ខុនោះ ពិចារណាឃើញថាមិនមែនជារបស់ខ្លួនក្នុងវិញ្ញាណ រមែងកំណត់ដឹងច្បាស់នូវរូប ៗ នូវវេទនា ៗ នូវសញ្ញា ៗ នូវសង្ខារ ៗ

វិញ្ញាណំ បរិជានាតិ ។ សោ រូបំ បរិជានំ ។ វេទនំ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ បរិជានំ បរិមុច្ចតិ រូបម្ហា បរិមុច្ចតិ វេទនាយ បរិមុច្ចតិ សញ្ញាយ បរិមុច្ចតិ សង្ខារេហិ បរិមុច្ចតិ វិញ្ញាណម្ហា បរិមុច្ចតិ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ បរិមុច្ចតិ ទុក្ខស្មាតិ វទាមីតិ ។

នតុម្ហាកវគ្គោ ចតុត្ថោ ។

## តស្សុទ្ទានំ

នតុម្ហាកេន ទ្វេ វុត្តា
ភិក្ខុហិ អបរេ ទុវេ
អានន្ទេន ច ទ្វេ វុត្តា
អនុធម្មេហិ ទ្វេ ទុកាតិ ។

កំណត់ដឹងច្បាស់នូវវិញ្ញាណ ។ កាលបើភិក្ខុនោះ កំណត់ដឹងច្បាស់នូវរូប ។ នូវវេទនា ។ នូវសញ្ញា ។ នូវសង្ខារ ។ កាលបើភិក្ខុនោះ កំណត់ដឹងច្បាស់នូវវិញ្ញាណ រមែងរួចស្រឡះចាករូប រួចស្រឡះចាកវេទនា រួចស្រឡះចាកសញ្ញា រួចស្រឡះចាកសង្ខារ រួចស្រឡះចាកវិញ្ញាណ រួចស្រឡះចាកជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស នឹងសេចក្តីចង្អៀតចង្អល់ចិត្ត តថាគតពោលថា បុគ្គលនោះរួចស្រឡះចាកទុក្ខ ។

ចប់ នតុម្ហាកវគ្គ ទី ៤ ។

## ឧទ្ទានក្នុងនតុម្ហាកវគ្គនោះ គឺ

និយាយអំពីធម៌ដែលព្រះមានព្រះភាគ ទ្រង់សំដែងថា មិនមែនជារបស់អ្នកទាំងឡាយទេ មានពីរលើក អំពីអញ្ញតរភិក្ខុចូលទៅគាល់ព្រះមានព្រះភាគ សូមឲ្យព្រះអង្គសំដែងធម៌ដោយសង្ខេប មានពីរលើក អំពីព្រះមានព្រះភាគត្រាស់សួរធម៌ចំពោះព្រះអានន្ទ មានពីរលើក អំពីព្រះមានព្រះភាគសំដែងអនុធម៌ ប្រមាណពីរ ៗ មានពីរលើក ។

# អត្តទីបវគ្គោ

(៨៧) សាវត្ថិយំ ។ តត្រ ខោ ។ អត្តទីបា ភិក្ខវេ វិហរថ អត្តសរណា អនញ្ញសរណា ធម្មទីបា ធម្មសរណា អនញ្ញសរណា ។ អត្តទីបានំ ភិក្ខវេ វិហរតំ អត្តសរណានំ អនញ្ញសរណានំ ធម្មទីបានំ ធម្មសរណានំ អនញ្ញសរណានំ យោនិសោ ឧបបរិក្ខិតព្វា កឹជាតិកា សោកបរិទេវទុក្ខទោមនស្សុបាយាសា កឹបហោតិកាតិ ។ កឹជាតិកា ច ភិក្ខវេ សោកបរិទេវទុក្ខទោមនស្សុបាយាសា កឹបហោតិកា ។ ឥធ ភិក្ខវេ អស្សុតវា បុថុជ្ជនោ អរិយានំ អទស្សាវី អរិយធម្មស្ស អកោវិទោ អរិយធម្មេ អវិនីតោ សប្បុរិសានំ អទស្សាវី

# អត្តទីបវគ្គ

(៨៧) ក្នុងក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរយកខ្លួនជាទីពឹង យកខ្លួនជាទីរឭក កុំយករបស់ដទៃជាទីពឹងទីរឭកឡើយ ចូរយកធម៌ជាទីពឹង យកធម៌ជាទីរឭក កុំយករបស់ដទៃជាទីពឹងទីរឭកឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលបើយកខ្លួនជាទីពឹង យកខ្លួនជាទីរឭក មិនយករបស់ដទៃជាទីពឹងទីរឭក យកធម៌ជាទីពឹង យកធម៌ជាទីរឭក មិនយករបស់ដទៃជាទីពឹងទីរឭកហើយ គប្បីពិចារណាតែហេតុដោយយោបល់ថា សេចក្ដីសោក សេចក្ដីខ្សឹកខ្សួល សេចក្ដីទុក្ខ ទោមនស្ស នឹងសេចក្ដីចង្អៀតចង្អល់ចិត្ត កើតមកអំពីអ្វី មានមកអំពីអ្វី ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្ដីសោក សេចក្ដីខ្សឹកខ្សួល សេចក្ដីទុក្ខ ទោមនស្ស នឹងសេចក្ដីចង្អៀតចង្អល់ចិត្ត តើកើតមកអំពីអ្វី មានមកអំពីអ្វី ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង មិនបានឃើញពួកព្រះអរិយៈ មិនឈ្លាសក្នុងអរិយធម៌ មិនសិក្សាក្នុងអរិយធម៌ មិនបានឃើញពួកសប្បុរស

សប្បុរិសធម្មស្ស អកោវិទោ សប្បុរិសធម្មេ អវិនីតោ រូបំ អត្តតោ សមនុបស្សតិ រូបវន្តំ វា អត្តានំ អត្តនិ វា រូបំ រូបស្មឹ វា អត្តានំ តស្ស តំ រូបំ វិបរិណមតិ អញ្ញថា ហោតិ តស្ស រូបវិបរិណាមញ្ញថាភាវា ឧប្បជ្ជន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសា ។ វេទនំ អត្តតោ សមនុបស្សតិ វេទនាវន្តំ វា អត្តានំ អត្តនិ វា វេទនំ វេទនាយ វា អត្តានំ តស្ស សា វេទនា វិបរិណមតិ អញ្ញថា ហោតិ តស្ស វេទនាវិបរិណាមញ្ញថាភាវា ឧប្បជ្ជន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសា ។ សញ្ញំ ។ សង្ខារេ អត្តតោ សមនុបស្សតិ ។ បេ ។ វិញ្ញាណំ អត្តតោ សមនុបស្សតិ វិញ្ញាណវន្តំ វា អត្តានំ អត្តនិ វា វិញ្ញាណំ វិញ្ញាណស្មឹ វា អត្តានំ តស្ស តំ វិញ្ញាណំ វិបរិណមតិ អញ្ញថា ហោតិ តស្ស វិញ្ញាណវិបរិណាមញ្ញថាភាវា ឧប្បជ្ជន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសា ។

មិនឈ្លាសវៃ ក្នុងសប្បុរិសធម៌ មិនសិក្សាក្នុងសប្បុរិសធម៌ រមែងពិចារណាឃើញនូវរូបថាជាខ្លួនខ្លះ ឃើញនូវខ្លួនថាមានរូបខ្លះ ឃើញនូវរូបថាមានក្នុងខ្លួនខ្លះ ឃើញនូវខ្លួនថាមានក្នុងរូបខ្លះ លុះរូបនោះ របស់បុគ្គលនោះប្រែប្រួលវិបត្តិផ្សេង ៗ ទៅ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្ត ក៏កើតឡើងដល់បុគ្គលនោះ ព្រោះរូបប្រែប្រួល វិបត្តិទៅផ្សេង ៗ ។ បុគ្គលនោះពិចារណាឃើញនូវវេទនាថាជាខ្លួនខ្លះ ឃើញនូវខ្លួនថាមានវេទនាខ្លះ ឃើញនូវវេទនាថាមានក្នុងខ្លួនខ្លះ ឃើញនូវខ្លួនថាមានក្នុងវេទនាខ្លះ លុះវេទនានោះ របស់បុគ្គលនោះប្រែប្រួលវិបត្តិផ្សេង ៗ ទៅ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្ត ក៏កើតឡើងដល់បុគ្គលនោះ ព្រោះវេទនាប្រែប្រួលវិបត្តិទៅផ្សេង ៗ ។ ឃើញនូវសញ្ញា ។ ពិចារណាឃើញនូវសង្ខារថាជាខ្លួន ។ បេ ។ ពិចារណាឃើញនូវវិញ្ញាណថាជាខ្លួនខ្លះ ឃើញនូវខ្លួនថាមានវិញ្ញាណខ្លះ ឃើញនូវវិញ្ញាណថាមានក្នុងខ្លួនខ្លះ ឃើញនូវខ្លួនថាមានក្នុងវិញ្ញាណខ្លះ លុះវិញ្ញាណនោះ របស់បុគ្គលនោះប្រែប្រួលវិបត្តិផ្សេង ៗ ទៅ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្ត ក៏កើតឡើងដល់បុគ្គលនោះ ព្រោះវិញ្ញាណប្រែប្រួលវិបត្តិទៅផ្សេង ៗ ។

(៨៨) រូបស្ស ចេ ភិក្ខវេ អនិច្ចតំ វិទិត្វា វិបរិណាមំ វិរាគំ និរោធំ បុព្វេ ចេវ រូបំ ឯតរហិ ច សព្វំ រូបំ អនិច្ចំ ទុក្ខំ វិបរិណាមធម្មន្តិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ បស្សតោ យេ សោកបរិទេវទុក្ខទោមនស្សុបាយាសា តេ បហីយន្តិ តេសំ បហានា ន បរិតស្សតិ អបរិតស្សំ សុខំ វិហរតិ សុខវិហារី(១) ភិក្ខុ តទង្គនិព្វុតោតិ វុច្ចតិ ។ វេទនាយ ចេ ភិក្ខវេ អនិច្ចតំ វិទិត្វា វិបរិណាមំ វិរាគំ និរោធំ បុព្វេ ចេវ វេទនា ឯតរហិ ច សព្វា វេទនា អនិច្ចា ទុក្ខា វិបរិណាមធម្មាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ បស្សតោ យេ សោកបរិទេវទុក្ខទោមនស្សុបាយាសា តេ បហីយន្តិ តេសំ បហានា ន បរិតស្សតិ អបរិតស្សំ

១ ឱ. សុខំ វិហរំ ។

(៩៨) ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុដឹងច្បាស់ នូវសេចក្តីមិនទៀង សេចក្តីប្រែប្រួល សេចក្តីវិនាស និងសេចក្តីរលត់នៃរូប ហើយឃើញច្បាស់តាមពិតដោយប្រាជ្ញាដ៏ប្រពៃ នូវរូបនុ៎ះយ៉ាងនេះថា រូបក្នុងកាលមុនក្តី ក្នុងកាលឥឡូវនេះក្តី រូបទាំងអស់ មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា ភិក្ខុនោះ ក៏លះបង់សេចក្តីសោក សេចក្តីខ្សឹក-ខ្សួល សេចក្តីទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្តចេញបាន កាលបើភិក្ខុនោះ លះបង់នូវសេចក្តីសោកជាដើមទាំងនោះចេញហើយ រមែងមិនតក់ស្លុត កាលបើមិនតក់ស្លុតហើយ រមែងនៅជាសុខ ភិក្ខុអ្នកមានធម៌ជាគ្រឿងនៅជាសុខ ហៅថា អ្នករំលត់កិលេសដោយអង្គនៃវិបស្សនានោះៗ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុដឹងច្បាស់ នូវសេចក្តីមិនទៀង សេចក្តីប្រែប្រួល សេចក្តីវិនាស និងសេចក្តីរលត់នៃវេទនា ហើយឃើញច្បាស់តាមពិតដោយប្រាជ្ញាដ៏ប្រពៃ នូវវេទនានុ៎ះយ៉ាងនេះថា វេទនាក្នុងកាលមុនក្តី ក្នុងកាលឥឡូវនេះក្តី វេទនាទាំងអស់ មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា ភិក្ខុនោះ ក៏លះបង់សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្តចេញបាន កាលបើភិក្ខុនោះ លះបង់សេចក្តីសោកជាដើមទាំងនោះចេញហើយ រមែងមិនតក់ស្លុត កាលបើមិនតក់ស្លុតហើយ

សុខំ វិហរតិ សុខវិហារី ភិក្ខុ តទង្គនិព្វុតោតិ វុច្ចតិ ។
សញ្ញាយ ។ សង្ខារានំ ត្វេវ ភិក្ខវេ អនិច្ចតំ វិទិត្វា
វិបរិណាមំ វិរាគំ និរោធំ បុព្វេ ចេវ សង្ខារា ឯតរហិ ច
សព្វេ សង្ខារា អនិច្ចា ទុក្ខា វិបរិណាមធម្មាតិ ឯវមេតំ
យថាភូតំ សម្មប្បញ្ញាយ បស្សតោ យេ សោកបរិ-
ទេវទុក្ខទោមនស្សុបាយាសា តេ បហិយ្យន្តិ តេសំ
បហានា ន បរិតស្សតិ អបរិតស្សំ សុខំ វិហរតិ សុខ-
វិហារី ភិក្ខុ តទង្គនិព្វុតោតិ វុច្ចតិ ។ វិញ្ញាណស្ស ត្វេវ
ភិក្ខវេ អនិច្ចតំ វិទិត្វា វិបរិណាមំ វិរាគំ និរោធំ បុព្វេ
ចេវ វិញ្ញាណំ ឯតរហិ ច សព្វំ វិញ្ញាណំ អនិច្ចំ

រមែងនៅជាសុខ ភិក្ខុអ្នកមានធម៌ជាគ្រឿងនៅជាសុខ ហៅថាអ្នករំលត់កិលេសដោយអង្គនៃវិបស្សនានោះ ៗ ( កាលបើភិក្ខុដឹងច្បាស់ នូវសេចក្តីមិនទៀង ) នៃសញ្ញា ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុដឹងច្បាស់ នូវសេចក្តីមិនទៀង សេចក្តីប្រែប្រួល សេចក្តីវិនាស និងសេចក្តីរលត់នៃសង្ខារហើយ បានឃើញច្បាស់តាមពិត ដោយប្រាជ្ញាដ៏ប្រពៃ នូវសង្ខារនុ៎ះយ៉ាងនេះថា សង្ខារក្នុងកាលមុនក្តី សង្ខារក្នុងកាលឥឡូវនេះក្តី សង្ខារទាំងអស់ មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា ភិក្ខុនោះ ក៏លះបង់សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្តចេញបាន កាលបើភិក្ខុនោះ លះបង់សេចក្តីសោកជាដើមទាំងនោះចេញហើយ រមែងមិនតក់ស្លុត កាលបើមិនតក់ស្លុតហើយ រមែងនៅជាសុខ ភិក្ខុអ្នកមានធម៌ជាគ្រឿងនៅជាសុខ ហៅថាអ្នករំលត់កិលេសដោយអង្គនៃវិបស្សនានោះ ៗ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុដឹងច្បាស់ នូវសេចក្តីមិនទៀង សេចក្តីប្រែប្រួល សេចក្តីវិនាស និងសេចក្តីរលត់នៃវិញ្ញាណហើយ បានឃើញច្បាស់តាមពិត ដោយប្រាជ្ញាដ៏ប្រពៃ នូវវិញ្ញាណនុ៎ះយ៉ាងនេះថា វិញ្ញាណក្នុងកាលមុនក្តី ក្នុងកាលឥឡូវនេះក្តី វិញ្ញាណទាំងអស់មិនទៀង

ទុក្ខំ វិបរិណាមធម្មន្តិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ បស្សតោ យេ សោកបរិទេវទុក្ខទោមនស្សុបាយាសា តេ បហិយ្យន្តិ តេសំ បហានា ន បរិតស្សតិ អបរិតស្សំ សុខំ វិហរតិ សុខវិហារី ភិក្ខុ តទង្គនិព្វុតោតិ វុច្ចតីតិ ។

[៨៩] សាវត្ថិយំ ។ តត្រ ខោ ។ សក្កាយសមុទយគាមិនិញ្ច វោ ភិក្ខវេ បដិបទំ ទេសេស្សាមិ សក្កាយនិរោធគាមិនិញ្ច បដិបទំ តំ សុណាថ ។ កតមា ច ភិក្ខវេ សក្កាយសមុទយគាមិនី បដិបទា ។ ឥធ ភិក្ខវេ អស្សុតវា បុថុជ្ជនោ អរិយានំ អទស្សាវី អរិយធម្មស្ស អកោវិទោ អរិយធម្មេ អវិនីតោ សប្បុរិសានំ អទស្សាវី សប្បុរិសធម្មស្ស អកោវិទោ សប្បុរិសធម្មេ អវិនីតោ រូបំ អត្តតោ សមនុបស្សតិ រូបវន្តំ វា អត្តានំ អត្តនិ វា រូបំ រូបស្មឹ វា អត្តានំ វេទនំ អត្តតោ ។ បេ ។

ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា ភិក្ខុនោះ ក៏លះបង់សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្តចេញបាន កាលបើភិក្ខុនោះ លះបង់សេចក្តីសោកជាដើមទាំងនោះចេញហើយ រមែងមិនតក់ស្លុត កាលបើមិនតក់ស្លុតហើយ រមែងនៅជាសុខ ភិក្ខុអ្នកមានធម៌ជាគ្រឿងនៅជាសុខ ហៅថាអ្នករំលត់កិលេសដោយអង្គនៃវិបស្សនានោះ ៗ ។

[៨៩] ក្នុងក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែង នូវបដិបទាជាដំណើរកើតឡើងនៃសក្កាយផង នូវបដិបទាជាដំណើររលត់នៃសក្កាយផង ដល់អ្នកទាំងឡាយ ។ ចូរស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ចុះបដិបទាជាដំណើរកើតឡើងនៃសក្កាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង មិនបានឃើញពួកព្រះអរិយៈ មិនឈ្លាសវៃក្នុងអរិយធម៌ មិនបានសិក្សាក្នុងអរិយធម៌ មិនបានឃើញពួកសប្បុរស មិនឈ្លាសវៃក្នុងសប្បុរិសធម៌ មិនបានសិក្សាក្នុងសប្បុរិសធម៌ រមែងពិចារណាឃើញនូវរូបថាជាខ្លួនខ្លះ ឃើញនូវខ្លួនថាមានរូបខ្លះ ឃើញនូវរូបថាមានក្នុងខ្លួនខ្លះ ឃើញនូវខ្លួនថាមានក្នុងរូបខ្លះ ឃើញនូវវេទនាថាជាខ្លួន ។បេ។

សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ អត្តតោ សមនុបស្សតិ វិញ្ញាណវន្តំ វា អត្តានំ អត្តនិ វា វិញ្ញាណំ វិញ្ញាណស្មឹ វា អត្តានំ ។ អយំ វុច្ចតិ ភិក្ខវេ សក្កាយសមុទយ-គាមិនី បដិបទាតិ ។ ឥតិ ហិទំ ភិក្ខវេ វុច្ចតិ ទុក្ខស-មុទយគាមិនី សមនុបស្សនាតិ អយមេវេត្ថ អត្ថោ ។

(៩០) កតមា ច ភិក្ខវេ សក្កាយនិរោធគាមិនី បដិបទា ។ ឥធ ភិក្ខវេ សុតវា អរិយសាវកោ អរិយានំ ទស្សាវី អរិយធម្មស្ស កោវិទោ អរិយធម្មេ សុវិនីតោ សប្បុរិសានំ ទស្សាវី សប្បុរិសធម្មស្ស កោវិទោ សប្បុ-រិសធម្មេ សុវិនីតោ ន រូបំ អត្តតោ សមនុបស្សតិ ន រូបវន្តំ វា អត្តានំ ន អត្តនិ វា រូបំ ន រូបស្មឹ វា អត្តានំ ន វេទនំ អត្តតោ ។ ន សញ្ញំ ។ ន សង្ខារេ ។ ន វិញ្ញាណំ អត្តតោ សមនុបស្សតិ ន វិញ្ញាណវន្តំ វា អត្តានំ ន

ឃើញនូវសញ្ញា ។ ឃើញនូវសង្ខារ ។ ពិចារណាឃើញនូវវិញ្ញាណថាជាខ្លួនខ្លះ ឃើញនូវខ្លួនថាមានវិញ្ញាណខ្លះ ឃើញនូវវិញ្ញាណថាមានក្នុងខ្លួនខ្លះ ឃើញនូវខ្លួនថាមានក្នុងវិញ្ញាណខ្លះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាបដិបទាជាដំណើរកើតឡើងនៃសក្កាយ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងហៅថាការយល់ឃើញ ជាដំណើរនាំឲ្យកើតឡើងនៃទុក្ខ នេះជាសេចក្តីអធិប្បាយក្នុងធម៌នុ៎ះ ដោយប្រការដូច្នេះឯង ។

[៩០] ម្នាលភិក្ខុទាំងឡាយ ចុះបដិបទាជាដំណើររលត់នៃសក្កាយតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កក្នុងលោកនេះ ជាអ្នកចេះដឹង បានឃើញពួកព្រះអរិយៈ ឈ្លាសវៃក្នុងអរិយធម៌ បានសិក្សាដោយល្អក្នុងអរិយធម៌ បានឃើញពួកសប្បុរស ឈ្លាសវៃក្នុងសប្បុរស-ធម៌ បានសិក្សាដោយល្អក្នុងសប្បុរសធម៌ រមែងមិនពិចារណាឃើញនូវរូបថាជាខ្លួនខ្លះ មិនឃើញនូវខ្លួនថាមានរូបខ្លះ មិនឃើញនូវរូបថាមានក្នុងខ្លួនខ្លះ មិនឃើញនូវខ្លួនថាមានក្នុងរូបខ្លះ មិនឃើញនូវវេទនាថាជាខ្លួន ។ មិនឃើញនូវសញ្ញា ។ មិនឃើញនូវសង្ខារ ។ មិនពិចារណាឃើញនូវវិញ្ញាណថាជាខ្លួនខ្លះ មិនឃើញនូវខ្លួនថាមានវិញ្ញាណខ្លះ មិនឃើញ

អត្តនិ វា វិញ្ញាណំ ន វិញ្ញាណស្មិំ វា អត្តានំ ។ អយំ វុច្ចតិ ភិក្ខវេ សក្កាយនិរោធគាមិនី បដិបទាតិ ។ ឥតិ ហិទំ ភិក្ខវេ វុច្ចតិ ទុក្ខនិរោធគាមិនី សមនុបស្សនាតិ អយមេវេត្ថ អត្ថោតិ ។

(៩១) សាវត្ថិយំ ។ តត្រ ខោ ។ រូបំ ភិក្ខវេ អនិច្ចំ យទនិច្ចំ តំ ទុក្ខំ យំ ទុក្ខំ តទនត្តា យទនត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ បស្សតោ ចិត្តំ វិរជ្ជតិ វិមុច្ចតិ អនុបាទាយ អាសវេហិ ។ វេទនា អនិច្ចា ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ អនិច្ចំ យទនិច្ចំ តំ ទុក្ខំ យំ ទុក្ខំ តទនត្តា យទនត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។

នូវវិញ្ញាណថាមានក្នុងខ្លួនខ្លះ មិនឃើញនូវខ្លួនថាមានក្នុងវិញ្ញាណខ្លះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បដិបទាជាដំណើររលត់នៃសក្កាយ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងហៅថាការយល់ឃើញ ជាដំណើរនាំឲ្យរលត់នៃទុក្ខ នេះជាសេចក្តីអធិប្បាយក្នុងធម៌នុ៎ះ ដោយប្រការដូច្នេះឯង ។

[៩១] ក្នុងក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ រូបមិនទៀង របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ របស់នោះមិនមែនជារបស់ខ្លួនទេ របស់ណាមិនមែនជារបស់ខ្លួន របស់នោះគួរយល់ឃើញតាមពិត ដោយប្រាជ្ញាដ៏ប្រពៃដូច្នេះថា នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ កាលបើយល់ឃើញតាមពិតដោយប្រាជ្ញាដ៏ប្រពៃ នូវរបស់នុ៎ះយ៉ាងនេះហើយ ចិត្តក៏រមែងនឿយណាយ រមែងរួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ។ វេទនា មិនទៀង ។ សញ្ញា ។ សង្ខារ ។ វិញ្ញាណមិនទៀង របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ របស់នោះមិនមែនជារបស់ខ្លួនទេ របស់ណាមិនមែនជារបស់ខ្លួន របស់នោះគួរយល់ឃើញតាមពិត ដោយប្រាជ្ញាដ៏ប្រពៃដូច្នេះថា នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។

ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ បស្សតោ ចិត្តំ វិរជ្ជតិ វិមុច្ចតិ អនុបាទាយ អាសវេហិ ។

(៩២) រូបធាតុយា ចេ ភិក្ខវេ ភិក្ខុនោ ចិត្តំ វិរត្តំ វិមុត្តំ ហោតិ អនុបាទាយ អាសវេហិ ។ វេទនាធាតុយា ចេ ។ សញ្ញាធាតុយា ចេ ។ សង្ខារធាតុយា ចេ ។ វិញ្ញាណធាតុយា ចេ ភិក្ខវេ ភិក្ខុនោ ចិត្តំ វិរត្តំ វិមុត្តំ ហោតិ អនុបាទាយ អាសវេហិ ។ វិមុត្តត្តា ឋិតំ ឋិតត្តា សន្តុសិតំ សន្តុសិតត្តា ន បរិតស្សតិ អបរិតស្សំ បច្ចត្តញ្ញេវ បរិនិព្វាយតិ ។ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

កាលបើយល់ឃើញ តាមពិតដោយប្រាជ្ញាដ៏ប្រពៃ នូវរបស់នុ៎ះយ៉ាងនេះហើយ ចិត្តក៏រមែងនឿយណាយ រមែងរួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ។

(៩២) ម្នាលភិក្ខុទាំងឡាយ បើចិត្តរបស់ភិក្ខុ បាននឿយណាយក្នុងរូបធាតុ បានរួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំហើយ ។ ក្នុងវេទនាធាតុ ។ ក្នុងសញ្ញាធាតុ ។ ក្នុងសង្ខារធាតុ ។ ម្នាលភិក្ខុទាំងឡាយ បើចិត្តរបស់ភិក្ខុ បាននឿយណាយក្នុងវិញ្ញាណធាតុ បានរួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំហើយ ។ ព្រោះហេតុតែរួចស្រឡះចាកអាសវៈ ចិត្តក៏តាំងនៅនឹង ព្រោះហេតុតែតាំងនៅនឹង ចិត្តក៏ត្រេកអរ ព្រោះហេតុតែត្រេកអរ បុគ្គលរមែងមិនតក់ស្លុត បុគ្គលដែលមិនតក់ស្លុត រមែងរំលត់កិលេសចំពោះខ្លួនឯង ។ បុគ្គលនោះរមែងដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយធម៌អាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

[៩៣] សាវត្ថិយំ ។ តត្រ ខោ ។ រូបំ ភិក្ខវេ អនិច្ចំ យទនិច្ចំ តំ ទុក្ខំ យំ ទុក្ខំ តទនត្តា យទនត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ វេទនា អនិច្ចា ។ សញ្ញា អនិច្ចា ។ សង្ខារា អនិច្ចា ។ វិញ្ញាណំ អនិច្ចំ យទនិច្ចំ តំ ទុក្ខំ យំ ទុក្ខំ តទនត្តា យទនត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ បស្សតោ បុព្វន្តានុទិដ្ឋិយោ ន ហោន្តិ បុព្វន្តានុទិដ្ឋីនំ អសតិ អបរន្តានុទិដ្ឋិយោ ន ហោន្តិ អបរន្តានុទិដ្ឋីនំ អសតិ ថាមសោ(១) បរាមាសោ ន ហោតិ ។ ថាមសេ បរាមាសេ អសតិ រូបស្មឹ វេទនាយ

---

១ ឋាមសោ បរាមាសោតិ ទិដ្ឋិឋាមសោ ចេវ ទិដ្ឋិបរាមាសោ ចាតិ អដ្ឋកថាយំ ទិស្សតិ ។

(៩៣) ក្នុងក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ រូបមិនទៀង របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ របស់នោះមិនមែនជារបស់ខ្លួនទេ របស់ណាមិនមែនជារបស់ខ្លួន របស់នោះគួរយល់ឃើញតាមពិត ដោយប្រាជ្ញាដ៏ប្រពៃដូច្នេះថា នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ វេទនាមិនទៀង ។ សញ្ញាមិនទៀង ។ សង្ខារមិនទៀង ។ វិញ្ញាណមិនទៀង របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ របស់នោះមិនមែនជារបស់ខ្លួន របស់ណាមិនមែនជារបស់ខ្លួន របស់នោះគួរយល់ឃើញ តាមពិត ដោយប្រាជ្ញាដ៏ប្រពៃដូច្នេះថា នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញទេ ។ កាលបើយល់ឃើញតាមពិត ដោយប្រាជ្ញាដ៏ប្រពៃ នូវរបស់នុ៎ះយ៉ាងនេះហើយ បុព្វន្តានុទិដ្ឋិ(១) រមែងមិនមាន កាលបើបុព្វន្តានុទិដ្ឋិមិនមានហើយ អបរន្តានុទិដ្ឋិ(២) ក៏មិនមាន កាលបើអបរន្តានុទិដ្ឋិមិនមានហើយ ការស្ទាបអង្អែលដោយកំឡាំងទិដ្ឋិក៏មិនមាន ។ កាលបើការស្ទាបអង្អែលដោយកំឡាំងទិដ្ឋិមិនមានហើយ ចិត្តក៏រមែងនឿយណាយ ក្នុងរូប ក្នុងវេទនា

---

១ ប្រែថា ការយល់ឃើញនូវខន្ធក្នុងអតីតកាល ទិដ្ឋិនេះមាន ១៨ ។ ២ ប្រែថា ការយល់ឃើញនូវខន្ធក្នុងអនាគតកាល ទិដ្ឋិនេះមាន ៤៤ ។ ទិដ្ឋិទាំង ២ យ៉ាងនេះ ចូរមើលក្នុងព្រហ្មជាលសូត្រ ទីឃនិកាយ សីលក្ខន្ធវគ្គ ។

សញ្ញាយ សង្ខារេសុ វិញ្ញាណស្មឹ ចិត្តំ វិរជ្ជតិ វិមុច្ចតិ អនុបាទាយ អាសវេហិ ។ វិមុត្តត្តា ឋិតំ ឋិតត្តា សន្តុសិតំ សន្តុសិតត្តា ន បរិតស្សតិ អបរិតស្សំ បច្ចត្តញ្ញេវ បរិនិព្វាយតិ ។ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

(៩៨) សាវត្ថិយំ ។ តត្រ ខោ ។ យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា អនេកវិហិតំ អត្តានំ សមនុបស្សមានា សមនុបស្សន្តិ សព្វេ តេ បញ្ចុបាទានក្ខន្ធេ សមនុបស្សន្តិ ឯតេសំ វា អញ្ញតរំ ។ កតមេ បញ្ច ។ ឥធ ភិក្ខវេ អស្សុតវា បុថុជ្ជនោ អរិយានំ អទស្សាវី ។បេ។ សប្បុរិសធម្មេ អវិនីតោ រូបំ អត្តតោ សមនុបស្សតិ រូបវន្តំ វា អត្តានំ អត្តនិ វា រូបំ

ក្នុងសញ្ញា ក្នុងសង្ខារ ក្នុងវិញ្ញាណ រមែងរួចស្រឡះចាកអាសវៈទាំង-ឡាយ ព្រោះមិនប្រកាន់មាំ ។ ព្រោះហេតុតែរួចស្រឡះចាកអាសវៈ ចិត្តក៏តាំងនៅនឹង ព្រោះហេតុតែតាំងនៅនឹង ចិត្តក៏ត្រេកអរ ព្រោះហេតុតែត្រេកអរ បុគ្គលរមែងមិនតក់ស្លុត បុគ្គលដែលមិនតក់ស្លុត រមែងរំលត់កិលេសចំពោះខ្លួនឯង ។ បុគ្គលនោះរមែងដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយធម៌ អាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

(៩៤) ក្នុងក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ណាមួយ កាលយល់ឃើញ តែងយល់ឃើញនូវខ្លួនជាច្រើនប្រការ សមណៈឬព្រាហ្មណ៍ទាំងអស់នោះ រមែងយល់ឃើញនូវឧបាទានក្ខន្ធទាំង ៥ ឬបណ្តាឧបាទានក្ខន្ធទាំង ៥ នុ៎ះ ឧបាទានក្ខន្ធណាមួយ ។ ចុះឧបាទានក្ខន្ធទាំង ៥ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង មិនបានឃើញពួកព្រះអរិយៈ ។ល។ មិនបានសិក្សាក្នុងសប្បុរិសធម៌ រមែងពិចារណាឃើញនូវរូបថាជាខ្លួនខ្លះ ឃើញនូវខ្លួនថាមានរូបខ្លះ ឃើញនូវរូបថាមានក្នុងខ្លួនខ្លះ

រូបស្មឹ វា អត្តានំ ។ វេទនំ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ អត្តតោ សមនុបស្សតិ វិញ្ញាណវន្តំ វា អត្តានំ អត្តនិ វា វិញ្ញាណំ វិញ្ញាណស្មឹ វា អត្តានំ ។ ឥតិ អយញ្ចេវ សមនុបស្សនា អស្មីតិ ចស្ស អវិគតំ ហោតិ ។ អស្មីតិ ខោ បន ភិក្ខវេ អវិគតេ អថ បញ្ចន្នំ ឥន្ទ្រិយានំ អវក្កន្តិ ហោតិ ចក្ខុន្ទ្រិយស្ស សោតិន្ទ្រិយស្ស ឃានិន្ទ្រិយស្ស ជិវ្ហិន្ទ្រិយស្ស កាយិន្ទ្រិយស្ស ។ អត្ថិ ភិក្ខវេ មនោ អត្ថិ ធម្មា អត្ថិ អវិជ្ជាធាតុ ។ អវិជ្ជាសម្ផស្សជេន ភិក្ខវេ វេទយិតេន ផុដ្ឋស្ស អស្សុតវតោ បុថុជ្ជនស្ស អស្មីតិបិស្ស ហោតិ អយមហមស្មីតិបិស្ស ហោតិ ភវិស្សន្តិបិស្ស ហោតិ ន ភវិស្សន្តិបិស្ស ហោតិ

ឃើញនូវខ្លួនថាមានក្នុងរូបខ្លះ ។ នូវវេទនា ។ នូវសញ្ញា ។ នូវសង្ខារ ។ ពិចារណាឃើញនូវវិញ្ញាណថាជាខ្លួនខ្លះ ឃើញនូវខ្លួនថាមានវិញ្ញាណខ្លះ ឃើញនូវវិញ្ញាណថាមានក្នុងខ្លួនខ្លះ ឃើញនូវខ្លួនថាមានវិញ្ញាណខ្លះ ។ យ៉ាងនេះឯង ហៅថាការយល់ឃើញ (ដោយទិដ្ឋិ) មួយទៀត បុគ្គលនោះរមែងបាននូវសេចក្តីប្រកាន់ថាអាត្មាអញមាន[1] ។ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលនោះ បាននូវសេចក្តីប្រកាន់ថាអាត្មាអញមានដូច្នេះហើយ បន្ទាប់អំពីនោះមក ឥន្ទ្រិយទាំង៥ គឺ ចក្ខុន្ទ្រិយ ១ សោតិន្ទ្រិយ ១ ឃានិន្ទ្រិយ ១ ជិវ្ហិន្ទ្រិយ ១ កាយិន្ទ្រិយ ១ រមែងកើតឡើងបាន ។ ម្នាលភិក្ខុទាំងឡាយ ចិត្តក៏មាន ធម្មារម្មណ៍ក៏មាន អវិជ្ជាធាតុក៏មាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាបុថុជ្ជនមិនចេះដឹង កាលបើវេទនាដែលកើតអំពីអវិជ្ជាសម្ផស្សពាល់ត្រូវហើយ តែងយល់ឃើញថា អាត្មាអញមានដូច្នេះខ្លះ យល់ឃើញថានេះអាត្មាអញដូច្នេះខ្លះ យល់ឃើញថាអាត្មាអញនឹងមានដូច្នេះខ្លះ យល់ឃើញថាអាត្មាអញនឹងមិនមានដូច្នេះខ្លះ

---

១ អដ្ឋកថាពន្យល់ថា ប្រកាន់ដោយបបញ្ចធម៌ ៣ យ៉ាងគឺ តណ្ហា មានះ ទិដ្ឋិ ។

រូបី ភវិស្សន្តិបិស្ស ហោតិ អរូបី ភវិស្សន្តិបិស្ស ហោតិ សញ្ញី ភវិស្សន្តិបិស្ស ហោតិ អសញ្ញី ភវិស្សន្តិបិស្ស ហោតិ នេវសញ្ញីនាសញ្ញី ភវិស្សន្តិបិស្ស ហោតិ ។ តិដ្ឋន្តិ ខោ បន ភិក្ខវេ តត្ថេវ បញ្ចិន្ទ្រិយានិ អថេត្ថ សុតវតោ អរិយសាវកស្ស អវិជ្ជា បហីយតិ វិជ្ជា ឧប្បជ្ជតិ តស្ស អវិជ្ជាវិរាគា វិជ្ជុប្បាទា អស្មីតិបិស្ស ន ហោតិ អយមហមស្មីតិបិស្ស ន ហោតិ ភវិស្សន្តិបិស្ស ន ហោតិ ន ភវិស្សន្តិបិស្ស ន ហោតិ រូបី ភវិស្សន្តិបិស្ស ន ហោតិ អរូបី ភវិស្សន្តិបិស្ស ន ហោតិ សញ្ញី ភវិស្សន្តិបិស្ស ន ហោតិ អសញ្ញី ភវិស្សន្តិបិស្ស ន ហោតិ នេវសញ្ញីនាសញ្ញី ភវិស្សន្តិបិស្ស ន ហោតិ ។

យល់ឃើញថាអាត្មាអញនឹងមានរូបដូច្នេះខ្លះ យល់ឃើញថាអាត្មាអញនឹងមិនមានរូបដូច្នេះខ្លះ យល់ឃើញថាអាត្មាអញនឹងមានសញ្ញាដូច្នេះខ្លះ យល់ឃើញថាអាត្មាអញនឹងមិនមានសញ្ញាដូច្នេះខ្លះ យល់ឃើញថាអាត្មាអញនឹងមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែនដូច្នេះខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ក៏ឥន្ទ្រិយទាំង ៥ តែងឋិតនៅក្នុងបុគ្គលនោះៗ ឯង ទុកជាឥន្ទ្រិយទាំងនោះឋិតនៅដោយប្រការដូច្នេះ ចំណែកអរិយសាវ័កអ្នកចេះដឹង រមែងលះបង់អវិជ្ជាចេញបាន វិជ្ជាក៏កើតឡើង ព្រោះវិនាសអវិជ្ជា ព្រោះកើតឡើងនៃវិជ្ជា អរិយសាវ័កនោះក៏មិនបានយល់ឃើញថាអាត្មាអញមានដូច្នេះផង មិនយល់ឃើញថានេះអាត្មាអញដូច្នេះផង មិនយល់ឃើញថាអាត្មាអញនឹងមានដូច្នេះផង មិនយល់ឃើញថាអាត្មាអញនឹងមិនមានដូច្នេះផង មិនយល់ឃើញថាអាត្មាអញនឹងមានរូបដូច្នេះផង មិនយល់ឃើញថាអាត្មាអញនឹងមិនមានរូបដូច្នេះផង មិនយល់ឃើញថាអាត្មាអញនឹងមានសញ្ញាដូច្នេះផង មិនយល់ឃើញថាអាត្មាអញនឹងមិនមានសញ្ញាដូច្នេះផង មិនយល់ឃើញថាអាត្មាអញនឹងមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែនដូច្នេះផង ។

(៩៥) សាវត្ថិយំ ។ តត្រ ខោ ។ បញ្ច ច ភិក្ខវេ ខន្ធេ ទេសេស្សាមិ បញ្ចុបាទានក្ខន្ធេ ច តំ សុណាថ ។ កតមេ ច ភិក្ខវេ បញ្ចក្ខន្ធា ។ យំ កិញ្ចិ ភិក្ខវេ រូបំ អតីតានាគតបច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា ។ អយំ វុច្ចតិ រូបក្ខន្ធោ ។ យា កាចិ វេទនា ។ យា កាចិ សញ្ញា ។ យេ កេចិ សង្ខារា អតីតានាគតបច្ចុប្បន្នា អជ្ឈត្តា[១] វា ពហិទ្ធា វា ឱឡារិកា វា សុខុមា វា ហីនា វា បណីតា វា យេ ទូរេ សន្តិកេ វា ។ អយំ វុច្ចតិ សង្ខារក្ខន្ធោ ។ យំ កិញ្ចិ វិញ្ញាណំ អតីតានាគតបច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា ។ អយំ វុច្ចតិ វិញ្ញាណក្ខន្ធោ ។ ឥមេ វុច្ចន្តិ ភិក្ខវេ បញ្ចក្ខន្ធា ។

---

១ ឱ. ម. អជ្ឈត្តំ វា

[៩៥] ក្នុងក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវខន្ធទាំង៥ផង នូវឧបាទានក្ខន្ធទាំង៥ផង ដល់អ្នកទាំងឡាយ ប្រុងស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ខន្ធទាំង៥ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ រូបណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ជាខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី ឋិតនៅក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី ។ នេះហៅថា រូបក្ខន្ធ ។ វេទនាណាមួយ ។ សញ្ញាណាមួយ ។ សង្ខារណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ជាខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី ឋិតនៅក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី ។ នេះហៅថា សង្ខារក្ខន្ធ ។ វិញ្ញាណណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ជាខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី ឋិតនៅក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី ។ នេះហៅថា វិញ្ញាណក្ខន្ធ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងហៅថា ខន្ធ៥ ។

(៩៦) កតមេ ច ភិក្ខវេ បញ្ចុបាទានក្ខន្ធា ។ យំ កិញ្ចិ ភិក្ខវេ រូបំ អតីតានាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា សាសវំ ឧបាទានិយំ ។ អយំ វុច្ចតិ រូបុបាទានក្ខន្ធោ ។ យា កាចិ វេទនា ។ បេ ។ យា ទូរេ សន្តិកេ វា សាសវា ឧបាទានិយា ។ អយំ វុច្ចតិ វេទនុបាទានក្ខន្ធោ ។ យា កាចិ សញ្ញា ។ បេ ។ យា ទូរេ សន្តិកេ វា សាសវា ឧបាទានិយា(១) ។ អយំវុច្ចតិ សញ្ញុបាទានក្ខន្ធោ ។ យេ កេចិ សង្ខារា ។ បេ ។ សាសវា ឧបាទានិយា ។ អយំ វុច្ចតិ សង្ខារុបាទានក្ខន្ធោ ។ យំ កិញ្ចិ វិញ្ញាណំ អតីតានាគតប្បច្ចុប្បន្នំ ។ បេ ។ យំ ទូរេ សន្តិកេ វា សាសវំ ឧបាទានិយំ ។ អយំ វុច្ចតិ វិញ្ញាណុបាទានក្ខន្ធោ ។ ឥមេ វុច្ចន្តិ ភិក្ខវេ បញ្ចុបាទានក្ខន្ធាតិ ។

---

១ ឧបាទានិយាតិបិ ។

[៩៦] ម្នាលភិក្ខុទាំងឡាយ ចុះឧបាទានក្ខន្ធទាំង ៥ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ រូបណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ជាខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី ឋិតនៅក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី ប្រកបដោយអាសវៈជាបច្ច័យនៃឧបាទាន ។ នេះហៅថា រូបុបាទានក្ខន្ធ ។ វេទនាណាមួយ ។ បេ ។ ឋិតនៅក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី ប្រកបដោយអាសវៈជាបច្ច័យនៃឧបាទាន ។ នេះហៅថា វេទនុបាទានក្ខន្ធ ។ សញ្ញាណាមួយ ។ បេ ។ ឋិតនៅក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី ប្រកបដោយអាសវៈជាបច្ច័យនៃឧបាទាន ។ នេះហៅថា សញ្ញុបាទានក្ខន្ធ ។ សង្ខារណាមួយ ។ បេ ។ ប្រកបដោយអាសវៈជាបច្ច័យនៃឧបាទាន ។ នេះហៅថា សង្ខារុបាទានក្ខន្ធ ។ វិញ្ញាណណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ។ បេ ។ ឋិតនៅក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី ប្រកបដោយអាសវៈជាបច្ច័យនៃឧបាទាន ។ នេះហៅថា វិញ្ញាណុបាទានក្ខន្ធ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងហៅថា ឧបាទានក្ខន្ធ ៥ ។

(៩៧) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ អថ ខោ សោណោ គហបតិបុត្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ។ បេ ។ ឯកមន្តំ និសិន្នំ ខោ សោណំ គហបតិបុត្តំ ភគវា ឯតទវោច យេ ហិ កេចិ សោណ សមណា វា ព្រាហ្មណា វា អនិច្ចេន រូបេន ទុក្ខេន វិបរិណាមធម្មេន សេយ្យោហមស្មីតិ វា សមនុបស្សន្តិ សទិសោហមស្មីតិ វា សមនុបស្សន្តិ ហីនោហមស្មីតិ វា សមនុបស្សន្តិ កិមញ្ញត្រ[១] យថាភូតស្ស អទស្សនា ។ អនិច្ចាយ វេទនាយ ទុក្ខាយ វិបរិណាមធម្មាយ សេយ្យោហមស្មីតិ វា សមនុបស្សន្តិ សទិសោហមស្មីតិ វា សមនុបស្សន្តិ ហីនោហមស្មីតិ វា សមនុបស្សន្តិ កិមញ្ញត្រ យថាភូតស្ស អទស្សនា ។ អនិច្ចាយ សញ្ញាយ ។ អនិច្ចេហិ សង្ខារេហិ ទុក្ខេហិ វិបរិណាមធម្មេហិ សេយ្យោហមស្មីតិ វា សមនុបស្សន្តិ សទិសោ-

---

១ ឱ. កិមញ្ញត្ថ ។

[៩៧] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ គ្រានោះ គហបតិបុត្រឈ្មោះសោណៈ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ។ បេ ។ លុះគហបតិបុត្រឈ្មោះសោណៈ អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលសោណៈ ពួកសមណៈឬព្រាហ្មណ៍ណាមួយ មានរូបមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា តែយល់ឃើញថាអាត្មាអញប្រសើរជាងគេក្តី យល់ឃើញថា អាត្មាអញស្មើនឹងគេក្តី យល់ឃើញថាអាត្មាអញថោកទាបជាងគេក្តី (ឯការយល់ឃើញបែបនេះ) មិនមែនមកអំពីហេតុអ្វីដទៃឡើយ គឺមកអំពីការមិនឃើញនូវសេចក្តីពិត ។ សមណៈឬព្រាហ្មណ៍ណាមួយ មានវេទនាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា តែយល់ឃើញថា អាត្មាអញប្រសើរជាងគេក្តី យល់ឃើញថាអាត្មាអញស្មើនឹងគេក្តី យល់ឃើញថាអាត្មាអញថោកទាបជាងគេក្តី (ឯការយល់ឃើញបែបនេះ) មិនមែនមកអំពីហេតុអ្វីដទៃឡើយ គឺមកអំពីការមិនឃើញនូវសេចក្តីពិត ។ មានសញ្ញាមិនទៀង ។ មានសង្ខារមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា តែយល់ឃើញថាអាត្មាអញប្រសើរជាងគេក្តី យល់ឃើញថាអាត្មាអញ

ហាមស្មីតិ វា សមនុបស្សន្តិ ហីនោហមស្មីតិ វា ស-
មនុបស្សន្តិ កិមញ្ញត្រ យថាភូតស្ស អទស្សនា ។
អនិច្ចេន វិញ្ញាណេន ទុក្ខេន វិបរិណាមធម្មេន សេ-
យ្យោហមស្មីតិ វា សមនុបស្សន្តិ សទិសោហមស្មីតិ
វា សមនុបស្សន្តិ ហីនោហមស្មីតិ វា សមនុបស្សន្តិ
កិមញ្ញត្រ យថាភូតស្ស អទស្សនា ។

(៩៨) យេ ច ខោ កេចិ សោណ សមណា វា
ព្រាហ្មណា វា អនិច្ចេន រូបេន ទុក្ខេន វិបរិណាមធម្មេន
សេយ្យោហមស្មីតិបិ ន សមនុបស្សន្តិ សទិសោហ-
មស្មីតិបិ ន សមនុបស្សន្តិ ហីនោហមស្មីតិបិ ន ស-
មនុបស្សន្តិ កិមញ្ញត្រ យថាភូតស្ស ទស្សនា ។
អនិច្ចាយ វេទនាយ ។ អនិច្ចាយ សញ្ញាយ ។ អនិច្ចេ-
ហិ សង្ខារេហិ ។ អនិច្ចេន វិញ្ញាណេន ទុក្ខេន វិបរិ-
ណាមធម្មេន សេយ្យោហមស្មីតិបិ ន សមនុបស្សន្តិ

ស្មើនឹងគេក្តី យល់ឃើញថា អាត្មាអញថោកទាបជាងគេក្តី (ឯការយល់ឃើញបែបនេះ) មិនមែនមកអំពីហេតុដទៃទៀតឡើយ គឺមកអំពីការមិនឃើញនូវសេចក្តីពិត ។ មានវិញ្ញាណមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា តែយល់ឃើញថា អាត្មាអញប្រសើរជាងគេក្តី យល់ឃើញថា អាត្មាអញស្មើនឹងគេក្តី យល់ឃើញថា អាត្មាអញថោកទាបជាងគេក្តី (ឯការយល់ឃើញបែបនេះ) មិនមែនមកអំពីហេតុដទៃទៀតឡើយ គឺមកអំពីការមិនឃើញនូវសេចក្តីពិត ។

[៩៨] ម្នាលសោណៈ ពួកសមណៈ ឬព្រាហ្មណ៍ណាមួយ មានរូបមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា មិនយល់ឃើញថា អាត្មាអញប្រសើរជាងគេក្តី មិនយល់ឃើញថា អាត្មាអញស្មើនឹងគេក្តី មិនយល់ឃើញថា អាត្មាអញថោកទាបជាងគេក្តី (ឯការមិនយល់ឃើញបែបនេះ) មិនមែនមកអំពីហេតុដទៃទៀតឡើយ គឺមកអំពីការឃើញនូវសេចក្តីពិត ។ មានវេទនាមិនទៀង ។ មានសញ្ញាមិនទៀង ។ មានសង្ខារមិនទៀង ។ មានវិញ្ញាណមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា មិនយល់ឃើញថា អាត្មាអញប្រសើរជាងគេក្តី

សទិសោហមស្មីតិបិ ន សមនុបស្សេយ្យ ហីនោហមស្មីតិបិ ន សមនុបស្សេយ្យ កិមញ្ញត្រ យថាភូតស្ស ទស្សនា ។

(៩៩) តំ កឹ មញ្ញសិ សោណ រូបំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ វេទនា និច្ចា វា អនិច្ចា វាតិ ។ អនិច្ចា ភន្តេ ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។

មិនយល់ឃើញថា អាត្មាអញស្មើនឹងគេក្តី មិនយល់ឃើញថាអាត្មាអញថោកទាបជាងគេក្តី (ឯការមិនយល់ឃើញបែបនេះ) មិនមែនមកអំពីហេតុអ្វីដទៃឡើយ គឺមកអំពីការឃើញនូវសេចក្តីពិត ។

[៩៩] ម្នាលសោណៈ អ្នកយល់សេចក្តីនោះថាដូចម្តេច រូបទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណា មិនទៀង របស់នោះជាទុក្ខ ឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ណា មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ដូច្នេះឬ ។ មិនគួរយល់ឃើញយ៉ាងនោះទេ ព្រះអង្គ ។ វេទនាទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ដូច្នេះឬ ។ មិនគួរនឹងយល់ឃើញយ៉ាងនុ៎ះទេ ព្រះអង្គ ។

(១០០) តស្មាតិហ សោណ យំ កិញ្ចិ រូបំ អតី-
តានាគតបច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា
សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា
សព្វំ រូបំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ
ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ យា កាចិ
វេទនា ។ យា កាចិ សញ្ញា ។ យេ កេចិ សង្ខារា ។
យំ កិញ្ចិ វិញ្ញាណំ អតីតានាគតបច្ចុប្បន្នំ អជ្ឈត្តំ វា
ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ
វា យំ ទូរេ សន្តិកេ វា សព្វំ វិញ្ញាណំ នេតំ មម
នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ
សម្មប្បញ្ញាយ ទដ្ឋព្វំ ។ ឯវំ បស្សំ សោណ សុតវា
អរិយសាវកោ រូបស្មិំបិ និព្វិន្ទតិ វេទនាយបិ និព្វិន្ទតិ
សញ្ញាយបិ និព្វិន្ទតិ សង្ខារេសុបិ និព្វិន្ទតិ វិញ្ញាណ-
ស្មិំបិ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ វិមុត្តស្មិំ

[១០០] ម្នាលសោណៈ ព្រោះហេតុនោះ រូបណានីមួយ ជាអតីត អនាគត បច្ចុប្បន្ន ជាខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី ឋិតនៅក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី រូបទាំងអស់នោះ គ្រាន់តែជារូប (ប៉ុណ្ណោះឯង) បុគ្គលគួរយល់ឃើញនូវរូបនោះ ដោយប្រាជ្ញាដ៏ប្រពៃតាមពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ វេទនាណាមួយ ។ សញ្ញាណាមួយ ។ សង្ខារទាំងឡាយណាមួយ ។ វិញ្ញាណណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ជាខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី ឋិតនៅក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី វិញ្ញាណទាំងអស់នោះ គ្រាន់តែជាវិញ្ញាណ (ប៉ុណ្ណោះឯង) គួរយល់ឃើញនូវវិញ្ញាណនុ៎ះ ដោយប្រាជ្ញាដ៏ប្រពៃតាមពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ ម្នាលសោណៈ អរិយសាវ័កជាអ្នកចេះដឹង កាលបើឃើញយ៉ាងនេះ រមែងនឿយណាយក្នុងរូបផង នឿយណាយក្នុងវេទនាផង នឿយណាយក្នុងសញ្ញាផង នឿយណាយក្នុងសង្ខារទាំងឡាយផង នឿយណាយក្នុងវិញ្ញាណផង កាលបើនឿយណាយ (យ៉ាងនេះហើយ) រមែងប្រាសចាកតម្រេក ព្រោះប្រាសចាកតម្រេក ចិត្តក៏ផុតស្រឡះ (ចាកអាសវៈ) កាលបើចិត្តផុត

វិមុត្តមិតិ ញាណំ ហោតិ ។ ខីណា ជាតិ វុសិតំ ព្រហ្ម-
ចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជា-
នាតីតិ ។

(១០១) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ អថខោ សោណោ គហបតិបុត្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ សោណំ គហបតិបុត្តំ ភគវា ឯតទវោច យេ ហិ កេចិ សោណ សមណា វា ព្រាហ្មណា វា រូបំ នប្បជានន្តិ រូបសមុទយំ នប្បជានន្តិ រូបនិរោធំ នប្បជានន្តិ រូបនិរោធគាមិនឹបដិបទំ នប្បជានន្តិ ។ វេទនំ នប្បជានន្តិ វេទនាសមុទយំ នប្បជានន្តិ

ស្រឡះហើយ ការដឹងក៏កើតឡើងថា អាត្មាអញរួចស្រឡះហើយ ។ អរិយសាវ័កនោះរមែងដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយធម៌ អាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

(១០១) ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ គ្រានោះឯង សោណគហបតិបុត្តចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះសោណគហបតិបុត្តអង្គុយក្នុងទីសមគួរហើយ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលសោណៈ ពួកសមណៈ ឬព្រាហ្មណ៍ណាមួយ មិនស្គាល់រូប មិនស្គាល់ហេតុ ជាទីកើតឡើងនៃរូប មិនស្គាល់ទីរលត់រូប មិនស្គាល់សេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរលត់រូប ។ មិនស្គាល់វេទនា មិនស្គាល់ហេតុជាទីកើត

វេទនានិរោធំ នប្បជានន្តិ វេទនានិរោធគាមិនីបដិបទំ នប្បជានន្តិ ។ សញ្ញំ នប្បជានន្តិ ។ បេ ។ សង្ខារេ នប្បជានន្តិ សង្ខារសមុទយំ នប្បជានន្តិ សង្ខារនិរោធំ នប្បជានន្តិ សង្ខារនិរោធគាមិនីបដិបទំ នប្បជានន្តិ ។ វិញ្ញាណំ នប្បជានន្តិ វិញ្ញាណសមុទយំ នប្បជានន្តិ វិញ្ញាណនិរោធំ នប្បជានន្តិ វិញ្ញាណនិរោធគាមិនីបដិបទំ នប្បជានន្តិ ។ នមេតេ សោណ សមណា វា ព្រាហ្មណា វា សមណេសុ វា សមណសម្មតា ព្រាហ្មណេសុ វា ព្រាហ្មណសម្មតា ន ច បន តេ អាយស្មន្តោ សាមញ្ញត្ថំ វា ព្រហ្មញ្ញត្ថំ វា ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តិ ។

ឡើងនៃវេទនា មិនស្គាល់ទីរលត់នៃវេទនា មិនស្គាល់សេចក្តីប្រតិបត្តិ ជាដំណើរទៅកាន់ទីរលត់នៃវេទនា ។ មិនស្គាល់សញ្ញា ។ បេ ។ មិនស្គាល់សង្ខារ មិនស្គាល់ហេតុជាទីកើតឡើងនៃសង្ខារ មិនស្គាល់ទីរលត់នៃសង្ខារ មិនស្គាល់សេចក្តីប្រតិបត្តិ ជាដំណើរទៅកាន់ទីរលត់នៃសង្ខារ ។ មិនស្គាល់វិញ្ញាណ មិនស្គាល់ហេតុជាទីកើតឡើងនៃវិញ្ញាណ មិនស្គាល់ទីរលត់នៃវិញ្ញាណ មិនស្គាល់សេចក្តីប្រតិបត្តិ ជាដំណើរទៅកាន់ទីរលត់នៃវិញ្ញាណ ។ ម្នាលសោណៈ សមណៈ ឬព្រាហ្មណ៍ទាំងនុ៎ះ មិនរាប់ថាជាសមណៈក្នុងពួកសមណៈផង មិនរាប់ថាជាព្រាហ្មណ៍ក្នុងពួកព្រាហ្មណ៍ផង មិនតែប៉ុណ្ណោះ សមណៈ ឬព្រាហ្មណ៍មានអាយុទាំងនោះឯង រមែងមិនបានធ្វើឲ្យជាក់ច្បាស់ សម្រេច នូវសាមញ្ញផល ឬព្រាហ្មញ្ញផល ដោយប្រាជ្ញាដ៏ឧត្តមរបស់ខ្លួនឯង ក្នុងបច្ចុប្បន្ននេះបានឡើយ ។

(១០២) យេ ច ខោ កេចិ សោណ សមណា វា ព្រាហ្មណា វា រូបំ បជានន្តិ រូបសមុទយំ បជានន្តិ រូបនិរោធំ បជានន្តិ រូបនិរោធគាមិនីបដិបទំ បជានន្តិ ។ វេទនំ បជានន្តិ ។ បេ ។ សញ្ញំ បជានន្តិ ។ សង្ខារេ បជានន្តិ ។ វិញ្ញាណំ បជានន្តិ វិញ្ញាណសមុទយំ បជានន្តិ វិញ្ញាណនិរោធំ បជានន្តិ វិញ្ញាណនិរោធគាមិនីបដិបទំ បជានន្តិ ។ តេ ខោ មេ សោណ សមណា វា ព្រាហ្មណា វា សមណេសុ ចេវ សមណសម្មតា ព្រាហ្មណេសុ ច ព្រាហ្មណសម្មតា តេ ច បនាយស្មន្តោ សាមញ្ញត្ថញ្ច ព្រហ្មញ្ញត្ថញ្ច ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តីតិ ។

[១០៦] ម្នាលសោណៈ លុះតែពួកសមណៈឬព្រាហ្មណ៍ណា នីមួយ ស្គាល់រូប ស្គាល់ហេតុជាទីកើតឡើងនៃរូប ស្គាល់ទីរលត់នៃរូប ស្គាល់សេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរលត់នៃរូប ។ ស្គាល់វេទនា ។បេ។ ស្គាល់សញ្ញា ។ ស្គាល់សង្ខារទាំងឡាយ ។ ស្គាល់វិញ្ញាណ ស្គាល់ហេតុជាទីកើតឡើងនៃវិញ្ញាណ ស្គាល់សេចក្តីរលត់នៃវិញ្ញាណ ស្គាល់សេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរលត់នៃវិញ្ញាណ ។ ម្នាលសោណៈ សមណៈឬព្រាហ្មណ៍ទាំងនោះឯង ទើបរាប់ថាជាសមណៈក្នុងពួកសមណៈផង រាប់ថាជាព្រាហ្មណ៍ក្នុងពួកព្រាហ្មណ៍ផង មិនតែប៉ុណ្ណោះ សមណៈឬព្រាហ្មណ៍មានអាយុទាំងនោះ រមែងបានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវសាមញ្ញផលផង នូវព្រហ្មញ្ញផលផង ដោយប្រាជ្ញាដ៏ឧត្តមរបស់ខ្លួនឯង ក្នុងបច្ចុប្បន្ននេះ ។

[១០៣] សាវត្ថិយំ ។ តត្រ ខោ ។ បេ ។ ឯតទវោច អនិច្ចញ្ញេវ ភិក្ខវេ ភិក្ខុ រូបំ អនិច្ចន្តិ បស្សតិ សាស្ស(១) ហោតិ សម្មាទិដ្ឋិ សម្មា បស្សំ និព្វិន្ទតិ ។ នន្ទិក្ខយា រាគក្ខយោ រាគក្ខយា នន្ទិក្ខយោ នន្ទិរាគក្ខយា ចិត្តំ វិមុត្តំ សុវិមុត្តន្តិ វុច្ចតិ ។ អនិច្ចញ្ញេវ ភិក្ខវេ ភិក្ខុ វេទនំ អនិច្ចាតិ បស្សតិ សាស្ស ហោតិ សម្មាទិដ្ឋិ សម្មា បស្សំ និព្វិន្ទតិ ។ នន្ទិក្ខយា រាគក្ខយោ រាគក្ខយា នន្ទិក្ខយោ នន្ទិរាគក្ខយា ចិត្តំ វិមុត្តំ សុវិមុត្តន្តិ វុច្ចតិ ។ អនិច្ចញ្ញេវ ភិក្ខវេ ភិក្ខុ សញ្ញំ អនិច្ចាតិ បស្សតិ ។ បេ ។ អនិច្ចេយេវ ភិក្ខវេ ភិក្ខុ សង្ខារេ អនិច្ចាតិ បស្សតិ សាស្ស ហោតិ សម្មាទិដ្ឋិ សម្មា បស្សំ

---

១ ឱ. ម. យាយំ ហោតិ ។

[១០៣] គង់ក្រុងសាវត្ថី ។ គង់ទីនោះឯង ។បេ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុឃើញរូបដែលមិនទៀងពិតថាមិនទៀង ភិក្ខុនោះឈ្មោះថាមានសេចក្តីយល់ឃើញត្រូវ កាលបើភិក្ខុយល់ឃើញត្រូវហើយ រមែងនឿយណាយ ។ ការអស់ទៅនៃតម្រេក ព្រោះអស់ទៅនៃសេចក្តីរីករាយ ការអស់ទៅនៃសេចក្តីរីករាយ ព្រោះការអស់ទៅនៃតម្រេក ចិត្តដែលរួចស្រឡះហើយ ព្រោះអស់ទៅនៃសេចក្តីរីករាយនិងតម្រេក ហៅថារួចស្រឡះដោយប្រពៃ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុឃើញវេទនាដែលមិនទៀងពិតថាមិនទៀង ភិក្ខុនោះឈ្មោះថាមានសេចក្តីយល់ឃើញត្រូវ កាលបើភិក្ខុយល់ឃើញត្រូវហើយ រមែងនឿយណាយ ។ ការអស់ទៅនៃតម្រេក ព្រោះអស់ទៅនៃសេចក្តីរីករាយ ការអស់ទៅនៃសេចក្តីរីករាយ ព្រោះអស់ទៅនៃតម្រេក ចិត្តដែលរួចស្រឡះហើយ ព្រោះការអស់ទៅនៃសេចក្តីរីករាយនិងតម្រេក ហៅថារួចស្រឡះដោយប្រពៃ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុឃើញសញ្ញាដែលមិនទៀងពិតថាមិនទៀង ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុឃើញសង្ខារដែលមិនទៀងពិតថាមិនទៀង ភិក្ខុនោះឈ្មោះថាមានសេចក្តីយល់ឃើញត្រូវ កាលបើភិក្ខុយល់ឃើញត្រូវហើយ

និព្វិន្ទតិ ។ នន្ទិក្ខយា រាគក្ខយោ រាគក្ខយា នន្ទិក្ខ-យោ នន្ទិរាគក្ខយា ចិត្តំ វិមុត្តំ សុវិមុត្តន្តិ វុច្ចតិ ។ អនិច្ចញ្ញេវ ភិក្ខវេ ភិក្ខុ វិញ្ញាណំ អនិច្ចន្តិ បស្សតិ សាស្ស ហោតិ សម្មាទិដ្ឋិ សម្មា បស្សំ និព្វិន្ទតិ ។ នន្ទិក្ខយា រាគក្ខយោ រាគក្ខយា នន្ទិក្ខយោ នន្ទិ-រាគក្ខយា ចិត្តំ វិមុត្តំ សុវិមុត្តន្តិ វុច្ចតីតិ ។

[១០៤] សាវត្ថិយំ ។ តត្រ ខោ ។ បេ ។ ឯតទវោច រូបំ ភិក្ខវេ យោនិសោ មនសិករោថ រូបានិច្ចតញ្ច យថាភូតំ សមនុបស្សថ ។ រូបំ ភិក្ខវេ ភិក្ខុ យោ-និសោ មនសិករោន្តោ រូបានិច្ចតញ្ច យថាភូតំ សមនុ-

រមែងនឿយណាយ ។ ការអស់ទៅនៃតម្រេក ព្រោះអស់ទៅនៃសេចក្តីរីករាយ ការអស់ទៅនៃសេចក្តីរីករាយ ព្រោះអស់ទៅនៃតម្រេក ចិត្តដែលរួចស្រឡះហើយ ព្រោះការអស់ទៅនៃសេចក្តីរីករាយនិងតម្រេក ហៅថារួចស្រឡះដោយប្រពៃ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុឃើញវិញ្ញាណដែលមិនទៀងពិតថាមិនទៀង ភិក្ខុនោះឈ្មោះថាមានសេចក្តីយល់ឃើញត្រូវ កាលបើភិក្ខុយល់ឃើញត្រូវហើយ រមែងនឿយណាយ ។ ការអស់ទៅនៃតម្រេក ព្រោះអស់ទៅនៃសេចក្តីរីករាយ ការអស់ទៅនៃសេចក្តីរីករាយ ព្រោះអស់ទៅនៃតម្រេក ចិត្តដែលរួចស្រឡះហើយ ព្រោះការអស់ទៅនៃសេចក្តីរីករាយនិងតម្រេក ហៅថារួចស្រឡះដោយប្រពៃ ។

[១០៤] គង់ក្រុងសាវត្ថី ។ គង់ទីនោះឯង ។ បេ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរធ្វើទុកក្នុងចិត្តចំពោះរូបដោយឧបាយផង ចូរពិចារណាតាមពិតនូវរូបថាមានសេចក្តីមិនទៀងផង ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុធ្វើទុកក្នុងចិត្តចំពោះរូបដោយឧបាយផង ពិចារណាឃើញតាមពិតនូវរូបថាមានសេចក្តី

បស្សន្តោ រូបស្មឹ និព្វិន្ទតិ ។ នន្ទិក្ខយា រាគក្ខ-
យោ រាគក្ខយា នន្ទិក្ខយោ នន្ទិរាគក្ខយា ចិត្តំ វិមុត្តំ
សុវិមុត្តន្តិ វុច្ចតិ ។ វេទនំ ភិក្ខវេ យោនិសោ មនសិ-
ករោថ វេទនានិច្ចតញ្ច យថាភូតំ សមនុបស្សថ ។
វេទនំ ភិក្ខវេ ភិក្ខុ យោនិសោ មនសិករោន្តោ វេ-
ទនានិច្ចតញ្ច យថាភូតំ សមនុបស្សន្តោ វេទនាយ
និព្វិន្ទតិ ។ នន្ទិក្ខយា រាគក្ខយោ រាគក្ខយា នន្ទិក្ខ-
យោ នន្ទិរាគក្ខយា ចិត្តំ វិមុត្តំ សុវិមុត្តន្តិ វុច្ចតិ ។
សញ្ញំ ភិក្ខវេ ។ សង្ខារេ ភិក្ខវេ យោនិសោ មន-
សិករោថ សង្ខារានិច្ចតញ្ច យថាភូតំ សមនុបស្ស-
ថ ។ សង្ខារេ ភិក្ខវេ ភិក្ខុ យោនិសោ មនសិក-
រោន្តោ សង្ខារានិច្ចតញ្ច យថាភូតំ សមនុបស្សន្តោ

មិនទៀងផងហើយ រមែងនឿយណាយក្នុងរូប ។ ការអស់ទៅនៃតម្រេក ព្រោះអស់ទៅនៃសេចក្តីរីករាយ ការអស់ទៅនៃសេចក្តីរីករាយ ព្រោះអស់ទៅនៃតម្រេក ចិត្តដែលរួចស្រឡះហើយ ព្រោះអស់ទៅនៃសេចក្តីរីករាយនិងតម្រេក ហៅថារួចស្រឡះដោយប្រពៃ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរធ្វើទុកក្នុងចិត្ត ចំពោះវេទនាដោយឧបាយផង ចូរពិចារណាតាមពិតនូវវេទនាថាមានសេចក្តីមិនទៀងផង ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុធ្វើទុកក្នុងចិត្ត ចំពោះវេទនាដោយឧបាយ ពិចារណាតាមពិតនូវវេទនាថាមានសេចក្តីមិនទៀងហើយ រមែងនឿយណាយក្នុងវេទនា ។ ការអស់ទៅនៃតម្រេក ព្រោះការអស់ទៅនៃសេចក្តីរីករាយ ការអស់ទៅនៃសេចក្តីរីករាយ ព្រោះការអស់ទៅនៃតម្រេក ចិត្តដែលរួចស្រឡះហើយ ព្រោះការអស់ទៅនៃសេចក្តីរីករាយ និងតម្រេក ហៅថារួចស្រឡះដោយប្រពៃ ។ ម្នាលភិក្ខុទាំងឡាយ (អ្នកទាំងឡាយចូរធ្វើទុកក្នុងចិត្ត) ចំពោះសញ្ញា ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរធ្វើទុកក្នុងចិត្ត ចំពោះសង្ខារដោយឧបាយផង ចូរពិចារណាតាមពិត នូវសង្ខារថាមានសេចក្តីមិនទៀងផង ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុធ្វើទុកក្នុងចិត្ត ចំពោះសង្ខារដោយឧបាយ ពិចារណាតាមពិតនូវសង្ខារថាមានសេចក្តីមិនទៀងហើយ រមែងនឿយណាយក្នុងសង្ខារ ។

សង្ខារេសុ និព្វិន្ទតិ ។ នន្ទិក្ខយា រាគក្ខយោ រាគក្ខយា នន្ទិក្ខយោ នន្ទិរាគក្ខយា ចិត្តំ វិមុត្តំ សុវិមុត្តន្តិ វុច្ចតិ ។ វិញ្ញាណំ ភិក្ខវេ យោនិសោ មនសិករោថ វិញ្ញាណានិច្ចតញ្ច យថាភូតំ សមនុបស្សថ ។ វិញ្ញាណំ ភិក្ខវេ ភិក្ខុ យោនិសោ មនសិករោន្តោ វិញ្ញាណានិច្ចតញ្ច យថាភូតំ សមនុបស្សន្តោ វិញ្ញាណស្មឹ និព្វិន្ទតិ ។ នន្ទិក្ខយា រាគក្ខយោ រាគក្ខយា នន្ទិក្ខយោ នន្ទិរាគក្ខយា ចិត្តំ វិមុត្តំ សុវិមុត្តន្តិ វុច្ចតីតិ ។

អត្តទីបវគ្គោ បញ្ចមោ ។

ការអស់ទៅនៃតម្រេក ព្រោះការអស់ទៅនៃសេចក្តីរីករាយ ការអស់ទៅនៃសេចក្តីរីករាយ ព្រោះការអស់ទៅនៃតម្រេក ចិត្តដែលរួចស្រឡះហើយ ព្រោះការអស់ទៅនៃសេចក្តីរីករាយនិងតម្រេក ហៅថារួចស្រឡះដោយប្រពៃ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរធ្វើទុកក្នុងចិត្តបំពោះវិញ្ញាណដោយឧបាយផង ចូរពិចារណាតាមពិតនូវវិញ្ញាណថាមានសេចក្តីមិនទៀងផង ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុធ្វើទុកក្នុងចិត្តបំពោះវិញ្ញាណដោយឧបាយ ពិចារណាតាមពិតនូវវិញ្ញាណថា មានសេចក្តីមិនទៀងហើយ រមែងនឿយណាយក្នុងវិញ្ញាណ ។ ការអស់ទៅនៃតម្រេក ព្រោះការអស់ទៅនៃសេចក្តីរីករាយ ការអស់ទៅនៃសេចក្តីរីករាយ ព្រោះការអស់ទៅនៃតម្រេក ចិត្តដែលរួចស្រឡះហើយ ព្រោះការអស់ទៅនៃសេចក្តីរីករាយនិងតម្រេក ហៅថារួចស្រឡះដោយប្រពៃ ។

ចប់អត្តទីបវគ្គទី ៥ ។

## តស្សុទ្ទានំ

អត្តទីបា បដិបទា
ទ្វេ ច ហោន្តិ អនិច្ចតា
សមនុបស្សនា ខន្ធា
ទ្វេ សោណា ទ្វេ នន្ទិក្ខយេន ចាតិ ។

មូលបណ្ណាសកំ សមត្តំ ។

## តស្ស មូលបណ្ណាសកវគ្គស្សុទ្ទានំ

នកុលបិតា អនិច្ចោ ច
ភារេន នតុម្ហាកេន ច
អត្តទីបេន បណ្ណាសោ
បឋមោ តេន វុច្ចតីតិ ។

## ឧទ្ទាននៃអត្តទីបវគ្គនោះគឺ

និយាយអំពីការយកខ្លួនជាទីពឹង អំពីបដិបទា អំពីសេចក្តីមិនទៀងមានពីរលើក អំពីការពិចារណាឃើញ អំពីខន្ធ អំពីសោណគហបតិបុត្តមានពីរលើក អំពីការអស់ទៅនៃសេចក្តីរីករាយមានពីរលើក ។

ចប់ មូលបណ្ណាសកៈ ។

## ឧទ្ទាននៃមូលបណ្ណាសកវគ្គនោះគឺ

នកុលបិតវគ្គ ១ អនិច្ចវគ្គ ១ ភារវគ្គ ១ នតុម្ហាកវគ្គ ១ អត្តទីបវគ្គ ១ ដែលលោកចាត់ថាជាបឋមបណ្ណាសកៈ ។

# ឧបាយវគ្គោ

[១០៩] សាវត្ថិយំ ។ តត្រ ខោ ។ បេ ។ ឯតទវោច

ឧបាយោ ភិក្ខវេ អវិមុត្តោ អនុបាយោ វិមុត្តោ ។ រូបុបាយំ វា ភិក្ខវេ វិញ្ញាណំ តិដ្ឋមានំ តិដ្ឋេយ្យ រូបារម្មណំ រូបប្បតិដ្ឋំ នន្ទូបសេចនំ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជេយ្យ ។ បេ ។ សង្ខារុបាយំ វា ភិក្ខវេ វិញ្ញាណំ តិដ្ឋមានំ តិដ្ឋេយ្យ សង្ខារារម្មណំ សង្ខារប្បតិដ្ឋំ នន្ទូបសេចនំ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជេយ្យ ។ យោ ភិក្ខវេ ឯវំ វទេយ្យ អហំ អញ្ញត្រ រូបា អញ្ញត្រ វេទនាយ អញ្ញត្រ សញ្ញាយ អញ្ញត្រ សង្ខារេហិ វិញ្ញាណស្ស អាគតឹ វា គតឹ វា ចុតឹ

# ឧបាយវគ្គ

[១០៥) ក្នុងក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ បេ ។ ព្រះមានព្រះភាគបានត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ សភាវៈដែលប្រកាន់មាំ (នូវខន្ធ ៥ ដោយអំណាច តណ្ហា មានះ ទិដ្ឋិ) រមែងមិនរួចផុតស្រឡះឡើយ សភាវៈដែលមិនបានប្រកាន់មាំ (នូវខន្ធ៥ ដោយអំណាច តណ្ហា មានះ ទិដ្ឋិ) ទើបរួចផុតស្រឡះបាន ។ ម្នាលភិក្ខុទាំងឡាយ វិញ្ញាណមានរូបជាហេតុ កាលនឹងឋិតនៅ ក៏ឋិតនៅបាន រូបារម្មណ៍មានរូបជាទីតាំង មានកិរិយាចូលទៅជិតសេពនូវសេចក្តីរីករាយ ដល់នូវសេចក្តីចម្រើន ដុះដាល ធំទូលាយឡើង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ វិញ្ញាណមានសង្ខារជាហេតុ កាលឋិតនៅ ក៏ឋិតនៅបាន សង្ខារារម្មណ៍មានសង្ខារជាទីតាំង មានកិរិយាចូលទៅជិតសេពនូវសេចក្តីរីករាយ ដល់នូវសេចក្តីចម្រើន ដុះដាល ធំទូលាយឡើង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលណា និយាយយ៉ាងនេះថា អាត្មាអញបើទុកជាវៀរចាករូប វៀរចាកវេទនា វៀរចាកសញ្ញា វៀរចាកសង្ខារទាំងឡាយហើយ ក៏គង់តែដឹងនូវដំណើរមក ឬដំណើរទៅ ការច្យុត

វា ឧបបត្តឹ វា វុឌ្ឍឹ វា វិរូឡ្ហឹ វា វេបុល្លំ វា បញ្ញបេស្សាមីតិ នេតំ ឋានំ វិជ្ជតិ ។ រូបធាតុយា ចេ ភិក្ខវេ ភិក្ខុនោ ។ វេទនាធាតុយា ចេ ភិក្ខវេ ភិក្ខុនោ ។ សញ្ញាធាតុយា ចេ ភិក្ខវេ ភិក្ខុនោ ។ សង្ខារធាតុយា ចេ ភិក្ខវេ ភិក្ខុនោ ។ វិញ្ញាណធាតុយា ចេ ភិក្ខវេ ភិក្ខុនោ រាគោ បហីនោ ហោតិ រាគស្ស បហានា វោច្ឆិជ្ជតារម្មណំ បតិដ្ឋា វិញ្ញាណស្ស ន ហោតិ តទប្បតិដ្ឋិតំ វិញ្ញាណំ អវិរូឡ្ហំ អនភិសង្ខច្ច វិមុត្តំ វិមុត្តត្តា ឋិតំ ឋិតត្តា សន្តុសិតំ សន្តុសិតត្តា ន បរិតស្សតិ អបរិតស្សំ បច្ចត្តញ្ញេវ បរិនិព្វាយតិ ។ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

ឬការកើត ការចម្រើន ឬការដុះដាល ធំទូលាយ របស់វិញ្ញាណបាន ពាក្យនេះមិនសមហេតុឡើយ ។ ម្នាលភិក្ខុទាំងឡាយ បើសេចក្តីត្រេកអរក្នុងរូបធាតុ ភិក្ខុបានលះបង់ហើយ ។ ម្នាលភិក្ខុទាំងឡាយ បើសេចក្តីត្រេកអរ ក្នុងវេទនាធាតុ ភិក្ខុបានលះបង់ហើយ ។ ម្នាលភិក្ខុទាំងឡាយ បើសេចក្តីត្រេកអរក្នុងសញ្ញាធាតុ ភិក្ខុបានលះបង់ហើយហើយ ។ ម្នាលភិក្ខុទាំងឡាយ បើសេចក្តីត្រេកអរ ក្នុងសង្ខារធាតុ ភិក្ខុបានលះបង់ហើយ ។ ម្នាលភិក្ខុទាំងឡាយ បើសេចក្តីត្រេកអរ ក្នុងវិញ្ញាណធាតុ ភិក្ខុបានលះបង់ហើយ ព្រោះបានលះបង់នូវសេចក្តីត្រេកអរ អារម្មណ៍ក៏ដាច់ចេញ ការទីពឹងរបស់វិញ្ញាណ ក៏មិនមាន វិញ្ញាណនោះបើមិនមានទីពឹងហើយ ក៏មិនដុះដាលឡើងបានឡើយ សឹងផុតស្រឡះ ព្រោះមិនបានតាក់តែងនូវបដិសន្ធិទៀត ព្រោះផុតស្រឡះហើយ ក៏រមែងតម្កល់នៅ ព្រោះតម្កល់នៅហើយ ក៏រមែងត្រេកអរ ព្រោះត្រេកអរហើយ ក៏រមែងមិនតក់ស្លុត កាលបើមិនតក់ស្លុតហើយ រមែងបរិនិព្វានដោយខ្លួនឯង ។ ភិក្ខុនោះដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញក៏បាននៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

[១០៦] សាវត្ថិយំ ។ តត្រ ខោ ។ បញ្ចិមានិ ភិក្ខវេ ពីជជាតានិ ។ កតមានិ បញ្ច ។ មូលពីជំ ខន្ធពីជំ ផលុពីជំ អគ្គពីជំ ពីជពីជញ្ញេវ បញ្ចមំ ។ ឥមានិ ចស្សុ ភិក្ខវេ បញ្ច ពីជជាតានិ អខណ្ឌានិ អបូតិកានិ អវាតាតបប្បហតានិ[១] សារាទានិ សុខសយិតានិ បឋវី ច នាស្ស អាបោ ច នាស្ស ។ អបិ នុមានិ ភិក្ខវេ បញ្ច ពីជជាតានិ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជេយ្យុន្តិ ។ នោ ហេតំ ភន្តេ ។ ឥមានិ ចស្សុ ភិក្ខវេ បញ្ច ពីជជាតានិ អខណ្ឌានិ ។ បេ ។ សុខសយិតានិ បឋវី ច អស្ស អាបោ ច អស្ស ។ អបិ នុមានិ ភិក្ខវេ បញ្ច ពីជជាតានិ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជេយ្យុន្តិ ។ ឯវំ ភន្តេ ។

១ ឱ. ម. អវាតាតបហតានិ ។

(១០៦) ក្នុងក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ពូជទាំងឡាយនេះ មាន៥ប្រការ ។ ពូជ៥ប្រការ តើអ្វីខ្លះ ។ គឺពូជកើតពីមើម១ ពូជកើតពីដើម១ ពូជកើតពីថ្នាំង១ ពូជកើតពីត្រួយ ១ និងពូជកើតពីគ្រាប់ ១ ជាគម្រប់៥ ។ ម្នាលភិក្ខុទាំងឡាយ ចុះបើពូជទាំង៥ប្រការនេះ មិនបាក់ មិនស្អុយ មិនវិនាស ដោយខ្យល់ និងកំដៅថ្ងៃ គួរកាន់យកនូវខ្លឹម នៅជាសុខ តែដីក៏គ្មាន ទឹកក៏គ្មាន ។ ម្នាលភិក្ខុទាំងឡាយ (កាលបើដូច្នេះ) ពូជទាំង៥ប្រការនេះ តើគួរនឹងដល់នូវសេចក្តីចម្រើន ដុះដាល ធំទូលាយឡើងបាន ដែរឬ ។ មិនបានទេ ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ ចុះបើពូជទាំង៥ប្រការនេះ មិនបាក់ ។បេ។ នៅជាសុខ ទាំងដីក៏មាន ទឹកក៏មាន ។ ម្នាលភិក្ខុទាំងឡាយ (កាលបើដូច្នេះ) ពូជទាំង៥នេះ តើគួរនឹងដល់នូវសេចក្តីចម្រើន ដុះដាល ធំទូលាយឡើងបាន ដែរឬ ។ ព្រះករុណា ព្រះអង្គ ។

(១០៧) សេយ្យថាបិ ភិក្ខវេ បថវីធាតុ ឯវំ ចតស្សោ វិញ្ញាណដ្ឋិតិយោ ទដ្ឋព្វា ។ សេយ្យថាបិ ភិក្ខវេ អាបោធាតុ ឯវំ នន្ទិរាគោ ទដ្ឋព្វោ ។ សេយ្យថាបិ ភិក្ខវេ បញ្ច ពីជជាតានិ ឯវំ វិញ្ញាណំ សាហារំ ទដ្ឋព្វំ ។ រូបូបាយំ វា ភិក្ខវេ វិញ្ញាណំ តិដ្ឋមានំ តិដ្ឋេយ្យ រូបារម្មណំ រូបប្បតិដ្ឋំ នន្ទូបសេចនំ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជេយ្យ ។ វេទនូបាយំ វា ភិក្ខវេ វិញ្ញាណំ តិដ្ឋមានំ តិដ្ឋេយ្យ ។ បេ ។ នន្ទូបសេចនំ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជេយ្យ ។ សញ្ញូបាយំ វា ។ បេ ។ សង្ខារូបាយំ វា ភិក្ខវេ វិញ្ញាណំ តិដ្ឋមានំ តិដ្ឋេយ្យ សង្ខារារម្មណំ សង្ខារប្បតិដ្ឋំ នន្ទូបសេចនំ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជេយ្យ ។ យោ ភិក្ខវេ ឯវំ វទេយ្យ អហំ អញ្ញត្រ រូបា អញ្ញត្រ វេទនាយ អញ្ញត្រ សញ្ញាយ

(១០៧) ម្នាលភិក្ខុទាំងឡាយ បឋវីធាតុ យ៉ាងណា វិញ្ញាណដ្ឋិតិ (ទីតម្កល់នៅនៃវិញ្ញាណ) ទាំង ៤ អ្នកទាំងឡាយក៏គប្បីឃើញ យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ អាបោធាតុយ៉ាងណា សេចក្តីរីករាយនិងសេចក្តីត្រេកអរ អ្នកទាំងឡាយក៏គប្បីឃើញ យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ពូជទាំង ៥ ប្រការ យ៉ាងណា វិញ្ញាណដែលប្រកបដោយអាហារ អ្នកទាំងឡាយក៏គប្បីឃើញ យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ វិញ្ញាណមានរូបជាហេតុ កាលដែលឋិតនៅ ក៏ឋិតនៅបាន រូបារម្មណ៍មានរូបជាទីតាំង មានកិរិយាចូលទៅជិតសេពនូវសេចក្តីរីករាយ ដល់នូវសេចក្តីចម្រើន ដុះដាល ធំទូលាយឡើងបាន ។ ម្នាលភិក្ខុទាំងឡាយ វិញ្ញាណមានវេទនាជាហេតុ កាលឋិតនៅ ក៏ឋិតនៅបាន ។ បេ ។ មានកិរិយាចូលទៅជិតសេពនូវសេចក្តីរីករាយ ដល់នូវសេចក្តីចម្រើន ដុះដាល ធំទូលាយឡើងបាន ។ មានសញ្ញា ជាហេតុ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ វិញ្ញាណ មានសង្ខារជាហេតុ កាលឋិតនៅ ក៏ឋិតនៅបាន សង្ខារារម្មណ៍មានសង្ខារជាទីតាំង មានកិរិយាចូលទៅជិតសេពនូវសេចក្តីរីករាយ ដល់នូវសេចក្តីចម្រើន ដុះដាល ធំទូលាយឡើងបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលណានិយាយយ៉ាងនេះថា អាត្មាអញទោះបីវៀរចាករូប វៀរចាកវេទនា វៀរចាកសញ្ញា

អញ្ញត្រ សង្ខារេហិ វិញ្ញាណស្ស អាគតឹ វា គតឹ វា ចុតឹ វា ឧបបត្តឹ វា វុឌ្ឍឹ វា វិរូឡ្ហឹ វា វេបុល្លំ វា បញ្ញបេស្សាមីតិ នេតំ ឋានំ វិជ្ជតិ ។ រូបធាតុយា ចេ ភិក្ខវេ ភិក្ខុនោ រាគោ បហីនោ ហោតិ រាគស្ស បហានា វោច្ឆិជ្ជតារម្មណំ បតិដ្ឋា វិញ្ញាណស្ស ន ហោតិ ។ វេទនាធាតុយា ចេ ។ សញ្ញាធាតុយា ចេ ។ សង្ខារធាតុយា ចេ ។ វិញ្ញាណធាតុយា ចេ ភិក្ខវេ ភិក្ខុនោ រាគោ បហីនោ ហោតិ រាគស្ស បហានា វោច្ឆិជ្ជតារម្មណំ បតិដ្ឋា វិញ្ញាណស្ស ន ហោតិ ។ តទប្បតិដ្ឋិតំ វិញ្ញាណំ អវិរូឡ្ហំ អនភិសង្ខច្ច(១ វិមុត្តំ វិមុត្តត្តា ឋិតំ ឋិតត្តា សន្តុសិតំ សន្តុសិតត្តា ន បរិតស្សតិ អបរិតស្សំ បច្ចត្តញ្ញេវ បរិនិព្វាយតិ ។ ខីណា ជាតិ ។បេ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

១ ឱ. ម. អនភិសង្ខារញ្ច ។

វៀរចាកសង្ខារទាំងឡាយ ក៏គង់តែដឹងនូវដំណើរមក ឬដំណើរទៅ ការឃ្លាត ឬការកើត ការចម្រើន ឬការដុះដាល ធំទូលាយ នៃវិញ្ញាណបាន ពាក្យនេះមិនសមហេតុឡើយ ។ ម្នាលភិក្ខុទាំងឡាយ បើសេចក្ដីត្រេកអរក្នុងរូបធាតុ ភិក្ខុបានលះបង់ហើយ ព្រោះលះបង់នូវសេចក្ដីត្រេកអរហើយ អារម្មណ៍ក៏ដាច់ចេញ ការទំពឹងរបស់វិញ្ញាណក៏មិនមាន ។ បើសេចក្ដីត្រេកអរក្នុងវេទនាធាតុ ។ ក្នុងសញ្ញាធាតុ ។ ក្នុងសង្ខារធាតុ ។ ម្នាលភិក្ខុទាំងឡាយ បើសេចក្ដីត្រេកអរក្នុងវិញ្ញាណធាតុ ភិក្ខុបានលះបង់ហើយ ព្រោះលះបង់នូវសេចក្ដីត្រេកអរហើយ អារម្មណ៍ក៏ដាច់ចេញ ការទំពឹងរបស់វិញ្ញាណក៏មិនមាន ។ វិញ្ញាណនោះ បើឥតមានទីពឹងហើយ ក៏មិនដុះដាលឡើងបានឡើយ សឹងផុតស្រឡះ ព្រោះមិនតាក់តែងនូវបដិសន្ធិទៀត ព្រោះផុតស្រឡះហើយ ក៏រមែងតម្កល់នៅ ព្រោះតម្កល់នៅហើយ ក៏រមែងត្រេកអរ ព្រោះត្រេកអរហើយ ក៏រមែងមិនតក់ស្លុត កាលបើមិនតក់ស្លុតហើយ ទើបបរិនិព្វានដោយខ្លួនឯង ។ ភិក្ខុនោះក៏ដឹងច្បាស់ថា ជាតិអស់ហើយ ។ បេ ។ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

(១០៨) សាវត្ថិយំ ។ តត្រ ខោ ។ ភគវា ឧទានំ ឧទានេសិ នោ ចស្សំ នោ ច មេ សិយា ន ភវិស្សតិ ន មេ ភវិស្សតីតិ ឯវំ វិមុច្ចមានោ(១) ភិក្ខុ ឆិន្ទេយ្យ ឱរម្ភាគិយានិ សញ្ញោជនានីតិ ។

(១០៩) ឯវំ វុត្តេ អញ្ញតរោ ភិក្ខុ ភគវន្តំ ឯតទវោច យថាកថំ បន ភន្តេ នោ ចស្សំ នោ ច មេ សិយា ន ភវិស្សតិ ន មេ ភវិស្សតីតិ ឯវំ វិមុច្ចមានោ ភិក្ខុ ឆិន្ទេយ្យ ឱរម្ភាគិយានិ សញ្ញោជនានីតិ ។ ឥធ ភិក្ខុ អស្សុតវា បុថុជ្ជនោ អរិយានំ អទស្សាវី ។ បេ ។ សប្បុរិសធម្មេ អវិនីតោ រូបំ អត្តតោ សមនុបស្សតិ

---

១ អធិមុច្ចមានោ ។

[១០៨] ក្នុងក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ព្រះមានព្រះភាគ ទ្រង់បន្លឺនូវឧទានថា ភិក្ខុកាលចុះចិត្តស៊ប់យ៉ាងនេះថា បើអាត្មាអញនឹងមិនមានទេ (បរិក្ខារ) របស់អាត្មាអញក៏នឹងមិនមាន (បើការកសាងនូវកម្មទុកទៅក្នុងអនាគត) នឹងមិនមានទេ (បដិសន្ធិ) របស់អាត្មាអញ (ក្នុងអនាគត) ក៏នឹងមិនមាន ដូច្នេះហើយ ទើបគួរកាត់នូវសញ្ញោជនៈ ដែលជាចំណែកខាងក្រោមបាន ។

[១០៩] កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ មានភិក្ខុមួយរូប ក្រាបទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ចុះភិក្ខុកាលចុះចិត្តស៊ប់យ៉ាងនេះថា បើអាត្មាអញនឹងមិនមានទេ (បរិក្ខារ) របស់អាត្មាអញក៏នឹងមិនមាន (បើការកសាងនូវកម្មទុកទៅក្នុងអនាគត) នឹងមិនមានទេ (បដិសន្ធិ) របស់អាត្មាអញ (ក្នុងអនាគត) ក៏នឹងមិនមានដែរ ដូច្នេះហើយ ទើបគួរកាត់នូវសញ្ញោជនៈ ជាចំណែកខាងក្រោមបាន តើដូចម្ដេច ។ ម្នាលភិក្ខុ ភិក្ខុក្នុងសាសនានេះ មិនបានចេះដឹង នៅជាបុថុជ្ជន មិនបានឃើញព្រះអរិយៈទាំងឡាយ ។បេ។ មិនបានទូន្មានខ្លួនក្នុងសប្បុរិសធម៌ហើយ ក៏រមែងពិចារណាឃើញរូបថាជាខ្លួនខ្លះ

រូបវន្តំ វា អត្តានំ អត្តនិ វា រូបំ រូបស្មឹ វា អត្តានំ ។ វេទនំ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ អត្តតោ សមនុបស្សតិ វិញ្ញាណវន្តំ វា អត្តានំ អត្តនិ វា វិញ្ញាណំ វិញ្ញាណស្មឹ វា អត្តានំ ។ សោ អនិច្ចំ រូបំ អនិច្ចំ រូបន្តិ យថាភូតំ នប្បជានាតិ អនិច្ចំ វេទនំ អនិច្ចា វេទនាតិ យថាភូតំ នប្បជានាតិ អនិច្ចំ សញ្ញំ អនិច្ចា សញ្ញាតិ យថាភូតំ នប្បជានាតិ អនិច្ចេ សង្ខារេ អនិច្ចា សង្ខារាតិ យថាភូតំ នប្បជានាតិ អនិច្ចំ វិញ្ញាណំ អនិច្ចំ វិញ្ញាណន្តិ យថាភូតំ នប្បជានាតិ ។ ទុក្ខំ រូបំ ទុក្ខំ រូបន្តិ យថាភូតំ នប្បជានាតិ ។ ទុក្ខំ រូបំ ទុក្ខំ សញ្ញំ ។ ទុក្ខេ សង្ខារេ ។ ទុក្ខំ វិញ្ញាណំ ទុក្ខំ វិញ្ញាណន្តិ យថាភូតំ នប្បជានាតិ ។ អនត្តំ រូបំ អនត្តំ រូបន្តិ យថាភូតំ នប្បជានាតិ ។ អនត្តំ វេទនំ ។ អនត្តំ សញ្ញំ ។

ឃើញខ្លួនថាមានរូបខ្លះ ឃើញរូបថាមានក្នុងខ្លួនខ្លះ ឃើញខ្លួនថាមានក្នុងរូបខ្លះ ។ នូវវេទនា ។ នូវសញ្ញា ។ នូវសង្ខារទាំងឡាយ ។ ឃើញនូវវិញ្ញាណថាជាខ្លួនខ្លះ ឃើញនូវខ្លួនថាមានវិញ្ញាណខ្លះ ឃើញវិញ្ញាណថាមានក្នុងខ្លួនខ្លះ ឃើញនូវខ្លួនថាមានក្នុងវិញ្ញាណខ្លះ ។ ភិក្ខុនោះ មិនដឹងច្បាស់តាមពិត នូវរូបមិនទៀង ថារូបមិនទៀង មិនដឹងច្បាស់តាមពិត នូវវេទនាមិនទៀង ថាវេទនាមិនទៀង មិនដឹងច្បាស់តាមពិត នូវសញ្ញាមិនទៀង ថាសញ្ញាមិនទៀង មិនដឹងច្បាស់តាមពិត នូវសង្ខារទាំង-ឡាយមិនទៀងថា សង្ខារទាំងឡាយមិនទៀង មិនដឹងច្បាស់តាមពិត នូវវិញ្ញាណមិនទៀង ថាវិញ្ញាណមិនទៀង ។ មិនដឹងច្បាស់តាមពិត នូវរូបជាទុក្ខ ថារូបជាទុក្ខ ។ នូវវេទនាជាទុក្ខ ។ នូវសញ្ញាជាទុក្ខ ។ នូវសង្ខារទាំងឡាយជាទុក្ខ ។ មិនដឹងច្បាស់តាមពិត នូវវិញ្ញាណជាទុក្ខ ថាវិញ្ញាណជាទុក្ខ ។ មិនដឹងច្បាស់តាមពិត នូវរូបជាអនត្តា ថារូបជាអនត្តា ។ នូវវេទនា ជាអនត្តា ។ នូវសញ្ញា ជាអនត្តា ។

អនត្តេ សង្ខារេ ។ អនត្តំ វិញ្ញាណំ អនត្តំ វិញ្ញាណន្តិ យថាភូតំ នប្បជានាតិ ។ សង្ខតំ រូបំ សង្ខតំ រូបន្តិ យថាភូតំ នប្បជានាតិ ។ សង្ខតំ វេទនំ ។ សង្ខតំ សញ្ញំ ។ សង្ខតេ សង្ខារេ ។ សង្ខតំ វិញ្ញាណំ សង្ខតំ វិញ្ញាណន្តិ យថាភូតំ នប្បជានាតិ ។ រូបំបិ ភវិស្សតីតិ យថាភូតំ នប្បជានាតិ ។ វេទនាបិ ភវិស្សតិ ។ សញ្ញាបិ ភវិស្សតិ ។ សង្ខារាបិ ភវិស្សន្តិ ។ វិញ្ញាណម្បិ ភវិស្សតីតិ យថាភូតំ នប្បជានាតិ ។

(១០០) សុតវា ច ខោ ភិក្ខុ(១) អរិយសាវកោ អរិយានំ ទស្សាវី អរិយធម្មស្ស កោវិទោ អរិយធម្មេ សុវិនីតោ សប្បុរិសានំ ទស្សាវី សប្បុរិសធម្មស្ស កោវិទោ សប្បុរិសធម្មេ សុវិនីតោ ន រូបំ អត្តតោ សមនុបស្សតិ ។ បេ ។ ន វេទនំ ។ ន សញ្ញំ ។ ន សង្ខារេ ។

---

១ ភិក្ខវេ ។

នូវសង្ខារទាំងឡាយជាអនត្តា ៗ មិនដឹងច្បាស់តាមពិត នូវវិញ្ញាណជាអនត្តា ថាវិញ្ញាណជាអនត្តា ៗ មិនដឹងច្បាស់តាមពិត នូវរូបដែលមានបច្ច័យប្រជុំតាក់តែង ថារូបមានបច្ច័យប្រជុំតាក់តែង ៗ នូវវេទនាដែលមានបច្ច័យប្រជុំតាក់តែង ៗ នូវសញ្ញាដែលមានបច្ច័យប្រជុំតាក់តែង ៗ នូវសង្ខារទាំងឡាយ ដែលមានបច្ច័យប្រជុំតាក់តែង ៗ មិនដឹងច្បាស់តាមពិត នូវវិញ្ញាណដែលមានបច្ច័យប្រជុំតាក់តែង ថាវិញ្ញាណមានបច្ច័យប្រជុំតាក់តែង ៗ មិនដឹងច្បាស់តាមពិត ថារូបនឹងមាន ៗ ថាវេទនានឹងមាន ៗ ថាសញ្ញានឹងមាន ៗ ថាសង្ខារទាំងឡាយនឹងមាន ៗ មិនដឹងច្បាស់តាមពិត ថាវិញ្ញាណនឹងមាន ដូច្នេះឡើយ ។

(១១០) ម្នាលភិក្ខុ អរិយសាវ័កជាអ្នកចេះដឹង បានឃើញនូវព្រះអរិយៈទាំងឡាយ អ្នកឈ្លាសវៃក្នុងអរិយធម៌ បានទូន្មានខ្លួនក្នុងអរិយធម៌ ឃើញនូវសប្បុរសទាំងឡាយ អ្នកឈ្លាសវៃក្នុងសប្បុរិសធម៌ បានទូន្មានខ្លួនក្នុងសប្បុរិសធម៌ ក៏រមែងមិនពិចារណាឃើញរូបថាជាខ្លួនខ្លះ ៗ បេ ៗ មិនឃើញវេទនា ៗ មិនឃើញសញ្ញា ៗ មិនឃើញសង្ខារទាំងឡាយ ៗ

ន វិញ្ញាណំ អត្តតោ សមនុបស្សតិ ។ សោ អនិច្ចំ រូបំ អនិច្ចំ រូបន្តិ យថាភូតំ បជានាតិ ។ អនិច្ចំ វេទនំ ។ អនិច្ចំ សញ្ញំ ។ អនិច្ចេ សង្ខារេ ។ អនិច្ចំ វិញ្ញាណំ អនិច្ចំ វិញ្ញាណន្តិ យថាភូតំ បជានាតិ ។ ទុក្ខំ រូបំ ។ បេ ។ ទុក្ខំ វិញ្ញាណំ ។ អនត្តំ រូបំ ។ បេ ។ អនត្តំ វិញ្ញាណំ ។ សង្ខតំ រូបំ ។ បេ ។ សង្ខតំ វិញ្ញាណំ សង្ខតំ វិញ្ញាណន្តិ យថាភូតំ បជានាតិ ។ រូបំ វិភវិស្សតីតិ យថាភូតំ បជានាតិ ។ វេទនា ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណម្បិ ភវិស្សតីតិ យថាភូតំ បជានាតិ ។ សោ រូបស្ស វិភវា វេទនាយ វិភវា សញ្ញាយ វិភវា សង្ខារានំ វិភវា វិញ្ញាណស្ស វិភវា ។ ឯវំ ខោ ភិក្ខុ នោ ចស្សំ នោ ច មេ សិយា ន ភវិស្សតិ ន មេ ភវិស្សតីតិ ឯវំ វិមុច្ចមានោ ភិក្ខុ ឆិន្ទេយ្យ ឱរម្ភាគិយានិ សញ្ញោជនានីតិ ។

មិនឃើញវិញ្ញាណថាជាខ្លួនខ្លះ ។ ភិក្ខុនោះ ដឹងច្បាស់តាមពិត នូវរូបមិនទៀង ថារូបមិនទៀង ។ នូវវេទនាមិនទៀង ។ នូវសញ្ញាមិនទៀង ។ នូវសង្ខារទាំងឡាយមិនទៀង ។ ដឹងច្បាស់តាមពិត នូវវិញ្ញាណមិនទៀង ថាវិញ្ញាណមិនទៀង ។ នូវរូបជាទុក្ខ ។បេ។ នូវវិញ្ញាណជាទុក្ខ ។ នូវរូបជាអនត្តា ។បេ។ នូវវិញ្ញាណជាអនត្តា ។ នូវរូបដែលមានបច្ច័យប្រជុំតាក់តែង ។បេ។ ដឹងច្បាស់តាមពិត នូវវិញ្ញាណដែលមានបច្ច័យប្រជុំតាក់តែង ថាវិញ្ញាណមានបច្ច័យប្រជុំតាក់តែង ។ ដឹងច្បាស់តាមពិត ថារូបនឹងមាន ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ ដឹងច្បាស់តាមពិត ថាវិញ្ញាណនឹងមាន ។ ភិក្ខុនោះ ទើបឈ្មោះថាប្រាសចាករូប ប្រាសចាកវេទនា ប្រាសចាកសញ្ញា ប្រាសចាកសង្ខារទាំងឡាយ ប្រាសចាកវិញ្ញាណ ។ ភិក្ខុ កាលចុះចិត្តស៊ប់យ៉ាងនេះថា បើអាត្មាអញនឹងមិនមាន (គ្រឿងបរិក្ខារ) របស់អាត្មាអញ ក៏នឹងមិនមាន (បើការកសាងនូវកម្មទុក្ខ ក្នុងអនាគត) នឹងមិនមាន (បដិសន្ធិ) របស់អាត្មាអញ (ក្នុងអនាគត) ក៏នឹងមិនមានដែរ ដូច្នេះហើយ ទើបគួរកាត់នូវសញ្ញោជនៈជាចំណែកខាងក្រោមបាន យ៉ាងនេះឯង ។

[១១១] ឯវំ វិមុច្ចមានោ ភន្តេ ភិក្ខុ ឆិន្ទេយ្យ ឱរម្ភាគិយានិ សញ្ញោជនានិ ។ កថំ បន ភន្តេ ជានតោ កថំ បស្សតោ អនន្តរា អាសវានំ ខយោ ហោតីតិ ។ ឥធ ភិក្ខុ អស្សុតវា បុថុជ្ជនោ ។ បេ ។ អតសិតាយេ ឋានេ តាសំ អាបជ្ជតិ ។ តាសោ ហេសោ ភិក្ខុ អស្សុតវតោ បុថុជ្ជនស្ស នោ ចស្សំ នោ ច មេ សិយា ន ភវិស្សតិ ន មេ ភវិស្សតីតិ ។ សុតវា ច ខោ ភិក្ខុ អរិយសាវកោ ។ បេ ។ អតសិតាយេ ឋានេ ន តាសំ អាបជ្ជតិ ។ ន ហេសោ ភិក្ខុ តាសោ សុតវតោ អរិយសាវកស្ស នោ ចស្សំ នោ ច មេ សិយា ន ភវិស្សតិ ន មេ ភវិស្សតីតិ ។ រូបុបាយំ វា ភិក្ខុ វិញ្ញាណំ តិដ្ឋមានំ តិដ្ឋេយ្យ រូបារម្មណំ រូបប្បតិដ្ឋំ នន្ទូបសេចនំ

[១១១] បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុកាលចុះចិត្តស៊ប់ យ៉ាងនេះហើយ ទើបគួរកាត់នូវសញ្ញោជនៈ ជាចំណែកខាងក្រោមបាន ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះភិក្ខុកាលដឹងដូចម្តេច កាលឃើញដូចម្តេច ទើបអស់អាសវៈក្នុងលំដាប់បាន ។ ម្នាលភិក្ខុ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនចេះដឹង ជាបុថុជ្ជន ។ បេ ។ តែងដល់នូវសេចក្តីតក់ស្លុតក្នុងហេតុដែលមិនគួរតក់ស្លុត ។ ម្នាលភិក្ខុ ព្រោះថា ភិក្ខុជាបុថុជ្ជន ជាអ្នកមិនចេះដឹង តែងមានសេចក្តីតក់ស្លុតនុះថា បើអាត្មាអញនឹងមិនមាន (បរិក្ខារ) របស់អាត្មាអញក៏នឹងមិនមាន ។ (បើការកសាងនូវកម្មក្នុងអនាគត) នឹងមិនមាន (បដិសន្ធិ) របស់អាត្មាអញ (ក្នុងអនាគត) ក៏នឹងមិនមាន ។ ម្នាលភិក្ខុ ឯអរិយសាវ័ក ជាអ្នកចេះដឹង ។ បេ ។ តែងមិនដល់នូវសេចក្តីតក់ស្លុតក្នុងហេតុដែលមិនគួរតក់ស្លុតឡើយ ។ ម្នាលភិក្ខុ ព្រោះថា អរិយសាវ័កជាអ្នកចេះដឹង តែងមិនមានសេចក្តីតក់ស្លុតនុះថា បើអាត្មាអញនឹងមិនមាន (បរិក្ខារ) របស់អាត្មាអញក៏នឹងមិនមាន (ការកសាងនូវកម្មក្នុងអនាគត) ក៏នឹងមិនមាន (បដិសន្ធិ) របស់អាត្មាអញ (ក្នុងអនាគត) ក៏នឹងមិនមានដូច្នេះឡើយ ។ ម្នាលភិក្ខុ វិញ្ញាណមានរូបជាហេតុ កាលដែលឋិតនៅ ក៏ឋិតនៅបាន រូបារម្មណ៍មានរូបជាទីតាំង មានកិរិយាចូលទៅជិតសេពនូវសេចក្តី

វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជេយ្យ ។ វេទនូបាយំ វា ភិក្ខុ ។ សញ្ញូបាយំ វា ភិក្ខុ ។ សង្ខារូបាយំ វា ភិក្ខុ វិញ្ញាណំ តិដ្ឋមានំ តិដ្ឋេយ្យ សង្ខារារម្មណំ សង្ខារប្បតិដ្ឋំ នន្ទូប-សេចនំ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជេយ្យ ។ យោ ភិក្ខុ ឯវំ វទេយ្យ អហមញ្ញត្រ រូបា អញ្ញត្រ វេទនាយ អញ្ញត្រ សញ្ញាយ អញ្ញត្រ សង្ខារេហិ វិញ្ញាណស្ស អាគតឹ វា គតឹ វា ចុតឹ វា ឧបបត្តឹ វា វុឌ្ឍឹ វា វិរូឡ្ហឹ វា វេបុល្លំ វា បញ្ញាបេស្សាមីតិ នេតំ ឋានំ វិជ្ជតិ ។ រូបធាតុយា ចេ ភិក្ខុ ភិក្ខុនោ រាគោ បហីនោ ហោតិ រាគស្ស បហានា វោច្ឆិជ្ជតារម្មណំ បតិដ្ឋា វិញ្ញាណស្ស ន ហោតិ ។ វេទនាធាតុយា ចេ ភិក្ខុ ភិក្ខុនោ ។ សញ្ញាធាតុយា ចេ ភិក្ខុ ភិក្ខុនោ ។ សង្ខារធាតុយា ចេ ភិក្ខុ ភិក្ខុនោ ។

រីករាយ គួរដល់សេចក្ដីចម្រើន ដុះដាល ធំទូលាយឡើងបាន ។ ម្នាលភិក្ខុ វិញ្ញាណ មានវេទនាជាហេតុ ។ ម្នាលភិក្ខុ វិញ្ញាណមានសញ្ញាជាហេតុ ។ ម្នាលភិក្ខុ វិញ្ញាណមានសង្ខារជាហេតុ កាលដែលឋិតនៅក៏ឋិតនៅបាន សង្ខារារម្មណ៍មានសង្ខារជាទីតាំង មានតិរិយាចូលទៅជិតសេពនូវសេចក្ដីរីករាយ គួរដល់សេចក្ដីចម្រើន ដុះដាល ធំទូលាយឡើងបាន ។ ម្នាលភិក្ខុ បុគ្គលនោះនិយាយយ៉ាងនេះថា អាត្មាអញទោះបីវៀរចាករូប វៀរចាកវេទនា វៀរចាកសញ្ញា វៀរចាកសង្ខារទាំងឡាយហើយ ក៏គង់ដឹងដំណើរមកឬដំណើរទៅ ការឃ្លាតឬការកើតឡើង ឬសេចក្ដីចម្រើន ដុះដាល ធំទូលាយឡើង របស់វិញ្ញាណបាន ពាក្យដូច្នេះនេះ មិនសមហេតុឡើយ ។ ម្នាលភិក្ខុ បើសេចក្ដីត្រេកអរ ក្នុងរូបធាតុ ភិក្ខុបានលះបង់ហើយ ព្រោះតែលះបង់នូវសេចក្ដីត្រេកអរ អារម្មណ៍ក៏ដាច់ចេញ ការតាំងនៅនៃវិញ្ញាណក៏មិនមាន ។ ម្នាលភិក្ខុ បើសេចក្ដីត្រេកអរ ក្នុងវេទនាធាតុ ភិក្ខុបានលះបង់ហើយ ។ ម្នាលភិក្ខុ បើសេចក្ដីត្រេកអរ ក្នុងសញ្ញាធាតុ ភិក្ខុបានលះបង់ហើយ ។ ម្នាលភិក្ខុ បើសេចក្ដីត្រេកអរ ក្នុងសង្ខារធាតុ ភិក្ខុបានលះបង់ហើយ ។

វិញ្ញាណធាតុយា ចេ ភិក្ខុ ភិក្ខុនោ រាគោ បហីនោ ហោតិ រាគស្ស បហានា វោច្ឆិជ្ជតារម្មណំ បតិដ្ឋា វិញ្ញាណស្ស ន ហោតិ ។ តទប្បតិដ្ឋិតំ វិញ្ញាណំ អវិរូឡ្ហំ អនភិសង្ខច្ច វិមុត្តំ វិមុត្តត្តា ឋិតំ ឋិតត្តា សន្តុសិតំ សន្តុសិតត្តា ន បរិតស្សតិ អបរិតស្សំ បច្ចត្តញ្ញេវ បរិនិព្វាយតិ ។ ខីណា ជាតិ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។ ឯវំ ខោ ភិក្ខុ ជានតោ ឯវំ បស្សតោ អនន្តរា អាសវានំ ខយោ ហោតីតិ ។

[១១២] សាវត្ថិយំ ។ តត្រ ខោ ។ បញ្ចិមេ ភិក្ខវេ ឧបាទានក្ខន្ធា ។ កតមេ បញ្ច ។ សេយ្យថីទំ ។ រូបូបាទានក្ខន្ធោ វេទនូបាទានក្ខន្ធោ សញ្ញូបាទានា-

ម្នាលភិក្ខុ បើសេចក្តីត្រេកអរ ក្នុងវិញ្ញាណធាតុ ភិក្ខុបានលះបង់ហើយ ព្រោះតែបានលះបង់នូវសេចក្តីត្រេកអរ អារម្មណ៍ក៏ដាច់ចេញ ការទីពឹងនៃវិញ្ញាណ ក៏មិនមាន ។ វិញ្ញាណដែលមិនមានទីពឹងហើយនោះ ក៏មិនដុះដាល សឹងផុតស្រឡះ ព្រោះមិនតាក់តែងនូវបដិសន្ធិទៅទៀត ព្រោះតែផុតស្រឡះ ក៏តំកល់នៅនឹង ព្រោះតំកល់នៅនឹងហើយ ក៏ត្រេកអរ ព្រោះតែត្រេកអរ ក៏មិនតក់ស្លុត កាលបើមិនតក់ស្លុត ទើបបរិនិព្វានចំពោះខ្លួនឯង ។ ដឹងច្បាស់ថា ជាតិអស់ហើយ ។ បេ ។ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលភិក្ខុ អរិយសាវ័ក កាលដឹងយ៉ាងនេះ កាលឃើញយ៉ាងនេះ ទើបអស់អាសវៈក្នុងលំដាប់បាន ។

[១១៥] ក្នុងក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ឧបាទានក្ខន្ធនេះ មាន ៥ ប្រការ ។ ឧបាទានក្ខន្ធ ៥ តើដូចម្តេច ។ គឺរូបូបាទានក្ខន្ធ ១ វេទនូបាទានក្ខន្ធ ១ សញ្ញូបាទា-

នក្ខន្ធោ សង្ខារុបាទានក្ខន្ធោ វិញ្ញាណុបាទានក្ខន្ធោ ។ យាវកីវញ្ចាហំ ភិក្ខវេ ឥមេ បញ្ចុបាទានក្ខន្ធេ ចតុបរិវដ្ដំ យថាភូតំ ន អព្ភញ្ញាសឹ នេវ តាវាហំ ភិក្ខវេ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោ[១] បច្ចញ្ញាសឹ ។ យតោ ច ខ្វាហំ ភិក្ខវេ ឥមេ បញ្ចុបាទានក្ខន្ធេ ចតុបរិវដ្ដំ យថាភូតំ អព្ភញ្ញាសឹ អថាហំ ភិក្ខវេ សទេវកេ ។ បេ ។ សទេវមនុស្សាយ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោ បច្ចញ្ញាសឹ ។ កថំ ចតុបរិវដ្ដំ ។ រូបំ អព្ភញ្ញាសឹ រូបសមុទយំ អព្ភញ្ញាសឹ រូបនិរោធំ អព្ភញ្ញាសឹ រូបនិរោធគាមិនឹ បដិបទំ អព្ភញ្ញាសឹ ។ វេទនំ អព្ភញ្ញាសឹ ។ សញ្ញំ ។

---

១ ឱ. ម. អភិសមទ្ធោតិ ។

នក្ខន្ធ១ សង្ខារុបាទានក្ខន្ធ១ វិញ្ញាណុបាទានក្ខន្ធ១ ។ ម្នាលភិក្ខុទាំង-ឡាយ តថាគតមិនទាន់ដឹងច្បាស់តាមពិត នូវឧបាទានក្ខន្ធ[1]ទាំង៥ នេះ ដែលមានបរិវដ្ដៈបួន ៗ ត្រឹមណា ម្នាលភិក្ខុទាំងឡាយ តថាគតមិនទាន់ប្ដេជ្ញាខ្លួន ថាជាអ្នកត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណដ៏ប្រសើរ ក្នុងលោកព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស ត្រឹមនោះដែរ ៗ ម្នាលភិក្ខុទាំងឡាយ កាលណា តថាគតបានដឹងច្បាស់តាមពិត នូវឧបាទានក្ខន្ធទាំង៥ នេះ ដែលមានបរិវដ្ដៈបួន ៗ ហើយ ម្នាលភិក្ខុទាំងឡាយ កាលនោះ ទើបតថាគតប្ដេជ្ញាខ្លួនថាជាអ្នកត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណដ៏ប្រសើរ ក្នុងលោកព្រមទាំងទេវលោក ។ បេ ។ ព្រមទាំងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេសបាន ។ ឧបាទានក្ខន្ធដែលមានបរិវដ្ដៈបួន ៗ ដូចម្ដេច ។ គឺតថាគតដឹងច្បាស់នូវរូប ដឹងច្បាស់នូវការកើតឡើងនៃរូប ដឹងច្បាស់នូវការរលត់នៃរូប ដឹងច្បាស់នូវសេចក្ដីប្រតិបត្តិទៅកាន់ទីរលត់នៃរូប ។ ដឹងច្បាស់នូវវេទនា ។ នូវសញ្ញា ។

---

១ ក្នុងខន្ធទាំងនេះ ខន្ធមួយ ៗ មានបរិវដ្ដៈបួន ៗ (អដ្ឋកថា) ។

សង្ខារេ ។ វិញ្ញាណំ អព្ភញ្ញាសឹ វិញ្ញាណសមុទយំ អព្ភញ្ញាសឹ វិញ្ញាណនិរោធំ អព្ភញ្ញាសឹ វិញ្ញាណនិរោធគាមិនីបដិបទំ អព្ភញ្ញាសឹ ។

[១១៣] កតមញ្ច ភិក្ខវេ រូបំ ។ ចត្តារោ ច មហាភូតា ចតុន្នញ្ច មហាភូតានំ ឧបាទាយរូបំ ។ ឥទំ វុច្ចតិ ភិក្ខវេ រូបំ ។ អាហារសមុទយា រូបសមុទយោ អាហារនិរោធា រូបនិរោធោ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ រូបនិរោធគាមិនីបដិបទា ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។ យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឯវំ រូបំ អភិញ្ញាយ ឯវំ រូបសមុទយំ អភិញ្ញាយ ឯវំ រូបនិរោធំ អភិញ្ញាយ ឯវំ រូបនិរោធគាមិនីបដិបទំ អភិញ្ញាយ រូបស្ស និព្វិទាយ វិរាគាយ និរោធាយ បដិបន្នា តេ សុប្បដិ-

នូវសង្ខារទាំងឡាយ ។ តថាគតដឹងច្បាស់នូវវិញ្ញាណ ដឹងច្បាស់នូវការកើតឡើងនៃវិញ្ញាណ ដឹងច្បាស់នូវការរលត់នៃវិញ្ញាណ ដឹងច្បាស់នូវសេចក្តីប្រតិបត្តិទៅកាន់ទីរលត់នៃវិញ្ញាណ ។

[១១៣] ម្នាលភិក្ខុទាំងឡាយ ចុះរូប តើដូចម្តេច ។ មហាភូតរូប ៤ និងឧបាទាយរូប (២៤ដែលអាស្រ័យ) នឹងមហាភូតរូប ៤ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា រូប ។ ការកើតឡើងនៃរូប ព្រោះកើតឡើងនៃអាហារ ការរលត់ទៅនៃរូប ព្រោះរលត់ទៅនៃអាហារ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯង ជាផ្លូវប្រតិបត្តិទៅកាន់សេចក្តីរលត់នៃរូប ។ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនោះ តើអ្វីខ្លះ ។ គឺ សម្មាទិដ្ឋិ ១ ។ បេ ។ សម្មាសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីពិតថា ពួកសមណៈឬព្រាហ្មណ៍ណាមួយ បានដឹងច្បាស់នូវរូបយ៉ាងនេះ ដឹងច្បាស់នូវការកើតឡើងនៃរូប យ៉ាងនេះ ដឹងច្បាស់នូវសេចក្តីរលត់នៃរូប យ៉ាងនេះ ដឹងច្បាស់នូវសេចក្តីប្រតិបត្តិទៅកាន់សេចក្តីរលត់នៃរូប យ៉ាងនេះ ហើយប្រតិបត្តិ ដើម្បីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីសេចក្តីរលត់នៃរូប សមណៈឬព្រាហ្មណ៍ទាំងនោះ ឈ្មោះថាបាន

បន្នា យេ សុប្បដិបន្នា តេ ឥមស្មិំ ធម្មវិនយេ គាធន្តិ ។ យេ ច ខោ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឯវំ រូបំ អភិញ្ញាយ ឯវំ រូបសមុទយំ អភិញ្ញាយ ឯវំ រូបនិរោធំ អភិញ្ញាយ ឯវំ រូបនិរោធគាមិនីបដិបទំ អភិញ្ញាយ រូបស្ស និព្ពិទា វិរាគា និរោធា អនុបាទា វិមុត្តា តេ សុវិមុត្តា យេ សុវិមុត្តា តេ កេវលិនោ យេ កេវលិនោ វដ្ដំ តេសំ នត្ថិ បញ្ញាបនាយ ។

(១១៤) កតមា ច ភិក្ខវេ វេទនា ។ ឆយិមេ ភិក្ខវេ វេទនាកាយា ចក្ខុសម្ផស្សជា វេទនា សោត-

ប្រតិបត្តិដោយល្អ សមណៈឬព្រាហ្មណ៍ណា បានប្រតិបត្តិល្អ សមណៈឬព្រាហ្មណ៍ទាំងនោះ ឈ្មោះថាតាំងនៅក្នុងធម្មវិន័យនេះ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកពួកសមណៈ ឬព្រាហ្មណ៍ ណាមួយ បានដឹងច្បាស់នូវរូបយ៉ាងនេះ ដឹងច្បាស់នូវការកើតឡើងនៃរូប យ៉ាងនេះ ដឹងច្បាស់នូវសេចក្ដីរលត់នៃរូប យ៉ាងនេះ ដឹងច្បាស់នូវសេចក្ដីប្រតិបត្តិទៅកាន់សេចក្ដីរលត់នៃរូបយ៉ាងនេះហើយ ក៏ផុតស្រឡះ ព្រោះនឿយណាយ ព្រោះប្រាសចាកតម្រេក ព្រោះរលត់ ព្រោះមិនបានប្រកាន់យកនូវរូប សមណៈឬព្រាហ្មណ៍ទាំងនោះ ឈ្មោះថាផុតស្រឡះដោយល្អ សមណៈឬព្រាហ្មណ៍ណា ផុតស្រឡះដោយល្អហើយ សមណៈឬព្រាហ្មណ៍ទាំងនោះ ឈ្មោះថាមានកិច្ចបានធ្វើហើយ សមណៈឬព្រាហ្មណ៍ទាំងឡាយណា មានកិច្ចបានធ្វើហើយ វដ្តៈរបស់សមណៈនិងព្រាហ្មណ៍ទាំងនោះ ក៏មិនមានជាប្រាកដ ។

[ ១១៨ ] ម្នាលភិក្ខុទាំងឡាយ ចុះវេទនា តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ពួកវេទនានេះមាន ៦ យ៉ាង គឺ ចក្ខុសម្ផស្សជាវេទនា ១ សោត-

សម្ផស្សជា វេទនា ឃានសម្ផស្សជា វេទនា ជិវ្ហា-
សម្ផស្សជា វេទនា កាយសម្ផស្សជា វេទនា មនោ-
សម្ផស្សជា វេទនា ។ អយំ វុច្ចតិ ភិក្ខវេ វេទនា ។
ផស្សសមុទយា វេទនាសមុទយោ ផស្សនិរោធា វេ-
ទនានិរោធោ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ
វេទនានិរោធគាមិនីបដិបទា ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ
។ បេ ។ សម្មាសមាធិ ។ យេ ហិ កេចិ ភិក្ខវេ ស-
មណា វា ព្រាហ្មណា វា ឯវំ វេទនំ អភិញ្ញាយ ឯវំ
វេទនាសមុទយំ អភិញ្ញាយ ឯវំ វេទនានិរោធំ អភិញ្ញា-
យ ឯវំ វេទនានិរោធគាមិនីបដិបទំ អភិញ្ញាយ វេទនា-
យ និព្វិទាយ វិរាគាយ និរោធាយ បដិបន្នា តេ
សុប្បដិបន្នា យេ សុប្បដិបន្នា តេ ឥមស្មឹ ធម្មវិនយេ
គាធន្តិ ។ យេ ច ខោ កេចិ ភិក្ខវេ សមណា វា
ព្រាហ្មណា វា ឯវំ វេទនំ អភិញ្ញាយ ឯវំ វេទនា-
សមុទយំ អភិញ្ញាយ ឯវំ វេទនានិរោធំ អភិញ្ញាយ

សម្ផស្សជាវេទនា ១ ឃានសម្ផស្សជាវេទនា ១ ជិវ្ហាសម្ផស្សជាវេទនា ១ កាយសម្ផស្សជាវេទនា ១ មនោសម្ផស្សជាវេទនា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា វេទនា ។ ការកើតឡើងនៃវេទនា ព្រោះកើតឡើងនៃផស្សៈ ការរលត់នៃវេទនា ព្រោះរលត់នៃផស្សៈ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯង ជាសេចក្តីប្រតិបត្តិ ដើម្បីដល់នូវការរលត់នៃវេទនា ។ មគ្គប្រកបដោយអង្គ ៨ តើដូចម្តេចខ្លះ ។ គឺ សម្មាទិដ្ឋិ ១ ។ បេ ។ សម្មាសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីពិតថា ពួកសមណៈឬព្រាហ្មណ៍ ណានីមួយ បានដឹងច្បាស់នូវវេទនា យ៉ាងនេះ បានដឹងច្បាស់នូវការកើតឡើងនៃវេទនា យ៉ាងនេះ បានដឹងច្បាស់នូវការរលត់នៃវេទនា យ៉ាងនេះ បានដឹងច្បាស់នូវសេចក្តីប្រតិបត្តិទៅកាន់ទីរលត់នៃវេទនា យ៉ាងនេះ ហើយប្រតិបត្តិ ដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីសេចក្តីរលត់នៃវេទនា ពួកសមណៈ ឬព្រាហ្មណ៍នោះ ឈ្មោះថាប្រតិបត្តិល្អ ពួកសមណៈឬព្រាហ្មណ៍ណា បានប្រតិបត្តិល្អ ពួកសមណៈឬព្រាហ្មណ៍ ទាំងនោះ ឈ្មោះថា ឋិតនៅក្នុងធម្មវិន័យនេះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈ ឬព្រាហ្មណ៍ណានីមួយ បានដឹងច្បាស់នូវវេទនា យ៉ាងនេះ បានដឹងច្បាស់នូវការកើតឡើងនៃវេទនា យ៉ាងនេះ បានដឹងច្បាស់នូវការរលត់ នៃវេទនា យ៉ាងនេះ

ឯវំ វេទនានិរោធគាមិនីបដិបទំ អភិញ្ញាយ ។បេ។ វដ្ដំ តេសំ នត្ថិ បញ្ញាបនាយ ។

[១០៨] កតមា ច ភិក្ខវេ សញ្ញា ។ ឆយិមេ ភិក្ខវេ សញ្ញាកាយា រូបសញ្ញា សទ្ទសញ្ញា គន្ធសញ្ញា រសសញ្ញា ផោដ្ឋព្វសញ្ញា ធម្មសញ្ញា ។ អយំ វុច្ចតិ ភិក្ខវេ សញ្ញា ។ ផស្សសមុទយា សញ្ញាសមុទយោ ផស្សនិរោធា សញ្ញានិរោធោ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ សញ្ញានិរោធគាមិនីបដិបទា ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។ យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឯវំ សញ្ញំ អភិញ្ញាយ ។បេ។ វដ្ដំ តេសំ នត្ថិ បញ្ញាបនាយ ។

បានដឹងច្បាស់ នូវសេចក្តីប្រតិបត្តិទៅកាន់ទីរលត់នៃវេទនា យ៉ាងនេះហើយ ។ បេ ។ វដ្តៈរបស់ពួកសមណៈនិងព្រាហ្មណ៍នោះ ក៏មិនមានជាប្រាកដ ។

[១១៩] ម្នាលភិក្ខុទាំងឡាយ ចុះសញ្ញា តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសញ្ញានេះ មាន ៦ យ៉ាងគឺ រូបសញ្ញា ១ សទ្ទសញ្ញា ១ គន្ធសញ្ញា ១ រសសញ្ញា ១ ផោដ្ឋព្វសញ្ញា ១ ធម្មសញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សញ្ញា ។ ការកើតឡើងនៃសញ្ញា ព្រោះកើតឡើងនៃផស្សៈ ការរលត់នៃសញ្ញា ព្រោះរលត់នៃផស្សៈ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯង ជាសេចក្តីប្រតិបត្តិ ដើម្បីដល់នូវការរលត់នៃសញ្ញា ។ មគ្គប្រកបដោយអង្គ ៨ តើដូចម្តេចខ្លះ ។ គឺសម្មាទិដ្ឋិ ១ ។ បេ ។ សម្មាសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីពិតថា ពួកសមណៈឬព្រាហ្មណ៍ ណាទីមួយ បានដឹងច្បាស់នូវសញ្ញាយ៉ាងនេះ ។ បេ ។ វដ្តៈរបស់សមណៈនិងព្រាហ្មណ៍ទាំងនោះ ក៏មិនមានជាប្រាកដ ។

[១១៦] កតមេ ច ភិក្ខវេ សង្ខារា ។ ឆយិមេ ភិក្ខវេ ចេតនាកាយា រូបសញ្ចេតនា សទ្ទសញ្ចេតនា គន្ធសញ្ចេតនា រសសញ្ចេតនា ផោដ្ឋព្វសញ្ចេតនា ធម្មសញ្ចេតនា ។ ឥមេ វុច្ចន្តិ ភិក្ខវេ សង្ខារា ។ ផស្សសមុទយា សង្ខារសមុទយោ ផស្សនិរោធា សង្ខារនិរោធោ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ សង្ខារនិរោធគាមិនីបដិបទា ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឯវំ សង្ខារេ អភិញ្ញាយ ឯវំ សង្ខារសមុទយំ អភិញ្ញាយ ឯវំ សង្ខារនិរោធំ អភិញ្ញាយ ឯវំ សង្ខារនិរោធគាមិនីបដិបទំ អភិញ្ញាយ សង្ខារានំ និព្វិទាយ វិរាគាយ និរោធាយ បដិបន្នា តេ សុប្បដិបន្នា ។ យេ សុប្បដិបន្នា តេ ឥមស្មឹ ធម្មវិនយេ គាធន្តិ ។

(១១៦) ម្នាលភិក្ខុទាំងឡាយ ចុះសង្ខារទាំងឡាយ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពួកចេតនានេះ មាន ៦ ប្រការ គឺ រូបសញ្ចេតនា ១ សទ្ទសញ្ចេតនា ១ គន្ធសញ្ចេតនា ១ រសសញ្ចេតនា ១ ផោដ្ឋព្វសញ្ចេតនា ១ ធម្មសញ្ចេតនា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សង្ខារ ។ ការកើតឡើងនៃសង្ខារ ព្រោះកើតឡើងនៃផស្សៈ ការរលត់ទៅនៃសង្ខារ ព្រោះរលត់ទៅនៃផស្សៈ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯង ជាសេចក្តីប្រតិបត្តិ ដើម្បីដល់នូវការរលត់នៃសង្ខារ ។ មគ្គប្រកបដោយអង្គ ៨ តើអ្វីខ្លះ ។ គឺ សម្មាទិដ្ឋិ ១ ។ បេ ។ សម្មាសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីពិតថា ពួកសមណៈឬព្រាហ្មណ៍ ណាមួយ បានដឹងច្បាស់ នូវសង្ខារទាំងឡាយយ៉ាងនេះ បានដឹងច្បាស់នូវការកើតឡើងនៃសង្ខារយ៉ាងនេះ បានដឹងច្បាស់ នូវការរលត់នៃសង្ខារយ៉ាងនេះ បានដឹងច្បាស់នូវសេចក្តីប្រតិបត្តិទៅកាន់ទីរលត់នៃសង្ខារយ៉ាងនេះ ហើយប្រតិបត្តិ ដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីសេចក្តីរលត់នៃសង្ខារ ពួកសមណៈឬព្រាហ្មណ៍នោះឈ្មោះថា បានប្រតិបត្តិល្អ ពួកសមណៈឬព្រាហ្មណ៍ណា ប្រតិបត្តិល្អ ពួកសមណៈឬព្រាហ្មណ៍នោះ ឈ្មោះថា ឋិតនៅក្នុងធម្មវិន័យនេះ ។

យេ ច ខោ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឯវំ សង្ខារេ អភិញ្ញាយ ឯវំ សង្ខារសមុទយំ អភិញ្ញាយ ឯវំ សង្ខារនិរោធំ អភិញ្ញាយ ឯវំ សង្ខារនិរោធគាមិនីបដិបទំ អភិញ្ញាយ សង្ខារានំ និព្វិទា វិរាគា និរោធា អនុបាទា វិមុត្តា តេ សុវិមុត្តា យេ សុវិមុត្តា តេ កេវលិនោ យេ កេវលិនោ វដ្ដំ តេសំ នត្ថិ បញ្ញាបនាយ ។

(១១៧) កតមញ្ច ភិក្ខវេ វិញ្ញាណំ ។ ឆយិមេ ភិក្ខវេ វិញ្ញាណកាយា ចក្ខុវិញ្ញាណំ សោតវិញ្ញាណំ ឃានវិញ្ញាណំ ជិវ្ហាវិញ្ញាណំ កាយវិញ្ញាណំ មនោវិញ្ញាណំ ។ ឥទំ វុច្ចតិ ភិក្ខវេ វិញ្ញាណំ ។ នាមរូបសមុទយា វិញ្ញាណសមុទយោ នាមរូបនិរោធា វិញ្ញាណនិរោធោ

ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ណាមួយ បានដឹងច្បាស់នូវសង្ខារទាំងឡាយ យ៉ាងនេះ បានដឹងច្បាស់នូវការកើតឡើង នៃសង្ខារយ៉ាងនេះ បានដឹងច្បាស់នូវទីរលត់នៃសង្ខារយ៉ាងនេះ បានដឹងច្បាស់នូវសេចក្តីប្រតិបត្តិទៅកាន់ទីរលត់នៃសង្ខារ យ៉ាងនេះ ហើយផុតស្រឡះ ព្រោះនឿយណាយ ព្រោះប្រាសចាកតម្រេក ព្រោះរលត់ ព្រោះមិនប្រកាន់យកនូវសង្ខារទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ទាំងនោះ ឈ្មោះថា ផុតស្រឡះដោយល្អ ពួកសមណៈឬព្រាហ្មណ៍ណា ផុតស្រឡះល្អ ពួកសមណៈឬព្រាហ្មណ៍នោះ ឈ្មោះថាមានកិច្ចបានធ្វើហើយ ពួកសមណៈឬព្រាហ្មណ៍ណា មានកិច្ចបានធ្វើហើយ វដ្តៈរបស់សមណៈនិងព្រាហ្មណ៍ទាំងនោះ ក៏មិនមានជាប្រាកដ ។

( ១១៧ ) ម្នាលភិក្ខុទាំងឡាយ ចុះវិញ្ញាណ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពួកវិញ្ញាណនេះ មាន ៦ យ៉ាង គឺ ចក្ខុវិញ្ញាណ ១ សោតវិញ្ញាណ ១ ឃានវិញ្ញាណ ១ ជិវ្ហាវិញ្ញាណ ១ កាយវិញ្ញាណ ១ មនោវិញ្ញាណ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា វិញ្ញាណ ។ ការកើតឡើងនៃវិញ្ញាណ ព្រោះកើតឡើងនៃនាមនិងរូប ការរលត់ទៅនៃ

អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ វិញ្ញាណនិរោធគាមិនីបដិបទា ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឯវំ វិញ្ញាណំ អភិញ្ញាយ ឯវំ វិញ្ញាណសមុទយំ អភិញ្ញាយ ឯវំ វិញ្ញាណនិរោធំ អភិញ្ញាយ ឯវំ វិញ្ញាណនិរោធគាមិនីបដិបទំ អភិញ្ញាយ វិញ្ញាណស្ស និព្វិទាយ វិរាគាយ និរោធាយ បដិបន្នា តេ សុប្បដិបន្នា យេ សុប្បដិបន្នា តេ ឥមស្មឹ ធម្មវិនយេ គាធន្តិ ។ យេ ច ខោ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឯវំ វិញ្ញាណំ អភិញ្ញាយ ឯវំ វិញ្ញាណសមុទយំ អភិញ្ញាយ ឯវំ វិញ្ញាណនិរោធំ អភិញ្ញាយ ឯវំ វិញ្ញាណនិរោធគាមិនីបដិបទំ អភិញ្ញាយ វិញ្ញាណស្ស និព្វិទា វិរាគា និរោធា

វិញ្ញាណ ព្រោះរលត់ទៅនៃនាមនិងរូប មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯង ជាសេចក្ដីប្រតិបត្តិទៅកាន់ទីរលត់ នៃវិញ្ញាណ ។ មគ្គប្រកបដោយអង្គ ៨ តើអ្វីខ្លះ ។ គឺ សម្មាទិដ្ឋិ ១ ។បេ។ សម្មាសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីពិតថា ពួកសមណៈឬព្រាហ្មណ៍ណាទីមួយ បានដឹងច្បាស់នូវវិញ្ញាណ យ៉ាងនេះ បានដឹងច្បាស់នូវការកើតឡើងនៃវិញ្ញាណ យ៉ាងនេះ បានដឹងច្បាស់នូវការរលត់នៃវិញ្ញាណ យ៉ាងនេះ បានដឹងច្បាស់នូវសេចក្ដីប្រតិបត្តិទៅកាន់ទីរលត់នៃវិញ្ញាណ យ៉ាងនេះ ហើយប្រតិបត្តិ ដើម្បីសេចក្ដីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីរលត់នៃវិញ្ញាណ សមណៈឬព្រាហ្មណ៍ទាំងនោះ ឈ្មោះថាបានប្រតិបត្តិដោយល្អ ពួកសមណៈ ឬព្រាហ្មណ៍ណា បានប្រតិបត្តិល្អ សមណៈឬព្រាហ្មណ៍ទាំងនោះ ឈ្មោះថា ឋិតនៅក្នុងធម្មវិន័យនេះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ណាទីមួយ បានដឹងច្បាស់នូវវិញ្ញាណ យ៉ាងនេះ បានដឹងច្បាស់នូវការកើតឡើង នៃវិញ្ញាណ យ៉ាងនេះ បានដឹងច្បាស់នូវការរលត់ នៃវិញ្ញាណ យ៉ាងនេះ បានដឹងច្បាស់នូវសេចក្ដីប្រតិបត្តិទៅកាន់ទីរលត់នៃវិញ្ញាណ យ៉ាងនេះ ហើយផុតស្រឡះ ព្រោះនឿយណាយ ព្រោះប្រាសចាកតម្រេក ព្រោះរលត់

អនុបាទា វិមុត្តា តេ សុវិមុត្តា យេ សុវិមុត្តា តេ កេ-
វលិនោ យេ កេវលិនោ វដ្ដំ តេសំ នត្ថិ បញ្ញាបនា-
យាតិ ។

(១១៨) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សា-
វត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។
តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភ-
ទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯ-
តទវោច សត្តដ្ឋានកុសលោ ភិក្ខវេ ភិក្ខុ តិវិធូប-
បរិក្ខី ឥមស្មឹ ធម្មវិនយេ កេវលី វុសិតវា ឧត្តមបុរិ-
សោតិ វុច្ចតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ សត្តដ្ឋានកុស-
លោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ រូបំ បជានាតិ រូប-
សមុទយំ បជានាតិ រូបនិរោធំ បជានាតិ រូបនិរោធ-

ព្រោះមិនប្រកាន់យកនូវវិញ្ញាណ សមណៈឬព្រាហ្មណ៍ទាំងនោះ ឈ្មោះថាបានផុតស្រឡះដោយល្អ ពួកសមណៈឬព្រាហ្មណ៍ណា បានផុតស្រឡះល្អ សមណៈ ឬព្រាហ្មណ៍ទាំងនោះ ឈ្មោះថា មានកិច្ចបានធ្វើហើយ ពួកសមណៈឬព្រាហ្មណ៍ណា មានកិច្ចបានធ្វើហើយ វដ្ដៈរបស់សមណៈនិងព្រាហ្មណ៍ទាំងនោះ ក៏មិនមានជាប្រាកដ ។

(១១៨) ខ្ញុំបានស្ដាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក្នុងទីនោះឯង ព្រះមានព្រះភាគ ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះមានព្រះភាគ ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកឈ្លាសវៃក្នុងហេតុ ៧ ប្រការ ជាអ្នកពិចារណានូវលក្ខណៈ ៣ ប្រការ តថាគតពោលថា ជាបុរសឧត្ដម មានកិច្ចបានធ្វើរួចហើយ មានព្រហ្មចរិយធម៌នៅរួចហើយ ក្នុងធម្មវិន័យនេះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកឈ្លាសវៃ ក្នុងហេតុ ៧ ប្រការ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់នូវរូប ដឹងច្បាស់នូវការកើតឡើងនៃរូប ដឹងច្បាស់នូវការរលត់នៃរូប ដឹងច្បាស់នូវសេចក្ដីប្រតិបត្តិ

គាមិនឹបដិបទំ បជានាតិ ។ រូបស្ស អស្សាទំ បជានាតិ រូបស្ស អាទីនវំ បជានាតិ រូបស្ស និស្សរណំ បជានាតិ ។ វេទនំ បជានាតិ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ បជានាតិ វិញ្ញាណសមុទយំ បជានាតិ វិញ្ញាណនិរោធំ បជានាតិ វិញ្ញាណនិរោធគាមិនឹបដិបទំ បជានាតិ ។ វិញ្ញាណស្ស អស្សាទំ បជានាតិ វិញ្ញាណស្ស អាទីនំ បជានាតិ វិញ្ញាណស្ស និស្សរណំ បជានាតិ ។

(១០៩) កតមញ្ច ភិក្ខវេ រូបំ ។ ចត្តារោ ច មហាភូតា ចតុន្នញ្ច មហាភូតានំ ឧបាទាយរូបំ ។ ឥទំ វុច្ចតិ ភិក្ខវេ រូបំ ។ អាហារសមុទយា រូបសមុទយោ អាហារនិរោធា រូបនិរោធោ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ រូបនិរោធគាមិនីបដិបទា ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ យំ រូបំ បដិច្ច ឧប្បជ្ជតិ សុខំ សោមនស្សំ អយំ រូបស្ស អស្សាទោ យំ រូបំ អនិច្ចំ ទុក្ខំ វិបរិណាមធម្មំ អយំ រូបស្ស អាទីនវោ

ទៅកាន់ទីរលត់នៃរូប ។ ដឹងច្បាស់នូវអានិសង្សរបស់រូប ដឹងច្បាស់នូវទោសរបស់រូប ដឹងច្បាស់នូវការរលាស់ចេញនូវរូប ។ ដឹងច្បាស់នូវវេទនា ។ នូវសញ្ញា ។ នូវសង្ខារទាំងឡាយ ។ ដឹងច្បាស់នូវវិញ្ញាណ ដឹងច្បាស់នូវការកើតឡើងនៃវិញ្ញាណ ដឹងច្បាស់នូវការរលត់នៃវិញ្ញាណ ដឹងច្បាស់នូវសេចក្តីប្រតិបត្តិទៅកាន់ទីរលត់នៃវិញ្ញាណ ។ ដឹងច្បាស់នូវអានិសង្សរបស់វិញ្ញាណ ដឹងច្បាស់នូវទោសរបស់វិញ្ញាណ ដឹងច្បាស់នូវការរលាស់ចេញនូវវិញ្ញាណ ។

(១១៩) ម្នាលភិក្ខុទាំងឡាយ ចុះរូប តើដូចម្តេច ។ មហាភូតរូប ៤ និងឧបាទាយរូប (២៤) ដែលអាស្រ័យនឹងមហាភូតរូប ៤ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា រូប ។ ការកើតឡើងនៃរូប ព្រោះការកើតឡើងនៃអាហារ ការរលត់ទៅនៃរូប ព្រោះការរលត់ទៅនៃអាហារ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯង ជាសេចក្តីប្រតិបត្តិទៅកាន់ទីរលត់នៃរូប ។ មគ្គប្រកបដោយអង្គ ៨ តើដូចម្តេចខ្លះ ។ គឺសម្មាទិដ្ឋិ១ ។ បេ ។ សម្មាសមាធិ១ ។ សេចក្តីសុខនិងសោមនស្សណា កើតឡើងព្រោះអាស្រ័យនូវរូប នេះឈ្មោះថាអានិសង្សរបស់រូប រូបណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា នេះឈ្មោះថាទោសរបស់រូប

យោ រូបស្មឹ ឆន្ទរាគវិនយោ ឆន្ទរាគប្បហានំ ឥទំ រូបស្ស និស្សរណំ ។ យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឯវំ រូបំ អភិញ្ញាយ ឯវំ រូបសមុទយំ អភិញ្ញាយ ឯវំ រូបនិរោធំ អភិញ្ញាយ ឯវំ រូបនិរោធគានិនីបដិបទំ អភិញ្ញាយ ឯវំ រូបស្ស អស្សាទំ អភិញ្ញាយ ឯវំ រូបស្ស អាទីនវំ អភិញ្ញាយ ឯវំ រូបស្ស និស្សរណំ អភិញ្ញាយ រូបស្ស និព្វិទាយ វិរាគាយ និរោធាយ បដិបន្នា តេ សុប្បដិបន្នា យេ សុប្បដិបន្នា តេ ឥមស្មឹ ធម្មវិនយេ គាធន្តិ ។ យេ ច ខោ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឯវំ រូបំ អភិញ្ញាយ ឯវំ រូបសមុទយំ អភិញ្ញាយ ឯវំ រូបនិរោធំ អភិញ្ញាយ ឯវំ រូបនិរោធគាមិនីបដិបទំ អភិញ្ញាយ ឯវំ រូបស្ស អស្សាទំ អភិញ្ញាយ

ការបន្ទោបង់នូវឆន្ទរាគ ការលះបង់នូវឆន្ទរាគ ណា នេះឈ្មោះថា ការរលាស់ចេញនូវរូប ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីពិតថា ពួកសមណៈឬព្រាហ្មណ៍ណាមួយ បានដឹងច្បាស់នូវរូបយ៉ាងនេះ បានដឹងច្បាស់នូវការកើតឡើងនៃរូប យ៉ាងនេះ បានដឹងច្បាស់នូវការរលត់នៃរូបយ៉ាងនេះ បានដឹងច្បាស់នូវសេចក្តីប្រតិបត្តិទៅកាន់ទីរលត់នៃរូបយ៉ាងនេះ បានដឹងច្បាស់នូវអានិសង្ស របស់រូបយ៉ាងនេះ បានដឹងច្បាស់នូវទោសរបស់រូបយ៉ាងនេះ បានដឹងច្បាស់នូវការរលាស់ចេញនូវរូបយ៉ាងនេះ ហើយប្រតិបត្តិ ដើម្បីសេចក្តីនឿយណាយ ដើម្បីការប្រាសចាកតម្រេក ដើម្បីសេចក្តីរលត់នៃរូប ពួកសមណៈឬព្រាហ្មណ៍នោះ ឈ្មោះថាបានប្រតិបត្តិដោយល្អ ពួកសមណៈឬព្រាហ្មណ៍ណា ប្រតិបត្តិល្អ ពួកសមណៈឬព្រាហ្មណ៍នោះ ឈ្មោះថា ប៉ិតនៅក្នុងធម្មវិន័យនេះ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីពិតថា ពួកសមណៈឬព្រាហ្មណ៍ណាមួយ បានដឹងច្បាស់នូវរូបយ៉ាងនេះ បានដឹងច្បាស់ នូវការកើតឡើងនៃរូបយ៉ាងនេះ បានដឹងច្បាស់នូវការរលត់នៃរូបយ៉ាងនេះ បានដឹងច្បាស់ នូវសេចក្តីប្រតិបត្តិទៅកាន់ទីរលត់នៃរូបយ៉ាងនេះ បានដឹងច្បាស់នូវអានិសង្សរបស់រូបយ៉ាងនេះ

យំ រូបស្ស អាទីនវំ អភិញ្ញាយ យំ រូបស្ស និស្សរណំ អភិញ្ញាយ រូបស្ស និព្វិទា វិរាគា និរោធា អនុបាទា វិមុត្តា តេ សុវិមុត្តា យេ សុវិមុត្តា តេ កេវលិនោ យេ កេវលិនោ វដ្ដំ តេសំ នត្ថិ បញ្ញាបនាយ ។

(១២០) កតមា ច ភិក្ខវេ វេទនា ។ ឆយិមេ ភិក្ខវេ វេទនាកាយា ចក្ខុសម្ផស្សជា វេទនា ។ បេ ។ មនោសម្ផស្សជា វេទនា ។ អយំ វុច្ចតិ ភិក្ខវេ វេទ-នា ។ ផស្សសមុទយា វេទនាសមុទយោ ផស្សនិរោធា វេទនានិរោធោ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ

បានដឹងច្បាស់នូវទោសរបស់រូបយ៉ាងនេះ បានដឹងច្បាស់នូវការរលាស់ចេញនូវរូបយ៉ាងនេះហើយ ក៏ផុតស្រឡះ ព្រោះនឿយណាយ ប្រាសចាកតម្រេក ព្រោះរលត់ ព្រោះមិនប្រកាន់យកនូវរូប ពួកសមណៈឬព្រាហ្មណ៍ទាំងនោះ ឈ្មោះថាបានផុតស្រឡះដោយល្អ ពួកសមណៈឬព្រាហ្មណ៍ណា បានផុតស្រឡះដោយល្អ ពួកសមណៈឬព្រាហ្មណ៍នោះ ឈ្មោះថា ជាអ្នកមានកិច្ចបានធ្វើហើយ ពួកសមណៈ ឬព្រាហ្មណ៍ណា មានកិច្ចបានធ្វើហើយ វដ្ដៈ របស់សមណៈនិងព្រាហ្មណ៍ទាំងនោះ ក៏មិនមានដាប្រាកដ ។

(១២០) ម្នាលភិក្ខុទាំងឡាយ ចុះវេទនាតើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពួកវេទនានេះមាន ៦ យ៉ាងគឺ ចក្ខុសម្ផស្សជាវេទនា ១ ។បេ។ មនោសម្ផស្សជាវេទនា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាវេទនា ។ ការកើតឡើងនៃវេទនា ព្រោះការកើតឡើងនៃផស្សៈ ការរលត់នៃវេទនា ព្រោះការរលត់នៃផស្សៈ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ

វេទនានិរោធគាមិនីបដិបទា ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ យំ វេទនំ បដិច្ច ឧប្បជ្ជតិ សុខំ សោមនស្សំ អយំ វេទនាយ អស្សាទោ យា វេទនា អនិច្ចា ទុក្ខា វិបរិណាមធម្មា អយំ វេទនាយ អាទីនវោ យោ វេទនាយ ឆន្ទរាគវិនយោ ឆន្ទរាគប្ប-ហានំ ឥទំ វេទនាយ និស្សរណំ ។ យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឯវំ វេទនំ អភិញ្ញាយ ឯវំ វេទនាសមុទយំ អភិញ្ញាយ ឯវំ វេ-ទនានិរោធំ អភិញ្ញាយ ឯវំ វេទនានិរោធគាមិនីបដិបទំ អភិញ្ញាយ ឯវំ វេទនាយ អស្សាទំ អភិញ្ញាយ ឯវំ វេទនាយ អាទីនវំ អភិញ្ញាយ ឯវំ វេទនាយ និស្សរណំ អភិញ្ញាយ វេទនាយ និព្វិទាយ វិរាគាយ និរោធាយ បដិបន្នា តេ សុប្បដិបន្នា យេ សុប្បដិបន្នា តេ

នេះឯង ជាផ្លូវទៅកាន់ទីរលត់នៃវេទនា ។ មគ្គប្រកបដោយអង្គ ៨ តើអ្វីខ្លះ ។ គឺសម្មាទិដ្ឋិ ១ ។ បេ ។ សម្មាសមាធិ ១ ។ សេចក្តីសុខនិងសោមនស្សណា កើតឡើង ព្រោះអាស្រ័យនូវវេទនា នេះឈ្មោះថាអានិសង្សរបស់វេទនា វេទនាណា មិនទៀង ជាទុក្ខ មានសភាពប្រែប្រួលទៅជាធម្មតា នេះឈ្មោះថាទោសរបស់វេទនា ការបន្ទោបង់នូវឆន្ទរាគ ការលះបង់នូវឆន្ទរាគរបស់វេទនា ណា នេះឈ្មោះថាការរលាស់ចេញនូវវេទនា ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីពិតថា ពួកសមណៈឬព្រាហ្មណ៍ណាមួយ បានដឹងច្បាស់ នូវវេទនាយ៉ាងនេះ បានដឹងច្បាស់ នូវការកើតឡើងនៃវេទនាយ៉ាងនេះ បានដឹងច្បាស់ នូវការរលត់នៃវេទនា យ៉ាងនេះ បានដឹងច្បាស់នូវសេចក្តីប្រតិបត្តិទៅកាន់ទីរលត់នៃវេទនាយ៉ាងនេះ បានដឹងច្បាស់នូវអានិសង្សរបស់វេទនាយ៉ាងនេះ បានដឹងច្បាស់នូវទោសរបស់វេទនា យ៉ាងនេះ បានដឹងច្បាស់នូវការរលាស់ចេញនូវវេទនាយ៉ាងនេះ ហើយប្រតិបត្តិ ដើម្បីសេចក្តីនឿយណាយ ដើម្បីការប្រាសចាកតម្រេក ដើម្បីសេចក្តីរលត់នៃវេទនា ពួកសមណៈឬព្រាហ្មណ៍ទាំងនោះ ឈ្មោះថា បានប្រតិបត្តិដោយល្អ ពួកសមណៈឬព្រាហ្មណ៍ណា បានប្រតិបត្តិដោយល្អ ពួកសមណៈឬព្រាហ្មណ៍ ទាំងនោះ

ឥមស្មឹ ធម្មវិនយេ គាធន្តិ ។ យេ ច ខោ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឯវំ វេទនំ អភិញ្ញាយ ។ បេ ។ វដ្ដំ តេសំ នត្ថិ បញ្ញាបនាយ ។

[១៦១] កតមា ច ភិក្ខវេ សញ្ញា ។ ឆយិមេ ភិក្ខវេ សញ្ញាកាយា រូបសញ្ញា សទ្ទសញ្ញា គន្ធសញ្ញា រសសញ្ញា ផោដ្ឋព្វសញ្ញា ធម្មសញ្ញា ។ អយំ វុច្ចតិ ភិក្ខវេ សញ្ញា ។ ផស្សសមុទយា សញ្ញាសមុទយោ ផស្សនិរោធា សញ្ញានិរោធោ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ សញ្ញានិរោធគាមិនីបដិបទា ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ បេ ។ វដ្ដំ តេសំ នត្ថិ បញ្ញាបនាយ ។

ឈ្មោះថាឋិតនៅក្នុងធម្មវិន័យនេះ ។ ម្នាលភិក្ខុទាំងឡាយ ក៏ឯពួកសមណៈឬព្រាហ្មណ៍ណាមួយ បានដឹងច្បាស់នូវវេទនាយ៉ាងនេះ ។ បេ ។ វដ្តៈរបស់សមណៈនិងព្រាហ្មណ៍ទាំងនោះ ក៏មិនមានជាប្រាកដ ។

[១២១] ម្នាលភិក្ខុទាំងឡាយ ចុះសញ្ញា តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសញ្ញានេះមាន ៦ យ៉ាងគឺ រូបសញ្ញា ១ សទ្ទសញ្ញា ១ គន្ធសញ្ញា ១ រសសញ្ញា ១ ផោដ្ឋព្វសញ្ញា ១ ធម្មសញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សញ្ញា ។ ការកើតឡើងនៃសញ្ញា ព្រោះការកើតឡើងនៃផស្សៈ ការរលត់នៃសញ្ញា ព្រោះការរលត់នៃផស្សៈ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯង ជាសេចក្ដីប្រតិបត្តិទៅកាន់ទីរលត់នៃសញ្ញា ។ មគ្គប្រកបដោយអង្គ ៨ តើអ្វីខ្លះ ។ គឺសម្មាទិដ្ឋិ ១ ។ បេ ។ សម្មាសមាធិ ១ ។ បេ ។ វដ្តៈរបស់សមណៈនិងព្រាហ្មណ៍ទាំងនោះ ក៏មិនមានជាប្រាកដ ។

(១២២) កតមេ ច ភិក្ខវេ សង្ខារា ។ ឆ-យិមេ ភិក្ខវេ ចេតនាកាយា រូបសញ្ចេតនា ។ បេ ។ ធម្មសញ្ចេតនា ។ ឥមេ វុច្ចន្តិ ភិក្ខវេ សង្ខារា ។ ផស្សសមុទយា សង្ខារសមុទយោ ផស្សនិរោធា សង្ខា-រនិរោធោ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ សង្ខា-រនិរោធគាមិនីបដិបទា ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ យំ សង្ខារេ បដិច្ច ឧប្បជ្ជ-តិ សុខំ សោមនស្សំ អយំ សង្ខារានំ អស្សាទោ យេ សង្ខារា អនិច្ចា ទុក្ខា វិបរិណាមធម្មា អយំ សង្ខារានំ អាទីនវោ យោ សង្ខារេសុ ឆន្ទរាគវិន-យោ ឆន្ទរាគប្បហានំ ឥទំ សង្ខារានំ និស្សរណំ ។

[១២២] ម្នាលភិក្ខុទាំងឡាយ ចុះសង្ខារទាំងឡាយ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពួកចេតនានេះមាន ៦ ប្រការ គឺ រូបសញ្ចេតនា ១ ។ បេ ។ ធម្មសញ្ចេតនា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាសង្ខារ ។ ការកើតឡើងនៃសង្ខារ ព្រោះការកើតឡើងនៃផស្សៈ ការរលត់នៃសង្ខារ ព្រោះការរលត់នៃផស្សៈ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯង ជាសេចក្តីប្រតិបត្តិទៅកាន់ទីរលត់នៃសង្ខារ ។ មគ្គប្រកបដោយអង្គ ៨ តើដូចម្តេចខ្លះ ។ គឺសម្មាទិដ្ឋិ ១ ។ បេ ។ សម្មាសមាធិ ១ ។ សេចក្តីសុខនិងសោមនស្សណា កើតឡើង ព្រោះអាស្រ័យសង្ខារទាំងឡាយនេះឈ្មោះថា អានិសង្សរបស់សង្ខារទាំងឡាយ សង្ខារទាំងឡាយណាមិនទៀង ជាទុក្ខ មានសភាពប្រែប្រួលជាធម្មតា នេះឈ្មោះថា ទោសរបស់សង្ខារទាំងឡាយ ការបន្ទោបង់នូវឆន្ទរាគ ការលះបង់នូវឆន្ទរាគ ក្នុងសង្ខារទាំងឡាយណា នេះឈ្មោះថា ការរលាស់ចេញនូវសង្ខារទាំងឡាយ ។

យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឯវំ សង្ខារេ អភិញ្ញាយ ឯវំ សង្ខារសមុទយំ អភិញ្ញាយ ឯវំ សង្ខារនិរោធំ អភិញ្ញាយ ឯវំ សង្ខារនិរោធគា-មិនឹបដិបទំ អភិញ្ញាយ ។បេ។ សង្ខារានំ និព្វិទាយ វិរាគាយ និរោធាយ បដិបន្នា តេ សុប្បដិបន្នា យេ សុប្បដិបន្នា តេ ឥមស្មឹ ធម្មវិនយេ គាធន្តិ ។បេ។ វដ្ដំ តេសំ នត្ថិ បញ្ញាបនាយ ។

(១២៣) កតមញ្ច ភិក្ខវេ វិញ្ញាណំ ។ ឆយិមេ ភិក្ខវេ វិញ្ញាណកាយា ចក្ខុវិញ្ញាណំ សោតវិញ្ញាណំ ឃានវិញ្ញាណំ ជិវ្ហាវិញ្ញាណំ កាយវិញ្ញាណំ មនោ-

ម្នាលភិក្ខុទាំងឡាយ សេចក្ដីពិតថា ពួកសមណៈ ឬ ព្រាហ្មណ៍ណា នីមួយ បានដឹងច្បាស់ នូវសង្ខារទាំងឡាយយ៉ាងនេះ បានដឹងច្បាស់ នូវការកើតឡើងនៃសង្ខារយ៉ាងនេះ បានដឹងច្បាស់ នូវការរលត់នៃសង្ខារ យ៉ាងនេះ បានដឹងច្បាស់នូវសេចក្ដីប្រតិបត្តិទៅកាន់ទីរលត់នៃសង្ខារទាំង-ឡាយយ៉ាងនេះ ។ បេ ។ ហើយប្រតិបត្តិដើម្បីសេចក្ដីនឿយណាយ ដើម្បីការប្រាសចាកតម្រេក ដើម្បីសេចក្ដីរលត់នៃសង្ខារទាំងឡាយ ពួកសមណៈ ឬ ព្រាហ្មណ៍នោះ ឈ្មោះថាបានប្រតិបត្តិដោយល្អ ពួកសមណៈ ឬ ព្រាហ្មណ៍ណាបានប្រតិបត្តិល្អ ពួកសមណៈឬព្រាហ្មណ៍នោះ ឈ្មោះថាឋិតនៅក្នុងធម្មវិន័យនេះ ។ បេ ។ វដ្ដៈ របស់ពួកសមណៈនិងព្រាហ្មណ៍ទាំងនោះ ក៏មិនមានជាប្រាកដ ។

(១៦៣) ម្នាលភិក្ខុទាំងឡាយ វិញ្ញាណ តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពួកវិញ្ញាណនេះមាន ៦ យ៉ាងគឺ ចក្ខុវិញ្ញាណ ១ សោត-វិញ្ញាណ ១ ឃានវិញ្ញាណ ១ ជិវ្ហាវិញ្ញាណ ១ កាយវិញ្ញាណ ១ មនោ-

វិញ្ញាណំ ។ ឥទំ វុច្ចតិ វិញ្ញាណំ ។ នាមរូបសមុទយា វិញ្ញាណសមុទយោ នាមរូបនិរោធា វិញ្ញាណនិរោធោ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ វិញ្ញាណនិរោធគាមិនីបដិបទា ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ យំ វិញ្ញាណំ បដិច្ច ឧប្បជ្ជតិ សុខំ សោមនស្សំ អយំ វិញ្ញាណស្ស អស្សាទោ យំ វិញ្ញាណំ អនិច្ចំ ទុក្ខំ វិបរិណាមធម្មំ អយំ វិញ្ញាណស្ស អាទីនវោ យោ វិញ្ញាណស្មឹ ឆន្ទរាគវិនយោ ឆន្ទរាគប្បហានំ ឥទំ វិញ្ញាណស្ស និស្សរណំ ។ យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឯវំ វិញ្ញាណំ អភិញ្ញាយ ឯវំ វិញ្ញាណសមុទយំ អភិញ្ញាយ ឯវំ វិញ្ញាណនិរោធំ អភិញ្ញាយ ឯវំ វិញ្ញាណនិរោធគាមិនីបដិបទំ អភិញ្ញាយ ឯវំ វិញ្ញាណស្ស អស្សាទំ អភិញ្ញាយ ឯវំ វិញ្ញាណស្ស អាទីនវំ អភិញ្ញាយ ឯវំ វិញ្ញាណស្ស និស្សរណំ អភិញ្ញាយ វិញ្ញាណស្ស និព្វិទាយ វិរាគាយ និរោធាយ

វិញ្ញាណ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា វិញ្ញាណ ។ ការកើតឡើងនៃវិញ្ញាណ ព្រោះការកើតឡើងនៃនាមនិងរូប ការរលត់នៃវិញ្ញាណ ព្រោះការរលត់នៃនាមនិងរូប មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯង ជាសេចក្តីប្រតិបត្តិទៅកាន់ទីរលត់នៃវិញ្ញាណ ។ មគ្គប្រកបដោយអង្គ ៨ តើអ្វីខ្លះ ។ គឺសម្មាទិដ្ឋិ ១ ។ បេ ។ សម្មាសមាធិ ១ ។ សេចក្តីសុខនិងសោមនស្សណា កើតឡើង ព្រោះអាស្រ័យវិញ្ញាណនេះ ឈ្មោះថាអានិសង្សរបស់វិញ្ញាណ វិញ្ញាណណា មិនទៀង ជាទុក្ខមានសភាពប្រែប្រួលជាធម្មតា នេះឈ្មោះថាទោសរបស់វិញ្ញាណ ការបន្ទោបង់នូវឆន្ទរាគ ការលះបង់នូវឆន្ទរាគ ក្នុងវិញ្ញាណណា នេះឈ្មោះថាការរលាស់ចេញនូវវិញ្ញាណ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីពិតថា ពួកសមណៈឬព្រាហ្មណ៍ណាមួយ បានដឹងច្បាស់ នូវវិញ្ញាណយ៉ាងនេះ បានដឹងច្បាស់ នូវការកើតឡើងនៃវិញ្ញាណយ៉ាងនេះ បានដឹងច្បាស់ នូវការរលត់នៃវិញ្ញាណយ៉ាងនេះ បានដឹងច្បាស់ នូវសេចក្តីប្រតិបត្តិទៅកាន់ទីរលត់នៃវិញ្ញាណយ៉ាងនេះ បានដឹងច្បាស់ នូវអានិសង្សរបស់វិញ្ញាណយ៉ាងនេះ បានដឹងច្បាស់នូវទោសរបស់វិញ្ញាណយ៉ាងនេះ បានដឹងច្បាស់នូវការរលាស់ចេញនូវវិញ្ញាណយ៉ាងនេះ ហើយប្រតិបត្តិ ដើម្បីសេចក្តីនឿយណាយ ដើម្បីការប្រាសចាកតម្រេក ដើម្បីសេចក្តីរលត់នៃវិញ្ញាណ

បដិបន្នា តេ សុប្បដិបន្នា យេ សុប្បដិបន្នា តេ ឥមស្មឹ ធម្មវិនយេ គាធន្តិ ។ យេ ច ខោ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឯវំ វិញ្ញាណំ អភិញ្ញាយ ឯវំ វិញ្ញាណសមុទយំ អភិញ្ញាយ ឯវំ វិញ្ញាណនិរោធំ អភិញ្ញាយ ឯវំ វិញ្ញាណនិរោធគាមិនឹបដិបទំ អភិញ្ញាយ ឯវំ វិញ្ញាណស្ស អស្សាទំ អភិញ្ញាយ ឯវំ វិញ្ញាណស្ស អាទីនវំ អភិញ្ញាយ ឯវំ វិញ្ញាណស្ស និស្សរណំ អភិញ្ញាយ វិញ្ញាណស្ស និព្វិទា វិរាគា និរោធា អនុបាទា វិមុត្តា តេ សុវិមុត្តា យេ សុវិមុត្តា តេ កេវលិនោ យេ កេវលិនោ វដ្ដំ តេសំ នត្ថិ បញ្ញាបនាយ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ សត្តដ្ឋានកុសលោ ហោតិ ។

សមណៈឬព្រាហ្មណ៍ទាំងនោះ ឈ្មោះថាបានប្រតិបត្តិល្អ ពួកសមណៈ ឬព្រាហ្មណ៍ណា បានប្រតិបត្តិល្អ ពួកសមណៈ ឬព្រាហ្មណ៍នោះ ឈ្មោះថាឋិតនៅក្នុងធម្មវិន័យនេះ ។ ម្នាលភិក្ខុទាំងឡាយ ក៏ពួកសមណៈឬព្រាហ្មណ៍ ណាមួយ បានដឹងច្បាស់ នូវវិញ្ញាណយ៉ាងនេះ បានដឹងច្បាស់ នូវការកើតឡើងនៃវិញ្ញាណយ៉ាងនេះ បានដឹងច្បាស់ នូវការរលត់នៃវិញ្ញាណយ៉ាងនេះ បានដឹងច្បាស់ នូវសេចក្តីប្រតិបត្តិទៅកាន់ទីរលត់នៃវិញ្ញាណយ៉ាងនេះ បានដឹងច្បាស់ នូវអានិសង្សរបស់វិញ្ញាណយ៉ាងនេះ បានដឹងច្បាស់ នូវទោសរបស់វិញ្ញាណយ៉ាងនេះ បានដឹងច្បាស់ នូវការរលាស់ចេញនូវវិញ្ញាណយ៉ាងនេះ ហើយក៏ផុតស្រឡះ ព្រោះសេចក្តីនឿយណាយ ព្រោះប្រាសចាកតម្រេក ព្រោះរលត់ ព្រោះមិនប្រកាន់យកនូវវិញ្ញាណ ពួកសមណៈឬព្រាហ្មណ៍នោះ ឈ្មោះថាផុតស្រឡះដោយល្អ ពួកសមណៈឬព្រាហ្មណ៍ណា បានផុតស្រឡះល្អ ពួកសមណៈឬព្រាហ្មណ៍នោះ ឈ្មោះថាជាអ្នកមានកិច្ចបានធ្វើហើយ ពួកសមណៈឬព្រាហ្មណ៍ណា មានកិច្ចបានធ្វើហើយ វដ្តៈរបស់សមណៈនិងព្រាហ្មណ៍ទាំងនោះ ក៏មិនមានជាប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកឈ្លាសវៃក្នុងហេតុ ៧ ប្រការ យ៉ាងនេះឯង ។

(១២៤) កថញ្ច ភិក្ខវេ ភិក្ខុ តិវិធូបបរិក្ខី ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ ធាតុសោ ឧបបរិក្ខតិ អាយតនសោ ឧបបរិក្ខតិ បដិច្ចសមុប្បាទសោ ឧបបរិក្ខតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ តិវិធូបបរិក្ខី ហោតិ ។ សត្តដ្ឋានកុសលោ ភិក្ខវេ ភិក្ខុ តិវិធូបបរិក្ខី ឥមស្មឹ ធម្មវិនយេ កេវលី វុសិតវា ឧត្តមបុរិសោតិ វុច្ចតីតិ ។

(១២៥) សាវត្ថិយំ ។ តត្រ ខោ ។ តថាគតោ ភិក្ខវេ អរហំ សម្មាសម្ពុទ្ធោ រូបស្ស និព្វិទា វិរាគា និរោធា អនុបាទា វិមុត្តោ សម្មាសម្ពុទ្ធោតិ វុច្ចតិ ។ ភិក្ខុបិ ភិក្ខវេ បញ្ញាវិមុត្តោ រូបស្ស និព្វិទា

(១២៨) ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកពិចារណា នូវលក្ខណៈ ៣ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាតាមធាតុ ពិចារណាតាមអាយតនៈ ពិចារណាតាមបដិច្ចសមុប្បាទ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកពិចារណា នូវលក្ខណៈ ៣ ប្រការ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកឈ្លាសក្នុងហេតុ ៧ ប្រការ ជាអ្នកពិចារណានូវលក្ខណៈ ៣ ប្រការ តថាគតហៅថាជាឧត្តមបុរស មានកិច្ចបានធ្វើហើយ មានព្រហ្មចរិយ-ធម៌នៅរួចហើយ ក្នុងធម្មវិន័យនេះ ។

(១២៩) ក្នុងក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ផុតស្រឡះហើយ ព្រោះនឿយណាយ ព្រោះប្រាសចាកតម្រេក ព្រោះរលត់ ព្រោះមិនប្រកាន់យកនូវរូប បានជាហៅថាសម្មាសម្ពុទ្ធ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកខាងភិក្ខុជាបញ្ញាវិមុត្ត ផុតស្រឡះហើយ ព្រោះនឿយណាយ

វិរាគា និរោធា អនុបាទា វិមុត្តោតិ បញ្ញាវិមុត្តោតិ វុច្ចតិ ។ តថាគតោ ភិក្ខវេ អរហំ សម្មាសម្ពុទ្ធោ វេទនាយ និព្វិទា វិរាគា និរោធា អនុបាទា វិមុត្តោ សម្មាសម្ពុទ្ធោតិ វុច្ចតិ ។ ភិក្ខុបិ ភិក្ខវេ បញ្ញាវិមុត្តោ វេទនាយ និព្វិទា ។បេ។ បញ្ញាវិមុត្តោតិ វុច្ចតិ ។ តថាគតោ ភិក្ខវេ អរហំ សម្មាសម្ពុទ្ធោ សញ្ញាយ ។ សង្ខារានំ ។ វិញ្ញាណស្ស និព្វិទា វិរាគា និរោធា អនុបាទា វិមុត្តោ សម្មាសម្ពុទ្ធោតិ វុច្ចតិ ។ ភិក្ខុបិ ភិក្ខវេ បញ្ញាវិមុត្តោ វិញ្ញាណស្ស និព្វិទា វិរាគា និរោធា អនុបាទា វិមុត្តោ បញ្ញាវិមុត្តោតិ វុច្ចតិ ។

(១២៦) តត្រ[១] ភិក្ខវេ កោ វិសេសោ កោ អធិប្បាយសោ កិំ នានាករណំ តថាគតស្ស អរហតោ សម្មាសម្ពុទ្ធស្ស បញ្ញាវិមុត្តេន ភិក្ខុនាតិ ។

១ ឱ. ម. តត្រ ខោ ។

ព្រោះប្រាសចាកតម្រេក ព្រោះរលត់ ព្រោះមិនប្រកាន់យកនូវរូប ហៅជាបញ្ញាវិមុត្ត ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ផុតស្រឡះហើយ ព្រោះនឿយណាយ ព្រោះប្រាសចាកតម្រេក ព្រោះរលត់ ព្រោះមិនប្រកាន់យកនូវវេទនា បានជាហៅថាសម្មាសម្ពុទ្ធ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកខាងភិក្ខុជាបញ្ញាវិមុត្ត ព្រោះនឿយណាយចាកវេទនា ។ បេ ។ ហៅថាបញ្ញាវិមុត្ត ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ផុតស្រឡះហើយ ព្រោះនឿយណាយ ព្រោះប្រាសចាកតម្រេក ព្រោះរលត់ ព្រោះមិនប្រកាន់យកនូវសញ្ញា ។ នូវសង្ខារទាំងឡាយ ។ នូវវិញ្ញាណ បានជាហៅថាសម្មាសម្ពុទ្ធ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកខាងភិក្ខុជាបញ្ញាវិមុត្ត ផុតស្រឡះហើយ ព្រោះនឿយណាយ ព្រោះប្រាសចាកតម្រេក ព្រោះរលត់ ព្រោះមិនប្រកាន់យកនូវវិញ្ញាណ ហៅថាបញ្ញាវិមុត្ត ។

(១២៦) ម្នាលភិក្ខុទាំងឡាយ បណ្ដាភិក្ខុទាំងនោះ ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ មានគុណវិសេសដូចម្ដេច មានព្យាយាមលើស-លុបដូចម្ដេច មានហេតុផ្សេងគ្នាដូចម្ដេច អំពីភិក្ខុជាបញ្ញាវិមុត្ត ។

ភគវំមូលកា នោ ភន្តេ ធម្មា ភគវំនេត្តិកា ភគវំបដិសរណា សាធុ វត ភន្តេ ភគវន្តញ្ញេវ បដិភាតុ ឯតស្ស ភាសិតស្ស អត្ថោ ភគវតោ សុត្វា ភិក្ខូ ធារេស្សន្តីតិ ។ តេនហិ ភិក្ខវេ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច តថាគតោ ភិក្ខវេ អរហំ សម្មាសម្ពុទ្ធោ អនុប្បន្នស្ស មគ្គស្ស ឧប្បាទេតា អសញ្ជាតស្ស មគ្គស្ស សញ្ជនេតា អនក្ខាតស្ស មគ្គស្ស អក្ខាតា មគ្គញ្ញូ មគ្គវិទូ មគ្គកោវិទោ ។ មគ្គានុគា ច ភិក្ខវេ ឯតរហិ សាវកា វិហរន្តិ បច្ឆា សមន្នាគតា ។ អយំ ខោ ភិក្ខវេ វិសេសោ អយំ អធិប្បាយោសោ ឥទំ នានាករណំ តថាគតស្ស អរហតោ សម្មាសម្ពុទ្ធស្ស បញ្ញាវិមុត្តេន ភិក្ខុនាតិ ។

បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយរបស់យើងខ្ញុំ មានព្រះមានព្រះភាគជាប្រធាន មានព្រះមានព្រះភាគជាអ្នកណែនាំ មានព្រះមានព្រះភាគជាទីពឹង បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគទ្រង់ព្រះមេត្តាប្រោស បំភ្លឺសេចក្តីនៃភាសិតនេះឲ្យបាន ភិក្ខុទាំងឡាយបានស្តាប់ព្រះមានព្រះភាគហើយ នឹងចាំទុក ។ ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយចូរស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យល្អចុះ តថាគតនឹងសំដែង ។ ភិក្ខុទាំងនោះទទួលស្តាប់ព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ជាអ្នកញុំាងមគ្គដែលមិនទាន់កើត ឲ្យកើតឡើង ពន្យល់មគ្គដែលមិនទាន់ដឹងច្បាស់ឲ្យដឹងច្បាស់ បង្ហាញមគ្គដែលមិនទាន់បង្ហាញ ទ្រង់ដឹងមគ្គ ទ្រង់ជ្រាបមគ្គ ឈ្លាសវៃក្នុងមគ្គ (និងមិនមែនមគ្គ) ។ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលឥឡូវនេះ មានពួកសាវ័កអ្នកដើរតាមមគ្គ បានប្រកបតាមជាខាងក្រោយហើយ ។ ម្នាលភិក្ខុទាំងឡាយ តថាគតជាអរហន្តសម្មា-សម្ពុទ្ធ មានគុណវិសេសនេះឯង មានព្យាយាមលើសលុបនេះឯង មានហេតុផ្សេងគ្នានេះឯង អំពីភិក្ខុជាបញ្ញាវិមុត្ត ។

[១២៧] ឯកំ សមយំ ភគវា ពារាណសិយំ វិហរតិ ឥសិបតនេ មិគទាយេ ។ តត្រ ខោ ភគវា បញ្ចវគ្គិយេ ភិក្ខូ អាមន្តេសិ ។ បេ ។ ឯតទវោច រូបំ ភិក្ខវេ អនត្តា ។ រូបញ្ច ហិទំ ភិក្ខវេ អត្តា អភវិស្ស នយិទំ រូបំ អាពាធាយ សំវត្តេយ្យ លព្ភេថ ច រូបេ ឯវំ មេ រូបំ ហោតុ ឯវំ មេ រូបំ មា អហោសីតិ ។ យស្មា ច ខោ ភិក្ខវេ រូបំ អនត្តា តស្មា រូបំ អាពាធាយ សំវត្តតិ ន ច លព្ភតិ រូបេ ឯវំ មេ រូបំ ហោតុ ឯវំ មេ រូបំ មា អហោសីតិ ។ វេទនា ភិក្ខវេ(១) អនត្តា ។ វេទនា ច ហិទំ ភិក្ខវេ អត្តា អភវិស្ស នយិទំ វេទនា អាពាធាយ សំវត្តេយ្យ លព្ភេថ ច វេទនាយ ឯវំ មេ វេទនា ហោតុ ឯវំ មេ វេទនា មា អហោសីតិ ។

---

១ ឱ. ម. ភិក្ខវេតិ បាឋោ ន ទិស្សតិ ។

(១៦៧) សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងឥសិបតនមិគទាយវ័ន ទៀបក្រុងពារាណសី ។ ក្នុងទីនោះ ព្រះមានព្រះភាគ ត្រាស់ហៅពួកបញ្ចវគ្គិយភិក្ខុ ។ បេ ។ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ រូបមិនមែនជារបស់ខ្លួនទេ ។ ម្នាលភិក្ខុទាំងឡាយ បើរូបនេះ ជារបស់ខ្លួន រូបនេះនឹងមិនប្រព្រឹត្តទៅ ដើម្បីអាពាធឡើយ បុគ្គលគប្បីបាន (នូវអំណាច) ក្នុងរូបថា រូបរបស់អាត្មាអញ ចូរជាយ៉ាងនេះចុះ រូបរបស់អាត្មាអញ កុំទៅជាយ៉ាងនេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ រូបមិនមែនជារបស់ខ្លួន ព្រោះហេតុណា ព្រោះហេតុនោះ បានជារូបនេះតែប្រព្រឹត្តទៅដើម្បីអាពាធ បុគ្គលមិនបាន (នូវអំណាច) ក្នុងរូបថា រូបរបស់អាត្មាអញ ចូរជាយ៉ាងនេះចុះ រូបរបស់អាត្មាអញ កុំទៅជាយ៉ាងនេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ វេទនាមិនមែនជារបស់ខ្លួនទេ ។ ម្នាលភិក្ខុទាំងឡាយ បើវេទនានេះជារបស់ខ្លួន វេទនានេះ នឹងមិនប្រព្រឹត្តទៅដើម្បីអាពាធឡើយ បុគ្គលគប្បីបាន (នូវអំណាច) ក្នុងវេទនាថា វេទនារបស់អាត្មាអញ ចូរជាយ៉ាងនេះចុះ វេទនារបស់អាត្មាអញ កុំទៅជាយ៉ាងនេះឡើយ ។

យស្មា ច ខោ ភិក្ខវេ វេទនា អនត្តា តស្មា វេទនា អាពាធាយ សំវត្តតិ ន ច លព្ភតិ វេទនាយ ឯវំ មេ វេទនា ហោតុ ឯវំ មេ វេទនា មា អហោសីតិ ។ សញ្ញា ភិក្ខវេ អនត្តា ។ សង្ខារា ភិក្ខវេ អនត្តា ។ សង្ខារា ច ហិទំ ភិក្ខវេ អត្តា អភវិស្សំសុ ន យិទំ សង្ខារា អាពាធាយ សំវត្តេយ្យុំ លព្ភេថ ច សង្ខារេសុ ឯវំ មេ សង្ខារា ហោន្តុ ឯវំ មេ សង្ខារា មា អហេសុន្តិ ។ យស្មា ច ខោ ភិក្ខវេ សង្ខារា អនត្តា តស្មា សង្ខារា អាពាធាយ សំវត្តន្តិ ន ច លព្ភតិ សង្ខារេសុ ឯវំ មេ សង្ខារា ហោន្តុ ឯវំ មេ សង្ខារា មា អហេសុន្តិ ។ វិញ្ញាណំ ភិក្ខវេ អនត្តា ។

ម្នាលភិក្ខុទាំងឡាយ វេទនា មិនមែនជារបស់ខ្លួន ព្រោះហេតុណា ព្រោះហេតុនោះ បានជាវេទនាចេះតែប្រព្រឹត្តទៅដើម្បីអាពាធ បុគ្គលមិនបាន (នូវអំណាច) ក្នុងវេទនាថា វេទនារបស់អាត្មាអញ ចូរជាយ៉ាងនេះចុះ វេទនារបស់អាត្មាអញ កុំទៅជាយ៉ាងនេះឡើយ ។ ម្នាលភិក្ខុទាំង-ឡាយ សញ្ញាមិនមែនជារបស់ខ្លួនទេ ។ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយមិនមែនជារបស់ខ្លួនទេ ។ ម្នាលភិក្ខុទាំងឡាយ បើសង្ខារនេះជារបស់ខ្លួន សង្ខារនេះ នឹងមិនប្រព្រឹត្តទៅ ដើម្បីអាពាធឡើយ បុគ្គលគប្បីបាន (នូវអំណាច) ក្នុងសង្ខារទាំងឡាយថា សង្ខារទាំង-ឡាយ របស់អាត្មាអញ ចូរជាយ៉ាងនេះចុះ សង្ខារទាំងឡាយរបស់អាត្មាអញ កុំទៅជាយ៉ាងនេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មិនមែនជារបស់ខ្លួន ព្រោះហេតុណា ព្រោះហេតុនោះ បានជាសង្ខារទាំងឡាយ ចេះតែប្រព្រឹត្តទៅដើម្បីអាពាធ បុគ្គលមិនបាន (នូវអំណាច) ក្នុងសង្ខារទាំងឡាយថា សង្ខារទាំងឡាយរបស់អាត្មាអញ ចូរជាយ៉ាងនេះចុះ សង្ខារទាំងឡាយរបស់អាត្មាអញ កុំទៅជាយ៉ាងនេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ វិញ្ញាណមិនមែនជារបស់ខ្លួនទេ ។

វិញ្ញាណញ្ច ហិទំ ភិក្ខវេ អត្តា អភវិស្ស នយិទំ វិញ្ញាណំ អាពាធាយ សំវត្តេយ្យ លព្ភេថ ច វិញ្ញាណេ ឯវំ មេ វិញ្ញាណំ ហោតុ ឯវំ មេ វិញ្ញាណំ មា អហោសីតិ ។ យស្មា ច ខោ ភិក្ខវេ វិញ្ញាណំ អនត្តា តស្មា វិញ្ញាណំ អាពាធាយ សំវត្តតិ ន ច លព្ភតិ វិញ្ញាណេ ឯវំ មេ វិញ្ញាណំ ហោតុ ឯវំ មេ វិញ្ញាណំ មា អហោសីតិ ។

(១២៨) តំ កិំ មញ្ញថ ភិក្ខវេ រូបំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ វេទនា ។

មាលុក្យបុត្ត ចាំងឡាយ បើវិញ្ញាណនេះ ជារបស់ខ្លួន វិញ្ញាណនេះនឹងមិនប្រព្រឹត្តទៅ ដើម្បីអាពាធឡើយ បុគ្គលគប្បីបាន (នូវអំណាច) ក្នុងវិញ្ញាណថា វិញ្ញាណរបស់អាត្មាអញ ចូរជាយ៉ាងនេះចុះ វិញ្ញាណរបស់អាត្មាអញ កុំទៅជាយ៉ាងនេះឡើយ ។ មាលុក្យបុត្តចាំងឡាយ វិញ្ញាណមិនមែនជារបស់ខ្លួន ព្រោះហេតុណា ព្រោះហេតុនោះ បានជាវិញ្ញាណរមែងតែប្រព្រឹត្តទៅ ដើម្បីអាពាធ បុគ្គលមិនបាន (នូវអំណាច) ក្នុងវិញ្ញាណថា វិញ្ញាណរបស់អាត្មាអញ ចូរជាយ៉ាងនេះចុះ វិញ្ញាណរបស់អាត្មាអញ កុំទៅជាយ៉ាងនេះឡើយ ។

(១២៨) មាលុក្យបុត្តចាំងឡាយ អ្នកចាំងឡាយសំគាល់ហេតុនោះដូចម្តេច រូបទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរូបណាមិនទៀង រូបនោះជាទុក្ខ ឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរូបណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា អ្នកចាំងឡាយ គួរយល់ឃើញនូវរូបនោះថា នុ៎ះរបស់អាត្មាអញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អាត្មាអញដែរឬ ។ មិនគួរយល់ឃើញយ៉ាងនុ៎ះទេ ព្រះអង្គ ។ វេទនា ។

សញ្ញា ។ សង្ខារា ។ វិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តា ។ នោ ហេតំ ភន្តេ ។

(១២៩) តស្មាតិហ ភិក្ខវេ យំ កិញ្ចិ រូបំ អតីតានាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា សព្វំ រូបំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ យា កាចិ វេទនា អតីតានាគតប្បច្ចុប្បន្នា ។បេ ។

សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះវិញ្ញាណណា មិនទៀង វិញ្ញាណនោះជាទុក្ខឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះវិញ្ញាណណា ដែលមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា អ្នកទាំងឡាយគួរយល់ឃើញនូវវិញ្ញាណនោះថា នុ៎ះរបស់អាត្មាអញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អាត្មាអញដែរឬ ។ មិនគួរយល់ឃើញយ៉ាងនុ៎ះទេ ព្រះអង្គ ។

[១៦៩] ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ រូបណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ជាខាងក្នុងក្តី ខាងក្រៅក្តី គ្រោត-គ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី ឬរូបណា ដែលមានក្នុងទីឆ្ងាយក្តី មានក្នុងទីជិតក្តី រូបទាំងអស់នោះ គ្រាន់តែជារូបប៉ុណ្ណោះ បុគ្គលគួរឃើញនូវរូបនុ៎ះ ដោយបញ្ញាដ៏ប្រពៃតាមពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អាត្មាអញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អាត្មាអញឡើយ ។ វេទនាណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ។បេ។

យា ទូរេ សន្តិកេ វា សព្វា វេទនា នេតំ មម នេសោ-
ហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្ប-
ញ្ញាយ ទដ្ឋព្វំ ។ យា កាចិ សញ្ញា ។ យេ កេចិ
សង្ខារា អតីតានាគតបច្ចុប្បន្នា ។ បេ ។ យេ ទូរេ
សន្តិកេ វា សព្វេ សង្ខារា នេតំ មម នេសោហមស្មិ
ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ
ទដ្ឋព្វំ ។ យំ កិញ្ចិ វិញ្ញាណំ អតីតានាគតបច្ចុប្បន្នំ
អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា
បណីតំ វា យំ ទូរេ សន្តិកេ វា សព្វំ វិញ្ញាណំ
នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ
យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។

ឬវេទនាណាមួយ ដែលមានក្នុងទីឆ្ងាយក្តី មានក្នុងទីជិតក្តី វេទនាទាំងអស់នោះ គ្រាន់តែជាវេទនាប៉ុណ្ណោះ បុគ្គលគួរឃើញនូវវេទនានុ៎ះដោយបញ្ញាដ៏ប្រពៃតាមពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អាត្មាអញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អាត្មាអញឡើយ ។ សញ្ញាណាមួយ ។ សង្ខារទាំងឡាយណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ។ បេ ។ ដែលមានក្នុងទីឆ្ងាយក្តី មានក្នុងទីជិតក្តី សង្ខារទាំងអស់នោះ គ្រាន់តែជាសង្ខារប៉ុណ្ណោះ បុគ្គលគប្បីឃើញនូវសង្ខារនុ៎ះដោយបញ្ញាដ៏ប្រពៃតាមពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អាត្មាអញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អាត្មាអញឡើយ ។ វិញ្ញាណណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ជាខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី ដែលមានក្នុងទីឆ្ងាយក្តី មានក្នុងទីជិតក្តី វិញ្ញាណទាំងអស់នោះ គ្រាន់តែជាវិញ្ញាណប៉ុណ្ណោះ បុគ្គលគួរឃើញនូវវិញ្ញាណនុ៎ះ ដោយបញ្ញាដ៏ប្រពៃតាមពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អាត្មាអញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អាត្មាអញឡើយ ។

[១៣០] ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ រូបស្មឹបិ និព្វិន្ទតិ វេទនាយបិ និព្វិន្ទតិ សញ្ញាយបិ និព្វិន្ទតិ សង្ខារេសុបិ និព្វិន្ទតិ វិញ្ញាណស្មឹបិ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ ។ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ។ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។ ឥទមវោច ភគវា ។ អត្តមនា បញ្ចវគ្គិយា ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុំ ។ ឥមស្មិញ្ច បន វេយ្យាករណស្មឹ ភញ្ញមានេ បញ្ចវគ្គិយានំ ភិក្ខូនំ អនុបាទាយ អាសវេហិ ចិត្តានិ វិមុច្ចឹសូតិ ។

[១៣១] ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ អថខោ មហាលិ លិច្ឆវី យេន ភគវា តេនុបសង្កមិ ។ បេ ។ ឯកមន្តំ និសិន្នោ ខោ មហាលិ លិច្ឆវី ភគវន្តំ ឯតទវោច

[១៣០] ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កជាអ្នកចេះដឹង កាលបើបានឃើញយ៉ាងនេះ រមែងនឿយណាយក្នុងរូបផង នឿយណាយក្នុងវេទនាផង នឿយណាយក្នុងសញ្ញាផង នឿយណាយក្នុងសង្ខារទាំង-ឡាយផង នឿយណាយក្នុងវិញ្ញាណផង កាលបើនឿយណាយ រមែងប្រាសចាកតម្រេក តែងផុតស្រឡះ ព្រោះប្រាសចាកតម្រេក ។ កាលបើចិត្តផុតស្រឡះហើយ ប្រាជ្ញាក៏កើតឡើងថា ចិត្តផុតស្រឡះហើយ ។ ព្រះអរិយសាវ័កនោះដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌ អាត្មាអញបាននៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើរួចហើយ មគ្គ-ភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ លុះព្រះមានព្រះភាគទ្រង់ត្រាស់ភាសិតនេះហើយ ។ ពួកបញ្ចវគ្គិយភិក្ខុក៏ពេញចិត្ត ត្រេកអរចំពោះភាសិត នៃព្រះមានព្រះភាគ ។ កាលដែលព្រះមានព្រះភាគ ទ្រង់ត្រាស់វេយ្យាករណ៍នេះហើយ ចិត្តរបស់បញ្ច-វគ្គិយភិក្ខុ ក៏ផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់ ។

[១៣១] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងកូដាគារសាលា នាមហាវ័ន ទៀបក្រុងវេសាលី ។ គ្រានោះឯងស្តេចលិច្ឆវីឈ្មោះមហាលិ ចូលទៅគាល់ព្រះមានព្រះភាគ ។ បេ ។ លុះមហាលិលិច្ឆវី គង់ក្នុងទីសមគួរហើយ ទើបក្រាបទូលព្រះមានព្រះភាគ

បូរណោ ភន្តេ កស្សបោ ឯវមាហ នត្ថិ ហេតុ នត្ថិ បច្ចយោ សត្តានំ សង្កិលេសាយ អហេតូ អប្បច្ចយា សត្តា សង្កិលិស្សន្តិ នត្ថិ ហេតុ នត្ថិ បច្ចយោ សត្តានំ វិសុទ្ធិយា អហេតូ អប្បច្ចយា សត្តា វិសុជ្ឈន្តីតិ ឥធ ភគវា កិមាហាតិ ។ អត្ថិ មហាលិ ហេតុ អត្ថិ បច្ចយោ សត្តានំ សង្កិលេសាយ សហេតូ សប្បច្ចយា សត្តា សង្កិលិស្សន្តិ អត្ថិ មហាលិ ហេតុ អត្ថិ បច្ចយោ សត្តានំ វិសុទ្ធិយា សហេតូ សប្បច្ចយា សត្តា វិសុជ្ឈន្តីតិ ។ កតមោ បន ភន្តេ ហេតុ កតមោ បច្ចយោ សត្តានំ សង្កិលេសាយ កថំ សហេតូ សប្បច្ចយា សត្តា សង្កិលិស្សន្តិ ។ រូបញ្ច ហិទំ មហាលិ ឯកន្តទុក្ខំ អភវិស្ស ទុក្ខានុបតិតំ ទុក្ខាវក្កន្តំ អនវក្កន្តំ សុខេន

យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន គ្រូឈ្មោះបូរណកស្សបបានពោលពាក្យយ៉ាងនេះថា ហេតុឬបច្ច័យ ដែលនាំឲ្យសត្វទាំងឡាយសៅហ្មងមិនមានឡើយ សត្វទាំងឡាយមិនមានហេតុ មិនមានបច្ច័យ នាំឲ្យសៅហ្មងទេ ទាំងហេតុឬបច្ច័យ ដែលនាំឲ្យសត្វទាំងឡាយបរិសុទ្ធ ក៏មិនមាន សត្វទាំងឡាយមិនមានហេតុ មិនមានបច្ច័យ នាំឲ្យបរិសុទ្ធឡើយ ចុះក្នុងរឿងនេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូចម្តេច ។ ម្នាលមហាលិ ហេតុ ឬបច្ច័យដែលនាំឲ្យសត្វទាំងឡាយសៅហ្មងតែងមាន សត្វទាំងឡាយ សុទ្ធតែមានហេតុមានបច្ច័យនាំឲ្យសៅហ្មង ម្នាលមហាលិ ហេតុឬបច្ច័យ ដែលនាំសត្វទាំងឡាយឲ្យបរិសុទ្ធមាន សត្វទាំងឡាយមានហេតុមានបច្ច័យនាំឲ្យបរិសុទ្ធស្អាតបាន ។ បពិត្រព្រះអង្គដ៏ចំរើន ចុះហេតុដូចម្តេច បច្ច័យដូចម្តេច ដែលនាំឲ្យសត្វទាំងឡាយសៅហ្មង ចុះសត្វទាំងឡាយ មានហេតុ មានបច្ច័យ នាំឲ្យសៅហ្មង ដោយប្រការដូចម្តេច ។ ម្នាលមហាលិ រូបនេះ មានទុក្ខតែម្យ៉ាង មានទុក្ខជាប់តាម មានទុក្ខគ្របសង្កត់ មិនទាន់មានសេចក្តីសុខ មកគ្របដណ្តប់នៅឡើយ

ន យិទំ សត្តា រូបស្មឹ សារជ្ជេយ្យុំ ។ យស្មា ច ខោ មហាលិ រូបំ សុខំ សុខានុបតិតំ សុខាវក្កន្តំ អនវក្កន្តំ ទុក្ខេន តស្មា សត្តា រូបស្មឹ សារជ្ជន្តិ សារាគា សញ្ញុជ្ជន្តិ សញ្ញោគា សង្កិលិស្សន្តិ ។ អយំបិ ខោ មហាលិ ហេតុ អយំ បច្ចយោ សត្តានំ សង្កិលេសាយ ។ ឯវំបិ សហេតូ សប្បច្ចយា សត្តា សង្កិលិស្សន្តិ ។ វេទនា ច ហិទំ មហាលិ ឯកន្តទុក្ខា អភវិស្ស ទុក្ខានុបតិតា ទុក្ខាវក្កន្តា អនវក្កន្តា សុខេន ន យិទំ សត្តា វេទនាយ សារជ្ជេយ្យុំ ។ យស្មា ច ខោ មហាលិ វេទនា សុខា សុខានុបតិតា សុខាវក្កន្តា អនវក្កន្តា ទុក្ខេន តស្មា សត្តា វេទនាយ សារជ្ជន្តិ សារាគា សញ្ញុជ្ជន្តិ សញ្ញោគា សង្កិលិស្សន្តិ ។ អយំបិ ខោ មហាលិ ហេតុ អយំ បច្ចយោ សត្តានំ សង្កិលេសាយ ។ ឯវំបិ សហេតូ សប្បច្ចយា សត្តា សង្កិលិស្សន្តិ ។ សញ្ញា ច ហិទំ មហាលិ ។ សង្ខារា ច ហិទំ មហាលិ ឯកន្តទុក្ខា អភវិស្សំសុ

ជារូបដែលពួកសត្វមិនគួរត្រេកអរទេ ។ ម្នាលមហាលិ តែរូបនេះជាសុខ មានសុខជាប់តាម មានសុខគ្របដណ្តប់ មិនទាន់មានទុក្ខគ្របសង្កត់ទៅឡើយ ព្រោះហេតុណា ព្រោះហេតុនោះ ពួកសត្វរមែងត្រេកអរ ក្នុងរូប ព្រោះតែមានសេចក្តីត្រេកអរ បានជាជាប់ចំពាក់ ព្រោះមានការជាប់ចំពាក់ បានជាសៅហ្មង ។ ម្នាលមហាលិ នេះឯងជាហេតុ នេះឯងជាបច្ច័យ ដែលនាំឲ្យសត្វទាំងឡាយសៅហ្មង ។ សត្វទាំងឡាយមានហេតុ មានបច្ច័យនាំឲ្យសៅហ្មង យ៉ាងនេះឯង ។ ម្នាលមហាលិ វេទនានេះ មានទុក្ខតែម្យ៉ាង មានទុក្ខជាប់តាម មានទុក្ខគ្របសង្កត់ មិនទាន់មានសុខគ្របដណ្តប់ទៅឡើយ ជាវេទនាដែលសត្វទាំងឡាយមិនគួរត្រេកអរទេ ។ ម្នាលមហាលិ តែវេទនានេះជាសុខ មានសុខជាប់តាម មានសុខគ្របដណ្តប់ មិនទាន់មានទុក្ខមកគ្របសង្កត់ទៅឡើយ ព្រោះហេតុណា ព្រោះហេតុនោះ សត្វទាំងឡាយរមែងត្រេកអរក្នុងវេទនា ព្រោះមានសេចក្តីត្រេកអរ បានជាជាប់ចំពាក់ ព្រោះមានការជាប់ចំពាក់បានជាសៅហ្មង ។ ម្នាលមហាលិ នេះឯងជាហេតុ នេះឯងជាបច្ច័យដែលនាំឲ្យសត្វទាំងឡាយសៅហ្មង ។ សត្វទាំងឡាយមានហេតុ មានបច្ច័យនាំឲ្យសៅហ្មង យ៉ាងនេះឯង ។ ម្នាលមហាលិ សញ្ញានេះ ។ ម្នាលមហាលិ សង្ខារទាំងឡាយនេះ មានទុក្ខតែម្យ៉ាង

ទុក្ខានុបតិតា ទុក្ខាវក្កន្តា អនវក្កន្តា សុខេន ន យិទំ សត្តា សង្ខារេសុ សារជ្ជេយ្យុំ ។ យស្មា ច ខោ មហាលិ សង្ខារា សុខា សុខានុបតិតា សុខាវក្កន្តា អនវក្កន្តា ទុក្ខេន តស្មា សត្តា សង្ខារេសុ សារជ្ជន្តិ សារាគា សញ្ញុជ្ជន្តិ សញ្ញោគា សង្កិលិស្សន្តិ ។ អយំបិ ខោ មហាលិ ហេតុ អយំ បច្ចយោ សត្តានំ សង្កិលេសាយ ។ ឯវំបិ សហេតូ សប្បច្ចយា សត្តា សង្កិលិស្សន្តិ ។ វិញ្ញាណញ្ចេ ហិទំ មហាលិ ឯកន្តទុក្ខំ អភវិស្ស ទុក្ខានុបតិតំ ទុក្ខាវក្កន្តំ អនវក្កន្តំ សុខេន ន យិទំ សត្តា វិញ្ញាណស្មឹ សារជ្ជេយ្យុំ ។ យស្មា ច ខោ មហាលិ វិញ្ញាណំ សុខំ សុខានុបតិតំ សុខាវក្កន្តំ អនវក្កន្តំ ទុក្ខេន តស្មា

មានទុក្ខជាប់តាម មានទុក្ខគ្របសង្កត់ មិនទាន់មានសេចក្តីសុខមកគ្របដណ្តប់នៅឡើយ ជាសង្ខារដែលសត្វទាំងឡាយ មិនគួរត្រេកអរទេ ។ ម្នាលមហាលិ តែសង្ខារទាំងឡាយនេះ ជាសុខ មានសុខជាប់តាម មានសុខគ្របដណ្តប់ មិនទាន់មានទុក្ខមកគ្របសង្កត់នៅឡើយ ព្រោះហេតុណា ព្រោះហេតុនោះ សត្វទាំងឡាយ តែងត្រេកអរក្នុងសង្ខារទាំងឡាយ ព្រោះតែមានសេចក្តីត្រេកអរ បានជាជាប់ចំពាក់ ព្រោះមានការជាប់ចំពាក់ បានជាសៅហ្មង ។ ម្នាលមហាលិ នេះឯងជាហេតុ នេះឯងជាបច្ច័យ ដែលនាំឲ្យសត្វទាំងឡាយសៅហ្មង ។ សត្វទាំងឡាយ មានហេតុ មានបច្ច័យនាំឲ្យសៅហ្មង យ៉ាងនេះឯង ។ ម្នាលមហាលិ វិញ្ញាណនេះ មានទុក្ខតែម្យ៉ាង មានទុក្ខជាប់តាម មានទុក្ខគ្របសង្កត់ មិនទាន់មានសេចក្តីសុខមកគ្របដណ្តប់នៅឡើយ ជាវិញ្ញាណដែលសត្វទាំងឡាយមិនគួរត្រេកអរទេ ។ ម្នាលមហាលិ តែវិញ្ញាណនេះជាសុខ មានសុខជាប់តាម មានសុខគ្របដណ្តប់ មិនទាន់មានទុក្ខមកគ្របសង្កត់នៅឡើយ ព្រោះហេតុណា ព្រោះហេតុនោះ

សត្តា វិញ្ញាណស្មឹ សារជ្ជន្តិ សារាគា សញ្ញុជ្ជន្តិ សញ្ញោគា សង្កិលិស្សន្តិ ។ អយំបិ ខោ មហាលិ ហេតុ អយំ បច្ចយោ សត្តានំ សង្កិលេសាយ ។ ឯវំបិ សហេតូ សប្បច្ចយា សត្តា សង្កិលិស្សន្តីតិ ។

(១៣៦) កតមោ ច ភន្តេ ហេតុ កតមោ បច្ចយោ សត្តានំ វិសុទ្ធិយា កថំ សហេតូ សប្បច្ចយា សត្តា វិសុជ្ឈន្តីតិ ។ រូបញ្ច ហិទំ មហាលិ ឯកន្តសុខំ អភវិស្ស សុខានុបតិតំ សុខាវក្កន្តំ អនវក្កន្តំ ទុក្ខេន ន យិទំ សត្តា រូបស្មឹ និព្វិន្ទេយ្យុំ ។ យស្មា ច ខោ មហាលិ រូបំ ទុក្ខំ ទុក្ខានុបតិតំ ទុក្ខាវក្កន្តំ អនវក្កន្តំ សុខេន តស្មា សត្តា រូបស្មឹ និព្វិន្ទន្តិ និព្វិន្ទំ វិរជ្ជន្តិ វិរាគា វិសុជ្ឈន្តិ ។ អយំបិ ខោ មហាលិ ហេតុ

សត្វទាំងឡាយ រមែងត្រេកអរក្នុងវិញ្ញាណ ព្រោះតែមានសេចក្តីត្រេកអរ បានជាជាប់ចំពាក់ ព្រោះមានការជាប់ចំពាក់ បានជាសៅហ្មង ។ ម្នាលមហាលិ នេះឯងជាហេតុ នេះឯងជាបច្ច័យ ដែលនាំឲ្យសត្វទាំងឡាយសៅហ្មង ។ សត្វទាំងឡាយ មានហេតុមានបច្ច័យ នាំឲ្យសៅហ្មងយ៉ាងនេះឯង ។

(១៣៤) បពិត្រព្រះអង្គដ៏ចម្រើន ចុះហេតុដូចម្តេច បច្ច័យដូចម្តេច ដែលនាំឲ្យសត្វទាំងឡាយបរិសុទ្ធ ចុះសត្វទាំងឡាយមានហេតុមានបច្ច័យនាំឲ្យបរិសុទ្ធ ដោយប្រការដូចម្តេច ។ ម្នាលមហាលិ រូបនេះ មានសេចក្តីសុខតែម្យ៉ាង មានសុខជាប់តាម មានសុខគ្របដណ្តប់ មិនទាន់មានទុក្ខមកគ្របសង្កត់នៅឡើយ ជារូបដែលសត្វទាំងឡាយ មិនគួរនឿយណាយទេ ។ ម្នាលមហាលិ តែរូបនេះជាទុក្ខ មានទុក្ខជាប់តាម មានទុក្ខគ្របសង្កត់ មិនទាន់មានសុខមកគ្របដណ្តប់នៅឡើយ ព្រោះហេតុណា ព្រោះហេតុនោះ សត្វទាំងឡាយរមែងនឿយណាយ ក្នុងរូប កាលបើនឿយណាយហើយ ក៏ប្រាសចាកតម្រេក ព្រោះប្រាសចាកតម្រេក ទើបបរិសុទ្ធ ។ ម្នាលមហាលិ នេះជាហេតុ

អយំ បច្ចយោ សត្តានំ វិសុទ្ធិយា ។ ឯវម្បិ សហេតូ
សប្បច្ចយា សត្តា វិសុជ្ឈន្តិ ។ វេទនា ច ហិទំ មហាលិ
ឯកន្តសុខា អភវិស្ស ។ បេ ។ សញ្ញា ច ហិទំ មហា-
លិ ។ សង្ខារា ច ហិទំ មហាលិ ឯកន្តសុខា អភវិស្សំ-
សុ ។ វិញ្ញាណញ្ច ហិទំ មហាលិ ឯកន្តសុខំ អភវិស្ស
សុខានុបតិតំ សុខាវក្កន្តំ អនវក្កន្តំ ទុក្ខេន ន យិទំ
សត្តា វិញ្ញាណស្មឹ និព្វិន្ទេយ្យុំ ។ យស្មា ច ខោ មហា-
លិ វិញ្ញាណំ ទុក្ខំ ទុក្ខានុបតិតំ ទុក្ខាវក្កន្តំ អនវក្កន្តំ
សុខេន តស្មា សត្តា វិញ្ញាណស្មឹ និព្វិន្ទន្តិ និព្វិន្ទំ
វិរជ្ជន្តិ វិរាគា វិសុជ្ឈន្តិ ។ អយំបិ ខោ មហាលិ ហេតុ
អយំ បច្ចយោ សត្តានំ វិសុទ្ធិយា ។ ឯវម្បិ សហេតូ
សប្បច្ចយា សត្តា វិសុជ្ឈន្តីតិ ។

នេះជាបច្ច័យ ដែលនាំឱ្យសត្វទាំងឡាយបរិសុទ្ធ ។ សត្វទាំងឡាយមានហេតុ មានបច្ច័យនាំឱ្យបរិសុទ្ធ យ៉ាងនេះឯង ។ ម្នាលមហាលិ វេទនានេះ មានសេចក្តីសុខតែម្យ៉ាង ។ បេ ។ បពិត្រមហាលិ សញ្ញានេះ ។ ម្នាលមហាលិ សង្ខារទាំងឡាយនេះ មានសេចក្តីសុខតែម្យ៉ាង ។ ម្នាលមហាលិ វិញ្ញាណនេះ មានសេចក្តីសុខតែម្យ៉ាង មានសុខជាប់តាម មានសុខគ្របដណ្តប់ មិនទាន់មានទុក្ខមកគ្របសង្កត់នៅឡើយ ជាវិញ្ញាណដែលសត្វទាំងឡាយមិនគួរនឿយណាយ ។ ម្នាលមហាលិ តែវិញ្ញាណនេះ ជាទុក្ខ មានទុក្ខជាប់តាម មានទុក្ខគ្របសង្កត់ មិនទាន់មានសុខមកគ្របដណ្តប់នៅឡើយ ព្រោះហេតុណា ព្រោះហេតុនោះ សត្វទាំងឡាយទើបនឿយណាយក្នុងវិញ្ញាណ កាលបើនឿយណាយហើយ ក៏ប្រាសចាកតម្រេក ព្រោះប្រាសចាកតម្រេក ទើបបរិសុទ្ធ ។ ម្នាលមហាលិ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឱ្យសត្វទាំងឡាយបរិសុទ្ធ ។ ពួកសត្វមានហេតុ មានបច្ច័យនាំឱ្យបរិសុទ្ធ យ៉ាងនេះឯង ។

(១៣៣) សាវត្ថិយំ ។ តត្រ ខោ ។ រូបំ ភិក្ខវេ អនិច្ចំ វេទនា អនិច្ចា សញ្ញា អនិច្ចា សង្ខារា អនិច្ចា វិញ្ញាណំ អនិច្ចំ ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ រូបស្មឹបិ និព្វិន្ទតិ វេទនាយបិ ។ សញ្ញាយបិ ។ សង្ខារេសុបិ ។ វិញ្ញាណស្មឹបិ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ ។បេ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

(១៣៤) សាវត្ថិយំ ។ តត្រ ខោ ។ តយោមេ ភិក្ខវេ និរុត្តិបថា អធិវចនបថា បញ្ញត្តិបថា អសង្កិណ្ណា អសង្កិណ្ណបុព្វា ន សង្កិយន្តិ ន សង្កិយិស្សន្តិ អប្បដិកុដ្ឋា សមណេហិ ព្រាហ្មណេហិ វិញ្ញូហិ ។ កតមេ តយោ ។ យំ(១) ភិក្ខវេ រូបំ អតីតំ និរុទ្ធំ វិបរិណតំ

១ ម. យំហិ ។

(១៣៣) ក្នុងក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ រូបក្តៅ វេទនាក្តៅ សញ្ញាក្តៅ សង្ខារក្តៅ វិញ្ញាណក្តៅ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវក ជាអ្នកចេះដឹងឃើញយ៉ាងនេះ រមែងនឿយណាយ ក្នុងរូបផង ក្នុងវេទនាផង ។ ក្នុងសញ្ញាផង ។ ក្នុងសង្ខារទាំងឡាយផង ។ នឿយណាយ ក្នុងវិញ្ញាណផង កាលបើនឿយណាយ ក៏ប្រាសចាកតម្រេក ។បេ។ រមែងដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

(១៣៤) ក្នុងក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ សភាវៈទាំង ៣ យ៉ាងនេះ គឺ គន្លងពាក្យ ១ គន្លងឈ្មោះ ១ គន្លងបញ្ញត្តិ ១ ពួកសមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញ មិនដែលលះបង់ មិនធ្លាប់លះបង់ មិនទំលាក់ចោល មិនដែលទំលាក់ចោល ទាំងមិនបានខាំងឃាត់ឡើយ ។ សភាវៈទាំង ៣ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ រូបណា ដែលកន្លងទៅ រលត់ទៅ ប្រែប្រួលទៅហើយ

អហោសីតិ តស្ស សង្ខា អហោសីតិ តស្ស សមញ្ញា អហោសីតិ តស្ស បញ្ញត្តិ ន តស្ស សង្ខា អត្ថីតិ ន តស្ស សង្ខា ភវិស្សតីតិ ។ យា វេទនា អតីតា និរុទ្ធា វិបរិណតា អហោសីតិ តស្សា សង្ខា អហោសីតិ តស្សា សមញ្ញា អហោសីតិ តស្សា បញ្ញត្តិ ន តស្សា សង្ខា អត្ថីតិ ន តស្សា សង្ខា ភវិស្សតីតិ ។ យា សញ្ញា ។បេ។ យេ សង្ខារា អតីតា និរុទ្ធា វិបរិណតា អហោសុន្តិ តេសំ សង្ខា អហោសុន្តិ តេសំ សមញ្ញា អហោសុន្តិ តេសំ បញ្ញត្តិ ន តេសំ សង្ខា អត្ថីតិ ន តេសំ សង្ខា ភវិស្សន្តីតិ ។ យំ វិញ្ញាណំ

ការពិចារណានូវរូបនោះ ថាកើតមានរួចហើយ ឈ្មោះរបស់រូបនោះ ថាកើតមានរួចហើយ បញ្ញត្តិរបស់រូបនោះ ថាកើតមានរួចហើយ តែការពិចារណានូវរូបនោះ ថាគ្មានក្នុងបច្ចុប្បន្ននេះទេ ការពិចារណានូវរូបនោះ ថាគ្មានទៅក្នុងអនាគតទេ ។ វេទនាណា ដែលកន្លងទៅ រលត់ទៅ ប្រែប្រួលទៅហើយ ការពិចារណានូវវេទនានោះ ថាកើតមានរួចហើយ ឈ្មោះរបស់វេទនានោះ ថាកើតមានរួចហើយ បញ្ញត្តិរបស់វេទនានោះ ថាកើតមានរួចហើយ តែការពិចារណានូវវេទនានោះ ថាគ្មានក្នុងបច្ចុប្បន្ននេះទេ ការពិចារណានូវវេទនានោះ ថាគ្មានទៅក្នុងអនាគតទេ ។ សញ្ញាណា ។ បេ ។ សង្ខារទាំងឡាយណា ដែលកន្លងទៅ រលត់ទៅ ប្រែប្រួលទៅហើយ ការពិចារណានូវសង្ខារទាំងឡាយនោះ ថាកើតមានរួចហើយ ឈ្មោះរបស់សង្ខារទាំងឡាយនោះ ថាកើតមានរួចហើយ បញ្ញត្តិរបស់សង្ខារទាំងឡាយនោះ ថាកើតមានរួចហើយ តែការពិចារណានូវសង្ខារទាំងឡាយនោះ ថាគ្មានក្នុងបច្ចុប្បន្ននេះទេ ការពិចារណានូវសង្ខារទាំងឡាយនោះ ថាគ្មានទៅក្នុងអនាគតទេ ។ វិញ្ញាណណា

អតីតំ និរុទ្ធំ វិបរិណតំ អហោសីតិ តស្ស សង្ខា អហោសីតិ តស្ស សមញ្ញា អហោសីតិ តស្ស បញ្ញត្តិ ន តស្ស សង្ខា អត្ថីតិ ន តស្ស សង្ខា ភវិស្សតីតិ ។

[១៣៥] យំ ភិក្ខវេ រូបំ អជាតំ អបាតុភូតំ ភវិស្សតីតិ តស្ស សង្ខា ភវិស្សតីតិ តស្ស សមញ្ញា ភវិស្សតីតិ តស្ស បញ្ញត្តិ ន តស្ស សង្ខា អត្ថីតិ ន តស្ស សង្ខា អហោសីតិ ។ យា វេទនា អជាតា អបាតុភូតា ភវិស្ស-តីតិ តស្សា សង្ខា ភវិស្សតីតិ តស្សា សមញ្ញា ភវិស្ស-តីតិ តស្សា បញ្ញត្តិ ន តស្សា សង្ខា អត្ថីតិ ន តស្សា សង្ខា អហោសីតិ ។ យា សញ្ញា ។ យេ សង្ខារា អជាតា

ដែលកន្លងទៅ រលត់ទៅ ប្រែប្រួលទៅហើយ ការពិចារណានូវវិញ្ញាណនោះ ថាកើតមានរួចហើយ ឈ្មោះរបស់វិញ្ញាណនោះ ថាកើតមានរួចហើយ បញ្ញត្តិរបស់វិញ្ញាណនោះ ថាកើតមានរួចហើយ តែការពិចារណានូវវិញ្ញាណនោះ ថាគ្មានក្នុងបច្ចុប្បន្នទេ ការពិចារណានូវវិញ្ញាណនោះ ថាគ្មានទៅក្នុងអនាគតទេ ។

[១៣៥] ម្នាលភិក្ខុទាំងឡាយ រូបណា មិនទាន់កើតហើយ មិនទាន់កើតប្រាកដហើយ ការពិចារណានូវរូបនោះ ថានឹងកើតមានទៅក្នុងអនាគត ឈ្មោះរបស់រូបនោះ ថានឹងកើតមានទៅក្នុងអនាគត បញ្ញត្តិរបស់រូបនោះ ថានឹងកើតមានទៅក្នុងអនាគត តែការពិចារណានូវរូបនោះ ថាគ្មានក្នុងបច្ចុប្បន្ននេះទេ ការពិចារណានូវរូបនោះ ថាគ្មានពីអតីតកាលមកទេ ។ វេទនាណា មិនទាន់កើតហើយ មិនទាន់កើតប្រាកដហើយ ការពិចារណានូវវេទនានោះ ថានឹងកើតមានទៅក្នុងអនាគត ឈ្មោះរបស់វេទនានោះ ថានឹងកើតមានទៅក្នុងអនាគត បញ្ញត្តិរបស់វេទនានោះ ថានឹងកើតមានទៅក្នុងអនាគត តែការពិចារណានូវវេទនានោះ ថាគ្មានក្នុងបច្ចុប្បន្ននេះទេ ការពិចារណានូវវេទនានោះ ថាគ្មានពីអតីតកាលមកទេ ។ សញ្ញាណា ។ សង្ខារទាំងឡាយណា មិនទាន់កើតហើយ

អបាតុភូតា ភវិស្សន្តីតិ តេសំ សង្ខា ភវិស្សន្តីតិ តេសំ សមញ្ញា ភវិស្សន្តីតិ តេសំ បញ្ញត្តិ ន តេសំ សង្ខា អត្ថីតិ ន តេសំ សង្ខា អហោសុន្តិ ។ យំ វិញ្ញាណំ អជាតំ អបាតុភូតំ ភវិស្សតីតិ តស្ស សង្ខា ភវិស្សតីតិ តស្ស សមញ្ញា ភវិស្សតីតិ តស្ស បញ្ញត្តិ ន តស្ស សង្ខា អត្ថីតិ ន តស្ស សង្ខា អហោសីតិ ។

មិនទាន់កើតប្រាកដហើយ ការពិចារណានូវសង្ខារទាំងឡាយនោះ ថានឹងកើតមានទៅក្នុងអនាគត បញ្ញត្តិរបស់សង្ខារទាំងឡាយនោះ ថានឹងកើតមានទៅក្នុងអនាគត ឈ្មោះរបស់សង្ខារទាំងឡាយនោះ ថានឹងកើតមានទៅក្នុងអនាគត តែការពិចារណានូវសង្ខារទាំងឡាយនោះ ថាគ្មានក្នុងបច្ចុប្បន្ននេះទេ ការពិចារណានូវសង្ខារទាំងឡាយនោះ ថាគ្មានពីអតីតកាលមកទេ ។ វិញ្ញាណណា មិនទាន់កើតហើយ មិនទាន់កើតប្រាកដហើយ ការពិចារណានូវវិញ្ញាណនោះ ថានឹងកើតមានទៅក្នុងអនាគត ឈ្មោះរបស់វិញ្ញាណនោះ ថានឹងកើតមានទៅ ក្នុងអនាគត បញ្ញត្តិរបស់វិញ្ញាណនោះ ថានឹងកើតមានទៅក្នុងអនាគត តែការពិចារណានូវវិញ្ញាណនោះ ថាគ្មានក្នុងបច្ចុប្បន្ននេះទេ ការពិចារណានូវវិញ្ញាណនោះ ថាគ្មានពីអតីតកាលមកទេ ។

(១៣៦) យំ ភិក្ខវេ រូបំ ជាតំ ភូតំ អត្ថិ តស្ស សង្ខា អត្ថិ តស្ស សមញ្ញា អត្ថិ តស្ស បញ្ញត្តិ ន តស្ស សង្ខា អហោសីតិ ន តស្ស សង្ខា ភវិស្សតីតិ ។ យា វេទនា ជាតា ភូតា ។ បេ ។ អត្ថិ តស្សា បញ្ញត្តិ ន តស្សា សង្ខា អហោសីតិ ន តស្សា សង្ខា ភវិស្សតីតិ ។ យា សញ្ញា ។ យេ សង្ខារា ជាតា ភូតា អត្ថិ តេសំ សង្ខា អត្ថិ តេសំ សមញ្ញា អត្ថិ តេសំ បញ្ញត្តិ ន តេសំ សង្ខា អហេសុន្តិ ន តេសំ សង្ខា ភវិស្សន្តីតិ ។ យំ វិញ្ញាណំ ជាតំ ភូតំ អត្ថិ តស្ស សង្ខា

(១៣៦) ម្នាលភិក្ខុទាំងឡាយ រូបណា ដែលកើតហើយ កើតប្រាកដហើយ ការពិចារណានូវរូបនោះ ថាមានក្នុងបច្ចុប្បន្ន ឈ្មោះរបស់រូបនោះ ថាមានក្នុងបច្ចុប្បន្ន បញ្ញត្តិរបស់រូបនោះ ថាមានក្នុងបច្ចុប្បន្ន តែការពិចារណានូវរូបនោះ ថាគ្មានពីអតីតកាលមកទេ ការពិចារណានូវរូបនោះ ថាឥតមានទៅក្នុងអនាគតទេ ។ វេទនាណា ដែលកើតហើយ កើតប្រាកដហើយ ។ បេ ។ បញ្ញត្តិរបស់វេទនានោះ ថាគ្មានក្នុងបច្ចុប្បន្ន តែការពិចារណានូវវេទនានោះ ថាគ្មានពីអតីតកាលមកទេ ការពិចារណានូវវេទនានោះ ថាឥតមានទៅក្នុងអនាគតទេ ។ សញ្ញាណា ។ សង្ខារទាំងឡាយណា ដែលកើតហើយ កើតប្រាកដហើយ ការពិចារណានូវសង្ខារទាំងឡាយនោះ ថាមានក្នុងបច្ចុប្បន្ន ឈ្មោះរបស់សង្ខារទាំងឡាយនោះ ថាមានក្នុងបច្ចុប្បន្ន បញ្ញត្តិរបស់សង្ខារទាំង-ឡាយនោះ ថាមានក្នុងបច្ចុប្បន្ន តែការពិចារណានូវសង្ខារទាំងឡាយនោះ ថាគ្មានពីអតីតកាលមកទេ ការពិចារណានូវសង្ខារទាំងឡាយនោះ ថាឥតមានទៅក្នុងអនាគតទេ ។ វិញ្ញាណណា ដែលកើតហើយ កើតប្រាកដហើយ ការពិចារណានូវវិញ្ញាណនោះ ថាមានក្នុងបច្ចុប្បន្ន

អត្ថីតិ តស្ស សមញ្ញា អត្ថីតិ តស្ស បញ្ញត្តិ ន តស្ស សង្ខា អហោសីតិ ន តស្ស សង្ខា ភវិស្សតីតិ ។ ឥមេ ខោ ភិក្ខវេ តយោ និរុត្តិបថា អធិវចនបថា បញ្ញត្តិបថា អសង្កិណ្ណា អសង្កិណ្ណបុព្វា ន សង្កិយន្តិ ន សង្កិយិស្សន្តិ អប្បដិកុដ្ឋា សមណេហិ ព្រាហ្មណេហិ វិញ្ញូហិ ។

[១៣៧] យេបិ តេ ភិក្ខវេ អហេសុំ ឧក្កលា វស្សភញ្ញា អហេតុកវាទា អកិរិយវាទា នត្ថិកវាទា តេបិមេ តយោ និរុត្តិបថេ អធិវចនបថេ បញ្ញត្តិបថេ ន គរហិតព្វំ ន បដិក្កោសិតព្វំ អមញ្ញិំសុ ។ តំ កិស្ស ហេតុ ។ និន្ទាព្យារោសឧបារម្ភភយាតិ ។

ឧបាយវគ្គោ បឋមោ ។

ឈ្មោះរបស់វិញ្ញាណនោះ ថាមានក្នុងបច្ចុប្បន្ន បញ្ញត្តិរបស់វិញ្ញាណនោះ ថាមានក្នុងបច្ចុប្បន្ន តែការពិចារណានូវវិញ្ញាណនោះ ថាគ្មានពីអតីតកាលមកទេ ការពិចារណានូវវិញ្ញាណនោះ ថាឥតមានទៅក្នុងអនាគតទេ ។ ម្នាលភិក្ខុទាំងឡាយ សភាវៈ ៣ យ៉ាងនេះឯង គឺ គន្លងពាក្យ ១ គន្លងឈ្មោះ ១ គន្លងបញ្ញត្តិ ១ ពួកសមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញ មិនដែលលះបង់ មិនធ្លាប់លះបង់ មិនទម្លាក់ចោល មិនដែលទម្លាក់ចោល មិនធ្លាប់ខាំងឃាត់ឡើយ ។

[១៣៧] ម្នាលភិក្ខុទាំងឡាយ ពួកជនណា អ្នកនៅក្នុងឧក្កលជនបទ ជាអ្នកពោលនូវក្តៀង ជាអហេតុកវាទ ជាអកិរិយវាទ ជានត្ថិកវាទ ជនទាំងនោះ បានសំគាល់នូវសភាវៈទាំង ៣ នេះគឺ គន្លងពាក្យ ១ គន្លងឈ្មោះ ១ គន្លងបញ្ញត្តិ ១ ថាជារបស់មិនគួរតិះដៀល មិនគួរហាមឃាត់ឡើយ ។ សេចក្តីនោះ ព្រោះហេតុអ្វី ។ ព្រោះខ្លាចសេចក្តីនិន្ទា ការលើកទោស និងសេចក្តីប្រណាំងប្រជែង ។

ចប់ ឧបាយវគ្គ ទី ១ ។

## តស្សុទ្ទានំ

ឧបាយោ(១) ពីជំ ឧបាទានំ

បរិវដ្ដំ សត្តដ្ឋានញ្ច

ពុទ្ធោ បញ្ចវគ្គិ មហាលី

អាទិត្តោ និរុត្តិបថេន ចាតិ ។

---

១ ឱ. ម. ឧបាយោ ពីជំ ឧទានំ ឧបាទានំ បរិវដ្ដំ សត្តដ្ឋានំ ច សម្ពុទ្ធោ បញ្ចមហាលិ អាទិត្តា វគ្គោ និរុត្តិបថេន ចាតិ ។

## ឧទ្ទាននៃឧបាយវគ្គនោះគឺ

និយាយអំពីឧបាយ ១ ពូជ ១ ឧបាទាន ១ បរិវដ្ដៈ ១ ហេតុ ៧ ប្រការ ១ ព្រះអរហន្តសម្មាសម្ពុទ្ធ ១ បញ្ចវគ្គិយ-ភិក្ខុ ១ មហាលិលិច្ឆវិរាជ ១ រូបដែលភ្លើងឆេះរុងរឿងជាដើម ១ សភាវៈ ៣ យ៉ាង មានគន្លងពាក្យជាដើម ១ ។

---

# អរហន្តវគ្គោ

[១៣៨] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ យមហំ ភគវតោ ធម្មំ សុត្វា ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរេយ្យន្តិ ។ ឧបាទិយមានោ ខោ ភិក្ខុ ពទ្ធោ មារស្ស អនុបាទិយមានោ មុត្តោ បាបិមតោតិ ។ អញ្ញាតំ ភគវា អញ្ញាតំ សុគតាតិ ។

# អរហត្តវគ្គ

(១៣៨) ខ្ញុំបានស្ដាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុមួយរូបចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុនោះអង្គុយក្នុងទីសមគួរហើយ ទើបក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់ព្រះមេត្តាប្រោសសំដែងធម៌ ដោយសង្ខេប ដល់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គបានស្ដាប់ធម៌របស់ព្រះមានព្រះភាគ នឹងចៀសចេញទៅតែម្នាក់ឯង មិនប្រមាទ មានតែសេចក្ដីព្យាយាម មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុ បុគ្គលដែលប្រកាន់យក ដោយអំណាចតណ្ហា មានះនិងទិដ្ឋិ ឈ្មោះថាជាប់ (ក្នុងអន្ទាក់) របស់មារ (បើ) មិនបានប្រកាន់យកទេ ឈ្មោះថារួចផុតស្រឡះអំពី (អន្ទាក់) របស់មារមានចិត្តបាប ។ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គយល់ហើយ បពិត្រព្រះសុគត ខ្ញុំព្រះអង្គយល់ហើយ ។

យថាកថំ បន ត្វំ ភិក្ខុ មយា សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ អាជានាសីតិ ។ រូបំ ខោ ភន្តេ ឧបាទិយមានោ ពន្ធោ មារស្ស អនុបាទិយមានោ មុត្តោ បាបិមតោ ។ វេទនំ ឧបាទិយមានោ ពន្ធោ មារស្ស អនុបាទិយមានោ មុត្តោ បាបិមតោ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ ឧបាទិយមានោ ពន្ធោ មារស្ស អនុបាទិយមានោ មុត្តោ បាបិមតោ ។ ឥមស្ស ខ្វាហំ ភន្តេ ភគវតា សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថំ អាជានាមីតិ ។ សាធុ សាធុ ភិក្ខុ សាធុ ខោ ត្វំ ភិក្ខុ មយា សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ អាជានាសិ ។ រូបំ ខោ ភិក្ខុ ឧបាទិយមានោ ពន្ធោ មារស្ស

ម្នាលភិក្ខុ អ្នកយល់នូវអត្ថនៃភាសិត ដែលតថាគតសំដែងសង្ខេបដោយពិស្តារបាន តើយ៉ាងណា ។ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលប្រកាន់យកនូវរូប ឈ្មោះថាជាប់ (អន្ទាក់) របស់មារ (បើ) មិនប្រកាន់យកទេ ឈ្មោះថារួចផុតស្រឡះអំពី (អន្ទាក់) របស់មារ មានបិត្តបាប ។ បុគ្គលប្រកាន់យកនូវវេទនា ឈ្មោះថាជាប់ (អន្ទាក់) របស់មារ (បើ) មិនប្រកាន់យកទេ ឈ្មោះថារួចផុតស្រឡះអំពី (អន្ទាក់) របស់មារមានបិត្តបាប ។ នូវសញ្ញា ។ នូវសង្ខារទាំងឡាយ ។ បុគ្គលប្រកាន់យកនូវវិញ្ញាណ ឈ្មោះថាជាប់ (អន្ទាក់) របស់មារ (បើ) មិនប្រកាន់យកទេ ឈ្មោះថារួចផុតស្រឡះអំពី (អន្ទាក់) របស់មារបិត្តបាប ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គយល់នូវអត្ថ នៃភាសិតសង្ខេប ដែលព្រះមានព្រះភាគសំដែងដោយពិស្តារបាន យ៉ាងនេះឯង ។ ម្នាលភិក្ខុ ប្រពៃហើយ ៗ ម្នាលភិក្ខុ ត្រូវពិតណាស់ហើយ ត្រង់ដែលអ្នកបានយល់ច្បាស់នូវអត្ថ នៃភាសិត ដែលតថាគតសំដែងសង្ខេប ដោយពិស្តារបាន ។ ម្នាលភិក្ខុ បុគ្គលប្រកាន់យកនូវរូប ឈ្មោះថាជាប់ (អន្ទាក់) របស់មារ (បើ)

អនុបាទិយមានោ មុត្តោ បាបិមតោ ។ វេទនំ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ ឧបាទិយមានោ ពទ្ធោ មារស្ស អនុបាទិយមានោ មុត្តោ បាបិមតោ ។ ឥមស្ស ខោ ភិក្ខុ មយា សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថោ ទដ្ឋព្វោតិ ។

[១៣៩] អថខោ សោ ភិក្ខុ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវា-ទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ សោ

មិនប្រកាន់យកទេ ឈ្មោះថារួចផុតស្រឡះអំពី (អន្ទាក់) របស់មារ មានចិត្តបាប ។ នូវវេទនា ។ នូវសញ្ញា ។ នូវសង្ខារទាំងឡាយ ។ បុគ្គល ប្រកាន់យកនូវវិញ្ញាណ ឈ្មោះថាជាប់ (អន្ទាក់) របស់មារ (បើ) មិនប្រកាន់យកទេ ឈ្មោះថារួចផុតស្រឡះអំពី (អន្ទាក់) របស់មារមានចិត្តបាប ។ម្នាលភិក្ខុ អត្ថនៃភាសិតនេះ ដែលតថាគតសំដែងដោយសង្ខេប អ្នកគប្បីយល់ឃើញដោយពិស្តារ យ៉ាងនេះឯង ។

[១៣៩] គ្រានោះឯង ភិក្ខុនោះ ត្រេកអរពេកក្រៃ ចំពោះភាសិត របស់ព្រះមានព្រះភាគហើយ ក្រោកអំពីអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណចៀសចេញទៅ ។ វេលាដែលភិក្ខុនោះ

ភិក្ខុ ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ នចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសិ ។ អញ្ញតរោ ច បន សោ ភិក្ខុ អរហតំ អហោសីតិ ។

(១៤០) សាវត្ថិយំ ។ អារាមេ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ ។ បេ ។ អាតាបី បហិតត្តោ វិហរេយ្យន្តិ ។ មញ្ញមានោ ខោ ភិក្ខុ ពន្ធោ មារស្ស

ចៀសចេញទៅ តែម្នាក់ឯង មិនមានសេចក្ដីប្រមាទ មានតែសេចក្ដីព្យាយាមដុតកំដៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ពួកកុលបុត្តចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា មិនយូរប៉ុន្មាន ក៏បានធ្វើឲ្យជាក់ច្បាស់ បានសម្រេចដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវអនុត្តរធម៌នោះ ដែលជាទីបំផុតនៃព្រហ្មចរិយៈ សម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ភិក្ខុនោះបានដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបាននៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ បណ្ដាព្រះអរហន្តទាំងឡាយ ភិក្ខុនោះ ក៏បានជាព្រះអរហន្តមួយអង្គដែរ ។

[១៤០] ក្នុងក្រុងសាវត្ថី ។ ក្នុងវត្ត ។ លុះភិក្ខុនោះអង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគសំដែងធម៌ដោយសង្ខេប ដល់ខ្ញុំព្រះអង្គ ។ បេ ។ ខ្ញុំព្រះអង្គ នឹងមានសេចក្ដីព្យាយាមដុតកំដៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន សម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ម្នាលភិក្ខុ បុគ្គលកាលសំគាល់ ឈ្មោះថាជាប់ (អន្ទាក់) របស់មារ

អមញ្ញមានោ មុត្តោ បាបិមតោតិ ។ អញ្ញាតំ ភគវា មយា អញ្ញាតំ សុគតាតិ ។ យថា កថំ បន ត្វំ ភិក្ខុ សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ អាជានាសីតិ ។ រូបំ ខោ ភន្តេ មញ្ញមានោ ពទ្ធោ មារស្ស អមញ្ញមានោ មុត្តោ បាបិមតោ ។ វេទនំ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ មញ្ញមានោ ពទ្ធោ មារស្ស អមញ្ញមានោ មុត្តោ បាបិមតោ ។ ឥមស្ស ខ្វាហំ ភន្តេ ភគវតា សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថំ អាជា-នាមីតិ ។ សាធុ សាធុ ភិក្ខុ សាធុ ខោ ត្វំ ភិក្ខុ មយា សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ អាជានាសិ ។ រូបំ ខោ ភិក្ខុ មញ្ញមានោ ពទ្ធោ មារស្ស អមញ្ញមានោ

(បើ) មិនសំគាល់ទេ ឈ្មោះថារូបផុតស្រឡះអំពី (អន្ទាក់) របស់មារមានចិត្តបាប ៗ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គយល់ហើយ បពិត្រព្រះសុគត ខ្ញុំព្រះអង្គយល់ហើយ ៗ ម្នាលភិក្ខុ អ្នកយល់នូវអត្ថនៃភាសិតដែលតថាគតសំដែងសង្ខេបដោយពិស្តារបាន តើយ៉ាងណា ៗ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលកាលសំគាល់នូវរូប ឈ្មោះថាជាប់ (អន្ទាក់) របស់មារ (បើ) មិនសំគាល់ទេ ឈ្មោះថារូបផុតស្រឡះអំពី (អន្ទាក់) របស់មារមានចិត្តបាប ៗ នូវវេទនា ៗ នូវសញ្ញា ៗ នូវសង្ខារទាំងឡាយ ៗ បុគ្គលកាលសំគាល់នូវវិញ្ញាណ ឈ្មោះថាជាប់ (អន្ទាក់) របស់មារ (បើ) មិនសំគាល់ទេ ឈ្មោះថារូបផុតស្រឡះអំពី (អន្ទាក់) របស់មារមានចិត្តបាប ៗ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គយល់នូវអត្ថនៃភាសិតនេះ ដែលព្រះមានព្រះភាគ ទ្រង់សំដែងសង្ខេបដោយពិស្តារបាន យ៉ាងនេះ ៗ ម្នាលភិក្ខុ ពីរោះហើយ ៗ ម្នាលភិក្ខុ ត្រូវមែនហើយ ត្រង់ដែលអ្នកយល់នូវអត្ថនៃភាសិត ដែលតថាគតសំដែងសង្ខេបដោយពិស្តារបាន ៗ ម្នាលភិក្ខុ បុគ្គលកាលសំគាល់នូវរូប ឈ្មោះថាជាប់ (អន្ទាក់) របស់មារ (បើ) មិនសំគាល់

មុត្តោ បាបិមតោ ។ វេទនំ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ មញ្ញមានោ ពទ្ធោ មារស្ស អមញ្ញមានោ មុត្តោ បាបិមតោ ។ ឥមស្ស ខោ ភិក្ខុ មយា សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថោ ទដ្ឋព្វោតិ ។ បេ ។ អញ្ញតរោ ច បន សោ ភិក្ខុ អរហតំ អហោសីតិ ។

[១៤១] សាវត្ថិយំ ។ អថ ខោ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ ។ បេ ។ បហិតត្តោ វិហរេយ្យន្តិ ។ អភិនន្ទមានោ ខោ ភិក្ខុ ពទ្ធោ មារស្ស អនភិនន្ទមានោ មុត្តោ បាបិមតោតិ ។ អញ្ញាតំ ភគវា អញ្ញាតំ សុគតាតិ ។ យថាកថំ បន ត្វំ ភិក្ខុ មយា សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ អាជានាសីតិ ។

ទេ ឈ្មោះថារូបផុតស្រឡះអំពី (អន្ទាក់) របស់មារមានចិត្តបាប ។ នូវវេទនា ។ នូវសញ្ញា ។ នូវសង្ខារទាំងឡាយ ។ បុគ្គល កាលសំគាល់នូវវិញ្ញាណ ឈ្មោះថាជាប់ (អន្ទាក់) របស់មារ (បើ) មិនសំគាល់ទេ ឈ្មោះថារូបផុតស្រឡះអំពី (អន្ទាក់) របស់មារមានចិត្តបាប ។ ម្នាលភិក្ខុ អត្ថនៃភាសិតនេះឯង ដែលតថាគតសំដែងដោយសង្ខេប អ្នកគប្បីយល់ឃើញដោយពិស្តារ យ៉ាងនេះឯង ។ បេ ។ បណ្តាព្រះអរហន្តទាំងឡាយ ភិក្ខុនោះ ក៏បានជាព្រះអរហន្តមួយអង្គដែរ ។

[១៤១] ទៀបក្រុងសាវត្ថី ។ គង់ទីនោះឯង ។ លុះភិក្ខុនោះអង្គុយគង់ទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់សំដែងធម៌ដោយសង្ខេបដល់ខ្ញុំព្រះអង្គ ។ បេ ។ ខ្ញុំព្រះអង្គនឹងមានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន សម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ភិក្ខុកាលត្រេកអរ ឈ្មោះថាជាប់ (អន្ទាក់) មារ កាលភិក្ខុមិនត្រេកអរ ឈ្មោះថារួចចាក (អន្ទាក់) មារមានចិត្តបាប ។ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គយល់ហើយ បពិត្រព្រះសុគត ខ្ញុំព្រះអង្គយល់ហើយ ។ ម្នាលភិក្ខុ ចុះភាសិតដែលតថាគតសំដែងដោយសង្ខេប តើអ្នកយល់សេចក្តីដោយពិស្តារដូចម្តេចទៅ ។

រូបំ ខោ ភន្តេ អភិនន្ទមានោ ពន្ធោ មារស្ស អនភិនន្ទមានោ មុត្តោ បាបិមតោ ។ វេទនំ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ អភិនន្ទមានោ ពន្ធោ មារស្ស អនភិនន្ទមានោ មុត្តោ បាបិមតោ ។ ឥមស្ស ខ្វាហំ ភន្តេ ភគវតា សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថំ អាជានាមីតិ ។ សាធុ សាធុ ភិក្ខុ សាធុ ខោ ត្វំ ភិក្ខុ មយា សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ អាជានាសិ ។ រូបំ ខោ ភិក្ខុ អភិនន្ទមានោ ពន្ធោ មារស្ស អនភិនន្ទមានោ មុត្តោ បាបិមតោ ។ វេទនំ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ អភិនន្ទមានោ ពន្ធោ មារស្ស អនភិនន្ទមានោ មុត្តោ បាបិមតោ ។ ឥមស្ស ខោ ភិក្ខុ មយា សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថោ ទដ្ឋព្វោតិ ។ បេ ។ អញ្ញតរោ ច បន សោ ភិក្ខុ អរហតំ អហោសីតិ ។

បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុកាលត្រេកអរនូវរូប ឈ្មោះថាជាប់ (អន្ទាក់) មារ កាលបើមិនត្រេកអរទេ ឈ្មោះថារួចចាក (អន្ទាក់) មារមានចិត្តបាប ។ នូវវេទនា ។ នូវសញ្ញា ។ នូវសង្ខារទាំងឡាយ ។ កាលបើភិក្ខុត្រេកអរនូវវិញ្ញាណ ឈ្មោះថាជាប់ (អន្ទាក់) មារ កាលបើមិនត្រេកអរទេ ឈ្មោះថារួចចាក (អន្ទាក់) មារមានចិត្តបាប ។ បពិត្រព្រះអង្គដ៏ចម្រើន ភាសិតនេះ ដែលព្រះមានព្រះភាគ ទ្រង់សំដែងហើយដោយសង្ខេប ខ្ញុំព្រះអង្គយល់សេចក្តីដោយពិស្តារ យ៉ាងនេះឯង ។ ម្នាលភិក្ខុ ប្រពៃហើយ ៗ ម្នាលភិក្ខុ ត្រូវណាស់ហើយ ត្រង់ភាសិតដែលតថាគតសំដែងដោយសង្ខេប អ្នកយល់សេចក្តីដោយពិស្តារបាន ។ ម្នាលភិក្ខុ កាលបើភិក្ខុត្រេកអរនូវរូប ឈ្មោះថាជាប់ (អន្ទាក់) មារ កាលបើមិនត្រេកអរទេ ឈ្មោះថារួចចាក (អន្ទាក់) មារមានចិត្តបាប ។ នូវវេទនា ។ នូវសញ្ញា ។ នូវសង្ខារទាំងឡាយ ។ កាលបើភិក្ខុត្រេកអរ នូវវិញ្ញាណ ឈ្មោះថាជាប់ (អន្ទាក់) មារ កាលបើមិនត្រេកអរទេ ឈ្មោះថារួចចាក (អន្ទាក់) មារមានចិត្តបាប ។ ម្នាលភិក្ខុ ភាសិតនេះ ដែលតថាគតសំដែងហើយដោយសង្ខេប អ្នកត្រូវយល់ឃើញសេចក្តីដោយពិស្តារយ៉ាងនេះឯង ។បេ។ បណ្តាព្រះអរហន្តទាំងឡាយ ភិក្ខុនោះជាព្រះអរហន្តមួយអង្គដែរ ។

[១៤២] សាវត្ថិយំ ។ អារាមេ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ ។ បេ ។ វិហរេយ្យន្តិ ។ យំ ខោ ភិក្ខុ អនិច្ចំ តត្រ តេ ឆន្ទោ បហាតព្វោតិ ។ អញ្ញាតំ ភគវា អញ្ញាតំ សុគតាតិ ។ យថាកថំ បន ត្វំ ភិក្ខុ មយា សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ អាជានាសីតិ ។ រូបំ ខោ ភន្តេ អនិច្ចំ តត្រ មេ ឆន្ទោ បហាតព្វោ ។ វេទនា ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ អនិច្ចំ តត្រ មេ ឆន្ទោ បហាតព្វោ ។ ឥមស្ស ខ្វាហំ ភន្តេ ភគវតា សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថំ អាជានាមីតិ ។ សាធុ សាធុ ភិក្ខុ សាធុ ខោ ត្វំ ភិក្ខុ មយា សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ អាជានាសិ ។

១៨២ ទៀបក្រុងសាវត្ថី ។ គង់ក្នុង ។ ព្រះភិក្ខុនោះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះមានព្រះភាគត្រាស់សំដែងធម៌ដោយសេចក្តីសង្ខេបដល់ខ្ញុំព្រះអង្គ ។ បេ ។ គប្បីសម្រាន្តទៅ ។ ម្នាលភិក្ខុ របស់ណាមិនទៀង អ្នកត្រូវលះបង់សេចក្តីប៉ុនប៉ងក្នុងរបស់នោះចេញ ។ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គយល់ហើយ បពិត្រព្រះសុគត ខ្ញុំព្រះអង្គយល់ហើយ ។ ម្នាលភិក្ខុ ចុះធម៌ដែលតថាគតសំដែងហើយដោយសេចក្តីសង្ខេប តើអ្នកយល់សេចក្តីដោយពិស្តារ ដូចម្តេចទៅ ។ បពិត្រព្រះអង្គដ៏ចំរើន រូបមិនទៀង ខ្ញុំព្រះអង្គត្រូវលះបង់សេចក្តីប៉ុនប៉ងក្នុងរូបនោះចេញ ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណមិនទៀង ខ្ញុំព្រះអង្គត្រូវលះបង់សេចក្តីប៉ុនប៉ង ក្នុងវិញ្ញាណនោះចេញ ។ បពិត្រព្រះអង្គដ៏ចំរើន ភាសិតដែលព្រះមានព្រះភាគត្រាស់ហើយ ដោយសង្ខេបនេះ ខ្ញុំព្រះអង្គយល់សេចក្តីដោយពិស្តារយ៉ាងនេះឯង ។ ម្នាលភិក្ខុ ប្រពៃហើយ ៗ ម្នាលភិក្ខុ ប្រពៃណាស់ហើយ ត្រង់ភាសិតដែលតថាគតសំដែងហើយដោយសង្ខេប អ្នកយល់សេចក្តីដោយពិស្តារបាន ។

រូបំ ខោ ភិក្ខុ អនិច្ចំ តត្រ តេ ឆន្ទោ បហាតព្វោ ។ វេទនា ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ អនិច្ចំ តត្រ តេ ឆន្ទោ បហាតព្វោ ។ ឥមស្ស ខោ ភិក្ខុ មយា សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថោ ទដ្ឋព្វោតិ ។ បេ ។ អញ្ញតរោ ច បន សោ ភិក្ខុ អរហតំ អហោសីតិ ។

(១៦៣) សាវត្ថិយំ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ ។ បេ ។ វិហរេយ្យន្តិ ។ យំ ខោ ភិក្ខុ ទុក្ខំ តត្រ តេ ឆន្ទោ បហាតព្វោតិ ។ អញ្ញាតំ ភគវា អញ្ញាតំ សុគតាតិ ។ យថាកថំ បន ត្វំ ភិក្ខុ មយា សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ អាជានាសីតិ ។ រូបំ ខោ ភន្តេ ទុក្ខំ តត្រ មេ ឆន្ទោ បហាតព្វោ ។

ម្នាលភិក្ខុ រូបមិនទៀង អ្នកត្រូវលះបង់សេចក្តីប៉ុនប៉ង ក្នុងរូបនោះចេញ ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណមិនទៀង អ្នកត្រូវលះបង់សេចក្តីប៉ុនប៉ង ក្នុងវិញ្ញាណនោះចេញ ។ ម្នាលភិក្ខុ ភាសិតនេះ ដែលតថាគត សំដែងហើយ ដោយសង្ខេប អ្នកត្រូវយល់ឃើញសេចក្តីដោយពិស្តារ យ៉ាងនេះឯង ។បេ។ បណ្តាព្រះអរហន្តទាំងឡាយ ភិក្ខុនោះ ក៏ជាព្រះអរហន្តមួយអង្គដែរ ។

[១៤៣] ទៀបក្រុងសាវត្ថី ។ លុះភិក្ខុនោះ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះមានព្រះភាគទ្រង់សំដែងធម៌ដោយសង្ខេប ដល់ខ្ញុំព្រះអង្គ ។បេ។ គប្បីសម្រាន្តនៅ ។ ម្នាលភិក្ខុ របស់ណាជាទុក្ខ អ្នកត្រូវលះបង់នូវសេចក្តីប៉ុនប៉ងក្នុងរបស់នោះចេញ ។ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គយល់ហើយ បពិត្រព្រះសុគត ខ្ញុំព្រះអង្គយល់ហើយ ។ ម្នាលភិក្ខុ ចុះភាសិតដែលតថាគតសំដែងដោយសង្ខេប តើអ្នកយល់សេចក្តីដោយពិស្តារដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន រូបហ្នឹងឯងជាទុក្ខ ខ្ញុំព្រះអង្គត្រូវលះបង់សេចក្តីប៉ុនប៉ង ក្នុងរូបនោះចេញ ។

វេទនា ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ ទុក្ខំ តត្រ មេ ឆន្ទោ បហាតព្វោ ។ ឥមស្ស ខ្វាហំ ភន្តេ ភគវតា សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថំ អាជានាមីតិ ។ សាធុ សាធុ ភិក្ខុ សាធុ ខោ ត្វំ ភិក្ខុ មយា សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ អាជានាសិ ។ រូបំ ខោ ភិក្ខុ ទុក្ខំ តត្រ តេ ឆន្ទោ បហាតព្វោ ។ វេទនា ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ ទុក្ខំ តត្រ តេ ឆន្ទោ បហាតព្វោ ។ ឥមស្ស ខោ ភិក្ខុ មយា សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថោ ទដ្ឋព្វោតិ ។ បេ ។ អញ្ញតរោ ច បន សោ ភិក្ខុ អរហតំ អហោសីតិ ។

[១៦៦] សាវត្ថិយំ ។ អារាមេ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ ។ បេ ។ វិហរេយ្យន្តិ ។

វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណជាទុក្ខ ខ្ញុំព្រះអង្គត្រូវលះបង់សេចក្តីប៉ុនប៉ង ក្នុងវិញ្ញាណនោះចេញ ។ បពិត្រព្រះអង្គដ៏ចំរើន ភាសិតនេះ ដែលព្រះមានព្រះភាគសំដែងហើយដោយសង្ខេប ខ្ញុំព្រះអង្គយល់សេចក្តីដោយពិស្តារ យ៉ាងនេះឯង ។ ម្នាលភិក្ខុ ប្រពៃហើយ ៗ ម្នាលភិក្ខុ ប្រពៃណាស់ហើយ ត្រង់ភាសិតដែលតថាគតសំដែងហើយដោយសង្ខេប អ្នកយល់សេចក្តីដោយពិស្តារបាន ។ ម្នាលភិក្ខុ រូបហ្នឹងឯងជាទុក្ខ អ្នកត្រូវលះបង់សេចក្តីប៉ុនប៉ង ក្នុងរូបនោះចេញ ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណជាទុក្ខ អ្នកត្រូវលះបង់សេចក្តីប៉ុនប៉ង ក្នុងវិញ្ញាណនោះចេញ ។ ម្នាលភិក្ខុ ភាសិតនេះ តថាគតសំដែងហើយដោយសង្ខេប អ្នកត្រូវយល់ឃើញសេចក្តីដោយពិស្តារយ៉ាងនេះឯង ។ បេ ។ បណ្តាព្រះអរហន្តទាំងឡាយ ភិក្ខុនោះ ក៏ជាព្រះអរហន្តមួយអង្គដែរ ។

(១៤៤) ទៀបក្រុងសាវត្ថី ។ ក្នុងវត្ត ។ លុះភិក្ខុនោះអង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះមានព្រះភាគទ្រង់សំដែងធម៌ដោយសង្ខេប ដល់ខ្ញុំព្រះអង្គ ។ បេ ។ គប្បីសម្រាន្តនៅ ។

យោ ខោ ភិក្ខុ អនត្តា តត្រ តេ ឆន្ទោ បហាតព្វោតិ ។
អញ្ញាតំ ភគវា អញ្ញាតំ សុគតាតិ ។ យថា កថំ បន
ត្វំ ភិក្ខុ មយា សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ
អាជានាសីតិ ។ រូបំ ខោ ភន្តេ អនត្តា តត្រ មេ
ឆន្ទោ បហាតព្វោ ។ វេទនា ។ សញ្ញា ។ សង្ខារា ។
វិញ្ញាណំ អនត្តា តត្រ មេ ឆន្ទោ បហាតព្វោ ។
ឥមស្ស ខ្វាហំ ភន្តេ ភគវតា សង្ខិត្តេន ភាសិ-
តស្ស ឯវំ វិត្ថារេន អត្ថំ អាជានាមីតិ ។ សាធុ សាធុ
ភិក្ខុ សាធុ ខោ ត្វំ ភិក្ខុ មយា សង្ខិត្តេន ភា-
សិតស្ស វិត្ថារេន អត្ថំ អាជានាសិ ។ រូបំ ខោ ភិក្ខុ

ម្នាលភិក្ខុ សភាវៈណា ជាអនត្តា អ្នកត្រូវលះបង់សេចក្តីប៉ុនប៉ងក្នុងសភាវៈនោះចេញ ។ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គយល់ហើយ បពិត្រព្រះសុគត ខ្ញុំព្រះអង្គយល់ហើយ ។ ម្នាលភិក្ខុ ចុះភាសិត ដែលតថាគត សំដែងហើយដោយសង្ខេប អ្នកយល់សេចក្តីដោយពិស្តារ ដូចម្តេចទៅ ។ បពិត្រព្រះអង្គដ៏ចម្រើន រូបហ្នឹងឯងជាអនត្តា ខ្ញុំព្រះអង្គត្រូវលះបង់សេចក្តីប៉ុនប៉ង ក្នុងរូបនោះចេញ ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណជាអនត្តា ខ្ញុំព្រះអង្គត្រូវលះបង់សេចក្តីប៉ុនប៉ងក្នុងវិញ្ញាណនោះចេញ ។ បពិត្រព្រះអង្គដ៏ចម្រើន ភាសិតនេះដែលព្រះមានព្រះភាគ សំដែងហើយ ដោយសង្ខេប ខ្ញុំព្រះអង្គយល់សេចក្តីដោយពិស្តារយ៉ាងនេះឯង ។ ម្នាលភិក្ខុ ប្រពៃមែនហើយ ៗ ម្នាលភិក្ខុ ប្រពៃណាស់ហើយ ត្រង់ភាសិតដែលតថាគត សំដែងហើយដោយសង្ខេប អ្នកយល់សេចក្តីដោយពិស្តារបាន ។ ម្នាលភិក្ខុ រូបហ្នឹងឯង

អនត្តា តត្រ តេ ឆន្ទោ បហាតព្វោ ។ វេទនា ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ អនត្តា តត្រ តេ ឆន្ទោ បហាតព្វោ ។ ឥមស្ស ខោ ភិក្ខុ មយា សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថោ ទដ្ឋព្វោតិ ។ បេ ។ អញ្ញតរោ ច បន សោ ភិក្ខុ អរហតំ អហោសីតិ ។

(១៤៨) សាវត្ថិយំ ។ តត្រ ខោ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ ។ បេ ។ វិហរេយ្យន្តិ ។ យំ ខោ ភិក្ខុ អនត្តនិយំ តត្រ តេ ឆន្ទោ បហាតព្វោតិ ។ អញ្ញាតំ ភគវា អញ្ញាតំ សុគតាតិ ។ យថាកថំ បន ត្វំ ភិក្ខុ មយា សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ អាជានាសីតិ ។ រូបំ ខោ ភន្តេ

ជាអនត្តា អ្នកត្រូវលះបង់សេចក្តីប៉ុនប៉ង ក្នុងរូបនោះចេញ ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណជាអនត្តា អ្នកត្រូវលះបង់សេចក្តីប៉ុនប៉ងក្នុងវិញ្ញាណនោះចេញ ។ ម្នាលភិក្ខុ ភាសិតនេះ ដែលតថាគតសំដែងហើយ ដោយសង្ខេប អ្នកត្រូវយល់ឃើញសេចក្តីដោយពិស្តារ យ៉ាងនេះឯង ។ បេ ។ បណ្តាព្រះអរហន្តទាំងឡាយ ភិក្ខុនោះជាព្រះអរហន្តមួយអង្គដែរ ។

(១៨៥) ទៀបក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ លុះភិក្ខុនោះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះមានព្រះភាគ ទ្រង់សំដែងធម៌ដោយសង្ខេបដល់ខ្ញុំព្រះអង្គ ។ បេ ។ គប្បីសម្រាន្តទៅ ។ ម្នាលភិក្ខុ របស់ណា មិនគួរជារបស់ខ្លួន អ្នកត្រូវលះបង់សេចក្តីប៉ុនប៉ងក្នុងរបស់នោះចេញ ។ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គយល់ហើយ បពិត្រព្រះសុគត ខ្ញុំព្រះអង្គយល់ហើយ ។ ម្នាលភិក្ខុ ចុះភាសិតដែលតថាគតសំដែងហើយ ដោយសង្ខេប អ្នកយល់សេចក្តីដោយពិស្តារដូចម្តេចទៅ ។ បពិត្រព្រះអង្គដ៏ចម្រើន រូបហ្នឹងឯង

អនត្តនីយំ តត្រ មេ ឆន្ទោ បហាតព្វោ ។ វេទនា ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ អនត្តនីយំ តត្រ មេ ឆន្ទោ បហាតព្វោ ។ ឥមស្ស ខ្វាហំ ភន្តេ ភគវតា សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថំ អាជានាមីតិ ។ សាធុ សាធុ ភិក្ខុ សាធុ ខោ ត្វំ ភិក្ខុ មយា សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ អាជានាសិ ។ រូបំ ខោ ភិក្ខុ អនត្តនីយំ តត្រ តេ ឆន្ទោ បហាតព្វោ ។ វេទនា ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ អនត្តនីយំ តត្រ តេ ឆន្ទោ បហាតព្វោ ។ ឥមស្ស ខោ ភិក្ខុ មយា សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថោ ទដ្ឋព្វោតិ ។ បេ ។ អញ្ញតរោ ច បន សោ ភិក្ខុ អរហតំ អហោសីតិ ។

មិនគួរជារបស់ខ្ញុំទេ ខ្ញុំព្រះអង្គត្រូវលះបង់សេចក្តីប៉ុនប៉ង ក្នុងរូបនោះចេញ ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណមិនគួរជារបស់ខ្ញុំទេ ខ្ញុំព្រះអង្គត្រូវលះបង់សេចក្តីប៉ុនប៉ង ក្នុងវិញ្ញាណនោះចេញ ។ បពិត្រព្រះអង្គដ៏ចម្រើន ភាសិតនេះ ដែលព្រះមានព្រះភាគសំដែងហើយដោយសង្ខេប ខ្ញុំព្រះអង្គយល់សេចក្តីដោយពិស្តារ យ៉ាងនេះឯង ។ ម្នាលភិក្ខុ ប្រពៃមែនហើយ ៗ ម្នាលភិក្ខុ ប្រពៃណាស់ហើយ ត្រង់ភាសិតដែលតថាគតសំដែងហើយ ដោយសង្ខេប អ្នកយល់សេចក្តីដោយពិស្តារបាន ។ ម្នាលភិក្ខុ រូបហ្នឹងឯង មិនគួរជារបស់ខ្ញុំទេ អ្នកត្រូវលះបង់សេចក្តីប៉ុនប៉ង ក្នុងរូបនោះចេញ ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណមិនគួរជារបស់ខ្ញុំទេ អ្នកត្រូវលះបង់សេចក្តីប៉ុនប៉ង ក្នុងវិញ្ញាណនោះចេញ ។ ម្នាលភិក្ខុ ភាសិតនេះ ដែលតថាគត សំដែងហើយដោយសង្ខេប អ្នកត្រូវយល់ឃើញសេចក្តីដោយពិស្តារ យ៉ាងនេះឯង ។បេ។ បណ្តាព្រះអរហន្តទាំងឡាយ ភិក្ខុនោះជាព្រះអរហន្តមួយអង្គដែរ ។

[១៤៦] សាវត្ថិយំ ។ តត្រ ខោ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ យមហំ ភគវតោ ធម្មំ សុត្វា ។ បេ ។ វិហរេយ្យន្តិ ។ យំ ខោ ភិក្ខុ រជនីយសណ្ឋិតំ តត្រ តេ ឆន្ទោ បហាតព្វោតិ ។ អញ្ញាតំ ភគវា អញ្ញាតំ សុគតាតិ ។ យថាកថំ បន ត្វំ ភិក្ខុ មយា សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ អាជានាសីតិ ។ រូបំ ខោ ភន្តេ រជនីយសណ្ឋិតំ តត្រ មេ ឆន្ទោ បហាតព្វោ ។ វេទនា ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ រជនីយសណ្ឋិតំ តត្រ មេ ឆន្ទោ បហាតព្វោ ។ ឥមស្ស ខ្វាហំ ភន្តេ ភគវតា សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថំ អាជានាមីតិ ។

[១៤៩] ទៀបក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ លុះភិក្ខុនោះ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះមានព្រះភាគទ្រង់សំដែងធម៌ ដោយសង្ខេប ដល់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គស្តាប់ធម៌របស់ព្រះមានព្រះភាគហើយ ។បេ។ គប្បីសម្រាន្តនៅ ។ ម្នាលភិក្ខុ របស់ណា តាំងនៅដោយអាការដែលបុគ្គលគប្បីត្រេកអរ អ្នកត្រូវលះបង់សេចក្តីប៉ុនប៉ង ក្នុងរបស់នោះចេញ ។ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គយល់ហើយ បពិត្រព្រះសុគត ខ្ញុំព្រះអង្គយល់ហើយ ។ ម្នាលភិក្ខុ ចុះភាសិតដែលតថាគតសំដែងហើយ ដោយសង្ខេប តើអ្នកយល់សេចក្តីដោយពិស្តារ ដូចម្តេចទៅ ។ បពិត្រព្រះអង្គដ៏ចំរើន រូបហ្នឹងឯង តាំងនៅដោយអាការដែលបុគ្គលគប្បីត្រេកអរ ខ្ញុំព្រះអង្គត្រូវលះបង់សេចក្តីប៉ុនប៉ងក្នុងរូបនោះចេញ ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណ តាំងនៅដោយអាការដែលបុគ្គលគប្បីត្រេកអរ ខ្ញុំព្រះអង្គត្រូវលះបង់សេចក្តីប៉ុនប៉ង ក្នុងវិញ្ញាណនោះចេញ ។ បពិត្រព្រះអង្គដ៏ចំរើន ភាសិតនេះ ដែលព្រះមានព្រះភាគសំដែងហើយ ដោយសង្ខេប ខ្ញុំព្រះអង្គយល់សេចក្តី ដោយពិស្តារ យ៉ាងនេះឯង ។

សាធុ សាធុ ភិក្ខុ សាធុ ខោ ត្វំ ភិក្ខុ មយា សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ អាជានាសិ ។ រូបំ ខោ ភិក្ខុ រជនីយសណ្ឋិតំ តត្រ តេ ឆន្ទោ បហាតព្វោ ។ វេទនា ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ រជនីយ-សណ្ឋិតំ តត្រ តេ ឆន្ទោ បហាតព្វោ ។ ឥមស្ស ខោ ភិក្ខុ មយា សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថោ ទដ្ឋព្វោតិ ។ បេ ។ អញ្ញតរោ ច បន សោ ភិក្ខុ អរហតំ អហោសីតិ ។

[១៨៧] សាវត្ថិយំ ។ តត្រ ខោ ។ អាយស្មា រាធោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ[១] ឯតទវោច កថំ នុ ខោ ភន្តេ ជានតោ កថំ បស្សតោ ឥមស្មិញ្ច សវិញ្ញាណកេ កាយេ ពហិទ្ធា ច សព្វនិមិត្តេសុ អហង្ការមមង្ការមានានុសយា ន ហោន្តីតិ ។ យំ កិញ្ចិ រាធ រូបំ អតីតានាគត-បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា

១ ឱ. ឯត្ថន្តរេ អភិវាទេត្វា ឯកមន្តំ និសីទិ ឯកមន្តំ និសិន្នោ ខោ អាយស្មា រាធោ ភគវន្តំ ឯតទវោចាតិ ទិស្សន្តិ ។

ម្នាលភិក្ខុ ប្រពៃមែនហើយ ៗ ម្នាលភិក្ខុ ប្រពៃណាស់ហើយ ត្រង់ភាសិតដែលតថាគតសំដែងហើយ ដោយសង្ខេប អ្នកយល់សេចក្ដីដោយពិស្ដារបាន ៗ ម្នាលភិក្ខុ រូបហ្នឹងឯង តាំងនៅដោយអាការ ដែលបុគ្គលគប្បីត្រេកអរ អ្នកត្រូវលះបង់សេចក្ដីប៉ុនប៉ង ក្នុងរូបនោះចេញ ៗ វេទនា ៗ សញ្ញា ៗ សង្ខារទាំងឡាយ ៗ វិញ្ញាណ តាំងនៅដោយអាការដែលបុគ្គលគប្បីត្រេកអរ អ្នកត្រូវលះបង់សេចក្ដីប៉ុនប៉ងក្នុងវិញ្ញាណនោះចេញ ៗ ម្នាលភិក្ខុ ភាសិតនេះ ដែលតថាគតសំដែងហើយ ដោយសង្ខេប អ្នកត្រូវយល់ឃើញសេចក្ដីដោយពិស្ដារ យ៉ាងនេះឯង ។បេ។ បណ្ដាព្រះអរហន្តទាំងឡាយ ភិក្ខុនោះ ជាព្រះអរហន្តមួយអង្គដែរ ។

[១៦៧] ទៀបក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ព្រះរាធៈមានអាយុ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ទើបក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន កាលបុគ្គលដឹងដូចម្ដេច ឃើញដូចម្ដេច អហង្ការមានានុស័យ និងមមង្ការមានានុស័យ ចំពោះកាយ ដែលប្រកបដោយវិញ្ញាណនេះផង ចំពោះនិមិត្តទាំងពួងជាខាងក្រៅផងមិនមាន ៗ ម្នាលរាធៈ រូបណានីមួយជាអតីត អនាគត បច្ចុប្បន្ន ជាខាងក្នុងក្ដី ខាងក្រៅក្ដី គ្រោតគ្រាតក្ដី ល្អិតក្ដី ថោកទាបក្ដី ឧត្ដមក្ដី រូបណា ឋិតនៅក្នុងទីឆ្ងាយក្ដី ទីជិតក្ដី

សព្វំ រូបំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ បស្សតិ ។ យា កាចិ វេទនា ។ យា កាចិ សញ្ញា ។ យេ កេចិ សង្ខារា ។ យំ កិញ្ចិ វិញ្ញាណំ អតីតានាគតប្បច្ចុប្បន្នំ ។ បេ ។ យំ ទូរេ សន្តិកេ វា សព្វំ វិញ្ញាណំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ បស្សតិ ។ ឯវំ ខោ រាធ ជានតោ ឯវំ បស្សតោ ឥមស្មិញ្ច សវិញ្ញាណកេ កាយេ ពហិទ្ធា ច សព្វនិមិត្តេសុ អហង្ការមមង្ការមានានុសយា ន ហោន្តីតិ ។ បេ ។ អញ្ញតរោ ច បនាយស្មា រាធោ អរហតំ អហោសីតិ ។

បុគ្គលតែងពិចារណាឃើញនូវរូបទាំងអស់នុ៎ះ តាមពិត ដោយប្រាជ្ញាដ៏ប្រពៃ យ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនអញ នុ៎ះមិនមែនជាខ្លួនរបស់អញទេ ។ វេទនាណានីមួយ ។ សញ្ញាណានីមួយ ។ សង្ខារទាំងឡាយណានីមួយ ។ វិញ្ញាណណានីមួយ ជាអតីត អនាគត បច្ចុប្បន្ន ។បេ។ វិញ្ញាណណា ឋិតនៅក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី បុគ្គលតែងពិចារណាឃើញវិញ្ញាណទាំងអស់នុ៎ះ តាមពិត ដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនអញ នុ៎ះមិនមែនជាខ្លួនរបស់អញទេ ។ ម្នាលរាធៈ កាលបុគ្គលដឹងយ៉ាងនេះ ឃើញយ៉ាងនេះ អហង្ការមានានុស័យ និងមមង្ការមានានុស័យ ចំពោះកាយដែលប្រកបដោយវិញ្ញាណនេះផង ចំពោះនិមិត្តទាំងពួងជាខាងក្រៅផង មិនមាន ។បេ។ បណ្តាព្រះអរហន្តទាំងឡាយ ព្រះរាធៈមានអាយុជាព្រះអរហន្តមួយអង្គដែរ ។

(១៦៨) សាវត្ថិយំ ។ តត្រ ខោ ។ អាយស្មា សុរាធោ ភគវន្តំ ឯតទវោច កថំ នុ ខោ ភន្តេ ជានតោ កថំ បស្សតោ ឥមស្មិញ្ច សវិញ្ញាណកេ កាយេ ពហិទ្ធា ច សព្វនិមិត្តេសុ អហង្ការមមង្ការមានាបគតំ មានសំ ហោតិ វិធា សមតិក្កន្តំ សន្តំ សុវិមុត្តន្តិ ។ យំ កិញ្ចិ សុរាធ រូបំ អតីតានាគតបច្ចុប្បន្នំ ។ បេ ។ យំ ទូរេ សន្តិកេ វា សព្វំ រូបំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទិស្វា អនុបាទា វិមុត្តោ ហោតិ ។ យា កាចិ វេទនា ។ យា កាចិ សញ្ញា ។ យេ កេចិ សង្ខារា ។ យំ កិញ្ចិ វិញ្ញាណំ អតីតានាគតបច្ចុប្បន្នំ ។ បេ ។ យំ ទូរេ សន្តិកេ វា សព្វំ វិញ្ញាណំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទិស្វា អនុបាទា វិមុត្តោ ហោតិ ។

(១៤៨) ទៀបក្រុងសាវត្ថី ។ គង់ទីនោះឯង ។ ព្រះសុរាធៈ មានអាយុ បានក្រាបទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ចុះកាលបុគ្គលដឹងដូចម្តេច ឃើញដូចម្តេច ចិត្ត ដែលប្រាសចាកសេចក្តីប្រកាន់អហង្ការ មមង្ការ ចំពោះកាយ ប្រកបដោយវិញ្ញាណនេះផង ចំពោះនិមិត្តទាំងពួង ជាខាងក្រៅផង ទើបជាចិត្តកន្លងបង់ ស្ងប់រម្ងាប់ រួចស្រឡះចាកវិធី (នេះបាន) ។ ម្នាលសុរាធៈ រូបណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ។បេ។ រូបណា ឋិតនៅក្នុងទីឆ្ងាយក្តី ទីជិតក្តី បុគ្គលឃើញរូបទាំងអស់នុ៎ះ តាមពិតដោយប្រាជ្ញាដ៏ប្រពៃ យ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនអញ នុ៎ះមិនមែនជាខ្លួនរបស់អញទេ ដូច្នេះហើយ រមែងរួចស្រឡះ ព្រោះការមិនប្រកាន់ ។ វេទនាណាមួយ ។ សញ្ញាណាមួយ ។ សង្ខារទាំងឡាយណាមួយ ។ វិញ្ញាណណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ។បេ។ វិញ្ញាណណា ឋិតនៅក្នុងទីឆ្ងាយក្តី ទីជិតក្តី បុគ្គលឃើញវិញ្ញាណទាំងអស់នុ៎ះ តាមពិត ដោយប្រាជ្ញា ដ៏ប្រពៃ យ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនអញ នុ៎ះមិនមែនជាខ្លួនរបស់អញទេ ដូច្នេះហើយ រមែងរួចស្រឡះ ព្រោះការមិនប្រកាន់ ។

ឯវំ ខោ សុរាធ ជានតោ ឯវំ បស្សតោ ឥមស្មិញ្ច សវិញ្ញាណកេ កាយេ ពហិទ្ធា ច សព្ពនិមិត្តេសុ អហង្ការមមង្ការមានាបគតំ មានសំ ហោតិ វិធា សមតិក្កន្តំ សន្តំ សុវិមុត្តន្តិ ។ បេ ។ អញ្ញតរោ ច បនាយស្មា សុរាធោ អរហតំ អហោសីតិ ។

អរហន្តវគ្គោ ទុតិយោ ។

តស្សុទ្ទានំ

ឧបាទិយមញ្ញមានា
អថាភិនន្ទមានោ ច
អនិច្ចំ ទុក្ខំ អនត្តា ច
អនត្តនិយំ រជនីយសណ្ឋិតំ
រាធសុរាធេន តេ ទសាតិ ។

ម្នាលសុរាធៈ កាលបុគ្គលដឹងយ៉ាងនេះ ឃើញយ៉ាងនេះឯង ក្នុងចិត្ត ដែលប្រាសចាកសេចក្ដីប្រកាន់អហង្ការ មមង្ការ ចំពោះកាយ ប្រកបដោយវិញ្ញាណនេះផង ចំពោះនិមិត្តទាំងពួងជាខាងក្រៅផង ទើបជាចិត្តកន្លងបង់ ស្ងប់រម្ងាប់ រួចស្រឡះចាកវិធី (នេះបាន) ។ បេ ។ បណ្ដាព្រះអរហន្តទាំងឡាយ ព្រះសុរាធៈមានអាយុ ជាព្រះអរហន្តមួយអង្គដែរ ។

ចប់ អរហន្តវគ្គ ទី ២ ។

## ឧទ្ទានក្នុងអរហន្តវគ្គនោះ គឺ

និយាយអំពីភិក្ខុប្រកាន់ ១ ភិក្ខុសំគាល់ ១ ភិក្ខុត្រេកអរ ១
ខន្ធមិនទៀង ១ ជាទុក្ខ ១ ជាអនត្តា ១ មិនគួរជារបស់ខ្លួន ១
តាំងនៅដោយអាការ ដែលបុគ្គលត្រេកអរ ១ ព្រះរាធៈ ១
ព្រះសុរាធៈ ១ (ទាំងអស់) នោះ ត្រូវជា ១០ ។

# ខជ្ជនីយវគ្គោ

[១៤៩] សាវត្ថិយំ ។ តត្រ ខោ ។ អស្សុតវា ភិក្ខវេ បុថុជ្ជនោ រូបស្ស អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ នប្បជានាតិ ។ វេទនាយ ។ សញ្ញាយ ។ សង្ខារានំ ។ វិញ្ញាណស្ស អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ នប្បជានាតិ ។ សុតវា ច ខោ ភិក្ខវេ អរិយសាវកោ រូបស្ស អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានាតិ ។ វេទនាយ ។ សញ្ញាយ ។ សង្ខារានំ ។ វិញ្ញាណស្ស អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានាតីតិ ។

[១៥០] សាវត្ថិយំ ។ តត្រ ខោ ។ អស្សុតវា ភិក្ខវេ បុថុជ្ជនោ រូបស្ស សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ នប្បជានាតិ ។ វេទនាយ ។ សញ្ញាយ ។ សង្ខារានំ ។

## ឆដ្ឋនិយវគ្គ

[១៨៩] ទៀបក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំង-ឡាយ បុថុជ្ជនអ្នកមិនចេះដឹង រមែងមិនដឹងច្បាស់តាមសេចក្ដីពិត នូវអានិសង្ស នូវទោស និងការរលាស់ចោល នៃរូប ។ នៃវេទនា ។ នៃសញ្ញា ។ នៃសង្ខារទាំងឡាយ ។ រមែងមិនដឹងច្បាស់តាមសេចក្ដីពិត នូវអានិសង្ស នូវទោស និងការរលាស់ចោល នៃវិញ្ញាណ ។ ម្នាលភិក្ខុទាំងឡាយ ឯអរិយសាវ័កអ្នកចេះដឹង រមែងដឹងច្បាស់តាមសេចក្ដីពិត នូវអានិសង្ស នូវទោស និងការរលាស់ចោល នៃរូប ។ នៃវេទនា ។ នៃសញ្ញា ។ នៃសង្ខារទាំងឡាយ ។ ដឹងច្បាស់តាមសេចក្ដីពិត នូវអានិសង្ស នូវទោស និងការរលាស់ចោល នៃវិញ្ញាណ ។

[១៩០] ទៀបក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំង-ឡាយ បុថុជ្ជនអ្នកមិនចេះដឹង រមែងមិនដឹងច្បាស់តាមសេចក្ដីពិត នូវការកើត នូវសេចក្ដីវិនាស នូវអានិសង្ស នូវទោស និងការរលាស់ចោល នៃរូប ។ នៃវេទនា ។ នៃសញ្ញា ។ នៃសង្ខារទាំងឡាយ ។

វិញ្ញាណស្ស សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ នប្បជានាតិ ។ សុតវា ច ខោ ភិក្ខវេ អរិយសាវកោ រូបស្ស សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានាតិ ។ វេទនាយ ។ សញ្ញាយ ។ សង្ខារានំ ។ វិញ្ញាណស្ស សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានាតីតិ ។

(១៨១) សាវត្ថិយំ ។ តត្រ ខោ ។ សុតវា ភិក្ខវេ អរិយសាវកោ រូបស្ស សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានាតិ ។ វេទនាយ ។ សញ្ញាយ ។ សង្ខារានំ ។ វិញ្ញាណស្ស សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានាតីតិ ។

មិនដឹងច្បាស់តាមសេចក្តីពិត នូវការកើត នូវសេចក្តីវិនាស នូវអានិសង្ស នូវទោស និងការរលាស់ចោល នៃវិញ្ញាណ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កអ្នកចេះដឹង រមែងដឹងច្បាស់តាមសេចក្តីពិត នូវការកើត នូវសេចក្តីវិនាស នូវអានិសង្ស នូវទោស និងការរលាស់ចោល នៃរូប ។ នៃវេទនា ។ នៃសញ្ញា ។ នៃសង្ខារទាំងឡាយ ។ ដឹងច្បាស់តាមសេចក្តីពិត នូវការកើត នូវសេចក្តីវិនាស នូវអានិសង្ស នូវទោស និងការរលាស់ចោល នៃវិញ្ញាណ ។

(១៩១) ទៀបក្រុងសាវត្ថី ។ កងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កអ្នកចេះដឹង រមែងដឹងច្បាស់តាមសេចក្តីពិត នូវការកើត នូវសេចក្តីវិនាស នូវអានិសង្ស នូវទោស និងការរលាស់ចោល នៃរូប ។ នៃវេទនា ។ នៃសញ្ញា ។ នៃសង្ខារទាំងឡាយ ។ ដឹងច្បាស់តាមសេចក្តីពិត នូវការកើត នូវសេចក្តីវិនាស នូវអានិសង្ស នូវទោស និងការរលាស់ចោល នៃវិញ្ញាណ ។

(១៨២) សាវត្ថិយំ ។ តត្រ ខោ ។ រូបំ ភិក្ខវេ អនិច្ចំ យទនិច្ចំ តំ ទុក្ខំ យំ ទុក្ខំ តទនត្តា យទនត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ វេទនា ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ អនិច្ចំ យទនិច្ចំ តំ ទុក្ខំ យំ ទុក្ខំ តទនត្តា យទនត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ រូបស្មឹបិ និព្វិន្ទតិ វេទនាយបិ ។ សញ្ញាយបិ ។ សង្ខារេសុបិ ។ វិញ្ញាណស្មឹបិ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ

[១៩២] ទៀបក្រុងសាវត្ថី ។ ក៏ឯទីនោះឯង ។ ម្នាលភិក្ខុទាំង-ឡាយ រូបមិនទៀង របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ របស់នោះជាអនត្តា របស់ណាជាអនត្តា របស់នោះ បណ្ឌិតត្រូវឃើញតាមសេចក្តីពិតដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនរបស់អញទេ នុ៎ះមិនមែនជាអញទេ នុ៎ះមិនមែនជាខ្លួនអញទេ ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណមិនទៀងទេ របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ របស់នោះ ជាអនត្តា របស់ណាជាអនត្តា របស់នោះ បណ្ឌិតត្រូវឃើញតាមសេចក្តីពិតដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនរបស់អញទេ នុ៎ះមិនមែនជាអញទេ នុ៎ះមិនមែនជាខ្លួនអញទេ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កអ្នកចេះដឹង កាលបើឃើញយ៉ាងនេះ រមែងនឿយណាយក្នុងរូបផង ក្នុងវេទនាផង ។ ក្នុងសញ្ញាផង ។ ក្នុងសង្ខារទាំងឡាយផង ។ រមែងនឿយណាយក្នុងវិញ្ញាណផង កាលបើនឿយណាយហើយ រមែងប្រាសចាកតម្រេក

វិរាគា វិមុច្ចតិ ។ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ។ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។ យាវតា ភិក្ខវេ សត្តាវាសា យាវតា ភវគ្គំ ឯតេ អគ្គា ឯតេ សេដ្ឋា លោកស្មឹ យទិទំ អរហន្តោតិ ។ ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា

(១៨៣) សុខិនោ វត អរហន្តោ
តណ្ហា តេសំ ន វិជ្ជតិ
អស្មិមានោ សមុច្ឆិន្នោ
មោហជាលំ បទាលិតំ ។
អនេជន្តេ អនុប្បត្តា
ចិត្តំ តេសំ អនាវិលំ
លោកេ អនុបលិត្តា តេ
ព្រហ្មភូតា អនាសវា ។
បញ្ចក្ខន្ធេ បរិញ្ញាយ
សត្តសទ្ធម្មគោចរា

ព្រោះតែប្រាសចាកតម្រេក ទើបចិត្តរួចស្រឡះ ។ កាលបើចិត្តរួចស្រឡះហើយ ញាណក៏កើតឡើងថា អាត្មាអញរួចស្រឡះហើយ ។ ដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈអាត្មាអញបាននៅរួចហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ លំនៅរបស់សត្វទាំងប៉ុន្មាន ភពដ៏ប្រសើរទាំងប៉ុន្មាន មានតែពួកអរហន្តទេ ដែលជាបុគ្គលខ្ពង់ខ្ពស់ ប្រសើរបំផុត ក្នុងលោក ។ ព្រះមានព្រះភាគត្រាស់សូត្រនេះចប់ហើយ លុះព្រះសុគតជាសាស្តា ត្រាស់សូត្រនេះចប់ហើយ ទើបត្រាស់គាថានេះ តទៅទៀតថា

[១៨៣] ពួកអរហន្តមានសេចក្តីសុខណាស់ ពួកអរហន្តទាំងនោះមិនមានតណ្ហាទេ អស្មិមានះ លោកផ្តាច់បង់ហើយ បណ្តាញគឺមោហៈ លោកទម្លាយចោលហើយ ។ លោកមិនដល់នូវការញាប់ញ័រ ដោយតណ្ហានិងទិដ្ឋិទេ ចិត្តរបស់អរហន្តទាំងនោះ មិនល្អក់ទេ អរហន្តទាំងនោះជាអ្នកប្រសើរ មិនមានអាសវៈ មិនជាប់នៅក្នុងលោក ។ លោកមានព្រះសទ្ធម្មទាំង ៧[១] ជាអារម្មណ៍ ព្រោះកំណត់ដឹងនូវខន្ធទាំង ៥

១ ព្រះសទ្ធម្មទាំង ៧ នោះ បានដល់ សទ្ធា ហិរិ ឱត្តប្បៈ ពាហុសច្ចៈ វីរិយៈ ឧបដ្ឋិតស្សតិ និងបញ្ញា ។ អដ្ឋកថា ។

បសំសិយា សប្បុរិសា
បុត្តា ពុទ្ធស្ស ឱរសា ។
សត្តរតនសម្បន្នា
តីសុ សិក្ខាសុ សិក្ខិតា
អនុវិចរន្តិ មហាវីរា
បហីនភយភេរវា ។
ទសហង្គេហិ សម្បន្នា
មហានាគា សមាហិតា
ឯតេ ខោ សេដ្ឋា លោកស្មឹ
តណ្ហា តេសំ ន វិជ្ជតិ ។
អសេក្ខញាណំ ឧប្បន្នំ
អន្តិមោយំ(១) សមុស្សយោ
យោ សារោ ព្រហ្មចរិយស្ស
តស្មឹ អបរប្បច្ចយា ។

---

១ ម. អន្តិមស្ស សមុស្សយោ ។

ពួកសប្បុរសតែងសរសើរចំពោះពួកអរហន្តជាបុត្រជាឱរស របស់ព្រះពុទ្ធ ។ ពួកអរហន្តបរិបូណ៌ដោយកែវគឺពោជ្ឈង្គ ទាំង ៧ ប្រការ បានសិក្សាចំពោះសិក្ខាទាំង ៣ មានព្យា-យាមច្រើន បានលះបង់នូវភ័យនិងសេចក្តីខ្លាចដ៏ពន្លឹកហើយ ប្រព្រឹត្តទៅ ។ ពួកអរហន្តជាមហានាគ ប្រកបដោយអង្គជា អសេក្ខៈទាំង ១០ មានចិត្តនឹងធឹង (ដោយឧបចារនិងអប្បនា ទាំងឡាយ) អរហន្តទាំងនុ៎ះប្រសើរបំផុតក្នុងលោក អរហន្ត ទាំងនោះមិនមានតណ្ហាទេ ។ ញាណរបស់អសេក្ខបុគ្គល កើតឡើងហើយ នេះជាទីបំផុតនៃអត្តភាព ផលណារបស់ មគ្គព្រហ្មចារ្យ លោកបានតាក់ដុះ ក្នុងផលនោះហើយ ។

វិធាសុ ន វិកម្បន្តិ

វិប្បមុត្តា បុនព្ភវា

ទន្តភូមឹ អនុប្បត្តា

តេ លោកេ វិជិតាវិនោ ។

ឧទ្ធំ តិរិយំ អបាចិនំ

នន្ទិ តេសំ ន វិជ្ជតិ

នទន្តិ(១) វេ សីហនាទំ

ពុទ្ធា លោកេ អនុត្តរាតិ ។

(១៥៤) សាវត្ថិយំ ។ តត្រ ខោ ។ រូបំ ភិក្ខវេ អនិច្ចំ យទនិច្ចំ តំ ទុក្ខំ យំ ទុក្ខំ តទនត្តា យទន-ត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ បេ ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ

២ ឱ. នន្ទន្តិ តេ ។

ពួកអរហន្តមិនញាប់ញ័រ ចំពោះមានះផ្សេង ៗ អរហន្តទាំង-
នោះ មានចិត្តផុតស្រឡះចាកភពថ្មីទៀត បានសម្រេចអរហត្ត
បានឈ្នះ (នូវកិលេសមានពកៈជាដើម) ក្នុងលោកហើយ
រមែងមិនញាប់ញ័រចំពោះមានះផ្សេង ៗ ។ អរហន្តទាំងនោះ
មិនមានសេចក្តីត្រេកអរ ចំពោះទេវលោក មនុស្សលោក
និងអបាយលោកឡើយ អរហន្តទាំងនោះ បានចាក់ធ្លុះនូវ
អរិយសច្ចទាំង ៤ ជាបុគ្គលប្រសើរបំផុតក្នុងលោក ហើយ
បន្លឺនូវសីហនាទ ។

(១៩៤) ទៀបក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំង-
ឡាយ រូបមិនទៀងទេ របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណា
ជាទុក្ខ របស់នោះជាអនត្តា របស់ណាជាអនត្តា របស់នោះ បណ្ឌិតត្រូវ
ឃើញតាមសេចក្តីពិតដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនរបស់
អញទេ នុ៎ះមិនមែនជាអញទេ នុ៎ះមិនមែនជាខ្លួនអញទេ ។ បេ ។ ម្នាល
ភិក្ខុទាំងឡាយ អរិយសាវ័កអ្នកចេះដឹង កាលបើឃើញយ៉ាងនេះហើយ

រូបស្មឹបិ និព្វិន្ទតិ វេទនាយបិ ។ សញ្ញាយបិ ។ សង្ខារេសុបិ ។ វិញ្ញាណស្មឹបិ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ ។ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ។ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។ យាវតា ភិក្ខវេ សត្តាវាសា យាវតា ភវគ្គំ ឯតេ អគ្គា ឯតេ សេដ្ឋា លោកស្មឹ យទិទំ អរហន្តោតិ ។

[១៥៥] សាវត្ថិយំ ។ តត្រ ខោ ។ សីហោ ភិក្ខវេ មិគរាជា សាយណ្ហសមយំ អាសយា និក្ខមតិ

រមែងនឿយណាយក្នុងរូបផង ក្នុងវេទនាផង ។ ក្នុងសញ្ញាផង ។ ក្នុងសង្ខារទាំងឡាយផង ។ រមែងនឿយណាយក្នុងវិញ្ញាណផង កាលបើនឿយណាយ រមែងប្រាសចាកតម្រេក ព្រោះតែប្រាសចាកតម្រេក ទើបចិត្តរួចស្រឡះបាន ។ កាលបើចិត្តរួចស្រឡះហើយ ញាណក៏កើតឡើងថា អាត្មាអញរួចស្រឡះហើយ ។ ដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចារ្យ អាត្មាអញនៅរួចហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ លំនៅរបស់ពួកសត្វទាំងប៉ុន្មាន ភពដ៏ប្រសើរទាំងប៉ុន្មាន មានតែអរហន្ត ជាបុគ្គលខ្ពង់ខ្ពស់ ប្រសើរបំផុតក្នុងលោកនេះ ។

[១៥៥] ទៀបក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ សត្វសីហៈជាស្តេចម្រឹគ ចេញអំពីលំនៅក្នុងសម័យថ្ងៃសៀល

អាសយា និក្ខមិត្វា វិជម្ភតិ វិជម្ភិត្វា សមន្តា ចតុទ្ទិសា អនុវិលោកេតិ សមន្តា ចតុទ្ទិសា អនុវិលោកេត្វា តិក្ខត្តុំ សីហនាទំ នទតិ តិក្ខត្តុំ សីហនាទំ នទិត្វា គោចរាយ បក្កមតិ ។ យេ ហិ កេចិ ភិក្ខវេ តិរច្ឆានគតា បាណា សីហស្ស មិគរញ្ញោ នទតោ សទ្ទំ សុណន្តិ យេភុយ្យេន សំវេគំ សន្តាសំ អាបជ្ជន្តិ ពិលំ ពិលាសយា បវិសន្តិ ទកំ ទកាសយា បវិសន្តិ វនំ វនាសយា បវិសន្តិ អាកាសំ បក្ខិនោ ភជន្តិ ។ យេបិ តេ ភិក្ខវេ រញ្ញោ នាគា គាមនិគមរាជធានីសុ ទឡ្ហេហិ(១) វរត្តេហិ ពន្ធនេហិ ពទ្ធា តេបិ តានិ ពន្ធនានិ សញ្ឆិន្ទិត្វា សម្បទាលេត្វា ភីតា មុត្តករីសំ ចជមានា(២) យេន វា តេន វា បលាយន្តិ ។ ឯវំមហិទ្ធិកោ ខោ ភិក្ខវេ សីហោ មិគរាជា តិរច្ឆានគតានំ បាណានំ ឯវំមហេសក្ខោ ឯវំមហានុភាវោ ។

---

១ ឱ. ម. ទឡ្ហេហិ យោត្តេហិ ។ ២ មោចត្តា ។

លុះចេញអំពីលំនៅហើយ រមែងមីតពត់ (កាយ) លុះមីតពត់ហើយ ទើបក្រឡេកមើលទិសទាំង ៤ ជុំវិញ លុះក្រឡេកមើលទិសទាំង ៤ ជុំវិញហើយ ក៏បន្លឺនូវសីហនាទអស់វារៈ ៣ ដង លុះបន្លឺនូវសីហនាទ ៣ ដងហើយ ទើបត្រាច់ចរទៅរកចំណី ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វតិរច្ឆានណានីមួយ ឮសំឡេងសត្វសីហៈជាមិគរាជ កំពុងបន្លឺ (នូវសីហនាទ) ហើយ ច្រើនតែដល់នូវសេចក្តីតក់ស្លុត ញ័រចំប្រប់ ពួកសត្វនៅរូងរមែងចូលទៅរូងវិញ ពួកសត្វទឹកចូលទៅក្នុងទឹកវិញ ពួកសត្វព្រៃចូលទៅរកព្រៃវិញ ពួកបក្សីក៏ហើរទៅរកអាកាសវិញ ។ ម្នាលភិក្ខុទាំងឡាយ ពួកដំរីណាជារបស់ព្រះរាជា ដែលគេចងដោយចំណងគឺព្រ័ត្រដ៏មាំ ក្នុងស្រុកនិគមនិងរាជធានី ដំរីទាំងនោះក៏រមែងផ្តាច់ទម្លាយចំណងទាំងនោះ ភិតភ័យលេចមូត្រនិងករីសហើយ ប៉ោលទៅផ្តេសផ្តាស ។ ម្នាលភិក្ខុទាំងឡាយ សត្វសីហៈជាមិគរាជ មានឫទ្ធិច្រើនយ៉ាងនេះ មានស័ក្តិធំយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ជាងសត្វតិរច្ឆានទាំងឡាយ ។

[១៥៦] ឯវមេវ ខោ ភិក្ខវេ យទា តថាគតោ លោកេ ឧប្បជ្ជតិ អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវា សោ ធម្មំ ទេសេតិ ឥតិ រូបំ ឥតិ រូបស្ស សមុទយោ ឥតិ រូបស្ស អត្ថង្គមោ ឥតិ វេទនា ។ ឥតិ សញ្ញា ។ ឥតិ សង្ខារា ។ ឥតិ វិញ្ញាណំ ឥតិ វិញ្ញាណស្ស សមុទយោ ឥតិ វិញ្ញាណស្ស អត្ថង្គមោតិ ។ យេបិ តេ ភិក្ខវេ ទេវា ទីឃាយុកា វណ្ណវន្តោ សុខពហុលា ឧច្ចេសុ វិមានេសុ ចិរដ្ឋិតិកា តេបិ តថាគតស្ស ធម្មទេសនំ សុត្វា យេភុយ្យេន ភយំ សំវេគំ សន្តាសំ អាបជ្ជន្តិ អនិច្ចា វ កិរ ភោ មយំ សមានា និច្ចម្ហាតិ អមញ្ញិម្ហ អទ្ធុវា វ កិរ ភោ មយំ សមានា ធុវម្ហាតិ អមញ្ញិម្ហ អសស្សតា វ កិរ ភោ មយំ សមានា សស្សតម្ហាតិ អមញ្ញិម្ហ មយំបិ កិរ ភោ អនិច្ចា អទ្ធុវា អសស្សតា សក្កាយបរិយាបន្នាតិ ។ ឯវំមហិទ្ធិកោ ខោ ភិក្ខវេ តថាគតោ

(១៩៦) ម្នាលភិក្ខុទាំងឡាយ កាលណា ព្រះតថាគត ជាព្រះអរហន្តសម្មាសម្ពុទ្ធ ទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណៈ ជាព្រះសុគត ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរបំផុត ជាសារថីទូន្មាននូវបុរស ជាសាស្តាចារ្យនៃពួកទេវតានិងមនុស្ស ត្រាស់ដឹងនូវចតុរារិយសច្ច លែងត្រឡប់មកកាន់ភពថ្មីទៀត ទ្រង់កើតឡើងក្នុងលោក ព្រះអង្គតែងសំម្តែង ថា រូបដូច្នេះ ការកើតនៃរូបដូច្នេះ សេចក្តីវិនាសនៃរូបដូច្នេះ វេទនាដូច្នេះ ។ សញ្ញាដូច្នេះ ។ សង្ខារទាំងឡាយដូច្នេះ ។ វិញ្ញាណដូច្នេះ ការកើតនៃវិញ្ញាណដូច្នេះ សេចក្តីវិនាសនៃវិញ្ញាណដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ ពួកទេវតាណា ដែលមានអាយុវែង មានពណ៌សម្បុរច្រើនដោយសេចក្តីសុខ ឋិតនៅលើវិមានដ៏ខ្ពស់ អស់កាលយូរ ពួកទេវតានោះ បានស្តាប់ធម៌ទេសនារបស់ព្រះតថាគតហើយ ច្រើនតែដល់នូវសេចក្តីភិតភ័យ តក់ស្លុត ញ័របំប្រប់ ដោយគិតថា អើហ្ន៎ យើងទាំងឡាយមិនទៀងទេតើ ប៉ុន្តែយើងសំគាល់ថាទៀង អើហ្ន៎ យើងទាំងឡាយមិនឋិតថេរទេតើ ប៉ុន្តែយើងសំគាល់ថាឋិតថេរ អើហ្ន៎ យើងទាំងឡាយមិនកំណត់ទេតើ ប៉ុន្តែយើងសំគាល់ថាកំណត់ អើហ្ន៎ យើងទាំងឡាយមិនទៀង មិនឋិតថេរ មិនកំណត់ទេ ប៉ុន្តែយើងរាប់អានព្រោះសក្កាយ ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគត មានឫទ្ធិច្រើនយ៉ាងនេះ

សទេវកស្ស លោកស្ស ឯវំមហេសក្ខោ ឯវំមហា-នុភាវោតិ ។ ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា

[១៩៧] យទា ពុទ្ធោ អភិញ្ញាយ
ធម្មចក្កំ បវត្តយិ
សទេវកស្ស លោកស្ស
សត្ថា អប្បដិបុគ្គលោ ។
សក្កាយស្ស និរោធញ្ច
សក្កាយស្ស ច សម្ភវំ
អរិយដ្ឋង្គិកំ(១) មគ្គំ
ទុក្ខូបសមគាមិនំ ។
យេបិ ទីឃាយុកា ទេវា
វណ្ណវន្តោ យសស្សិនោ
ភីតា សន្តាសមាបាទុំ

១ ឱ. ម. អរិយញ្ចដ្ឋង្គិកំ ។

មានស័ក្តិធំយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ដល់មនុស្សលោក ព្រមទាំងទេវលោក ក៏យ៉ាងនោះដែរ ។ ព្រះមានព្រះភាគបានត្រាស់ភាសិតនេះចប់ហើយ លុះព្រះសុគតជាសាស្តា ត្រាស់ភាសិតនេះចប់ហើយ ទើបត្រាស់គាថានេះតទៅទៀតថា

(១៨៧) កាលណា ព្រះពុទ្ធបានត្រាស់ដឹងឡើង សំដែងធម្មចក្រហើយ ព្រះអង្គជាគ្រូរបស់មនុស្សលោក ព្រមទាំងទេវលោក ឥតមានបុគ្គលប្រៀបផ្ទឹមបាន ។ (ទ្រង់សំដែង) នូវការរលត់នៃសក្កាយផង នូវហេតុកើតនៃសក្កាយផង នូវមគ្គដ៏ប្រសើរ ប្រកបដោយអង្គ ៨ ជាផ្លូវសម្រាប់ទៅកាន់ទីរលត់ទុក្ខផង ។ ពួកទេវតាណា មានអាយុវែង មានពណ៌សម្បុរ មានយស ជាអ្នកខ្លាច ជាអ្នកដល់នូវសេចក្តីតក់ស្លុត

សីហស្សេវិតរេ មិគា ។
អវីតិវត្តា សក្កាយំ
អនិច្ចា កិរ ភោ មយំ
សុត្វា អរហតោ វាក្យំ
វិប្បមុត្តស្ស តាទិនោតិ ។

[១៤៨] សាវត្ថិយំ ។ តត្រ ខោ ។ យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា អនេកវិហិតំ បុព្វេនិវាសំ អនុស្សរមានា អនុស្សរន្តិ សព្វេ តេ បញ្ចុបាទានក្ខន្ធេ អនុស្សរន្តិ ឯតេសំ វា អញ្ញតរំ ។ កតមេ បញ្ច ។ ឯវំរូបោ អហោសឹ អតីតមទ្ធានន្តិ ឥតិ វា ហិ ភិក្ខវេ អនុស្សរមានោ រូបញ្ញេវ អនុស្សរតិ ។ ឯវំវេទនោ អហោសឹ អតីតមទ្ធានន្តិ ឥតិ វា ហិ ភិក្ខវេ អនុស្សរមានោ វេទនញ្ញេវ អនុស្សរតិ ។ ឯវំសញ្ញោ(១) អហោសឹ អតីតមទ្ធានន្តិ ។ ឯវំសង្ខារោ អហោសឹ អតីតមទ្ធានន្តិ ។ ឯវំវិញ្ញាណោ អហោសឹ អតីតមទ្ធានន្តិ ឥតិ វា ហិ ភិក្ខវេ អនុស្សរមានោ វិញ្ញាណញ្ញេវ អនុស្សរតិ ។

១ ឱ. ឯវំសញ្ញី ។

ដូចជាហ្វូងម្រឹគខ្លាចសីហៈ ។ សត្វទាំងឡាយ មិនទាន់លះបង់នូវសក្កាយ បានស្តាប់ពាក្យរបស់ព្រះអរហន្តសម្មាសម្ពុទ្ធ មានចិត្តផុតស្រឡះ ប្រកបដោយតាទិគុណថា អើហ្ន៎ យើងទាំងឡាយមិនទៀងទេ ដូច្នេះ ។

[១៩៨] ទៀបក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ កាលបើពួកសមណៈឬព្រាហ្មណ៍ណាមួយ រឭកឃើញ រមែងរឭកឃើញនូវបុព្វេនិវាស មានប្រការផ្សេង ៗ ពួកសមណព្រាហ្មណ៍ទាំងអស់នោះ រមែងរឭកឃើញនូវឧបាទានក្ខន្ធទាំង ៥ ឬបណ្តាឧបាទានក្ខន្ធទាំង ៥ នុ៎ះ រឭកឃើញនូវឧបាទានក្ខន្ធណាមួយ ។ ឧបាទានក្ខន្ធទាំង ៥ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កាលបើសមណព្រាហ្មណ៍ រឭកឃើញ រមែងរឭកឃើញនូវរូប ដូច្នេះថា អាត្មាអញមានរូបយ៉ាងនេះក្នុងកាលជាអតីត ។ ម្នាលភិក្ខុទាំងឡាយ កាលបើសមណព្រាហ្មណ៍រឭកឃើញ រមែងឃើញនូវវេទនា ដូច្នេះថា អាត្មាអញមានវេទនាយ៉ាងនេះក្នុងកាលជាអតីត ។ អាត្មាអញមានសញ្ញាយ៉ាងនេះក្នុងកាលជាអតីត ។ អាត្មាអញមានសង្ខារយ៉ាងនេះក្នុងកាលជាអតីត ។ ម្នាលភិក្ខុទាំងឡាយ កាលបើសមណព្រាហ្មណ៍រឭកឃើញ រមែងរឭកឃើញនូវវិញ្ញាណដូច្នេះថា អាត្មាអញមានវិញ្ញាណយ៉ាងនេះក្នុងកាលជាអតីត ។

[១៥៩] កិញ្ច ភិក្ខវេ រូបំ វទេថ ។ រុប្បតីតិ ខោ ភិក្ខវេ តស្មា រូបន្តិ វុច្ចតិ ។ កេន រុប្បតិ ។ សីតេនបិ រុប្បតិ ឧណ្ហេនបិ រុប្បតិ ជិឃច្ឆាយបិ រុប្បតិ បិបាសាយបិ រុប្បតិ ឌំសមកសវាតាតប-សិរីសបសម្ផស្សេនបិ រុប្បតិ ។ រុប្បតីតិ ខោ ភិក្ខវេ តស្មា រូបន្តិ វុច្ចតិ ។ កិញ្ច ភិក្ខវេ វេទនំ វទេថ ។ វេទយតីតិ ខោ ភិក្ខវេ តស្មា វេទនាតិ វុច្ចតិ ។ កិញ្ច វេទយតិ ។ សុខំបិ វេទយតិ ទុក្ខំបិ វេទយតិ អទុក្ខម-សុខំបិ វេទយតិ ។ វេទយតីតិ ខោ ភិក្ខវេ តស្មា វេទ-នាតិ វុច្ចតិ ។ កិញ្ច ភិក្ខវេ សញ្ញំ វទេថ ។ សញ្ជា-នាតីតិ ខោ ភិក្ខវេ តស្មា សញ្ញាតិ វុច្ចតិ ។ កិញ្ច សញ្ជានាតិ ។ នីលំបិ សញ្ជានាតិ បីតកំបិ សញ្ជានាតិ

(១៥៩) ម្នាលភិក្ខុទាំងឡាយ ចុះអ្នកទាំងឡាយហៅថារូប តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ របស់ណាវិនាស របស់នោះហៅថារូប ។ ចុះវិនាសដោយអ្វី ។ វិនាសដោយត្រជាក់ក៏មាន វិនាសដោយក្តៅក៏មាន វិនាសដោយឃ្លានក៏មាន វិនាសដោយស្រេកក៏មាន វិនាសដោយសម្ផ័ស្សនៃរបោមមូសខ្យល់កំដៅថ្ងៃពោះតូចពោះធំក៏មាន ។ ម្នាលភិក្ខុទាំងឡាយ របស់ណាវិនាស របស់នោះហៅថារូប ។ ម្នាលភិក្ខុទាំងឡាយ ចុះអ្នកទាំងឡាយ ហៅថាវេទនា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ធម្មជាតិណារងនូវអារម្មណ៍ ធម្មជាតិនោះ ហៅថាវេទនា ។ ចុះធម្មជាតិនោះ រងអ្វីខ្លះ ។ រងនូវសុខក៏មាន រងនូវទុក្ខក៏មាន រងនូវអទុក្ខមសុខក៏មាន ។ ម្នាលភិក្ខុទាំងឡាយ ធម្មជាតិណា រងនូវអារម្មណ៍ ធម្មជាតិនោះ ហៅថាវេទនា ។ ម្នាលភិក្ខុទាំងឡាយ ចុះអ្នកទាំងឡាយ ហៅថាសញ្ញា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ធម្មជាតិណាចំណាំ (នូវអារម្មណ៍) ធម្មជាតិនោះ ហៅថាសញ្ញា ។ ចុះចំណាំនូវអ្វី ។ ចំណាំព័ណ៌ខៀវក៏មាន ចំណាំព័ណ៌លឿងក៏មាន

លោហិតកំបិ សញ្ជានាតិ ឱទាតំបិ សញ្ជានាតិ ។ សញ្ជានាតីតិ ខោ ភិក្ខវេ តស្មា សញ្ញាតិ វុច្ចតិ ។ កិញ្ច ភិក្ខវេ សង្ខារេ វទេថ ។ សង្ខតំ អភិសង្ខរោន្តីតិ ខោ ភិក្ខវេ តស្មា សង្ខារាតិ វុច្ចន្តិ ។ កិញ្ច សង្ខតំ អភិសង្ខរោន្តិ ។ រូបំ រូបត្តាយ សង្ខតំ អភិសង្ខរោន្តិ វេទនំ វេទនត្តាយ សង្ខតំ អភិសង្ខរោន្តិ សញ្ញំ សញ្ញត្តាយ សង្ខតំ អភិសង្ខរោន្តិ សង្ខារេ សង្ខារត្តាយ សង្ខតំ អភិសង្ខរោន្តិ វិញ្ញាណំ វិញ្ញាណត្តាយ សង្ខតំ អភិសង្ខរោន្តិ ។ សង្ខតំ អភិសង្ខរោន្តីតិ ខោ ភិក្ខវេ តស្មា សង្ខារាតិ វុច្ចន្តិ ។ កិញ្ច ភិក្ខវេ វិញ្ញាណំ វទេថ ។ វិជានាតីតិ ខោ ភិក្ខវេ តស្មា វិញ្ញាណន្តិ វុច្ចតិ ។ កិញ្ច វិជានាតិ(១) ។ អម្ពិលំបិ វិជានាតិ តិត្តកំបិ វិជានាតិ កដុកំបិ វិជានាតិ

១ ឱ. ម. កិញ្ច វិជានាតិ ។

ចំណាំពណ៌ក្រហមក៏មាន ចំណាំពណ៌សក៏មាន ។ ម្នាលភិក្ខុទាំងឡាយ ធម្មជាតិណាចំណាំ (នូវអារម្មណ៍) ធម្មជាតិនោះហៅថាសញ្ញា ។ ម្នាលភិក្ខុទាំងឡាយ ចុះអ្នកទាំងឡាយហៅថាសង្ខារទាំងឡាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សភាវៈទាំងឡាយណា តាក់តែងនូវសង្ខតធម៌ សភាវៈទាំងឡាយនោះ ហៅថាសង្ខារ ។ សភាវៈទាំងឡាយតាក់តែងនូវសង្ខតធម៌ តើដូចម្តេច ។ តាក់តែងនូវសង្ខតធម៌គឺរូប តាមសភាពរូប តាក់តែងនូវសង្ខតធម៌គឺវេទនា តាមសភាពវេទនា តាក់តែងនូវសង្ខតធម៌គឺសញ្ញា តាមសភាពចំណាំនូវអារម្មណ៍ តាក់តែងនូវសង្ខតធម៌គឺសង្ខារទាំងឡាយ តាមសភាពតាក់តែង តាក់តែងនូវសង្ខតធម៌គឺវិញ្ញាណ តាមសភាពដឹងច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ សភាវៈទាំងឡាយណា តាក់តែងនូវសង្ខតធម៌ សភាវៈទាំងឡាយនោះ ហៅថាសង្ខារ ។ ម្នាលភិក្ខុទាំងឡាយ ចុះអ្នកទាំងឡាយហៅថាវិញ្ញាណ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ធម្មជាតណាដឹងច្បាស់ (នូវរស) ធម្មជាតនោះ ហៅថាវិញ្ញាណ ។ ចុះដឹងច្បាស់នូវអ្វី ។ ដឹងច្បាស់នូវរសជូរក៏មាន ដឹងច្បាស់នូវរសល្វីងក៏មាន ដឹងច្បាស់នូវរសហឹរក៏មាន

មធុរំបិ វិជានាតិ ខារិកំបិ វិជានាតិ អខារិកំបិ វិជានាតិ លោណិកំបិ វិជានាតិ អលោណិកំបិ វិជានាតិ ។ វិជានាតីតិ ខោ ភិក្ខវេ តស្មា វិញ្ញាណន្តិ វុច្ចតិ ។

(១៦០) តត្រ ភិក្ខវេ សុតវា អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ អហំ ខោ ឯតរហិ រូបេន ខជ្ជាមិ អតីតំបាហំ អទ្ធានំ ឯវមេវ រូបេន ខជ្ជឹ សេយ្យថាបិ ឯតរហិ បច្ចុប្បន្នេន រូបេន ខជ្ជាមិ អហញ្ចេវ ខោ បន អនាគតំ រូបំ អភិនន្ទេយ្យំ អនាគតំបាហំ អទ្ធានំ ឯវមេវ រូបេន ខជ្ជេយ្យំ សេយ្យថាបិ ឯតរហិ បច្ចុប្បន្នេន រូបេន ខជ្ជាមីតិ ។ សោ ឥតិ បដិសង្ខាយ អតីតស្មឹ រូបស្មឹ អនបេក្ខោ ហោតិ អនាគតំ រូបំ នាភិនន្ទតិ បច្ចុប្បន្នស្ស រូបស្ស និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតិ ។ អហំ ខោ ឯតរហិ វេទនាយ ខជ្ជាមិ អតីតំបាហំ

ដឹងច្បាស់នូវរសផ្អែមក៏មាន ដឹងច្បាស់នូវរសខារក៏មាន ដឹងច្បាស់នូវរបស់មិនខារក៏មាន ដឹងច្បាស់នូវរសប្រៃក៏មាន ដឹងច្បាស់នូវរសសាបក៏មាន ។ ម្នាលភិក្ខុទាំងឡាយ ធម្មជាតណា ដឹងច្បាស់ (នូវរស) ធម្មជាតនោះ ហៅថាវិញ្ញាណ ។

[១៦០] ម្នាលភិក្ខុទាំងឡាយ ក្នុងសេចក្តីនោះ អរិយសាវកអ្នកចេះដឹង រមែងពិចារណាឃើញដូច្នេះថា អាត្មាអញទំពាស៊ីដោយសាររូបក្នុងកាលឥឡូវនេះ បើដូច្នោះ មានតែអាត្មាអញបានទំពាស៊ីដោយសាររូបក្នុងអតីតកាលយ៉ាងនេះហើយ ដូចជាអាត្មាអញទំពាស៊ីដោយសាររូបជាបច្ចុប្បន្ន ក្នុងកាលឥឡូវនេះដែរ បើអាត្មាអញត្រេកអរនឹងរូបជាអនាគតហើយ អាត្មាអញគង់នឹងទំពាស៊ីដោយសាររូប ក្នុងអនាគតកាលយ៉ាងនេះ ដូចជាអាត្មាអញទំពាស៊ីដោយសាររូបជាបច្ចុប្បន្ន ក្នុងកាលឥឡូវនេះដែរ ។ អរិយសាវកនោះកាលបើពិចារណាឃើញដូច្នេះហើយ មិនអាឡោះអាល័យក្នុងរូបជាអតីត មិនត្រេកអរនឹងរូបជាអនាគត ជាអ្នកប្រតិបត្តិដើម្បីនឿយណាយ ប្រាសចាកតម្រេក ដើម្បីរលត់រូបជាបច្ចុប្បន្ន ។ អាត្មាអញទំពាស៊ីដោយសារវេទនាក្នុងកាលឥឡូវនេះ បើដូច្នោះមានតែអាត្មាអញបាន

អទ្ធានំ ឯវមេវ វេទនាយ ខជ្ជឹ សេយ្យថាបិ ឯតរហិ បច្ចុប្បន្នាយ វេទនាយ ខជ្ជាមិ អហញ្ចេវ ខោ បន អនាគតំ វេទនំ អភិនន្ទេយ្យំ អនាគតំបាហំ អទ្ធានំ ឯវមេវ វេទនាយ ខជ្ជេយ្យំ សេយ្យថាបិ ឯតរហិ បច្ចុប្បន្នាយ វេទនាយ ខជ្ជាមីតិ ។ សោ ឥតិ បដិសង្ខាយ អតីតាយ វេទនាយ អនបេក្ខោ ហោតិ អនាគតំ វេទនំ នាភិនន្ទតិ បច្ចុប្បន្នាយ វេទនាយ និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតិ ។ អហំ ខោ ឯតរហិ សញ្ញាយ ខជ្ជាមិ ។ អហំ ខោ ឯតរហិ សង្ខារេហិ ខជ្ជាមិ អតីតំបាហំ អទ្ធានំ ឯវមេវ សង្ខារេហិ ខជ្ជឹ សេយ្យថាបិ ឯតរហិ បច្ចុប្បន្នេហិ សង្ខារេហិ ខជ្ជាមិ អហញ្ចេវ ខោ បន អនាគតេ សង្ខារេ អភិនន្ទេយ្យំ អនាគតំបាហំ អទ្ធានំ ឯវមេវ សង្ខារេហិ ខជ្ជេយ្យំ សេយ្យថាបិ ឯតរហិ បច្ចុប្បន្នេហិ សង្ខារេហិ ខជ្ជាមីតិ ។ សោ ឥតិ បដិសង្ខាយ អតីតេសុ សង្ខារេសុ អនបេក្ខោ ហោតិ អនាគតេ សង្ខារេ នាភិនន្ទតិ

ទំពាស៊ីដោយសារវេទនាជាអតីតកាលយ៉ាងនេះហើយ ដូចជាអាត្មាអញទំពាស៊ីដោយសារវេទនាជាបច្ចុប្បន្នក្នុងកាលឥឡូវនេះដែរ បើអាត្មាអញត្រេកអរ នឹងវេទនាជាអនាគតហើយ អាត្មាអញគង់នឹងទំពាស៊ីដោយសារវេទនាជាអនាគតកាលយ៉ាងនេះទៀត ដូចជាអាត្មាអញទំពាស៊ីដោយសារវេទនាជាបច្ចុប្បន្ន ក្នុងកាលឥឡូវនេះដែរ ។ អរិយសាវ័កនោះ កាលបើពិចារណាឃើញដូច្នេះហើយ មិនអាឡោះអាល័យក្នុងវេទនាជាអតីត មិនត្រេកអរនឹងវេទនាជាអនាគត ជាអ្នកប្រតិបត្តិ ដើម្បីនឿយណាយ ប្រាសចាកតម្រេក ដើម្បីរលត់វេទនាជាបច្ចុប្បន្ន អាត្មាអញទំពាស៊ីដោយសារសញ្ញា ក្នុងកាលឥឡូវនេះ ។ អាត្មាអញទំពាស៊ីដោយសារសង្ខារ ក្នុងកាលឥឡូវនេះ បើដូច្នោះ មានតែអាត្មាអញបានទំពាស៊ីដោយសារសង្ខារ ក្នុងកាលជាអតីតយ៉ាងនេះហើយ ដូចជាអាត្មាអញទំពាស៊ីដោយសារសង្ខារជាបច្ចុប្បន្ន ក្នុងកាលឥឡូវនេះដែរ បើអាត្មាអញត្រេក-អរនឹងសង្ខារ ជាអនាគតកាល អាត្មាអញគង់នឹងទំពាស៊ីដោយសារសង្ខារ ក្នុងកាលជាអនាគត យ៉ាងនេះទៀត ដូចជាអាត្មាអញទំពាស៊ី ដោយសារសង្ខារជាបច្ចុប្បន្ន ក្នុងកាលឥឡូវនេះដែរ ។ កាលបើអរិយសាវ័កនោះ ពិចារណាឃើញដូច្នេះហើយ រមែងមិនអាឡោះអាល័យ ក្នុងសង្ខារទាំងឡាយជាអតីត មិនត្រេកអរនឹងសង្ខារទាំងឡាយ ជាអនាគត

បច្ចុប្បន្នានំ ។ សង្ខារានំ និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតិ ។ អហំ ខោ ឯតរហិ វិញ្ញាណេន ខជ្ជាមិ អតីតម្បាហំ អទ្ធានំ ឯវមេវ វិញ្ញាណេន ខជ្ជឹ សេយ្យថាបិ ឯតរហិ បច្ចុប្បន្នេន វិញ្ញាណេន ខជ្ជាមិ អហញ្ចេវ ខោ បន អនាគតំ វិញ្ញាណំ អភិនន្ទេយ្យំ អនាគតម្បាហំ អទ្ធានំ ឯវមេវ វិញ្ញាណេន ខជ្ជេយ្យំ សេយ្យថាបិ ឯតរហិ បច្ចុប្បន្នេន វិញ្ញាណេន ខជ្ជាមីតិ ។ សោ ឥតិ បដិសង្ខាយ អតីតស្មឹបិ វិញ្ញាណស្មឹ អនបេក្ខោ ហោតិ អនាគតំ វិញ្ញាណំ នាភិនន្ទតិ បច្ចុប្បន្នស្ស វិញ្ញាណស្ស និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតិ ។

(១៦១) តំ កឹ មញ្ញថ ភិក្ខវេ រូបំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ

ហើយប្រតិបត្តិដើម្បីនឿយណាយ ប្រាសចាកតម្រេក ដើម្បីរំលត់សង្ខារទាំងឡាយជាបច្ចុប្បន្ន ។ អាត្មាអញទំពាស៊ីដោយសារវិញ្ញាណក្នុងកាលឥឡូវនេះ បើដូច្នោះមានតែអាត្មាអញបានទំពាស៊ីដោយសារវិញ្ញាណក្នុងអតីតកាលយ៉ាងនេះហើយ ដូចជាអាត្មាអញទំពាស៊ីដោយសារវិញ្ញាណជាបច្ចុប្បន្នក្នុងកាលឥឡូវនេះដែរ បើអាត្មាអញត្រេកអរនឹងវិញ្ញាណជាអនាគត អាត្មាអញគង់នឹងទំពាស៊ីដោយសារវិញ្ញាណក្នុងកាលជាអនាគតយ៉ាងនេះទៀត ដូចជាអាត្មាអញទំពាស៊ីដោយសារវិញ្ញាណជាបច្ចុប្បន្នក្នុងកាលឥឡូវនេះដែរ ។ កាលបើអរិយសាវ័កនោះ ពិចារណាឃើញដូច្នេះហើយ តែងមិនអាឡោះអាល័យ ក្នុងវិញ្ញាណជាអតីតឡើយ មិនត្រេកអរនឹងវិញ្ញាណជាអនាគត ហើយប្រតិបត្តិ ដើម្បីនឿយណាយ ប្រាសចាកតម្រេក ដើម្បីរំលត់ នូវវិញ្ញាណជាបច្ចុប្បន្ន ។

(១៦១) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់សេចក្តីនោះជាដូចម្តេច រូបទៀង ឬមិនទៀង ។ បពិត្រព្រះអង្គដ៏ចម្រើន មិនទៀងទេ ។ ចុះរបស់ណាដែលមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ បពិត្រព្រះអង្គដ៏ចម្រើន របស់នោះជាទុក្ខ ។ ចុះរបស់ណា មិនទៀងជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា តើគួរយល់ឃើញនូវរបស់នោះថា

ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ វេទនា ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។

(១៦២) តស្មាតិហ ភិក្ខវេ យំ កិញ្ចិ រូបំ អតីតានាគតបច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា សព្វំ រូបំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ យា កាចិ វេទនា ។

នុះជារបស់អញ នុះជាអញ នុះជាខ្លួនអញដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនគួរនឹងយល់ឃើញយ៉ាងនុះទេ ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណទៀងឬមិនទៀង ។ បពិត្រព្រះអង្គដ៏ចម្រើន មិនទៀងទេ ។ ចុះរបស់ណាមិនទៀង របស់នោះ ជាទុក្ខឬជាសុខ ។ បពិត្រព្រះអង្គដ៏ចម្រើន របស់នោះជាទុក្ខ ។ ចុះរបស់ណា មិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា តើគួរយល់ឃើញនូវរបស់នោះថា នុះជារបស់អញ នុះជាអញ នុះជាខ្លួនអញដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនគួរនឹងយល់ឃើញយ៉ាងនោះទេ ។

[១៦២] ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងលោកនេះ រូបណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ជាខាងក្នុងក្ដី ខាងក្រៅក្ដី គ្រោតគ្រាតក្ដី ល្អិតក្ដី ថោកទាបក្ដី ឧត្ដមក្ដី ឬ រូបណា ឋិតនៅក្នុងទីឆ្ងាយក្ដី ទីជិតក្ដី រូបទាំងនុះ អ្នកត្រូវយល់ឃើញ តាមសេចក្ដីពិត ដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះថា នុះមិនមែនរបស់អញទេ នុះមិនមែនជាអញទេ នុះមិនមែនជាខ្លួនអញទេ ។ វេទនាណាមួយ ។

យា កាចិ សញ្ញា ។ យេ កេចិ សង្ខារា ។ យំ កិញ្ចិ វិញ្ញាណំ អតីតានាគតបច្ចុប្បន្នំ ។បេ។ យំ ទូរេ សន្តិកេ វា សព្វំ វិញ្ញាណំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ អយំ វុច្ចតិ ភិក្ខវេ អរិយសាវកោ អបចិនាតិ នោ អាចិនាតិ បជហាតិ ន ឧបាទិយតិ វិសិនេតិ[១] ន ឧស្សិនេតិ វិធូបេតិ ន សន្ធូបេតិ ។

[១៦៣] កិញ្ច អបចិនាតិ នោ អាចិនាតិ ។ រូបំ អបចិនាតិ នោ អាចិនាតិ ។ វេទនំ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ អបចិនាតិ នោ អាចិនាតិ ។ កិញ្ច បជហាតិ ន ឧបាទិយតិ ។ រូបំ បជហាតិ ន ឧបាទិយតិ ។ វេទនំ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ បជហាតិ ន ឧបាទិយតិ ។ កិញ្ច វិសិនេតិ ន ឧស្សិនេតិ ។ រូបំ វិសិនេតិ ន ឧស្សិនេតិ ។ កិញ្ច វិធូបេតិ ន សន្ធូបេតិ ។ រូបំ វិធូបេតិ ន សន្ធូបេតិ ។ វេទនំ ។ សញ្ញំ ។ សង្ខារេ ។

---

១ ឱ. វិសេនេតិ ។

សញ្ញាណានីមួយ ៗ សង្ខារទាំងឡាយ ណានីមួយ ៗ វិញ្ញាណណានីមួយ ជាអតីត អនាគត បច្ចុប្បន្ន ។បេ។ ឬវិញ្ញាណណា ឋិតនៅក្នុងទីឆ្ងាយក្តី ទីជិតក្តី វិញ្ញាណទាំងអស់នុ៎ះ ត្រូវអ្នកយល់ឃើញតាមសេចក្តីពិត ដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនរបស់អញទេ នុ៎ះមិនមែនជាអញទេ នុ៎ះមិនមែនជាខ្លួនអញទេ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាអរិយសាវ័ក ញុំាងវដ្តៈឲ្យវិនាស មិនសន្សំ (វដ្តៈ) លះបង់ មិនប្រកាន់ បាចសាចចោល មិនប្រមូល រំលត់ មិនបង្កាត់ឲ្យឆេះ ។

(១៦៣) ចុះអរិយសាវ័ក ធ្វើឲ្យវិនាស មិនសន្សំនូវអ្វី ។ អរិយសាវ័ក ធ្វើឲ្យវិនាស មិនសន្សំនូវរូប ។ នូវវេទនា ។ នូវសញ្ញា ។ នូវសង្ខារទាំងឡាយ ។ ធ្វើឲ្យវិនាស មិនសន្សំនូវវិញ្ញាណ ។ ចុះអរិយសាវ័ក លះបង់មិនប្រកាន់នូវអ្វី ។ អរិយសាវ័ក លះបង់ មិនប្រកាន់នូវរូប ។ នូវវេទនា ។ នូវសញ្ញា ។ នូវសង្ខារទាំងឡាយ ។ អរិយសាវ័ក លះបង់ មិនប្រកាន់នូវវិញ្ញាណ ។ ចុះអរិយសាវ័ក បាចសាចចោល មិនប្រមូលនូវអ្វី ។ អរិយសាវ័ក បាចសាចចោល មិនប្រមូលនូវរូប ។ ចុះអរិយសាវ័ក រំលត់ចោល មិនបង្កាត់នូវអ្វី ។ អរិយសាវ័ក រំលត់ចោល មិនបង្កាត់ឲ្យឆេះនូវរូប ។ នូវវេទនា ។ នូវសញ្ញា ។ នូវសង្ខារទាំងឡាយ ។

វិញ្ញាណំ វិធូបេតិ ន សន្ធូបេតិ ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ រូបស្មឹបិ និព្វិន្ទតិ ។ វេទនាយបិ ។ សញ្ញាយបិ ។ សង្ខារេសុបិ ។ វិញ្ញាណស្មឹបិ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ ។ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ។ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ នេវ អាចិនាតិ ន អបចិនាតិ អបចិនិត្វា ឋិតោ នេវ បជហតិ ន ឧបាទិយតិ បជហិត្វា ឋិតោ នេវ វិសិនេតិ ន ឧស្សេនេតិ វិសិនេត្វា ឋិតោ នេវ វិធូបេតិ ន សន្ធូបេតិ វិធូបេត្វា ឋិតោ ។

អរិយសាវ័ក រំលត់ពោល មិនបង្គាត់ឲ្យនេះនូវវិញ្ញាណ ។ ម្នាល ភិក្ខុទាំងឡាយ កាលបើអរិយសាវ័កអ្នកចេះដឹង បានឃើញយ៉ាងនេះ រមែងនឿយណាយ ក្នុងរូបផង ។ ក្នុងវេទនាផង ។ ក្នុងសញ្ញាផង ។ ក្នុងសង្ខារទាំងឡាយផង ។ នឿយណាយ ក្នុងវិញ្ញាណផង កាលបើនឿយណាយ រមែងប្រាសចាកតម្រេក ព្រោះតែប្រាសចាកតម្រេក ចិត្តរមែងរួចស្រឡះបាន ។ កាលបើចិត្តផុតស្រឡះហើយ ញាណក៏កើតឡើងថា ចិត្តរបស់អាត្មាអញរួចស្រឡះហើយ ។ អរិយសាវ័ក រមែងដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈអាត្មាអញនៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ នេះតថាគតពោលថា ភិក្ខុមិនសន្សំ មិនធ្វើឲ្យវិនាសទេ តែឈ្មោះថាអ្នកធ្វើឲ្យវិនាស ភិក្ខុមិនលះបង់ មិនប្រកាន់ទេ តែឈ្មោះថាអ្នកលះបង់ ភិក្ខុមិនបាចសាចពោល មិនប្រមូលទេ តែឈ្មោះថា អ្នកបាចសាចពោល ភិក្ខុមិនរំលត់ពោល មិនបង្គាត់ទេ តែឈ្មោះថា អ្នករំលត់ពោល ។

[១៦៤] កិញ្ច នេវ អាចិនាតិ ន អបចិនាតិ អបចិនិត្វា ឋិតោ ។ រូបំ នេវ អាចិនាតិ ន អបចិនាតិ អបចិនិត្វា ឋិតោ ។ វេទនំ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ នេវ អាចិនាតិ ន អបចិនាតិ អបចិនិត្វា ឋិតោ ។ កិញ្ច នេវ បជហាតិ ន ឧបាទិយតិ បជហិត្វា ឋិតោ ។ រូបំ នេវ បជហាតិ ន ឧបាទិយតិ បជហិត្វា ឋិតោ ។ វេទនំ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ នេវ បជហាតិ ន ឧបាទិយតិ បជហិត្វា ឋិតោ ។ កិញ្ច នេវ វិសិនេតិ ន ឧស្សិនេតិ វិសិនេត្វា ឋិតោ ។ រូបំ នេវ វិសិនេតិ ន ឧស្សិនេតិ វិសិនេត្វា ឋិតោ ។ វេទនំ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ នេវ វិសិនេតិ ន ឧស្សិនេតិ វិសិនេត្វា ឋិតោ ។ កិញ្ច នេវ វិធូបេតិ ន សន្ធូបេតិ វិធូបេត្វា ឋិតោ ។ រូបំ នេវ វិធូបេតិ ន សន្ធូបេតិ វិធូបេត្វា ឋិតោ ។ វេទនំ ។ សញ្ញំ ។

[១៦៨] ចុះភិក្ខុមិនសន្សំ មិនធ្វើឲ្យវិនាសនូវអ្វី ដែលឈ្មោះថាអ្នកធ្វើឲ្យវិនាស ។ ភិក្ខុមិនសន្សំ មិនធ្វើឲ្យវិនាសនូវរូប ឈ្មោះថាអ្នកធ្វើឲ្យវិនាស ។ ភិក្ខុមិនសន្សំ មិនធ្វើឲ្យវិនាស នូវវេទនា ។ នូវសញ្ញា ។ នូវសង្ខារទាំងឡាយ ។ នូវវិញ្ញាណ ឈ្មោះថាអ្នកធ្វើឲ្យវិនាស ។ ភិក្ខុមិនលះបង់ មិនប្រកាន់នូវអ្វី ដែលឈ្មោះថាអ្នកលះបង់ ។ ភិក្ខុមិនលះបង់ មិនប្រកាន់នូវរូប ឈ្មោះថាអ្នកលះបង់ ។ ភិក្ខុមិនលះបង់ មិនប្រកាន់នូវវេទនា ។ នូវសញ្ញា ។ នូវសង្ខារទាំងឡាយ ។ នូវវិញ្ញាណ ឈ្មោះថាអ្នកលះបង់ ។ ចុះភិក្ខុមិនបាចសាចចោល មិនប្រមូលនូវអ្វី ដែលឈ្មោះថាអ្នកបាចសាច ។ ភិក្ខុមិនបាចសាចចោល មិនប្រមូលនូវរូប ឈ្មោះថាអ្នកបាចសាច ។ ភិក្ខុមិនបាចសាចចោល មិនប្រមូលនូវវេទនា ។ នូវសញ្ញា ។ នូវសង្ខារទាំងឡាយ ។ នូវវិញ្ញាណ ឈ្មោះថាអ្នកបាចសាចចោល ។ ចុះភិក្ខុមិនរំលត់ មិនបង្កាត់នូវអ្វី ដែលឈ្មោះថាអ្នករំលត់ចោល ។ ភិក្ខុមិនរំលត់ មិនបង្កាត់នូវរូប ឈ្មោះថាអ្នករំលត់ចោល ។ ភិក្ខុមិនរំលត់មិនបង្កាត់នូវវេទនា ។ នូវសញ្ញា ។

សង្ខារេ ។ វិញ្ញាណំ នេវ វិធូបេតិ ន សន្ធូបេតិ វិធូបេត្វា ឋិតោ ។ ឯវំ វិមុត្តចិត្តំ ខោ ភិក្ខវេ ភិក្ខុំ សឥន្ទា ទេវា សព្រហ្មកា សបជាបតិកា អារកា វ នមស្សន្តិ

នមោ តេ បុរិសាជញ្ញ
នមោ តេ បុរិសុត្តម
យស្ស តេ នាភិជានាម
យម្បិ និស្សាយ ឈាយសីតិ ។

[១៦៨] ឯកំ សមយំ ភគវា សក្កេសុ វិហរតិ កបិលវត្ថុស្មឹ និគ្រោធារាមេ ។ អថខោ ភគវា កិស្មិញ្ចិ-ទេវ បករណេ ភិក្ខុសង្ឃំ បណាមេត្វា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ កបិលវត្ថុំ បិណ្ឌាយ បាវិសិ កបិលវត្ថុស្មឹ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្ប-ដិក្កន្តោ យេន មហាវនំ តេនុបសង្កមិ ទិវាវិហារាយ ម-ហាវនំ អជ្ឈោគាហេត្វា វេលុវលដ្ឋិកាយ មូលេ ទិវាវិហារំ និសីទិ ។ អថខោ ភគវតោ រហោគតស្ស បដិសល្លី-

នូវសង្ខារទាំងឡាយ ៗ នូវវិញ្ញាណ ឈ្មោះថាអ្នករំលត់ចោល ៗ ម្នាលភិក្ខុទាំងឡាយ ទេវតាទាំងឡាយ ព្រមទាំងឥន្ទ្រ ព្រមទាំងព្រហ្ម ព្រមទាំងបជាបតិទេវពជ តែងនមស្ការភិក្ខុ ដែលមានចិត្តរួចស្រឡះ យ៉ាងនេះ អំពីចម្ងាយថា

បពិត្របុរសអាជានេយ្យ យើងខ្ញុំ សូមក្រាបថ្វាយបង្គំលោក
បពិត្របុរសដ៏ឧត្តម យើងខ្ញុំ សូមក្រាបថ្វាយបង្គំលោក
លោកដុតបង់ (កិលេស) ព្រោះអាស្រ័យធម៌ណា ពួកយើង
មិនដឹង (ធម៌នោះ) របស់លោកទេ ៗ

[១៦៥] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងនិគ្រោធារាម ទៀបក្រុងកបិលព័ស្តុ ក្នុងដែនសក្កៈ ។ គ្រានោះឯង ព្រះមានព្រះភាគទ្រង់បណ្តេញភិក្ខុសង្ឃ ព្រោះតែហេតុណាមួយ ហើយប្រដាប់បាត្រនិងចីវរក្នុងបុព្វណ្ហសម័យ ទ្រង់ចូលទៅកាន់ក្រុងកបិលព័ស្តុ ដើម្បីបិណ្ឌបាត លុះត្រាច់ទៅដើម្បីបិណ្ឌបាត ក្នុងក្រុងកបិលព័ស្តុ ត្រឡប់អំពីបិណ្ឌបាត (បានធ្វើភត្តកិច្ចស្រេចហើយ) ជាខាងក្រោយនៃភត្ត ស្តេចចូលសំដៅទៅរកមហាវ័ន ដើម្បីសម្រាកក្នុងវេលាថ្ងៃ លុះចូលទៅកាន់មហាវ័នហើយ ក៏គង់សម្រាកក្នុងវេលាថ្ងៃ ទៀបគល់ព្នៅ ៗ លំដាប់នោះ ព្រះមានព្រះភាគ គង់នៅក្នុងទីស្ងាត់ ពួនសម្ងំនៅក្នុង

តស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ មយា ខោ ភិក្ខុសង្ឃោ បណាមេឡ្ហោ[១] សន្តេត្ថ ភិក្ខូ នវា អចិរបព្វជិតា អធុនាគតា ឥមំ ធម្មវិនយំ តេសំ មមំ អបស្សន្តានំ សិយា អញ្ញថត្តំ សិយា វិបរិណាមោ សេយ្យថាបិ នាម វច្ឆស្ស តរុណស្ស មាតរំ អបស្សន្តស្ស សិយា អញ្ញថត្តំ សិយា វិបរិណាមោ ឯវមេវ សន្តេត្ថ ភិក្ខូ នវា អចិរបព្វជិតា អធុនាគតា ឥមំ ធម្មវិនយំ តេសំ មមំ អបស្សន្តានំ សិយា អញ្ញថត្តំ សិយា វិបរិណាមោ សេយ្យថាបិ នាម ពីជានំ តរុណានំ ឧទកំ អលភន្តានំ សិយា អញ្ញថត្តំ សិយា វិបរិណាមោ ឯវមេវ សន្តេត្ថ ភិក្ខូ នវា អចិរបព្វជិតា អធុនាគតា ឥមំ ធម្មវិនយំ តេសំ មមំ អលភន្តានំ ទស្សនាយ សិយា អញ្ញថត្តំ សិយា វិបរិណាមោ យន្នូនាហំ យថេវ មយា បុព្វេ ភិក្ខុសង្ឃោ អនុគ្គហិតោ ឯវមេវ ឯតរហិ អនុគ្គណ្ហេយ្យំ ភិក្ខុសង្ឃន្តិ ។

១ បណាមេឡ្ហោតិ ច បាឋោ បណាមិតោតិ អត្ថោតិ អដ្ឋកថាយំ ទិស្សតិ ។

ផលសមាបត្តិ ក៏មានសេចក្តីត្រិះរិះ កើតឡើងក្នុងព្រះទ័យ យ៉ាងនេះថា ភិក្ខុសង្ឃដែលតថាគតបានបណ្តេញចោលហើយ ក្នុងទីនេះ មានពួកភិក្ខុថ្មី ដែលបួសមិនទាន់យូរប៉ុន្មាន ទើបនឹងមកកាន់ធម្មវិន័យនេះ កាលបើពួកភិក្ខុនោះ មិនឃើញតថាគត មុខជានឹងមានចិត្តរាយមាយ មានចិត្តប្រែប្រួលផ្សេងៗ ដូចជាកូនគោតូច កាលបើមិនឃើញមេវា មុខជានឹងមានចិត្តរាយមាយ មានចិត្តប្រែប្រួលទៅផ្សេងៗ យ៉ាងណាមិញ ក្នុងទីនេះ មានពួកភិក្ខុថ្មី ដែលបួសមិនទាន់យូរប៉ុន្មាន ទើបនឹងមកកាន់ធម្មវិន័យនេះ កាលបើភិក្ខុទាំងនោះ មិនឃើញតថាគត មុខជានឹងមានចិត្តរាយមាយ មានចិត្តប្រែប្រួលទៅផ្សេងៗ ក៏យ៉ាងនោះដែរ មួយទៀត ដូចពូជថ្មី កាលបើមិនមានទឹក រមែងកក្រាយ ខ្វាត់ខ្វាយទៅផ្សេងៗ យ៉ាងណាមិញ ក្នុងទីនេះ មានពួកភិក្ខុថ្មី ដែលបួសមិនទាន់យូរប៉ុន្មាន ទើបនឹងមកកាន់ធម្មវិន័យនេះ កាលបើពួកភិក្ខុទាំងនោះមិនបានឃើញតថាគត រមែងមានចិត្តរាយមារាយ ប្រែប្រួលទៅផ្សេងៗ ក៏យ៉ាងនោះដែរ បើដូច្នោះ គួរតថាគត អនុគ្រោះភិក្ខុសង្ឃ ក្នុងកាលឥឡូវនេះ តាមចំនង ដែលតថាគត អនុគ្រោះភិក្ខុសង្ឃ ក្នុងកាលមុនមកហើយ ។

[១៦៦] អថខោ ព្រហ្មា សហម្បតិ ភគវតោ ចេតសា ចេតោបរិវិតក្កមញ្ញាយ សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ ព្រហ្មលោកេ អន្តរហិតោ ភគវតោ បុរតោ បាតុរហោសិ ។ អថខោ ព្រហ្មា សហម្បតិ ឯកំសំ ឧត្តរាសង្គំ ករិត្វា យេន ភគវា តេនញ្ជលិំ បណាមេត្វា ភគវន្តំ ឯតទវោច ឯវមេតំ ភគវា ឯវមេតំ សុគត ភគវតា ភន្តេ ភិក្ខុសង្ឃោ បណាមិតោ សន្តេត្ថ ភិក្ខូ នវា អចិរបព្វជិតា អធុនាគតា ឥមំ ធម្មវិនយំ តេសំ ភគវន្តំ អបស្សន្តានំ សិយា អញ្ញថត្តំ សិយា វិបរិណាមោ សេយ្យថាបិ នាម វច្ឆស្ស តរុណស្ស មាតរំ អបស្សន្តស្ស សិយា អញ្ញថត្តំ សិយា វិបរិណាមោ ឯវមេវ សន្តេត្ថ ភិក្ខូ នវា អចិរបព្វជិតា អធុនាគតា ឥមំ ធម្មវិនយំ តេសំ ភគវន្តំ អបស្សន្តានំ សិយា

[១៦៦] គ្រានោះឯង សហម្បតិព្រហ្មដឹងនូវសេចក្តីត្រិះរិះ ក្នុងព្រះទ័យតាមព្រះទ័យ របស់ព្រះមានព្រះភាគហើយ ក៏បាត់អំពីព្រហ្មលោក មកប្រាកដក្នុងទីចំពោះព្រះភក្ត្រ នៃព្រះមានព្រះភាគ ដូចជាបុរសមានកម្លាំងលាដៃដែលខ្វិនបត់ ឬបត់ដៃដែលខ្វិនលាដូច្នោះឯង ៗ លំដាប់នោះឯង សហម្បតិព្រហ្ម ធ្វើសំពត់ឧត្តរាសង្គៈឆៀងស្មាម្ខាង ប្រណម្យអញ្ជលី ចំពោះព្រះមានព្រះភាគ ក្រាបទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ដំណើរនុ៎ះយ៉ាងនេះមែនហើយ បពិត្រព្រះសុគត ដំណើរនុ៎ះយ៉ាងនេះមែនហើយ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុសង្ឃដែលព្រះមានព្រះភាគ បណ្តេញចោលហើយ (ព្រោះ) ក្នុងទីនេះ មានពួកភិក្ខុថ្មី ដែលបួសមិនទាន់យូរប៉ុន្មាន ទើបនឹងមកកាន់ធម្មវិន័យនេះ កាលបើពួកភិក្ខុនោះ មិនឃើញព្រះមានព្រះភាគ រមែងមានចិត្តកាយមាយ មានចិត្តប្រែប្រួលទៅផ្សេង ៗ ដូចជាកូនគោតូច កាលបើមិនឃើញមេវា រមែងមានចិត្តកាយមាយ ប្រែប្រួលទៅផ្សេង ៗ យ៉ាងណាមិញ ក្នុងទីនេះ មានពួកភិក្ខុថ្មី ដែលបួសមិនទាន់យូរប៉ុន្មាន ទើបនឹងមកកាន់ធម្មវិន័យនេះ កាលបើពួកភិក្ខុទាំងនោះ មិនបានឃើញព្រះមានព្រះភាគ

អញ្ញថត្តំ សិយា វិបរិណាមោ សេយ្យថាបិ នាម ពីជានិ តរុណានិ ឧទកំ អលភន្តានិ សិយា អញ្ញថត្តំ សិយា វិបរិណាមោ ឯវមេវ សចេត្ថ ភិក្ខូ នវា អចិរបព្វជិតា អធុនាគតា ឥមំ ធម្មវិនយំ តេសំ ភគវន្តំ អលភន្តានំ ទស្សនាយ សិយា អញ្ញថត្តំ សិយា វិបរិណាមោ អភិនន្ទតុ ភន្តេ ភគវា ភិក្ខុសង្ឃំ អភិវទតុ ភន្តេ ភគវា ភិក្ខុសង្ឃំ យថេវ ភគវតា បុព្វេ ភិក្ខុសង្ឃោ អនុគ្គហិតោ ឯវមេវ ឯតរហិ អនុគ្គណ្ហាតុ ភិក្ខុសង្ឃន្តិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។ អថខោ ព្រហ្មា សហម្បតិ ភគវតោ អធិវាសនំ វិទិត្វា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវន្តរធាយិ ។

មុខជានឹងមានចិត្តរាយមាយ មានចិត្តប្រែប្រួលទៅផ្សេង ៗ យ៉ាងនោះដែរ មួយទៀត ដូចពូជខ្ចី កាលមិនបានទឹក មុខជារាត់រាយ ខ្ចាត់ខ្ចាយទៅផ្សេង ៗ យ៉ាងណា ក្នុងទីនេះ មានពួកភិក្ខុ ដែលបួសមិនទាន់យូរប៉ុន្មាន ទើបនឹងមកកាន់ធម្មវិន័យនេះ កាលបើពួកភិក្ខុទាំងនោះ មិនបានឃើញព្រះមានព្រះភាគ មុខជាមានចិត្តរាយមាយ ប្រែប្រួលទៅផ្សេង ៗ ក៏យ៉ាងនោះដែរ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគត្រេកអរនឹងភិក្ខុសង្ឃ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ រួសរាយនឹងភិក្ខុសង្ឃ ព្រះមានព្រះភាគ អនុគ្រោះភិក្ខុសង្ឃក្នុងកាលមុន យ៉ាងណា សូមព្រះមានព្រះភាគ អនុគ្រោះភិក្ខុសង្ឃ ក្នុងកាលឥឡូវនេះ យ៉ាងនោះឲ្យបាន ៗ ព្រះមានព្រះភាគ ទ្រង់ទទួលនិមន្តដោយតុណ្ហីភាព ៗ គ្រានោះ សហម្បតិព្រហ្ម ដឹងច្បាស់នូវការទទួលនិមន្តរបស់ព្រះមានព្រះភាគហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយ ក៏បាត់ក្នុងទីនោះទៅ ៗ

[១៦៧] អថ ខោ ភគវា សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេន និគ្រោធារាមោ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ ខោ ភគវា តថារូបំ ឥទ្ធាភិសង្ខារំ អភិសង្ខាសិ(១) យថា តេ ភិក្ខូ ឯកទ្វីហិកាយ សារជ្ជមានរូបា(២) យេន(៣) ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នេ ខោ តេ ភិក្ខូ ភគវា ឯតទវោច អន្តមិទំ ភិក្ខវេ ជីវិកានំ យទិទំ បិណ្ឌោល្យំ ។ អភិសាបោយំ(៤) ភិក្ខវេ លោកស្មឹ បិណ្ឌោលោ វិចរសិ បត្តបាណីតិ ។ តញ្ច ខោ ឯតំ(៥) ភិក្ខវេ កុលបុត្តា ឧបេន្តិ អត្ថវសិកា អត្ថវសំ បដិច្ច នេវ រាជាភិនីតា ន ចោរាភិនីតា ន ឥណដ្ដា ន ភយដ្ដា ន អាជីវិកាបកតា អបិច ខោ ឱតិណ្ណាម្ហ ជាតិយា ជរាយ មរណេន សោកេហិ

---

១ ឱ. អភិសង្ខាយិ ។ ម. អភិសង្ខរោសិ ។ ២ ឱ. សារជ្ជាយ មានរូបា ។ ៣ ឱ. យេនាហំ តេនុបសង្កមេយ្យុំ ។ តេ ភិក្ខូ ឯកទ្វីហិកាយ សារជ្ជាយ មានរូបាតិ បាឋោ ទិស្សន្តិ ។ ៤ កត្ថចិ អភិសាបាយន្តិ វា អភិសាបេយ្យន្តិ វា បាឋោ ។ ៥ ឱ. ម. ឯវំ ។

[១៦៧] គ្រានោះ ព្រះមានព្រះភាគ ទ្រង់ចេញអំពីទីសម្ងំក្នុងសាយណ្ហសម័យ ចូលទៅឯនិគ្រោធារាម លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈ ដែលគេក្រាលថ្វាយ ។ លុះព្រះមានព្រះភាគ គង់ហើយ ក៏គាក់តែងនូវឥទ្ធាភិសង្ខារមានសភាពដូច្នោះ ទើបពួកភិក្ខុទាំងនោះភិតភ័យ ចូលមករកព្រះមានព្រះភាគ មួយរូបម្តង ពីររូបម្តង លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុទាំងនោះអង្គុយ ក្នុងទីដ៏សមគួរហើយ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ការត្រាច់ទៅរកដុំបាយ ដើម្បីចិញ្ចឹមជីវិតនេះ ជាការថោកទាបបំផុត ជាងការចិញ្ចឹមជីវិតទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ការត្រាច់ទៅរកដុំបាយ (ដើម្បីចិញ្ចឹមជីវិត) នេះ គេតែងផ្តាសា ក្នុងលោកថា លោកជាអ្នកមានបាត្រក្នុងដៃត្រាច់ទៅ (បិណ្ឌបាត) ។ ម្នាលភិក្ខុទាំងឡាយ ពួកកុលបុត្ត ដែលប្រកបដោយកម្លាំងប្រយោជន៍ អាស្រ័យនូវកម្លាំងប្រយោជន៍ ជាអ្នកដែលស្តេចមិនរឹបជាន់ ចោរមិនរឹបជាន់ មិនបំពាក់បំណុល មិនប្រកបដោយភ័យ មិនលុះក្នុងការចិញ្ចឹមជីវិត រមែងចូលចិត្តនឹងការត្រាច់ទៅ ដើម្បីដុំបាយនោះឯង ដោយគិតថា ពួកយើងជាអ្នកធ្លាក់ចុះ (ក្នុងអំណាច) នៃជាតិ ជរា មរណៈ សេចក្តីសោក

បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ ទុក្ខោតិណ្ណា ទុក្ខបរេតា អប្បេវនាម ឥមស្ស កេវលស្ស ទុក្ខក្ខន្ធស្ស អន្តកិរិយា បញ្ញាយេថាតិ ។ ឯវំ បព្វជិតោ ចាយំ ភិក្ខវេ កុលបុត្តោ សោ ច ហោតិ អភិជ្ឈាលុ កាមេសុ តិព្វសារាគោ ព្យាបន្នចិត្តោ បទុដ្ឋមនសង្កប្បោ មុដ្ឋស្សតី អសម្បជានោ អសមាហិតោ វិព្ភន្តចិត្តោ បាកតិន្ទ្រិយោ ។ សេយ្យថាបិ ភិក្ខវេ ឆវាលាតំ ឧភតោ បទិត្តំ មជ្ឈេ គូថគតំ នេវ គាមេ កដ្ឋត្ថំ ផរតិ នារញ្ញេ កដ្ឋត្ថំ ផរតិ ។ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ គិហិភោគា ច បរិហីនោ សាមញ្ញត្ថំ ច ន បរិបូរេតិ ។

សេចក្តីខ្សឹកខ្សួល ទុក្ខ ទោមនស្ស ឧបាយាស ធ្លាក់ចុះកន្លះសេចក្តីទុក្ខ ត្រូវទុកបៀតបៀន ដូចម្តេចហ្ន៎ នឹងធ្វើឲ្យដល់ទីបំផុតនៃកងទុក្ខទាំងអស់នេះ ឲ្យប្រាកដបាន ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្តនេះ ដែលបួសយ៉ាងនេះហើយ ក៏កុលបុត្តនោះ ជាអ្នកច្រើនដោយអភិជ្ឈា មានតម្រេកដ៏ក្លៀវក្លា ក្នុងកាមទាំងឡាយ មានចិត្តព្យាបាទ មានសេចក្តីត្រិះរិះក្នុងចិត្តដ៏អាក្រក់ ភ្លេចស្មារតី មិនមានសម្បជញ្ញៈ មានចិត្តមិននឹងធឹង មានចិត្តរវើរវាយ មានឥន្ទ្រិយនៅជាប្រក្រតី ។ ម្នាលភិក្ខុទាំងឡាយ ដូចអង្កត់ខុសដែលគេដុតខ្មោចស្រស់ ភ្លើងឆេះទាំងសងខាង ត្រង់កណ្តាលប្រឡាក់ដោយគូថ (អាចម៍) មិនផ្សាយទៅដើម្បីជាខុសក្នុងស្រុក មិនផ្សាយទៅដើម្បីជាខុសក្នុងព្រៃឡើយ មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ តថាគតហៅបុគ្គលនេះ ថាជាអ្នកសាបសូន្យចាកភោគៈរបស់គ្រហស្ថផង មិនបំពេញប្រយោជន៍របស់សមណៈផង មានឧបមេយ្យដូចយ៉ាងអង្កត់ខុស ដូច្នោះឯង ។

(១៦៨) តយោមេ ភិក្ខវេ អកុសលវិតក្កា កាមវិតក្កោ ព្យាបាទវិតក្កោ វិហឹសាវិតក្កោ ។ ឥមេ ច ខោ ភិក្ខវេ តយោ អកុសលវិតក្កា តំ(១)អបរិសេសា និរុជ្ឈន្តិ ចតូសុ វា សតិបដ្ឋានេសុ សុប្បតិដ្ឋិតចិត្តស្ស វិហរតោ អនិមិត្តំ វា សមាធិំ ភាវយតោ ។ យាវញ្ចិទំ ភិក្ខវេ អលមេវ អនិមិត្តោ សមាធិ ភាវេតុំ ។ អនិមិត្តោ ភិក្ខវេ សមាធិ ភាវិតោ ពហុលីកតោ មហប្ផលោ ហោតិ មហានិសំសោ ។

(១៦៩) ទ្វេមា ភិក្ខវេ ទិដ្ឋិយោ ភវទិដ្ឋិ ច វិភវទិដ្ឋិ ច ។ តត្រ ភិក្ខវេ សុតវា អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ អត្ថិ នុ ខោ តំ កិញ្ចិ លោកស្មឹ យមហំ ឧបាទិយមានោ ន វជ្ជវា អស្សន្តិ ។ សោ ឯវំ បជានាតិ នត្ថិ នុ ខោ តំ កិញ្ចិ លោកស្មឹ យមហំ ឧបាទិយមានោ ន វជ្ជវា អស្សន្តិ ។ សោ ឯវំ បជានាតិ អហញ្ចេ រូបញ្ញេវ ឧបាទិយមានោ ឧបាទិយេយ្យំ វេទនញ្ញេវ ឧបាទិយមានោ ឧបាទិយេយ្យំ

១ ឱ. ម. ក្វ អបរិសេសា ។

(១៦៨) ម្នាលភិក្ខុទាំងឡាយ អកុសលវិតក្កៈនេះ មាន ៣ យ៉ាង គឺ កាមវិតក្កៈ១ ព្យាបាទវិតក្កៈ១ វិហឹសាវិតក្កៈ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានចិត្តតាំងស៊ប់ក្នុងសតិប្បដ្ឋានទាំង ៤ ឬចម្រើននូវអនិមិត្តសមាធិ អកុសលវិតក្កៈទាំង ៣ យ៉ាងនេះ រមែងរលត់ទៅឥតមានសេសសល់ឡើយ ។ ម្នាលភិក្ខុទាំងឡាយ អនិមិត្តសមាធិនេះ បុគ្គលគួរចម្រើនឲ្យច្រើនក្រៃលែង ។ ម្នាលភិក្ខុទាំងឡាយ (ព្រោះថា) អនិមិត្តសមាធិ ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ។

(១៦៩) ម្នាលភិក្ខុទាំងឡាយ ទិដ្ឋិនេះមានពីរប្រការ គឺភវទិដ្ឋិ១ វិភវទិដ្ឋិ១ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងទិដ្ឋិទាំងពីរនោះ អរិយសាវ័កអ្នកចេះដឹង រមែងពិចារណាដូច្នេះថា កាលបើអាត្មាអញប្រកាន់របស់ណាដែលមិនមានទោស របស់នោះគង់មានតិចតួចខ្លះក្នុងលោក ដែរឬ ។ អរិយសាវ័កនោះ រមែងដឹងយ៉ាងនេះថា កាលបើអាត្មាអញប្រកាន់របស់ណា ដែលមិនមានទោស របស់នោះ រមែងមិនមានតិចតួច ក្នុងលោកទេ ។ អរិយសាវ័កនោះ ដឹងច្បាស់យ៉ាងនេះថា កាលបើអាត្មាអញប្រកាន់ ទឹងប្រកាន់រូប កាលបើប្រកាន់ ទឹងប្រកាន់វេទនា

សញ្ញាញ្ញេវ ឧបាទិយមានោ ឧបាទិយេយ្យំ សង្ខារេយេវ ឧបាទិយមានោ ឧបាទិយេយ្យំ វិញ្ញាណញ្ញេវ ឧបាទិយមានោ ឧបាទិយេយ្យំ តស្ស មេ អស្ស ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវេយ្យុំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ អស្ស ។ តំ កឹ មញ្ញថ ភិក្ខវេ រូបំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ វេទនា ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ និច្ចំ ។បេ។ តស្មាតិហ ភិក្ខវេ ។បេ។ ឯវំ បស្សំ ។បេ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

កាលបើប្រកាន់ នឹងប្រកាន់សញ្ញា កាលបើប្រកាន់ នឹងប្រកាន់សង្ខារទាំងឡាយ កាលបើប្រកាន់ នឹងប្រកាន់វិញ្ញាណ ភពរបស់អាត្មាអញនោះនឹងកើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិកើតមាន ព្រោះភពជាបច្ច័យ ជរា មរណៈ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត កើតមាន ព្រោះជាតិជាបច្ច័យ ហេតុដែលឲ្យកើតកងទុក្ខទាំងអស់នុ៎ះ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់នូវសេចក្តីនោះដូចម្តេច រូបទៀងឬមិនទៀង ។ បពិត្រព្រះអង្គដ៏ចម្រើន មិនទៀងទេ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ បពិត្រព្រះអង្គដ៏ចម្រើន របស់នោះជាទុក្ខ ។ ចុះរបស់ណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរយល់ឃើញរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អាត្មាអញ ដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនគួរយល់ឃើញដូច្នោះទេ ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណទៀងឬ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងសាសនានេះ ។ បេ ។ កាលបើឃើញយ៉ាងនេះ ។ បេ ។ ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

(១៧០) ឯកំ សមយំ ភគវា កោសម្ពិយំ វិហរតិ ឃោសិតារាមេ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ កោសម្ពឹ បិណ្ឌាយ បាវិសិ កោសម្ពិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ សាមំ សេនាសនំ សំសាមេត្វា បត្តចីវរមាទាយ អនាមន្តេត្វា ឧបដ្ឋាកេ អនបលោកេត្វា ភិក្ខុសង្ឃំ ឯកោ អទុតិយោ ចារិកំ បក្កាមិ ។

(១៧១) អថខោ អញ្ញតរោ ភិក្ខុ អចិរបក្កន្តស្ស ភគវតោ យេនាយស្មា អានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ ឯតទវោច ឯសោវុសោ អានន្ទ ភគវា សាមំ សេនាសនំ សំសាមេត្វា បត្តចីវរមាទាយ អនាមន្តេត្វា ឧបដ្ឋាកេ អនបលោកេត្វា ភិក្ខុសង្ឃំ ឯកោ អទុតិយោ ចារិកំ បក្កន្តោតិ ។ យស្មឹ អាវុសោ សមយេ ភគវា សាមំ សេនាសនំ សំសាមេត្វា បត្តចីវរមាទាយ អនាមន្តេត្វា ឧបដ្ឋាកេ អនបលោកេត្វា ភិក្ខុសង្ឃំ ឯកោ

[ ១៧០ ] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងឃោសិតារាម ទៀបក្រុងកោសម្ពី ។ គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ស្បង់ ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ទ្រង់ចូលទៅកាន់ក្រុងកោសម្ពី ដើម្បីបិណ្ឌបាត លុះត្រាច់ទៅបិណ្ឌបាតក្នុងក្រុងកោសម្ពីហើយ ត្រឡប់មកពីបិណ្ឌបាត (ធ្វើភត្តកិច្ចស្រេចហើយ) ក្នុងពេលជាខាងក្រោយភត្ត ទ្រង់រៀបចំទុកដាក់សេនាសនៈដោយព្រះអង្គឯង ប្រដាប់បាត្រនិងចីវរ មិនបានប្រាប់ពួកឧបដ្ឋាក មិនបានលាភិក្ខុសង្ឃ តែមួយព្រះអង្គឯង ឥតមានបុគ្គលជាគម្រប់ពីរ ចៀសចេញទៅកាន់ចារិក ។

[ ១៧១ ] គ្រានោះឯង ភិក្ខុមួយរូប កាលព្រះមានព្រះភាគចៀសចេញទៅមិនយូរប៉ុន្មាន ក៏ចូលទៅរកព្រះអានន្ទមានអាយុ លុះចូលទៅដល់ហើយ និយាយនឹងព្រះអានន្ទមានអាយុ យ៉ាងនេះថា ម្នាលអាវុសោអានន្ទ បរអែកមកអាយ ព្រះមានព្រះភាគ រៀបចំទុកដាក់សេនាសនៈដោយព្រះអង្គឯង ប្រដាប់បាត្រនិងចីវរ មិនបានប្រាប់ពួកឧបដ្ឋាក មិនបានលាភិក្ខុសង្ឃ តែមួយព្រះអង្គឯង ឥតមានបុគ្គលជាគម្រប់ពីរ ស្តេចទៅកាន់ចារិកហើយ ។ ម្នាលអាវុសោ ព្រះមានព្រះភាគរៀបចំទុកដាក់សេនាសនៈ ដោយព្រះអង្គឯង ប្រដាប់បាត្រនិងចីវរ មិនបានប្រាប់ពួកឧបដ្ឋាក មិនបានលាភិក្ខុសង្ឃ តែមួយព្រះអង្គ

អទុតិយោ ចារិកំ បក្កមតិ ឯកោវ ភគវា តស្មឹ សមយេ វិហរិតុកាមោ ហោតិ ន ភគវា តស្មឹ សមយេ កេនចិ អនុពន្ធិតព្វោ ហោតីតិ ។

[១៧២] អថខោ ភគវា អនុបុព្វេន ចារិកំ ចរមានោ យេន បាលិលេយ្យកំ(1) តទវសរិ ។ តត្រ សុទំ ភគវា បាលិលេយ្យកេ វិហរតិ ភទ្ទសាលមូលេ ។ អថខោ សម្ពហុលា ភិក្ខូ យេនាយស្មា អានន្ទោ តេនុបសង្កមឹសុ ឧបសង្កមិត្វា អាយស្មតា អានន្ទេន សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ អាយស្មន្តំ អានន្ទំ ឯតទវោចុំ ចិរស្សុតា(2) ខោ នោ អាវុសោ អានន្ទ ភគវតោ សម្មុខា ធម្មីកថា ឥច្ឆាម មយំ អាវុសោ អានន្ទ ភគវតោ សម្មុខា ធម្មឹ កថំ សោតុន្តិ ។ អថខោ អាយស្មា អានន្ទោ តេហិ ភិក្ខូហិ សទ្ធឹ យេន បាលិលេយ្យកំ ភទ្ទសាលមូលំ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា

១ បារិលេយ្យកន្តិបិ ។ ២ ឱ. ម. ចិរស្សំ សុតា ខោ ។

ឥតមានបុគ្គលជាគម្រប់ពីរ ស្តេចទៅកាន់ចារិក ក្នុងសម័យណា ព្រះមានព្រះភាគ ចង់នៅតែមួយព្រះអង្គឯង ក្នុងសម័យនោះ ព្រះមានព្រះភាគ មិនឲ្យបុគ្គលណាមួយទៅតាមព្រះអង្គ ក្នុងសម័យនោះ ។

[១៧២] គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ស្តេចទៅកាន់ចារិកតាមលំដាប់ បានដល់ទៅក្រុងបាលិលេយ្យកៈ ។ ក្នុងទីនោះឯង បានឮថា ព្រះមានព្រះភាគ ទ្រង់គង់នៅក្បែរគល់សាលព្រឹក្សដ៏ប្រសើរ ជិតក្រុងបាលិលេយ្យកៈ ។ គ្រានោះឯង ពួកភិក្ខុមានប្រមាណច្រើនរូប បានចូលទៅរកព្រះអានន្ទ មានអាយុ លុះចូលទៅដល់ហើយ ក៏ពក់ទាក់ទៅរកព្រះអានន្ទ មានអាយុ លុះបញ្ចប់ពាក្យគួរពក់ទាក់ និងពាក្យគួររឭកហើយ ទើបអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ ក៏និយាយនឹងព្រះអានន្ទ មានអាយុ យ៉ាងនេះថា ម្នាលអាវុសោអានន្ទ ពួកយើងបានស្តាប់ធម្មីកថា ក្នុងទីចំពោះព្រះភក្ត្រព្រះមានព្រះភាគយូរហើយ ម្នាលអាវុសោអានន្ទ ឥឡូវនេះ យើងចង់ស្តាប់ធម្មីកថា ក្នុងទីចំពោះព្រះភក្ត្រព្រះមានព្រះភាគ ។ ទើបព្រះអានន្ទមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ ទៀបគល់សាលព្រឹក្សដ៏ប្រសើរ ជិតក្រុងបាលិលេយ្យកៈ ជាមួយនឹងភិក្ខុទាំងនោះ លុះចូលទៅដល់ហើយ

ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និ-
សិន្នេ ខោ តេ ភិក្ខូ ភគវា ធម្មិយា កថាយ សន្ទស្សេ-
សិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។

[១៧៣] តេន ខោ បន សមយេន អញ្ញតរស្ស
ភិក្ខុនោ ឯវញ្ចេតសោ បរិវិតក្កោ ឧទបាទិ កថំ នុ
ខោ ជានតោ កថំ បស្សតោ អនន្តរា អាសវានំ
ខយោ ហោតីតិ ។ អថ ខោ ភគវា តស្ស ភិក្ខុនោ
ចេតសា ចេតោបរិវិតក្កមញ្ញាយ ភិក្ខូ អាមន្តេ
សិ វិចយសោ ទេសិតោ ភិក្ខវេ មយា ធម្មោ
វិចយសោ ទេសិតា ចត្តារោ សតិបដ្ឋានា វិចយ-
សោ ទេសិតា សម្មប្បធានា វិចយសោ ទេសិតា

ទើបក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះពួកភិក្ខុនោះ អង្គុយក្នុងទីដ៏សមគួរហើយ ទើបព្រះមានព្រះភាគទ្រង់ពន្យល់ណែនាំ (ភិក្ខុទាំងនោះ) ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា ។

[១៧៣] សម័យនោះឯង ភិក្ខុមួយរូប មានសេចក្តីត្រិះរិះកើតឡើងក្នុងចិត្ត យ៉ាងនេះថា កាលបុគ្គលដឹងដូចម្តេចហ្ន៎ ឃើញដូចម្តេចហ្ន៎ ទើបអស់ទៅនៃអាសវៈទាំងឡាយ ជាលំដាប់ ។ គ្រានោះឯង ព្រះមានព្រះភាគ ជ្រាបច្បាស់នូវបរិវិតក្កៈក្នុងចិត្ត តាមចិត្តរបស់ភិក្ខុនោះហើយ ទើបត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ធម៌តថាគតសម្តែងហើយដោយការពិចារណា សតិប្បដ្ឋាន ៤ តថាគតសម្តែងហើយដោយការពិចារណា សម្មប្បធាន ៤ តថាគតសម្តែងហើយដោយ

ចត្តារោ ឥទ្ធិបាទា វិចយសោ ទេសិតានិ បញ្ចិន្ទ្រិយានិ វិចយសោ ទេសិតានិ បញ្ច ពលានិ វិចយសោ ទេសិតា សត្ត ពោជ្ឈង្គា វិចយសោ ទេសិតោ អរិយោ អដ្ឋង្គិកោ មគ្គោ ។ ឯវំ វិចយសោ ទេសិតោ ភិក្ខវេ មយា ធម្មោ ឯវំ វិចយសោ ទេសិតោ ខោ ភិក្ខវេ មយា ធម្មោ ។ អថ ច បនិធេកច្ចស្ស ភិក្ខុនោ ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ កថំ នុ ខោ ជានតោ កថំ បស្សតោ អនន្តរា អាសវានំ ខយោ ហោតីតិ ។

(១៧៤) កថញ្ច ភិក្ខវេ ជានតោ កថំ បស្សតោ អនន្តរា អាសវានំ ខយោ ហោតិ ។ ឥធ ភិក្ខវេ អស្សុតវា បុថុជ្ជនោ អរិយានំ អទស្សាវី អរិយធម្មស្ស អកោវិទោ អរិយធម្មេ អវិនីតោ សប្បុរិសានំ អទស្សាវី ។ បេ ។ សប្បុរិសធម្មេ អវិនីតោ រូបំ អត្តតោ សមនុបស្សតិ ។ យា ខោ បន សា ភិក្ខវេ សមនុបស្សនា សង្ខារោ សោ ។ សោ បន សង្ខារោ កឹនិទានោ

ការពិចារណា ឥទ្ធិបាទ ៤ តថាគតសម្តែងហើយ ដោយការពិចារណា ឥន្ទ្រិយ ៥ តថាគតសម្តែងហើយ ដោយការពិចារណា ពលៈ៥ តថាគតសម្តែងហើយ ដោយការពិចារណា ពោជ្ឈង្គ ៧ តថាគតសម្តែងហើយ ដោយការពិចារណា មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ តថាគតសម្តែងហើយដោយការពិចារណា ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលតថាគតសម្តែងហើយ ដោយការពិចារណា យ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលតថាគតសម្តែងហើយ ដោយការពិចារណា យ៉ាងនេះ ។ ម្យ៉ាងទៀត ភិក្ខុខ្លះក្នុងសាសនានេះ មានសេចក្តីត្រិះរិះកើតឡើង ដោយចិត្តយ៉ាងនេះថា កាលបុគ្គលដឹងដូចម្តេច ឃើញដូចម្តេច ទើបអស់ទៅនៃអាសវៈទាំងឡាយជាលំដាប់ ។

(១៧៤) ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលដឹងដូចម្តេច ឃើញដូចម្តេច ទើបអស់ទៅនៃអាសវៈទាំងឡាយជាលំដាប់ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងលោកនេះ បុថុជ្ជនអ្នកមិនចេះដឹង មិនបានឃើញពួកព្រះអរិយៈ មិនឈ្លាសវៃក្នុងធម៌ព្រះអរិយៈ មិនបានហាត់ក្នុងធម៌ព្រះអរិយៈ មិនបានឃើញពួកសប្បុរស ។ បេ ។ មិនបានហាត់ក្នុងធម៌របស់សប្បុរស រមែងពិចារណាឃើញរូប ថាជាខ្លួន ។ ម្នាលភិក្ខុទាំងឡាយ ការពិចារណាឃើញនោះ ឈ្មោះថាសង្ខារ ។ ចុះសង្ខារនោះ មានអ្វីជាហេតុ

កឹសមុទយោ កឹជាតិកោ កឹបភវោ ។ អវិជ្ជាសម្ផស្សជេន ភិក្ខវេ វេទយិតេន ផុដ្ឋស្ស អស្សុតវតោ បុថុជ្ជនស្ស ឧប្បន្នា តណ្ហា តតោជោ សោ សង្ខារោ ។ ឥតិ ខោ ភិក្ខវេ សោបិ សង្ខារោ អនិច្ចោ សង្ខតោ បដិច្ចសមុប្បន្នោ សាបិ តណ្ហា អនិច្ចា សង្ខតា បដិច្ចសមុប្បន្នា សាបិ វេទនា ។ សោបិ ផស្សោ ។ សាបិ អវិជ្ជា អនិច្ចា សង្ខតា បដិច្ចសមុប្បន្នា ។ ឯវំបិ ខោ ភិក្ខវេ ជានតោ ឯវំ បស្សតោ អនន្តរា អាសវានំ ខយោ ហោតិ ។

(១៧៥) ន ហេវ ខោ រូបំ អត្តតោ សមនុបស្សតិ អបិច ខោ រូបវន្តំ អត្តានំ សមនុបស្សតិ ។ យា ខោ បន សា ភិក្ខវេ សមនុបស្សនា សង្ខារោ សោ ។ សោ បន សង្ខារោ កឹនិទានោ កឹសមុទយោ

មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត ។ ម្នាលភិក្ខុទាំងឡាយ តណ្ហាកើតឡើងដល់បុថុជ្ជនអ្នកមិនចេះដឹង ដែលត្រូវវេទនាកើតអំពីសម្ផស្សនៃអវិជ្ជាប៉ះពាល់ សង្ខារនោះកើតអំពីតណ្ហានោះ ។ ម្នាលភិក្ខុទាំងឡាយ សង្ខារនោះក៏មិនទៀង មានបច្ច័យតាក់តែងកើតឡើងហើយ ព្រោះអាស្រ័យហេតុ តណ្ហានោះសោតក៏មិនទៀង មានបច្ច័យតាក់តែងកើតឡើងហើយ ព្រោះអាស្រ័យហេតុ វេទនានោះក៏ (មិនទៀង) ដូចពោលមកយ៉ាងនេះ ។ ផស្សៈនោះក៏ដូច្នោះដែរ ។ អវិជ្ជានោះក៏មិនទៀង មានបច្ច័យតាក់តែងកើតឡើងហើយ ព្រោះអាស្រ័យហេតុ ។ ម្នាលភិក្ខុទាំងឡាយ កាលបុគ្គលដឹងយ៉ាងនេះ ឃើញយ៉ាងនេះ រមែងអស់ទៅនៃអាសវៈទាំងឡាយជាលំដាប់ ។

[១៧៩] បុគ្គលមិនពិចារណាឃើញនូវរូបថាជាខ្លួនទេ តែពិចារណាឃើញខ្លួនថាមានរូប ។ ម្នាលភិក្ខុទាំងឡាយ ការពិចារណាឃើញនោះឈ្មោះថា សង្ខារ ។ ចុះសង្ខារនោះ តើមានអ្វីជាហេតុ មានអ្វីនាំឲ្យកើត

កឹជាតិកោ កឹបភវោ ។ អវិជ្ជាសម្ផស្សជេន ភិក្ខវេ វេទយិតេន ផុដ្ឋស្ស អស្សុតវតោ បុថុជ្ជនស្ស ឧប្បន្នា តណ្ហា តតោជោ សោ សង្ខារោ ។ ឥតិ ខោ ភិក្ខវេ សោបិ សង្ខារោ អនិច្ចោ សង្ខតោ បដិច្ចសមុប្បន្នោ សាបិ តណ្ហា ។ សាបិ វេទនា ។ សោបិ ផស្សោ ។ សាបិ អវិជ្ជា អនិច្ចា សង្ខតា បដិច្ចសមុប្បន្នា ។ ឯវម្បិ ខោ ភិក្ខវេ ជានតោ ឯវំ បស្សតោ អនន្តរា អាសវានំ ខយោ ហោតិ ។

(១៧៦) ន ហេវ ខោ រូបំ អត្តតោ សមនុបស្សតិ ន រូបវន្តំ អត្តានំ សមនុបស្សតិ អបិច ខោ អត្តនិ រូបំ សមនុបស្សតិ ។ យា ខោ បន សា ភិក្ខវេ សមនុបស្សនា សង្ខារោ សោ ។ សោ បន សង្ខារោ កឹនិទានោ កឹសមុទយោ កឹជាតិកោ កឹបភវោ ។

មានអ្វីជាកំណើត មានអ្វីជាដែនកើត ។ ម្នាលភិក្ខុទាំងឡាយ តណ្ហាកើតឡើង ដល់បុថុជ្ជនជាអ្នកមិនចេះដឹង ដែលត្រូវវេទនាកើតអំពីសម្ផស្សនៃអវិជ្ជាប៉ះពាល់ សង្ខារនោះកើតមកអំពីតណ្ហានោះ ។ ម្នាលភិក្ខុទាំងឡាយ សង្ខារនោះក៏មិនទៀង មានបច្ច័យតាក់តែងកើតឡើងហើយ ព្រោះអាស្រ័យហេតុ តណ្ហានោះក៏មិនទៀង ដោយប្រការដូចេ្នះ ។ វេទនាក៏ដូច្នោះដែរ ។ ផស្សៈក៏ដូច្នោះដែរ ។ អវិជ្ជានោះក៏មិនទៀង មានបច្ច័យតាក់តែងកើតឡើងហើយ ព្រោះអាស្រ័យហេតុ ។ ម្នាលភិក្ខុទាំងឡាយ កាលបុគ្គលដឹងយ៉ាងនេះ ឃើញយ៉ាងនេះ រមែងអស់អាសវៈទាំងឡាយជាលំដាប់ ។

(១៧៦) បុគ្គលមិនពិចារណាឃើញនូវរូបថាជាខ្លួន មិនពិចារណាឃើញខ្លួនថាមានរូបទេ ប៉ុន្តែពិចារណាឃើញរូបថាមានក្នុងខ្លួន ។ ម្នាលភិក្ខុទាំងឡាយ ការពិចារណាឃើញនោះ ឈ្មោះថាសង្ខារ ។ ចុះសង្ខារនោះមានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត ។

អវិជ្ជាសម្ផស្សជេន ភិក្ខវេ វេទយិតេន ផុដ្ឋស្ស អស្សុតវតោ បុថុជ្ជនស្ស ឧប្បន្នា តណ្ហា តតោជោ សោ សង្ខារោ ។ ឥតិ ខោ ភិក្ខវេ សោបិ សង្ខារោ អនិច្ចោ សង្ខតោ បដិច្ចសមុប្បន្នោ សាបិ តណ្ហា ។ សាបិ វេទនា ។ សោបិ ផស្សោ ។ សាបិ អវិជ្ជា អនិច្ចា សង្ខតា បដិច្ចសមុប្បន្នា ។ ឯវំបិ ខោ ភិក្ខវេ ជានតោ ឯវំ បស្សតោ អនន្តរា អាសវានំ ខយោ ហោតិ ។

(១៧៧) ន ហេវ ខោ រូបំ អត្តតោ សមនុបស្សតិ ន រូបវន្តំ អត្តានំ សមនុបស្សតិ ន អត្តនិ រូបំ សមនុបស្សតិ អបិច ខោ រូបស្មឹ អត្តានំ សមនុបស្សតិ ។ យា ខោ បន សា ភិក្ខវេ សមនុបស្សនា សង្ខារោ សោ ។ សោ បន សង្ខារោ កឹនិទានោ កឹសមុទយោ កឹជាតិកោ កឹបភវោ ។ អវិជ្ជាសម្ផស្សជេន ភិក្ខវេ វេទយិតេន ផុដ្ឋស្ស អស្សុតវតោ បុថុជ្ជនស្ស ឧប្បន្នា

ម្នាលភិក្ខុទាំងឡាយ តណ្ហាកើតឡើងដល់បុថុជ្ជនជាអ្នកមិនចេះដឹង ដែលត្រូវវេទនាកើតអំពីសម្ផស្សនៃអវិជ្ជាប៉ះពាល់ សង្ខារនោះ កើតអំពីតណ្ហានោះ ។ ម្នាលភិក្ខុទាំងឡាយ សង្ខារនោះមិនទៀងទេ មានបច្ច័យតាក់តែងកើតឡើងហើយ ព្រោះអាស្រ័យហេតុ តណ្ហានោះក៏ដូច្នោះដែរ ។ វេទនានោះក៏ដូច្នោះដែរ ។ ផស្សៈនោះក៏ដូច្នោះដែរ ។ អវិជ្ជានោះមិនទៀង មានបច្ច័យតាក់តែងកើតឡើងហើយ ព្រោះអាស្រ័យហេតុ ។ ម្នាលភិក្ខុទាំងឡាយ កាលបុគ្គលដឹងយ៉ាងនេះ ឃើញយ៉ាងនេះ រមែងអស់អាសវៈទាំងឡាយជាលំដាប់ ។

(១៧៧) បុគ្គលមិនពិចារណាឃើញ នូវរូបថាជាខ្លួន មិនពិចារណាឃើញនូវខ្លួនថាមានរូប មិនពិចារណាឃើញនូវរូបថាមានក្នុងខ្លួនទេ ប៉ុន្តែពិចារណាឃើញខ្លួនថាមានក្នុងរូប ។ ម្នាលភិក្ខុទាំង-ឡាយ ការពិចារណាឃើញនោះ ឈ្មោះថា សង្ខារ ។ ចុះសង្ខារនោះ តើមានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត ។ ម្នាលភិក្ខុទាំងឡាយ តណ្ហាកើតឡើង ដល់បុថុជ្ជនជាអ្នកមិនចេះដឹង ដែលត្រូវវេទនាកើតអំពីសម្ផស្ស នៃអវិជ្ជាប៉ះពាល់

តណ្ហា តតោជា សោ សង្ខារោ ។ ឥតិ ខោ ភិក្ខវេ សោបិ សង្ខារោ អនិច្ចោ សង្ខតោ បដិច្ចសមុប្បន្នោ សាបិ តណ្ហា ។ សាបិ វេទនា ។ សោបិ ផស្សោ ។ សាបិ អវិជ្ជា អនិច្ចា សង្ខតា បដិច្ចសមុប្បន្នា ។ ឯវំបិ ខោ ភិក្ខវេ ជានតោ ឯវំ បស្សតោ អនន្តរា អាសវានំ ខយោ ហោតិ ។

(១៧៨) ន ហេវ ខោ រូបំ អត្តតោ សមនុបស្សតិ ន រូបវន្តំ អត្តានំ ន អត្តនិ រូបំ ន រូបស្មឹ អត្តានំ សមនុបស្សតិ អបិច ខោ វេទនំ អត្តតោ សមនុ-បស្សតិ ។ អបិច ខោ វេទនាវន្តំ អត្តានំ សមនុ-បស្សតិ ។ អបិច ខោ អត្តនិ វេទនំ សមនុបស្សតិ ។ អបិច ខោ វេទនាយ អត្តានំ សមនុបស្សតិ ។ អបិច ខោ សញ្ញំ អត្តតោ ។ អបិច ខោ សង្ខារេ អត្តតោ សមនុបស្សតិ ។ អបិច ខោ សង្ខារវន្តំ អត្តានំ សម-នុបស្សតិ ។ អបិច ខោ អត្តនិ សង្ខារេ សមនុបស្សតិ អបិច ខោ សង្ខារេសុ អត្តានំ សមនុបស្សតិ ។ អបិច ខោ វិញ្ញាណំ អត្តតោ សមនុបស្សតិ ។

សង្ខារនោះកើតអំពីតណ្ហានោះ ៗ ម្នាលភិក្ខុទាំងឡាយ សង្ខារនោះ មិនទៀង មានបច្ច័យតាក់តែងកើតឡើងហើយ ព្រោះអាស្រ័យហេតុ តណ្ហានោះ ក៏ដូច្នោះដែរ ៗ វេទនាក៏ដូច្នោះដែរ ៗ ផស្សៈក៏ដូច្នោះ ដែរ ៗ អវិជ្ជានោះ មិនទៀងទេ មានបច្ច័យតាក់តែងកើតឡើងហើយ ព្រោះអាស្រ័យហេតុ ៗ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គល ដឹងយ៉ាង នេះ ឃើញយ៉ាងនេះ រមែងអស់អាសវៈទាំងឡាយជាលំដាប់ ៗ

[១៧៨] ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនពិចារណាឃើញរូបថា ជាខ្លួន មិនពិចារណាឃើញខ្លួន ថាមានរូប មិនពិចារណាឃើញរូប ថា មានក្នុងខ្លួន មិនពិចារណាឃើញខ្លួន ថាមានក្នុងរូបទេ ប៉ុន្តែពិចារណា ឃើញវេទនា ថាជាខ្លួន ៗ ពិចារណាឃើញខ្លួន ថាមានវេទនា ៗ ពិចារ-ណាឃើញវេទនា ថាមានក្នុងខ្លួន ៗ ពិចារណាឃើញខ្លួន ថាមានក្នុង វេទនា ៗ ពិចារណាឃើញសញ្ញា ថាជាខ្លួន ៗ ពិចារណាឃើញ សង្ខារទាំងឡាយ ថាជាខ្លួន ៗ ពិចារណាឃើញខ្លួន ថាមានសង្ខារ ៗ ពិចារណាឃើញសង្ខារទាំងឡាយ ថាមានក្នុងខ្លួន ៗ ពិចារណាឃើញ ខ្លួន ថាមានក្នុងសង្ខារទាំងឡាយ ៗ ពិចារណាឃើញវិញ្ញាណ ថាជាខ្លួន ៗ

អបិច ខោ វិញ្ញាណវន្តំ អត្តានំ ។ អបិច ខោ អត្តនិ វិញ្ញាណំ ។ អបិច ខោ វិញ្ញាណស្មឹ អត្តានំ សមនុបស្សតិ ។ យា ខោ បន សា ភិក្ខវេ សមនុបស្សនា សង្ខារោ សោ ។ សោ បន សង្ខារោ កឹនិទានោ ។ បេ ។ កឹបភវោ ។ អវិជ្ជាសម្ផស្សជេន ភិក្ខវេ វេទយិតេន ផុដ្ឋស្ស អស្សុតវតោ បុថុជ្ជនស្ស ឧប្បន្នា តណ្ហា តតោជោ សោ សង្ខារោ ។ ឥតិ ខោ ភិក្ខវេ សោបិ សង្ខារោ អនិច្ចោ សង្ខតោ បដិច្ចសមុប្បន្នោ ។ សាបិ តណ្ហា ។ សាបិ វេទនា ។ សោបិ ផស្សោ ។ សាបិ អវិជ្ជា អនិច្ចា សង្ខតា បដិច្ចសមុប្បន្នា ។ ឯវំបិ ខោ ភិក្ខវេ ជានតោ ឯវំ បស្សតោ អនន្តរា អាសវានំ ខយោ ហោតិ ។

(១៧៩) ន ហេវ ខោ រូបំ អត្តតោ សមនុបស្សតិ ។ ន វេទនំ ។ ន សញ្ញំ ។ ន សង្ខារេ ។ ន វិញ្ញាណំ អត្តតោ សមនុបស្សតិ អបិច ខោ ឯវំទិដ្ឋិ ហោតិ សោ អត្តា សោ លោកោ

ពិចារណាឃើញខន្ធ ថាមានវិញ្ញាណ ។ ពិចារណាឃើញវិញ្ញាណ ថាមានក្នុងខន្ធ ។ ពិចារណាឃើញខន្ធថាមានក្នុងវិញ្ញាណ ។ ម្នាលភិក្ខុទាំងឡាយ ការពិចារណាឃើញនោះ ឈ្មោះថាសង្ខារ ។ ចុះសង្ខារនោះ មានអ្វីជាហេតុ ។បេ។ មានអ្វីជាដែនកើត ។ ម្នាលភិក្ខុទាំងឡាយ តណ្ហាកើតឡើងដល់បុថុជ្ជនជាអ្នកមិនចេះដឹង ដែលត្រូវវេទនាកើតអំពីសម្ផស្សនៃអវិជ្ជាប៉ះពាល់ សង្ខារនោះកើតអំពីតណ្ហានោះ ។ ម្នាលភិក្ខុទាំងឡាយ សង្ខារនោះមិនទៀងទេ មានបច្ច័យតាក់តែងកើតឡើងហើយ ព្រោះអាស្រ័យហេតុ ដូចពោលមកនេះ ។ តណ្ហានោះក៏ដែរ ។ វេទនានោះក៏ដែរ ។ ផស្សៈនោះក៏ដែរ ។ អវិជ្ជានោះមិនទៀងទេ មានបច្ច័យតាក់តែងកើតឡើងហើយ ព្រោះអាស្រ័យហេតុ ។ ម្នាលភិក្ខុទាំងឡាយ កាលបុគ្គលដឹងយ៉ាងនេះ ឃើញយ៉ាងនេះ រមែងអស់អាសវៈទាំងឡាយជាលំដាប់ ។

[១៧៩] ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនពិចារណាឃើញរូបថាជាខ្លួន ។ មិនពិចារណាឃើញវេទនា ។ មិនពិចារណាឃើញសញ្ញា ។ មិនពិចារណាឃើញសង្ខារទាំងឡាយ ។ មិនពិចារណាឃើញវិញ្ញាណថាជាខ្លួន តែមានសេចក្តីយល់យ៉ាងនេះថា នោះជាខ្លួន នោះជាលោក

សោ បេច្ច ភវិស្សាមិ និច្ចោ ធុវោ សស្សតោ អវិបរិណា-មធម្មោតិ ។ យា ខោ បន សា ភិក្ខវេ សស្សតទិដ្ឋិ សង្ខារោ សោ ។ សោ បន សង្ខារោ កឹនិទានោ ។បេ។ ឯវំបិ ខោ ភិក្ខវេ ជានតោ ឯវំ បស្សតោ អនន្តរា អាសវានំ ខយោ ហោតិ ។

(១៨០) ន ហេវ ខោ រូបំ អត្តតោ សមនុបស្សតិ ។ ន វេទនំ ។ ន សញ្ញំ ។ ន សង្ខារេ ។ ន វិញ្ញាណំ អត្ត-តោ សមនុបស្សតិ អបិច ឯវំទិដ្ឋី ហោតិ សោ អត្តា សោ លោកោ សោ បេច្ច ភវិស្សាមិ និច្ចោ ធុវោ សស្ស-តោ អវិបរិណាមធម្មោតិ អបិច ខោ ឯវំទិដ្ឋី ហោតិ នោ ចស្សំ នោ ច មេ សិយា ន ភវិស្សាមិ ន មេ ភវិស្សតីតិ ។

អាត្មាអញនោះ នឹងទៅខាងមុខ ក៏ទៀង ឋិតថេរ ពិតប្រាកដ មិនប្រែប្រួលជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ សស្សតទិដ្ឋិនោះ ឈ្មោះថា សង្ខារ ។ ចុះសង្ខារនោះ មានអ្វីជាហេតុ ។បេ។ ម្នាលភិក្ខុទាំងឡាយ កាលបុគ្គលដឹងយ៉ាងនេះ ឃើញយ៉ាងនេះ រមែងអស់អាសវៈទាំងឡាយជាលំដាប់ ។

[ ១៨០ ] បុគ្គលមិនពិចារណាឃើញរូបថាជាខ្លួន ។ មិនពិចារណាឃើញវេទនា ។ មិនពិចារណាឃើញសញ្ញា ។ មិនពិចារណាឃើញសង្ខារទាំងឡាយ ។ មិនពិចារណាឃើញវិញ្ញាណថាជាខ្លួន ទាំងមិនមានសេចក្តីយល់ឃើញយ៉ាងនេះថា នោះជាខ្លួន នោះជាលោក អាត្មាអញនោះ លុះទៅខាងមុខ ក៏ទៀង ឋិតថេរ ពិតប្រាកដ មិនបានប្រែប្រួលជាធម្មតាឡើយ តែមានសេចក្តីយល់ឃើញយ៉ាងនេះថា បើអាត្មាអញនឹងមិនកើត បរិក្ខាររបស់អាត្មាអញក៏នឹងមិនកើត បើអាត្មាអញនឹងមិនកើតទៀតទេ បរិក្ខាររបស់អាត្មាអញក៏នឹងមិនកើតទៀតដែរ ។

យា ខោ បន សា ភិក្ខវេ ឧច្ឆេទទិដ្ឋិ សង្ខារោ សោ ។ សោ បន សង្ខារោ កិំនិទានោ កិំសមុទយោ កិំជាតិកោ កិំបភវោ ។ អវិជ្ជាសម្ផស្សជេន ភិក្ខវេ វេទយិតេន ផុដ្ឋស្ស អស្សុតវតោ បុថុជ្ជនស្ស ឧប្បន្នា តណ្ហា តតោជា សោ សង្ខារោ ។ ឥតិ ខោ ភិក្ខវេ សោបិ សង្ខារោ អនិច្ចោ ។ បេ ។ ឯវំបិ ខោ ភិក្ខវេ ជានតោ ឯវំ បស្សតោ អនន្តរា អាសវានំ ខយោ ហោតិ ។

(១៨១) ន ហេវ ខោ រូបំ អត្តតោ សមនុបស្សតិ ។ ន វេទនំ ។ ន សញ្ញំ ។ ន សង្ខារេ ។ ន វិញ្ញាណំ អត្តតោ សមនុបស្សតិ ។ បេ ។ ន វិញ្ញាណស្មឹ អត្តានំ សមនុបស្សតិ នាបិ ឯវំទិដ្ឋិ ហោតិ សោ អត្តា សោ លោកោ សោ បេច្ច ភវិស្សាមិ និច្ចោ ធុវោ សស្សតោ អវិបរិណាមធម្មោតិ នាបិ ឯវំទិដ្ឋិ ហោតិ នោ ចស្សំ

ម្នាលភិក្ខុទាំងឡាយ ឧច្ឆេទទិដ្ឋិនោះ ឈ្មោះថា សង្ខារ ។ ចុះសង្ខារនោះ តើមានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត ។ ម្នាលភិក្ខុទាំងឡាយ តណ្ហាកើតឡើងដល់បុថុជ្ជនជាអ្នកមិនចេះដឹង ដែលត្រូវវេទនាកើតអំពីសម្ផស្សនៃអវិជ្ជាប៉ះពាល់ សង្ខារនោះកើតអំពីតណ្ហានោះ ។ ម្នាលភិក្ខុទាំងឡាយ សង្ខារនោះក៏មិនទៀង ដោយប្រការដូច្នេះ ។បេ។ ម្នាលភិក្ខុទាំងឡាយ កាលបុគ្គលដឹងយ៉ាងនេះ ឃើញយ៉ាងនេះ រមែងអស់អាសវៈទាំងឡាយជាលំដាប់ ។

(១៨១) បុគ្គលមិនពិចារណាឃើញរូបថាជាខ្លួន ។ មិនពិចារណាឃើញវេទនា ។ មិនពិចារណាឃើញសញ្ញា ។ មិនពិចារណាឃើញសង្ខារទាំងឡាយ ។ មិនពិចារណាឃើញវិញ្ញាណថាជាខ្លួន ។បេ។ មិនពិចារណាឃើញខ្លួនថាមានក្នុងវិញ្ញាណ ទាំងមិនមានសេចក្តីយល់ឃើញយ៉ាងនេះថា នោះជាខ្លួន នោះជាលោក អាត្មាអញនោះលុះទៅខាងមុខ ក៏ទៀងទាត់ ឋិតថេរ ពិតប្រាកដ មិនមានការប្រែប្រួលជាធម្មតាឡើយ ទាំងមិនមានសេចក្តីយល់ឃើញយ៉ាងនេះថា បើអាត្មាអញនឹងមិនកើត បរិក្ខាររបស់អាត្មាអញ ក៏នឹងមិនកើតដែរ បើអាត្មាអញនឹងមិន

នោ ច មេ សិយា ន ភវិស្សាមិ ន មេ ភវិស្សតីតិ អបិច ខោ កង្ខី ហោតិ វិចិកិច្ឆី អនិដ្ឋង្គតោ សទ្ធម្មេ ។ យា ខោ បន សា ភិក្ខវេ កង្ខិតា វិចិកិច្ឆិតា អនិដ្ឋង្គតតា សទ្ធម្មេ សង្ខារោ សោ ។ សោ បន សង្ខារោ កឹនិទានោ កឹសមុទយោ កឹជាតិកោ កឹបភវោ ។ អវិជ្ជាសម្ផស្សជេន ភិក្ខវេ វេទយិតេន ផុដ្ឋស្ស អស្សុតវតោ បុថុជ្ជនស្ស ឧប្បន្នា តណ្ហា តតោជោ សោ សង្ខារោ ។ ឥតិ ខោ ភិក្ខវេ សោបិ សង្ខារោ អនិច្ចោ សង្ខតោ បដិច្ចសមុប្បន្នោ សាបិ តណ្ហា អនិច្ចា សង្ខតា បដិច្ចសមុប្បន្នា សាបិ វេទនា អនិច្ចា សង្ខតា បដិច្ចសមុប្បន្នា សោបិ ផស្សោ អនិច្ចោ សង្ខតោ បដិច្ចសមុប្បន្នោ សាបិ អវិជ្ជា អនិច្ចា សង្ខតា បដិច្ចសមុប្បន្នា ។ ឯវំបិ ខោ ភិក្ខវេ ជានតោ ឯវំ បស្សតោ អនន្តរា អាសវានំ ខយោ ហោតីតិ ។

កើតទៀតទេ បរិក្ខាររបស់អាត្មាអញក៏នឹងមិនកើតដែរ តែជាអ្នកមានសេចក្តីសង្ស័យងឿងឆ្ងល់ មិនដល់នូវសេចក្តីចូលចិត្តក្នុងព្រះសទ្ធម្ម ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីសង្ស័យងឿងឆ្ងល់ មិនដល់នូវសេចក្តីចូលចិត្តក្នុងព្រះសទ្ធម្មនោះ ឈ្មោះថាសង្ខារ ។ ចុះសង្ខារនោះ មានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត ។ ម្នាលភិក្ខុទាំងឡាយ តណ្ហាកើតឡើងដល់បុថុជ្ជនជាអ្នកមិនចេះដឹង ដែលត្រូវវេទនាកើតអំពីសម្ផស្សនៃអវិជ្ជាប៉ះពាល់ សង្ខារនោះកើតមកអំពីតណ្ហានោះ ។ ម្នាលភិក្ខុទាំងឡាយ សង្ខារនោះមិនទៀងទេ មានបច្ច័យតាក់តែងកើតឡើង ព្រោះអាស្រ័យហេតុផង តណ្ហានោះមិនទៀង មានបច្ច័យតាក់តែងកើតឡើង ព្រោះអាស្រ័យហេតុផង វេទនានោះមិនទៀង មានបច្ច័យតាក់តែងកើតឡើង ព្រោះអាស្រ័យហេតុផង ផស្សៈនោះក៏មិនទៀង មានបច្ច័យតាក់តែងកើតឡើង ព្រោះអាស្រ័យហេតុផង អវិជ្ជានោះក៏មិនទៀង មានបច្ច័យតាក់តែងកើតឡើង ព្រោះអាស្រ័យហេតុផង ដោយប្រការដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ កាលបុគ្គលដឹងយ៉ាងនេះ ឃើញយ៉ាងនេះ រមែងអស់អាសវៈទាំងឡាយជាលំដាប់ ។

(១៨២) ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ បុព្វារាមេ មិគារមាតុបាសាទេ មហតា ភិក្ខុសង្ឃេន សទ្ធឹ ។ តេន ខោ បន សមយេន ភគវា តទហុបោ-សថេ បណ្ណរសេ បុណ្ណាយ បុណ្ណមាយ រត្តិយា ភិក្ខុ-សង្ឃបរិវុតោ អព្ភោកាសេ និសិន្នោ ហោតិ ។

(១៨៣) អថខោ អញ្ញតរោ ភិក្ខុ ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ករិត្វា យេន ភគវា តេនញ្ជ-លឹ បណាមេត្វា ភគវន្តំ ឯតទវោច បុច្ឆេយ្យាហំ ភន្តេ ភគវន្តំ កិញ្ចិទេវ ទេសំ សចេ មេ ភគវា ឱកាសំ ករោតិ បញ្ហស្ស វេយ្យាករណាយាតិ ។ តេនហិ ត្វំ ភិក្ខុ សកេ អាសនេ និសីទិត្វា បុច្ឆ យទាកង្ខសីតិ ។ ឯវំ ភន្តេតិ ខោ សោ ភិក្ខុ ភគវតោ បដិស្សុត្វា

[១៨២] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងប្រាសាទ របស់នាងវិសាខាជាមិគារមាតា នាបុព្វារាម ជិតក្រុងសាវត្ថី មួយអន្លើ ដោយភិក្ខុសង្ឃច្រើនរូប ។ សម័យនោះឯង ព្រះមានព្រះភាគ មានភិក្ខុសង្ឃចោមរោម ទ្រង់គង់ក្នុងទីវាល នាពេលរាត្រីមានព្រះចន្ទពេញវង់ ក្នុងថ្ងៃពេញបូណ៌មី ជាឧបោសថ ទី ១៥ ។

[១៨៣] គ្រានោះ ភិក្ខុមួយរូប ក្រោកចាកអាសនៈ ធ្វើចីវរ ឆៀងស្មាម្ខាង ប្រណម្យអញ្ជលីចំពោះព្រះមានព្រះភាគ ក្រាបបង្គំទូល ព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន បើព្រះមានព្រះភាគ ទ្រង់ធ្វើឱកាសបម្រុងនឹងដោះស្រាយប្រស្នា របស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គ សូមទូលសួរហេតុនីមួយ ចំពោះព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ត្រាស់ថា ម្នាលភិក្ខុ បើដូច្នោះ អ្នកប្រាថ្នានឹងសួរប្រស្នាណា ចូរអ្នកអង្គុយលើអាសនៈជារបស់ខ្លួន ហើយសួរប្រស្នានោះចុះ ។ ភិក្ខុនោះ ទទួលស្តាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ

សារោ អាសនេ និសីទិត្វា ភគវន្តំ ឯតទវោច ឥមេ នុ ខោ ភន្តេ បញ្ចុបាទានក្ខន្ធា ។ សេយ្យថីទំ ។ រូបុបាទានក្ខន្ធោ វេទនុបាទានក្ខន្ធោ សញ្ញុបាទានក្ខន្ធោ សង្ខារុបាទានក្ខន្ធោ វិញ្ញាណុបាទានក្ខន្ធោតិ ។ ឥមេ ខោ ភិក្ខុ បញ្ចុបាទានក្ខន្ធា ។ សេយ្យថីទំ ។ រូបុបាទានក្ខន្ធោ ។ បេ ។ វិញ្ញាណុបាទានក្ខន្ធោតិ ។

(១៨៤) សាធុ ភន្តេតិ ខោ សោ ភិក្ខុ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ភគវន្តំ ឧត្តរឹ បញ្ហំ អបុច្ឆិ ឥមេ ខោ បន ភន្តេ បញ្ចុបាទានក្ខន្ធា កឹមូលកាតិ ។ ឥមេ ខោ ភិក្ខុ បញ្ចុបាទានក្ខន្ធា ឆន្ទមូលកាតិ ។ បេ ។ តញ្ញេវ នុ ខោ ភន្តេ ឧបាទានំ តេ ច បញ្ចុបាទានក្ខន្ធា ឧទាហុ អញ្ញត្រ បញ្ចហិ ឧបាទានក្ខន្ធេហិ ឧបាទានន្តិ ។ ន ខោ ភិក្ខុ តញ្ញេវ ឧបាទានំ តេ ច បញ្ចុបាទានក្ខន្ធា នបិ អញ្ញត្រ បញ្ចហិ ឧបាទានក្ខន្ធេហិ ឧបាទានំ អបិច យោ តត្ថ ឆន្ទរាគោ តំ តត្ថ ឧបាទានន្តិ ។

ហើយអង្គុយលើអាសនៈ ជារបស់ខ្លួន ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ឧបាទានក្ខន្ធនេះ មាន ៥ ឬហ្ន៎ ។ ឧបាទានក្ខន្ធ ៥ ដូចម្តេចខ្លះ ។ គឺឧបាទានក្ខន្ធគឺរូប ១ ឧបាទានក្ខន្ធគឺវេទនា ១ ឧបាទានក្ខន្ធគឺសញ្ញា ១ ឧបាទានក្ខន្ធគឺសង្ខារ ១ ឧបាទានក្ខន្ធគឺវិញ្ញាណ ១ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុ នេះឯងជាឧបាទានក្ខន្ធ ៥ ។ ឧបាទានក្ខន្ធ ៥ ដូចម្តេចខ្លះ ។ គឺ ឧបាទានក្ខន្ធគឺរូប ១ ។ បេ ។ ឧបាទានក្ខន្ធគឺវិញ្ញាណ ១ ។

[ ១៨៤ ] ភិក្ខុនោះ ត្រេកអរ អនុមោទនាចំពោះភាសិតរបស់ព្រះមានព្រះភាគថា ប្រពៃហើយ ព្រះអង្គ រួចក្រាបបង្គំទូលសួរប្រស្នានឹងព្រះមានព្រះភាគតទៅទៀតថា បពិត្រព្រះអង្គដ៏ចម្រើន ចុះឧបាទានក្ខន្ធ ៥ នេះ មានអ្វីជាឫស ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុ ឧបាទានក្ខន្ធ ៥ នេះឯង មានឆន្ទៈជាឫស ។ បេ ។ បពិត្រព្រះអង្គដ៏ចម្រើន ឧបាទាននោះឬហ្ន៎ ជាឧបាទានក្ខន្ធទាំង ៥ នោះ ឬថាឧបាទានផ្សេងអំពីឧបាទានក្ខន្ធទាំង ៥ ។ ម្នាលភិក្ខុ ឧបាទាននោះ ជាឧបាទានក្ខន្ធទាំង ៥ នោះឯង ក៏ទេ ឧបាទានផ្សេងអំពីឧបាទានក្ខន្ធទាំង ៥ ក៏ទេដែរ ឯសេចក្តីត្រេកត្រអាលក្នុងឧបាទានក្ខន្ធទាំង ៥ នោះទើប ជាឧបាទាន ។

(១៨៥) សាធុ ភន្តេតិ ខោ សោ ភិក្ខុ។បេ។ ឧត្តរិ បញ្ហំ អបុច្ឆិ សិយា បន ភន្តេ បញ្ចុបាទានក្ខន្ធេសុ ឆន្ទរាគវេមត្តតាតិ។ សិយា ភិក្ខូតិ ភគវា អវោច ឥធ ភិក្ខុ ឯកច្ចស្ស ឯវំ ហោតិ ឯវំរូបោ សិយំ អនាគតមទ្ធានំ ឯវំវេទនោ សិយំ អនាគតមទ្ធានំ ឯវំសញ្ញោ សិយំ អនាគតមទ្ធានំ ឯវំសង្ខារោ សិយំ អនាគតមទ្ធានំ ឯវំវិញ្ញាណោ សិយំ អនាគតមទ្ធានន្តិ។ ឯវំ ខោ ភិក្ខុ សិយា បញ្ចុបាទានក្ខន្ធេសុ ឆន្ទរាគវេមត្តតាតិ។

(១៨៦) សាធុ ភន្តេតិ ខោ សោ ភិក្ខុ។បេ។ ឧត្តរិ បញ្ហំ អបុច្ឆិ កិត្តាវតា នុ ខោ ភន្តេ ខន្ធានំ ខន្ធាធិវចនន្តិ។ យំ កិញ្ចិ ភិក្ខុ រូបំ អតីតានាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា។ អយំ វុច្ចតិ រូបក្ខន្ធោ។ យា កាចិ វេទនា។ យា កាចិ សញ្ញា។ យេ កេចិ សង្ខារា។

[១៨៥] ភិក្ខុនោះក្រាបបង្គំទូលថា ប្រពៃហើយ ព្រះអង្គ ។ បេ ។ រួចក្រាបទូលសួរប្រស្នាតទៅទៀតថា បពិត្រព្រះអង្គដ៏ចម្រើន ចុះសេចក្តីត្រេកត្រអាលក្នុងឧបាទានក្ខន្ធទាំង ៥ ផ្សេងទៀត មានដែរឬ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុ មាន រួចត្រាស់ថា ម្នាលភិក្ខុ បុគ្គលពួកខ្លះក្នុងលោកនេះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ក្នុងអនាគតកាល សូមឲ្យអញមានរូបយ៉ាងនេះ ក្នុងអនាគតកាល សូមឲ្យអញមានវេទនាយ៉ាងនេះ ក្នុងអនាគតកាល សូមឲ្យអញមានសញ្ញាយ៉ាងនេះ ក្នុងអនាគតកាល សូមឲ្យអញមានសង្ខារ យ៉ាងនេះ ក្នុងអនាគតកាល សូមឲ្យអញមានវិញ្ញាណយ៉ាងនេះ ។ ម្នាលភិក្ខុ សេចក្តីត្រេកត្រអាលក្នុងឧបាទានក្ខន្ធទាំង ៥ ផ្សេងទៀត មាន យ៉ាងនេះឯង ។

[១៨៦] ភិក្ខុនោះក្រាបបង្គំទូលថា ប្រពៃហើយ ព្រះអង្គ ។ បេ ។ រួចក្រាបទូលសួរប្រស្នាតទៅទៀតថា បពិត្រព្រះអង្គដ៏ចម្រើន ដោយហេតុដូចម្តេច បានជាខន្ធទាំងឡាយ មានឈ្មោះថា ខន្ធ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុ រូបណានីមួយ ជាអតីត អនាគត បច្ចុប្បន្ន ជាខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី ដែលមានក្នុងទីឆ្ងាយឬក្នុងទីជិត ។ នេះហៅថារូបក្ខន្ធ ។ វេទនាណានីមួយ ។ សញ្ញាណានីមួយ ។ សង្ខារទាំងឡាយណានីមួយ ។

យំ កិញ្ចិ វិញ្ញាណំ អតីតានាគតបច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា ។ អយំ វុច្ចតិ វិញ្ញាណក្ខន្ធោ ។ ឯត្តាវតា ខោ ភិក្ខុ ខន្ធានំ ខន្ធាធិវចនន្តិ ។

[១៨៧] សាធុ ភន្តេតិ ខោ សោ ភិក្ខុ ។បេ។ អបុច្ឆិ កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ រូបក្ខន្ធស្ស បញ្ញាបនាយ ។ កោ ហេតុ កោ បច្ចយោ វេទនាក្ខន្ធស្ស បញ្ញាបនាយ ។ កោ ហេតុ កោ បច្ចយោ សញ្ញាក្ខន្ធស្ស បញ្ញាបនាយ ។ កោ ហេតុ កោ បច្ចយោ សង្ខារក្ខន្ធស្ស បញ្ញាបនាយ ។

វិញ្ញាណណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ជាខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី ដែលមានក្នុងទីឆ្ងាយឬក្នុងទីជិត ។ នេះ ហៅថាវិញ្ញាណក្ខន្ធ ។ ម្នាលភិក្ខុ ដោយហេតុប៉ុណ្ណោះឯង បានជាខន្ធទាំងឡាយ មានឈ្មោះថាខន្ធ ។

(១៨៧) ភិក្ខុនោះក្រាបបង្គំទូលថា ប្រពៃហើយ ព្រះអង្គ ។ បេ ។ រួចក្រាបទូលសួរប្រស្នាតទៅទៀតថា បពិត្រព្រះអង្គដ៏ចំរើន ចុះអ្វីជាហេតុ អ្វីជាបច្ច័យ នៃការបញ្ញត្តិរូបក្ខន្ធ ។ អ្វីជាហេតុ អ្វីជាបច្ច័យ នៃការបញ្ញត្តិវេទនាខន្ធ ។ អ្វីជាហេតុ អ្វីជាបច្ច័យ នៃការបញ្ញត្តិសញ្ញាខន្ធ ។ អ្វីជាហេតុ អ្វីជាបច្ច័យ នៃការបញ្ញត្តិសង្ខារក្ខន្ធ ។

កោ ហេតុ កោ បច្ចយោ វិញ្ញាណក្ខន្ធស្ស បញ្ញាបនាយាតិ ។ ចត្តារោ ខោ ភិក្ខុ មហាភូតា ហេតុ ចត្តារោ មហាភូតា បច្ចយោ រូបក្ខន្ធស្ស បញ្ញាបនាយ ។ ផស្សោ ហេតុ ផស្សោ បច្ចយោ វេទនាក្ខន្ធស្ស បញ្ញាបនាយ ។ ផស្សោ ហេតុ ផស្សោ បច្ចយោ សញ្ញាក្ខន្ធស្ស បញ្ញាបនាយ ។ ផស្សោ ហេតុ ផស្សោ បច្ចយោ សង្ខារក្ខន្ធស្ស បញ្ញាបនាយ ។ នាមរូបំ ហេតុ នាមរូបំ បច្ចយោ វិញ្ញាណក្ខន្ធស្ស បញ្ញាបនាយាតិ ។

(១៨៨) សាធុ ភន្តេតិ ខោ សោ ភិក្ខុ ។ បេ ។ អបុច្ឆិ កថំ នុ ខោ ភន្តេ សក្កាយទិដ្ឋិ ហោតីតិ ។ ឥធ ភិក្ខុ អស្សុតវា បុថុជ្ជនោ អរិយានំ អទស្សាវី អរិយធម្មស្ស អកោវិទោ អរិយធម្មេ អវិនីតោ សប្បុរិសានំ អទស្សាវី សប្បុរិសធម្មស្ស អកោវិទោ សប្បុរិសធម្មេ អវិនីតោ រូបំ អត្តតោ សមនុបស្សតិ

អ្វីជាហេតុ អ្វីជាបច្ច័យ នៃការបញ្ញត្តិវិញ្ញាណក្ខន្ធ ។ ម្នាលភិក្ខុ មហាភូតទាំង៤ ជាហេតុ មហាភូតទាំង៤ ជាបច្ច័យ នៃការបញ្ញត្តិរូបក្ខន្ធ ។ ផស្សៈជាហេតុ ផស្សៈជាបច្ច័យ នៃការបញ្ញត្តិវេទនាខន្ធ ។ ផស្សៈជាហេតុ ផស្សៈជាបច្ច័យ នៃការបញ្ញត្តិសញ្ញាខន្ធ ។ ផស្សៈជាហេតុ ផស្សៈជាបច្ច័យ នៃការបញ្ញត្តិសង្ខារក្ខន្ធ ។ នាមរូប ជាហេតុ នាមរូប ជាបច្ច័យ នៃការបញ្ញត្តិវិញ្ញាណក្ខន្ធ ។

[១៨៨] ភិក្ខុនោះក្រាបបង្គំទូលថា ប្រពៃហើយ ព្រះអង្គ ។ បេ ។ រួចក្រាបទូលសួរប្រស្នាតទៅទៀតថា បពិត្រព្រះអង្គដ៏ចម្រើន ចុះអ្វីជាសក្កាយទិដ្ឋិ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង មិនធ្លាប់ឃើញពួកព្រះអរិយៈ មិនឈ្លាសវៃក្នុងធម៌របស់ព្រះអរិយៈ មិនបានហ្វឹកហ្វឺនក្នុងធម៌របស់ព្រះអរិយៈ មិនធ្លាប់ឃើញពួកសប្បុរស មិនឈ្លាសវៃ ក្នុងធម៌របស់សប្បុរស មិនបានហ្វឹកហ្វឺន ក្នុងធម៌របស់សប្បុរស រមែងពិចារណាឃើញរូបថាជាខ្លួនខ្លះ

រូបវន្តំ វា អត្តានំ អត្តនិ វា រូបំ រូបស្មឹ វា អត្តានំ ។ វេទនំ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ អត្តតោ សមនុបស្សតិ វិញ្ញាណវន្តំ វា អត្តានំ អត្តនិ វា វិញ្ញាណំ វិញ្ញាណស្មឹ វា អត្តានំ ។ ឯវំ ខោ ភិក្ខុ សក្កាយទិដ្ឋិ ហោតីតិ ។

(១៨៩) សាធុ ភន្តេតិ ខោ សោ ភិក្ខុ ។ បេ ។ អបុច្ឆិ កថំ បន ភន្តេ សក្កាយទិដ្ឋិ ន ហោតីតិ ។ ឥធ ភិក្ខុ សុតវា អរិយសាវកោ អរិយានំ ទស្សាវី អរិយធម្មស្ស កោវិទោ អរិយធម្មេ សុវិនីតោ សប្បុរិសានំ ទស្សាវី សប្បុរិសធម្មស្ស កោវិទោ សប្បុរិសធម្មេ សុវិនីតោ ន រូបំ អត្តតោ សមនុបស្សតិ ន រូបវន្តំ វា អត្តានំ ន អត្តនិ វា រូបំ ន រូបស្មឹ វា អត្តានំ ។ ន វេទនំ ។ ន សញ្ញំ ។ ន សង្ខារេ ។ ន វិញ្ញាណំ អត្តតោ សមនុបស្សតិ ន វិញ្ញាណវន្តំ វា អត្តានំ ន អត្តនិ វា វិញ្ញាណំ ន វិញ្ញាណស្មឹ វា អត្តានំ ។ ឯវំ ខោ ភិក្ខុ សក្កាយទិដ្ឋិ ន ហោតីតិ ។

ឃើញខ្លួនថាមានរូបខ្លះ ឃើញរូបថាមានក្នុងខ្លួនខ្លះ ឃើញខ្លួនថាមានក្នុងរូបខ្លះ ។ ឃើញវេទនា ។ ឃើញសញ្ញា ។ ឃើញសង្ខារទាំងឡាយ ។ រមែងពិចារណាឃើញវិញ្ញាណ ថាជាខ្លួនខ្លះ ឃើញខ្លួនថាមានវិញ្ញាណខ្លះ ឃើញវិញ្ញាណ ថាមានក្នុងខ្លួនខ្លះ ឃើញខ្លួនថាមានក្នុងវិញ្ញាណខ្លះ ។ ម្នាលភិក្ខុ យ៉ាងនេះឯង ឈ្មោះថាសក្កាយទិដ្ឋិ ។

[១៨៩] ភិក្ខុនោះក្រាបបង្គំទូលថា ប្រពៃហើយ ព្រះអង្គ ។បេ។ រួចក្រាបទូលសួរប្រស្នាតទៅទៀតថា បពិត្រព្រះអង្គដ៏ចម្រើន ចុះដូចម្តេចដែលមិនមែនជាសក្កាយទិដ្ឋិ ។ ម្នាលភិក្ខុ អរិយសាវ័កក្នុងសាសនានេះ ជាអ្នកចេះដឹង ធ្លាប់បានឃើញពួកព្រះអរិយៈ ឈ្លាសវៃ ក្នុងធម៌របស់ព្រះអរិយៈ បានហ្វឹកហ្វឺនក្នុងធម៌របស់ព្រះអរិយៈ ជាអ្នកបានឃើញពួកសប្បុរស ឈ្លាសវៃ ក្នុងធម៌របស់សប្បុរស បានហ្វឹកហ្វឺនក្នុងធម៌របស់សប្បុរស មិនពិចារណាឃើញរូប ថាជាខ្លួនខ្លះ មិនឃើញខ្លួនថាមានរូបខ្លះ មិនឃើញរូបថាមានក្នុងខ្លួនខ្លះ មិនឃើញខ្លួនថាមានក្នុងរូបខ្លះ មិនឃើញវេទនា ។ មិនឃើញសញ្ញា ។ មិនឃើញសង្ខារទាំងឡាយ ។ មិនពិចារណាឃើញវិញ្ញាណថាជាខ្លួនខ្លះ មិនឃើញខ្លួនថាមានវិញ្ញាណខ្លះ មិនឃើញវិញ្ញាណថាមានក្នុងខ្លួនខ្លះ មិនឃើញខ្លួន ថាមានក្នុងវិញ្ញាណខ្លះ ។ ម្នាលភិក្ខុ យ៉ាងនេះ មិនមែនឈ្មោះថាសក្កាយទិដ្ឋិទេ ។

[១៩០] សាធុ ភន្តេតិ ខោ សោ ភិក្ខុ ។បេ។ កោ នុ ខោ ភន្តេ រូបស្ស អស្សាទោ កោ អាទីនវោ កឹ និស្សរណំ ។ កោ វេទនាយ ។ កោ សញ្ញាយ ។ កោ សង្ខារានំ ។ កោ វិញ្ញាណស្ស អស្សាទោ កោ អាទីនវោ កឹ និស្សរណន្តិ ។ យំ ខោ ភិក្ខុ រូបំ បដិច្ច ឧប្បជ្ជតិ សុខំ សោមនស្សំ អយំ រូបស្ស អស្សាទោ យំ រូបំ អនិច្ចំ ទុក្ខំ វិបរិណាមធម្មំ អយំ រូបស្ស អាទីនវោ យោ រូបស្មឹ ឆន្ទរាគវិនយោ ឆន្ទរាគប្បហានំ ឥទំ រូបស្ស និស្សរណំ ។ យំ វេទនំ បដិច្ច ។ យំ សញ្ញំ បដិច្ច ។ យំ សង្ខារេ បដិច្ច ។ យំ វិញ្ញាណំ បដិច្ច ឧប្បជ្ជតិ សុខំ សោមនស្សំ អយំ វិញ្ញាណស្ស អស្សាទោ យំ វិញ្ញាណំ អនិច្ចំ ទុក្ខំ វិបរិណាមធម្មំ អយំ វិញ្ញាណស្ស អាទីនវោ យោ វិញ្ញាណស្មឹ ឆន្ទរាគវិនយោ ឆន្ទរាគប្បហានំ ឥទំ វិញ្ញាណស្ស និស្សរណន្តិ ។

[ ១៩០ ] ភិក្ខុនោះ ក្រាបបង្គំទូលថា ប្រពៃហើយ ព្រះអង្គ ។ បេ ។ រួចក្រាបទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ចុះអ្វីជាអានិសង្ស អ្វី ជាទោស អ្វី ជាការរលាស់ចេញ នៃរូប ។ អ្វី ជាអានិសង្សរបស់វេទនា ។ អ្វីជាអានិសង្សរបស់សញ្ញា ។ អ្វីជាអានិសង្សរបស់សង្ខារទាំងឡាយ ។ អ្វី ជាអានិសង្ស អ្វី ជាទោស អ្វី ជាការរលាស់ចេញនៃវិញ្ញាណ ។ ម្នាលភិក្ខុ សេចក្តីសុខនិងសោមនស្សណា កើតឡើងព្រោះអាស្រ័យរូប នេះ ជាអានិសង្សរបស់រូប រូបណា ដែលមិនទៀង ជាទុក្ខ មានសភាពប្រែប្រួល នេះ ជាទោសរបស់រូប ការបន្ទោបង់នូវសេចក្តីត្រេកត្រអាល ការលះបង់នូវសេចក្តីត្រេកត្រអាល ក្នុងរូបណា នេះជាការរលាស់ចេញនូវរូប ។ សេចក្តីសុខនិងសោមនស្សណា កើតឡើងព្រោះអាស្រ័យវេទនា ។ ព្រោះអាស្រ័យសញ្ញា ។ ព្រោះអា-ស្រ័យសង្ខារទាំងឡាយ ។ សេចក្តីសុខនិងសោមនស្សណា កើតឡើងព្រោះអាស្រ័យវិញ្ញាណ នេះ ជាអានិសង្សរបស់វិញ្ញាណ វិញ្ញាណណាដែលមិនទៀង ជាទុក្ខ មានសភាពប្រែប្រួល នេះ ជាទោសរបស់វិញ្ញាណ ការបន្ទោបង់នូវសេចក្តីត្រេកត្រអាល ការលះបង់នូវសេចក្តីត្រេកត្រអាល ក្នុងវិញ្ញាណណា នេះ ជាការរលាស់ចេញនូវវិញ្ញាណ ។

[១៩១] សាធុ ភន្តេតិ ខោ សោ ភិក្ខុ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ភគវន្តំ ឧត្តរឹ បញ្ហំ អបុច្ឆិ កិំ នុ ខោ ភន្តេ ជានតោ កិំ បស្សតោ ឥមស្មិញ្ច សវិញ្ញាណកេ កាយេ ពហិទ្ធា ច សព្វនិមិត្តេសុ អហង្ការមមង្ការមានានុសយា ន ហោន្តីតិ ។ យំ កិញ្ចិ ភិក្ខុ រូបំ អតីតានាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា សព្វំ រូបំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ បស្សតិ ។ យា កាចិ វេទនា ។ យា កាចិ សញ្ញា ។ យេ កេចិ សង្ខារា ។ យំ កិញ្ចិ វិញ្ញាណំ អតីតានាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា សព្វំ វិញ្ញាណំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ បស្សតិ ។

[១៩១] ភិក្ខុនោះ ត្រេកអរ អនុមោទនាចំពោះភាសិតព្រះមានព្រះភាគថា ប្រពៃហើយ ព្រះអង្គ រួចក្រាបទូលសួរប្រស្នា នឹងព្រះមានព្រះភាគតទៅទៀតថា បពិត្រព្រះអង្គដ៏ចំរើន ចុះបុគ្គលកាលដឹងដូចម្តេច ឃើញដូចម្តេច ទើបអនុស័យគឺសេចក្តីប្រកាន់អហង្ការមមង្ការ មិនមាន ក្នុងកាយដែលប្រកបដោយវិញ្ញាណនេះ និងក្នុងនិមិត្តទាំងពួងជាខាងក្រៅ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុ រូបណានីមួយ ជាអតីត អនាគត បច្ចុប្បន្ន ជាខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី ដែលមានក្នុងទីឆ្ងាយឬក្នុងទីជិត បុគ្គលឃើញរូបទាំងអស់នុ៎ះ ដោយប្រាជ្ញាដ៏ប្រពៃ តាមសេចក្តីពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ ។ វេទនាណានីមួយ ។ សញ្ញាណានីមួយ ។ សង្ខារទាំងឡាយណានីមួយ ។ វិញ្ញាណណានីមួយ ជាអតីត អនាគត បច្ចុប្បន្ន ជាខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី ដែលមានក្នុងទីឆ្ងាយឬក្នុងទីជិត បុគ្គលឃើញនូវវិញ្ញាណទាំងអស់នុ៎ះ ដោយប្រាជ្ញាដ៏ប្រពៃ តាមសេចក្តីពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ ។

ឯវំ ខោ ភិក្ខុ ជានតោ ឯវំ បស្សតោ ឥមស្មិញ្ច សវិញ្ញាណកេ កាយេ ពហិទ្ធា ច សព្វនិមិត្តេសុ អហង្ការមមង្ការមានានុសយា ន ហោន្តីតិ ។

(១៩២) តេន ខោ បន សមយេន អញ្ញតរស្ស ភិក្ខុនោ ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ ឥតិ កិរ ភោ រូបំ អនត្តា ។ វេទនា ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ អនត្តា អនត្តកតានិ កម្មានិ កមត្តានំ ផុសិស្សន្តីតិ ។ អថ ខោ ភគវា តស្ស ភិក្ខុនោ ចេតសា ចេតោបរិវិតក្កមញ្ញាយ ភិក្ខូ អាមន្តេសិ ឋានំ ខោ បនេតំ ភិក្ខវេ វិជ្ជតិ យំ ឥធេកច្ចោ មោឃបុរិសោ អវិជ្ជាគតោ តណ្ហាធិគតេន ចេតសា សត្ថុសាសនំ អតិធាវិតព្វំ មញ្ញេយ្យ ឥតិ កិរ ភោ រូបំ អនត្តា ។ វេទនា ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ អនត្តា អនត្តកតានិ កម្មានិ កមត្តានំ ផុសិស្សន្តីតិ ។ បដិបុច្ឆា វិនីតា ខោ មេ តុម្ហេ ភិក្ខវេ តត្រ តត្រ តេសុ តេសុ ធម្មេសុ តំ កឹ មញ្ញថ ភិក្ខវេ រូបំ និច្ចំ វា អនិច្ចំ វាតិ ។

ម្នាលភិក្ខុ កាលបុគ្គលដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ទើបអនុស័យគឺសេចក្តីប្រកាន់អហង្ការ មមង្ការ មិនមានក្នុងកាយ ដែលប្រកបដោយវិញ្ញាណនេះ និងក្នុងនិមិត្តទាំងពួងជាខាងក្រៅ ។

(១៩២) សម័យនោះឯង ភិក្ខុមួយរូបមានគំនិតត្រិះរិះកើតឡើងយ៉ាងនេះថា ឱហ្ន៎ រូបជាអនត្តា ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណជាអនត្តា កម្មទាំងឡាយដែលអនត្តាធ្វើហើយ គង់នឹងបាននូវអត្តា ព្រោះកម្ម ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ជ្រាបគំនិតត្រិះរិះក្នុងចិត្ត របស់ភិក្ខុនោះហើយ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ហេតុនុ៎ះ រមែងមានជាប្រាកដ ត្រង់ដែល មោឃបុរសពួកខ្លះ ក្នុងលោកនេះ ជាអ្នកប្រកប ដោយអវិជ្ជា មានចិត្តលុះ ក្នុងអំណាចតណ្ហា មុខជាសំគាល់ នូវសាសនានៃព្រះសាស្តាដែលខ្លួនត្រូវកាន់ថា ឱហ្ន៎ រូបជាអនត្តា ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណជាអនត្តា កម្មទាំងឡាយដែលអនត្តាធ្វើហើយ គង់នឹងបាននូវអត្តា ព្រោះកម្ម ។ ម្នាលភិក្ខុទាំងឡាយ ការបុច្ឆាតបពាក្យសួរ តថាគតបានពន្យល់ហើយ ម្នាលភិក្ខុទាំងឡាយ ចុះអ្នកទាំងឡាយ យល់សេចក្តីនោះ ក្នុងធម៌ទាំងនោះ ក្នុងទីនោះៗ ថាដូចម្តេច ម្នាលភិក្ខុទាំងឡាយ រូបទៀង ឬមិនទៀង ។

អនិច្ចំ ភន្តេ ។ វេទនា ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ តស្មាតិហ ។បេ។ ឯវំ បស្សំ ។បេ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

ទ្វេ ខន្ធា តញ្ញេវ សិយំ
អនិច្ចំ ច ហេតុនា
សក្កាយេន ទុវេ វុត្តា
អស្សាទវិញ្ញាណកេន ច
ឯតេ ទសវិធា វុត្តា
ហោតិ ភិក្ខុ បុដ្ឋាយាតិ ។

ខន្ធិយវគ្គោ តតិយោ ។

មិនទៀងទេ ព្រះអង្គ ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណា មិនទៀង របស់នោះជាទុក្ខ ឬជាសុខ ។ បពិត្រព្រះអង្គដ៏ចម្រើន របស់នោះជាទុក្ខ ។ ចុះរបស់ណា មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរនឹងយល់ឃើញ នូវរបស់នោះថា នុ៎ះជារបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនគួរនឹងយល់ឃើញយ៉ាងនុ៎ះទេ ។ ព្រោះហេតុនោះ អរិយសាវ័កក្នុងសាសនានេះ ។ បេ ។ កាលយល់ឃើញយ៉ាងនេះ ។ បេ ។ ក៏ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

និយាយអំពីខន្ធ ២ លើក អំពីឧបាទាននោះឯង ដែលជារបស់គួរត្រេកអរ ១ អំពីឈ្មោះរបស់ខ្លួន ១ អំពីហេតុ ១ អំពីសក្កាយទិដ្ឋិ ដែលព្រះមានព្រះភាគ ទ្រង់សំដែង ២ លើក អំពីអានិសង្ស ១ អំពីវិញ្ញាណ ១ អំពីភិក្ខុសួរប្រស្នា ១ ទាំង ១០ នេះ ព្រះមានព្រះភាគ ពោលហើយ ។

ចប់ ខជ្ជនីយវគ្គ ទី ៣ ។

## តត្រុទ្ទានំ

អស្សាទោ ទ្វេ សមុទយា
អរហន្តេហិ អបរេ ទ្វេ
សីហោ ខជ្ជនិ បិណ្ឌោល្យំ
ចាលិលេយ្យេន បុណ្ណមាតិ ។

---

# ឧទ្ទានក្នុងខជ្ជនីយវគ្គនោះគឺ

និយាយអំពីអាទិសង្ស ១ អំពីការកើតនៃរូប មាន ២ លើក អំពីការយល់ឃើញរបស់ព្រះអរហន្ត និងសមណព្រាហ្មណ៍ ដទៃទៀតមាន ២ លើក អំពីព្រះសម្មាសម្ពុទ្ធប្រៀបដូចស្តេចសីហៈ ១ អំពីការទំពាស៊ីដោយសាររូបជាដើម ១ អំពីព្រះសម្មាសម្ពុទ្ធទ្រង់ស្តេចទៅបិណ្ឌបាត ក្នុងក្រុងកបិលពស្តុ ១ អំពីព្រះសម្មាសម្ពុទ្ធទ្រង់គង់ ក្នុងនគរបាលិលេយ្យ ១ អំពីព្រះសម្មាសម្ពុទ្ធ ទ្រង់គង់ក្នុងទីវាល នារាត្រីពេញបូណ៌មី ១ ។

---

# ថេរវគ្គោ

(១៩៣) សាវត្ថិយំ វិហរតិ ។ អារាមេ ។ តត្រ ខោ អាយស្មា អានន្ទោ ភិក្ខូ អាមន្តេសិ អាវុសោ ភិក្ខវេតិ ។ អាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ អានន្ទស្ស បច្ចស្សោសុំ ។ អាយស្មា អានន្ទោ ឯតទវោច បុណ្ណោ នាម អាវុសោ អាយស្មា មន្តានិបុត្តោ អម្ហាកំ នវកានំ សតំ ពហូបការោ ហោតិ សោ អម្ហេ ឥមិនា ឱវាទេន ឱវទតិ ឧបាទាយ អាវុសោ អានន្ទ អស្មីតិ ហោតិ នោ អនុបាទាយ ។ កិញ្ច ឧបាទាយ អស្មីតិ ហោតិ នោ អនុបាទាយ ។ រូបំ ឧបាទាយ អស្មីតិ ហោតិ នោ អនុបាទាយ ។ វេទនំ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ ឧបាទាយ អស្មីតិ ហោតិ នោ អនុបាទាយ ។ សេយ្យថាបិ អាវុសោ អានន្ទ ឥត្ថី វា បុរិសោ វា ទហរោ យុវា មណ្ឌនកជាតិកោ

# ថេរវគ្គ

(១៩៣) ទ្រង់គង់នៅ ជិតក្រុងសាវត្ថី ។ ក្នុងវត្ត ។ ក្នុងទីនោះ ព្រះអានន្ទ មានអាយុ ហៅភិក្ខុទាំងឡាយថា អាវុសោភិក្ខុទាំងឡាយ ។ ភិក្ខុអម្បាលនោះ ទទួលថេរពាក្យរបស់ព្រះអានន្ទមានអាយុថា អាវុសោ ។ ព្រះអានន្ទមានអាយុនិយាយដូច្នេះថា អាវុសោទាំងឡាយ ព្រះបុណ្ណមន្តានីបុត្ត មានអាយុ លោកមានឧបការៈច្រើនដល់យើងទាំងឡាយ ដែលជាភិក្ខុថ្មីច្រើនរូប លោកតែងទូន្មានយើងទាំងឡាយ ដោយឱវាទនេះថា ម្នាលអាវុសោអានន្ទ សេចក្តីប្រកាន់ថាអញ រមែងមាន ព្រោះអាស្រ័យហេតុ មិនមាន ព្រោះមិនអាស្រ័យហេតុ ។ ចុះសេចក្តីប្រកាន់ ថាអញ រមែងមាន ព្រោះអាស្រ័យហេតុអ្វី មិនមាន ព្រោះមិនអាស្រ័យហេតុអ្វី ។ សេចក្តីប្រកាន់ថាអញ រមែងមាន ព្រោះអាស្រ័យរូប មិនមាន ព្រោះមិនអាស្រ័យរូប ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ សេចក្តីប្រកាន់ថាអញ រមែងមាន ព្រោះអាស្រ័យវិញ្ញាណ មិនមាន ព្រោះមិនអាស្រ័យវិញ្ញាណ ។ ម្នាលអាវុសោអានន្ទ ស្ត្រីឬបុរស កំពុងពេញកំលោះ ពេញក្រមុំ មានជាតិជាអ្នកចូលចិត្ត នឹងការស្អិតស្អាង

អាទាសេ វា បរិសុទ្ធេ បរិយោទាតេ អច្ឆេ វា ឧទកបត្តេ សកំ មុខនិមិត្តំ បច្ចវេក្ខមានោ ឧបាទាយ បស្សេយ្យ នោ អនុបាទាយ ។ ឯវមេវ ខោ អាវុសោ អានន្ទ រូបំ ឧបាទាយ អស្មីតិ ហោតិ នោ អនុបាទាយ ។ វេទនំ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ ឧបាទាយ អស្មីតិ ហោតិ នោ អនុបាទាយ ។ តំ កឹ មញ្ញសិ អាវុសោ អានន្ទ រូបំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ អាវុសោ ។ វេទនា ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ អាវុសោ ។ តស្មាតិហ ។ បេ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។ បុណ្ណោ នាម អាវុសោ អាយស្មា មន្តានីបុត្តោ អម្ហាកំ នវកានំ សតំ ពហុបការោ ហោតិ សោ អម្ហេ ឥមិនា ឱវាទេន ឱវទតិ ឥទំ បន មេ អាយស្មតោ បុណ្ណស្ស មន្តានីបុត្តស្ស ធម្មទេសនំ សុត្វា ធម្មោ អភិសមិតោតិ ។

កាលពិនិត្យមើលនិមិត្តមុខរបស់ខ្លួន ក្នុងកញ្ចក់ដ៏បរិសុទ្ធស្អាតឬក្នុងភាជន:ទឹកដ៏ថ្លា ក៏ឃើញព្រោះអាស្រ័យកញ្ចក់ ឬភាជន:ទឹក មិនឃើញព្រោះមិនអាស្រ័យកញ្ចក់ឬភាជន:ទឹក ដូចម្តេចមិញ ។ ម្នាលអាវុសោអានន្ទ សេចក្តីប្រកាន់ ថាអញ រមែងមាន ព្រោះអាស្រ័យរូប មិនមាន ព្រោះមិនអាស្រ័យរូប ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ សេចក្តីប្រកាន់ ថាអញ រមែងមាន ព្រោះអាស្រ័យវិញ្ញាណ មិនមាន ព្រោះមិនអាស្រ័យវិញ្ញាណ ក៏ដូច្នោះដែរ ។ ម្នាលអាវុសោអានន្ទ អ្នកយល់សេចក្តីនោះដូចម្តេច រូបទៀងឬមិនទៀង ។ ម្នាលអាវុសោ មិនទៀងទេ ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណ ទៀង ឬមិនទៀង ។ ម្នាលអាវុសោ មិនទៀងទេ ។ ព្រោះហេតុនោះ អរិយសាវកក្នុងសាសនានេះ ។ បេ ។ ការយល់ឃើញយ៉ាងនេះ ។ បេ ។ ក៏ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលអាវុសោ ព្រះបុណ្ណមន្តានីបុត្ត មានអាយុ លោកមានឧបការ:ច្រើន ដល់យើងទាំងឡាយ ដែលជាភិក្ខុថ្មីច្រើនរូប លោកតែងទូន្មានយើងដោយឱវាទនេះ មួយទៀត ធម៌ដែលយើងបានសម្រេចហើយ ក៏ព្រោះតែស្តាប់ធម៌ទេសនា របស់ព្រះបុណ្ណ-មន្តានីបុត្តមានអាយុនេះឯង ។

(១៩៦) សាវត្ថិយំ វិហរតិ ។ អារាមេ ។ តេន ខោ
បន សមយេន អាយស្មា តិស្សោ ភគវតោ បិតុច្ឆាបុត្តោ
សម្ពហុលានំ ភិក្ខូនំ ឯវមារោចេតិ អបិ មេ អាវុសោ
មធុរកជាតោ វិយ កាយោ ទិសាបិ មេ ន បក្ខាយន្តិ
ធម្មាបិ មំ នប្បដិភន្តិ ថីនមិទ្ធញ្ច មេ ចិត្តំ បរិយា-
ទាយ តិដ្ឋតិ អនភិរតោ ច ព្រហ្មចរិយំ ចរាមិ ហោតិ
ច មេ ធម្មេសុ វិចិកិច្ឆាតិ ។

(១៩៧) អថខោ សម្ពហុលា ភិក្ខូ យេន ភគវា
តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯក-
មន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ
ភគវន្តំ ឯតទវោចុំ អាយស្មា ភន្តេ តិស្សោ ភគវតោ
បិតុច្ឆាបុត្តោ សម្ពហុលានំ ភិក្ខូនំ ឯវមារោចេតិ អបិ
មេ អាវុសោ មធុរកជាតោ វិយ កាយោ ទិសាបិ
មេ ន បក្ខាយន្តិ ធម្មាបិ មំ នប្បដិភន្តិ ថីនមិទ្ធញ្ច
មេ ចិត្តំ បរិយាទាយ តិដ្ឋតិ អនភិរតោ ច ព្រហ្មចរិ-
យំ ចរាមិ ហោតិ ច មេ ធម្មេសុ វិចិកិច្ឆាតិ ។

[ ១៩៨ ] ទ្រង់គង់នៅជិតក្រុងសាវត្ថី ។ គង់វត្ត ។ ក៏សម័យនោះឯង ព្រះតិស្សៈមានអាយុជាបុត្តនៃព្រះបិតុច្ឆា របស់ព្រះមានព្រះភាគ បាននិយាយប្រាប់ភិក្ខុទាំងឡាយជាច្រើនរូប យ៉ាងនេះថា ម្នាលអាវុសោ កាយរបស់ខ្ញុំដូចជាសត្វដែលធ្វើនូវរសផ្អែម (មានឃ្មុំជាដើម) ទិសទាំងឡាយមិនប្រាកដដល់ខ្ញុំ ធម៌ទាំងឡាយ មិនភ្លឺដល់ខ្ញុំ ព្រោះថីនមិទ្ធៈ គ្របសង្កត់ចិត្តរបស់ខ្ញុំ ខ្ញុំមិនត្រេកអរនឹងប្រព្រឹត្តព្រហ្មចរិយៈផង ខ្ញុំមានសេចក្តីសង្ស័យក្នុងធម៌ទាំងឡាយផង ។

[ ១៩៩ ] លំដាប់នោះ ភិក្ខុទាំងឡាយច្រើនរូប ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុអម្បាលនោះ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះតិស្សៈមានអាយុ ជាបុត្តនៃព្រះបិតុច្ឆា របស់ព្រះមានព្រះភាគ និយាយប្រាប់ភិក្ខុទាំងឡាយច្រើនរូបយ៉ាងនេះថា ម្នាលអាវុសោ កាយរបស់ខ្ញុំដូចសត្វដែលធ្វើនូវរសផ្អែម ទិសទាំងឡាយមិនប្រាកដដល់ខ្ញុំ ធម៌ទាំង-ឡាយមិនភ្លឺដល់ខ្ញុំ ព្រោះថីនមិទ្ធៈគ្របសង្កត់ចិត្តរបស់ខ្ញុំ ខ្ញុំមិនត្រេកអរនឹងប្រព្រឹត្តព្រហ្មចរិយៈផង ខ្ញុំមានសេចក្តីសង្ស័យក្នុងធម៌ទាំងឡាយផង ។

អថខោ ភគវា អញ្ញតរំ ភិក្ខុំ អាមន្តេសិ ឯហិ ត្វំ ភិក្ខុ មម វចនេន តិស្សំ ភិក្ខុំ អាមន្តេហិ សត្ថា តំ អាវុសោ តិស្ស អាមន្តេតីតិ ។ ឯវំ ភន្តេតិ ខោ សោ ភិក្ខុ ភគវតោ បដិស្សុត្វា យេនាយស្មា តិស្សោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ តិស្សំ ឯតទវោច សត្ថា តំ អាវុសោ តិស្ស អាមន្តេតីតិ ។ ឯវំ អាវុសោតិ ខោ អាយស្មា តិស្សោ តស្ស ភិក្ខុនោ បដិស្សុត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ តិស្សំ ភគវា ឯតទវោច សច្ចំ កិរ ត្វំ តិស្ស សម្ពហុលានំ ភិក្ខូនំ ឯវមារោចេសិ អបិ មេ អាវុសោ មធុរកជាតោ វិយ កាយោ ។ បេ ។ ហោតិ ច មេ ធម្មេសុ វិចិកិច្ឆាតិ ។ ឯវំ ភន្តេ ។

លំដាប់នោះ ព្រះមានព្រះភាគ ត្រាស់ហៅភិក្ខុមួយរូបមកថា ម្នាលភិក្ខុ អ្នកចូរចូលមកអាយ អ្នកចូរហៅតិស្សភិក្ខុ តាមពាក្យតថាគតថា ម្នាលអាវុសោតិស្សៈ ព្រះសាស្តាត្រាស់ហៅលោក ។ ភិក្ខុនោះទទួលព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ហើយចូលទៅរកព្រះតិស្សៈ មានអាយុ លុះចូលទៅដល់ ក៏ប្រាប់ព្រះតិស្សៈមានអាយុ ដូច្នេះថា ម្នាលអាវុសោតិស្សៈ ព្រះសាស្តាទ្រង់ត្រាស់ហៅលោក ។ ព្រះតិស្សៈមានអាយុ ទទួលស្តាប់ពាក្យរបស់ភិក្ខុនោះថា ករុណា អាវុសោ ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះតិស្សៈមានអាយុ អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលតិស្សៈ ឮថាអ្នកនិយាយនឹងភិក្ខុទាំងឡាយច្រើនរូបយ៉ាងនេះថា ម្នាលអាវុសោ កាយរបស់ខ្ញុំ ដូចជាសត្វដែលធ្វើនូវរសផ្អែម ។បេ។ ខ្ញុំមានសេចក្តីសង្ស័យក្នុងធម៌ទាំងឡាយផង ដូច្នេះពិតឬ ។ ព្រះតិស្សៈមានអាយុក្រាបបង្គំទូលថា យ៉ាងនុ៎ះមែន ព្រះអង្គ ។

តំ កឹ មញ្ញសិ តិស្ស រូបេ អវីតរាគស្ស អវីតច្ឆន្ទស្ស អវីតប្បេមស្ស អវីតបិបាសស្ស អវីតបរិឡាហស្ស អវីតតណ្ហស្ស តស្ស រូបស្ស វិបរិណាមញ្ញថាភាវា ឧប្បជ្ជន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសាតិ ។ ឯវំ ភន្តេ ។ សាធុ សាធុ តិស្ស ឯវំ ហោតំ តិស្ស ហោតិ យថា តំ រូបេ អវីតរាគស្ស ។ វេទនាយ ។ សញ្ញាយ ។ សង្ខារេសុ អវីតរាគស្ស ។ បេ ។ តេសំ សង្ខារានំ វិបរិណាមញ្ញថាភាវា ឧប្បជ្ជន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសាតិ ។ ឯវំ ភន្តេ ។ សាធុ សាធុ តិស្ស ឯវំ ហោតំ តិស្ស ហោតិ យថា តំ សង្ខារេសុ អវីតរាគស្ស ។

ម្នាលតិស្សៈ អ្នកសំគាល់សេចក្ដីនោះដូចម្ដេច កាលបើបុគ្គលមានតម្រេកមិនទាន់ទៅប្រាស មានសេចក្ដីពេញចិត្តមិនទាន់ទៅប្រាស មានសេចក្ដីស្រឡាញ់មិនទាន់ទៅប្រាស មានសេចក្ដីស្រេកឃ្លានមិនទាន់ទៅប្រាស មានសេចក្ដីក្រហល់ក្រហាយមិនទាន់ទៅប្រាស មានតណ្ហាមិនទាន់ទៅប្រាសចាករូបទេ សេចក្ដីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ការតានតឹងក្នុងចិត្តទាំងឡាយតែងកើតឡើង ព្រោះសេចក្ដីប្រែប្រួលទៅជាយ៉ាងដទៃនៃរូបនោះឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលតិស្សៈ ប្រពៃហើយ ប្រពៃហើយ ម្នាលតិស្សៈ កាលបើបុគ្គលមានតម្រេកមិនទាន់ទៅប្រាសចាករូប យ៉ាងណា ដំណើរនុ៎ះរមែងមាន យ៉ាងនុ៎ះឯង ។ កាលបើបុគ្គលមានតម្រេកមិនទាន់ទៅប្រាសចាកវេទនា ។ ចាកសញ្ញា ។ ចាកសង្ខារទាំងឡាយ ។បេ។ សេចក្ដីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ការតានតឹងក្នុងចិត្តទាំងឡាយតែងកើតឡើង ព្រោះសេចក្ដីប្រែប្រួលទៅជាយ៉ាងដទៃនៃសង្ខារទាំងនោះឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលតិស្សៈប្រពៃហើយ ប្រពៃហើយ ម្នាលតិស្សៈ កាលបើបុគ្គលមានតម្រេកមិនទាន់ទៅប្រាសចាកសង្ខារទាំងឡាយ យ៉ាងណា ដំណើរនុ៎ះរមែងមាន យ៉ាងនុ៎ះឯង ។

វិញ្ញាណេ អវីតរាគស្ស អវីតច្ឆន្ទស្ស អវីតបេមស្ស អវីតបិបាសស្ស អវីតបរិឡាហស្ស អវីតតណ្ហាស្ស តស្ស វិញ្ញាណស្ស វិបរិណាមញ្ញថាភាវា ឧប្បជ្ជន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសាតិ ។ ឯវំ ភន្តេ ។ សាធុ សាធុ តិស្ស ឯវំ ហេតំ តិស្ស ហោតិ យថា តំ វិញ្ញាណេ អវីតរាគស្ស ។

(១៩៦) តំ កឹ មញ្ញសិ តិស្ស រូបេ វីតរាគស្ស វីតច្ឆន្ទស្ស វីតបេមស្ស វីតបិបាសស្ស វីតបរិឡាហស្ស វីតតណ្ហាស្ស តស្ស រូបស្ស វិបរិណាមញ្ញថាភាវា ឧប្ប-ជ្ជន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសាតិ ។ នោ ហេតំ ភន្តេ ។ សាធុ សាធុ តិស្ស ឯវំ ហេតំ តិស្ស

កាលបើបុគ្គល មានតម្រេកមិនទាន់ទៅប្រាស មានសេចក្តីពេញចិត្តមិនទាន់ទៅប្រាស មានសេចក្តីស្រឡាញ់មិនទាន់ទៅប្រាស មានសេចក្តីស្រេកឃ្លានមិនទាន់ទៅប្រាស មានសេចក្តីក្រហល់ក្រហាយមិនទាន់ទៅប្រាស មានតណ្ហាមិនទាន់ទៅប្រាសចាកវិញ្ញាណ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស សេចក្តីតានតឹងក្នុងចិត្តទាំងឡាយ តែងកើតឡើង ព្រោះសេចក្តីប្រែប្រួលទៅជាយ៉ាងដទៃ នៃវិញ្ញាណនោះឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលតិស្សៈ ប្រពៃហើយ ប្រពៃហើយ ម្នាលតិស្សៈ កាលបើបុគ្គល មានតម្រេកមិនទាន់ទៅប្រាសចាកវិញ្ញាណ យ៉ាងណា ដំណើរនុះ រមែងមានយ៉ាងនុះឯង ។

[១៩៦] ម្នាលតិស្សៈ អ្នកសំគាល់សេចក្តីនោះដូចម្តេច កាលបើបុគ្គល មានតម្រេកទៅប្រាសហើយ មានសេចក្តីពេញចិត្តទៅប្រាសហើយ មានសេចក្តីស្រឡាញ់ទៅប្រាសហើយ មានសេចក្តីស្រេកឃ្លានទៅប្រាសហើយ មានសេចក្តីក្រហល់ក្រហាយទៅប្រាសហើយ មានតណ្ហាទៅប្រាសហើយ ចាករូប តើសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស សេចក្តីតានតឹងក្នុងចិត្តទាំងឡាយកើតឡើង ព្រោះសេចក្តីប្រែប្រួលទៅជាយ៉ាងដទៃ នៃរូបនោះដែរឬ ។ មិនដូច្នោះទេ ព្រះអង្គ ។ ម្នាលតិស្សៈ ប្រពៃហើយ ប្រពៃហើយ ម្នាលតិស្សៈ

ហោតិ យថា តំ រូបេ វីតរាគស្ស ។ វេទនាយ ។ សញ្ញា-
យ ។ សង្ខារេសុ ។ វិញ្ញាណេ វីតរាគស្ស វីតច្ឆន្ទស្ស
វីតប្បេមស្ស វីតបិបាសស្ស វីតបរិឡាហស្ស វីតតណ្ហា-
ស្ស តស្ស វិញ្ញាណស្ស វិបរិណាមញ្ញថាភាវា ឧប្បជ្ជន្តិ
សោកបរិទេវទុក្ខទោមនស្សុបាយាសាតិ ។ នោ ហោតិ
ភន្តេ ។ សាធុ សាធុ តិស្ស ឯវំ ហោតិ តិស្ស ហោតិ
យថា តំ វិញ្ញាណេ វីតរាគស្ស ។ តំ កឹ មញ្ញសិ
តិស្ស រូបំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ បេ ។
វេទនា ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ និច្ចំ វា អនិច្ចំ
វាតិ ។ អនិច្ចំ ភន្តេ ។ បេ ។ តស្មាតិហ ។ បេ ។ ឯវំ
បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។

កាលបើបុគ្គលមានតម្រេកទៅប្រាសហើយចាករូប យ៉ាងណា ដំណើរនុ៎ះរមែងមានយ៉ាងនុ៎ះឯង ។ កាលបើបុគ្គល មានតម្រេកទៅប្រាសហើយ មានសេក្តីពេញចិត្តទៅប្រាសហើយ មានសេចក្តីស្រឡាញ់ទៅប្រាសហើយ មានសេចក្តីស្រេកឃ្លានទៅប្រាសហើយ មានសេចក្តីក្រហល់ក្រហាយទៅប្រាសហើយ មានតណ្ហាទៅប្រាសហើយ ចាកវេទនា ។ ចាកសញ្ញា ។ ចាកសង្ខារទាំងឡាយ ។ ចាកវិញ្ញាណ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស សេចក្តីតានតឹងក្នុងចិត្ត តែងកើតឡើង ព្រោះសេចក្តីប្រែប្រួលទៅជាយ៉ាងដទៃ នៃវិញ្ញាណនោះដែរឬ ។ មិនដូច្នោះទេ ព្រះអង្គ ។ ម្នាលតិស្សៈ ប្រពៃហើយ ប្រពៃហើយ ម្នាលតិស្សៈ កាលបើបុគ្គល មានតម្រេកទៅប្រាសហើយចាកវិញ្ញាណយ៉ាងណា ដំណើរនុ៎ះរមែងមានយ៉ាងនុ៎ះឯង ។ ម្នាលតិស្សៈ អ្នកសំគាល់សេចក្តីនោះដូចម្តេច រូបទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ បេ ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ បេ ។ ព្រោះហេតុនោះ អរិយសាវកក្នុងសាសនានេះ ។ បេ ។ យល់ឃើញយ៉ាងនេះ ។ បេ ។ ក៏ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

(១៩៧) សេយ្យថាបិ តិស្ស ទ្វេ បុរិសា ឯកោ បុរិសោ អមគ្គកុសលោ ឯកោ បុរិសោ មគ្គកុសលោ តមេនំ សោ អមគ្គកុសលោ បុរិសោ អមុំ មគ្គកុសលំ បុរិសំ មគ្គំ បុច្ឆេយ្យ សោ ឯវំ វទេយ្យ ឯហិ ភោ បុរិស អយំ មគ្គោ តេន មុហុត្តំ គច្ឆ តេន មុហុត្តំ គន្ត្វា ទក្ខិស្សសិ ទ្វេធាបថំ តត្ថ វាមំ មុញ្ចិត្វា ទក្ខិណំ គណ្ហា តេន មុហុត្តំ គច្ឆ តេន មុហុត្តំ គន្ត្វា ទក្ខិស្សសិ តិព្វំ វនសណ្ឌំ តេន មុហុត្តំ គច្ឆ តេន មុហុត្តំ គន្ត្វា ទក្ខិស្សសិ មហន្តំ និន្នំ បល្លលំ តេន មុហុត្តំ គច្ឆ តេន មុហុត្តំ គន្ត្វា ទក្ខិស្សសិ សោព្ភំ បបាតំ តេន មុហុត្តំ គច្ឆ តេន មុហុត្តំ គន្ត្វា ទក្ខិស្សសិ សមំ ភូមិភាគំ រមណីយំ ។ ឧបមា ខោ ម្យាយំ តិស្ស កតា អត្ថស្ស វិញ្ញាបនាយ អយំ ចេវេត្ថ អត្ថោ ។

(១៩៧) ព្រះមានព្រះភាគត្រាស់ថា ម្នាលតិស្សៈ ដូចជាបុរសពីរនាក់ បុរសម្នាក់ជាអ្នកមិនស្ទាត់ក្នុងផ្លូវ បុរសម្នាក់ជាអ្នកស្ទាត់ក្នុងផ្លូវ បុរសដែលមិនស្ទាត់ក្នុងផ្លូវនោះ សួរផ្លូវឯណោះ នឹងបុរសដែលស្ទាត់ក្នុងផ្លូវនោះ បុរសដែលស្ទាត់ក្នុងផ្លូវប្រាប់យ៉ាងនេះថា ម្នាលបុរសដ៏ចម្រើន នេះផ្លូវ ចូរអ្នកទៅតាមផ្លូវនោះបន្តិចចុះ លុះអ្នកទៅតាមផ្លូវនោះបន្តិចទៅ នឹងឃើញផ្លូវបែកជាពីរ បណ្ដាផ្លូវទាំងពីរនោះ ចូរអ្នកលះបង់ផ្លូវខាងឆ្វេង កាន់យកផ្លូវខាងស្ដាំ ចូរអ្នកទៅតាមផ្លូវខាងស្ដាំនោះបន្តិចទៀត លុះអ្នកទៅតាមផ្លូវខាងស្ដាំនោះបន្តិចទៅ នឹងបានឃើញដងព្រៃស្រោង ចូរអ្នកទៅតាមដងព្រៃស្រោងនោះ បន្តិចទៀត លុះអ្នកទៅតាមដងព្រៃស្រោងនោះ បន្តិចទៅ នឹងបានឃើញល្បាប់ទំនាបធំ ចូរអ្នកទៅតាមល្បាប់ទំនាបធំនោះ បន្តិចទៀត លុះអ្នកទៅតាមល្បាប់ទំនាបធំនោះបន្តិចទៅ នឹងបានឃើញអូរនិងជ្រោះ ចូរអ្នកទៅតាមអូរនិងជ្រោះនោះបន្តិចទៀត លុះអ្នកទៅតាមអូរនិងជ្រោះនោះបន្តិចទៅ នឹងបានឃើញភូមិភាគដ៏រាបស្មើគួរជាទីត្រេកអរ ។ ម្នាលតិស្សៈ តថាគតធ្វើសេចក្ដីឧបមានេះ ដើម្បីឲ្យអ្នកយល់សេចក្ដី នេះឯងជាសេចក្ដីអធិប្បាយក្នុងដំណើរនុ៎ះ ។

បុរិសោ អមគ្គកុសលោតិ ខោ តិស្ស បុថុជ្ជនស្សេតំ អធិវចនំ ។ បុរិសោ មគ្គកុសលោតិ ខោ តិស្ស តថាគតស្សេតំ អធិវចនំ អរហតោ សម្មាសម្ពុទ្ធស្ស ។ ទ្វេធាបថោតិ ខោ តិស្ស វិចិកិច្ឆាយេតំ អធិវចនំ ។ វាមោ មគ្គោតិ ខោ តិស្ស អដ្ឋង្គិកស្សេតំ មិច្ឆាមគ្គស្ស អធិវចនំ ។ សេយ្យថីទំ ។ មិច្ឆាទិដ្ឋិយា ។បេ។ មិច្ឆាសមាធិស្ស ។ ទក្ខិណោ មគ្គោតិ ខោ តិស្ស អរិយស្សេតំ អដ្ឋង្គិកស្ស មគ្គស្ស អធិវចនំ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិយា ។បេ។ សម្មាសមាធិស្ស ។ តិព្វោ វនសណ្ឌោតិ ខោ តិស្ស អវិជ្ជាយេតំ អធិវចនំ ។ មហន្តំ និន្នំ បល្លលន្តិ ខោ តិស្ស កាមានមេតំ អធិវចនំ ។ សោព្ភោ បបាតោតិ ខោ តិស្ស កោធុបាយាសស្សេតំ អធិវចនំ ។ សមោ ភូមិភាគោ រមណីយោតិ ខោ តិស្ស និព្វានស្សេតំ អធិវចនំ ។ អភិរម តិស្ស

ម្នាលតិស្សៈ ពាក្យថា បុរសមិនស្ទាត់ក្នុងផ្លូវនុ៎ះ ជាឈ្មោះរបស់បុថុជ្ជន ។ ម្នាលតិស្សៈ ពាក្យថា បុរសស្ទាត់ក្នុងផ្លូវនុ៎ះ ជាឈ្មោះរបស់ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ។ ម្នាលតិស្សៈ ពាក្យថា ផ្លូវបែកជាពីរនុ៎ះ ជាឈ្មោះរបស់វិចិកិច្ឆា ។ ម្នាលតិស្សៈ ពាក្យថា ផ្លូវខាងឆ្វេងនុ៎ះ ជាឈ្មោះរបស់ផ្លូវខុសប្រកបដោយអង្គ ៨ ។ អង្គ ៨ តើដូចម្តេច ។ គឺមិច្ឆាទិដ្ឋិ ។ បេ ។ មិច្ឆាសមាធិ ។ ម្នាលតិស្សៈ ពាក្យថា ផ្លូវខាងស្តាំនុ៎ះជាឈ្មោះរបស់ផ្លូវ ប្រកបដោយអង្គ ៨ ។ អង្គ ៨ តើដូចម្តេច ។ គឺសម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ ម្នាលតិស្សៈ ពាក្យថា ដងព្រៃស្រោងនុ៎ះ ជាឈ្មោះរបស់អវិជ្ជា ។ ម្នាលតិស្សៈ ពាក្យថា ល្បាប់ទំនាបធំនុ៎ះ ជាឈ្មោះរបស់កាមទាំងឡាយ ។ ម្នាលតិស្សៈ ពាក្យថា អូរនិងជ្រោះនុ៎ះ ជាឈ្មោះរបស់សេចក្តីក្រោធនិងសេចក្តីតានតឹងក្នុងចិត្ត ។ ម្នាលតិស្សៈ ពាក្យថា ភូមិភាគដ៏រាបស្មើគួរជាទីត្រេកអរនុ៎ះ ជាឈ្មោះរបស់ព្រះនិព្វាន ។ ម្នាលតិស្សៈ ចូរអ្នកត្រេកអរចុះ

អភិរម តិស្ស អហោវាទេន អហមនុគ្គហេន អហមនុសាសនិយាតិ(១) ។ ឥទមវោច ភគវា ។ អត្តមនោ អាយស្មា តិស្សោ ភគវតោ ភាសិតំ អភិនន្ទីតិ ។

[១៩៨] ឯកំ សមយំ អាយស្មា សារីបុត្តោ សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្សារាមេ ។ តេន ខោ បន សមយេន យមកស្ស នាម ភិក្ខុនោ ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ ហោតិ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា ខីណាសវោ ភិក្ខុ កាយស្ស ភេទា ឧច្ឆិជ្ជតិ វិនស្សតិ ន ហោតិ បរម្មរណាតិ ។ អស្សោសុំ ខោ សម្ពហុលា ភិក្ខូ យមកស្ស កិរ នាម ភិក្ខុនោ ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ ហោតិ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា ខីណាសវោ ភិក្ខុ កាយស្ស ភេទា ឧច្ឆិជ្ជតិ វិនស្សតិ ន ហោតិ បរម្មរណាតិ ។ អថ ខោ តេ ភិក្ខូ យេនាយស្មា យមកោ តេនុបសង្កមឹសុ

១ ម. អហមាមិសធម្មានុគ្គហេន មមោវាទេន មមានុសាសនិយាតិ ។

ម្នាលតិស្សៈ ចូរអ្នកត្រេកអរចុះថា អាត្មាអញត្រេកអរដោយនុវាទ អាត្មាអញត្រេកអរ ដោយសេចក្តីអនុគ្រោះ អាត្មាអញត្រេកអរ ដោយពាក្យប្រៀនប្រដៅ ។ ព្រះមានព្រះភាគ បានត្រាស់ព្រះសូត្រនេះចប់ហើយ ។ ព្រះតិស្សៈមានអាយុ មានចិត្តត្រេកអររីករាយនឹងភាសិតរបស់ព្រះមានព្រះភាគ ។

[១៩៨] សម័យមួយ ព្រះសារីបុត្តមានអាយុ គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក៏សម័យនោះឯង ភិក្ខុឈ្មោះយមកៈ កើតទិដ្ឋិអាក្រក់មានសភាពយ៉ាងនេះថា អញយល់ច្បាស់នូវធម៌ដែលព្រះមានព្រះភាគសំដែងហើយថា ភិក្ខុជាខីណាស្រព តែងម្លាយកាយហើយ ខាងមុខអំពីសេចក្តីស្លាប់ទៅ រមែងដាច់សូន្យទៅ មិនកើតទៀតទេ ។ ភិក្ខុទាំងឡាយច្រើនរូប បានឮថា យមកភិក្ខុ កើតទិដ្ឋិអាក្រក់មានសភាពយ៉ាងនេះថា អញយល់ច្បាស់នូវធម៌ដែលព្រះមានព្រះភាគសំដែងហើយថា ភិក្ខុជាខីណាស្រព តែងម្លាយកាយហើយ ខាងមុខអំពីសេចក្តីស្លាប់ទៅ រមែងដាច់សូន្យទៅ មិនកើតទៀតទេ ។ លំដាប់នោះ ភិក្ខុអម្បាលនោះ ចូលទៅរកយមកភិក្ខុ

ឧបសង្កមិត្វា អាយស្មតា យមកេន សទ្ធឹ សម្មោ-
ទឹសុ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា
ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ
ភិក្ខូ អាយស្មន្តំ យមកំ ឯតទវោចុំ សច្ចំ កិរ
តេ អាវុសោ យមក ឯវរូបំ បាបកំ ទិដ្ឋិគតំ
ឧប្បន្នំ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ
យថា ខីណាសវោ ភិក្ខុ កាយស្ស ភេទា ឧច្ឆិជ្ជតិ វិ-
នស្សតិ ន ហោតិ បរម្មរណាតិ ។ ឯវំ ខ្វាហំ អាវុសោ
ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា ខីណាសវោ
ភិក្ខុ កាយស្ស ភេទា ឧច្ឆិជ្ជតិ វិនស្សតិ ន ហោតិ
បរម្មរណាតិ ។ មា អាវុសោ យមក ឯវំ អវច មា
ភគវន្តំ អព្ភាចិក្ខិ ន ហិ សាធុ ភគវតោ អព្ភក្ខានំ
ន ហិ ភគវា ឯវំ វទេយ្យ ខីណាសវោ ភិក្ខុ

មានអាយុ លុះចូលទៅដល់ហើយ ក៏ពក់ទាក់ជាមួយនឹងយមកភិក្ខុមានអាយុ លុះបញ្ចប់ពាក្យគួររីករាយនិងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះភិក្ខុអម្បាលនោះអង្គុយក្នុងទីសមគួរហើយ ទើបពោលនឹងយមកភិក្ខុមានអាយុដូច្នេះថា ម្នាលអាវុសោយមកៈ ឮថាលោកកើតទិដ្ឋិអាក្រក់ មានសភាពយ៉ាងនេះថា អញយល់ច្បាស់នូវធម៌ដែលព្រះមានព្រះភាគសំដែងហើយថា ភិក្ខុជាខីណាស្រព តែទម្លាយកាយហើយ ខាងមុខអំពីសេចក្ដីស្លាប់ទៅ រមែងដាច់សូន្យទៅ មិនកើតទៀត ដូច្នេះពិតឬ ។ យមកភិក្ខុមានអាយុ ឆ្លើយថា ម្នាលអាវុសោ យ៉ាងហ្នឹងមែនហើយ ខ្ញុំយល់ច្បាស់នូវធម៌ដែលព្រះមានព្រះភាគសំដែងហើយថា ភិក្ខុជាខីណាស្រព តែទម្លាយកាយហើយ ខាងមុខអំពីសេចក្ដីស្លាប់ទៅ រមែងដាច់សូន្យទៅ មិនកើតទៀតទេ ។ ម្នាលអាវុសោយមកៈ លោកកុំពោលយ៉ាងនេះឡើយ លោកកុំពោលបង្កាច់ព្រះមានព្រះភាគឡើយ ការពោលបង្កាច់ព្រះមានព្រះភាគ មិនល្អទេ ព្រោះព្រះមានព្រះភាគ មិនមែនត្រាស់យ៉ាងនេះថា ភិក្ខុជាខីណាស្រព

កាយស្ស ភេទា ឧច្ឆិជ្ជតិ វិនស្សតិ ន ហោតិ បរម្មរណាតិ ។ ឯវំ ខោ អាយស្មា យមកោ តេហិ ភិក្ខូហិ វុច្ចមានោ តថេវ តំ បាបកំ ទិដ្ឋិគតំ ថាមសា បរាមាសា អភិនិវិស្ស វោហរតិ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា ខីណាសវោ ភិក្ខុ កាយស្ស ភេទា ឧច្ឆិជ្ជតិ វិនស្សតិ ន ហោតិ បរម្មរណាតិ ។ យតោ ខោ តេ ភិក្ខូ នាសក្ខឹសុ អាយស្មន្តំ យមកំ ឯតស្មា បាបកា ទិដ្ឋិគតា វិវេចេតុំ ។ អថ ខោ តេ ភិក្ខូ ឧដ្ឋាយាសនា យេនាយស្មា សារីបុត្តោ តេនុបសង្កមឹសុ ឧបសង្កមិត្វា អាយស្មន្តំ សារីបុត្តំ ឯតទវោចុំ យមកស្ស នាម អាវុសោ សារីបុត្ត ភិក្ខុនោ ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា ខីណាសវោ ភិក្ខុ កាយស្ស ភេទា ឧច្ឆិជ្ជតិ វិនស្សតិ ន ហោតិ បរម្មរណាតិ សាធាយស្មា សារីបុត្តោ យេន យមកោ ភិក្ខុ តេនុបសង្កមតុ

តែទម្លាយកាយហើយ ខានមុខអំពីសេចក្តីស្លាប់ទៅ រមែងដាច់សូន្យមិនកើតទៀត យ៉ាងនេះទេ ។ កាលភិក្ខុអម្បាលនោះ ពោល (ហាមឃាត់) យ៉ាងនេះហើយ យមកភិក្ខុមានអាយុក៏នៅតែក្ដួបកាន់ ស្ទាបអង្អែលទិដ្ឋិអាក្រក់នោះ ដូច្នោះដដែល ហើយពោលថា ខ្ញុំយល់ច្បាស់នូវធម៌ដែលព្រះមានព្រះភាគសំដែងហើយថា ភិក្ខុជាខីណាស្រព តែទម្លាយកាយហើយ ខានមុខអំពីសេចក្តីស្លាប់ទៅ រមែងដាច់សូន្យបាត់ទៅ មិនកើតទៀតទេ ។ កាលបើភិក្ខុអម្បាលនោះ មិនអាចរំដោះយមកភិក្ខុមានអាយុ ចាកទិដ្ឋិអាក្រក់នេះបានទេ ។ ទើបភិក្ខុអម្បាលនោះ ក្រោកចាកអាសនៈ ចូលទៅរកព្រះសារីបុត្តមានអាយុ លុះចូលទៅដល់ហើយ ក៏ពោលនឹងព្រះសារីបុត្តមានអាយុដូច្នេះថា ម្នាលអាវុសោសារីបុត្ត យមកភិក្ខុកើតទិដ្ឋិអាក្រក់ មានសភាពយ៉ាងនេះថា អញយល់ច្បាស់នូវធម៌ដែលព្រះមានព្រះភាគសំដែងហើយថា ភិក្ខុជាខីណាស្រព តែទម្លាយកាយហើយ ខានមុខអំពីសេចក្តីស្លាប់ទៅ រមែងដាច់សូន្យទៅ មិនកើតទៀតទេ សូមព្រះសារីបុត្តមានអាយុ និមន្តចូលទៅរកយមកភិក្ខុ

អនុកម្បំ ឧបាទាយាតិ ។ អធិវាសេសិ ខោ អាយស្មា សារីបុត្តោ តុណ្ហីភាវេន ។

(១៩៩) អថខោ អាយស្មា សារីបុត្តោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេនាយស្មា យមកោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា យមកេន សទ្ធឹ សម្មោទិ ។បេ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ អាយស្មន្តំ យមកំ ឯតទវោច សច្ចំ កិរ តេ អាវុសោ យមក ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា ខីណាសវោ ភិក្ខុ កាយស្ស ភេទា ឧច្ឆិជ្ជតិ វិនស្សតិ ន ហោតិ បរម្មរណាតិ ។ ឯវំ ខ្វាហំ អាវុសោ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា ខីណាសវោ ភិក្ខុ កាយស្ស ភេទា ឧច្ឆិជ្ជតិ វិនស្សតិ ន ហោតិ បរម្មរណាតិ ។

ដើម្បីធ្វើនូវសេចក្តីអនុគ្រោះ ។ ព្រះសារីបុត្តមានអាយុ ក៏ទទួលដោយតុណ្ហីភាព ។

[១៩៩] លំដាប់នោះ ព្រះសារីបុត្តមានអាយុ ចេញអំពីទីសម្ងំក្នុងសាយណ្ហសម័យ ហើយចូលទៅរកយមកភិក្ខុមានអាយុ លុះចូលទៅដល់ ក៏ពោលពាក្យរាក់ទាក់ជាមួយនឹងយមកភិក្ខុមានអាយុ ។ បេ ។ លុះព្រះសារីបុត្តមានអាយុ គង់ក្នុងទីសមគួរហើយ ក៏ពោលនឹងយមកភិក្ខុមានអាយុ ដូច្នេះថា ម្នាលអាវុសោយមកៈ ឮថាលោកកើតទិដ្ឋិអាក្រក់មានសភាពយ៉ាងនេះថា អញយល់ច្បាស់នូវធម៌ដែលព្រះមានព្រះភាគសំដែងហើយថា ភិក្ខុជាខីណាស្រព តែទម្លាយកាយហើយ ខាងមុខអំពីសេចក្តីស្លាប់ទៅ រមែងដាច់សូន្យទៅ មិនកើតទៀត ដូច្នេះមែនឬ ។ យមកភិក្ខុមានអាយុឆ្លើយថា យ៉ាងហ្នឹងមែនហើយ ម្នាលអាវុសោ ខ្ញុំយល់ច្បាស់នូវធម៌ ដែលព្រះមានព្រះភាគសំដែងហើយ ថាភិក្ខុជាខីណាស្រព តែទម្លាយកាយហើយ ខាងមុខអំពីសេចក្តីស្លាប់ទៅ រមែងដាច់សូន្យទៅ មិនកើតទៀតទេ ។

តំ កឹ មញ្ញសិ អាវុសោ យមក រូបំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ អាវុសោ ។ វេទនា ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ អាវុសោ ។ តស្មាតិហ ។ បេ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។

[២០០] តំ កឹ មញ្ញសិ អាវុសោ យមក រូបំ តថាគតោតិ សមនុបស្សសីតិ ។ នោ ហេតំ អាវុសោ ។ វេទនំ តថាគតោតិ សមនុបស្សសីតិ ។ នោ ហេតំ អាវុសោ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ តថាគតោតិ សមនុបស្សសីតិ ។ នោ ហេតំ អាវុសោ ។

[២០១] តំ កឹ មញ្ញសិ អាវុសោ យមក រូបស្មឹ តថាគតោតិ សមនុបស្សសីតិ ។ នោ ហេតំ អាវុសោ ។ អញ្ញត្រ រូបា តថាគតោតិ សមនុបស្សសីតិ ។ នោ ហេតំ អាវុសោ ។ វេទនាយ ។ បេ ។ អញ្ញត្រ វេទនាយ ។ បេ ។ សញ្ញាយ ។ អញ្ញត្រ សញ្ញាយ ។ សង្ខារេសុ ។ អញ្ញត្រ សង្ខារេហិ ។

ម្នាលអាវុសោយមកៈ លោកសំគាល់សេចក្ដីនោះដូចម្ដេច រូបទៀងឬមិនទៀង ។ មិនទៀងទេ អាវុសោ ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណទៀងឬមិនទៀង ។ មិនទៀងទេ អាវុសោ ។ ព្រោះហេតុនោះ អរិយសាវកក្នុងសាសនានេះ ។ បេ ។ ឃើញយ៉ាងនេះ ។ បេ ។ ក៏ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

(២០០) ម្នាលអាវុសោយមកៈ លោកសំគាល់សេចក្ដីនោះដូចម្ដេច លោកពិចារណាឃើញរូប ថាជាសត្វឬ ។ មិនដូច្នោះទេ អាវុសោ ។ ព្រះសារីបុត្តសួរថា លោកពិចារណាឃើញវេទនា ថាជាសត្វឬ ។ មិនដូច្នោះទេ អាវុសោ ។ សញ្ញា ។ សង្ខារទាំងឡាយ ។ លោកពិចារណាឃើញវិញ្ញាណ ថាជាសត្វឬ ។ មិនដូច្នោះទេ អាវុសោ ។

(២០១) ម្នាលអាវុសោយមកៈ លោកសំគាល់សេចក្ដីនោះដូចម្ដេច លោកពិចារណាឃើញ ថាសត្វមានក្នុងរូបឬ ។ មិនដូច្នោះទេ អាវុសោ ។ លោកពិចារណាឃើញថាសត្វផ្សេងពីរូបឬ ។ មិនដូច្នោះទេ អាវុសោ ។ ក្នុងវេទនា ។ បេ ។ ផ្សេងពីវេទនា ។ បេ ។ ក្នុងសញ្ញា ។ ផ្សេងពីសញ្ញា ។ ក្នុងសង្ខារទាំងឡាយ ។ ផ្សេងពីសង្ខារទាំងឡាយ ។

វិញ្ញាណស្មឹ តថាគតោតិ សមនុបស្សសីតិ ។ នោ ហេតំ អាវុសោ ។ អញ្ញត្រ វិញ្ញាណា តថាគតោតិ សមនុបស្សសីតិ ។ នោ ហេតំ អាវុសោ ។

[២០២] តំ កឹ មញ្ញសិ អាវុសោ យមក រូបំ ។ វេទនា ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ តថាគតោតិ សមនុបស្សសីតិ ។ នោ ហេតំ អាវុសោ ។

[២០៣] តំ កឹ មញ្ញសិ អាវុសោ យមក អយំ សោ អរូបី អវេទនោ អសញ្ញី អសង្ខារោ អវិញ្ញាណោ តថាគតោតិ សមនុបស្សសីតិ ។ នោ ហេតំ អាវុសោ ។ ឯត្ថ ច តេ អាវុសោ យមក ទិដ្ឋេវ ធម្មេ សច្ចតោ ថេតតោ តថាគតោ អនុបលព្ភិយមានោ កល្លំ នុ តេ តំ វេយ្យាករណំ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា ខីណាសវោ ភិក្ខុ កាយស្ស ភេទា ឧច្ឆិជ្ជតិ វិនស្សតិ ន ហោតិ បរម្មរណាតិ ។

លោកពិចារណាឃើញ ថាសត្វមានក្នុងវិញ្ញាណឬ ។ មិនដូច្នោះទេ អាវុសោ ។ លោកពិចារណាឃើញថាសត្វផ្សេងពីវិញ្ញាណឬ ។ មិនដូច្នោះទេ អាវុសោ ។

(២០២) ម្នាលអាវុសោយមកៈ លោកសំគាល់សេចក្តីនោះដូចម្តេច លោកពិចារណាឃើញរូប ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណ ថាជាសត្វឬ ។ មិនដូច្នោះទេ អាវុសោ ។

(២០៣) ម្នាលអាវុសោយមកៈ លោកសំគាល់សេចក្តីនោះដូចម្តេច លោកពិចារណាឃើញសត្វនេះថា មិនមានរូប មិនមានវេទនា មិនមានសញ្ញា មិនមានសង្ខារ មិនមានវិញ្ញាណឬ ។ មិនដូច្នោះទេ អាវុសោ ។ ម្នាលអាវុសោយមកៈ ក្នុងស្ថាននេះ កាលបើលោកកំណត់សត្វ ថាទៀង ថាពិត ក្នុងបច្ចុប្បន្នហើយ ការព្យាករណ៍របស់លោកនោះគួរហើយឬ ថាអញយល់ច្បាស់នូវធម៌ ដែលព្រះមានព្រះភាគ សំដែងហើយថា ភិក្ខុជាខីណាស្រព តែទម្លាយកាយហើយ ខាងមុខអំពីសេចក្តីស្លាប់ទៅ រមែងដាច់សូន្យបាត់ទៅ មិនកើតទៀត ។ ម្នាល

អហុ ខោ មេ តំ អាវុសោ សារីបុត្ត បុព្វេ អវិទ្ទសុ-
នោ បាបកំ ទិដ្ឋិគតំ ឥទញ្ច បន មេ អាយស្ម-
តោ សារីបុត្តស្ស ធម្មទេសនំ សុត្វា តញ្ចេវ បាបកំ
ទិដ្ឋិគតំ បហីនំ ធម្មោ ច មេ អភិសមិតោតិ ។

(២០៨) សចេ តំ អាវុសោ យមក ឯវំ បុច្ឆេយ្យុំ
យោ សោ អាវុសោ យមក ភិក្ខុ អរហំ ខីណា-
សវោ សោ កាយស្ស ភេទា បរម្មរណា កឹ ហោតីតិ
ឯវំ បុដ្ឋោ ត្វំ អាវុសោ យមក កិន្តិ ព្យាករេយ្យា-
សីតិ ។ សចេ មំ អាវុសោ ឯវំ បុច្ឆេយ្យុំ យោ
សោ អាវុសោ យមក ភិក្ខុ អរហំ ខីណាសវោ
សោ កាយស្ស ភេទា បរម្មរណា កឹ ហោតីតិ ឯវំ
បុដ្ឋោ អហមាវុសោ ឯវំ ព្យាករេយ្យំ រូបំ ខោ
អាវុសោ អនិច្ចំ យទនិច្ចំ តំ ទុក្ខំ យំ ទុក្ខំ តំ
និរុទ្ធំ តទត្ថង្គតំ ។ វេទនា ។ សញ្ញា ។ សង្ខារា ។
វិញ្ញាណំ អនិច្ចំ យទនិច្ចំ តំ ទុក្ខំ យំ ទុក្ខំ តំ និរុទ្ធំ

អាវុសោសារីបុត្ត កាលពីដើម ខ្ញុំមិនដឹងថា ទិដ្ឋិរបស់ខ្ញុំនោះ ជាទិដ្ឋិអាក្រក់ ឥឡូវនេះ ខ្ញុំលះបង់ទិដ្ឋិអាក្រក់នោះហើយ ព្រោះបានស្តាប់ធម្មទេសនារបស់ព្រះសារីបុត្តមានអាយុនេះ មួយទៀត ខ្ញុំក៏បានសម្រេចធម៌វិសេសហើយ ។

[២០៤] ម្នាលអាវុសោយមកៈ បើជនទាំងឡាយសួរលោកយ៉ាងនេះថា ម្នាលអាវុសោយមកៈ ភិក្ខុណាជាអរហន្តខីណាស្រព ភិក្ខុនោះ ទម្លាយកាយហើយ ខាងមុខអំពីសេចក្តីស្លាប់ទៅនឹងកើតទៀតឬ ម្នាលអាវុសោយមកៈ កាលបើគេសួរយ៉ាងនេះ លោកគប្បីព្យាករ (ឆ្លើយ) ដូចម្តេចទៅ ។ ម្នាលអាវុសោ បើគេសួរខ្ញុំយ៉ាងនេះថា ម្នាលអាវុសោយមកៈ ភិក្ខុណាជាអរហន្តខីណាស្រព ភិក្ខុនោះ លុះទម្លាយកាយហើយ ខាងមុខអំពីសេចក្តីស្លាប់ទៅ នឹងកើតទៀតឬ ម្នាលអាវុសោ កាលបើគេសួរយ៉ាងនេះហើយ ខ្ញុំគប្បីព្យាករយ៉ាងនេះថា ម្នាលអាវុសោ រូបមិនទៀងទេ រូបណា មិនទៀង រូបនោះជាទុក្ខ រូបណា ជាទុក្ខ រូបនោះរលត់ទៅ ដល់នូវសេចក្តីវិនាសទៅ ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណមិនទៀងទេ វិញ្ញាណណា មិនទៀង វិញ្ញាណនោះជាទុក្ខ វិញ្ញាណណា ជាទុក្ខ វិញ្ញាណនោះរលត់ទៅ

តទត្ថំ គតន្តិ ឯវំ បុដ្ឋោ អហំ អាវុសោ ឯវំ ព្យាករេយ្យន្តិ ។

(២០៥) សាធុ សាធុ អាវុសោ យមក តេនហាវុសោ យមក ឧបមន្តេ ករិស្សាមិ ឯតស្សេវ អត្ថស្ស ភិយ្យោសោ មត្តាយ ញាណាយ ។ សេយ្យថាបិ អាវុសោ យមក គហបតិ វា គហបតិបុត្តោ វា អឌ្ឍោ មហទ្ធនោ មហាភោគោ សោ ច អារក្ខសម្បន្នោ តស្ស កោចិទេវ បុរិសោ ឧប្បជ្ជេយ្យ អនត្ថកាមោ អហិតកាមោ អយោគក្ខេមកាមោ ជីវិតា វោរោបេតុកាមោ តស្ស ឯវមស្ស អយំ ខោ គហបតិ វា គហបតិបុត្តោ វា អឌ្ឍោ មហទ្ធនោ មហាភោគោ សោ ច អារក្ខសម្បន្នោ ន ហាយំ សុករោ បសយ្ហ ជីវិតា វោរោបេតុំ យន្នូនាហំ អនុបខជ្ជ ជីវិតា វោរោបេយ្យន្តិ ។ សោ តំ គហបតឹ វា គហបតិបុត្តំ វា ឧបសង្កមិត្វា ឯវំ វទេយ្យ ឧបដ្ឋហេយ្យំ តំ ភន្តេតិ ។ តមេតំ សោ គហបតិ វា គហបតិបុត្តោ វា ឧបដ្ឋាបេយ្យ

ដល់នូវសេចក្ដីវិនាសទៅ ម្នាលអាវុសោ កាលបើគេសួរយ៉ាងនេះ ខ្ញុំគប្បីព្យាករយ៉ាងនេះឯង ។

[២០៥] ម្នាលអាវុសោយមកៈ ប្រពៃហើយ ប្រពៃហើយ ម្នាលអាវុសោយមកៈ បើដូច្នោះ ខ្ញុំនឹងធ្វើសេចក្ដីឧបមាឲ្យលោកស្ដាប់ ដើម្បីឲ្យដឹងសេចក្ដីនោះ ច្បាស់លាស់ឡើងទៀត ។ ម្នាលអាវុសោយមកៈ ដូចជាគហបតីឬគហបតិបុត្ត ជាអ្នកស្ដុកស្ដម្ភ មានទ្រព្យច្រើន មានភោគៈច្រើន គហបតីឬគហបតិបុត្តនោះក៏ប្រកបដោយការរក្សាមាំមួន ទោះបីបុរសណាមួយ ចង់ឲ្យគហបតីឬគហបតិបុត្តនោះវិនាស ចង់ឲ្យខូចប្រយោជន៍ មិនចង់ឲ្យក្សេមក្សាន្តចាកយោគៈ ចង់សម្លាប់គហបតីឬគហបតិបុត្តនោះ បុរសនោះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា គហបតីឬគហបតិបុត្តនេះឯង ជាអ្នកស្ដុកស្ដម្ភ មានទ្រព្យច្រើន មានភោគៈច្រើន គហបតីឬគហបតិបុត្តនោះ ក៏ប្រកបដោយការរក្សាមាំមួន អញមិនងាយនឹងកំហែងសម្លាប់គហបតី ឬគហបតិបុត្តនេះបានទេ បើដូច្នោះមានតែអញចូលទៅលួងលោមហើយ សឹមសម្លាប់ ។ បុរសនោះក៏ចូលទៅរកគហបតីឬគហបតិបុត្តនោះ ហើយនិយាយយ៉ាងនេះថា សូមមេត្តាប្រោសខ្ញុំបាទសូមបម្រើលោក ។ គហបតីឬគហបតិបុត្តនោះ ក៏ឲ្យបុរសនោះបម្រើ

សោ ឧបដ្ឋហេយ្យ បុព្វុដ្ឋាយី បច្ឆានិបាតី កឹកា-
រប្បដិស្សាវី មនាបចារី បិយវាទី តស្ស សោ គ-
ហបតិ វា គហបតិបុត្តោ វា មិត្តតោបិ នំ ទហេយ្យ
សុហជ្ជតោបិ នំ ទហេយ្យ តស្មិញ្ច វិស្សាសំ អា-
បជ្ជេយ្យ ។ យតោ ខោ អាវុសោ តស្ស បុរិសស្ស ឯវ-
មស្ស សំវិស្សត្ថោ ខោ ម្យាយំ គហបតិ វា គហបតិ-
បុត្តោ វាតិ អថ នំ រហោគតំ វិទិត្វា តិណ្ហេន សត្ថេន
ជីវិតា វោរោបេយ្យ ។ តំ កឹ មញ្ញសិ អាវុសោ យ-
មក យទាបិ សោ បុរិសោ អមុំ គហបតឹ វា គហ-
បតិបុត្តំ វា ឧបសង្កមិត្វា ឯវមាហ ឧបដ្ឋហេយ្យំ តំ
ភន្តេតិ តទាបិ សោ វធកោ វ វធកញ្ច បន សន្តំ
ន អញ្ញាសិ វធកោ មេតិ ។ យទាបិ សោ ឧបដ្ឋាតិ
បុព្វុដ្ឋាយី បច្ឆានិបាតី កឹការប្បដិស្សាវី មនាបចារី

ឬ បុរសនោះ ចូលទៅបម្រើ ក៏ក្រោកឡើងមុន ដេកក្រោយ ទទួលធ្វើការអ្វី ៗ ប្រព្រឹត្តជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់នៃគហបតីបុត្រ គហបតិបុត្រនោះ ឬគហបតីបុត្រគហបតិបុត្រនោះ ជឿបុរសនោះថា ជាមិត្តផង ជឿបុរសនោះថា ជាបុគ្គលមានចិត្តល្អផង ហើយក៏ដល់នូវសេចក្ដីស្និទ្ធស្នាលនឹងបុរសនោះ ។ ម្នាលអាវុសោ កាលណាបើបុរសនោះគិតយ៉ាងនេះថា គហបតីបុត្តគហបតិបុត្តនេះអញបានស្និទ្ធស្នាលល្អហើយ ឬវេលាខាងក្រោយដឹងថា គហបតីបុត្តគហបតិបុត្តនោះនៅក្នុងទីស្ងាត់ ក៏សម្លាប់ដោយសស្ត្រាដ៏មុត ។ ម្នាលអាវុសោយមកៈ លោកសំគាល់សេចក្ដីនោះដូចម្ដេច កាលដែលបុរសនោះ ចូលទៅរកគហបតីបុត្តគហបតិបុត្តឯណោះ ហើយនិយាយ យ៉ាងនេះថា សូមមេត្តាប្រោស ខ្ញុំបាទសូមបម្រើលោក គហបតីបុត្តគហបតិបុត្ត ដែលត្រូវគេសម្លាប់នោះឯង មិនស្គាល់បុរសអ្នកសម្លាប់ថា ជាអ្នកសម្លាប់ខ្លួនទេឬ ។ កាលដែលបុរសនោះចូលទៅបម្រើ ក៏ក្រោកឡើងមុន ដេកក្រោយ ទទួលធ្វើការអ្វី ៗ ប្រព្រឹត្តជាទីពេញចិត្ត

បិយកាមី តទាបិ សោ វធកោ ។ វធកញ្ច បន សន្តំ ន អញ្ញាសិ វធកោ មេតិ ។ យទាបិ នំ រហោគតំ វិទិត្វា តិណ្ហេន សត្ថេន ជីវិតា វោរោបេតិ តទាបិ សោ វធកោ ។ វធកញ្ច បន សន្តំ ន អញ្ញាសិ វធកោ មេតិ ។ ឯវមាវុសោតិ ។

(២០៦) ឯវមេវ ខោ អាវុសោ អស្សុតវា បុថុជ្ជនោ អរិយានំ អទស្សាវី អរិយធម្មស្ស អកោវិទោ អរិយធម្មេ អវិនីតោ សប្បុរិសានំ អទស្សាវី សប្បុរិសធម្មស្ស អកោវិទោ សប្បុរិសធម្មេ អវិនីតោ រូបំ អត្តតោ សមនុបស្សតិ រូបវន្តំ វា អត្តានំ អត្តនិ វា រូបំ រូបស្មឹ វា អត្តានំ ។ វេទនំ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ អត្តតោ សមនុបស្សតិ ។ បេ ។ វិញ្ញាណស្មឹ វា អត្តានំ ។ សោ អនិច្ចំ រូបំ អនិច្ចំ រូបន្តិ យថាភូតំ នប្បជានាតិ អនិច្ចំ វេទនំ អនិច្ចា វេទនាតិ យថាភូតំ នប្បជានាតិ អនិច្ចំ សញ្ញំ អនិច្ចា សញ្ញាតិ យថាភូតំ នប្បជា-

ពោលពាក្យជាទីស្រឡាញ់ គហបតីឬគហបតិបុត្ត ដែលត្រូវគេសម្លាប់នោះឯង មិនស្គាល់បុរសអ្នកសម្លាប់ថា ជាអ្នកសម្លាប់ខ្លួនទេ ។ កាលដែលបុរសនោះដឹងថា គហបតីឬគហបតិបុត្តនោះ នៅក្នុងទីស្ងាត់ហើយ ក៏សម្លាប់ដោយសស្ត្រាដ៏មុត តើគហបតីឬគហបតិបុត្ត ដែលត្រូវគេសម្លាប់នោះឯង មិនស្គាល់បុរសអ្នកសម្លាប់ថា ជាអ្នកសម្លាប់ខ្លួនទេឬ ។ យ៉ាងហ្នឹងឯង អាវុសោ ។

(២០៦) ព្រះសារីបុត្តពោលថា ម្នាលអាវុសោ បុថុជ្ជនអ្នកមិនចេះដឹង មិនធ្លាប់ឃើញពួកព្រះអរិយៈ មិនឈ្លាសវៃ ក្នុងអរិយធម៌ មិនហ្វឹកហ្វឺនក្នុងអរិយធម៌ មិនឃើញពួកសប្បុរស មិនឈ្លាសវៃ ក្នុងសប្បុរិសធម៌ មិនហ្វឹកហ្វឺនក្នុងសប្បុរិសធម៌ រមែងឃើញរូបថាជាខ្លួនខ្លះ ឃើញខ្លួនថាមានរូបខ្លះ ឃើញរូបថាមានក្នុងខ្លួនខ្លះ ឃើញខ្លួនថាមានក្នុងរូបខ្លះ ។ ឃើញវេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណ ថាជាខ្លួន ។ បេ ។ ឃើញខ្លួនថាមានក្នុងវិញ្ញាណខ្លះ ។ បុថុជ្ជននោះ រមែងមិនដឹងច្បាស់តាមសេចក្តីពិត នូវរូបមិនទៀង ថារូបមិនទៀង រមែងមិនដឹងច្បាស់តាមសេចក្តីពិត នូវវេទនាមិនទៀង ថាវេទនាមិនទៀង រមែងមិនដឹងច្បាស់តាមសេចក្តីពិត នូវសញ្ញាមិនទៀង ថាសញ្ញាមិនទៀង

ជាតិ អនិច្ចេ សង្ខារេ អនិច្ចា សង្ខារាតិ យថាភូតំ នប្បជានាតិ អនិច្ចំ វិញ្ញាណំ អនិច្ចំ វិញ្ញាណន្តិ យថាភូតំ នប្បជានាតិ ។ ទុក្ខំ រូបំ ទុក្ខំ រូបន្តិ យថាភូតំ នប្បជានាតិ ។ ទុក្ខំ វេទនំ ។ ទុក្ខំ សញ្ញំ ។ ទុក្ខេ សង្ខារេ ។ ទុក្ខំ វិញ្ញាណំ ទុក្ខំ វិញ្ញាណន្តិ យថាភូតំ នប្បជានាតិ ។ អនត្តំ រូបំ អនត្តំ រូបន្តិ យថាភូតំ នប្បជានាតិ ។ អនត្តំ វេទនំ ។ អនត្តំ សញ្ញំ ។ អនត្តេ សង្ខារេ ។ អនត្តំ វិញ្ញាណំ អនត្តំ វិញ្ញាណន្តិ យថាភូតំ នប្បជានាតិ ។ សង្ខតំ រូបំ សង្ខតំ រូបន្តិ យថាភូតំ នប្បជានាតិ ។ សង្ខតំ វេទនំ ។ សង្ខតំ សញ្ញំ ។ សង្ខតេ សង្ខារេ ។

រមែងមិនដឹងច្បាស់ តាមសេចក្តីពិត នូវសង្ខារទាំងឡាយមិនទៀង ថាសង្ខារទាំងឡាយមិនទៀងឡើយ រមែងមិនដឹងច្បាស់តាមសេចក្តីពិត នូវវិញ្ញាណមិនទៀង ថាវិញ្ញាណមិនទៀងឡើយ ។ រមែងមិនដឹងច្បាស់តាមសេចក្តីពិត នូវរូបធាតុ ថារូបធាតុឡើយ ។ នូវវេទនាធាតុ ។ នូវសញ្ញាធាតុ ។ នូវសង្ខារទាំងឡាយ ធាតុ ។ រមែងមិនដឹងច្បាស់ តាមសេចក្តីពិត នូវវិញ្ញាណធាតុ ថាវិញ្ញាណធាតុឡើយ ។ រមែងមិនដឹងច្បាស់ តាមសេចក្តីពិត នូវរូបមិនមែនខ្លួន ថារូបមិនមែនខ្លួនឡើយ ។ នូវវេទនាមិនមែនខ្លួន ។ នូវសញ្ញាមិនមែនខ្លួន ។ នូវសង្ខារទាំងឡាយមិនមែនខ្លួន ។ រមែងមិនដឹងច្បាស់ តាមសេចក្តីពិត នូវវិញ្ញាណមិនមែនខ្លួន ថាវិញ្ញាណមិនមែនខ្លួនឡើយ ។ រមែងមិនដឹងច្បាស់ តាមសេចក្តីពិត នូវរូបមានបច្ច័យតាក់តែង ថារូបមានបច្ច័យតាក់តែងឡើយ ។ នូវវេទនាមានបច្ច័យតាក់តែង ។ នូវសញ្ញាមានបច្ច័យតាក់តែង ។ នូវសង្ខារទាំងឡាយ មានបច្ច័យតាក់តែង ។

សង្ខតំ វិញ្ញាណំ សង្ខតំ វិញ្ញាណន្តិ យថាភូតំ នប្បជានាតិ ។ វធកំ រូបំ វធកំ រូបន្តិ យថាភូតំ នប្បជានាតិ ។ វធកំ វេទនំ ។ វធកំ សញ្ញំ ។ វធកេ សង្ខារេ ។ វធកំ វិញ្ញាណំ វធកំ វិញ្ញាណន្តិ យថាភូតំ នប្បជានាតិ ។ សោ រូបំ ឧបេតិ ឧបាទិយតិ អធិដ្ឋាតិ អត្តា មេតិ ។ វេទនំ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ ឧបេតិ ឧបាទិយតិ អធិដ្ឋាតិ អត្តា មេតិ ។ តស្សិមេ បញ្ចុបាទានក្ខន្ធា ឧបេតា ឧបាទិន្នា ទីឃរត្តំ អហិតាយ ទុក្ខាយ សំវត្តន្តិ ។

(២០៧) សុតវា ច ខោ អាវុសោ អរិយសាវកោ អរិយានំ ទស្សាវី អរិយធម្មស្ស កោវិទោ អរិយធម្មេ សុវិនីតោ ។ បេ ។ សប្បុរិសធម្មេ សុវិនីតោ ន រូបំ អត្តតោ សមនុបស្សតិ ន រូបវន្តំ វា អត្តានំ ន អត្តនិ វា រូបំ ន រូបស្មឹ វា អត្តានំ ។ ន វេទនំ ។ ន សញ្ញំ ។ ន សង្ខារេ ។ ន វិញ្ញាណំ អត្តតោ សមនុបស្សតិ

រមែងមិនដឹងច្បាស់តាមសេចក្តីពិត នូវវិញ្ញាណមានបច្ច័យតាក់តែង ថាវិញ្ញាណមានបច្ច័យតាក់តែងឡើយ ។ រមែងមិនដឹងច្បាស់តាមសេចក្តីពិត នូវរូបជាអ្នកសម្លាប់ ថារូបជាអ្នកសម្លាប់ឡើយ ។ នូវវេទនាជាអ្នកសម្លាប់ ។ នូវសញ្ញាជាអ្នកសម្លាប់ ។ នូវសង្ខារទាំងឡាយជាអ្នកសម្លាប់ ។ រមែងមិនដឹងច្បាស់តាមសេចក្តីពិត នូវវិញ្ញាណជាអ្នកសម្លាប់ ថាវិញ្ញាណជាអ្នកសម្លាប់ឡើយ ។ បុថុជ្ជននោះ រមែងចូលទៅប្រកាន់ខ្ជាប់ តាំងចិត្តស៊ប់ នូវរូបថាជាខ្លួនរបស់អញ ។ រមែងចូលទៅប្រកាន់ខ្ជាប់ តាំងចិត្តស៊ប់ នូវវេទនា ។ នូវសញ្ញា ។ នូវសង្ខារទាំងឡាយ ។ នូវវិញ្ញាណថាជាខ្លួនរបស់អញ ។ ឧបាទានក្ខន្ធទាំង ៥ នេះ ដែលបុថុជ្ជននោះ ចូលទៅប្រកាន់ខ្ជាប់ហើយ រមែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ដើម្បីទុក្ខ អស់កាលជាអង្វែង ។

(២០៧) ព្រះសារីបុត្តពោលថា ម្នាលអាវុសោ ឯអរិយសាវ័កជាអ្នកចេះដឹង បានឃើញពួកព្រះអរិយៈ ឈ្លាសវៃ ក្នុងអរិយធម៌ ហ្វឹកហ្វឺនក្នុងអរិយធម៌ ។ បេ ។ ជាអ្នកហ្វឹកហ្វឺនក្នុងសប្បុរិសធម៌ រមែងមិនឃើញរូបថាជាខ្លួន មិនឃើញខ្លួនថាមានរូបខ្លះ មិនឃើញរូបថាមានក្នុងខ្លួនខ្លះ មិនឃើញខ្លួនថាមានក្នុងរូបខ្លះ ។ មិនឃើញវេទនា ។ មិនឃើញសញ្ញា ។ មិនឃើញសង្ខារទាំងឡាយ ។ មិនឃើញវិញ្ញាណថាជាខ្លួន

ន វិញ្ញាណវន្តំ វា អត្តានំ ន អត្តនិ វា វិញ្ញាណំ ន វិញ្ញាណស្មឹ វា អត្តានំ ។ សោ អនិច្ចំ រូបំ អនិច្ចំ រូបន្តិ យថាភូតំ បជានាតិ ។ អនិច្ចំ វេទនំ ។ អនិច្ចំ សញ្ញំ ។ អនិច្ចេ សង្ខារេ ។ អនិច្ចំ វិញ្ញាណំ អនិច្ចំ វិញ្ញាណន្តិ យថាភូតំ បជានាតិ ។ ទុក្ខំ រូបំ ទុក្ខំ រូបន្តិ យថាភូតំ បជានាតិ ។ ទុក្ខំ វេទនំ ។ ទុក្ខំ សញ្ញំ ។ ទុក្ខេ សង្ខារេ ។ ទុក្ខំ វិញ្ញាណំ ទុក្ខំ វិញ្ញាណន្តិ យថាភូតំ បជានាតិ ។ អនត្តំ រូបំ អនត្តំ រូបន្តិ យថាភូតំ បជានាតិ ។ អនត្តំ វេទនំ ។ អនត្តំ សញ្ញំ ។ អនត្តេ សង្ខារេ ។ អនត្តំ វិញ្ញាណំ អនត្តំ វិញ្ញាណន្តិ យថាភូតំ បជានាតិ ។ សង្ខតំ រូបំ សង្ខតំ រូបន្តិ យថាភូតំ បជានាតិ ។ សង្ខតំ វេទនំ ។ សង្ខតំ សញ្ញំ ។ សង្ខតេ សង្ខារេ ។

មិនឃើញខ្លួនថាមានវិញ្ញាណខ្លះ មិនឃើញវិញ្ញាណថាមានក្នុងខ្លួនខ្លះ មិនឃើញខ្លួនថាមានក្នុងវិញ្ញាណខ្លះ ។ អរិយសាវ័កនោះ ដឹងច្បាស់តាមសេចក្តីពិត នូវរូបមិនទៀងថា រូបមិនទៀងមែន ។ នូវវេទនាមិនទៀង ។ នូវសញ្ញាមិនទៀង ។ នូវសង្ខារទាំងឡាយមិនទៀង ។ ដឹងច្បាស់តាមសេចក្តីពិត នូវវិញ្ញាណមិនទៀងថា វិញ្ញាណមិនទៀងមែន ។ ដឹងច្បាស់តាមសេចក្តីពិត នូវរូបជាទុក្ខថា រូបជាទុក្ខមែន ។ ដឹងច្បាស់តាមសេចក្តីពិត នូវវេទនាជាទុក្ខ ។ នូវសញ្ញាជាទុក្ខ ។ នូវសង្ខារទាំងឡាយជាទុក្ខ ។ នូវវិញ្ញាណជាទុក្ខថា វិញ្ញាណជាទុក្ខមែន ។ ដឹងច្បាស់តាមសេចក្តីពិត នូវរូបមិនមែនខ្លួនថា រូបមិនមែនខ្លួនមែន ។ ដឹងច្បាស់តាមសេចក្តីពិត នូវវេទនាមិនមែនខ្លួន ។ នូវសញ្ញាមិនមែនខ្លួន ។ នូវសង្ខារទាំងឡាយមិនមែនខ្លួន ។ នូវវិញ្ញាណមិនមែនខ្លួនថា វិញ្ញាណមិនមែនខ្លួនមែន ។ ដឹងច្បាស់តាមសេចក្តីពិត នូវរូបមានបច្ច័យតាក់តែងថា រូបមានបច្ច័យតាក់តែងមែន ។ ដឹងច្បាស់តាមសេចក្តីពិត នូវវេទនាមានបច្ច័យតាក់តែង ។ នូវសញ្ញា មានបច្ច័យតាក់តែង ។ នូវសង្ខារទាំងឡាយមានបច្ច័យតាក់តែង ។

សង្ខតំ វិញ្ញាណំ សង្ខតំ វិញ្ញាណន្តិ យថាភូតំ បជានាតិ ។ ឯតំ រូបំ ឯតំ រូបន្តិ យថាភូតំ បជានាតិ ។ ឯតំ វេទនំ ។ ឯតំ សញ្ញំ ។ ឯតេ សង្ខារេ ឯតេ សង្ខារាតិ យថាភូតំ បជានាតិ ។ ឯតំ វិញ្ញាណំ ឯតំ វិញ្ញាណន្តិ យថាភូតំ បជានាតិ ។ សោ រូបំ ន ឧបេតិ ន ឧបាទិយតិ ន អធិដ្ឋាតិ អត្តា មេតិ ។ វេទនំ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ ន ឧបេតិ ន ឧបាទិយតិ ន អធិដ្ឋាតិ អត្តា មេតិ ។ តស្សិមេ បញ្ចុបាទានក្ខន្ធា អនុបេតា(១) អនុបាទិន្នា ទីឃរត្តំ ហិតាយ សុខាយ សំវត្តន្តីតិ ។ ឯវញ្ហេតំ(២) អាវុសោ សារីបុត្ត ហោតិ យេសំ អាយស្មន្តានំ តាទិសា សព្រហ្មចារីនោ អនុកម្បកា អត្ថកាមា ឱវាទកា អនុសាសកា ឥទញ្ច បន មេ អាយស្មតោ សារីបុត្តស្ស ធម្មទេសនំ សុត្វា អនុបាទាយ អាសវេហិ ចិត្តំ វិមុត្តន្តិ ។

---

១ អនុប្បន្នាតិ វា អនុប្បេន្តាតិ វា បាឋោ ភវេយ្យ ។ ២ ម. ឯវមេតំ ។

នូវវិញ្ញាណមានបច្ច័យតាក់តែងថា វិញ្ញាណមានបច្ច័យតាក់តែងមែន ៗ ដឹងច្បាស់តាមសេចក្តីពិត នូវរូបជាអ្នកសម្លាប់ថា រូបជាអ្នកសម្លាប់មែន ៗ ដឹងច្បាស់តាមសេចក្តីពិត នូវវេទនាជាអ្នកសម្លាប់ ៗ នូវសញ្ញាជាអ្នកសម្លាប់ ៗ នូវសង្ខារទាំងឡាយជាអ្នកសម្លាប់ថា សង្ខារទាំងឡាយជាអ្នកសម្លាប់មែន ៗ ដឹងច្បាស់តាមសេចក្តីពិត នូវវិញ្ញាណជាអ្នកសម្លាប់ថា វិញ្ញាណជាអ្នកសម្លាប់មែន ៗ អរិយសាវ័កនោះ ក៏មិនចូលទៅជិត មិនប្រកាន់ខ្ជាប់ មិនតាំងចិត្តស៊ប់ នូវរូបថាជាខ្លួនរបស់អញ ៗ មិនចូលទៅជិត មិនប្រកាន់ខ្ជាប់ មិនតាំងចិត្តស៊ប់ នូវវេទនា ៗ នូវសញ្ញា ៗ នូវសង្ខារទាំងឡាយ ៗ នូវវិញ្ញាណ ថាជាខ្លួនរបស់អញ ៗ ឧបាទានក្ខន្ធទាំង ៥ នេះ ដែលអរិយសាវ័កនោះ មិនចូលទៅជិត មិនប្រកាន់ខ្ជាប់ រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ អស់កាលជាអង្វែង ៗ យមកភិក្ខុ តបថា ម្នាលអាវុសោសារីបុត្ត សេចក្តីនុ៎ះយ៉ាងហ្នឹងមែនហើយ បណ្តាលោកមានអាយុទាំងឡាយណា លោកមានអាយុទាំងឡាយនោះ ប្រាកដដូចជាលោកម្ចាស់ ឈ្មោះថាជាសព្រហ្មចារី ជាអ្នកអនុគ្រោះ ចង់ឲ្យបានប្រយោជន៍ ជាអ្នកឲ្យឱវាទ ជាអ្នកប្រៀនប្រដៅមែន ឯចិត្តរបស់ខ្ញុំរួចចាកអាសវៈមិនប្រកាន់មាំហើយ ព្រោះបានស្តាប់ធម្មទេសនានេះ របស់ព្រះសារីបុត្តមានអាយុ ៗ

[២០៨] ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ តេន ខោ បន សមយេន អាយស្មា អនុរាធោ ភគវតោ អវិទូរេ អរញ្ញកុដិកាយំ វិហរតិ ។ អថខោ សម្ពហុលា អញ្ញតិត្ថិយា បរិព្វាជកា យេនាយស្មា អនុរាធោ តេនុបសង្កមឹសុ ឧបសង្កមិត្វា អាយស្មតា អនុរាធេន សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ អញ្ញតិត្ថិយា បរិព្វាជកា អាយស្មន្តំ អនុរាធំ ឯតទវោចុំ យោ សោ អាវុសោ អនុរាធ តថាគតោ ឧត្តមបុរិសោ បរមបុរិសោ បរមបត្តិបត្តោ តំ តថាគតោ ឥមេសុ ចតូសុ ឋានេសុ បញ្ញាបយមានោ បញ្ញាបេតិ ហោតិ តថាគតោ បរម្មរណាតិ វា ន ហោតិ តថាគតោ បរម្មរណាតិ វា ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណាតិ វា នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ វាតិ ។ ឯវំ វុត្តេ អាយស្មា អនុរាធោ

(២០៨) សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងកូដាគារសាលា នាមហាវ័ន ជិតក្រុងវេសាលី ។ សម័យនោះឯង ព្រះអនុរាធមានអាយុ នៅក្នុងអរញ្ញកុដិ ក្នុងទីជិតព្រះមានព្រះភាគ ។ គ្រានោះ ពួកបរិព្វាជក ជាអន្យតិរ្ថិយច្រើនរូប ចូលទៅរកព្រះអនុរាធមានអាយុ លុះចូលទៅដល់ ក៏ធ្វើសេចក្តីរីករាយ ជាមួយនឹងព្រះអនុរាធមានអាយុ លុះបញ្ចប់ពាក្យគួររីករាយ និងពាក្យគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះបរិព្វាជក ជាអន្យតិរ្ថិយអម្បាលនោះ អង្គុយក្នុងទីសមគួរហើយ ក៏និយាយនឹងព្រះអនុរាធមានអាយុដូច្នេះថា ម្នាលអាវុសោអនុរាធ ព្រះតថាគតណា ជាបុរសឧត្តម ជាបុរសដ៏ខ្ពង់ខ្ពស់ ដល់នូវគំណែងដ៏ខ្ពង់ខ្ពស់ ព្រះតថាគតនោះ កាលនឹងបញ្ញត្តនូវសត្វនោះ តែងបញ្ញត្តក្នុងស្ថាន ៤ នេះថា សត្វស្លាប់ទៅកើតទៀតក៏មាន សត្វស្លាប់ទៅមិនកើតទៀតក៏មាន សត្វស្លាប់ទៅកើតទៀតខ្លះ មិនកើតទៀតខ្លះក៏មាន សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក៏មាន ។ កាលបើពួកបរិព្វាជកជាអន្យតិរ្ថិយ ពោលយ៉ាងនេះហើយ ព្រះអនុរាធមានអាយុ

តេ អញ្ញតិត្ថិយេ បរិព្វាជកេ ឯតទវោច យោ សោ អាវុសោ តថាគតោ ឧត្តមបុរិសោ បរមបុរិសោ បរមបត្តិបត្តោ តំ តថាគតោ អញ្ញត្រ ឥមេហិ ចតូហិ ឋានេហិ បញ្ញាបយមានោ បញ្ញាបេតិ ហោតិ តថាគតោ បរម្មរណាតិ វា ន ហោតិ តថាគតោ បរម្មរណាតិ វា ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណាតិ វា នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ វាតិ ។ ឯវំ វុត្តេ តេ អញ្ញតិត្ថិយា បរិព្វាជកា អាយស្មន្តំ អនុរាធំ ឯតទវោចុំ សោ ចាយំ ភិក្ខុ នវោ ភវិស្សតិ អចិរបព្វជិតោ ថេរោ វា បន ពាលោ អព្យត្តោតិ ។ អថខោ អញ្ញតិត្ថិយា បរិព្វាជកា អាយស្មន្តំ អនុរាធំ នវវាទេន ច ពាលវាទេន ច អបសាទេត្វា ឧដ្ឋាយាសនា បក្កមឹសុ ។

ក៏និយាយនឹងពួកបរិព្វាជក ជាអន្យតិរ្ថិយទាំងនោះ ដូច្នេះថា ម្នាលអាវុសោ ព្រះតថាគតណា ជាបុរសដ៏ឧត្តម ជាបុរសដ៏ខ្ពង់ខ្ពស់ ដល់នូវតំណែងដ៏ខ្ពង់ខ្ពស់ ព្រះតថាគតនោះ កាលនឹងបញ្ញត្តនូវសត្វនោះ តែងបញ្ញត្តក្រៅអំពីស្ថាន ៤ នេះថា សត្វស្លាប់ទៅកើតទៀតក៏មាន សត្វស្លាប់ទៅមិនកើតទៀតក៏មាន សត្វស្លាប់ទៅកើតទៀតខ្លះ មិនកើតទៀតខ្លះក៏មាន សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក៏មាន ។ កាលព្រះអនុរាធ និយាយយ៉ាងនេះហើយ បរិព្វាជក ជាអន្យតិរ្ថិយទាំងនោះ និយាយនឹងព្រះអនុរាធមានអាយុ យ៉ាងនេះថា ភិក្ខុនេះជាភិក្ខុថ្មី បួសមិនទាន់បានយូរ ចុះនោះសោត លោកជាថេរៈដែរ តែល្ងង់មិនឈ្លាសវៃ ។ លំដាប់នោះ ពួកបរិព្វាជក ជាអន្យតិរ្ថិយ ក៏តិះដៀលព្រះអនុរាធមានអាយុ ដោយពាក្យថាថ្មីផង ដោយពាក្យថាល្ងង់ផង ហើយក្រោកអំពីអាសនៈ ចៀសចេញទៅ ។

(២០៩) អថខោ អាយស្មតោ អនុរាធស្ស អចិរបក្កន្តេសុ តេសុ អញ្ញតិត្ថិយេសុ បរិព្វាជកេសុ ឯតទហោសិ សចេ ខោ មំ តេ អញ្ញតិត្ថិយា បរិព្វាជកា ឧត្តរឹ បុច្ឆេយ្យុំ កថំ ព្យាករមានោ នុ ខ្វាហំ តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ វុត្តវាទី ចេវ ភគវតោ អស្សំ ន ច ភគវន្តំ អភូតេន អព្ភាចិក្ខេយ្យំ ធម្មស្ស ចានុធម្មំ ព្យាករេយ្យំ ន ច កោចិ សហធម្មិកោ វាទានុវាទោ(១) គារយ្ហំ ឋានំ អាគច្ឆេយ្យាតិ ។ អថខោ អាយស្មា អនុរាធោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ។ បេ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អនុរាធោ ភគវន្តំ ឯតទវោច ឥធាហំ ភន្តេ ភគវតោ អវិទូរេ អរញ្ញកុដិកាយំ វិហរាមិ អថខោ ភន្តេ

---

១ វាទានុវាទោតិបិ បាឋោ ។

[២០៩] កាលដែលបរិញ្ញាជកជាអន្យតិរ្ថិយទាំងនោះ ចៀសចេញទៅ មិនយូរប៉ុន្មាន ព្រះអនុរាធមានអាយុ ក៏មានសេចក្តីត្រិះរិះ ដូច្នេះថា ប្រសិនបើបរិញ្ញាជកជាអន្យតិរ្ថិយទាំងនោះ សួរអាត្មាអញតទៅទៀត អាត្មាអញ ទឹងព្យាករដល់បរិញ្ញាជកជាអន្យតិរ្ថិយទាំងនោះដូចម្តេច ទើបឈ្មោះថាពោលតាមពាក្យ ដែលព្រះមានព្រះភាគពោលហើយផង មិនពោលបង្អាប់ព្រះមានព្រះភាគ ដោយពាក្យមិនពិតផង ឈ្មោះថាព្យាករទូវធម៌តាមធម៌ផង ពាក្យពោលនីមួយដែលប្រកបដោយធម៌ មិនមកកាន់ស្ថានដែលបណ្ឌិតគប្បីតិះដៀលផង ។ គ្រានោះ ព្រះអនុរាធមានអាយុចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ។ បេ ។ លុះព្រះអនុរាធមានអាយុ គង់ក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ ខ្ញុំព្រះអង្គសម្រាកនៅក្នុងអរញ្ញកុដិជិតព្រះមានព្រះភាគ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះ

សម្ពហុលា អញ្ញតិត្ថិយា បរិព្វាជកា យេនាហំ តេ-
នុបសង្កមិំសុ ។បេ។ មំ ឯតទវោចុំ យោ សោ
អាវុសោ អនុរាធ តថាគតោ ឧត្តមបុរិសោ បរមបុរិសោ
បរមបត្តិបត្តោ តំ តថាគតោ ឥមេសុ ចតូសុ ឋានេសុ
បញ្ញាបយមានោ បញ្ញបេតិ ហោតិ តថាគតោ បរម្មរ-
ណាតិ វា ន ហោតិ តថាគតោ បរម្មរណាតិ វា
ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណាតិ វា
នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ
វាតិ ។ ឯវំ វុត្តាហំ ភន្តេ តេ អញ្ញតិត្ថិយេ បរិព្វាជ-
កេ ឯតទវោចំ យោ សោ អាវុសោ តថាគតោ
ឧត្តមបុរិសោ បរមបុរិសោ បរមបត្តិបត្តោ តំ តថាគតោ
អញ្ញត្រ ឥមេហិ ចតូហិ ឋានេហិ បញ្ញាបយមានោ
បញ្ញបេតិ ហោតិ តថាគតោ បរម្មរណាតិ វា ។បេ។
នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ
វាតិ ។ ឯវំ វុត្តេ ភន្តេ តេ អញ្ញតិត្ថិយា បរិព្វាជកា

ពួកបរិព្វាជក ជាអន្យតិរ្ថិយច្រើនរូប ចូលមករកខ្ញុំព្រះអង្គ ។ បេ ។ បាននិយាយនឹងខ្ញុំព្រះអង្គដូច្នេះថា ម្នាលអាវុសោអនុរាធ ព្រះតថាគតណា ជាបុរសដ៏ឧត្តម ជាបុរសដ៏ខ្ពង់ខ្ពស់ ដល់នូវតំណែងដ៏ខ្ពង់ខ្ពស់ ព្រះតថាគតនោះ កាលនឹងបញ្ញត្តសត្វនោះ តែងបញ្ញត្ត ក្នុងស្ថានទាំង ៤ នេះថា សត្វស្លាប់ទៅកើតទៀតក៏មាន សត្វស្លាប់ទៅមិនកើតទៀតក៏មាន សត្វស្លាប់ទៅកើតទៀតខ្លះ មិនកើតទៀតខ្លះក៏មាន សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក៏មាន ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើគេនិយាយយ៉ាងនេះហើយ ខ្ញុំព្រះអង្គក៏និយាយទៅនឹងបរិព្វាជកជាអន្យតិរ្ថិយទាំងនោះដូច្នេះថា ម្នាលអាវុសោ ព្រះតថាគតណា ជាបុរសដ៏ឧត្តម ជាបុរសដ៏ខ្ពង់ខ្ពស់ ដល់នូវតំណែងដ៏ខ្ពង់ខ្ពស់ ព្រះតថាគតនោះ កាលនឹងបញ្ញត្តនូវសត្វនោះ តែងបញ្ញត្ត ក្រៅអំពីស្ថាន ៤ នេះថា សត្វស្លាប់ទៅកើតទៀតក៏មាន ។ បេ ។ សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក៏មាន ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើខ្ញុំព្រះអង្គនិយាយយ៉ាងនេះហើយ ទើបបរិព្វាជកជាអន្យតិរ្ថិយទាំងនោះ

មំ ឯតទវោចុំ សោ ចាយំ ភិក្ខុ នវោ ភវិស្សតិ អចិរប្បព្វជិតោ ថេរោ វា បន ពាលោ អព្យត្តោតិ ។ អថខោ មំ ភន្តេ តេ អញ្ញតិត្ថិយា បរិព្វាជកា នវវាទេន ច ពាលវាទេន ច អបសាទេត្វា ឧដ្ឋាយាសនា បក្កមិំសុ ។ តស្ស មយ្ហំ ភន្តេ អចិរបក្កន្តេសុ តេសុ អញ្ញតិត្ថិយេសុ បរិព្វាជកេសុ ឯតទហោសិ សចេ ខោ មំ តេ អញ្ញតិត្ថិយា បរិព្វាជកា ឧត្តរិំ បុច្ឆេយ្យុំ កថំ ព្យាករមានោ នុ ខ្វាហំ តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ វុត្តវាទី ចេវ ភគវតោ អស្សំ ន ច ភគវន្តំ អភូតេន អព្ភាចិក្ខេយ្យំ ធម្មស្ស ចានុធម្មំ ព្យាករេយ្យំ ន ច កោចិ សហធម្មិកោ វាទានុបាតោ គារយ្ហំ ឋានំ អាគច្ឆេយ្យាតិ ។

និយាយមកនឹងខ្ញុំព្រះអង្គវិញដូច្នេះថា ភិក្ខុនេះប្រហែលជាភិក្ខុថ្មី បួសមិនទាន់បានយូរ ពុំនោះសោត លោកជាថេរៈដែរ តែល្ងង់មិនឈ្លាសវៃ ។ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះ បរិព្វាជក ជាអន្យតិរ្ថិយទាំងនោះ តិះដៀលខ្ញុំព្រះអង្គ ដោយពាក្យថានៅថ្មីផង ដោយពាក្យថាល្ងង់ផង ហើយក្រោកចាកអាសនៈ ចៀសចេញទៅ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលដែលបរិព្វាជកជាអន្យតិរ្ថិយទាំងនោះ ចៀសចេញទៅមិនយូរប៉ុន្មាន ខ្ញុំព្រះអង្គក៏មានសេចក្តីត្រិះរិះដូច្នេះថា បើបរិព្វាជកជាអន្យតិរ្ថិយទាំងនោះ សួរអាត្មាអញតទៅទៀត អាត្មាអញនឹងព្យាករដល់បរិព្វាជកជាអន្យតិរ្ថិយទាំងនោះដូចម្តេច ទើបឈ្មោះថាពោលតាមពាក្យដែលព្រះមានព្រះភាគពោលហើយផង មិនឈ្មោះថាពោលបង្កាច់ព្រះមានព្រះភាគ ដោយពាក្យមិនពិតផង ឈ្មោះថាព្យាករនូវធម៌តាមធម៌ផង ពាក្យពោលនីមួយដែលប្រកបដោយធម៌ មិនមកកាន់ស្ថានដែលបណ្ឌិតគប្បីតិះដៀលផង ។

[២៦០] តំ កឹ មញ្ញសិ អនុរាធ រូបំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ វេទនា ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ បេ ។ តស្មាតិហ ។ បេ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។

[២៦១] តំ កឹ មញ្ញសិ អនុរាធ រូបំ តថាគតោតិ សមនុបស្សសីតិ ។ នោ ហេតំ ភន្តេ ។ វេទនំ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ តថាគតោតិ សមនុបស្សសីតិ ។ នោ ហេតំ ភន្តេ ។

(៦១០) ព្រះអង្គត្រាស់ថា ម្នាលអនុរាធ អ្នកសំគាល់សេចក្តីនោះដូចម្តេច រូបទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណា មិនទៀង របស់នោះជាទុក្ខ ឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ណា ដែលមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរយល់ឃើញនូវរបស់នោះថា នុ៎ះជារបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ដូច្នេះដែរឬ ។ មិនគួរយល់ឃើញយ៉ាងនោះទេ ព្រះអង្គ ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។បេ។ ព្រោះហេតុនោះ ក្នុងសាសនានេះ ។បេ។ អរិយសាវកកាលឃើញយ៉ាងនេះ ។បេ។ រមែងដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

(៦១១) ម្នាលអនុរាធ អ្នកសំគាល់សេចក្តីនោះដូចម្តេច អ្នកពិចារណាឃើញនូវរូប ថាជាសត្វឬ ។ មិនដូច្នោះទេ ព្រះអង្គ ។ អ្នកពិចារណាឃើញ នូវវេទនា ។ នូវសញ្ញា ។ នូវសង្ខារទាំងឡាយ ។ នូវវិញ្ញាណ ថាជាសត្វឬ ។ មិនដូច្នោះទេ ព្រះអង្គ ។

(២១២) តំ កឹ មញ្ញសិ អនុរាធ រូបស្មឹ តថាគតោតិ សមនុបស្សសីតិ ។ នោ ហេតំ ភន្តេ ។ អញ្ញត្រ រូបា តថាគតោតិ សមនុបស្សសីតិ ។ នោ ហេតំ ភន្តេ ។ វេទនាយ ។ បេ ។ អញ្ញត្រ វេទនាយ ។ បេ ។ សញ្ញាយ ។ អញ្ញត្រ សញ្ញាយ ។ សង្ខារេសុ ។ អញ្ញត្រ សង្ខារេហិ ។ វិញ្ញាណស្មឹ ។ អញ្ញត្រ វិញ្ញាណា តថាគតោតិ សមនុបស្សសីតិ ។ នោ ហេតំ ភន្តេ ។

(២១៣) តំ កឹ មញ្ញសិ អនុរាធ រូបំ ។ វេទនា ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ តថាគតោតិ សមនុបស្សសីតិ ។ នោ ហេតំ ភន្តេ ។

(២១៤) តំ កឹ មញ្ញសិ អនុរាធ អយំ សោ អរូបី អវេទនោ អសញ្ញី អសង្ខារោ អវិញ្ញាណោ តថាគតោតិ សមនុបស្សសីតិ ។ នោ ហេតំ ភន្តេ ។ ឯត្ថ ច តេ អនុរាធ ទិដ្ឋេវ ធម្មេ សច្ចតោ ថេតតោ តថាគតោ អនុបលព្ភិយមានោ កល្លំ នុ តេ តំ វេយ្យាករណំ

[២១២] ម្នាលអនុរាធ អ្នកសំគាល់សេចក្ដីនោះ ដូចម្ដេច អ្នកពិចារណាឃើញថា សត្វមានក្នុងរូបឬ ។ មិនដូច្នោះទេ ព្រះអង្គ ។ អ្នកពិចារណាឃើញថា សត្វផ្សេងអំពីរូបឬ ។ មិនដូច្នោះទេ ព្រះអង្គ ។ ក្នុងវេទនា ។ បេ ។ ផ្សេងអំពីវេទនា ។ បេ ។ ក្នុងសញ្ញា ។ ផ្សេងអំពីសញ្ញា ។ ក្នុងសង្ខារទាំងឡាយ ។ ផ្សេងអំពីសង្ខារទាំងឡាយ ។ ក្នុងវិញ្ញាណ ។ អ្នកពិចារណាឃើញថា សត្វផ្សេងអំពីវិញ្ញាណឬ ។ មិនដូច្នោះទេ ព្រះអង្គ ។

[២១៣] ម្នាលអនុរាធ អ្នកសំគាល់សេចក្ដីនោះ ដូចម្ដេច អ្នកពិចារណាឃើញរូប ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ អ្នកពិរណាឃើញវិញ្ញាណថាជាសត្វឬ ។ មិនដូច្នោះទេ ព្រះអង្គ ។

[២១៤] ម្នាលអនុរាធ អ្នកសំគាល់សេចក្ដីនោះដូចម្ដេច អ្នកពិចារណាឃើញថាសត្វនេះ មិនមានរូប មិនមានវេទនា មិនមានសញ្ញា មិនមានសង្ខារ មិនមានវិញ្ញាណឬ ។ មិនដូច្នោះទេ ព្រះអង្គ ។ ម្នាលអនុរាធ ក៏ក្នុងរឿងនេះ កាលបើអ្នកកំណត់ថា ជារបស់ទៀង ជារបស់ពិត ក្នុងបច្ចុប្បន្នហើយ ការព្យាករណ៍របស់អ្នកនោះគួរហើយឬ ថា

យោ សោ អាវុសោ តថាគតោ ឧត្តមបុរិសោ បរមបុរិ-សោ បរមបត្តិបត្តោ តំ តថាគតោ អញ្ញត្រ ឥមេហិ ចតូហិ ឋានេហិ បញ្ញាបយមានោ បញ្ញាបេតិ ហោតិ តថាគតោ បរម្មរណាតិ វា ន ហោតិ តថាគតោ បរម្មរណាតិ វា ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណាតិ វា នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ វាតិ ។ នោ ហេតំ ភន្តេ ។ សាធុ សាធុ អនុរាធ បុព្វេ ចាហំ អនុរាធ ឯតរហិ ច ទុក្ខញ្ចេវ បញ្ញាបេមិ ទុក្ខស្ស ច និរោធន្តិ ។

(៦១៥) ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន អាយស្មា វក្កលិ កុម្ភការនិវេសនេ វិហរតិ អាពាធិកោ ទុក្ខិតោ ពាឡ្ហគិលានោ ។ អថខោ អាយស្មា វក្កលិ ឧបដ្ឋាកេ អាមន្តេសិ ឯថ តុម្ហេ អាវុសោ យេន ភគវា តេនុបសង្កមថ ឧបសង្កមិត្វា មម វចនេន ភគវតោ បាទេ សិរសា វន្ទថ វក្កលិ ភិក្ខុ អាពាធិកោ

ម្នាលអាវុសោ ព្រះតថាគតណា ជាបុរសដ៏ឧត្តម ជាបុរសដ៏ខ្ពង់ខ្ពស់ ដល់នូវតំណែងដ៏ខ្ពង់ខ្ពស់ ព្រះតថាគតនោះ កាលនឹងបញ្ញត្តនូវសត្វនោះ តែងបញ្ញត្តក្រៅពីស្ថាន ៤ នេះថា សត្វស្លាប់ទៅកើតទៀតក៏មាន សត្វស្លាប់ទៅមិនកើតទៀតក៏មាន សត្វស្លាប់ទៅកើតទៀតខ្លះ មិនកើតទៀតខ្លះក៏មាន សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក៏មាន ។ មិនគួរទេ ព្រះអង្គ ។ ម្នាលអនុរាធ ប្រពៃហើយ ប្រពៃហើយ ម្នាលអនុរាធ ក្នុងកាលមុនក្តី ក្នុងកាលឥឡូវនេះក្តី តថាគតបញ្ញត្ត នូវទុក្ខនិងសេចក្តីរលត់ទុក្ខ ។

[២១៥] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះវក្កលិមានអាយុ មានអាពាធ ដល់នូវសេចក្តីទុក្ខ មានជម្ងឺជាទម្ងន់ នៅក្នុងសាលារបស់ស្មូនឆ្នាំង ។ ព្រះវក្កលិមានអាយុ ក៏ហៅពួកភិក្ខុជាឧបដ្ឋាកមកថា ម្នាលអាវុសោទាំងឡាយ ចូរអ្នកទាំងឡាយមក ចូរអ្នកទាំងឡាយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ចូរថ្វាយបង្គំព្រះបាទារបស់ព្រះមានព្រះភាគដោយត្បូង តាមពាក្យរបស់ខ្ញុំថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុឈ្មោះវក្កលិ មានអាពាធ

ទុក្ខិតោ ពាឡ្ហគិលានោ សោ ភគវតោ បាទេ សិរសា វន្ទតីតិ ឯវញ្ច វទេថ សាធុ កិរ ភន្តេ ភគវា យេន វក្កលិ ភិក្ខុ តេនុបសង្កមតុ អនុកម្បំ ឧបាទាយាតិ ។ ឯវមាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ វក្កលិស្ស បដិស្សុត្វា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ។ បេ ។ ភគវន្តំ ឯតទវោចុំ វក្កលិ ភន្តេ ភិក្ខុ អាពាធិកោ ទុក្ខិតោ ពាឡ្ហគិលានោ សោ ភគវតោ បាទេ សិរសា វន្ទតិ ឯវញ្ច វទេតិ សាធុ កិរ ភន្តេ ភគវា យេន វក្កលិ ភិក្ខុ តេនុបសង្កមតុ អនុកម្បំ ឧបាទាយាតិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។

ដល់នូវសេចក្ដីទុក្ខ មានជម្ងឺជាទម្ងន់ លោកថ្វាយបង្គំព្រះបាទាព្រះមានព្រះភាគដោយត្បូង ហើយអ្នកទាំងឡាយ ចូរពោលយ៉ាងនេះទៀតថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគស្ដេចទៅរកភិក្ខុឈ្មោះវក្កលិ ដោយសេចក្ដីអនុគ្រោះ ។ ភិក្ខុអម្បាលនោះទទួលពាក្យរបស់ព្រះវក្កលិ មានអាយុថា ករុណា អាវុសោ ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ។ បេ ។ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុឈ្មោះវក្កលិ មានអាពាធ ដល់នូវសេចក្ដីទុក្ខ មានជម្ងឺជាទម្ងន់ លោកថ្វាយបង្គំព្រះបាទាព្រះមានព្រះភាគដោយត្បូង មួយទៀត លោកពោលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគស្ដេចទៅរកព្រះវក្កលិ ដោយសេចក្ដីអនុគ្រោះ ។ ព្រះមានព្រះភាគទ្រង់ទទួល ដោយតុណ្ហីភាព ។

[២០៦] អថខោ ភគវា និវាសេត្វា បត្តចីវរមាទាយ យេនាយស្មា វក្កលិ តេនុបសង្កមិ ។ អទ្ទសា ខោ អាយស្មា វក្កលិ ភគវន្តំ ទូរតោវ អាគច្ឆន្តំ ទិស្វាន មញ្ចកេ សមញ្ចោសិ(១) ។ អថខោ ភគវា អាយស្មន្តំ វក្កលឹ ឯតទវោច អលំ វក្កលិ មា ត្វំ មញ្ចកេ សមញ្ចោសិ សន្តិមានិ អាសនានិ បញ្ញត្តានិ តត្ថាហំ និសីទិស្សាមីតិ ។ និសីទិ ភគវា បញ្ញត្តេ អាសនេ ។ និសជ្ជ ខោ ភគវា អាយស្មន្តំ វក្កលឹ ឯតទវោច កច្ចិ តេ វក្កលិ ខមនីយំ កច្ចិ យាបនីយំ កច្ចិ ទុក្ខា វេទនា បដិក្កមន្តិ នោ អភិក្កមន្តិ បដិក្កមោសានំ បញ្ញាយតិ នោ អភិក្កមោតិ ។ ន មេ ភន្តេ ខមនីយំ ន យាបនីយំ ពាឡ្ហា មេ ទុក្ខា វេទនា អភិក្កមន្តិ នោ បដិក្កមន្តិ អភិក្កមោសានំ បញ្ញាយតិ នោ បដិក្កមោតិ ។ កច្ចិ តេ វក្កលិ ន កិញ្ចិ កុក្កុច្ចំ ន កោចិ វិប្បដិសារោតិ ។ តគ្ឃ មេ ភន្តេ អនប្បកំ កុក្កុច្ចំ អនប្បកោ វិប្បដិសារោតិ ។

---

១ ម. សមធោសិ ។

[២១៦] លំដាប់នោះ ព្រះមានព្រះភាគទ្រង់ស្បង់ប្រដាប់បាត្រ និងចីវរហើយ ទ្រង់ស្តេចទៅរកព្រះវក្កលិមានអាយុ ។ ព្រះវក្កលិមានអាយុ បានឃើញព្រះមានព្រះភាគ កំពុងស្តេចមកអំពីចម្ងាយ លុះឃើញហើយ ក៏សំដែងកិរិយាតេះតះលើគ្រែ ។ ទើបព្រះមានព្រះភាគត្រាស់នឹងព្រះវក្កលិមានអាយុដូច្នេះថា ម្នាលវក្កលិ ណ្ហើយចុះ អ្នកកុំតេះតះលើគ្រែឡើយ តថាគតនឹងអង្គុយលើអាសនៈដែលគេក្រាលបំរុងហើយនេះ ។ ព្រះមានព្រះភាគ ក៏គង់លើអាសនៈដែលគេក្រាលហើយ ។ លុះព្រះមានព្រះភាគគង់ហើយ ទើបត្រាស់នឹងព្រះវក្កលិមានអាយុដូច្នេះថា ម្នាលវក្កលិ អ្នកល្មមអត់ធន់បានខ្លះឬ អ្នកល្មមប្រព្រឹត្តទៅបានខ្លះឬ ទុក្ខវេទនាធូរថយមិនចំរើនឡើង សេចក្តីធូរថយរមែងប្រាកដ មិនចំរើនឡើងទេឬ ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គអត់ធន់មិនបានទេ ខ្ញុំព្រះអង្គប្រព្រឹត្តទៅមិនបានទេ ទុក្ខវេទនាជាទម្ងន់ចំរើនឡើងដល់ខ្ញុំព្រះអង្គ មិនធូរថយទេ សេចក្តីចំរើនប្រាកដឡើង មិនធូរថយទេ ។ ម្នាលវក្កលិ អ្នកឥតមានសេចក្តីរង្កៀសបន្តិចបន្តួចទេឬ អ្នកឥតមានសេចក្តីក្តៅក្រហាយអ្វីទេឬ ។ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមានសេចក្តីរង្កៀសជាច្រើន ខ្ញុំព្រះអង្គមានសេចក្តីក្តៅក្រហាយជាច្រើន ។

កច្ចិ បន តំ វក្កលិ អត្តា សីលតោ ន ឧបវទតីតិ ។
ន ខោ មំ ភន្តេ អត្តា សីលតោ ឧបវទតីតិ ។
នោ ចេ កិរ តំ វក្កលិ អត្តា សីលតោ ឧបវទតិ
អថ កិញ្ច តេ កុក្កុច្ចំ កោ ច វិប្បដិសារោតិ ។
ចិរប្បដិកាហំ ភន្តេ ភគវន្តំ ទស្សនាយ ឧបសង្កមិ-
តុកាមោ នត្ថិ ច មេ កាយស្មឹ តាវតិកា ពលមត្តា
យាវតាហំ ភគវន្តំ ទស្សនាយ ឧបសង្កមេយ្យន្តិ ។
អលំ វក្កលិ កឹ តេ ឥមិនា បូតិកាយេន ទិដ្ឋេន ។
យោ ខោ វក្កលិ ធម្មំ បស្សតិ សោ មំ បស្សតិ យោ
មំ បស្សតិ សោ ធម្មំ បស្សតិ ។ ធម្មំ ហិ វក្កលិ
បស្សន្តោ មំ បស្សតិ មំ បស្សន្តោ ធម្មំ បស្សតិ ។
តំ កឹ មញ្ញសិ វក្កលិ រូបំ និច្ចំ វា អនិច្ចំ វាតិ ។

ម្នាលវក្កលិ ខ្លួនអ្នកមិនតិះដៀលអ្នកឯង ដោយសីលទេឬ ។ បពិត្រព្រះអង្គដ៏ចំរើន ខ្លួនខ្ញុំមិនតិះដៀលខ្ញុំព្រះអង្គ ដោយសីលទេ ។ ម្នាលវក្កលិ បើខ្លួនអ្នកមិនតិះដៀលអ្នកឯងដោយសីលទេ ចុះអ្នកឯងរង្កៀសដូចម្តេច ក្តៅក្រហាយដូចម្តេច ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចង់ចូលទៅចួបព្រះមានព្រះភាគ តាំងពីយូរយារហើយ ប៉ុន្តែខ្ញុំព្រះអង្គមិនមានកម្លាំងកាយ ល្មមចូលទៅចួបព្រះមានព្រះភាគបានសោះឡើយ ។ កុំឡើយ វក្កលិ ប្រយោជន៍អ្វីដោយកាយស្អុយ ដែលអ្នកឃើញហើយនេះ ។ ម្នាលវក្កលិ បុគ្គលណាមួយឃើញធម៌ បុគ្គលនោះឈ្មោះថាឃើញតថាគត បុគ្គលណាឃើញតថាគត បុគ្គលនោះឈ្មោះថាឃើញធម៌ ។ ម្នាលវក្កលិ ព្រោះថា កាលបើបុគ្គលឃើញធម៌ ឈ្មោះថាឃើញតថាគត កាលបើបុគ្គលឃើញតថាគត ឈ្មោះថាឃើញធម៌ ។ ម្នាលវក្កលិ អ្នកសំគាល់សេចក្តីនោះ ដូចម្តេច រូបទៀង ឬមិនទៀង ។

អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ វេទនា ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ បេ ។ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ តស្មាតិហ ។ បេ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។ អថខោ ភគវា អាយស្មន្តំ វក្កលិំ ឥមិនា ឱវាទេន ឱវទិត្វា ឧដ្ឋាយាសនា យេន គិជ្ឈកូដោ បព្វតោ តេន បក្កាមិ(១) ។

---

១ ម. តេនុបសង្កមិ ។

បពិត្រព្រះអង្គដ៏ចម្រើន មិនទៀងទេ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ បពិត្រព្រះអង្គដ៏ចម្រើន ជាទុក្ខ ។ ចុះរបស់ណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា របស់នោះគួរដើម្បីយល់ឃើញថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនគួរដើម្បីយល់ឃើញយ៉ាងនោះទេ ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណទៀង ឬមិនទៀង ។ បពិត្រព្រះអង្គដ៏ចម្រើន មិនទៀងទេ ។ បេ ។ នុ៎ះជាខ្លួនអញដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនគួរដើម្បីយល់ឃើញយ៉ាងនោះទេ ។ ព្រោះហេតុនោះ អរិយសាវ័កក្នុងសាសនានេះ ។ បេ ។ យល់ឃើញយ៉ាងនេះ ។ បេ ។ ក៏ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ លុះព្រះមានព្រះភាគ ទ្រង់ទូន្មានព្រះវក្កលិមានអាយុ ដោយព្រះឱវាទនេះហើយ ក៏ក្រោកចាកអាសនៈ ស្តេចចេញទៅកាន់ភ្នំគិជ្ឈកូដ ។

[២០៧] អថខោ អាយស្មា វក្កលិ អចិរបក្កន្តស្ស ភគវតោ ឧបដ្ឋាកេ អាមន្តេសិ ឯថ មំ អាវុសោ មញ្ចកំ អារោបេត្វា យេន ឥសិគិលិបស្សំ កាឡសិលា តេនុបសង្កមថ កថំ ហិ នាម មាទិសោ អន្តរឃរេ កាលំ កត្តព្វំ មញ្ញេយ្យាតិ ។ ឯវមាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ វក្កលិស្ស បដិស្សុត្វា អាយស្មន្តំ វក្កលឹ មញ្ចកំ អារោបេត្វា យេន ឥសិគិលិបស្សំ កាឡសិលា តេនុបសង្កមឹសុ ។ អថខោ ភគវា តញ្ច រត្តឹ តញ្ច ទិវាសាវសេសំ គិជ្ឈកូដេ បព្វតេ វិហាសិ ។ អថខោ ទ្វេ ទេវតាយោ អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ គិជ្ឈកូដំ ឱភាសេត្វា យេន ភគវា តេនុបសង្កមឹសុ ។ បេ ។ ឯកមន្តំ អដ្ឋំសុ ។

(១១៧) កាលព្រះមានព្រះភាគ ទ្រង់ស្ដេចចេញទៅ មិនយូរប៉ុន្មាន ព្រះវក្កលិ ក៏ហៅពួកភិក្ខុជាឧបដ្ឋាកមកថា ម្នាលអាវុសោទាំងឡាយ ចូរអ្នកទាំងឡាយមកអាយ ចូរអ្នកទាំងឡាយ លើកខ្ញុំឡើងកាន់គ្រែ ហើយនាំទៅឯវត្តកាឡសិលា ក្បែរភ្នំឥសិគិលិ ព្រោះបុគ្គលដូចជាខ្ញុំមិនសមបើនឹងធ្វើកាលកិរិយា ក្នុងចន្លោះផ្ទះឡើយ ។ ភិក្ខុទាំងនោះ ទទួលពាក្យរបស់ព្រះវក្កលិមានអាយុដូច្នេះថា ករុណា អាវុសោ ហើយលើកព្រះវក្កលិមានអាយុឡើងកាន់គ្រែ សែងនាំទៅឯវត្តកាឡសិលា ក្បែរភ្នំឥសិគិលិ ។ គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់គង់លើភ្នំគិជ្ឈកូដអស់រាត្រីនោះនឹងថ្ងៃនោះ ។ កាលរាត្រី (បឋមយាម) កន្លងហើយ ទេវតា ២ អង្គ មានរស្មីដ៏រុងរឿង ញ៉ាំងភ្នំគិជ្ឈកូដទាំងមូលឲ្យភ្លឺ ហើយចូលទៅគាល់ព្រះមានព្រះភាគ ។ បេ ។ ឋិតនៅក្នុងទីដ៏សមគួរ ។

ឯកមន្តំ ឋិតា ខោ ឯកា ទេវតា ភគវន្តំ ឯតទវោច វក្កលិ ភន្តេ ភិក្ខុ វិមោក្ខាយ ចេតេតីតិ ។ អបរា ទេវតា ភគវន្តំ ឯតទវោច សោ ហិ នូន សោ(១) ភន្តេ សុវិមុត្តោ វិមុច្ចិស្សតីតិ ។ ឥទមវោចុំ តា ទេវតាយោ ឥទំ វត្វា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេ-វន្តរធាយឹសុ ។

(២១៨) អថខោ ភគវា តស្សា រត្តិយា អច្ចយេន ភិក្ខូ អាមន្តេសិ ឯថ តុម្ហេ ភិក្ខវេ យេន វក្កលិ ភិក្ខុ តេនុបសង្កមថ ឧបសង្កមិត្វា វក្កលឹ ភិក្ខុំ ឯវំ វទេថ សុណាវុសោ ត្វំ វក្កលិ ភគវតោ វចនំ ទ្វិន្នំ ទេវតានំ ឥមំ អាវុសោ រត្តឹ ទ្វេ ទេវតាយោ អភិក្កន្តា-យ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ គិជ្ឈកូដំ ឱភាសេត្វា យេន ភគវា តេនុបសង្កមឹសុ ឧបសង្ក-មិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ ឯកមន្តំ ឋិតា ខោ អាវុសោ ឯកា ទេវតា ភគវន្តំ ឯតទវោច

១ ម. អយំ សទ្ទោ ន ទិស្សតិ ។

លុះទេវតាមួយអង្គឋិតនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន វក្កលិភិក្ខុកំពុងត្រិះរិះដើម្បីមគ្គវិមោក្ខ ។ ទេវតាមួយអង្គទៀត ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន វក្កលិភិក្ខុនោះ ជាអ្នកចិត្តរួចស្រឡះចាកកិលេស មុខជានឹងរួចដោយពិត ។ ទេវតាទាំងនោះបានពោលពាក្យនេះ លុះពោលពាក្យនេះហើយ ក៏អភិវាទព្រះមានព្រះភាគ ធ្វើប្រទក្សិណ ហើយបាត់ទៅក្នុងទីនោះឯង ។

[២១៨] លុះរាត្រីនោះ កន្លងទៅហើយ ព្រះមានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយមកអាយ ចូរអ្នកទាំងឡាយចូលទៅរកវក្កលិភិក្ខុ លុះចូលទៅដល់ហើយត្រូវប្រាប់វក្កលិភិក្ខុយ៉ាងនេះថា ម្នាលអាវុសោវក្កលិ ចូរអ្នកស្តាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគ និងពាក្យរបស់ទេវតាទាំងពីរអង្គ ម្នាលអាវុសោ ក្នុងយប់មិញនេះ កាលដែលរាត្រី (បឋមយាម) កន្លងហើយទេវតាពីរអង្គ មានរស្មីដ៏រុងរឿង ញុំាងភ្នំគិជ្ឈកូដទាំងមូលឲ្យភ្លឺ ចូលមកគាល់ព្រះមានព្រះភាគ លុះចូលមកដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ ម្នាលអាវុសោ លុះទេវតាមួយអង្គឋិតនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា

វក្កលិ ភន្តេ ភិក្ខុ វិមោក្ខាយ ចេតេតីតិ ។ អបរា ទេវតា ភគវន្តំ ឯតទវោច សោ ហិ នូន សោ(១) ភន្តេ សុវិមុត្តោ វិមុច្ចិស្សតីតិ ។ ភគវា ច តំ អាវុសោ វក្កលិ ឯវមាហ មា ភាយិ វក្កលិ មា ភាយិ វក្កលិ អបាបកន្តេ មរណំ ភវិស្សតិ អបាបិកា កាល-កិរិយាតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បដិស្សុត្វា យេនាយស្មា វក្កលិ តេនុបសង្កមឹសុ ឧ-បសង្កមិត្វា អាយស្មន្តំ វក្កលឹ ឯតទវោចុំ សុណា-វុសោ វក្កលិ ភគវតោ វចនំ ទ្វិន្នញ្ច ទេវតានន្តិ ។

[២១៩] អថខោ អាយស្មា វក្កលិ ឧបដ្ឋាកេ អាមន្តេសិ ឯថ មំ អាវុសោ មញ្ចកា ឱរោបេថ កថំ ហិ នាម មាទិសោ ឧច្ចេ អាសនេ និសីទិត្វា តស្ស ភគវតោ សាសនំ សោតព្វំ មញ្ញេយ្យាតិ ។ ឯវ-មាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ វក្កលិស្ស បដិស្សុត្វា អាយស្មន្តំ វក្កលឹ មញ្ចកា ឱរោបេសុំ

១ ម. អយំ ន ទិស្សតិ ។

បពិត្រព្រះអង្គដ៏ចម្រើន វក្កលិភិក្ខុ កំពុងត្រិះរិះដើម្បីវិមោក្ខ ។ ទេវតាមួយអង្គទៀត ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន វក្កលិភិក្ខុនោះ ជាអ្នកចង់រួចស្រឡះចាកកិលេស មុខជានឹងរួចដោយពិត ។ ម្នាលអាវុសោវក្កលិ ទាំងព្រះមានព្រះភាគ ក៏បានត្រាស់នឹងអ្នកយ៉ាងនេះថា ម្នាលវក្កលិ អ្នកកុំខ្លាចឡើយ ម្នាលវក្កលិ អ្នកកុំខ្លាចឡើយ មរណៈរបស់អ្នក មុខជាមិនអាក្រក់ទេ កាលកិរិយា ក៏មុខជាមិនអាក្រក់ទេ ដូច្នេះដែរ ។ ភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ហើយចូលទៅរកព្រះវក្កលិមានអាយុ លុះចូលទៅដល់ហើយ ក៏និយាយនឹងព្រះវក្កលិមានអាយុដូច្នេះថា ម្នាលអាវុសោវក្កលិ អ្នកចូរស្តាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគ នឹងពាក្យរបស់ទេវតាទាំងពីរអង្គ ។

( ៦១៩ ) លំដាប់នោះ ព្រះវក្កលិមានអាយុ ហៅភិក្ខុទាំងឡាយជាឧបដ្ឋាកថា ម្នាលអាវុសោទាំងឡាយ ចូរអ្នកទាំងឡាយ មកអាយ ចូរអ្នកទាំងឡាយ ដាក់ខ្ញុំចុះអំពីគ្រែ ព្រោះបុគ្គលដូចជាខ្ញុំ មិនសមបើនឹងអង្គុយលើអាសនៈខ្ពស់ ស្តាប់ពាក្យប្រៀនប្រដៅ របស់ព្រះមានព្រះភាគអង្គនោះទេ ។ ភិក្ខុទាំងនោះ ទទួលស្តាប់ពាក្យរបស់ព្រះវក្កលិមានអាយុថា ករុណា អាវុសោ ហើយដាក់ព្រះវក្កលិមានអាយុចុះអំពីគ្រែ

ឥមំ អាវុសោ រត្តឹ ទ្វេ ទេវតាយោ អភិក្កន្តាយ រត្តិយា ។ បេ ។ ឯកមន្តំ អដ្ឋំសុ ឯកមន្តំ ឋិតា ខោ អាវុសោ ឯកា ទេវតា ភគវន្តំ ឯតទវោច វក្កលិ ភន្តេ ភិក្ខុ វិមោក្ខាយ ចេតេតីតិ ។ អបរា ទេវតា ភគវន្តំ ឯតទវោច សោ ហិ នូន សោ(១) ភន្តេ សុវិមុត្តោ វិមុច្ចិស្សតីតិ ។ ភគវា ច តំ អាវុសោ វក្កលិ ឯវមាហ មា ភាយិ វក្កលិ មា ភាយិ វក្កលិ អបាបកន្តេ មរណំ ភវិស្សតិ អបាបិកា កាលកិរិយាតិ ។ តេនហាវុសោ មម វចនេន ភគវតោ បាទេ សិរសា វន្ទ វក្កលិ ភន្តេ ភិក្ខុ អាពាធិកោ ទុក្ខិតោ ពាឡ្ហគិលានោ សោ ភគវតោ បាទេ សិរសា វន្ទតិ ឯវញ្ច វទេតិ រូបំ អនិច្ចំ តាហំ ភន្តេ ន កង្ខាមិ

១ ម. អយំ ន ទិស្សតិ ។

រូបពោលថា ម្នាលអាវុសោ យប់មិញនេះ កាលដែលរាត្រី (បឋមយាម) កន្លងហើយ ទេវតាពីរអង្គ ។ បេ ។ បានឋិតនៅក្នុងទីសមគួរ ម្នាលអាវុសោ លុះទេវតាមួយអង្គ ឋិតនៅក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន វក្កលិភិក្ខុ កំពុងត្រិះរិះដើម្បីមគ្គវិមោក្ខ ។ ទេវតាមួយអង្គទៀត ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន វក្កលិភិក្ខុនោះ ជាអ្នកចន្លូវរូបស្រឡះ បាកកិលេស មុខជានឹងរួចដោយពិត ។ ម្នាលអាវុសោវក្កលិ ចាំង ព្រះមានព្រះភាគ ត្រាស់នឹងអ្នកយ៉ាងនេះថា ម្នាលវក្កលិ អ្នកកុំខ្លាចឡើយ ម្នាលវក្កលិ អ្នកកុំខ្លាចឡើយ មរណៈរបស់អ្នក មុខជាមិនអាក្រក់ទេ កាលកិរិយារបស់អ្នក ក៏មុខជាមិនអាក្រក់ទេ ដូច្នេះដែរ ។ ព្រះវក្កលិពោលថា ម្នាលអាវុសោទាំងឡាយ បើដូច្នោះ ចូរអ្នកទាំងឡាយថ្វាយបង្គំព្រះបាទា របស់ព្រះមានព្រះភាគ ដោយត្បូង តាមពាក្យរបស់ខ្ញុំថា បពិត្រព្រះអង្គដ៏ចម្រើន វក្កលិភិក្ខុ មានអាពាធ ដល់នូវសេចក្តីទុក្ខ មានជម្ងឺជាទម្ងន់ លោកថ្វាយបង្គំព្រះបាទា របស់ព្រះមានព្រះភាគ ដោយត្បូង មួយទៀត លោកពោលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនងឿងឆ្ងល់ទេ ត្រង់ពាក្យថា រូបមិនទៀង

យទនិច្ចំ តំ ទុក្ខន្តិ ន វិចិកិច្ឆាមិ យទនិច្ចំ ទុក្ខំ វិបរិណាមធម្មំ នត្ថិ មេ តត្ថ ឆន្ទោ វា រាគោ វា បេមំ វាតិ ន វិចិកិច្ឆាមិ ។ វេទនា អនិច្ចាតាហំ កង្ខេ ន កង្ខាមិ យទនិច្ចំ តំ ទុក្ខន្តិ ន វិចិកិច្ឆាមិ យទនិច្ចំ ទុក្ខំ វិបរិណាមធម្មំ នត្ថិ មេ តត្ថ ឆន្ទោ វា រាគោ វា បេមំ វាតិ ន វិចិកិច្ឆាមិ ។ សញ្ញា អនិច្ចាតាហំ កង្ខេ ន កង្ខាមិ យទនិច្ចំ តំ ទុក្ខន្តិ ន វិចិកិច្ឆាមិ យទនិច្ចំ ទុក្ខំ វិបរិណាមធម្មំ នត្ថិ មេ តត្ថ ឆន្ទោ វា រាគោ វា បេមំ វាតិ ន វិចិកិច្ឆាមិ ។ សង្ខារា អនិច្ចាតាហំ កង្ខេ ន កង្ខាមិ

ខ្ញុំព្រះអង្គមិនសង្ស័យទេ ត្រង់ពាក្យថា រូបណាមិនទៀង រូបនោះជាទុក្ខ ខ្ញុំព្រះអង្គមិនសង្ស័យទេ ត្រង់ពាក្យថា រូបណាមិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា ខ្ញុំព្រះអង្គមិនមានសេចក្ដីពេញចិត្ត ឬសេចក្ដីត្រេកត្រអាល សេចក្ដីស្រឡាញ់ ក្នុងរូបនោះឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ មិនងឿងឆ្ងល់ទេ ត្រង់ពាក្យថា វេទនាមិនទៀង ខ្ញុំព្រះអង្គមិនសង្ស័យទេ ត្រង់ពាក្យថា វេទនាណាមិនទៀង វេទនានោះជាទុក្ខ ខ្ញុំព្រះអង្គមិនសង្ស័យទេ ត្រង់ពាក្យថា វេទនាណាមិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា ខ្ញុំព្រះអង្គមិនមានសេចក្ដីពេញចិត្ត ឬសេច-ក្ដីត្រេកត្រអាល សេចក្ដីស្រឡាញ់ ក្នុងវេទនានោះឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនងឿងឆ្ងល់ទេ ត្រង់ពាក្យថា សញ្ញាមិនទៀង ខ្ញុំព្រះអង្គមិនសង្ស័យទេ ត្រង់ពាក្យថា សញ្ញាណាមិនទៀង សញ្ញានោះជាទុក្ខ ខ្ញុំព្រះអង្គមិនសង្ស័យទេ ត្រង់ពាក្យថា សញ្ញាណា មិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា ខ្ញុំព្រះអង្គមិនមានសេចក្ដីពេញចិត្ត ឬសេចក្ដីត្រេកត្រអាល សេចក្ដីស្រឡាញ់ ក្នុងសញ្ញានោះឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនងឿងឆ្ងល់ទេ ត្រង់ពាក្យថា ពួកសង្ខារមិនទៀង

យទនិច្ចំ តំ ទុក្ខន្តិ ន វិចិកិច្ឆាមិ យទនិច្ចំ ទុក្ខំ វិបរិណាមធម្មំ នត្ថិ មេ តត្ថ ឆន្ទោ វា រាគោ វា បេមំ វាតិ ន វិចិកិច្ឆាមិ ។ វិញ្ញាណំ អនិច្ចតាហំ ភន្តេ ន កង្ខាមិ យទនិច្ចំ តំ ទុក្ខន្តិ ន វិចិកិច្ឆាមិ យទនិច្ចំ ទុក្ខំ វិបរិណាមធម្មំ នត្ថិ មេ តត្ថ ឆន្ទោ វា រាគោ វា បេមំ វាតិ ន វិចិកិច្ឆាមីតិ ។ ឯវ-មាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ វក្កលិស្ស បដិស្សុត្វា បក្កមឹសុ ។ អថខោ អាយស្មា វក្កលិ អចិរបក្កន្តេសុ តេសុ ភិក្ខូសុ សត្ថំ អាហរេសិ ។

ខ្ញុំព្រះអង្គមិនសង្ស័យទេ ត្រង់ពាក្យថា សង្ខារណាមិនទៀង សង្ខារនោះជាទុក្ខ ខ្ញុំព្រះអង្គមិនសង្ស័យទេ ត្រង់ពាក្យថា សង្ខារណាមិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា ខ្ញុំព្រះអង្គមិនមានសេចក្ដីពេញចិត្ត ឬសេចក្ដីត្រេកត្រអាល សេចក្ដីស្រឡាញ់ ក្នុងសង្ខារទាំងនោះឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនងឿងឆ្ងល់ទេ ត្រង់ពាក្យថា វិញ្ញាណមិនទៀង ខ្ញុំព្រះអង្គមិនសង្ស័យទេ ត្រង់ពាក្យថា វិញ្ញាណណាមិនទៀង វិញ្ញាណនោះជាទុក្ខ ខ្ញុំព្រះអង្គមិនសង្ស័យទេ ត្រង់ពាក្យថា វិញ្ញាណណាមិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា ខ្ញុំព្រះអង្គមិនមានសេចក្ដីពេញចិត្ត ឬសេចក្ដីត្រេកត្រអាល សេចក្ដីស្រឡាញ់ ក្នុងវិញ្ញាណនោះឡើយ ។ ភិក្ខុអម្បាលនោះ ទទួលស្ដាប់ពាក្យរបស់ព្រះវក្កលិមានអាយុថា ករុណា អាវុសោ ហើយក៏ចៀសចេញទៅ ។ កាលភិក្ខុទាំងឡាយចៀសចេញទៅ មិនយូរប៉ុន្មាន ព្រះវក្កលិមានអាយុ ក៏ទាញយកកាំបិតមក ។

(២២០) អថខោ តេ ភិក្ខូ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ វក្កលិ ភន្តេ ភិក្ខុ អាពាធិកោ ទុក្ខិតោ ពាឡ្ហគិលានោ សោ ភគវតោ បាទេ សិរសា វន្ទតិ ឯវញ្ច វទេតិ រូបំ អនិច្ចំតាហំ ភន្តេ ន កង្ខាមិ យទនិច្ចំ តំ ទុក្ខន្តិ ន វិចិកិច្ឆាមិ យទនិច្ចំ ទុក្ខំ វិបរិណាមធម្មំ នត្ថិ មេ តត្ថ ឆន្ទោ វា រាគោ វា បេមំ វាតិ ន វិចិកិច្ឆាមិ ។ វេទនា ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ អនិច្ចំតាហំ ភន្តេ ន កង្ខាមិ យទនិច្ចំ តំ ទុក្ខន្តិ

[២២០] លំដាប់នោះ ភិក្ខុទាំងអម្បាលនោះ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីដ៏សមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន វក្កលិភិក្ខុ មានអាពាធ ដល់នូវសេចក្តីទុក្ខ មានជម្ងឺជាទម្ងន់ លោកថ្វាយបង្គំព្រះបាទា របស់ព្រះមានព្រះភាគដោយត្បូង មួយទៀត លោកពោលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនងឿងឆ្ងល់ទេ ត្រង់ពាក្យថា រូបមិនទៀង ខ្ញុំព្រះអង្គមិនសង្ស័យទេ ត្រង់ពាក្យថា រូបណាមិនទៀង រូបនោះជាទុក្ខ ខ្ញុំព្រះអង្គមិនសង្ស័យទេ ត្រង់ពាក្យថា រូបណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា ខ្ញុំព្រះអង្គមិនមានសេចក្តីពេញចិត្ត ឬសេចក្តីត្រេកត្រអាល សេចក្តីស្រឡាញ់ ក្នុងរូបនោះឡើយ ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនងឿងឆ្ងល់ទេ ត្រង់ពាក្យថា វិញ្ញាណមិនទៀង ខ្ញុំព្រះអង្គមិនសង្ស័យទេ ត្រង់ពាក្យថា វិញ្ញាណណាមិនទៀង វិញ្ញាណនោះជាទុក្ខ

ន វិចិកិច្ឆាមិ យទនិច្ចំ ទុក្ខំ វិបរិណាមធម្មំ នត្ថិ មេ តត្ថ ឆន្ទោ វា រាគោ វា បេមំ វាតិ ន វិចិកិច្ឆា-មីតិ ។

(២២១) អថខោ ភគវា ភិក្ខូ អាមន្តេសិ អាយាម ភិក្ខវេ យេន ឥសិគិលិបស្សំ កាឡសិលា តេនុប-សង្កមិស្សាម យត្ថ វក្កលិនា កុលបុត្តេន សត្ថំ អាហរិ-តន្តិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោ-សុំ ។ អថខោ ភគវា សម្ពហុលេហិ ភិក្ខូហិ សទ្ធឹ យេន ឥសិគិលិបស្សំ កាឡសិលា តេនុបសង្កមិ ។ អទ្ទសា ខោ ភគវា អាយស្មន្តំ វក្កលឹ ទូរតោវ មញ្ចកេ វិវត្តក្ខន្ធំ សេយ្យមានំ ។ តេន ខោ បន សមយេន ធូមាយិតត្តំ តិមិរាយិតត្តំ គច្ឆតេវ បុរិមទិសំ គច្ឆតិ បច្ឆិមទិសំ គច្ឆតិ ឧត្តរទិសំ គច្ឆតិ ទក្ខិណទិ-សំ គច្ឆតិ ឧទ្ធំទិសំ គច្ឆតិ អធោទិសំ គច្ឆតិ អនុទិ-សំ ។ អថខោ ភគវា ភិក្ខូ អាមន្តេសិ បស្សថ នោ តុម្ហេ ភិក្ខវេ ឯតំ ធូមាយិតត្តំ តិមិរាយិតត្តំ គច្ឆតេវ បុរិមទិសំ ។បេ។ គច្ឆតិ អនុទិសន្តិ ។ ឯវំ ភន្តេ ។

ខ្ញុំព្រះអង្គមិនសង្ស័យទេ ត្រង់ពាក្យថា វិញ្ញាណមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា ខ្ញុំព្រះអង្គមិនមានសេចក្តីពេញចិត្ត ឬសេចក្តីត្រេកត្រអាល សេចក្តីស្រឡាញ់ ក្នុងវិញ្ញាណនោះឡើយ ។

[៥៦១] គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ មក យើងនឹងទៅកាន់វត្តកាឡសិលា ក្បែរភ្នំឥសិគិលិ ត្រង់ទីដែលវក្កលិកុលបុត្តទាញយកកាំបិតមក ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ទើបព្រះមានព្រះភាគ ទ្រង់ស្តេចសំដៅទៅកាន់វត្តកាឡសិលា ក្បែរភ្នំឥសិគិលិ មួយអន្លើដោយពួកភិក្ខុជាច្រើនរូប ។ ព្រះមានព្រះភាគ បានឃើញព្រះវក្កលិមានអាយុអំពីចម្ងាយ កំពុងដេកផ្អាកកលើគ្រែ ។ សម័យនោះឯង ផ្សែងអ័ព្ទ ក៏ផ្សាយទៅកាន់ទិសខាងកើត ទៅកាន់ទិសខាងលិច ទៅកាន់ទិសខាងជើង ទៅកាន់ទិសខាងត្បូង ទៅកាន់ទិសខាងលើ ទៅកាន់ទិសខាងក្រោម ទៅកាន់ទិសតូច ។ លំដាប់នោះ ព្រះមានព្រះភាគ ក៏ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញផ្សែងអ័ព្ទ ផ្សាយទៅកាន់ទិសខាងកើត ។បេ។ ទៅកាន់ទិសតូច យ៉ាងនេះដែរឬ ។ ព្រះករុណា ព្រះអង្គ ។

ឯសោ ខោ ភិក្ខវេ មារោ បាបិមា វក្កលិស្ស កុលបុត្តស្ស វិញ្ញាណំ សមន្វេសតិ កត្ថ វក្កលិស្ស កុលបុត្តស្ស វិញ្ញាណំ បតិដ្ឋិតន្តិ ។ អប្បតិដ្ឋិតេន ច ភិក្ខវេ វិញ្ញាណេន វក្កលិ កុលបុត្តោ បរិនិព្វុតោតិ ។

[២២២] ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន អាយស្មា អស្សជិ កស្សបការាមេ វិហរតិ អាពាធិកោ ទុក្ខិតោ ពាឡ្ហគិលានោ ។ អថខោ អាយស្មា អស្សជិ ឧបដ្ឋាកេ អាមន្តេសិ ឯថ តុម្ហេ អាវុសោ យេន ភគវា តេនុបសង្កមថ ឧបសង្កមិត្វា មម វចនេន ភគវតោ បាទេ សិរសា វន្ទថ អស្សជិ ភន្តេ ភិក្ខុ អាពាធិកោ ទុក្ខិតោ ពាឡ្ហគិលានោ

ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ +ទុះឯង ជាមារមានចិត្តបាប ស្វែងរកវិញ្ញាណរបស់កុលបុត្តថា វិញ្ញាណរបស់កុលបុត្តប្រតិស្ឋាន ក្នុងទីណា+អេះ ៗ ម្នាលភិក្ខុទាំងឡាយ ឯកុលបុត្តមានវិញ្ញាណ ពុំបានប្រតិស្ឋានទៅ (ក្នុងទីណា) ទេ បរិនិព្វានហើយ ៗ

[២២២] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ៗ សម័យនោះឯង ព្រះអស្សជិមានអាយុ នៅក្នុងអារាម របស់សេដ្ឋីឈ្មោះកស្សប មានអាពាធ ដល់នូវសេចក្តីទុក្ខ មានជម្ងឺជាទម្ងន់ ៗ គ្រានោះ ព្រះអស្សជិមានអាយុ បានហៅភិក្ខុទាំងឡាយ ជាឧបដ្ឋាកមកថា ម្នាលអាវុសោទាំងឡាយ ចូរអ្នកទាំងឡាយ មកណាយ ចូរអ្នកទាំងឡាយ ទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ចូរថ្វាយបង្គំព្រះបាទា របស់ព្រះមានព្រះភាគ ដោយត្បូង តាមពាក្យរបស់ខ្ញុំថា បពិត្រព្រះអង្គដ៏ចម្រើន អស្សជិភិក្ខុ មានអាពាធ ដល់នូវសេចក្តីទុក្ខ មានជម្ងឺជាទម្ងន់

សោ ភគវតោ បាទេ សិរសា វន្ទតីតិ ឯវញ្ច វទេថ សាធុ កិរ ភន្តេ ភគវា យេន អស្សជិ ភិក្ខុ តេនុបសង្កមតុ អនុកម្បំ ឧបាទាយាតិ ។ ឯវមាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ អស្សជិស្ស បដិស្សុត្វា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ អស្សជិ ភន្តេ ភិក្ខុ អាពាធិកោ ទុក្ខិតោ ពាឡ្ហគិលានោ សោ ភគវតោ បាទេ សិរសា វន្ទតិ ឯវញ្ច វទេតិ សាធុ កិរ ភន្តេ ភគវា យេន អស្សជិ ភិក្ខុ តេនុបសង្កមតុ អនុកម្បំ ឧបាទាយាតិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។

លោកថ្វាយបង្គំព្រះបាទា របស់ព្រះមានព្រះភាគ ដោយត្បូង មួយទៀត ចូរអ្នកទាំងឡាយពោលយ៉ាងនេះទៀតថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ធ្វើនូវសេចក្តីអនុគ្រោះ ចូលទៅរកអស្សជិភិក្ខុ ភិក្ខុទាំងនោះទទួលស្តាប់ពាក្យ របស់ព្រះអស្សជិមានអាយុថា ករុណា អាវុសោ ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អស្សជិភិក្ខុ មានអាពាធ ដល់នូវសេចក្តីទុក្ខ មានជម្ងឺជាទម្ងន់ លោកថ្វាយបង្គំព្រះបាទា របស់ព្រះមានព្រះភាគ ដោយត្បូង មួយទៀត លោកពោលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ធ្វើនូវសេចក្តីអនុគ្រោះ ចូលទៅរកអស្សជិភិក្ខុ ។ ព្រះមានព្រះភាគ ទ្រង់ទទួលដោយតុណ្ហីភាព ។

[២២៣] អថខោ ភគវា សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេនាយស្មា អស្សជិ តេនុបសង្កមិ ។ អទ្ទសា ខោ អាយស្មា អស្សជិ ភគវន្តំ ទូរតោវ អាគច្ឆន្តំ ទិស្វាន មញ្ចកេ សមធោសិ ។ អថខោ ភគវា អាយស្មន្តំ អស្សជឹ(១) ឯតទវោច អលំ អស្សជិ មា ត្វំ មញ្ចកេ សមធោសិ សន្តិមានិ អាសនានិ បញ្ញត្តានិ តត្ថាហំ និសីទិស្សាមីតិ ។ និសីទិ ភគវា បញ្ញត្តេ អាសនេ ។ និសជ្ជ ខោ ភគវា អាយស្មន្តំ អស្សជឹ ឯតទវោច កច្ចិ តេ អស្សជិ ខមនីយំ កច្ចិ យាបនីយំ ។ បេ ។ បដិក្កមោសានំ បញ្ញាយតិ នោ អភិក្កមោតិ ។ ន មេ ភន្តេ ខមនីយំ ន យាបនីយំ ។ បេ ។ អភិក្កមោសានំ បញ្ញាយតិ នោ បដិក្កមោតិ ។

---

១ ម. អាយស្មតោ អស្សជិស្ស ។

[២២៣] គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ស្តេចចេញអំពីទីសម្ងំគង់សាយណ្ហសម័យ ហើយស្តេចទៅរកព្រះអស្សជិមានអាយុ ។ ព្រះអស្សជិមានអាយុ ក៏បានឃើញព្រះមានព្រះភាគ កំពុងតែស្តេចមកពីចម្ងាយ លុះឃើញហើយ ក៏សំដែងកិរិយាតគេះតគះលើគ្រែ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងព្រះអស្សជិមានអាយុ ដូច្នេះថា ណ្ហើយ អស្សជិ អ្នកកុំសំដែងកិរិយាតគេះតគះលើគ្រែឡើយ នេះអាសនៈតាំងឡាយ ដែលគេតែងតាំងបម្រុងទុក មានស្រាប់ហើយ តថាគតនឹងអង្គុយលើអាសនៈនោះ ៗ ព្រះមានព្រះភាគគង់លើអាសនៈដែលគេតែងតាំងបម្រុងទុក ៗ លុះព្រះមានព្រះភាគ គង់ស្រេចហើយ ទ្រង់ត្រាស់សួរព្រះអស្សជិមានអាយុ ដូច្នេះថា ម្នាលអស្សជិ អ្នកល្មមអត់ធន់បានខ្លះឬ អ្នកល្មមប្រព្រឹត្តទៅបានខ្លះឬ ។ បេ ។ សេចក្តីធូរថយប្រាកដ មិនចម្រើនឡើងទេឬ ។ ព្រះអស្សជិ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គអត់ធន់មិនបានទេ ខ្ញុំព្រះអង្គប្រព្រឹត្តទៅមិនបានទេ ។ បេ ។ សេចក្តីចម្រើនប្រាកដឡើង មិនធូរថយទេ ។

កច្ចិ តេ អស្សជិ ន កិញ្ចិ កុក្កុច្ចំ ន កោចិ វិប្បដិសារោតិ ។ តគ្ឃ មេ ភន្តេ អនប្បកំ កុក្កុច្ចំ អនប្បកោ វិប្បដិសារោតិ ។ កច្ចិ បន តំ អស្សជិ អត្តា សីលតោ ន ឧបវទតីតិ ។ ន ខោ មំ ភន្តេ អត្តា សីលតោ ឧបវទតីតិ ។ នោ ចេ កិរ តំ អស្សជិ អត្តា សីលតោ ឧបវទតិ អថ កិញ្ច តេ កុក្កុច្ចំ កោ ច វិប្បដិសារោតិ ។ បុព្វេ ខ្វាហំ ភន្តេ គេលញ្ញេ បស្សម្ភេត្វា កាយសង្ខារេ វិហរាមិ សោហំ សមាធឹ នប្បដិលភាមិ តស្ស មយ្ហំ ភន្តេ តំ សមាធឹ អប្បដិលភតោ ឯវំ ហោតិ នោ ច ខ្វាហំ បរិហាយាមីតិ ។ យេ តេ អស្សជិ សមណព្រាហ្មណា សមាធិសារកា សមាធិសាមញ្ញា តេសំ តំ សមាធឹ អប្បដិលភតំ ឯវំ ហោតិ នោ ចស្សុ មយំ បរិហាយាមាតិ ។ តំ កឹ មញ្ញសិ អស្សជិ រូបំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ បេ ។

ម្នាលអស្សជិ អ្នកមិនមានសេចក្ដីរង្កៀសបន្តិចបន្តួចទេឬ អ្នកមិនមានសេចក្ដីក្ដៅក្រហាយអ្វីទេឬ ។ ព្រះករុណា ព្រះអង្គ ខ្ញុំព្រះអង្គមានសេចក្ដីរង្កៀសជាច្រើន មានសេចក្ដីក្ដៅក្រហាយជាច្រើន ។ ម្នាលអស្សជិ ចុះខ្លួនមិនតិះដៀលអ្នកឯង ដោយសីលទេឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្លួន (របស់ខ្ញុំព្រះអង្គ) មិនតិះដៀលខ្ញុំព្រះអង្គដោយសីលទេ ។ ម្នាលអស្សជិ បើខ្លួនមិនតិះដៀលអ្នកឯង ដោយសីលទេ ចុះអ្នកឯងមានសេចក្ដីរង្កៀសដូចម្ដេច មានសេចក្ដីក្ដៅក្រហាយដូចម្ដេច ។ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងកាលមុន ខ្ញុំព្រះអង្គរម្ងាប់នូវសេចក្ដីលំបាក ក្នុងកាយសង្ខារ (អស្សាសបស្សាសៈ) ក៏ខ្ញុំព្រះអង្គនៅតែមិនបានសមាធិ បពិត្រព្រះអង្គដ៏ចម្រើន កាលដែលខ្ញុំព្រះអង្គមិនបានសមាធិនោះហើយ ក៏មានសេចក្ដីត្រិះរិះយ៉ាងនេះថា អញមិនសាបសូន្យ (ចាកសាសនា) ទេ ។ ម្នាលអស្សជិ ពួកសមណព្រាហ្មណ៍ណា ក៏ដោយ ដែលមានសមាធិជាខ្លឹម មានសមាធិ ជាសាមញ្ញផល កាលបើសមណព្រាហ្មណ៍ទាំងនោះមិនបានសមាធិនោះហើយ ក៏រមែងមានសេចក្ដីត្រិះរិះយ៉ាងនេះថា យើងមិនសាបសូន្យ (ចាកសាសនា) ទេ ។ ម្នាលអស្សជិ អ្នកយល់សេចក្ដីនោះដូចម្ដេច រូបទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ បេ ។

វិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ តស្មាតិហ ។ បេ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។ សោ សុខញ្ចេ វេទនំ វេទយតិ សា អនិច្ចាតិ បជានាតិ អនជ្ឈោសិតាតិ បជានាតិ អនភិនន្ទិតាតិ បជានាតិ ទុក្ខញ្ចេ វេទនំ វេទយតិ សា អនិច្ចាតិ បជានាតិ អនជ្ឈោសិតាតិ បជានាតិ អនភិនន្ទិតាតិ បជានាតិ អទុក្ខមសុខញ្ចេ វេទនំ វេទយតិ សា អនិច្ចាតិ ។ បេ ។ អនភិនន្ទិតាតិ បជានាតិ ។ សោ សុខញ្ចេ វេទនំ វេទយតិ វិសញ្ញុត្តោ នំ វេទយតិ ទុក្ខញ្ចេ វេទនំ វេទយតិ វិសញ្ញុត្តោ នំ វេទយតិ អទុក្ខមសុខញ្ចេ វេទនំ វេទយតិ វិសញ្ញុត្តោ នំ វេទយតិ សា អនិច្ចាតិ បជានាតិ ។ បេ ។ អនភិនន្ទិតាតិ បជានាតិ ។ សោ កាយបរិយន្តិកញ្ចេ វេទនំ វេទយមានោ

វិញ្ញាណទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ បេ ។ ព្រោះហេតុនោះ អរិយសាវ័កក្នុងសាសនានេះ ។ បេ ។ ពិចារណាឃើញយ៉ាងនេះ ។ បេ ។ ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។ បើអរិយសាវ័កនោះទទួលសុខវេទនា ក៏ដឹងច្បាស់ថា សុខវេទនានោះមិនទៀង ដឹងច្បាស់ថា មិនគួរជ្រប់ ដឹងច្បាស់ថា មិនគួរត្រេកអរ បើរងទុក្ខវេទនា ក៏ដឹងច្បាស់ថា ទុក្ខវេទនានោះមិនទៀង ដឹងច្បាស់ថា មិនគួរជ្រប់ ដឹងច្បាស់ថា មិនគួរត្រេកអរ បើរងអទុក្ខមសុខវេទនា ក៏ដឹងច្បាស់ថា អទុក្ខមសុខវេទនានោះមិនទៀង ។ បេ ។ ដឹងច្បាស់ថា មិនគួរត្រេកអរ ។ បើអរិយសាវ័កនោះរងសុខវេទនា ក៏មិនប្រកបសុខវេទនានោះហើយរងទេ បើរងទុក្ខ-វេទនា ក៏មិនប្រកបទុក្ខវេទនានោះហើយរងទេ បើរងអទុក្ខមសុខ-វេទនា ក៏មិនប្រកបអទុក្ខមសុខវេទនានោះហើយរងទេ រមែងដឹងច្បាស់ថា អទុក្ខមសុខវេទនានោះមិនទៀង ។ បេ ។ ដឹងច្បាស់ថា មិនគួរត្រេកអរ ។ បើអរិយសាវ័កនោះ កំពុងរងកាយបរិយន្តិកវេទនា

កាយបរិយន្តិកំ វេទនំ វេទយាមីតិ បជានាតិ ជីវិតបរិយន្តិកញ្ចេ វេទនំ វេទយមានោ ជីវិតបរិយន្តិកំ វេទនំ វេទយាមីតិ បជានាតិ កាយស្ស ភេទា ឧទ្ធំ ជីវិតបរិយាទានា ឥធេវ សព្វវេទយិតានិ អនភិនន្ទិតានិ សីតី ភវិស្សន្តីតិ បជានាតិ ។

(២២៤) សេយ្យថាបិ អស្សជិ តេលញ្ច បដិច្ច វដ្ដិញ្ច បដិច្ច តេលប្បទីបោ ឈាយេយ្យ តស្សេវ តេលស្ស ច វដ្ដិយា ច បរិយាទានា អនាហារោ និព្វាយេយ្យ ។ ឯវមេវ ខោ អស្សជិ ភិក្ខុ កាយបរិយន្តិកំ វេទនំ វេទយមានោ កាយបរិយន្តិកំ វេទនំ វេទយាមីតិ បជានាតិ ជីវិតបរិយន្តិកំ វេទនំ វេទយមានោ ជីវិតបរិយន្តិកំ វេទនំ វេទយាមីតិ បជានាតិ កាយស្ស ភេទា ឧទ្ធំ ជីវិតបរិយាទានា ឥធេវ សព្វវេទយិតានិ អនភិនន្ទិតានិ សីតី ភវិស្សន្តីតិ ៗ

(វេទនាដែលប្រព្រឹត្តទៅ ក្នុងទីបំផុតកាយ) ក៏ដឹងច្បាស់ថា អាត្មាអញ កំពុងរងនូវកាយបរិយន្តិកវេទនា បើកំពុងរងនូវជីវិតបរិយន្តិកវេទនា (វេទនាដែលប្រព្រឹត្តទៅក្នុងទីបំផុតនៃជីវិត) ក៏ដឹងច្បាស់ថា អាត្មាអញកំពុងរងនូវជីវិតបរិយន្តិកវេទនា លុះទម្លាយរាងកាយ ខាងលើអំពីទីបំផុតនៃជីវិតទៅ ក៏ដឹងច្បាស់ថា អារម្មណ៍ទាំងពួងដែលបុគ្គលរងក្នុងលោកនេះ មិនជាអារម្មណ៍ត្រេកអរ គួរត្រេកអរទេ ។

[២២៤] ម្នាលអស្សជិ ដូចប្រទីបប្រេង លុះតែអាស្រ័យប្រេងផង អាស្រ័យប្រឆេះផង ទើបឆេះឡើងបាន បើប្រទីបមិនមានអាហារ ព្រោះអស់ប្រេងនិងប្រឆេះនោះឯង ក៏រលត់ទៅ ដូចម្តេចមិញ ។ ម្នាលអស្សជិ កាលភិក្ខុរងនូវកាយបរិយន្តិកវេទនា ក៏ដឹងច្បាស់ថា អាត្មាអញ រងនូវកាយបរិយន្តិកវេទនា កាលរងនូវជីវិតបរិយន្តិកវេទនា ក៏ដឹងច្បាស់ថា អាត្មាអញ រងនូវជីវិតបរិយន្តិកវេទនា លុះទម្លាយរាងកាយ ខាងលើអំពីទីបំផុតជីវិតទៅ ក៏ដឹងច្បាស់ថា អារម្មណ៍ទាំងពួងដែលបុគ្គលរងក្នុងលោកនេះ មិនជាអារម្មណ៍ត្រេកអរ គួរត្រេកអរទេ ។

(២២៩) ឯកំ សមយំ សម្ពហុលា ថេរា ភិក្ខូ កោសម្ពិយំ វិហរន្តិ ឃោសិតារាមេ ។ តេន ខោ បន សមយេន អាយស្មា ខេមកោ ពទរិការាមេ វិហរតិ អាពាធិកោ ទុក្ខិតោ ពាឡ្ហគិលានោ ។ អថ ខោ ថេរា ភិក្ខូ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតា អាយស្មន្តំ ទាសកំ អាមន្តេសុំ ឯហិ ត្វំ អាវុសោ ទាសក យេន ខេមកោ ភិក្ខុ តេនុបសង្កម ឧបសង្កមិត្វា ខេមកំ ភិក្ខុំ ឯវំ វទេហិ ថេរា តំ អាវុសោ ខេមក ឯវមាហំសុ កច្ចិ តេ អាវុសោ ខមនីយំ កច្ចិ យាបនីយំ កច្ចិ ទុក្ខា វេទនា បដិក្កមន្តិ នោ អភិក្កមន្តិ បដិក្កមោសានំ បញ្ញាយតិ នោ អភិក្កមោតិ ។ ឯវមាវុសោតិ ខោ អាយស្មា ទាសកោ ថេរានំ ភិក្ខូនំ បដិស្សុត្វា យេ-នាយស្មា ខេមកោ តេនុបសង្កមិ ឧបសង្កមិត្វា អា-យស្មន្តំ ខេមកំ ឯតទវោច ថេរា តំ អាវុសោ ខេមក

(២២៥) សម័យមួយ ភិក្ខុទាំងឡាយ ជាថេរៈច្រើនរូប នៅក្នុងឃោសិតារាម ជិតក្រុងកោសម្ពី ។ សម័យនោះឯង ព្រះខេមកៈមានអាយុនៅក្នុងពទរិការាម មានអាពាធ ដល់នូវសេចក្ដីទុក្ខ មានជម្ងឺជាទម្ងន់ ។ គ្រានោះ ភិក្ខុទាំងឡាយ ជាថេរៈ ចេញអំពីទីសម្ងំក្នុងសាយណ្ហសម័យ ហើយហៅព្រះទាសកៈមានអាយុមកថា អាវុសោទាសកៈ ចូរលោកមកអាយ ចូរលោកទៅរកខេមកភិក្ខុ លុះចូលទៅដល់ហើយ ចូរប្រាប់ខេមកភិក្ខុយ៉ាងនេះថា អាវុសោខេមកៈ ព្រះថេរៈទាំងឡាយ សួរលោកយ៉ាងនេះថា អាវុសោ អ្នកល្មមអត់ធន់បានខ្លះឬ អ្នកល្មមប្រព្រឹត្តទៅបានខ្លះឬ ទុក្ខវេទនាធូរថយ មិនចម្រើនឡើង ការធូរថយប្រាកដ មិនចម្រើនឡើងទេឬ ។ ព្រះទាសកៈមានអាយុ ទទួលស្ដាប់ពាក្យរបស់ភិក្ខុទាំងឡាយជាថេរៈថា ករុណា អាវុសោ ហើយចូលទៅរកព្រះខេមកៈមានអាយុ លុះចូលទៅដល់ហើយ ក៏ពោលនឹងព្រះខេមកៈមានអាយុដូច្នេះថា អាវុសោខេមកៈ ព្រះថេរៈទាំងឡាយ

ឯវមាហំសុ កច្ចិ តេ អាវុសោ ខមនីយំ កច្ចិ យាបនីយំ កច្ចិ ទុក្ខា វេទនា បដិក្កមន្តិ នោ អភិក្កមន្តិ បដិក្កមោសានំ បញ្ញាយតិ នោ អភិក្កមោតិ ។ ន មេ អាវុសោ ខមនីយំ ន យាបនីយំ ពាឡ្ហា មេ ទុក្ខា វេទនា អភិក្កមន្តិ នោ បដិក្កមន្តិ អភិក្កមោសានំ បញ្ញាយតិ នោ បដិក្កមោតិ ។

(៤៤៦) អថខោ អាយស្មា ទាសកោ យេន ថេរា ភិក្ខូ តេនុបសង្កមិ ឧបសង្កមិត្វា ថេរេ ភិក្ខូ ឯតទវោច ខេមកោ អាវុសោ ភិក្ខុ ឯវមាហ ន មេ អាវុសោ ខមនីយំ ន យាបនីយំ ពាឡ្ហា មេ ទុក្ខា វេទនា អភិក្កមន្តិ នោ បដិក្កមន្តិ អភិក្កមោសានំ បញ្ញាយតិ នោ បដិក្កមោតិ ។ ឯហិ ត្វំ អាវុសោ ទាសក យេន ខេមកោ ភិក្ខុ តេនុបសង្កម ឧបសង្កមិត្វា ខេមកំ ភិក្ខុំ ឯវំ វទេហិ ថេរា តំ អាវុសោ ខេមក ឯវមាហំសុ បញ្ចិមេ អាវុសោ ឧបាទានក្ខន្ធា

សួរលោកយ៉ាងនេះថា អាវុសោ អ្នកល្មមអត់ធន់បានខ្លះឬ អ្នកល្មមប្រព្រឹត្តទៅបានខ្លះឬ ទុក្ខវេទនាធូរថយ មិនចំរើនឡើង ការធូរថយប្រាកដ មិនចំរើនឡើងទេឬ ។ ព្រះខេមកៈពោលថា អាវុសោ ខ្ញុំអត់ធន់មិនបានទេ ខ្ញុំប្រព្រឹត្តទៅមិនបានទេ ទុក្ខវេទនារបស់ខ្ញុំចំរើនឡើងខ្លាំងណាស់ មិនធូរថយទេ សេចក្តីចំរើនប្រាកដឡើង មិនធូរថយទេ ។

[២២៦] លំដាប់នោះ ព្រះទាសកៈមានអាយុ ចូលមករកភិក្ខុទាំងឡាយជាថេរៈវិញ លុះចូលមកដល់ហើយ ក៏ពោលនឹងភិក្ខុទាំងឡាយជាថេរៈដូច្នេះថា ម្នាលអាវុសោទាំងឡាយ ខេមកភិក្ខុពោលយ៉ាងនេះថា អាវុសោ ខ្ញុំអត់ធន់មិនបានទេ ខ្ញុំប្រព្រឹត្តទៅមិនបានទេ ទុក្ខវេទនារបស់ខ្ញុំចំរើនឡើងខ្លាំងណាស់ មិនធូរថយទេ សេចក្តីចំរើនប្រាកដឡើងមិនធូរថយទេ ។ ភិក្ខុទាំងឡាយជាថេរៈ ពោលថា អាវុសោទាសកៈ ចូរលោកមកអាយ ចូរលោកចូលទៅរកខេមកភិក្ខុ លុះចូលទៅដល់ហើយ ចូរពោលនឹងខេមកភិក្ខុយ៉ាងនេះថា អាវុសោខេមកៈ ព្រះថេរៈទាំងឡាយប្រាប់លោកយ៉ាងនេះថា អាវុសោ ឧបាទានក្ខន្ធទាំង ៥ នេះ

វុត្តា ភគវតា ។ សេយ្យថីទំ ។ រូបូបាទានក្ខន្ធោ វេទនូ-
បាទានក្ខន្ធោ សញ្ញុបាទានក្ខន្ធោ សង្ខារូបាទានក្ខន្ធោ
វិញ្ញាណូបាទានក្ខន្ធោ ។ ឥមេសុ អាយស្មា ខេមកោ
បញ្ចសុ ឧបាទានក្ខន្ធេសុ កិញ្ចិ អត្តំ វា អត្តនិយំ វា
សមនុបស្សតីតិ ។ ឯវមាវុសោតិ ខោ អាយស្មា ទា-
សកោ ថេរកំ ភិក្ខុំ បដិស្សុត្វា យេនាយស្មា ខេ-
មកោ តេនុបសង្កមិ ។ បេ ។ ថេរា តំ អាវុសោ ខេមក
ឯវមាហំសុ បញ្ចិមេ អាវុសោ ឧបាទានក្ខន្ធា វុត្តា
ភគវតា ។ សេយ្យថីទំ ។ រូបូបាទានក្ខន្ធោ ។ បេ ។
វិញ្ញាណូបាទានក្ខន្ធោ ។ ឥមេសុ អាយស្មា ខេមកោ
បញ្ចសុ ឧបាទានក្ខន្ធេសុ កិញ្ចិ អត្តំ វា អត្តនិយំ វា
សមនុបស្សតីតិ ។ បញ្ចិមេ អាវុសោ ឧបាទានក្ខន្ធា
វុត្តា ភគវតា ។ សេយ្យថីទំ ។ រូបូបាទានក្ខន្ធោ ។ បេ ។
វិញ្ញាណូបាទានក្ខន្ធោ ។ ឥមេសុ ខ្វាហំ អាវុសោ
បញ្ចសុ ឧបាទានក្ខន្ធេសុ ន កិញ្ចិ អត្តំ វា អត្តនិយំ
វា សមនុបស្សាមីតិ ។

ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ។ ឧបាទានក្ខន្ធទាំង ៥ តើដូចម្ដេចខ្លះ ។ គឺរូបូបាទានក្ខន្ធ ១ វេទនូបាទានក្ខន្ធ ១ សញ្ញូបាទានក្ខន្ធ ១ សង្ខារូបាទានក្ខន្ធ ១ វិញ្ញាណូបាទានក្ខន្ធ ១ ។ ក្ទង់ឧបាទានក្ខន្ធទាំង ៥នេះ ព្រះខេមកៈមានអាយុ យល់ឃើញរបស់អ្វីបន្តិចបន្តួចថាជាខ្លួន ឬថាជាបរិក្ខាររបស់ខ្លួនដែរឬ ។ ព្រះទាសកៈ មានអាយុ ទទួលស្ដាប់ពាក្យរបស់ភិក្ខុទាំងឡាយជាថេរៈថា ករុណា អាវុសោ ហើយក៏ចូលទៅរកព្រះខេមកៈមានអាយុ ។បេ។ អាវុសោខេមកៈ ព្រះថេរៈទាំងឡាយប្រាប់លោកយ៉ាងនេះថា អាវុសោ ឧបាទានក្ខន្ធទាំង៥ នេះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ។ ឧបាទានក្ខន្ធទាំង ៥ តើដូចម្ដេចខ្លះ ។ គឺរូបូបាទានក្ខន្ធ ១ ។បេ។ វិញ្ញាណូបាទានក្ខន្ធ ១ ។ ក្ទង់ឧបាទានក្ខន្ធទាំង ៥ នេះ ព្រះខេមកៈមានអាយុ យល់ឃើញរបស់អ្វីបន្តិចបន្តួចថាជាខ្លួន ឬថាជាបរិក្ខាររបស់ខ្លួនដែរឬ ។ ព្រះខេមកៈពោលថា អាវុសោ ឧបាទានក្ខន្ធទាំង៥នេះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ។ ឧបាទានក្ខន្ធទាំង៥តើដូចម្ដេចខ្លះ ។ គឺរូបូបាទានក្ខន្ធ១ ។បេ។ វិញ្ញាណូបាទានក្ខន្ធ១ ។ អាវុសោ ក្ទង់ឧបាទានក្ខន្ធទាំង ៥ នេះ ខ្ញុំមិនយល់ឃើញរបស់អ្វីបន្តិចបន្តួចថាជាខ្លួន ឬថាជាបរិក្ខាររបស់ខ្លួនឡើយ ។

[២២៧] អថខោ អាយស្មា ទាសកោ យេន ថេរា ភិក្ខូ តេនុបសង្កមិ ឧបសង្កមិត្វា ថេរេ ភិក្ខូ ឯតទវោច ខេមកោ អាវុសោ ភិក្ខុ ឯវមាហ បញ្ចិមេ ឧបាទានក្ខន្ធា វុត្តា ភគវតា ។ សេយ្យថីទំ ។ រូបូបាទានក្ខន្ធោ ។ បេ ។ វិញ្ញាណូបាទានក្ខន្ធោ ។ ឥមេសុ ខ្វាហំ អាវុសោ បញ្ចសុ ឧបាទានក្ខន្ធេសុ ន កិញ្ចិ អត្តំ វា អត្តនិយំ វា សមនុបស្សាមីតិ ។ ឯហិ ត្វំ អាវុសោ ទាសក យេន ខេមកោ ភិក្ខុ តេនុបសង្កម ឧបសង្កមិត្វា ខេមកំ ភិក្ខុំ ឯវំ វទេហិ ថេរា តំ អាវុសោ ខេមក ឯវមាហំសុ បញ្ចិមេ អាវុសោ ឧបាទានក្ខន្ធា វុត្តា ភគវតា ។ សេយ្យថីទំ ។ រូបូបាទានក្ខន្ធោ ។ បេ ។ វិញ្ញាណូបាទានក្ខន្ធោ ។ នោ ចេ កិរាយស្មា ខេមកោ ឥមេសុ បញ្ចសុ ឧបាទានក្ខន្ធេសុ កិញ្ចិ អត្តំ វា អត្តនិយំ វា សមនុបស្សតិ តេនាយស្មា ខេមកោ អរហំ

(២២៧) លំដាប់នោះ ព្រះទាសកៈមានអាយុ ចូលទៅរកភិក្ខុទាំងឡាយ ជាថេរៈ លុះចូលទៅដល់ហើយ ពោលនឹងភិក្ខុទាំងឡាយជាថេរៈដូច្នេះថា ម្នាលអាវុសោទាំងឡាយ ខេមកភិក្ខុពោលយ៉ាងនេះថា ឧបាទានក្ខន្ធទាំង ៥ នេះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ។ ឧបាទានក្ខន្ធទាំង ៥ តើដូចម្តេចខ្លះ ។ គឺរូបូបាទានក្ខន្ធ ១ ។បេ។ វិញ្ញាណូបាទានក្ខន្ធ ១ ។ អាវុសោ ក្នុងឧបាទានក្ខន្ធ ទាំង ៥ នេះ ខ្ញុំមិនយល់ឃើញរបស់អ្វីបន្តិចបន្តួចថាជាខ្លួន ឬថាជាបរិក្ខាររបស់ខ្លួនឡើយ ។ ព្រះថេរៈទាំងឡាយពោលថា អាវុសោទាសកៈ ចូរលោកមកអាយ ចូរលោកចូលទៅរកខេមកភិក្ខុ លុះចូលទៅដល់ហើយ ចូរពោលនឹងខេមកភិក្ខុយ៉ាងនេះថា អាវុសោខេមកៈ ព្រះថេរៈទាំងឡាយប្រាប់លោកយ៉ាងនេះថា អាវុសោ ឧបាទានក្ខន្ធទាំង ៥ នេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ។ ឧបាទានក្ខន្ធទាំង៥ តើដូចម្តេចខ្លះ ។ គឺរូបូបាទានក្ខន្ធ ១ ។បេ។ វិញ្ញាណូបាទានក្ខន្ធ ១ ។ បានឮថា ក្នុងឧបាទានក្ខន្ធទាំង៥នេះ បើព្រះខេមកៈមានអាយុ មិនយល់ឃើញរបស់អ្វីបន្តិចបន្តួច ថាជាខ្លួន ឬថាជាបរិក្ខាររបស់ខ្លួនទេ មានតែព្រះខេមកៈមានអាយុ ជាព្រះអរហន្ត

ខីណាសវោតិ ។ ឯវមាវុសោតិ ខោ អាយស្មា ទាសកោ ថេរានំ ភិក្ខូនំ បដិស្សុត្វា យេនាយស្មា ខេមកោ ។ បេ ។ ថេរា តំ អាវុសោ ខេមក ឯវមាហំសុ បញ្ចិមេ អាវុសោ ឧបាទានក្ខន្ធា វុត្តា ភគវតា ។ សេយ្យថីទំ ។ រូបូបាទានក្ខន្ធោ ។ បេ ។ វិញ្ញាណូបាទានក្ខន្ធោ ។ នោ ចេ កិរាយស្មា ខេមកោ ឥមេសុ បញ្ចសុ ឧបាទានក្ខន្ធេសុ កិញ្ចិ អត្តំ វា អត្តនិយំ វា សមនុបស្សតិ តេនាយស្មា ខេមកោ អរហំ ខីណាសវោតិ ។ បញ្ចិមេ អាវុសោ ឧបាទានក្ខន្ធា វុត្តា ភគវតា ។ សេយ្យថីទំ ។ រូបូបាទានក្ខន្ធោ ។ បេ ។ វិញ្ញាណូបាទានក្ខន្ធោ ។ ឥមេសុ ខ្វាហំ អាវុសោ បញ្ចសុ ឧបាទានក្ខន្ធេសុ ន កិញ្ចិ អត្តំ វា អត្តនិយំ វា សមនុបស្សាមិ ន ចម្ហិ អរហំ ខីណាសវោ អបិច មេ អាវុសោ បញ្ចសុ ឧបាទានក្ខន្ធេសុ អស្មីតិ អធិគតំ អយមហមស្មីតិ ច ន សមនុបស្សាមីតិ ។

ខីណាស្រពហើយ ៗ ព្រះទាសកៈមានអាយុ ទទួលស្តាប់ពាក្យរបស់ភិក្ខុទាំងឡាយជាថេរៈថា ករុណា អាវុសោ ហើយចូលទៅរកព្រះខេមកៈមានអាយុ ៗ បេ ៗ អាវុសោខេមកៈ ព្រះថេរៈទាំងឡាយប្រាប់លោកយ៉ាងនេះថា អាវុសោ ឧបាទានក្ខន្ធទាំង ៥ នេះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ៗ ឧបាទានក្ខន្ធទាំង ៥ តើដូចម្តេចខ្លះ ៗ គឺរូបូបាទានក្ខន្ធ ១ ៗ បេ ៗ វិញ្ញាណូបាទានក្ខន្ធ ១ ៗ បានឮថា ក្នុងឧបាទានក្ខន្ធទាំង ៥ នេះ បើព្រះខេមកៈមានអាយុ មិនយល់ឃើញរបស់អ្វីបន្តិចបន្តួច ថាជាខ្លួន ឬថាជាបរិក្ខាររបស់ខ្លួនទេ មានតែព្រះខេមកៈមានអាយុ ជាព្រះអរហន្ត-ខីណាស្រពហើយ ៗ ព្រះខេមកៈឆ្លើយថា អាវុសោ ឧបាទានក្ខន្ធទាំង ៥ នេះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ៗ ឧបាទានក្ខន្ធទាំង ៥ តើដូចម្តេចខ្លះ ៗ គឺរូបូបាទានក្ខន្ធ ១ ៗ បេ ៗ វិញ្ញាណូបាទានក្ខន្ធ ១ ៗ អាវុសោ ក្នុងឧបាទានក្ខន្ធទាំង ៥ នេះឯង ខ្ញុំមិនយល់ឃើញរបស់អ្វីបន្តិចបន្តួចថាជាខ្លួន ឬថាជាបរិក្ខាររបស់ខ្លួនទេ ទាំងខ្ញុំ ក៏មិនមែនជាអរហន្តខីណាស្រពដែរ អាវុសោ ខ្ញុំគ្រាន់តែប្រកាន់ថា អញមានក្នុងឧបាទា-នក្ខន្ធទាំង ៥ ប៉ុណ្ណោះ តែខ្ញុំមិនយល់ឃើញថា ឧបាទានក្ខន្ធទាំង ៥ នេះជាអញទេឡើយ ៗ

(២២៨) អថខោ អាយស្មា ទាសកោ យេន ថេរា ភិក្ខូ តេនុបសង្កមិ ឧបសង្កមិត្វា ថេរេ ភិក្ខូ ឯតទវោច ខេមកោ អាវុសោ ភិក្ខុ ឯវមាហ បញ្ចិមេ អាវុសោ ឧបាទានក្ខន្ធា វុត្តា ភគវតា ។ សេយ្យថីទំ ។ រូបូបាទានក្ខន្ធោ ។ បេ ។ វិញ្ញាណុបាទានក្ខន្ធោ ។ ឥមេសុ ខ្វាហំ អាវុសោ បញ្ចសុ ឧបាទានក្ខន្ធេសុ ន កិញ្ចិ អត្តំ វា អត្តនិយំ វា សមនុបស្សាមិ ន ចម្ហិ អរហំ ខីណាសវោ អបិច មេ អាវុសោ បញ្ចសុ ឧបាទានក្ខន្ធេសុ អស្មីតិ អធិគតំ អយមហមស្មីតិ ច ន សមនុបស្សាមីតិ ។ ឯហិ ត្វំ អាវុសោ ទាសក យេន ខេមកោ ភិក្ខុ តេនុបសង្កម ឧបសង្កមិត្វា ខេមកំ ភិក្ខុំ ឯវំ វទេហិ ថេរា តំ អាវុសោ ខេមក ឯវមាហំសុ យមេតំ អាវុសោ ខេមក អស្មីតិ វទេសិ កិមេតំ អស្មីតិ វទេសិ ។ រូបំ អស្មីតិ វទេសិ ។ អញ្ញត្រ រូបា អស្មីតិ វទេសិ ។ វេទនំ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ អស្មីតិ វទេសិ ។ បេ ។ អញ្ញត្រ វិញ្ញាណា អស្មីតិ វទេសិ ។

(២២៨) លំដាប់នោះ ព្រះទាសកៈមានអាយុ ចូលទៅរកភិក្ខុទាំងឡាយជាថេរៈ លុះចូលទៅដល់ហើយ ក៏ពោលនឹងភិក្ខុទាំងឡាយជាថេរៈដូច្នេះថា ម្នាលអាវុសោទាំងឡាយ ខេមកភិក្ខុពោលយ៉ាងនេះថា អាវុសោ ឧបាទានក្ខន្ធ ទាំង៥នេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ។ ឧបាទានក្ខន្ធទាំង៥ តើដូចម្តេចខ្លះ ។ គឺរូបូបាទានក្ខន្ធ ១ ។បេ។ វិញ្ញាណូបាទានក្ខន្ធ ១ ។ អាវុសោ ក្នុងឧបាទានក្ខន្ធទាំង ៥ នេះឯង ខ្ញុំមិនយល់ឃើញរបស់អ្វីបន្តិចបន្តួច ថាជារបស់ខ្លួន ឬថាជាបរិក្ខាររបស់ខ្លួនទេ ទាំងខ្ញុំក៏មិនមែនជាអរហន្តខីណាស្រពដែរ អាវុសោ ខ្ញុំគ្រាន់តែប្រកាន់ថា អញមានក្នុងឧបាទានក្ខន្ធទាំង ៥ ប៉ុណ្ណោះ តែខ្ញុំមិនយល់ឃើញថាឧបាទានក្ខន្ធទាំង ៥ នេះជាអញឡើយ ។ ព្រះថេរៈទាំងឡាយពោលថា អាវុសោទាសកៈ ចូរលោកមកអាយ ចូរលោកទៅរកខេមកភិក្ខុ លុះចូលទៅដល់ហើយ ចូរពោលនឹងខេមកភិក្ខុយ៉ាងនេះថា អាវុសោខេមកៈ ព្រះថេរៈទាំងឡាយ សួរលោកយ៉ាងនេះថា អាវុសោខេមកៈ ដែលលោកហៅថា អញនុ៎ះ តើលោកហៅអ្វីថាជាអញ ។ លោកហៅរូបថាជាអញឬ ។ ឬលោកហៅរបស់ដទៃអំពីរូបថាជាអញ ។ លោកហៅវេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ លោកហៅវិញ្ញាណថាជាអញឬ ។បេ។ ឬលោកហៅរបស់ដទៃអំពីវិញ្ញាណថាជាអញ ។

យមេតំ អាវុសោ ខេមក អស្មីតិ វទេសិ កិមេតំ អស្មីតិ វទេសីតិ ។ ឯវមាវុសោតិ ខោ អាយស្មា ទាសកោ ថេរានំ ភិក្ខូនំ បដិស្សុត្វា យេនាយស្មា ខេមកោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ ខេមកំ ឯតទវោច ថេរា តំ អាវុសោ ខេមក ឯវមាហំសុ យមេតំ អាវុសោ ខេមក អស្មីតិ វទេសិ កិមេតំ អស្មីតិ វទេសិ ។ រូបំ អស្មីតិ វទេសិ ។ អញ្ញត្រ រូបា អស្មីតិ វទេសិ ។ វេទនំ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ អស្មីតិ វទេសិ ។ អញ្ញត្រ វិញ្ញាណា អស្មីតិ វទេសិ ។ យមេតំ អាវុសោ ខេមក អស្មីតិ វទេសិ កិមេតំ អស្មីតិ វទេសីតិ ។ អលំ អាវុសោ ទាសក កឹ ឥមាយ សន្ធាវនិកាយ អាហរាវុសោ ទណ្ឌំ អហមេវ យេន ថេរា តេនុបសង្កមិស្សាមីតិ ។

អាវុសោខេមកៈ ដែលលោកហៅថាជាអញនុ៎ះ តើលោកហៅអ្វីថាជាអញ ៗ ព្រះទាសកៈមានអាយុ ទទួលស្តាប់ពាក្យរបស់ភិក្ខុទាំងឡាយជាថេរៈថា ករុណា អាវុសោ ហើយចូលទៅរកព្រះខេមកៈមានអាយុ លុះចូលទៅដល់ហើយ ក៏ពោលនឹងព្រះខេមកៈមានអាយុដូច្នេះថា អាវុសោខេមកៈ ព្រះថេរៈទាំងឡាយសួរលោកយ៉ាងនេះថា អាវុសោខេមកៈ ដែលលោកហៅថាអញនុ៎ះ តើលោកហៅអ្វីថាជាអញ ៗ លោកហៅរូបថាជាអញឬ ៗ ឬលោកហៅរបស់ដទៃអំពីរូបថាជាអញ ៗ លោកហៅវេទនា ៗ សញ្ញា ៗ សង្ខារទាំងឡាយ ៗ លោកហៅវិញ្ញាណថាជាអញឬ ៗ ឬលោកហៅរបស់ដទៃអំពីវិញ្ញាណថាជាអញ ៗ អាវុសោខេមកៈ ដែលលោកហៅថាជាអញនុ៎ះ តើលោកហៅអ្វីថាជាអញ ៗ ព្រះខេមកៈពោលថា កុំឡើយ អាវុសោទាសកៈ ប្រយោជន៍អ្វីដោយការត្រឡប់ទៅ ត្រឡប់មកនេះ អាវុសោ ចូរលោកហុចឈើច្រត់មក ខ្ញុំឯងនឹងចូលទៅរកភិក្ខុទាំងឡាយជាថេរៈ ៗ

[២៤៩] អថខោ អាយស្មា ខេមកោ ទណ្ឌមោលុព្ភ យេន ថេរា ភិក្ខូ តេនុបសង្កមិ ឧបសង្កមិត្វា ថេរេហិ ភិក្ខូហិ សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ ខេមកំ ថេរា ភិក្ខូ ឯតទវោចុំ យមេតំ អាវុសោ ខេមក អស្មីតិ វទេសិ កិមេតំ អស្មីតិ វទេសិ ។ រូបំ អស្មីតិ វទេសិ ។ អញ្ញត្រ រូបា អស្មីតិ វទេសិ ។ វេទនំ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ អស្មីតិ វទេសិ ។ អញ្ញត្រ វិញ្ញាណា អស្មីតិ វទេសិ ។ យមេតំ អាវុសោ ខេមក អស្មីតិ វទេសិ កិមេតំ អស្មីតិ វទេសីតិ ។ ន ខ្វាហំ អាវុសោ រូបំ អស្មីតិ វទាមិ នបិ អញ្ញត្រ រូបា អស្មីតិ វទាមិ ។ ន វេទនំ ។ ន សញ្ញំ ។ ន សង្ខារេ ។

[ ២២៩ ] លំដាប់នោះ ព្រះខេមកៈមានអាយុ ច្រត់ឈើច្រត់ ដើរចូលទៅរកភិក្ខុទាំងឡាយជាថេរៈ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងភិក្ខុទាំងឡាយជាថេរៈ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះព្រះខេមកៈមានអាយុអង្គុយក្នុងទីសមគួរហើយ ភិក្ខុទាំងឡាយជាថេរៈក៏សួរដូច្នេះថា អាវុសោខេមកៈ ដែលលោកហៅថាអញ្ញនុ៎ះ តើលោកហៅអ្វីថាជាអញ ។ លោកហៅរូបថា ជាអញឬ ។ ឬលោកហៅរបស់ដទៃអំពីរូបថាជាអញ ។ លោកហៅវេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ លោកហៅវិញ្ញាណថាជាអញឬ ។ ឬលោកហៅរបស់ដទៃអំពីវិញ្ញាណថាជាអញ ។ អាវុសោខេមកៈ ដែលលោកហៅថាអញ្ញនុ៎ះ តើលោកហៅអ្វីថាជាអញ ។ ព្រះខេមកៈឆ្លើយថា អាវុសោ ខ្ញុំមិនហៅរូបថាជាអញទេ សូម្បីរបស់ដទៃអំពីរូប ក៏ខ្ញុំមិនហៅថាជាអញដែរ ។ ខ្ញុំមិនហៅវេទនា ។ មិនហៅសញ្ញា ។ មិនហៅសង្ខារទាំងឡាយ ។

ន វិញ្ញាណំ អស្មីតិ វទាមិ នបិ អញ្ញត្រ វិញ្ញាណា អស្មីតិ វទាមិ អបិច មេ អាវុសោ បញ្ចសុ ឧបាទានក្ខន្ធេសុ អស្មីតិ អធិគតំ អយមហមស្មីតិ ន ច សមនុបស្សាមិ ។ សេយ្យថាបិ អាវុសោ ឧប្បលស្ស វា បទុមស្ស វា បុណ្ឌរីកស្ស វា គន្ធោ យោ នុ ខោ ឯវំ វទេយ្យ បត្តស្ស គន្ធោតិ វា វណ្ណស្ស គន្ធោតិ វា កិញ្ជក្ខស្ស គន្ធោតិ វា សម្មា នុ ខោ សោ វទមានោ វទេយ្យាតិ ។ នោ ហេតំ អាវុសោ ។ យថាកថំ បនាវុសោ សម្មា អាវុសោ ព្យាករមានោ ព្យាករេយ្យាតិ ។ បុប្ផស្ស គន្ធោតិ សម្មា ព្យាករមានោ ព្យាករេយ្យាតិ ។ ឯវមេវ ខ្វាហំ ខោ អាវុសោ ន រូបំ អស្មីតិ វទាមិ នបិ អញ្ញត្រ រូបា អស្មីតិ វទាមិ ។ ន វេទនំ ។ ន សញ្ញំ ។ ន សង្ខារេ ។ វិញ្ញាណំ អស្មីតិ វទាមិ នបិ អញ្ញត្រ វិញ្ញាណា អស្មីតិ វទាមិ អបិច មេ អាវុសោ បញ្ចសុ ឧបាទានក្ខន្ធេសុ អស្មីតិ អធិគតំ អយមហមស្មីតិ ន ច សមនុបស្សាមិ ។

មិនហៅវិញ្ញាណ ថាជាអញទេ សូម្បីរបស់ដទៃអំពីវិញ្ញាណ ក៏ខ្ញុំមិនហៅថាជាអញដែរ អាវុសោ ខ្ញុំគ្រាន់តែប្រកាន់ថា អញមានក្នុងឧបាទានក្ខន្ធទាំង ៥ ប៉ុណ្ណោះ តែខ្ញុំមិនយល់ឃើញថា ឧបាទានក្ខន្ធទាំង ៥ នេះ ជាអញទេ ។ អាវុសោ ដូចជាក្លិននៃផ្កាព្រលិត ផ្កាឈូកក្រហម ឬផ្កាឈូកស បុគ្គលណា និយាយយ៉ាងនេះថា ក្លិនរបស់ត្របកក្តី ក្លិនរបស់ពណ៌ក្តី ក្លិនរបស់កេសរក្តី បុគ្គលនោះកាលបើនិយាយ (យ៉ាងនេះ) ឈ្មោះថានិយាយត្រូវដែរឬ ។ យ៉ាងនុ៎ះមិនត្រូវទេ អាវុសោ ។ អាវុសោ ចុះកាលបើបុគ្គលនឹងព្យាករឲ្យត្រូវ តើគប្បីព្យាករដូចម្តេចវិញ ។ អាវុសោ កាលបើបុគ្គលនឹងព្យាករឲ្យត្រូវ គប្បីព្យាករថា ក្លិនរបស់ផ្កា ។ អើអាវុសោ យ៉ាងនោះមែន ឯខ្ញុំមិនហៅរូប ថាជាអញទេ សូម្បីរបស់ដទៃអំពីរូប ក៏ខ្ញុំមិនហៅថាជាអញដែរ ។ ខ្ញុំមិនហៅវេទនា ។ មិនហៅសញ្ញា ។ មិនហៅសង្ខារទាំងឡាយ ។ មិនហៅវិញ្ញាណ ថាជាអញទេ សូម្បីរបស់ដទៃអំពីវិញ្ញាណ ក៏ខ្ញុំមិនហៅថាជាអញដែរ អាវុសោ ខ្ញុំគ្រាន់តែប្រកាន់ថា អញមានក្នុងឧបាទានក្ខន្ធទាំង ៥ ប៉ុណ្ណោះ តែខ្ញុំមិនយល់ឃើញថា ឧបាទានក្ខន្ធ ទាំង ៥ នេះ ជាអញទេ ។

កិញ្ចាបិ អាវុសោ អរិយសាវកស្ស បញ្ចោរម្ភាគិយានិ សញ្ញោជនានិ បហីនានិ ភវន្តិ អថខ្វស្ស ហោតិ យោ ច បញ្ចសុ ឧបាទានក្ខន្ធេសុ អនុសហគតោ អស្មីតិ មានោ អស្មីតិ ឆន្ទោ អស្មីតិ អនុសយោ អសមូហតោ ។ សោ អបរេន សមយេន បញ្ចសុ ឧបាទានក្ខន្ធេសុ ឧទយព្វយានុបស្សី វិហរតិ ឥតិ រូបំ ឥតិ រូបស្ស សមុទយោ ឥតិ រូបស្ស អត្ថង្គមោ ។ ឥតិ វេទនា ។ ឥតិ សញ្ញា ។ ឥតិ សង្ខារា ។ ឥតិ វិញ្ញាណំ ឥតិ វិញ្ញាណស្ស សមុទយោ ឥតិ វិញ្ញាណស្ស អត្ថង្គមោតិ ។ តស្សិមេសុ បញ្ចសុ ឧបាទានក្ខន្ធេសុ ឧទយព្វយានុបស្សិនោ វិហរតោ យោបិស្ស ហោតិ បញ្ចសុ ឧបាទានក្ខន្ធេសុ អនុសហគតោ អស្មីតិ មានោ អស្មីតិ ឆន្ទោ អស្មីតិ អនុសយោ អសមូហតោ សោបិ សមុគ្ឃាតំ គច្ឆតិ ។ សេយ្យថាបិ អាវុសោ វត្ថំ សង្កិលិដ្ឋំ មលគ្គហិតំ តមេនំ សាមិកា រជកស្ស អនុប្បទេយ្យុំ តមេនំ រជកោ ឩសេ វា ខារេ វា គោមយេ វា សម្មទ្ទិត្វា

អាវុសោ ពួកនុះម្ចាគិយសំយោជនៈ (សំយោជនៈជាចំណែកខាងក្រោម) ៥ ប្រការ ដែលអរិយសាវ័កលះបង់បាន ក៏មែនពិតហើយ តែថាមានះ (សេចក្តីប្រកាន់) ថាជាអញ ឆន្ទៈ (សេចក្តីគាប់ចិត្ត) ថាជាអញ អនុស័យ (កិលេសដែលដេកត្រាំក្នុងចិត្ត) ថាជាអញ យ៉ាងល្អិត នៅក្នុងឧបាទានក្ខន្ធទាំង ៥ លោកមិនទាន់គាស់រំលើងបាននៅឡើយ ។ លុះសម័យខាងក្រោយមក លោកពិចារណាឃើញ នូវសេចក្តីកើត និងសេចក្តីរលត់ ក្នុងឧបាទានក្ខន្ធទាំង៥ថា ដូច្នេះជារូប ដូច្នេះជាហេតុឲ្យកើតរូប ដូច្នេះជាសេចក្តីរលត់រូប ។ ដូច្នេះជាវេទនា ។ ដូច្នេះជាសញ្ញា ។ ដូច្នេះជាសង្ខារទាំងឡាយ ។ ដូច្នេះជាវិញ្ញាណ ដូច្នេះជាហេតុឲ្យកើតវិញ្ញាណ ដូច្នេះជាសេចក្តីរលត់នៃវិញ្ញាណ ។ កាលលោកពិចារណាឃើញ នូវសេចក្តីកើតសេចក្តីរលត់ក្នុងឧបាទានក្ខន្ធទាំង ៥ នេះហើយ មានះថាជាអញ ឆន្ទៈថាជាអញ អនុស័យថាជាអញ ជាកិលេសយ៉ាងល្អិត ដែលលោកគាស់រំលើង មិនទាន់បាននៅឡើយ ក៏ដល់នូវកិរិយាគាស់រំលើងឡើងបាន ។ អាវុសោ ដូចសំពត់ដ៏សៅហ្មង ប្រឡាក់ក្អែល ពួកជនជាម្ចាស់យកសំពត់នោះទៅប្រគល់ឲ្យជាងជ្រលក់ ជាងជ្រលក់ក៏ប្របាច់ប្របល់សំពត់នោះ ក្នុងទឹកប្រែក្តី ក្នុងទឹកក្បុងក្តី ក្នុងទឹកគោម័យក្តី

អច្ឆេ ឧទកេ វិក្ខាលេតិ កិញ្ចាបិ តំ ហោតិ វត្ថំ បរិ-
សុទ្ធំ បរិយោទាតំ អថខ្វស្ស ហោតិ យោ ច អនុស-
ហគតោ ឩសគន្ធោ វា ខារគន្ធោ វា គោមយគន្ធោ
វា អសមូហតោ តមេនំ រជកោ សាមិកានំ ទេតិ
តមេនំ សាមិកា គន្ធបរិភាវិតេ ករណ្ឌកេ និក្ខិបន្តិ
យោបិស្ស ហោតិ អនុសហគតោ ឩសគន្ធោ វា
ខារគន្ធោ វា គោមយគន្ធោ វា អសមូហតោ សោបិ
សមុគ្ឃាតំ គច្ឆតិ ។ ឯវមេវ ខោ អាវុសោ កិញ្ចាបិ
អរិយសាវកស្ស បញ្ចោរម្ភាគិយានិ សញ្ញោជនានិ ប-
ហីនានិ ភវន្តិ អថខ្វស្ស ហោតិ យេវ បញ្ចសុ ឧបា-
ទានក្ខន្ធេសុ អនុសហគតោ អស្មីតិ មានោ អស្មីតិ
ឆន្ទោ អស្មីតិ អនុសយោ អសមូហតោ សោ អបរេន
សមយេន បញ្ចសុ ឧបាទានក្ខន្ធេសុ ឧទយព្វយា-
នុបស្សី វិហរតិ ឥតិ រូបំ ឥតិ រូបស្ស សមុទយោ
ឥតិ រូបស្ស អត្ថង្គមោ ។ ឥតិ វេទនា ។ ឥតិ
សញ្ញា ។ ឥតិ សង្ខារា ។ ឥតិ វិញ្ញាណំ ឥតិ វិញ្ញា-
ណស្ស សមុទយោ ឥតិ វិញ្ញាណស្ស អត្ថង្គមោតិ ។

ហើយយកទៅគក់ក្នុងទឹកដ៏ថ្លា សំពត់នោះត្រឡប់ជា សំពត់ស្អាត ផូរ-ផង់ ក៏មែនពិតហើយ តែថាសំពត់នោះ គង់មានក្លិនទឹកប្រៃ ក្លិនទឹកក្បុង ក្លិនទឹកគោម័យដែលជ្រួតជ្រាបមិនទាន់បាត់នៅឡើយ លុះតែជាងជ្រលក់ ឲ្យសំពត់នោះដល់ពួកជនជាម្ចាស់ ពួកជនជាម្ចាស់ក៏ដាក់សំពត់នោះក្នុងទូដែលអប់ដោយក្លិន ឯក្លិនទឹកប្រៃក្តី ក្លិនទឹកក្បុងក្តី ក្លិនទឹកគោម័យក្តី ដែលជ្រួតជ្រាបនៅ ក៏ហើរបាត់អស់ទៅ យ៉ាងណាមិញ ។ អាវុសោ ពួកឱរម្ភាគិយសំយោជនៈ ៥ ប្រការ ដែលអរិយសាវ័កលះបង់បាន ក៏មែនពិតហើយ តែថា មានះថាជាអញ ឆន្ទៈថាជាអញ អនុស័យថាជាអញ ជាកិលេសយ៉ាងល្អិត នៅក្នុងឧបាទានក្ខន្ធទាំង ៥ ក៏លោកគាស់រំលើងមិនទាន់បាននៅឡើយ លុះសម័យខាងក្រោយមក លោកពិ-ចារណាឃើញនូវសេចក្តីកើត និងសេចក្តីរលត់ ក្នុងឧបាទានក្ខន្ធទាំង៥ ថាដូច្នេះជារូប ដូច្នេះជាហេតុឲ្យកើតរូប ដូច្នេះជាសេចក្តីរលត់រូប ។ ដូច្នេះជាវេទនា ។ ដូច្នេះជាសញ្ញា ។ ដូច្នេះជាសង្ខារទាំងឡាយ ។ ដូច្នេះជាវិញ្ញាណ ដូច្នេះជាហេតុឲ្យកើតវិញ្ញាណ ដូច្នេះជាសេចក្តីរលត់វិញ្ញាណ ។

តស្សិមេសុ បញ្ចសុ ឧបាទានក្ខន្ធេសុ ឧទយព្វយានុបស្សិនោ វិហរតោ យោបិស្ស ហោតិ បញ្ចសុ ឧបាទានក្ខន្ធេសុ អនុសហគតោ អស្មីតិ មានោ អស្មីតិ ឆន្ទោ អស្មីតិ អនុសយោ អសមូហតោ សោបិ សមុគ្ឃាតំ គច្ឆតីតិ ។

[២៣០] ឯវំ វុត្តេ ថេរា ភិក្ខូ អាយស្មន្តំ ខេមកំ ឯតទវោចុំ ន ខោ មយំ អាយស្មន្តំ ខេមកំ វិហេសាបេក្ខា អបុច្ឆិម្ហា[១] អបិ អាយស្មា ខេមកោ បហោតិ តស្ស ភគវតោ សាសនំ វិត្ថារេន អាចិក្ខិតុំ ទេសេតុំ បញ្ញបេតុំ បដ្ឋបេតុំ វិវរិតុំ វិភជិតុំ ឧត្តានីកាតុំ យន្នូន អាយស្មតា ខេមកេន តស្ស ភគវតោ សាសនំ វិត្ថារេន អាចិក្ខិតំ ទេសិតំ បញ្ញបិតំ បដ្ឋបិតំ វិវរិតំ វិភជិតំ[២] ឧត្តានីកតន្តិ ។ ឥទមវោច អាយស្មា ខេមកោ ។

---

១ ឱ. ម. បុច្ឆិម្ហា ។ ២ ឱ. វិវដំ វិភត្តំ ។

កាលបើលោកពិចារណាឃើញនូវសេចក្តីកើត និងសេចក្តីរលត់ ក្នុងឧបាទានក្ខន្ធទាំង៥ ហើយ មានះថាជាអញ ឆន្ទៈថាជាអញ អនុស័យថាជាអញ ជាកិលេសយ៉ាងល្អិត ក្នុងឧបាទានក្ខន្ធទាំង៥ ដែលលោកគាស់រំលើងមិនទាន់បាននៅឡើយ ក៏ដល់នូវកិរិយាគាស់រំលើងឡើងបានយ៉ាងនោះឯង ។

[២៣០] លុះព្រះខេមកៈពោលយ៉ាងនេះហើយ ភិក្ខុទាំងឡាយជាថេរៈក៏ពោលនឹងព្រះខេមកៈមានអាយុ ដូច្នេះថា យើងទាំងឡាយមិនសួរព្រះខេមកៈមានអាយុព្រោះប្រាថ្នានឹងបៀតបៀនទេ បានជាសួរ (ដោយយល់ឃើញថា) ព្រះខេមកៈមានអាយុអាចនឹងប្រាប់ សំដែង បញ្ញត្ត តែងតាំង បើក ចែក ធ្វើឲ្យរាក់ នូវសាសនារបស់ព្រះមានព្រះភាគអង្គនោះ ដោយពិស្តារបាន ដូចជាសាសនារបស់ព្រះមានព្រះភាគអង្គនោះ ដែលព្រះខេមកៈមានអាយុ បានប្រាប់ បានសំដែង បានបញ្ញត្ត បានតែងតាំង បានបើក បានចែក បានធ្វើឲ្យរាក់ហើយ ដោយសេចក្តីពិស្តារនេះឯង ។ ព្រះខេមកៈមានអាយុ បានពោលភាសិតនេះចប់ហើយ ។

អត្តមនា ថេរា ភិក្ខូ អាយស្មតោ ខេមកស្ស ភាសិតំ អភិនន្ទុំ ។ ឥមស្មិញ្ច បន វេយ្យាករណស្មឹ ភញ្ញមានេ សដ្ឋីមត្តានំ ថេរានំ ភិក្ខូនំ អនុបាទាយ អាសវេហិ ចិត្តានិ វិមុច្ចិំសុ អាយស្មតោ ច ខេមកស្សាតិ ។

(២៣១) ឯកំ សមយំ សម្ពហុលា ថេរា ភិក្ខូ ពារាណសិយំ វិហរន្តិ ឥសិបតនេ មិគទាយេ ។ អថ-ខោ អាយស្មា ឆន្នោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ អវាបុរណំ អាទាយ វិហារេន វិហារំ ឧប-សង្កមិត្វា ថេរេ ភិក្ខូ ឯតទវោច ឱវទន្តុ មំ អាយស្មន្តោ ថេរា អនុសាសន្តុ មំ អាយស្មន្តោ ថេរា ករោន្តុ មេ អា-យស្មន្តោ ថេរា ធម្មឹ កថំ យថាហំ ធម្មំ បស្សេយ្យន្តិ ។

ភិក្ខុទាំងឡាយជាថេរៈ មានចិត្តត្រេកអរកែកាយ នឹងភាសិតរបស់ព្រះខេមកៈមានអាយុក្រៃលែង ។ ក៏កាលដែលព្រះខេមកៈមានអាយុ កំពុងពោលវេយ្យាករណ៍នេះ ចិត្តរបស់ភិក្ខុទាំងឡាយជាថេរៈ ប្រមាណ ៦០ រូប ព្រមទាំងព្រះខេមកៈមានអាយុ ក៏រួចផុតស្រឡះចាកអាសវៈទាំងឡាយ ។

[២៣១] សម័យមួយ ភិក្ខុទាំងឡាយ ជាថេរៈច្រើនរូប នៅក្នុងឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ។ គ្រានោះឯង ព្រះឆន្នៈមានអាយុ ចេញអំពីទីសម្ងំ ក្នុងសាយណ្ហសម័យ ហើយកាន់កូនសោដើរចេញពីវិហារមួយ ចូលទៅកាន់វិហារមួយ និយាយនឹងភិក្ខុទាំងឡាយជាថេរៈដូច្នេះថា សូមព្រះថេរៈទាំងឡាយ មានអាយុ ទូន្មានខ្ញុំករុណា សូមព្រះថេរៈទាំងឡាយ មានអាយុ ប្រៀនប្រដៅខ្ញុំករុណា សូមព្រះថេរៈទាំងឡាយ មានអាយុ ធ្វើធម្មីកថាដល់ខ្ញុំករុណា សមគួរតាមធម៌ដែលខ្ញុំករុណាល្មមយល់បាន ។

[២៣២] ឯវំ វុត្តេ ថេរា ភិក្ខូ អាយស្មន្តំ ឆន្នំ
ឯតទវោចុំ រូបំ ខោ អាវុសោ ឆន្ន អនិច្ចំ វេទនា
អនិច្ចា សញ្ញា អនិច្ចា សង្ខារា អនិច្ចា វិញ្ញាណំ អ-
និច្ចំ ។ រូបំ អនត្តា ។ វេទនា ។ សញ្ញា ។ សង្ខារា ។
វិញ្ញាណំ អនត្តា សព្វេ សង្ខារា អនិច្ចា សព្វេ ធម្មា
អនត្តាតិ ។ អថខោ អាយស្មតោ ឆន្នស្ស ឯតទហោសិ
មយ្ហំបិ ខោ ឯវំ ហោតិ រូបំ អនិច្ចំ ។ វេទនា ។ សញ្ញា ។
សង្ខារា ។ វិញ្ញាណំ អនិច្ចំ ។ រូបំ អនត្តា ។ វេទនា ។
សញ្ញា ។ សង្ខារា ។ វិញ្ញាណំ អនត្តា សព្វេ
សង្ខារា អនិច្ចា សព្វេ ធម្មា អនត្តាតិ អថ ច បន
មេ សព្វសង្ខារសមថេ សព្វូបធិបដិនិស្សគ្គេ តណ្ហាក្ខ-
យេ វិរាគេ និរោធេ និព្វានេ ចិត្តំ ន បក្ខន្ទតិ នប្ប-
សីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ បរិតស្សនា ឧបា-
ទានំ ឧប្បជ្ជតិ បច្ចុទាវត្តតិ មានសំ អថ កោចរហិ
មេ អត្តាតិ ។ ន ខោ បនេតំ ធម្មំ បស្សតោ ហោតិ

(២៣២) កាលដែលព្រះឆន្នៈនិយាយយ៉ាងនេះហើយ ភិក្ខុទាំងឡាយជាថេរៈ និយាយនឹងព្រះឆន្នៈមានអាយុដូច្នេះថា អាវុសោឆន្នៈ រូបមិនទៀង វេទនាមិនទៀង សញ្ញាមិនទៀង សង្ខារទាំងឡាយ មិនទៀង វិញ្ញាណមិនទៀង ។ រូបជាអនត្តា ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណជាអនត្តា សង្ខារទាំងឡាយទាំងពួងមិនទៀង ធម៌ទាំងឡាយទាំងពួងជាអនត្តា ។ លំដាប់នោះ ព្រះឆន្នៈមានអាយុ មានសេចក្តីត្រិះរិះដូច្នេះថា អាត្មាអញក៏មានសេចក្តីត្រិះរិះ យ៉ាងនេះដែរថា រូបមិនទៀង ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណមិនទៀង ។ រូបជាអនត្តា ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណជាអនត្តា សង្ខារទាំងឡាយទាំងពួងមិនទៀង ធម៌ទាំងឡាយទាំងពួងជាអនត្តាដែរ ប៉ុន្តែចិត្តរបស់អញ មិនស្ទុះ មិនជ្រះថ្លា មិនតម្កល់ខ្ជាប់ មិនបង្អោនទៅរកព្រះនិព្វាន ដែលមានអាការរម្ងាប់នូវសង្ខារទាំងពួង ជាទីរលាស់ចេញនូវឧបធិទាំងពួង ជាទីអស់ទៅនៃតណ្ហា ជាទីប្រាសចាកតម្រេក ជាទីរលត់ទេ ទើបសេចក្តីតក់ស្លុត សេចក្តីប្រកាន់មាំ ក៏កើតឡើង ចិត្តរបស់អញក៏ត្រឡប់គិតថា អ្វីហ្ន៎ ជាខ្លួនរបស់អញអេះ ។ មួយទៀត កាលបើអញ មិនទាន់ឃើញចតុស្សច្ចធម៌នុ៎ះ

កោ នុ ខោ មេ តថា ធម្មំ ទេសេយ្យ យថាហំ ធម្មំ បស្សេយ្យន្តិ ។

(២៣៣) អថខោ អាយស្មតោ ឆន្នស្ស ឯតទហោសិ អយំ ខោ អាយស្មា អានន្ទោ កោសម្ពិយំ វិហរតិ ឃោសិតារាមេ សត្ថុ ចេវ សំវណ្ណិតោ សម្ភាវិតោ ច វិញ្ញូនំ សព្រហ្មចារីនំ បហោតិ ច មេ អាយស្មា អានន្ទោ តថា ធម្មំ ទេសេតុំ យថាហំ ធម្មំ បស្សេយ្យំ អត្ថិ ច មេ អាយស្មន្តេ អានន្ទេ តាវតិកា វិស្សដ្ឋិ យន្នូនាហំ យេនាយស្មា អានន្ទោ តេនុបសង្កមេយ្យន្តិ ។ អថខោ អាយស្មា ឆន្នោ សេនាសនំ សំសាមេត្វា បត្តចីវរមាទាយ យេន កោសម្ពី ឃោសិតារាមោ យេនាយស្មា អានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា អានន្ទេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា ឆន្នោ

ហើយនរណាឡើយ នឹងសំដែងធម៌ដល់អញ សមគួរតាមធម៌ដែលអញ ល្មមយល់បាន ។

[២៣៣] លំដាប់នោះ ព្រះឆន្នៈមានអាយុ មានសេចក្តីត្រិះរិះ ដូច្នេះថា ព្រះអានន្ទ មានអាយុនេះ នៅក្នុងឃោសិតារាម ជិតក្រុងកោសម្ពី ជាអ្នកដែលព្រះសាស្តាទ្រង់សរសើរផង ជាអ្នកដែលពួកវិញ្ញូជនជាសព្រហ្មចារីលើកតំកើងផង មានតែព្រះអានន្ទមានអាយុទើបអាចសំដែងធម៌ដល់អញ សមគួរតាមធម៌ដែលអញល្មមយល់បាន ទាំងអញក៏មានសេចក្តីស្និទ្ធស្នាល នឹងព្រះអានន្ទមានអាយុជាដរាបមក បើដូច្នោះ គួរតែអញ ចូលទៅរកព្រះអានន្ទមានអាយុចុះ ។ ទើបព្រះឆន្នៈមានអាយុរៀបចំទុកដាក់សេនាសនៈ រួចស្រេចហើយ កាន់យកបាត្រនិងចីវរ ចូលទៅរកព្រះអានន្ទមានអាយុ ឯឃោសិតារាម ជិតក្រុងកោសម្ពី លុះចូលទៅដល់ហើយ ធ្វើកិរិយារីករាយ ជាមួយនឹងព្រះអានន្ទមានអាយុ លុះបញ្ចប់ពាក្យ ដែលគួររីករាយនិងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះឆន្នៈមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ

អាយស្មន្តំ អានន្ទំ ឯតទវោច ឯកមិទាហំ អាវុសោ អានន្ទ សមយំ ពារាណសិយំ វិហរាមិ ឥសិបតនេ មិគទាយេ អថខ្វាហំ អាវុសោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ អវាបុរណំ អាទាយ វិហារេន វិហារំ ឧបសង្កមិត្វា ថេរេ ភិក្ខូ ឯតទវោចំ ឱវទន្តុ មំ អាយស្មន្តោ ថេរា អនុសាសន្តុ មំ អាយស្មន្តោ ថេរា ករោន្តុ មេ អាយស្មន្តោ ថេរា ធម្មិំ កថំ យថាហំ ធម្មំ បស្សេយ្យន្តិ ។ ឯវំ វុត្តេ មំ អាវុសោ ថេរា ភិក្ខូ ឯតទវោចុំ រូបំ ខោ អាវុសោ ឆន្ន អនិច្ចំ ។ វេទនា ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ អនិច្ចំ ។ រូបំ អនត្តា ។ បេ ។ វិញ្ញាណំ អនត្តា សព្វេ សង្ខារា អនិច្ចា សព្វេ ធម្មា អនត្តាតិ ។ តស្ស មយ្ហំ អាវុសោ ឯតទហោសិ មយ្ហំបិ ខោ ឯវំ ហោតិ រូបំ អនិច្ចំ ។ បេ ។ វិញ្ញាណំ អនិច្ចំ ។ រូបំ អនត្តា ។ វេទនា ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ អនត្តា សព្វេ សង្ខារា អនិច្ចា សព្វេ ធម្មា អនត្តាតិ

ក៏ពោលនឹងព្រះអានន្ទមានអាយុ ដូច្នេះថា អាវុសោអានន្ទ សម័យមួយ ខ្ញុំនៅក្នុងឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី អាវុសោ គ្រានោះ ខ្ញុំចេញចាកទីសម្ងំ ក្នុងសាយណ្ហសម័យ ហើយកាន់កូនសោដើរចេញពីវិហារមួយ ចូលទៅកាន់វិហារមួយ និយាយនឹងភិក្ខុទាំងឡាយជាថេរៈដូច្នេះថា សូមព្រះថេរៈទាំងឡាយមានអាយុ ទូន្មានខ្ញុំករុណា សូមព្រះថេរៈទាំងឡាយមានអាយុ ប្រៀនប្រដៅខ្ញុំករុណា សូមព្រះថេរៈទាំងឡាយមានអាយុ ធ្វើធម្មីកថាដល់ខ្ញុំករុណា ឲ្យសមគួរតាមធម៌ដែលខ្ញុំករុណាល្មមយល់បាន ។ អាវុសោ កាលខ្ញុំនិយាយយ៉ាងនេះហើយ ភិក្ខុទាំងឡាយជាថេរៈ និយាយនឹងខ្ញុំករុណាដូច្នេះថា អាវុសោឆន្នៈ រូបមិនទៀង ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណមិនទៀង ។ រូបជាអនត្តា ។ បេ ។ វិញ្ញាណជាអនត្តា សង្ខារទាំងឡាយទាំងពួងមិនទៀង ធម៌ទាំងឡាយទាំងពួង ជាអនត្តា ។ អាវុសោ ខ្ញុំនោះ មានសេចក្តីត្រិះរិះ ដូច្នេះថា អាត្មាអញក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា រូបមិនទៀង ។ បេ ។ វិញ្ញាណមិនទៀង ។ រូបជាអនត្តា ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណជាអនត្តា សង្ខារទាំងឡាយទាំងពួងមិនទៀង ធម៌ទាំងឡាយទាំងពួងជាអនត្តាដែរ

អថ ច បន មេ សព្វសង្ខារសមថេ សព្វូបធិប្បដិ-
និស្សគ្គេ តណ្ហាក្ខយេ វិរាគេ និរោធេ និព្វានេ ចិត្តំ ន
បក្ខន្ទតិ នប្បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ បរិ-
តស្សនា ឧបាទានំ ឧប្បជ្ជតិ បច្ចុទាវត្តតិ មានសំ អថ
កោ ចរហិ មេ អត្តាតិ ។ ន ខោ បនេតំ ធម្មំ បស្ស-
តោ ហោតិ កោ នុ ខោ មេ តថា ធម្មំ ទេសេយ្យ យ-
ថាហំ ធម្មំ បស្សេយ្យន្តិ ។ តស្ស មយ្ហំ អាវុសោ ឯ-
តទហោសិ អយំ ខោ អាយស្មា អានន្ទោ កោសម្ពិយំ
វិហរតិ ឃោសិតារាមេ សត្ថុ ចេវ សំវណ្ណិតោ សម្ភាវិតោ
ច វិញ្ញូនំ សព្រហ្មចារីនំ បហោតិ ច មេ អាយស្មា
អានន្ទោ តថា ធម្មំ ទេសេតុំ យថាហំ ធម្មំ បស្សេយ្យំ
អត្ថិ ច អាយស្មន្តេ អានន្ទេ តាវតិកា វិស្សដ្ឋិ យន្នូ-
នាហំ យេនាយស្មា អានន្ទោ តេនុបសង្កមេយ្យ-
ន្តិ ។ ឱវទតុ មំ អាយស្មា អានន្ទោ អនុសាសតុ
មំ អាយស្មា អានន្ទោ ការោតុ មេ អាយស្មា អានន្ទោ
ធម្មិំ កថំ យថាហំ ធម្មំ បស្សេយ្យន្តិ ។

ប៉ុន្តែចិត្តរបស់ខ្ញុំ មិនស្ទុះ មិនជ្រះថ្លា មិនតំកល់ខ្ជាប់ មិនបង្អោនទៅក្នុងព្រះនិព្វាន ដែលមានអាការរម្ងាប់នូវសង្ខារទាំងពួង ជាទីលាស់ចេញនូវឧបធិទាំងពួង ជាទីអស់ទៅនៃតណ្ហា ជាទីប្រាសចាកតម្រេក ជាទីរលត់ទៅ ទើបសេចក្តីតក់ស្លុត សេចក្តីប្រកាន់មាំ ក៏កើតឡើង ចិត្តរបស់ខ្ញុំក៏ត្រឡប់គិតថា អ្វីហ្ន៎ជាខ្លួនរបស់អញអេះ ៗ មួយទៀត កាលបើខ្ញុំមិនទាន់ឃើញចតុស្សច្ចធម៌ទេ នរណាឡើយ នឹងសំដែងធម៌ដល់ខ្ញុំសមគួរដល់ធម៌ ដែលខ្ញុំយល់បាន ៗ អាវុសោ ខ្ញុំក៏មានសេចក្តីត្រិះរិះដូច្នេះថា ព្រះអានន្ទមានអាយុអង្គនេះ នៅក្នុងឃោសិតារាម ជិតក្រុងកោសម្ពី ជាអ្នកដែលព្រះសាស្តាទ្រង់សរសើរផង ជាអ្នកដែលពួកវិញ្ញូជនជាសព្រហ្មចារីលើកតំកើងផង មានតែព្រះអានន្ទមានអាយុ អាចនឹងសំដែងធម៌ដល់អញ សមគួរតាមធម៌ដែលអញយល់បាន ទាំងអញក៏មានសេចក្តីស្និទ្ធស្នាល នឹងព្រះអានន្ទមានអាយុ ជាដរាបមក បើដូច្នោះ គួរតែអាត្មាអញ ចូលទៅរកព្រះអានន្ទមានអាយុចុះ ៗ សូមព្រះអានន្ទមានអាយុ ទូន្មានខ្ញុំករុណា សូមព្រះអានន្ទមានអាយុ ប្រៀនប្រដៅខ្ញុំករុណា សូមព្រះអានន្ទមានអាយុ ធ្វើធម្មីកថាដល់ខ្ញុំករុណាសមគួរតាមធម៌ដែលខ្ញុំករុណាយល់បាន ៗ

[២៣៤] ឯត្តកេនបិ មយំ អាយស្មតោ ឆន្នស្ស អត្តមនា អភិរទ្ធា តំ អាយស្មា ឆន្នោ អាវិអកាសិ ខីលំ បភិន្ទិ ឱទហាវុសោ ឆន្ន សោតំ ភព្វោសិ ធម្មំ វិញ្ញាតុន្តិ ។ អថខោ អាយស្មតោ ឆន្នស្ស តាវទេវ ឧឡារំ បីតិបាមោជ្ជំ ឧប្បជ្ជិ ភព្វោ កិរស្មិ ធម្មំ វិញ្ញាតុន្តិ ។ សម្មុខា មេតំ អាវុសោ ឆន្ន ភគវតោ សុតំ សម្មុខា បដិគ្គហិតំ កច្ចានគោត្តំ ភិក្ខុំ ឱវទន្តស្ស ទ្វយនិស្សិតោ ខោយំ កច្ចាន លោកោ យេភុយ្យេន អត្ថិតញ្ចេវ នត្ថិតញ្ច ។ លោកសមុទយំ ខោ កច្ចាន យថាភូតំ សម្មប្បញ្ញាយ បស្សតោ យា

[២៣៤] ព្រះអានន្ទពោលថា ខ្ញុំរីករាយត្រេកអរនឹងព្រះឆន្នៈមានអាយុ ដោយហេតុដែលព្រះឆន្នៈមានអាយុ ធ្វើសេចក្តីនោះឲ្យជាក់ច្បាស់ ទម្លាយសេចក្តីរឹងត្អឹង អាវុសោឆន្នៈ ចូរលោកផ្ទៀងសោតប្រសាទចុះ លោកជាបុគ្គលគួរយល់ធម៌បានហើយ ។ ព្រះឆន្នៈមានអាយុ ក៏កើតបីតិនិងបាមោជ្ជដ៏ក្រៃលែង ដោយហេតុគ្រាន់តែឮថា ខ្លួនជាបុគ្គលគួរយល់ធម៌បានហើយប៉ុណ្ណោះ ។ ព្រះអានន្ទមានអាយុ ពោលថា អាវុសោឆន្នៈ សូត្រនេះខ្ញុំបានស្តាប់មក ខ្ញុំបានទទួលមក ក្នុងទីចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ កាលដែលទ្រង់ទូន្មានភិក្ខុជាកច្ចានគោត្រថា ម្នាលកច្ចានៈ សត្វលោកនេះ ច្រើនតែអាស្រ័យនូវទិដ្ឋិ ២ ប្រការ គឺ ការប្រកាន់ថាមាន (សស្សតទិដ្ឋិ) ១ ការប្រកាន់ថាមិនមាន (ឧច្ឆេទទិដ្ឋិ) ១ ។ ម្នាលកច្ចានៈ កាលបើគេពិចារណាឃើញ តាមសេចក្តីពិត ដោយប្រាជ្ញាដ៏ប្រពៃ នូវហេតុដែលឲ្យកើតលោក ការប្រកាន់ថាមិនមាន ណា

លោកេ នត្ថិតា សា ន ហោតិ ។ លោកនិរោធំ ខោ កច្ចាន យថាភូតំ សម្មប្បញ្ញាយ បស្សតោ យា លោកេ អត្ថិតា សា ន ហោតិ ។ ឧបាយុបាទានាភិនិវេសវិនិពន្ធោ ខ្វាយំ កច្ចាន លោកោ យេភុយ្យេន តញ្ចាយំ ឧបាយុបាទានំ ចេតសោ អធិដ្ឋានំ អភិនិវេសានុសយំ ន ឧបេតិ ន ឧបាទិយតិ នាធិដ្ឋាតិ អត្តា មេតិ ។ ទុក្ខមេវ ឧប្បជ្ជមានំ ឧប្បជ្ជតិ ទុក្ខំ និរុជ្ឈមានំ និរុជ្ឈតីតិ ន កង្ខតិ ន វិចិកិច្ឆតិ ។ អបរប្បច្ចយា ញាណមេវស្ស ឯត្ថ ហោតិ ។ ឯត្តាវតា ខោ កច្ចាន សម្មាទិដ្ឋិ ហោតិ ។ សព្វមត្ថីតិ ខោ កច្ចាន អយមេកោ អន្តោ សព្វំ នត្ថីតិ អយំ ទុតិយោ អន្តោ ។

ក្នុងលោក គេមិនមានការប្រកាន់ថា មិនមាននោះទេ ។ ម្នាលកច្ចានៈ កាលបើគេពិចារណាឃើញ តាមសេចក្តីពិត ដោយប្រាជ្ញាដ៏ប្រពៃ នូវសេចក្តីរលត់របស់លោក ការប្រកាន់ថាមាន ណា ក្នុងលោក គេមិនមានការប្រកាន់ថា មាននោះឡើយ ។ ម្នាលកច្ចានៈ សត្វលោកនេះ ច្រើនតែជាប់ចំពាក់ដោយឧបាយ (តណ្ហាទិដ្ឋិ) ឧបាទាន និងអភិនិវេសៈ គឺតណ្ហាទិដ្ឋិ ចំណែកអរិយសាវ័កនេះ រមែងមិនផ្តេកផ្តួល មិនប្រកាន់ មិនតាំងចិត្តខ្ជាប់ នូវឧបាយនិងឧបាទាននោះ ដែលជាអធិដ្ឋាន (ទីឈរ) ជាអភិនិវេសៈ (ទីអង្គុយ) និងជាអនុស័យ (ទីដេក) នៃចិត្តថា ខ្លួនរបស់អញឡើយ ។ អរិយសាវ័កនោះមិនសង្ស័យ មិនងឿងឆ្ងល់ថា ទុក្ខក្នុងឧបាទានក្ខន្ធទាំង ៥ កាលកើតឡើង រមែងកើតឡើងពិត ទុក្ខកាលរលត់ទៅ រមែងរលត់ទៅពិត ។ ព្រះអរិយសាវ័កនោះ មានសេចក្តីយល់ចំពោះខ្លួន ក្នុងឧបាទានក្ខន្ធទុក្ខនុ៎ះ មិនបាច់មានបុគ្គលដទៃជាបច្ច័យ ។ ម្នាលកច្ចានៈ សម្មាទិដ្ឋិ រមែងកើតមាន ដោយហេតុមានប្រមាណប៉ុណ្ណោះឯង ។ ម្នាលកច្ចានៈ សេចក្តីយល់ថា អ្វីទាំងអស់មាន នេះជាសេចក្តីយល់ដ៏លាមកទី ១ គឺសស្សតទិដ្ឋិ សេចក្តីយល់ថា អ្វីទាំងអស់មិនមាន នេះជាសេចក្តីយល់ដ៏លាមកទី ២ គឺឧច្ឆេទទិដ្ឋិ ។

ឯតេ តេ កច្ចាន ឧភោ អន្តេ អនុបគម្ម មជ្ឈេន តថាគតោ ធម្មំ ទេសេតិ អវិជ្ជាបច្ចយា សង្ខារា សង្ខារបច្ចយា វិញ្ញាណំ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។ អវិជ្ជាយ ត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតីតិ ។ ឯវមេតំ អាវុសោ អានន្ទ ហោតិ យេសំ អាយស្មន្តានំ តាទិសា សព្រហ្មចារិយោ អនុកម្បកា អត្ថកាមា ឱវាទកា អនុសាសកា ឥទញ្ច បន មេ អាយស្មតោ អានន្ទស្ស ធម្មទេសនំ សុត្វា ធម្មោ អភិសមិតោតិ ។

(២៣៩) សាវត្ថិយំ ។ អថខោ អាយស្មា រាហុលោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា រាហុលោ ភគវន្តំ ឯតទវោច កថន្នុ ខោ ភន្តេ ជានតោ កថំ បស្សតោ

ម្នាលកច្ចានៈ តថាគតសំដែងធម៌ ប្រាប់អ្នកតាមផ្លូវកណ្តាល មិនប្រឡូកប្រឡំក្នុងសេចក្តីយល់ ដ៏លាមកទាំង ២ នេះឡើយថា សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ ។បេ។ ហេតុជាដែនកើត នៃកងទុក្ខទាំងអស់នេះ រមែងកើតមាន ដោយប្រការដូច្នេះ ។ មួយទៀត សេចក្តីរលត់នូវសង្ខារ ព្រោះវិនាសនឹងរលត់មិនសេសសល់ នៃអវិជ្ជា ។បេ។ សេចក្តីរលត់នៃកងទុក្ខទាំងអស់នេះ រមែងកើតមាន ដោយប្រការដូច្នេះ ។ ព្រះឆន្នៈពោលថា អាវុសោអានន្ទ សេចក្តីនុ៎ះយ៉ាងហ្នឹងមែនហើយ បណ្តាលោកមានអាយុទាំងឡាយណា លោកមានអាយុទាំងនោះ ប្រាកដដូចលោកម្ចាស់ ឈ្មោះថាជាសព្រហ្មចារី ជាអ្នកអនុគ្រោះ អ្នកប៉ងឲ្យប្រយោជន៍ អ្នកឲ្យឱវាទ អ្នកប្រៀនប្រដៅមែន ចំណែកខ្ញុំទើបនឹងយល់ធម៌ច្បាស់ ព្រោះបានស្តាប់ធម៌ទេសនា របស់ព្រះអានន្ទមានអាយុនេះឯង ។

(២៣៩) ជិតក្រុងសាវត្ថី ។ គ្រានោះ ព្រះរាហុលមានអាយុចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះរាហុល មានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន កាលបុគ្គលដឹងដូចម្តេច ឃើញដូចម្តេច

ឥមស្មិញ្ច សវិញ្ញាណកេ កាយេ ពហិទ្ធា ច សព្វនិមិត្តេសុ អហង្ការមមង្ការមានានុសយា ន ហោន្តីតិ ។ យំ កិញ្ចិ រាហុល រូបំ អតីតានាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា សព្វំ រូបំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ បស្សតិ ។ យា កាចិ វេទនា ។ យា កាចិ សញ្ញា ។ យេ កេចិ សង្ខារា ។ យំ កិញ្ចិ វិញ្ញាណំ អតីតានាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ។ បេ ។ សព្វំ វិញ្ញាណំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ បស្សតិ ។ ឯវំ ខោ រាហុល ជានតោ ឯវំ បស្សតោ ឥមស្មិញ្ច សវិញ្ញាណកេ កាយេ ពហិទ្ធា ច សព្វនិមិត្តេសុ អហង្ការមមង្ការមានានុសយា ន ហោន្តីតិ ។

ទើបមិនមានអនុស័យ គឺសេចក្តីប្រកាន់អហង្ការមមង្ការ ក្នុងកាយដែលប្រកបដោយវិញ្ញាណនេះផង ក្នុងនិមិត្តគ្រប់ចំពូកជាខាងក្រៅផង ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលរាហុល រូបណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី ឬរូបណា មានក្នុងទីឆ្ងាយ ក្នុងទីជិត បុគ្គលឃើញនូវរូបទាំងអស់នុ៎ះ ដោយប្រាជ្ញាដ៏ប្រពៃតាមសេចក្តីពិត យ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ ។ វេទនាណាមួយ ។ សញ្ញាណាមួយ ។ សង្ខារទាំងឡាយណាមួយ ។ វិញ្ញាណណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ខាងក្នុងក្តី ខាងក្រៅក្តី ។ បេ ។ បុគ្គលឃើញនូវវិញ្ញាណទាំងអស់នុ៎ះ ដោយប្រាជ្ញាដ៏ប្រពៃតាមសេចក្តីពិត យ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ ។ ម្នាលរាហុល កាលបុគ្គលដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ទើបមិនមានអនុស័យ គឺសេចក្តីប្រកាន់អហង្ការមមង្ការ ក្នុងកាយដែលប្រកបដោយវិញ្ញាណនេះផង ក្នុងនិមិត្តគ្រប់ចំពូកជាខាងក្រៅផង ។

[២៣៦] សាវត្ថិយំ ។ អារាមេ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា រាហុលោ ភគវន្តំ ឯតទវោច កថំ នុ ខោ ភន្តេ ជានតោ កថំ បស្សតោ ឥមស្មិញ្ច សវិញ្ញាណកេ កាយេ ពហិទ្ធា ច សព្វនិមិត្តេសុ អហង្ការមមង្ការមានាបគតំ មានសំ ហោតិ វិធា សមតិក្កន្តំ សន្តំ សុវិមុត្តន្តិ ។ យំ កិញ្ចិ រាហុល រូបំ អតីតានាគតបច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា ។ បេ ។ យំ ទូរេ សន្តិកេ វា សព្វំ រូបំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទិស្វា អនុបាទា វិមុត្តោ ហោតិ ។ យា កាចិ វេទនា ។ យា កាចិ សញ្ញា ។ យេ កេចិ សង្ខារា ។ យំ កិញ្ចិ វិញ្ញាណំ អតីតានាគតបច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ

(២៣៦) ជិតក្រុងសាវត្ថី ។ ក្នុងវត្ត ។ លុះព្រះរាហុលមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន កាលបុគ្គលដឹងដូចម្តេច ឃើញដូចម្តេច ទើបមានចិត្តប្រាសចាកសេចក្តីប្រកាន់អហង្ការមមង្ការ ក្នុងកាយដែលប្រកបដោយវិញ្ញាណនេះផង ក្នុងនិមិត្តគ្រប់ចំពូកជាខាងក្រៅផង ហើយកន្លងផុត ស្ងប់រម្ងាប់ រួចស្រឡះដោយចំណែក ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលរាហុល រូបណានីមួយ ជាអតីត អនាគត បច្ចុប្បន្ន ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ។ បេ ។ ឬរូបណា មានក្នុងទីឆ្ងាយ ក្នុងទីជិត បុគ្គលឃើញនូវរូបទាំងអស់នុ៎ះ ដោយប្រាជ្ញាដ៏ប្រពៃ តាមសេចក្តីពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ ទើបជាអ្នកផុតស្រឡះចាកសេចក្តីប្រកាន់មាំ ។ វេទនាណានីមួយ ។ សញ្ញាណានីមួយ ។ សង្ខារទាំងឡាយណានីមួយ ។ វិញ្ញាណណានីមួយ ជាអតីត អនាគត បច្ចុប្បន្ន ជាខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី ឬវិញ្ញាណណា

ទូរេ សន្តិកេ វា សព្វំ វិញ្ញាណំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទិស្វា អនុបាទា វិមុត្តោ ហោតិ ។ ឯវំ ខោ រាហុល ជានតោ ឯវំ បស្សតោ ឥមស្មិញ្ច សវិញ្ញាណកេ កាយេ ពហិទ្ធា ច សព្វនិមិត្តេសុ អហង្ការមមង្ការមានាបគតំ មានសំ ហោតិ វិធា សមតិក្កន្តំ សន្តំ សុវិមុត្តន្តិ ។

ថេរវគ្គោ ចតុត្ថោ ។

## តត្រុទ្ទានំ ភវតិ

អានន្ទោ តិស្សោ យមកោ
អនុរាធោ ច វក្កលិ
អស្សជិ ខេមកោ ឆន្នោ
រាហុលា អបរេ ទុវេ
ថេរវគ្គោតិ វុច្ចតីតិ ។

ដែលមានក្នុងទីឆ្ងាយ ក្នុងទីជិត បុគ្គលឃើញនូវវិញ្ញាណទាំងអស់នុ៎ះ ដោយប្រាជ្ញាដ៏ប្រពៃតាមសេចក្តីពិត យ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ ទើបផុតស្រឡះ ចាកសេចក្តីប្រកាន់មាំ ៗ ម្នាលរាហុល បុគ្គលដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ទើបមានចិត្តប្រាសចាកសេចក្តីប្រកាន់អហង្ការមមង្ការ ក្នុងកាយដែលប្រកបដោយវិញ្ញាណនេះផង ក្នុងនិមិត្តគ្រប់ចំពូកជាខាងក្រៅផង ហើយកន្លងផុត ស្ងប់រម្ងាប់ រួចស្រឡះដោយចំណែក ៗ

ចប់ ថេរវគ្គ ទី ៤ ។

## ឧទ្ទានក្នុងថេរវគ្គនោះ គឺ

និយាយអំពីព្រះអានន្ទ ១ ព្រះតិស្សៈ ១ ព្រះយមកៈ ១ ព្រះអនុរាធ ១ ព្រះវក្កលិ ១ ព្រះអស្សជិ ១ ព្រះខេមកៈ ១ ព្រះឆន្នៈ ១ និងព្រះរាហុល ២ រឿងទៀត លោកហៅថា ថេរវគ្គ ៗ

## បុប្ផវគ្គោ

(២៣៧) សាវត្ថិយំ ។ តត្រ ខោ ។ បេ ។ សេយ្យថាបិ ភិក្ខវេ នទី បព្វតេយ្យា ឱហារិនី ទូរង្គមា សីឃសោតា តស្សា ឧភតោ[១] តីរេសុ កាសា ចេបិ ជាតា អស្សុ តេ នំ អជ្ឈោលម្ពេយ្យុំ កុសា ចេបិ ជាតា អស្សុ តេ នំ អជ្ឈោលម្ពេយ្យុំ បព្វជា ចេបិ ជាតា អស្សុ តេ នំ អជ្ឈោលម្ពេយ្យុំ វីរណា ចេបិ ជាតា អស្សុ តេ នំ អជ្ឈោលម្ពេយ្យុំ រុក្ខា ចេបិ ជាតា អស្សុ តេ នំ អជ្ឈោលម្ពេយ្យុំ តស្សា បុរិសោ សោតេន វុយ្ហមានោ កាសេ ចេបិ គណ្ហេយ្យ តេ បលុជ្ជេយ្យុំ សោ តតោនិទានំ អនយព្យសនំ អាបជ្ជេយ្យ ។ កុសេ ចេបិ គណ្ហេយ្យ ។ បព្វជេ ចេបិ គណ្ហេយ្យ ។ វីរណេ ចេបិ គណ្ហេយ្យ ។

១ ឱ. ម. ឧភោសុ ។

# បុប្ផវគ្គ

(២៣៧) ដិតក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។បេ។ ម្នាល ភិក្ខុទាំងឡាយ ដូចជាស្ទឹងជាប់មកអំពីកំពូលភ្នំ មានប្រក្រតីនាំសំណាត់ ហូរចុះមក ហូរទៅកាន់ទីឆ្ងាយ មានខ្សែទឹករហ័ស ប្រសិនបើមានត្រែង ដុះនៅឰដ៏ឆ្នេរទាំងពីរនៃស្ទឹងនោះ ត្រែងនោះ នឹងសំយុងចុះទៅរកស្ទឹងនោះ ប្រសិនបើមានស្បូវដុះនៅ ស្បូវទាំងនោះ នឹងសំយុងចុះទៅរកស្ទឹងនោះ ប្រសិនបើមានស្មៅដំណេកទន្សាយដុះនៅ ស្មៅដំណេកទន្សាយទាំងនោះ នឹងសំយុងចុះទៅរកស្ទឹងនោះ ប្រសិនបើមានស្បូវរណ្តាសដុះនៅ ស្បូវរណ្តាសទាំងនោះ នឹងសំយុងចុះទៅរកស្ទឹងនោះ ប្រសិនបើមានឈើដុះនៅ ឈើទាំងនោះ នឹងសំយុងចុះទៅរកស្ទឹងនោះ កាលបើមានបុរស អណ្តែតទៅតាមខ្សែទឹកស្ទឹងនោះ ទុកជាចាប់កាន់ត្រែងក្តី ត្រែងនោះក៏ដេកទៅ បុរសនោះ នឹងដល់នូវសេចក្តីមិនចម្រើននិងសេចក្តីវិនាស ព្រោះដំណើរនោះជាហេតុ ។ ទុកជាចាប់កាន់ស្បូវក្តី ។ ទុកជាចាប់កាន់ស្មៅដំណេកទន្សាយក្តី ។ ទុកជាចាប់កាន់ស្បូវរណ្តាសក្តី ។

រុក្ខេ ចេបិ គណ្ហេយ្យ តេ បលុជ្ជេយ្យុំ សោ តតោនិទានំ អនយព្យសនំ អាបជ្ជេយ្យ ។ ឯវមេវ ខោ ភិក្ខវេ អស្សុតវា បុថុជ្ជនោ អរិយានំ អទស្សាវី អរិយធម្មស្ស អកោវិទោ អរិយធម្មេ អវិនីតោ សប្បុរិសានំ អទស្សាវី សប្បុរិសធម្មស្ស អកោវិទោ សប្បុរិសធម្មេ អវិនីតោ រូបំ អត្តតោ សមនុបស្សតិ រូបវន្តំ វា អត្តានំ អត្តនិ វា រូបំ រូបស្មឹ វា អត្តានំ តស្ស តំ រូបំ បលុជ្ជតិ សោ តតោនិទានំ អនយព្យសនំ អាបជ្ជតិ ។ វេទនំ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ អត្តតោ សមនុបស្សតិ វិញ្ញាណវន្តំ វា អត្តានំ អត្តនិ វា វិញ្ញាណំ វិញ្ញាណស្មឹ វា អត្តានំ តស្ស តំ វិញ្ញាណំ បលុជ្ជតិ សោ តតោនិទានំ អនយព្យសនំ អាបជ្ជតិ ។

ទុកជាចាប់កាន់ដើមឈើក្តី ឈើទាំងនោះក៏ដេកទៅ បុរសនោះនឹងដល់នូវសេចក្តីមិនចម្រើននឹងសេចក្តីវិនាស ព្រោះដំណើរនោះជាហេតុ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនដែលមិនចេះដឹង មិនបានឃើញពួកព្រះអរិយៈ មិនឈ្លាសវៃក្នុងអរិយធម៌ មិនសិក្សាក្នុងអរិយធម៌ មិនបានឃើញពួកសប្បុរស មិនឈ្លាសវៃក្នុងសប្បុរិសធម៌ មិនបានសិក្សាក្នុងសប្បុរិសធម៌ រមែងពិចារណាឃើញនូវរូបថាជាខ្លួន ឃើញនូវខ្លួនថាមានរូបខ្លះ ឃើញនូវរូបថាមានក្នុងខ្លួនខ្លះ ឃើញនូវខ្លួនថាមានក្នុងរូបខ្លះ រូបនោះរបស់បុថុជ្ជននោះ រមែងរលុបរលាយទៅ បុថុជ្ជននោះក៏ដល់នូវសេចក្តីមិនចម្រើននឹងសេចក្តីវិនាស ព្រោះដំណើរនោះជាហេតុ ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ ឃើញនូវវិញ្ញាណថាជាខ្លួន ឃើញនូវខ្លួនថាមានវិញ្ញាណខ្លះ ឃើញនូវវិញ្ញាណថាមានក្នុងខ្លួនខ្លះ ឃើញនូវខ្លួនថាមានក្នុងវិញ្ញាណខ្លះ វិញ្ញាណនោះរបស់បុថុជ្ជននោះ រមែងរលុបរលាយទៅ បុថុជ្ជននោះក៏ដល់នូវសេចក្តីមិនចម្រើននឹងសេចក្តីវិនាស ព្រោះដំណើរនោះជាហេតុ ក៏យ៉ាងនោះឯង ។

[២៣៨] តំ កឹ មញ្ញថ ភិក្ខវេ រូបំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ វេទនា ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ តស្មា-តិហ ភិក្ខវេ ។បេ។ ឯវំ បស្សំ ។បេ។ នាបរំ ឥត្ថត្តា-យាតិ បជានាតីតិ ។

[២៣៩] សាវត្ថិយំ ។ តត្រ ខោ ។បេ។ នាហំ ភិក្ខវេ លោកេន វិវទាមិ ។ លោកោ ច ខោ ភិក្ខវេ មយា វិវទតិ ។ ន ភិក្ខវេ ធម្មវាទី កេនចិ លោ-កស្មឹ វិវទតិ ។ យំ ភិក្ខវេ នត្ថិសម្មតំ លោកេ បណ្ឌិតានំ អហំបិ តំ អត្ថីតិ វទាមិ ។ យំ ភិក្ខវេ អត្ថិសម្មតំ លោកេ បណ្ឌិតានំ អហំបិ តំ អត្ថីតិ វទាមិ ។ កិញ្ច ភិក្ខវេ នត្ថិសម្មតំ លោកេ បណ្ឌិ-តានំ យមហំ នត្ថីតិ វទាមិ ។ រូបំ ភិក្ខវេ និច្ចំ ធុវំ

(២៣៨) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សំគាល់នូវសេចក្ដីនោះ ដូចម្ដេច រូបទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងសាសនានេះ ។ បេ ។ កាលបើភិក្ខុឃើញយ៉ាងនេះ ។ បេ ។ រមែងដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។

(២៣៩) ជិតក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនដែលពោលទាស់នឹងសត្វលោកទេ ។ ម្នាលភិក្ខុទាំងឡាយ តែសត្វលោកតែងពោលទាស់នឹងតថាគត ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលជាធម្មកថិករមែងមិនពោលទាស់នឹងបុគ្គលនីមួយក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ របស់ណាដែលបណ្ឌិតសន្មតហើយថា មិនមានក្នុងលោក តថាគតក៏ពោលនូវរបស់នោះថាមិនមានដែរ ។ ម្នាលភិក្ខុទាំងឡាយ របស់ណាដែលបណ្ឌិតសន្មតហើយថាមានក្នុងលោក តថាគតក៏ពោលនូវរបស់នោះថាមានដែរ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវរបស់ណាថាមិនមាន ចុះរបស់នោះ ដូចម្ដេច ដែលបណ្ឌិតសន្មតហើយថាមិនមានក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ រូបដែលទៀងទាត់

សស្សតំ អវិបរិណាមធម្មំ នត្ថិសម្មតំ លោកេ បណ្ឌិតានំ អហំបិ តំ នត្ថីតិ វទាមិ ។ វេទនា ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ និច្ចំ ធុវំ សស្សតំ អវិបរិណាមធម្មំ នត្ថិសម្មតំ លោកេ បណ្ឌិតានំ អហំបិ តំ នត្ថីតិ វទាមិ ។ ឥទំ ខោ ភិក្ខវេ នត្ថិសម្មតំ លោកេ បណ្ឌិតានំ យមហំ នត្ថីតិ វទាមិ ។ កិញ្ច ភិក្ខវេ អត្ថិសម្មតំ លោកេ បណ្ឌិតានំ យមហំ អត្ថីតិ វទាមិ ។ រូបំ ភិក្ខវេ អនិច្ចំ ទុក្ខំ វិបរិណាមធម្មំ អត្ថិសម្មតំ លោកេ បណ្ឌិតានំ អហំបិ តំ អត្ថីតិ វទាមិ ។ វេទនា ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ អនិច្ចំ ទុក្ខំ វិបរិណាមធម្មំ អត្ថិសម្មតំ លោកេ បណ្ឌិតានំ អហំបិ តំ អត្ថីតិ វទាមិ ។ ឥទំ ខោ ភិក្ខវេ អត្ថិសម្មតំ លោកេ បណ្ឌិតានំ យមហំ អត្ថីតិ វទាមិ ។

ឋិតថេរ មិនប្រែប្រួលជាធម្មតា ដែលបណ្ឌិតសន្មតថាមិនមានក្នុងលោក តថាគតក៏ពោលនូវរូបនោះថាមិនមានដែរ ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណដែលទៀងទាត់ ឋិតថេរ មិនប្រែប្រួលជាធម្មតា ដែលបណ្ឌិតសន្មតថាមិនមានក្នុងលោក តថាគតក៏ពោលនូវវិញ្ញាណនោះថាមិនមានដែរ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវរបស់ណាថាមិនមាន របស់នោះឯង ក៏បណ្ឌិតសន្មតថាមិនមានក្នុងលោកដែរ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវរបស់ណាថាមាន ចុះរបស់នោះដូចម្តេច ដែលបណ្ឌិតសន្មតថាមានក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ រូបមិនទៀង ជាទុក្ខ ប្រែប្រួលជាធម្មតា ដែលបណ្ឌិតសន្មតថាមានក្នុងលោក តថាគតក៏ពោលនូវរូបនោះថាមានដែរ ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណមិនទៀង ជាទុក្ខ ប្រែប្រួលជាធម្មតា ដែលបណ្ឌិតសន្មតថាមានក្នុងលោក តថាគតក៏ពោលនូវវិញ្ញាណនោះថាមានដែរ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវរបស់ណាថាមាន របស់នេះឯង ក៏បណ្ឌិតសន្មតថាមានក្នុងលោកដែរ ។

(២៤០) អត្ថិ ភិក្ខវេ លោកេ លោកធម្មោ តំ(១) តថាគតោ អភិសម្ពុជ្ឈតិ អភិសមេតិ អភិសម្ពុជ្ឈិត្វា អភិសមេត្វា អាចិក្ខតិ ទេសេតិ បញ្ញបេតិ បដ្ឋបេតិ វិវរតិ វិភជតិ ឧត្តានីករោតិ ។ កិញ្ច ភិក្ខវេ លោកេ លោកធម្មោ តំ តថាគតោ អភិសម្ពុជ្ឈតិ អភិសមេតិ អភិសម្ពុជ្ឈិត្វា អភិសមេត្វា អាចិក្ខតិ ទេសេតិ បញ្ញបេតិ បដ្ឋបេតិ វិវរតិ វិភជតិ ឧត្តានីករោតិ ។ រូបំ ភិក្ខវេ លោកេ លោកធម្មោ តំ តថាគតោ អភិសម្ពុជ្ឈតិ ។ បេ ។ ឧត្តានីករោតិ ។ យោ ភិក្ខវេ តថាគតេន ឯវំ អាចិក្ខិយមានេ ទេសិយមានេ បញ្ញបិយមានេ បដ្ឋបិយមានេ វិវរិយមានេ វិភជិយមានេ ឧត្តានីករិយមានេ ន ជានាតិ ន បស្សតិ តមហំ ភិក្ខវេ ពាលំ បុថុជ្ជនំ អន្ធំ អចក្ខុកំ អជានន្តំ អបស្សន្តំ កិន្តិ ករោមិ ។ វេទនា ភិក្ខវេ ។ សញ្ញា ភិក្ខវេ ។ សង្ខារា ភិក្ខវេ ។

១ ឱ. សព្វវារេសុ យត្ថិ ភិ ឃាហោ ។

[២៨០] ម្នាលភិក្ខុទាំងឡាយ លោកធម៌(១) រមែងមានក្នុងលោក ព្រះតថាគតបានចាក់ធ្លុះត្រាស់ដឹង នូវលោកធម៌នោះ លុះចាក់ធ្លុះត្រាស់ដឹងហើយ ក៏រមែងប្រាប់ សំដែង បញ្ញត្ត តែងតាំង បើក វែកញែក ធ្វើឲ្យរាក់ ៗ ម្នាលភិក្ខុទាំងឡាយ ចុះធម្មជាតដូចម្តេច ជាលោកធម៌ក្នុងលោក ដែលព្រះតថាគតចាក់ធ្លុះត្រាស់ដឹងនូវធម្មជាតនោះ លុះចាក់ធ្លុះត្រាស់ដឹងហើយ ក៏រមែងប្រាប់ សំដែង បញ្ញត្ត តែងតាំង វែកញែក ធ្វើឲ្យរាក់ ៗ ម្នាលភិក្ខុទាំងឡាយ រូបជាលោកធម៌ក្នុងលោក ព្រះតថាគតបានចាក់ធ្លុះ នូវរូបនោះ ៗ បេ ៗ ធ្វើឲ្យរាក់ ៗ ម្នាលភិក្ខុទាំងឡាយ កាលបើរូបដែលព្រះតថាគតប្រាប់ សំដែង បញ្ញត្ត តែងតាំង បើក វែកញែក ធ្វើឲ្យរាក់យ៉ាងនេះ បុគ្គលណានៅតែមិនដឹងមិនយល់ទៀត ម្នាលភិក្ខុទាំងឡាយ តថាគតនឹងធ្វើដូចម្តេច នូវបុគ្គល ដែលល្ងង់ ជាបុថុជ្ជន ខ្វាក់ មិនមានចក្ខុ មិនដឹង មិនយល់នោះ ៗ ម្នាលភិក្ខុទាំងឡាយ វេទនា ៗ ម្នាលភិក្ខុទាំងឡាយ សញ្ញា ៗ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ ៗ

១ សំដៅយកខន្ធបញ្ចកៈ ។

វិញ្ញាណំ ភិក្ខវេ លោកេ លោកធម្មោ តំ តថាគតោ អភិសម្ពុជ្ឈតិ អភិសមេតិ អភិសម្ពុជ្ឈិត្វា អភិសមេត្វា អាចិក្ខតិ ទេសេតិ បញ្ញបេតិ បដ្ឋបេតិ វិវរតិ វិភជតិ ឧត្តានីករោតិ ។ យោ ភិក្ខវេ តថាគតេន ឯវំ អាចិក្ខិយមានេ ទេសិយមានេ ឧត្តានីករិយមានេ ន ជានាតិ ន បស្សតិ តមហំ ភិក្ខវេ ពាលំ បុថុជ្ជនំ អន្ធំ អចក្ខុកំ អជានន្តំ អបស្សន្តំ កិន្តិ ករោមិ ។

(២៤១) សេយ្យថាបិ ភិក្ខវេ ឧប្បលំ វា បទុមំ វា បុណ្ឌរីកំ វា ឧទកេ ជាតំ ឧទកេ សំវឌ្ឍំ(១) ឧទកា អច្ចុគ្គម្ម ឋាតិ(២) អនុបលិត្តំ ឧទកេន ។ ឯវមេវ ខោ ភិក្ខវេ តថាគតោ លោកេ ជាតោ លោកេ សំវឌ្ឍោ(៣) លោកំ អភិភុយ្យ វិហរតិ អនុបលិត្តោ លោកេនាតិ ។

---

១ ម. សំវទ្ធំ ។ ២ តិដ្ឋតិ ។ ៣ សំវទ្ធោ ។

ម្នាលភិក្ខុទាំងឡាយ វិញ្ញាណជាលោកធម៌ក្នុងលោក ព្រះតថាគតតាក់ស្ទះត្រាស់ដឹងនូវវិញ្ញាណនោះ លុះតាក់ស្ទះត្រាស់ដឹងហើយ ក៏រមែងប្រាប់ សំដែង បញ្ញត្ត តែងតាំង បើក វែកញែក ធ្វើឲ្យរាក់ ។ ម្នាលភិក្ខុទាំងឡាយ កាលបើវិញ្ញាណដែលព្រះតថាគតប្រាប់ សំដែង បញ្ញត្ត តែងតាំង បើក វែកញែក ធ្វើឲ្យរាក់យ៉ាងនេះ បុគ្គលណានៅតែមិនដឹង មិនយល់ទៀត ម្នាលភិក្ខុទាំងឡាយ តថាគតនឹងធ្វើដូចម្តេចកើត នូវបុគ្គលនោះ ដែលល្ងង់ ជាបុថុជ្ជន ខ្វាក់ មិនមានចក្ខុ មិនដឹង មិនយល់នោះ ។

[២៤១] ម្នាលភិក្ខុទាំងឡាយ ដូចជាព្រលិតក្តី ឈូកក្រហមក្តី ឈូកសក្តី ដែលដុះក្នុងទឹក ចំរើនឡើងក្នុងទឹក លូតផុតអំពីទឹក មិនទទឹកដោយទឹក យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគត ដែលកើតក្នុងលោក ចំរើនក្នុងលោក រមែងគ្របសង្កត់នូវលោក មិនជាប់ចំពាក់ដោយលោក ក៏យ៉ាងនោះឯង ។

[៦៤៦] ឯកំ សមយំ ភគវា អយុជ្ឈាយំ វិហរតិ គង្គាយ នទិយា តីរេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ សេយ្យថាបិ ភិក្ខវេ អយំ គង្គា នទី មហន្តំ ផេណបិណ្ឌំ អាវហេយ្យ តមេនំ ចក្ខុមា បុរិសោ បស្សេយ្យ និជ្ឈាយេយ្យ យោនិសោ ឧបបរិក្ខេយ្យ តស្ស បស្សតោ និជ្ឈាយតោ យោនិសោ ឧបបរិក្ខតោ រិត្តកញ្ញេវ ខាយេយ្យ តុច្ឆកញ្ញេវ ខាយេយ្យ អសារកញ្ញេវ ខាយេយ្យ កិញ្ហិ សិយា ភិក្ខវេ ផេណបិណ្ឌេ សារោ ។ ឯវមេវ ខោ ភិក្ខវេ យំ កិញ្ចិ រូបំ អតីតានាគតប្បច្ចុប្បន្នំ ។បេ។ យំ ទូរេ សន្តិកេ វា តំ ភិក្ខុ បស្សតិ និជ្ឈាយតិ យោនិសោ ឧបបរិក្ខតិ តស្ស បស្សតោ និជ្ឈាយតោ យោនិសោ ឧបបរិក្ខតោ រិត្តកញ្ញេវ ខាយតិ តុច្ឆកញ្ញេវ ខាយតិ អសារកញ្ញេវ ខាយតិ កិញ្ហិ សិយា ភិក្ខវេ រូបេ សារោ ។

[២៤២] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅទៀបឆ្នេរនៃស្ទឹងគង្គា ជិតក្រុងអយុជ្ឈា ។ ក្នុងទីនោះ ព្រះមានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ដូចជាស្ទឹងគង្គានេះ បន្សាត់ទៅ នូវដុំនៃពពុះទឹកដ៏ធំ បុរសមានភ្នែកក្រឡេកមើលឃើញដុំនៃពពុះទឹកនោះ ហើយពិចារណា ដោយឧបាយ កាលបើបុរសនោះក្រឡេកមើលឃើញ ពិចារណាដោយឧបាយ ដុំនៃពពុះទឹកនោះក៏ប្រាកដជារបស់សោះសូន្យ ប្រាកដជារបស់ទទេ ប្រាកដជារបស់មិនមានខ្លឹម ម្នាលភិក្ខុទាំងឡាយ ខ្លឹមនឹងមានក្នុងដុំនៃពពុះទឹក ដូចម្តេចបាន យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ រូបណានីមួយ ជាអតីត អនាគត បច្ចុប្បន្ន ។ បេ ។ រូបណា ក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី ភិក្ខុក្រឡេកមើលឃើញរូបនោះ ពិចារណាដោយឧបាយ កាលបើភិក្ខុនោះក្រឡេកមើលឃើញ ពិចារណាដោយឧបាយ រូបនោះក៏ប្រាកដជារបស់សោះសូន្យ ប្រាកដជារបស់ទទេ ប្រាកដជារបស់មិនមានខ្លឹម ម្នាលភិក្ខុទាំងឡាយ ខ្លឹមនឹងមានក្នុងរូបដូចម្តេចបាន ក៏យ៉ាងនោះឯង ។

[៦៤៣] សេយ្យថាបិ ភិក្ខវេ សារទសមយេ ថុល្លផុសិតកេ ទេវេ វស្សន្តេ ឧទកេ ឧទកបុព្វុឡំ(១) ឧប្បជ្ជតិ ចេវ និរុជ្ឈតិ ច តមេនំ ចក្ខុមា បុរិសោ បស្សេយ្យ និជ្ឈាយេយ្យ យោនិសោ ឧបបរិក្ខេយ្យ តស្ស(២) បស្សតោ និជ្ឈាយតោ យោនិសោ ឧបបរិក្ខតោ រិត្តកញ្ញេវ ខាយេយ្យ តុច្ឆកញ្ញេវ ខាយេយ្យ អសារកញ្ញេវ ខាយេយ្យ កិញ្ហិ សិយា ភិក្ខវេ ឧទកបុព្វុឡេ សារោ ។ ឯវមេវ ខោ ភិក្ខវេ យា កាចិ វេទនា អតីតានាគតបច្ចុប្បន្នា ។បេ។ យា ទូរេ សន្តិកេ វា តំ ភិក្ខុ បស្សតិ និជ្ឈាយតិ យោនិសោ ឧបបរិក្ខតិ តស្ស បស្សតោ និជ្ឈាយតោ យោនិសោ ឧបបរិក្ខតោ រិត្តកញ្ញេវ ខាយតិ តុច្ឆកញ្ញេវ ខាយតិ អសារកញ្ញេវ ខាយតិ កិញ្ហិ សិយា ភិក្ខវេ វេទនាយ សារោ ។

---

១ ឧទកពុព្វុឡន្តិបិ បាឋោ ។ ២ ឱ. តស្ស តម្បស្សតោ ។

(២៤៣) ម្នាលភិក្ខុទាំងឡាយ ដូចជាភ្លៀងមានតំណក់ដ៏ថ្លោស បង្អុរចុះមក ក្នុងសារទសម័យ ឯក្រពេញទឹកតែងកើតឡើងក្នុងទឹកផង បែកធ្លាយទៅក្នុងទឹកផង បុរសមានភ្នែក ក្រឡេកមើលឃើញក្រពេញទឹកនោះ ពិចារណាដោយឧបាយ កាលបើបុរសនោះ ក្រឡេកមើលឃើញ ពិចារណាដោយឧបាយ ក្រពេញទឹកនោះ ក៏ប្រាកដជារបស់សោះសូន្យ ប្រាកដជារបស់ទទេ ប្រាកដជារបស់មិនមានខ្លឹម ម្នាលភិក្ខុទាំងឡាយ ខ្លឹមនឹងមានក្នុងក្រពេញទឹកដូចម្តេចបាន យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ វេទនាណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ។ បេ ។ វេទនាណា ក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី ភិក្ខុតែងក្រឡេកមើលឃើញវេទនានោះ ពិចារណាដោយឧបាយ កាលបើភិក្ខុនោះក្រឡេកមើលឃើញ ពិចារណាដោយឧបាយ វេទនានោះ ក៏ប្រាកដជារបស់សោះសូន្យ ប្រាកដជារបស់ទទេ ប្រាកដជារបស់មិនមានខ្លឹម ម្នាលភិក្ខុទាំងឡាយ ខ្លឹមនឹងមានក្នុងវេទនាដូចម្តេចបាន ក៏យ៉ាងនោះឯង ។

(២៤៤) សេយ្យថាបិ ភិក្ខវេ គិម្ហានំ បច្ឆិមេ មាសេ ឋិតេ មជ្ឈន្ហិកេ កាលេ មរីចិ(១) ផន្ទតិ តមេនំ ចក្ខុមា បុរិសោ បស្សេយ្យ និជ្ឈាយេយ្យ យោនិសោ ឧបបរិក្ខេយ្យ តស្ស បស្សតោ និជ្ឈាយតោ យោនិសោ ឧបបរិក្ខតោ រិត្តកញ្ញេវ ខាយេយ្យ ។បេ។ កិញ្ហិ សិយា ភិក្ខវេ មរីចិកាយ សារោ ។ ឯវមេវ ខោ ភិក្ខវេ យា កាចិ សញ្ញា ។បេ។

១ ឱ. ម. មរីចិកា ។

(២៤៤) ម្នាលភិក្ខុទាំងឡាយ ព្រេញថ្ងៃរមែងញាប់ញ័រក្នុងវេលាថ្ងៃត្រង់ ក្នុងខែជាខាងចុងនៃគិម្ហរដូវ បុរសមានភ្នែក ក្រឡេកមើលឃើញព្រេញថ្ងៃនោះ ពិចារណាដោយឧបាយ កាលបើបុរសនោះក្រឡេកមើលឃើញ ពិចារណាដោយឧបាយ ព្រេញថ្ងៃនោះក៏ប្រាកដជារបស់សោះសូន្យ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ខ្លឹមនឹងមានក្នុងព្រេញថ្ងៃដូចម្តេចបាន យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ សញ្ញាណាទីមួយ ក៏យ៉ាងនោះឯង ។ បេ ។

[២៤៥] សេយ្យថាបិ ភិក្ខវេ បុរិសោ សារត្ថិកោ សារគវេសី សារបរិយេសនំ ចរមានោ តិណ្ហំ កុឋារឹ អាទាយ វនំ បវិសេយ្យ សោ តត្ថ បស្សេយ្យ មហន្តំ កទលិក្ខន្ធំ ឧជុំ នវំ អកុក្កុជកជាតំ(១) តមេនំ មូលេ ឆិន្ទេយ្យ មូលេ ឆេត្វា អគ្គេ ឆិន្ទេយ្យ អគ្គេ ឆេត្វា បត្តវដ្ដឹ វិនិព្ភុជេយ្យ សោ តត្ថ បត្តវដ្ដឹ វិនិព្ភុជន្តោ ផេគ្គុំបិ នាធិគច្ឆេយ្យ កុតោ សារំ តមេនំ ចក្ខុមា បុរិសោ បស្សេយ្យ និជ្ឈាយេយ្យ យោនិសោ ឧបបរិក្ខេយ្យ តស្ស បស្សតោ និជ្ឈាយតោ យោនិសោ ឧបបរិក្ខតោ រិត្តកញ្ញេវ ខាយេយ្យ តុច្ឆកញ្ញេវ ខាយេយ្យ អសារកញ្ញេវ ខាយេយ្យ កិញ្ហិ សិយា ភិក្ខវេ កទលិក្ខន្ធេ សារោ ។ ឯវមេវ ខោ ភិក្ខវេ យេ កេចិ សង្ខារា អតីតានាគតបច្ចុប្បន្នា ។បេ។ យេ ទូរេ សន្តិកេ វា តំ ភិក្ខុ បស្សតិ និជ្ឈាយតិ

---

១ ឱ. អកុក្កជាតំ ។

[២៤៥] ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅកាន់ទីស្វែងរកខ្លឹមឈើ បានកាន់យកដឹងដ៏មុត ចូលទៅកាន់ព្រៃ បុរសនោះឃើញដើមចេកធំ ត្រង់ នៅខ្ចី មិនទាន់មានត្រយូង ក្នុងព្រៃនោះ ក៏កាត់ដើមចេកនោះត្រង់គល់ លុះកាត់គល់ហើយ ក៏កាត់ចុង លុះកាត់ចុងហើយ ក៏បកស្រទប កាលបើបុរសនោះបកស្រទប ក៏មិនបានសូម្បីតែស្រាយក្នុងដើមចេកនោះទេ ទឹងបាននូវខ្លឹមពីណា បុរសមានភ្នែក ក្រឡេកមើលឃើញដើមចេកនោះ ពិចារណាដោយឧបាយ កាលបើបុរសនោះក្រឡេកមើលឃើញ ពិចារណាដោយឧបាយ ដើមចេកនោះក៏ប្រាកដជារបស់សោះសូន្យ ប្រាកដជារបស់ទទេ ប្រាកដជារបស់មិនមានខ្លឹម ម្នាលភិក្ខុទាំងឡាយ ខ្លឹមទឹងមានក្នុងដើមចេកដូចម្តេចបាន យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ សង្ខារណានីមួយ ជាអតីត អនាគត បច្ចុប្បន្ន ។ បេ ។ សង្ខារណា ក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី ភិក្ខុក្រឡេកមើលឃើញសង្ខារនោះ

យោនិសោ ឧបបរិក្ខតិ តស្ស បស្សតោ និជ្ឈាយតោ យោនិសោ ឧបបរិក្ខតោ រិត្តកញ្ញេវ ខាយតិ តុច្ឆ-កញ្ញេវ ខាយតិ អសារកញ្ញេវ ខាយតិ កិញ្ហិ សិយា ភិក្ខវេ សង្ខារេសុ សារោ ។

(២៤៦) សេយ្យថាបិ ភិក្ខវេ មាយាការោ វា មាយាការន្តេវាសី វា ចាតុម្មហាបថេ មាយំ វិទំសេយ្យ តមេនំ ចក្ខុមា បុរិសោ បស្សេយ្យ និជ្ឈាយេយ្យ យោនិសោ ឧបបរិក្ខេយ្យ តស្ស បស្សតោ និជ្ឈាយតោ យោនិសោ ឧបបរិក្ខតោ រិត្តកញ្ញេវ ខាយេយ្យ តុច្ឆ-កញ្ញេវ ខាយេយ្យ អសារកញ្ញេវ ខាយេយ្យ កិញ្ហិ សិយា ភិក្ខវេ មាយាយ សារោ ។ ឯវមេវ ខោ ភិក្ខវេ យំ កិញ្ចិ វិញ្ញាណំ អតីតានាគតប្បច្ចុប្បន្នំ ។បេ។ យំ ទូរេ សន្តិកេ វា តំ ភិក្ខុ បស្សតិ និជ្ឈាយតិ យោនិសោ ឧបបរិក្ខតិ តស្ស បស្សតោ និជ្ឈាយតោ យោនិសោ ឧបបរិក្ខតោ រិត្តកញ្ញេវ ខាយតិ តុច្ឆកញ្ញេវ ខាយតិ

ពិចារណាដោយឧបាយ កាលបើភិក្ខុនោះក្រឡេកមើលឃើញ ពិចារណាដោយឧបាយ សង្ខារនោះប្រាកដជារបស់សោះសូន្យ ប្រាកដជារបស់ទទេ ប្រាកដជារបស់មិនមានខ្លឹម ម្នាលភិក្ខុទាំងឡាយ ខ្លឹមនឹងមានក្នុងសង្ខារដូចម្តេចបាន ក៏យ៉ាងនោះឯង ។

[២៤៦] ម្នាលភិក្ខុទាំងឡាយ ដូចជាបុគ្គលអ្នកធ្វើកិច្ចកលក្តី កូនសិស្សរបស់បុគ្គលអ្នកធ្វើកិច្ចកលក្តី បញ្ចេញនូវកិច្ចកល ក្នុងផ្លូវធំបែកជា ៤ ឯបុរសមានភ្នែកក្រឡេកមើលឃើញនូវកិច្ចកលនោះ ពិចារណាដោយឧបាយ កាលបើបុរសនោះក្រឡេកមើលឃើញ ពិចារណាដោយឧបាយ កិច្ចកលនោះក៏ប្រាកដជារបស់សោះសូន្យ ប្រាកដជារបស់ទទេ ប្រាកដជារបស់មិនមានខ្លឹម ម្នាលភិក្ខុទាំងឡាយ ខ្លឹមនឹងមានក្នុងកិច្ចកលដូចម្តេចបាន យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ វិញ្ញាណណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ។បេ។ វិញ្ញាណណា ក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី ភិក្ខុក្រឡេកមើលឃើញវិញ្ញាណនោះ ពិចារណាដោយឧបាយ កាលបើភិក្ខុនោះក្រឡេកមើលឃើញ ពិចារណាដោយឧបាយ វិញ្ញាណនោះក៏ប្រាកដជារបស់សោះសូន្យ ប្រាកដជារបស់ទទេ

អសារកញ្ញេវ ខាយតិ កិញ្ហិ សិយា ភិក្ខវេ វិញ្ញាណេ សារោ ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ រូបស្មឹបិ និព្វិន្ទតិ វេទនាយបិ ។ សញ្ញាយបិ ។ សង្ខារេសុបិ ។ វិញ្ញាណស្មឹបិ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ ។ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។ ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា

(២៦៧) ផេណបិណ្ឌូបមំ រូបំ
វេទនា ពុព្វុឡូបមា
មរីចិកូបមា សញ្ញា
សង្ខារា កទលូបមា
មាយូបមញ្ច វិញ្ញាណំ
ទេសិតាទិច្ចពន្ធុនា ។
យថា យថា និជ្ឈាយតិ

ប្រាកដជារបស់មិនមានខ្លឹម ម្នាលភិក្ខុទាំងឡាយ ខ្លឹមទីងមាន ក្នុងវិញ្ញាណដូចម្តេចបាន ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវ័កអ្នកចេះដឹង ឃើញយ៉ាងនេះហើយ រមែងនឿយណាយក្នុងរូបផង ក្នុងវេទនាផង ។ ក្នុងសញ្ញាផង ។ ក្នុងសង្ខារផង ។ រមែងនឿយណាយក្នុងវិញ្ញាណផង កាលបើនឿយណាយហើយ រមែងប្រាសចាកតម្រេក ចិត្តក៏ផុតស្រឡះ ព្រោះប្រាសចាកតម្រេក ។ កាលបើចិត្តផុតស្រឡះហើយ សេចក្តីដឹងថា ចិត្តផុតស្រឡះក៏កើតមាន ។ បេ ។ ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់សូត្រនេះហើយ លុះព្រះសុគតជាសាស្តាទ្រង់ត្រាស់សូត្រនេះហើយ ទ្រង់ត្រាស់គាថានេះតទៅទៀតថា

(២៤៧) ព្រះពុទ្ធមានផៅពន្ធុដូចជាព្រះអាទិត្យ សំដែង
ហើយថា រូបដូចជាដុំនៃពពុះទឹក វេទនាដូចជាក្រពេញទឹក
សញ្ញាដូចជាព្រេញថ្ងៃ សង្ខារដូចជាដើមចេក វិញ្ញាណ
ដូចជាកិច្ចកល ។ បុគ្គលក្រឡេកមើលដោយប្រការណា ៗ

យោនិសោ ឧបបរិក្ខតិ
រិត្តកំ តុច្ឆកំ ហោតិ
យោ នំ បស្សតិ យោនិសោ ។
ឥមញ្ច កាយំ អារព្ភ
ភូរិបញ្ញេន ទេសិតំ
បហានំ តិណ្ណំ ធម្មានំ
រូបំ បស្សថ ឆឌ្ឌិតំ ។
អាយុ ឧស្មា ច វិញ្ញាណំ
យទា កាយំ ជហន្តិមំ
អបវិទ្ធោ តទា សេតិ
បរភត្តំ អចេតនំ ។
ឯតាទិសាយំ សន្តានោ
មាយាយំ ពាលលាបិនី
វធកោ ឯកោ អក្ខាតោ
សារោ ឯត្ថ ន វិជ្ជតិ ។

រមែងពិចារណាដោយឧបាយ ដោយប្រការនោះៗ បុគ្គលណាឃើញនូវខន្ធបញ្ចកៈនោះដោយឧបាយ ខន្ធបញ្ចកៈនោះជារបស់សោះសូន្យទទេ តែងប្រាកដ (ដល់បុគ្គលនោះ) ។ ការលះបង់នូវធម៌ទាំង ៣ ដែលព្រះមានព្រះភាគមានបញ្ញាដូចជាផែនដី ទ្រង់ប្រារព្ធនូវកាយនេះហើយសំដែង អ្នកទាំងឡាយចូរឃើញនូវរូបដែលគេចោលហើយ ។ អាយុក្តី ភ្លើងធាតុក្តី វិញ្ញាណក្តី តែងលះបង់នូវកាយនេះដែលជាចំណីនៃសត្វដទៃ មិនមានចេតនា ក្នុងកាលណាហើយ កាយដែលគេចោលហើយ រមែងដេកលើផែនដី ក្នុងកាលនោះ ។ ធម៌ជាគំណា[១]នេះ ប្រាកដដូច្នេះឯង កិច្ចកលនេះជាគ្រឿងប្រឡោមនូវជនពាល ខន្ធនេះអ្នកប្រាជ្ញពោលហើយ ថាជាពេជ្ឈឃាដមួយ ឯខ្លឹមរមែងមិនមានក្នុងខន្ធនេះឡើយ ។

---

១ ធម៌ជាបវេណី ។

ឯវំ ខន្ធេ អវេក្ខេយ្យ
ភិក្ខុ អារទ្ធវីរិយោ
ទិវា វា យទិ វា រត្តិំ(១)
សម្បជានោ បដិស្សតោ ។
បជហេ សព្វសំយោគំ
ករេយ្យ សរណត្តនោ
ចរេយ្យាទិត្តសីសោវ
បត្ថយំ អច្ចុតំ បទន្តិ ។

[២៤៨] សាវត្ថិយំ ។ អញ្ញតរោ ភិក្ខុ ។ បេ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច អត្ថិ នុ ខោ ភន្តេ កិញ្ចិ រូបំ យំ រូបំ និច្ចំ ធុវំ សស្សតំ អវិបរិណាមធម្មំ សស្សតិសមំ តថេវ ឋស្សតិ ។ អត្ថិ នុ ខោ ភន្តេ កាចិ វេទនា យា វេទនា និច្ចា ធុវា សស្សតា អវិបរិណាមធម្មា សស្សតិសមំ តថេវ ឋស្សតិ ។ អត្ថិ នុ ខោ ភន្តេ កាចិ សញ្ញា យា សញ្ញា ។ បេ ។

---

១ ម. រត្តឹ ។

ភិក្ខុមានព្យាយាមតឹងតែង មានសេចក្តីដឹងខ្លួន មានសតិដ៏មាំ គប្បីពិចារណា នូវខន្ធយ៉ាងនេះ តាំងយប់តាំងថ្ងៃ ។ គប្បីលះបង់ នូវសំយោគទាំងពួង គប្បីធ្វើនូវទីពឹងសម្រាប់ខ្លួន កាលបើប្រាថ្នានូវព្រះនិព្វានដែលមិនមានចុតិ គប្បីប្រព្រឹត្តស្រេក ដូចជាបុគ្គលមានភ្លើងឆេះក្បាល ។

[៦៤៨] ជិតក្រុងសាវត្ថី ។ គ្រានោះ ភិក្ខុមួយរូប ។ បេ ។ លុះភិក្ខុនោះ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន រូបណា ដែលទៀងទាត់ ឋិតថេរ មិនប្រែប្រួលជាធម្មតា ឋិតនៅនឹងដដែល ស្មើដោយសស្សតិវត្ថុ រូបនោះ បន្តិចបន្តួច មានដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន វេទនាណា ដែលទៀងទាត់ ឋិតថេរ មិនប្រែប្រួលជាធម្មតា ឋិតនៅនឹងដដែល ស្មើដោយសស្សតិវត្ថុ វេទនានោះ បន្តិចបន្តួច មានដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន សញ្ញាណា ។ បេ ។ សញ្ញានោះ បន្តិចបន្តួច មានដែរ ។

អត្ថិ នុ ខោ ភន្តេ កេចិ សង្ខារា យេ សង្ខារា និច្ចា ធុវា សស្សតា អវិបរិណាមធម្មា សស្សតិសមំ តថេវ ឋស្សន្តិ ។ អត្ថិ នុ ខោ ភន្តេ កិញ្ចិ វិញ្ញាណំ យំ វិញ្ញាណំ និច្ចំ ធុវំ សស្សតំ អវិបរិណាមធម្មំ សស្សតិសមំ តថេវ ឋស្សតីតិ ។ នត្ថិ ខោ ភិក្ខុ កិញ្ចិ រូបំ យំ រូបំ និច្ចំ ធុវំ សស្សតំ អវិបរិណាមធម្មំ សស្សតិសមំ តថេវ ឋស្សតិ ។ នត្ថិ ខោ ភិក្ខុ កាចិ វេទនា ។ កាចិ សញ្ញា ។ កេចិ សង្ខារា ។ កិញ្ចិ វិញ្ញាណំ យំ វិញ្ញាណំ និច្ចំ ធុវំ សស្សតំ អវិបរិណាមធម្មំ សស្សតិសមំ តថេវ ឋស្សតិ ។

បពិត្រព្រះអង្គដ៏ចម្រើន សង្ខារណា ដែលទៀងទាត់ ឋិតថេរ មិនប្រែប្រួលជាធម្មតា ឋិតនៅនឹងដដែល ស្មើដោយសស្សតកាល សង្ខារនោះ បន្តិចបន្តួច មាននៃវត្ថុ ។ បពិត្រព្រះអង្គដ៏ចម្រើន វិញ្ញាណណា ដែលទៀងទាត់ ឋិតថេរ មិនប្រែប្រួលជាធម្មតា ឋិតនៅនឹងដដែលស្មើដោយសស្សតកាល វិញ្ញាណនោះ បន្តិចបន្តួច មាននៃវត្ថុ ។ មាលកិក្ខុ រូបណា ដែលទៀងទាត់ ឋិតថេរ មិនប្រែប្រួលជាធម្មតា ឋិតនៅនឹងដដែល ស្មើដោយសស្សតកាល រូបនោះ បន្តិចបន្តួច មិនមានទេ ។ មាលកិក្ខុ វេទនានោះ បន្តិចបន្តួច មិនមានទេ ។ សញ្ញានោះ បន្តិចបន្តួច ។ សង្ខារនោះ បន្តិចបន្តួច ។ វិញ្ញាណណា ដែលទៀងទាត់ ឋិតថេរ មិនប្រែប្រួលជាធម្មតា ឋិតនៅនឹងដដែល ស្មើដោយសស្សតកាល វិញ្ញាណនោះ បន្តិចបន្តួច (មិនមានទេ) ។

(២៤៩) អថខោ ភគវា បរិត្តំ គោមយបិណ្ឌំ បាណិនា គហេត្វា តំ ភិក្ខុំ ឯតទវោច ឯត្តកោបិ ខោ ភិក្ខុ អត្តភាវប្បដិលាភោ នត្ថិ និច្ចោ ធុវោ សស្សតោ អវិបរិណាមធម្មោ សស្សតិសមំ តថេវ ឋស្សតិ ។ ឯត្តកោ ចេបិ ភិក្ខុ អត្តភាវប្បដិលាភោ អភវិស្ស និច្ចោ ធុវោ សស្សតោ អវិបរិណាមធម្មោ ន យិទំ ព្រហ្មចរិយវាសោ បញ្ញាយេថ សម្មាទុក្ខក្ខយាយ ។ យស្មា ច ខោ ភិក្ខុ ឯត្តកោបិ អត្តភាវប្បដិលាភោ នត្ថិ និច្ចោ ធុវោ សស្សតោ អវិបរិណាមធម្មោ តស្មា ព្រហ្មចរិយវាសោ បញ្ញាយតិ សម្មាទុក្ខក្ខយាយ ។

(២៥០) ភូតបុព្វាហំ ភិក្ខុ រាជា អហោសឹ ខត្តិយោ មុទ្ធាវសិត្តោ ។ តស្ស មយ្ហំ ភិក្ខុ រញ្ញោ សតោ ខត្តិយស្ស មុទ្ធាវសិត្តស្ស ចតុរាសីតិ នគរសហស្សានិ អហេសុំ កុសាវតីរាជធានិប្បមុខានិ ។ តស្ស មយ្ហំ ភិក្ខុ រញ្ញោ សតោ ខត្តិយស្ស មុទ្ធាវសិត្តស្ស ចតុរាសីតិ បាសាទសហស្សានិ អហេសុំ ធម្មប្បាសា-

(២៤៩) គ្រានោះ ព្រះមានព្រះភាគ យកព្រះហស្តទៅចាប់ដុំអាចម៍គោបន្តិចហើយ ទ្រង់មានព្រះពុទ្ធដីកានឹងភិក្ខុនោះដូច្នេះថា ម្នាលភិក្ខុ (ការបាននូវអត្តភាពណា) ដែលទៀងទាត់ ឋិតថេរ មិនប្រែប្រួលជាធម្មតា ឋិតនៅនឹងដដែល ស្មើដោយសស្សតវត្ថុ ការបាននូវអត្តភាព (នោះ) សូម្បីប៉ុនអាចម៍គោនេះ មិនមានទេ ។ ម្នាលភិក្ខុ ប្រសិនបើការបាននូវអត្តភាពប៉ុណ្ណេះ ជារបស់ទៀងទាត់ ឋិតថេរ មិនប្រែប្រួលជាធម្មតា នឹងមានហើយ ការអប់រំព្រហ្មចរិយៈនេះ មិនប្រាកដ ដើម្បីអស់ទៅនៃទុក្ខ ដោយប្រពៃឡើយ ។ ម្នាលភិក្ខុ ព្រោះការបាននូវអត្តភាពប៉ុណ្ណេះ ជារបស់ទៀងទាត់ ឋិតថេរ មិនប្រែប្រួលជាធម្មតា មិនមានទេ បានជាការអប់រំព្រហ្មចរិយៈ ប្រាកដដើម្បីអស់ទៅនៃទុក្ខ ដោយប្រពៃបាន ។

(២៥០) ម្នាលភិក្ខុ កាលពីព្រេងនាយ តថាគតជាខត្តិយរាជ បានមុទ្ធាភិសេកហើយ ។ ម្នាលភិក្ខុ កាលដែលតថាគតជាខត្តិយរាជ បានមុទ្ធាភិសេកហើយនោះ មាននគរ ៨៤.០០០ (ប្រាំបីម៉ឺនបួនពាន់) មានកុសាវតីរាជធានីជាប្រធាន ។ ម្នាលភិក្ខុ កាលដែលតថាគតជាខត្តិយរាជបានមុទ្ធាភិសេកហើយនោះ មានប្រាសាទ ៨៤.០០០ មានធម្ម-

នប្បមុខានិ ។ តស្ស មយ្ហំ ភិក្ខុ រញ្ញោ សតោ ខត្តិយស្ស មុទ្ធាវសិត្តស្ស ចតុរាសីតិ កូដាគារសហស្សានិ អហេសុំ មហាព្យូហកូដាគារប្បមុខានិ ។ តស្ស មយ្ហំ ភិក្ខុ រញ្ញោ សតោ ខត្តិយស្ស មុទ្ធាវសិត្តស្ស ចតុរាសីតិ បល្លង្កសហស្សានិ អហេសុំ ទន្តមយានិ សារមយានិ សោវណ្ណមយានិ រូបិយមយានិ គោនកត្ថតានិ បដិកត្ថតានិ បដលិកត្ថតានិ កាទលិមិគប្បវរបច្ចត្ថរណានិ សឧត្តរច្ឆទានិ[១] ឧភតោ លោហិតកូបធានានិ ។ តស្ស មយ្ហំ ភិក្ខុ រញ្ញោ សតោ ខត្តិយស្ស មុទ្ធាវសិត្តស្ស ចតុរាសីតិ នាគសហស្សានិ អហេសុំ សោវណ្ណាលង្ការានិ សោវណ្ណធជានិ ហេមជាលប្បដិច្ឆន្នានិ ឧបោសថនាគរាជប្បមុខានិ ។ តស្ស មយ្ហំ ភិក្ខុ រញ្ញោ សតោ ខត្តិយស្ស មុទ្ធាវសិត្តស្ស ចតុរាសីតិ អស្សសហស្សានិ អហេសុំ សោវណ្ណាលង្ការានិ សោវណ្ណធជានិ ហេមជាលប្បដិច្ឆន្នានិ វលាហកអស្សរាជប្បមុខានិ ។ តស្ស មយ្ហំ ភិក្ខុ រញ្ញោ សតោ ខត្តិយស្ស មុទ្ធាវសិត្តស្ស

---

១ ឱ. សឧត្តរច្ឆទានិ ។

ប្រាសាទជាប្រធាន ។ ម្នាលភិក្ខុ កាលដែលតថាគតជាខត្តិយរាជបាន មុទ្ធាភិសេកហើយនោះ មានផ្ទះកំពូល ៨៤.០០០ មានផ្ទះកំពូលឈ្មោះ មហាព្យូហៈជាប្រធាន ។ ម្នាលភិក្ខុ កាលដែលតថាគតជាខត្តិយរាជ បានមុទ្ធាភិសេកហើយនោះ មានបល្ល័ង្ក ៨៤.០០០ ធ្វើអំពីភ្លុក ធ្វើអំពី ឈើខ្លឹម ធ្វើអំពីមាស ធ្វើអំពីប្រាក់ ក្រាលដោយព្រំមានរោមវែងជាង ៤ ធ្នាប់ ក្រាលដោយកម្រាលមានពណ៌ស ធ្វើដោយរោមសត្វ ក្រាល ដោយកម្រាលធ្វើអំពីរោមសត្វជាផ្កាចង្កោម មានកម្រាលដ៏ប្រសើរធ្វើអំពី ស្បែកឈ្លូស មានខ្នើយពណ៌ក្រហមទាំងពីរខាង គឺខ្នើយក្បាលនិងខ្នើយ ជើង ព្រមទាំងពិតាន មានពណ៌ក្រហម ។ ម្នាលភិក្ខុ កាលដែល តថាគតជាខត្តិយរាជ បានមុទ្ធាភិសេកហើយនោះ មានដំរី ៨៤.០០០ មានគ្រឿងប្រដាប់ធ្វើអំពីមាស មានទង់ធ្វើអំពីមាស គ្រោបដោយ បណ្តាញមាស មានស្តេចដំរីឈ្មោះឧបោសថជាប្រធាន ។ ម្នាលភិក្ខុ កាលដែលតថាគត ជាខត្តិយរាជ បានមុទ្ធាភិសេកហើយនោះ មាន សេះ ៨៤.០០០ មានគ្រឿងប្រដាប់ធ្វើអំពីមាស មានទង់ធ្វើអំពីមាស គ្រោបដោយបណ្តាញមាស មានស្តេចសេះឈ្មោះវលាហកជាប្រធាន ។ ម្នាលភិក្ខុ កាលដែលតថាគត ជាខត្តិយរាជ បានមុទ្ធាភិសេកហើយនោះ

ចតុរាសីតិ រថសហស្សានិ អហេសុំ សោវណ្ណាលង្ការានិ សោវណ្ណធជានិ ហេមជាលប្បដិច្ឆន្នានិ វេជយន្តរថប្បមុខានិ ។ តស្ស មយ្ហំ ភិក្ខុ រញ្ញោ សតោ ខត្តិយស្ស មុទ្ធាវសិត្តស្ស ចតុរាសីតិ មណិសហស្សានិ អហេសុំ មណិរតនប្បមុខានិ ។ តស្ស មយ្ហំ ភិក្ខុ រញ្ញោ សតោ ខត្តិយស្ស មុទ្ធាវសិត្តស្ស ចតុរាសីតិ ឥត្ថីសហស្សានិ អហេសុំ ភទ្ទាទេវិប្បមុខានិ(១) ។ តស្ស មយ្ហំ ភិក្ខុ ។បេ។ ចតុរាសីតិ ខត្តិយសហស្សានិ អហេសុំ អនុយន្តានិ បរិណាយករតនប្បមុខានិ ។ តស្ស មយ្ហំ ភិក្ខុ ។បេ។ ចតុរាសីតិ ធេនុសហស្សានិ អហេសុំ ទុកុលសន្ទនានិ កំសុបធារណានិ ។ តស្ស មយ្ហំ ភិក្ខុ ។បេ។ ចតុរាសីតិ វត្ថកោដិសហស្សានិ អហេសុំ ខោមសុខុមានិ កោសេយ្យសុខុមានិ កម្ពលសុខុមានិ កប្បាសិកសុខុមានិ ។ តស្ស មយ្ហំ ភិក្ខុ ។បេ។ ចតុរាសីតិ ថាលិបាកសហស្សានិ អហេសុំ សាយំ បាតំ ភត្តាភិហារោ អភិហរិយិត្ថ ។

១ ឱ. ម. សុភទ្ទាទេវីប្បមុខានិ ។

មានរថ ៨៤.០០០ មានគ្រឿងប្រដាប់ធ្វើអំពីមាស មានទង់ធ្វើអំពីមាស បិទបាំងដោយបណ្តាញមាស មានវេជយន្តរថជាប្រធាន ។ ម្នាលភិក្ខុ កាលដែលតថាគត ជាខត្តិយរាជបានមុទ្ធាភិសេកហើយនោះ មានមណី ៨៤.០០០ មានមណីរ័តន៍ជាប្រធាន ។ ម្នាលភិក្ខុ កាលដែលតថាគត ជាខត្តិយរាជបានមុទ្ធាភិសេកហើយនោះ មានស្ត្រី ៨៤.០០០ មាននាងភទ្ទាទេវីជាប្រធាន ។ ម្នាលភិក្ខុ កាលដែលតថាគត ។បេ។ មានក្សត្រ ៨៤.០០០ ជាចំណុះ មានបរិនាយករ័តន៍ជាប្រធាន ។ ម្នាលភិក្ខុ កាលដែលតថាគត ។បេ។ មានមេគោ ៨៤.០០០ សម្រាប់រឹតបង្ហូរយកទឹកដោះ មានភាជនៈប្រាក់សម្រាប់ត្រង ។ ម្នាលភិក្ខុ កាលដែលតថាគត ។បេ។ មានសំពត់ ៨៤.០០០ កោដិ គឺសំពត់សម្បកឈើមានសាច់ដ៏ល្អិត សំពត់សូត្រមានសាច់ដ៏ល្អិត សំពត់កម្ពលមានសាច់ដ៏ល្អិត សំពត់អម្បោះមានសាច់ដ៏ល្អិត ។ ម្នាលភិក្ខុ កាលដែលតថាគត ។បេ។ មានសម្រាប់ ៨៤.០០០ ជាភត្តាភិហារ ដែលរាជបុរសនាំមកថ្វាយ រាល់ពេលល្ងាចព្រឹក ។

[២៨១] តេសំ ខោ បន ភិក្ខុ ចតុរាសីតិយា នគរសហស្សានំ ឯតញ្ញេវ តំ នគរំ ហោតិ យមហំ តេន សមយេន អជ្ឈាវសាមិ កុសាវតី រាជធានី ។ តេសំ ខោ បន ភិក្ខុ ចតុរាសីតិយា បាសាទសហស្សានំ ឯកោយេវ សោ បាសាទោ ហោតិ យមហំ តេន សមយេន អជ្ឈាវសាមិ ធម្មោ បាសាទោ ។ តេសំ ខោ បន ភិក្ខុ ចតុរាសីតិយា កូដាគារសហស្សានំ ឯតញ្ញេវ តំ កូដាគារំ ហោតិ យមហំ តេន សមយេន អជ្ឈាវសាមិ មហាព្យូហំ កូដាគារំ ។ តេសំ ខោ បន ភិក្ខុ ចតុរាសីតិយា បល្លង្កសហស្សានំ ឯកោយេវ សោ បល្លង្កោ ហោតិ យមហំ តេន សមយេន បរិភុញ្ជាមិ ទន្តមយោ វា សារមយោ វា សុវណ្ណមយោ វា រូបិយមយោ វា ។ តេសំ ខោ បន ភិក្ខុ ចតុរាសីតិយា នាគសហស្សានំ ឯកោយេវ សោ នាគោ ហោតិ យមហំ តេន សមយេន អភិរូហាមិ ឧបោសថោ នាគរាជា ។ តេសំ ខោ បន ភិក្ខុ ចតុរាសីតិយា អស្សសហស្សានំ

(២៥១) ម្នាលភិក្ខុ បណ្ដានគរទាំង ៨៤.០០០ នោះ មានតែនគរ ១ ដែលតថាគតតែងនៅអាស្រ័យក្នុងសម័យនោះ គឺកុសាវតីរាជធានី ។ ម្នាលភិក្ខុ បណ្ដាប្រាសាទទាំង ៨៤.០០០ នោះ មានតែប្រាសាទ ១ ដែលតថាគតតែងនៅអាស្រ័យក្នុងសម័យនោះ គឺធម្មប្រាសាទ ។ ម្នាលភិក្ខុ បណ្ដាផ្ទះកំពូលទាំង ៨៤.០០០ នោះ មានតែផ្ទះកំពូល ១ ដែលតថាគត តែងនៅអាស្រ័យក្នុងសម័យនោះ គឺផ្ទះកំពូលឈ្មោះមហាព្យូហៈ ។ ម្នាលភិក្ខុ បណ្ដាបល្ល័ង្កទាំង ៨៤.០០០ នោះ មានតែបល្ល័ង្ក ១ ដែលតថាគតតែងប្រើប្រាស់ក្នុងសម័យនោះ គឺបល្ល័ង្កធ្វើអំពីភ្លុក ឬបល្ល័ង្កធ្វើអំពីខ្លឹមឈើ បល្ល័ង្កធ្វើអំពីមាស ឬបល្ល័ង្កធ្វើអំពីប្រាក់ ។ ម្នាលភិក្ខុ បណ្ដាដំរីទាំង ៨៤.០០០ នោះ មានតែដំរី ១ ដែលតថាគតតែងជិះក្នុងសម័យនោះ គឺស្ដេចដំរីឈ្មោះឧបោសថ ។ ម្នាលភិក្ខុ បណ្ដាសេះទាំង ៨៤.០០០ នោះ

ឯកោយេវ សោ អស្សោ ហោតិ យមហំ តេន សមយេន អភិរុហាមិ វលាហោ(១) អស្សរាជា ។ តេសំ ខោ បន ភិក្ខុ ចតុរាសីតិយា រថសហស្សានំ ឯកោយេវ សោ រថោ ហោតិ យមហំ តេន សមយេន អភិរុហាមិ វេជយន្តោ រថោ ។ តេសំ ខោ បន ភិក្ខុ ចតុរាសីតិយា ឥត្ថីសហស្សានំ ឯកាយេវ សា ឥត្ថី ហោតិ យមហំ តេន សមយេន បច្ចុបដ្ឋាតិ ខត្តិយា វា វេលាមិកា វា ។ តេសំ ខោ បន ភិក្ខុ ចតុរាសីតិយា វត្ថកោដិសហស្សានំ ឯកញ្ញេវ តំ វត្ថយុគំ ហោតិ យមហំ តេន សមយេន បរិទហាមិ ខោមសុខុមំ វា កោសេយ្យសុខុមំ វា កម្ពលសុខុមំ វា កប្បាសិកសុខុមំ វា ។ តេសំ ខោ បន ភិក្ខុ ចតុរាសីតិយា ថាលិបាកសហស្សានំ ឯកោយេវ សោ ថាលិបាកោ ហោតិ យតោ នាឡិកោទនបរមំ ភុញ្ជាមិ តទុបិយំ ច សូបព្យញ្ជនំ(២) ។ ឥតិ ខោ ភិក្ខុ សព្វេ តេ សង្ខារា អតីតា

១ ម. វលាហកោ ។ ឱ. វលាហកអស្សរាជា ។ ២ ឱ. ម. សូបេយ្យំ ។

មានតែសេះ ១ ដែលតថាគតតែងជិះក្នុងសម័យនោះ គឺសេះឈ្មោះវលាហកៈ ។ ម្នាលភិក្ខុ បណ្ដារថទាំង ៨៤.០០០ នោះ មានតែរថ ១ ដែលតថាគតតែងជិះក្នុងសម័យនោះ គឺវេជយន្តរថ ។ ម្នាលភិក្ខុ បណ្ដាស្ត្រីទាំង ៨៤.០០០ នោះ មានតែស្ត្រី ១ ដែលជាអ្នកបម្រើផ្លុំតថាគតក្នុងសម័យនោះ គឺស្ត្រីជាខត្តិយា ឬស្ត្រីជាវេលាមិកា(១) ។ ម្នាលភិក្ខុ បណ្ដាសំពត់ទាំង ៨៤.០០០ កោដិនោះ មានតែសំពត់ ១ គូ ដែលតថាគតតែងស្លៀកដណ្ដប់ក្នុងសម័យនោះ គឺសំពត់សម្បកឈើមានសាច់ដ៏ល្អិត ឬសំពត់សូត្រមានសាច់ដ៏ល្អិត សំពត់កម្ពលមានសាច់ដ៏ល្អិត ឬសំពត់អម្បោះមានសាច់ដ៏ល្អិត ។ ម្នាលភិក្ខុ បណ្ដាសម្រាប់ទាំង ៨៤.០០០ នោះ មានតែសម្រាប់១ ដែលតថាគតតែងបរិភោគ គឺបាយដែលគេចំអិនដោយអង្ករ ១ នាឡិ ជាកំណត់ ទាំងសម្ល និងម្ហូបគ្រឿងដ៏សមគួរដល់បាយនោះ ។ ម្នាលភិក្ខុ សង្ខារទាំងអស់នោះ សុទ្ធតែកន្លងហើយ

១ គឺស្ត្រីមានបិតាជាក្សត្រិយ៍ មាតាជាព្រាហ្មណ៍ ឬបិតាជាព្រាហ្មណ៍ មាតាជាក្សត្រិយ៍ (អដ្ឋកថា) ។

និរុទ្ធា វិបរិណតា ឯវំ អនិច្ចា ខោ ភិក្ខុ សង្ខារា ឯវំ អទ្ធុវា ខោ ភិក្ខុ សង្ខារា ឯវំ អនស្សាសិកា ខោ ភិក្ខុ សព្វេ សង្ខារា ។ យាវញ្ចិទំ ភិក្ខុ អលមេវ សព្វសង្ខារេសុ និព្វិន្ទិតុំ អលំ វិរជ្ជិតុំ អលំ វិមុច្ចិតុន្តិ ។

(២៤២) សាវត្ថិយំ ។ អារាមេ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច អត្ថិ នុ ខោ ភន្តេ កិញ្ចិ រូបំ យំ រូបំ និច្ចំ ធុវំ សស្សតំ អវិបរិណាមធម្មំ សស្សតិសមំ តថេវ ឋស្សតិ ។ អត្ថិ នុ ខោ ភន្តេ កាចិ វេទនា យា វេទនា និច្ចា ធុវា សស្សតា អវិបរិណាម-ធម្មា សស្សតិសមំ តថេវ ឋស្សតិ ។ អត្ថិ នុ ខោ ភន្តេ កាចិ សញ្ញា ។ បេ ។ កេចិ សង្ខារា យេ សង្ខារា និច្ចា ធុវា សស្សតា អវិបរិណាមធម្មា សស្សតិសមំ តថេវ ឋស្សន្តិ ។ អត្ថិ នុ ខោ ភន្តេ កិញ្ចិ វិញ្ញាណំ យំ វិញ្ញាណំ និច្ចំ ធុវំ សស្សតំ អវិបរិណាមធម្មំ

រលត់ហើយ មានសេចក្តីប្រែប្រួលទៅហើយ ដោយប្រការដូច្នេះ ម្នាលភិក្ខុ សង្ខារមិនទៀងយ៉ាងនេះឯង ម្នាលភិក្ខុ សង្ខារមិនឋិតថេរ យ៉ាងនេះឯង ម្នាលភិក្ខុ សង្ខារទាំងពួង មិនមានគ្រឿងទំនុកបម្រុង យ៉ាងនេះឯង ។ ម្នាលភិក្ខុ ហេតុនេះ គួរដើម្បីនឿយណាយ គួរដើម្បីធុញទ្រាន់ គួរដើម្បីជិនឆ្អន់ ក្នុងសង្ខារទាំងពួង ។

[២៩២] ជិតក្រុងសាវត្ថី ។ ក្នុងវត្ត ។ លុះភិក្ខុនោះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន រូបណា ដែលទៀងទាត់ ឋិតថេរ មិនប្រែប្រួលជាធម្មតា ឋិតនៅនឹងដដែល ស្មើដោយសស្សតវត្ថុ រូបនោះ បន្តិចបន្តួច មានដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន វេទនាណា ដែលទៀងទាត់ ឋិតថេរ មិនប្រែប្រួលជាធម្មតា ឋិតនៅនឹងដដែល ស្មើដោយសស្សតវត្ថុ វេទនានោះ បន្តិចបន្តួច មានដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន សញ្ញានោះ បន្តិចបន្តួច មានដែរឬ ។ បេ ។ សង្ខារណា ដែលទៀងទាត់ ឋិតថេរ មិនប្រែប្រួលជាធម្មតា ឋិតនៅនឹងដដែល ស្មើដោយសស្សតវត្ថុ សង្ខារនោះ បន្តិចបន្តួច មានដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន វិញ្ញាណណា ដែលទៀងទាត់ ឋិតថេរ មិនប្រែប្រួលទៅជាធម្មតា

សស្សតិសមំ តថេវ ឋស្សតីតិ ។ នត្ថិ ខោ ភិក្ខុ កិញ្ចិ រូបំ យំ រូបំ និច្ចំ ធុវំ សស្សតំ អវិបរិណាមធម្មំ សស្សតិសមំ តថេវ ឋស្សតិ ។ នត្ថិ ខោ ភិក្ខុ កាចិ វេទនា ។ កាចិ សញ្ញា ។ កេចិ សង្ខារា ។ កិញ្ចិ វិញ្ញាណំ យំ វិញ្ញាណំ និច្ចំ ធុវំ សស្សតំ អវិបរិណាមធម្មំ សស្សតិសមំ តថេវ ឋស្សតីតិ ។

[២៤៣] អថខោ ភគវា បរិត្តំ នខសិខាយំ បំសុំ អារោបេត្វា តំ ភិក្ខុំ ឯតទវោច ឯត្តកំបិ ខោ ភិក្ខុ រូបំ នត្ថិ និច្ចំ ធុវំ សស្សតំ អវិបរិណាមធម្មំ សស្សតិសមំ តថេវ ឋស្សតិ ។ ឯត្តកំបិ ចេ ភិក្ខុ រូបំ អភវិស្ស និច្ចំ ធុវំ សស្សតំ អវិបរិណាមធម្មំ ន យិទំ ព្រហ្មចរិយវាសោ

ឋិតនៅទឹងដដែល ស្មើដោយសស្សតិវត្ថុ វិញ្ញាណនោះ បន្តិចបន្តួចមាន ដែរឬ ។ ម្នាលភិក្ខុ រូបណា ដែលទៀងទាត់ ឋិតថេរ មិនប្រែប្រួល ជាធម្មតា ឋិតនៅទឹងដដែល ស្មើដោយសស្សតិវត្ថុ រូបនោះ បន្តិច បន្តួច មិនមានទេ ។ ម្នាលភិក្ខុ វេទនានោះ បន្តិចបន្តួច មិនមានទេ ។ សញ្ញានោះ បន្តិចបន្តួច ។ សង្ខារនោះ បន្តិចបន្តួច ។ វិញ្ញាណណា ដែលទៀងទាត់ ឋិតថេរ មិនប្រែប្រួលជាធម្មតា ឋិតនៅទឹងដដែល ស្មើដោយសស្សតិវត្ថុ វិញ្ញាណនោះ បន្តិចបន្តួច មិនមានទេ ។

(២៤៣) គ្រានោះ ព្រះមានព្រះភាគ ទ្រង់ចូកអាចម៍ដីបន្តិច ដោយចុងព្រះនខា ហើយទ្រង់មានព្រះពុទ្ធដីកានឹងភិក្ខុនោះ ដូច្នេះថា ម្នាលភិក្ខុ រូបណា ដែលទៀងទាត់ ឋិតថេរ មិនប្រែប្រួលជាធម្មតា ឋិតនៅទឹងដដែល ស្មើដោយសស្សតិវត្ថុ រូបនោះសូម្បីប៉ុនអាចម៍ដីនេះមិន មានទេ ។ ម្នាលភិក្ខុ ប្រសិនបើរូបប៉ុណ្ណេះជារបស់ទៀងទាត់ ឋិតថេរ មិនប្រែប្រួលជាធម្មតានឹងមានហើយ ការអប់រំព្រហ្មចរិយៈនេះ មិន

បញ្ញាយេថ សម្មាទុក្ខក្ខយាយ ។ យស្មា ច ខោ ភិក្ខុ ឯត្តកំបិ រូបំ នត្ថិ និច្ចំ ធុវំ សស្សតំ អវិបរិណាមធម្មំ តស្មា ព្រហ្មចរិយវាសោ បញ្ញាយតិ សម្មាទុក្ខក្ខយាយ ។ ឯត្តកាបិ ខោ ភិក្ខុ វេទនា នត្ថិ និច្ចា ធុវា សស្សតា អវិបរិណាមធម្មា សស្សតិសមំ តថេវ ឋស្សតិ ។ ឯត្តកាបិ ចេ ភិក្ខុ វេទនា អភវិស្ស និច្ចា ធុវា សស្សតា អវិបរិណាមធម្មា ន យិទំ ព្រហ្មចរិយវាសោ បញ្ញាយេថ សម្មាទុក្ខក្ខយាយ ។ យស្មា ច ខោ ភិក្ខុ ឯត្តកាបិ វេទនា នត្ថិ និច្ចា ធុវា សស្សតា អវិបរិណាមធម្មា តស្មា ព្រហ្មចរិយវាសោ បញ្ញាយតិ សម្មាទុក្ខក្ខយាយ ។ ឯត្តកាបិ ខោ ភិក្ខុ សញ្ញា ។ បេ ។ ឯត្តកាបិ ខោ ភិក្ខុ សង្ខារា នត្ថិ និច្ចា ធុវា

ប្រាកដដើម្បីអស់ទៅនៃទុក្ខ ដោយប្រពៃឡើយ ។ ម្នាលភិក្ខុ ព្រោះរូប ប៉ុណ្ណោះជារបស់ទៀងទាត់ ឋិតថេរ មិនប្រែប្រួលទៅជាធម្មតា មិនមាន បានជាការអប់រំព្រហ្មចរិយៈ ប្រាកដដើម្បីអស់ទៅនៃទុក្ខ ដោយប្រពៃ បាន ។ ម្នាលភិក្ខុ វេទនាណា ដែលទៀងទាត់ ឋិតថេរ មិនប្រែប្រួល ជាធម្មតា ឋិតនៅនឹងដដែល ស្មើដោយសស្សតិវត្ថុ វេទនានោះសូម្បី ប៉ុនអាចម៍ដីនេះ មិនមានទេ ។ ម្នាលភិក្ខុ ប្រសិនបើវេទនាប៉ុណ្ណោះ ជារបស់ទៀងទាត់ ឋិតថេរ មិនប្រែប្រួលទៅជាធម្មតា នឹងមានហើយ ការអប់រំព្រហ្មចរិយៈនេះ មិនប្រាកដដើម្បីអស់ទៅនៃទុក្ខ ដោយប្រពៃ ឡើយ ។ ម្នាលភិក្ខុ ព្រោះវេទនាប៉ុណ្ណោះជារបស់ទៀងទាត់ ឋិតថេរ មិន ប្រែប្រួលទៅជាធម្មតា មិនមាន បានជាការអប់រំព្រហ្មចរិយៈ ប្រាកដ ដើម្បីអស់ទៅនៃទុក្ខ ដោយប្រពៃបាន ។ ម្នាលភិក្ខុ សញ្ញានោះ សូម្បីប៉ុនអាចម៍ដីនេះ ។បេ។ ម្នាលភិក្ខុ សង្ខារណា ដែលទៀងទាត់

សស្សតា អវិបរិណាមធម្មា សស្សតិសមំ តថេវ ឋស្សន្តិ ។ ឯត្តកា ចេបិ ភិក្ខុ សង្ខារា អភវិស្សំសុ និច្ចា ធុវា សស្សតា អវិបរិណាមធម្មា ន យិទំ ព្រហ្មចរិយវាសោ បញ្ញាយេថ សម្មាទុក្ខក្ខយាយ ។ យស្មា ច ខោ ភិក្ខុ ឯត្តកាបិ សង្ខារា នត្ថិ និច្ចា ធុវា សស្សតា អវិបរិណាមធម្មា តស្មា ព្រហ្មចរិយវាសោ បញ្ញាយតិ សម្មាទុក្ខក្ខយាយ ។ ឯត្តកំបិ ខោ ភិក្ខុ វិញ្ញាណំ នត្ថិ និច្ចំ ធុវំ សស្សតំ អវិបរិណាមធម្មំ សស្សតិសមំ តថេវ ឋស្សតិ ។ ឯត្តកំ ចេបិ ភិក្ខុ វិញ្ញាណំ អភវិស្ស និច្ចំ ធុវំ សស្សតំ អវិបរិណាមធម្មំ ន យិទំ ព្រហ្មចរិយវាសោ បញ្ញាយេថ សម្មាទុក្ខក្ខយាយ ។ យស្មា ច ខោ ភិក្ខុ ឯត្តកំបិ វិញ្ញាណំ នត្ថិ និច្ចំ ធុវំ សស្សតំ អវិបរិណាមធម្មំ តស្មា ព្រហ្មចរិយវាសោ បញ្ញាយតិ សម្មាទុក្ខក្ខយាយ ។

ឋិតថេរ មិនប្រែប្រួលជាធម្មតា ឋិតនៅនឹងដដែល ស្មើដោយសស្សតិវត្ថុ សង្ខារនោះ សូម្បីប៉ុនអាចម៍ដីនេះ មិនមានឡើយ ៗ ម្នាលភិក្ខុ ប្រសិនបើសង្ខារប៉ុណ្ណោះជារបស់ទៀងទាត់ ឋិតថេរ មិនប្រែប្រួលជាធម្មតា នឹងមានហើយ ការអប់រំព្រហ្មចរិយៈនេះ មិនប្រាកដដើម្បីអស់ទៅនៃទុក្ខដោយប្រពៃឡើយ ៗ ម្នាលភិក្ខុ ព្រោះសង្ខារប៉ុណ្ណោះជារបស់ទៀងទាត់ ឋិតថេរ មិនប្រែប្រួលជាធម្មតា មិនមាន បានជាការអប់រំព្រហ្មចរិយៈ តែងប្រាកដដើម្បីអស់ទៅនៃទុក្ខ ដោយប្រពៃបាន ៗ ម្នាលភិក្ខុ វិញ្ញាណណា ដែលទៀងទាត់ ឋិតថេរ មិនប្រែប្រួលជាធម្មតា ឋិតនៅនឹងដដែល ស្មើដោយសស្សតិវត្ថុ វិញ្ញាណនោះ សូម្បីប៉ុនអាចម៍ដីនេះ មិនមានឡើយ ៗ ម្នាលភិក្ខុ ប្រសិនបើវិញ្ញាណប៉ុណ្ណោះ ជារបស់ទៀងទាត់ ឋិតថេរ មិនប្រែប្រួលទៅជាធម្មតា នឹងមានហើយ ការអប់រំព្រហ្មចរិយៈនេះ មិនប្រាកដដើម្បីអស់ទៅនៃទុក្ខដោយប្រពៃបានឡើយ ៗ ម្នាលភិក្ខុ ព្រោះវិញ្ញាណប៉ុណ្ណោះ ជារបស់ទៀងទាត់ ឋិតថេរ មិនប្រែប្រួលជាធម្មតា មិនមាន បានជាការអប់រំព្រហ្មចរិយៈ តែងប្រាកដដើម្បីអស់ទៅនៃទុក្ខដោយប្រពៃបាន ៗ

(២៥៤) តំ កឹ មញ្ញសិ ភិក្ខុ រូបំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ វេទនា ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ បេ ។ តស្មាតិហ ។ បេ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

(២៥៥) សាវត្ថិយំ ។ អារាមេ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច អត្ថិ នុ ខោ ភន្តេ កិញ្ចិ រូបំ យំ រូបំ និច្ចំ ធុវំ សស្សតំ អវិបរិណាមធម្មំ សស្សតិសមំ តថេវ ឋស្សតិ ។ អត្ថិ នុ ខោ ភន្តេ កាចិ វេទនា ។ កាចិ សញ្ញា ។ កេចិ សង្ខារា ។ កិញ្ចិ វិញ្ញាណំ យំ វិញ្ញាណំ និច្ចំ ធុវំ សស្សតំ អវិបរិណាមធម្មំ សស្សតិសមំ តថេវ ឋស្សតីតិ ។ នត្ថិ ខោ ភិក្ខុ កិញ្ចិ រូបំ យំ រូបំ និច្ចំ ធុវំ សស្សតំ អវិបរិណាមធម្មំ សស្សតិសមំ តថេវ ឋស្សតិ ។

[២៤៤] ម្នាលភិក្ខុ អ្នកសំគាល់សេចក្តីនោះដូចម្តេច រូបទៀង ឬ មិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ វេទនា ។ សញ្ញា ។ សង្ខារ ។ វិញ្ញាណទៀង ឬ មិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ បេ ។ ព្រោះហេតុនោះ គប្បីសាសនានេះ ។ បេ ។ កាលបើអរិយសាវកឃើញយ៉ាងនេះ ។ បេ ។ រមែងដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

[២៤៥] ជិតគ្រង់សាវត្ថី ។ គប្បីវត្ត ។ លុះភិក្ខុនោះអង្គុយគប្បីទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន រូបណា ដែលទៀងទាត់ ឋិតថេរ មិនប្រែប្រួលជាធម្មតា ឋិតនៅនឹងដដែល ស្មើដោយសស្សតិវត្ថុ រូបនោះ បន្តិចបន្តួច មានដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន វេទនាបន្តិចបន្តួចមានដែរឬ ។ សញ្ញាបន្តិចបន្តួច ។ សង្ខារបន្តិចបន្តួច ។ វិញ្ញាណណា ដែលទៀងទាត់ ឋិតថេរ មិនប្រែប្រួលជាធម្មតា ឋិតនៅនឹងដដែល ស្មើដោយសស្សតិវត្ថុ វិញ្ញាណនោះ បន្តិចបន្តួចមានដែរឬ ។ ម្នាលភិក្ខុ រូបណា ដែលទៀងទាត់ ឋិតថេរ មិនប្រែប្រួលជាធម្មតា ឋិតនៅនឹងដដែល ស្មើដោយសស្សតិវត្ថុ រូបនោះ បន្តិចបន្តួចមិនមានទេ ។

នត្ថិ ខោ ភិក្ខុ កាចិ វេទនា ។ កាចិ សញ្ញា ។ កេចិ សង្ខារា ។ កិញ្ចិ វិញ្ញាណំ យំ វិញ្ញាណំ និច្ចំ ធុវំ សស្សតំ អវិបរិណាមធម្មំ សស្សតិសមំ តថេវ ឋស្សតីតិ ។

(៤៦៦) សាវត្ថិយំ ។ អាភមេ ។ អនមតគ្គោយំ ភិក្ខវេ សំសារោ បុព្វា កោដិ ន បញ្ញាយតិ អវិជ្ជានីវរណានំ សត្តានំ តណ្ហាសញ្ញោជនានំ សន្ធាវតំ សំសរតំ ។ ហោតិ សោ ភិក្ខវេ សមយោ យំ មហាសមុទ្ទោ ឧស្សុស្សតិ វិសុស្សតិ ន ភវតិ ។ ន ត្វេវាហំ ភិក្ខវេ អវិជ្ជានីវរណានំ សត្តានំ តណ្ហាសញ្ញោជនានំ សន្ធាវតំ សំសរតំ ទុក្ខស្ស អន្តកិរិយំ វទាមិ ។ ហោតិ សោ ភិក្ខវេ សមយោ យំ សិនេរុ បព្វតរាជា

ម្នាលភិក្ខុ វេទនាបដិច្ចបច្ចយមិនមានទេ ។ សញ្ញាបដិច្ចបច្ចយ ។ សង្ខារបដិច្ចបច្ចយ ។ វិញ្ញាណណា ដែលទៀងទាត់ ឋិតថេរ មិនប្រែប្រួលជាធម្មតា ឋិតនៅនឹងដដែល ស្មើដោយសស្សតវត្ថុ វិញ្ញាណនោះបដិច្ចបច្ចយ (មិនមានទេ) ។

[២៤៦] ជិតក្រុងសាវត្ថី ។ កន្លវគ្គ ។ ម្នាលភិក្ខុទាំងឡាយ សង្សារនេះ មានទីបំផុតគេមិនអាចដឹងបាន គឺទីបំផុតខាងដើម របស់សត្វទាំងឡាយ ដែលមានអវិជ្ជាជាគ្រឿងបិទបាំង មានតណ្ហាជាចំណងអន្ទោលទៅ ត្រាច់រង្គាត់ទៅ មិនប្រាកដឡើយ ។ ម្នាលភិក្ខុទាំងឡាយ មានសម័យដែលត្រូវមហាសមុទ្ររីងស្ងួត មិនមានសល់នៅ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលមានអវិជ្ជាជាគ្រឿងបិទបាំង មានតណ្ហាជាចំណង អន្ទោលទៅ ត្រាច់រង្គាត់ទៅ តថាគតមិនពោលថាធ្វើនូវទីបំផុតនៃទុក្ខបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ មានសម័យដែលស្ដេចភ្នំ

ឧឌ្ឌយ្ហតិ វិនស្សតិ ន ភវតិ ។ ន ត្វេវាហំ ភិក្ខវេ អវិជ្ជានីវរណានំ សត្តានំ តណ្ហាសញ្ញោជនានំ សន្ធាវតំ សំសរតំ ទុក្ខស្ស អន្តកិរិយំ វទាមិ ។ ហោតិ សោ ភិក្ខវេ សមយោ យំ មហាបថវី ឧឌ្ឌយ្ហតិ វិនស្សតិ ន ភវតិ ។ ន ត្វេវាហំ ភិក្ខវេ អវិជ្ជានីវរណានំ សត្តានំ តណ្ហាសញ្ញោជនានំ សន្ធាវតំ សំសរតំ ទុក្ខស្ស អន្តកិរិយំ វទាមិ ។

[២៨៧] សេយ្យថាបិ ភិក្ខវេ សា គទ្ទុលពទ្ធោ(១) ទឡ្ហេ ខីលេ វា ថម្ភេ វា ឧបនិពទ្ធោ តមេវ ខីលំ វា ថម្ភំ វា អនុបរិធាវតិ អនុបរិវត្តតិ ។ ឯវមេវ ខោ ភិក្ខវេ អស្សុតវា បុថុជ្ជនោ អរិយានំ អទស្សាវី ។ បេ ។ សប្បុរិសធម្មេ អវិនីតោ រូបំ អត្តតោ សមនុបស្សតិ ។ បេ ។ វេទនំ អត្តតោ សមនុបស្សតិ ។ សញ្ញំ ។ សង្ខារេ អត្តតោ សមនុបស្សតិ ។ វិញ្ញាណំ អត្តតោ សមនុបស្សតិ វិញ្ញាណវន្តំ វា អត្តានំ អត្តនិ វា វិញ្ញាណំ

១ ឱ. គទ្ទូលពទ្ធោ ។

ឈ្មោះសិនេរុ ត្រូវភ្លើងឆេះវិនាសទៅ មិនមានសល់នៅ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលមានអវិជ្ជាជាគ្រឿងបិទបាំង មានតណ្ហាជាចំណង អន្ទោលទៅ ត្រាច់រង្គាត់ទៅ តថាគតមិនពោលថាធ្វើនូវទីបំផុតនៃទុក្ខបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ មានសម័យដែលមហាប្រឹថពីត្រូវភ្លើងឆេះវិនាសទៅ មិនមានសល់នៅ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលមានអវិជ្ជាជាគ្រឿងបិទបាំង មានតណ្ហាជាចំណង អន្ទោលទៅ ត្រាច់រង្គាត់ទៅ តថាគតមិនពោលថាធ្វើនូវទីបំផុតនៃទុក្ខបានឡើយ ។

[២៤៧] ម្នាលភិក្ខុទាំងឡាយ ដូចជាឆ្កែដែលគេចង ដោយដងដោយ ចងភ្ជាប់នឹងបង្គោលឬសសរដ៏មាំ រមែងស្ទុះក្រឡឹង ដើរក្រឡឹងបង្គោលឬសសរនោះឯង យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនជាអ្នកមិនចេះដឹង មិនឃើញពួកព្រះអរិយៈ ។ បេ ។ មិនបានសិក្សាក្នុងសប្បុរិសធម៌ រមែងពិចារណាឃើញនូវរូប ថាជាខ្លួន ។ បេ ។ ពិចារណាឃើញនូវវេទនា ថាជាខ្លួន ។ នូវសញ្ញា ។ ពិចារណាឃើញនូវសង្ខារថាជាខ្លួន ។ ពិចារណាឃើញនូវវិញ្ញាណ ថាជាខ្លួន ឃើញនូវខ្លួន ថាមានវិញ្ញាណខ្លះ ឃើញនូវវិញ្ញាណថាមានក្នុងខ្លួនខ្លះ

វិញ្ញាណស្មឹ វា អត្តានំ ។ សោ រូបញ្ញេវ អនុបរិធាវតិ អនុបរិវត្តតិ ។ វេទនញ្ញេវ ។ សញ្ញញ្ញេវ ។ សង្ខារេយេវ ។ វិញ្ញាណញ្ញេវ អនុបរិធាវតិ អនុបរិវត្តតិ ។ សោ រូបំ អនុបរិធាវំ អនុបរិវត្តំ ។ វេទនំ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ អនុបរិធាវំ អនុបរិវត្តំ ន បរិមុច្ចតិ រូបម្ហា ន បរិមុច្ចតិ វេទនាយ ន បរិមុច្ចតិ សញ្ញាយ ន បរិមុច្ចតិ សង្ខារេហិ ន បរិមុច្ចតិ វិញ្ញាណម្ហា ន បរិមុច្ចតិ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ ន បរិមុច្ចតិ ទុក្ខស្មាតិ វទាមិ ។ សុតវា ច ខោ ភិក្ខវេ អរិយសាវកោ អរិយានំ ទស្សាវី ។ បេ ។ សប្បុរិសធម្មេ សុវិនីតោ ន រូបំ អត្តតោ សមនុបស្សតិ ។ ន វេទនំ ។ ន សញ្ញំ ។ ន សង្ខារេ ។ ន វិញ្ញាណំ អត្តតោ សមនុបស្សតិ ន វិញ្ញាណវន្តំ វា អត្តានំ ន អត្តនិ វា វិញ្ញាណំ ន វិញ្ញាណស្មឹ វា អត្តានំ ។ សោ រូបំ នានុបរិធាវតិ នានុបរិវត្តតិ ។ វេទនំ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ នានុបរិធាវតិ នានុបរិវត្តតិ ។ សោ រូបំ អននុបរិធាវំ

ឃើញនូវខន្ធថាមានក្នុងវិញ្ញាណខ្លះ ។ បុថុជ្ជននោះ រមែងស្ទុះក្រឡឹង ដើរក្រឡឹងនូវរូបដដែល ៗ ។ នូវវេទនាដដែល ៗ ។ នូវសញ្ញាដដែល ៗ ។ នូវសង្ខារដដែល ៗ ។ រមែងស្ទុះក្រឡឹង ដើរក្រឡឹង នូវវិញ្ញាណដដែល ៗ ។ កាលដែលបុថុជ្ជននោះ ស្ទុះក្រឡឹង ដើរក្រឡឹងនូវរូប ។ នូវវេទនា ។ នូវសញ្ញា ។ នូវសង្ខារ ។ ស្ទុះក្រឡឹង ដើរក្រឡឹង នូវវិញ្ញាណ តថាគតពោលថាមិនរួចចាករូប មិនរួចចាកវេទនា មិនរួចចាកសញ្ញា មិនរួចចាកសង្ខារ មិនរួចចាកវិញ្ញាណ មិនរួចចាកជាតិ ជរមរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ លំបាកចិត្ត និងសេចក្តីចង្អៀតចង្អល់ចិត្តទាំងឡាយ មិនរួចចាកទុក្ខឡើយ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកខាងអរិយសាវកជាអ្នកចេះដឹង ឃើញពួកព្រះអរិយៈ ។ បេ ។ បានសិក្សាដោយប្រពៃ ក្នុងសប្បុរិសធម៌ រមែងមិនពិចារណាឃើញនូវរូប ថាជាខ្លួន ។ មិនឃើញនូវវេទនា ។ មិនឃើញនូវសញ្ញា ។ មិនឃើញនូវសង្ខារ ។ មិនឃើញនូវវិញ្ញាណថាជាខ្លួន នូវខ្លួនថាមានវិញ្ញាណខ្លះ នូវវិញ្ញាណថាមានក្នុងខ្លួនខ្លះ នូវខ្លួនថាមានក្នុងវិញ្ញាណខ្លះ ។ អរិយសាវកនោះ រមែងមិនស្ទុះក្រឡឹង មិនដើរក្រឡឹងនូវរូប ។ នូវវេទនា ។ នូវសញ្ញា ។ នូវសង្ខារ ។ មិនស្ទុះក្រឡឹង មិនដើរក្រឡឹង នូវវិញ្ញាណ ។ កាលដែលអរិយសាវកនោះ មិនស្ទុះក្រឡឹង

អនុបរិវត្តំ ។ វេទនំ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ អនុបរិធាវំ អនុបរិវត្តំ បរិមុច្ចតិ រូបម្ហា បរិមុច្ចតិ វេទនាយ បរិមុច្ចតិ សញ្ញាយ បរិមុច្ចតិ សង្ខារេហិ បរិមុច្ចតិ វិញ្ញាណម្ហា បរិមុច្ចតិ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ បរិមុច្ចតិ ទុក្ខស្មាតិ វទាមិ ។

[២៤៨] សាវត្ថិយំ ។ អារាមេ ។ អនមតគ្គាយំ ភិក្ខវេ សំសារោ បុព្វា កោដិ ន បញ្ញាយតិ អវិជ្ជានីវរណានំ សត្តានំ តណ្ហាសញ្ញោជនានំ សន្ធាវតំ សំសរតំ ។ សេយ្យថាបិ ភិក្ខវេ សា គទ្ទុលពទ្ធោ ទឡ្ហេ ខីលេ វា ថម្ភេ វា ឧបនិពទ្ធោ សោ គច្ឆតិ ចេបិ តមេវ ខីលំ វា ថម្ភំ វា ឧបគច្ឆតិ តិដ្ឋតិ ចេបិ តមេវ ខីលំ វា ថម្ភំ វា ឧបតិដ្ឋតិ និសីទតិ ចេបិ តមេវ ខីលំ វា ថម្ភំ វា ឧបនិសីទតិ និបជ្ជតិ ចេបិ តមេវ ខីលំ វា ថម្ភំ វា ឧបនិបជ្ជតិ ។ ឯវមេវ ខោ ភិក្ខវេ អស្សុតវា បុថុជ្ជនោ រូបំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ សមនុបស្សតិ ។

មិនដើរក្រឡឹងនូវរូប ។ នូវវេទនា ។ នូវសញ្ញា ។ នូវសង្ខារ ។ មិនសុះក្រឡឹង មិនដើរក្រឡឹងនូវវិញ្ញាណ តថាគតពោលថា រួចចាករូប រួចចាកវេទនា រួចចាកសញ្ញា រួចចាកសង្ខារ រួចចាកវិញ្ញាណ រួចចាកជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ លំបាកចិត្ត និងសេចក្តីចង្អៀតចង្អល់ចិត្តទាំងឡាយ រួចចាកទុក្ខបាន ។

(២៥៨) ជិតក្រុងសាវត្ថី ។ ក្ទុងវគ្គ ។ ម្នាលភិក្ខុទាំងឡាយ សង្សារនេះ មានទីបំផុតគេមិនអាចដឹងបាន គឺទីបំផុតខាងដើម របស់សត្វទាំងឡាយ ដែលមានអវិជ្ជាជាគ្រឿងបិទបាំង មានតណ្ហាជាចំណង អន្ទោលទៅ ត្រាច់រង្គាត់ទៅ មិនប្រាកដឡើយ ។ ម្នាលភិក្ខុទាំង-ឡាយ ដូចជាឆ្កែដែលគេចងដោយដងដោយ ចងភ្ជាប់នឹងបង្គោលឬសសរដ៏មាំ ប្រសិនបើឆ្កែនោះដើរទៅ រមែងដើរជិតបង្គោលឬសសរនោះឯងដែល ប្រសិនបើឈរ រមែងឈរជិតបង្គោលឬសសរនោះឯងដែល ប្រសិនបើអង្គុយ រមែងអង្គុយជិតបង្គោលឬសសរនោះឯងដែល ប្រសិនបើដេក រមែងដេកជិតបង្គោលឬសសរនោះឯងដែល យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនចេះដឹង រមែងពិចារណាឃើញនូវរូបថា នុ៎ះជារបស់អាត្មាអញ នុ៎ះជាអាត្មាអញ នុ៎ះជាខ្លួនរបស់អាត្មាអញ ។

វេទនំ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ ឯតំ មម ឯសោ-
ហមស្មិ ឯសោ មេ អត្តាតិ សមនុបស្សតិ ។ សោ គច្ឆតិ
ចេបិ ឥមេវ បញ្ចុបាទានក្ខន្ធេ ឧបគច្ឆតិ តិដ្ឋតិ ចេបិ
ឥមេវ បញ្ចុបាទានក្ខន្ធេ ឧបតិដ្ឋតិ និសីទតិ ចេបិ ឥ-
មេវ បញ្ចុបាទានក្ខន្ធេ ឧបនិសីទតិ និបជ្ជតិ ចេបិ ឥមេវ
បញ្ចុបាទានក្ខន្ធេ ឧបនិបជ្ជតិ ។ តស្មាតិហ ភិក្ខវេ
អភិក្ខណំ សកំ ចិត្តំ បច្ចវេក្ខិតព្វំ ទីឃរត្តមិទំ ចិត្តំ
សង្កិលិដ្ឋំ រាគេន ទោសេន មោហេនាតិ ។

[២៥៩] ចិត្តសង្កិលេសា ភិក្ខវេ សត្តា សង្កិ-
លិស្សន្តិ ចិត្តវោទានា សត្តា វិសុជ្ឈន្តិ ។ ទិដ្ឋំ វោ
ភិក្ខវេ ចរណំ នាម ចិត្តន្តិ ។ ឯវម្ភន្តេ ។ តម្បិ ខោ
ភិក្ខវេ ចរណំ នាម ចិត្តំ ចិត្តេនេវ ចិន្តិតំ ។ តេនបិ
ខោ ភិក្ខវេ ចរណេន ចិត្តេន ចិត្តញ្ញេវ ចិត្តតរំ ។

នូវវេទនា ។ នូវសញ្ញា ។ នូវសង្ខារ ។ ពិចារណាឃើញនូវវិញ្ញាណថា នុ៎ះជារបស់អាត្មាអញ នុ៎ះជាអាត្មាអញ នុ៎ះជាខ្លួនរបស់អាត្មាអញ ។ ប្រសិនបើបុគ្គលនោះដើរទៅ រមែងដើរទៅជិតឧបាទានក្ខន្ធទាំង ៥ នេះដដែល ប្រសិនបើឈរ រមែងឈរជិតឧបាទានក្ខន្ធទាំង៥ នេះដដែល ប្រសិនបើអង្គុយ រមែងអង្គុយជិតឧបាទានក្ខន្ធទាំង៥ នេះដដែល ប្រសិនបើដេក រមែងដេកជិតឧបាទានក្ខន្ធទាំង៥ នេះដដែល ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ បុគ្គលក្នុងលោកនេះ គួរពិចារណានូវចិត្តរបស់ខ្លួនឲ្យរឿយៗ ថា ចិត្តនេះសៅហ្មងដោយរាគៈ ទោសៈ មោហៈ អស់កាលជាអង្វែង ។

(២៥៩) ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលមានធម៌ជាគ្រឿងសៅហ្មងនៃចិត្ត រមែងជ្រោកជ្រាក ពួកសត្វដែលមានធម៌ជាគ្រឿងផូរផង់នៃចិត្ត រមែងបរិសុទ្ធ ។ ម្នាលភិក្ខុទាំងឡាយ រូបគំនូរ អ្នកទាំងឡាយបានឃើញហើយឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ រូបគំនូរនោះ គេរចនាដោយការវិចិត្រជាប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ ចិត្តនេះឯង វិចិត្រដោយវិសេសជាងរូបគំនូរដែលគេរចនា ។

តស្មាតិហ ភិក្ខវេ អភិក្ខណំ សកំ ចិត្តំ បច្ចវេក្ខិតព្វំ ទីឃរត្តមិទំ ចិត្តំ សង្កិលិដ្ឋំ រាគេន ទោសេន មោហេនាតិ ។ ចិត្តសង្កិលេសា ភិក្ខវេ សត្តា សង្កិលិស្សន្តិ ចិត្តវោទានា សត្តា វិសុជ្ឈន្តិ ។ នាហំ ភិក្ខវេ អញ្ញំ ឯកនិកាយម្បិ សមនុបស្សាមិ ឯវំ ចិត្តំ យថយិទំ ភិក្ខវេ តិរច្ឆានគតា បាណា ។ តេបិ ខោ ភិក្ខវេ តិរច្ឆានគតា បាណា ចិត្តេនេវ ចិន្តិតា ។ តេហិបិ ខោ ភិក្ខវេ តិរច្ឆានគតេហិ បាណេហិ ចិត្តញ្ញេវ ចិត្តតរំ ។ តស្មាតិហ ភិក្ខវេ អភិក្ខណំ(១) សកំ ចិត្តំ បច្ចវេក្ខិតព្វំ ទីឃរត្តមិទំ ចិត្តំ សង្កិលិដ្ឋំ រាគេន ទោសេន មោហេនាតិ ។ ចិត្តសង្កិលេសា ភិក្ខវេ សត្តា សង្កិលិស្សន្តិ ចិត្តវោទានា សត្តា វិសុជ្ឈន្តិ ។ សេយ្យថាបិ ភិក្ខវេ រជកោ វា ចិត្តការកោ វា សតិ រជនាយ វា លាខាយ វា ហលិទ្ទិយា វា

១ ឱ. ភិក្ខុនា អភិក្ខណំ ។

ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ បុគ្គលគប្បីពិចារណានូវចិត្តរបស់ខ្លួនឲ្យរឿយ ៗ ថា ចិត្តនេះសៅហ្មងហើយ ដោយរាគៈ ទោសៈ មោហៈ អស់កាលជាអង្វែង ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលមានធម៌ជាគ្រឿងសៅហ្មងនៃចិត្ត រមែងជ្រោកជ្រាក ពួកសត្វដែលមានធម៌ជាគ្រឿងផូរផង់នៃចិត្ត រមែងបរិសុទ្ធ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វតិរច្ឆាននេះ ដ៏វិចិត្រ យ៉ាងណា ចិត្តណាដែលវិចិត្រ យ៉ាងនោះ ម្នាលភិក្ខុទាំងឡាយ តថាគតមិនដែលឃើញ សូម្បីនូវពួកធម៌មួយ ដទៃអំពីចិត្តនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ សត្វតិរច្ឆានទាំងនោះឯង គេនឹកគិតដោយចិត្តដូចគ្នា ។ ម្នាលភិក្ខុទាំងឡាយ ចិត្តនេះឯង វិចិត្រដោយវិសេសជាងពួកសត្វតិរច្ឆាននោះ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ បុគ្គលគប្បីពិចារណានូវចិត្តរបស់ខ្លួនឲ្យរឿយ ៗ ថា ចិត្តនេះសៅហ្មងដោយរាគៈ ទោសៈ មោហៈ អស់កាលជាអង្វែង ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលមានធម៌ជាគ្រឿងសៅហ្មងនៃចិត្ត រមែងជ្រោកជ្រាក ពួកសត្វដែលមានធម៌ជាគ្រឿងផូរផង់នៃចិត្ត រមែងបរិសុទ្ធ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាជាងជ្រលក់ក្តី ជាងគំនូរក្តី កាលបើទឹកជ្រលក់ក្តី ទឹកល័ក្តក្តី ទឹករមៀតក្តី

នីលាយ វា មញ្ជេដ្ឋាយ វា សុបរិមដ្ឋេ(១) វា ផល-
កេ ភិត្តិយា វា ទុស្សបដ្ដេ(២) វា ឥត្ថីរូបំ វា បុរិសរូបំ
វា(៣) អភិនិម្មិនេយ្យ សព្វង្គបច្ចង្គី ។ ឯវំ ខោ ភិក្ខវេ
អស្សុតវា បុថុជ្ជនោ រូបញ្ញេវ អភិនិព្វត្តេន្តោ អភិនិព្វ-
ត្តេតិ ។ វេទនញ្ញេវ ។ សញ្ញញ្ញេវ ។ សង្ខារេយេវ ។
វិញ្ញាណញ្ញេវ អភិនិព្វត្តេន្តោ អភិនិព្វត្តេតិ ។ តំ កឹ
មញ្ញថ ភិក្ខវេ រូបំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ
ភន្តេ ។ វេទនា ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ និច្ចំ វា
អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ តស្មាតិហ ភិក្ខវេ ។ បេ ។
ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

១ ឱ. ម. សុបរិមដ្ឋេ ។ ២ ទុស្សវដ្ដេតិ វា បាឋោ ។ ៣ ម. ឯត្តន្តរេ កោបីតិ ទិស្សតិ ។

ទឹកមានពណ៌ខៀវក្តី ពណ៌ហង្សបាទក្តី ផែនក្តារដែលគេខាត់ល្អហើយក្តី ជញ្ជាំងក្តី ផ្ទាំងសំពត់ក្តី មានហើយ គប្បីគាក់តែងនូវរូបស្ត្រីឬរូបបុរស មានអវយវៈតូចនិងអវយវៈធំសព្វគ្រប់បាន យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនជាអ្នកមិនចេះដឹង កាលបើចង់ឲ្យរូបកើត រមែងញុំាងរូបឲ្យកើតឡើងបាន ។ ញុំាងវេទនា ។ ញុំាងសញ្ញា ។ ញុំាងសង្ខារ ។ កាលបើចង់ឲ្យវិញ្ញាណកើត រមែងញុំាងវិញ្ញាណឲ្យកើតឡើងបាន ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់សេចក្តីនោះដូចម្តេច រូបទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ វេទនា ។ សញ្ញា ។ សង្ខារ ។ វិញ្ញាណទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងសាសនានេះ ។បេ។ អរិយសាវ័កកាលបើឃើញយ៉ាងនេះ ។បេ។ រមែងដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

[២៦០] សាវត្ថិយំ ។ ជានតោហំ ភិក្ខវេ បស្សតោ អាសវានំ ខយំ វទាមិ នោ អជានតោ នោ អបស្សតោ ។ កិញ្ច ភិក្ខវេ ជានតោ កឹ បស្សតោ អាសវានំ ខយោ ហោតិ ។ ឥតិ រូបំ ឥតិ រូបស្ស សមុទយោ ឥតិ រូបស្ស អត្ថង្គមោ ។ ឥតិ វេទនា ។ ឥតិ សញ្ញា ។ ឥតិ សង្ខារា ។ ឥតិ វិញ្ញាណំ ឥតិ វិញ្ញាណស្ស សមុទយោ ឥតិ វិញ្ញាណស្ស អត្ថង្គមោតិ ។ ឯវំ ខោ ភិក្ខវេ ជានតោ ឯវំ បស្សតោ អាសវានំ ខយោ ហោតិ ។

[២៦១] ភាវនានុយោគំ អននុយុត្តស្ស ភិក្ខវេ ភិក្ខុនោ វិហរតោ កិញ្ចាបិ ឯវំ ឥច្ឆា ឧប្បជ្ជេយ្យ អហោ វត មេ អនុបាទាយ អាសវេហិ ចិត្តំ វិមុច្ចេយ្យាតិ អថខ្វស្ស នេវ អនុបាទាយ អាសវេហិ ចិត្តំ វិមុច្ចតិ ។ តំ កិស្ស ហេតុ ។ អភាវិតត្តាតិស្ស វចនីយំ ។ កិស្ស អភាវិតត្តា ។ អភាវិតត្តា ចតុន្នំ សតិបដ្ឋានានំ អភាវិតត្តា ចតុន្នំ សម្មប្បធានានំ

[២៦០] ដំណើរនោះក្រៀមចូរ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវកិរិយាអស់ទៅនៃអាសវៈ ចំពោះបុគ្គលដែលដឹងច្បាស់ ឃើញច្បាស់ មិនពោលចំពោះបុគ្គលដែលមិនដឹងច្បាស់ មិនឃើញច្បាស់ឡើយ ។ ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈ រមែងមានដល់បុគ្គលដែលដឹងអ្វី ឃើញអ្វី ។ (ដល់បុគ្គលដឹងឃើញ) ថារូបដូច្នេះ ហេតុឲ្យកើតឡើងនៃរូបដូច្នេះ សេចក្ដីអស់ទៅនៃរូបដូច្នេះ ។ វេទនាដូច្នេះ ។ សញ្ញាដូច្នេះ ។ សង្ខារដូច្នេះ ។ វិញ្ញាណដូច្នេះ ហេតុឲ្យកើតឡើងនៃវិញ្ញាណដូច្នេះ សេចក្ដីអស់ទៅនៃវិញ្ញាណដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈ រមែងមានដល់បុគ្គលដែលដឹងយ៉ាងនេះ ឃើញយ៉ាងនេះឯង ។

[២៦១] ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលមិនប្រកបរឿយ ៗ នូវការនានុយោគ ទុកជាមានសេចក្ដីប្រាថ្នា កើតឡើងយ៉ាងនេះថា ឱហ្ន៎ ចិត្តរបស់អាត្មាអញគប្បីរួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនបានប្រកាន់មាំដោយ ចិត្តរបស់ភិក្ខុនោះក៏នៅតែមិនរួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនបានប្រកាន់មាំឡើយ ។ សេចក្ដីនោះ ព្រោះហេតុដូចម្ដេច ។ គប្បីឆ្លើយថា ព្រោះភិក្ខុនោះមិនបានចម្រើន ។ មិនបានចម្រើនអ្វី ។ មិនបានចម្រើនសតិប្បដ្ឋានទាំង ៤ មិនបានចម្រើនសម្មប្បធានទាំង ៤

អភាវិតត្តា ចតុន្នំ ឥទ្ធិបាទានំ អភាវិតត្តា បញ្ចន្នំ ឥន្ទ្រិយានំ អភាវិតត្តា បញ្ចន្នំ ពលានំ អភាវិតត្តា សត្តន្នំ ពោជ្ឈង្គានំ អភាវិតត្តា អរិយស្ស អដ្ឋង្គិកស្ស មគ្គស្ស ។ សេយ្យថាបិ ភិក្ខវេ កុក្កុដិយា អណ្ឌានិ អដ្ឋ វា ទស វា ទ្វាទស វា តានស្សុ កុក្កុដិយា ន សម្មាអភិសយិតានិ ន សម្មាបរិសេទិតានិ ន សម្មាបរិភាវិតានិ កិញ្ចាបិ តស្សា កុក្កុដិយា ឯវំ ឥច្ឆា ឧប្បជ្ជេយ្យ អហោ វត មេ កុក្កុដបោតកា បាទនខសិខាយ វា មុខតុណ្ឌកេន វា អណ្ឌកោសំ បទាលេត្វា សោត្ថិនា អភិនិព្ភិជ្ជេយ្យុន្តិ អថខោ អភព្វាវ តេ កុក្កុដបោតកា បាទនខសិខាយ វា មុខតុណ្ឌកេន វា អណ្ឌកោសំ បទាលេត្វា សោត្ថិនា អភិនិព្ភិជ្ជិតុំ ។ តំ កិស្ស ហេតុ ។ តថា ហិ បន ភិក្ខវេ កុក្កុដិយា អណ្ឌានិ អដ្ឋ វា ទស វា ទ្វាទស វា តានស្សុ(១) កុក្កុដិយា ន សម្មាអភិសយិតានិ ន សម្មាបរិសេទិតានិ ន សម្មាបរិភាវិតានិ ។

---

១ ឱ. ម. តានិ កុក្កុដិយា ។

មិនបានចម្រើនឥទ្ធិបាទទាំង ៤ មិនបានចម្រើនឥន្ទ្រិយទាំង ៥ មិនបានចម្រើនពលៈទាំង ៥ មិនបានចម្រើនពោជ្ឈង្គទាំង ៧ មិនបានចម្រើនអរិយមគ្គប្រកបដោយអង្គ ៨ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាមេមាន់មានស៊ុត ៨ ក្តី ១០ ក្តី ១២ ក្តី ឯស៊ុតទាំងនោះមេមាន់មិនបានក្រាបដោយប្រពៃ មិនបានឲ្យបំហាយដោយប្រពៃ មិនបានអប់កំដៅដោយប្រពៃទេ មេមាន់នោះទុកជាមានសេចក្តីប្រាថ្នាកើតឡើងយ៉ាងនេះថា ឱហ្ន៎ កូនមាន់របស់អាត្មាអញគប្បីទម្លាយនូវសម្បកស៊ុត ដោយចុងក្រចកជើង ឬដោយចុងចំពុះ ហើយញាស់មកដោយសួស្តីដូច្នេះក៏ដោយ កូនមាន់ទាំងនោះ ក៏មិនគួរដើម្បីទម្លាយនូវសម្បកស៊ុត ដោយចុងក្រចកជើង ឬដោយចុងចំពុះ ហើយញាស់មកដោយសួស្តីបានឡើយ ។ សេចក្តីនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាមេមាន់ដែលមានស៊ុត ៨ ក្តី ១០ ក្តី ១២ ក្តី ឯស៊ុតទាំងនោះ មេមាន់មិនបានក្រាបដោយប្រពៃ មិនបានឲ្យបំហាយដោយប្រពៃ មិនបានអប់កំដៅដោយប្រពៃ យ៉ាងណាមិញ ។

ឯវមេវ ខោ ភិក្ខវេ ភាវនានុយោគំ អននុយុត្តស្ស ភិក្ខុនោ វិហរតោ កិញ្ចាបិ ឯវំ ឥច្ឆា ឧប្បជ្ជេយ្យ អហោ វត មេ អនុបាទាយ អាសវេហិ ចិត្តំ វិមុច្ចេយ្យាតិ អថខ្វស្ស នេវ អនុបាទាយ អាសវេហិ ចិត្តំ វិមុច្ចតិ ។ តំ កិស្ស ហេតុ ។ អភាវិតត្តាតិស្ស វចនីយំ ។ កិស្ស អភាវិតត្តា ។ អភាវិតត្តា ចតុន្នំ សតិបដ្ឋានានំ អភាវិតត្តា ចតុន្នំ សម្មប្បធានានំ អភាវិតត្តា ចតុន្នំ ឥទ្ធិបាទានំ អភាវិតត្តា បញ្ចន្នំ ឥន្ទ្រិយានំ អភាវិតត្តា បញ្ចន្នំ ពលានំ អភាវិតត្តា សត្តន្នំ ពោជ្ឈង្គានំ អភាវិតត្តា អរិយស្ស អដ្ឋង្គិកស្ស មគ្គស្ស ។ ភាវនានុយោគំ អនុយុត្តស្ស ភិក្ខវេ ភិក្ខុនោ វិហរតោ កិញ្ចាបិ ន ឯវំ ឥច្ឆា ឧប្បជ្ជេយ្យ អហោ វត មេ អនុបាទាយ អាសវេហិ ចិត្តំ វិមុច្ចេយ្យាតិ អថខ្វស្ស អនុបាទាយ អាសវេហិ ចិត្តំ វិមុច្ចតិ ។

ម្នាលភិក្ខុទាំងឡាយ ឯភិក្ខុដែលមិនបានប្រកបរឿយ ៗ នូវភាវនានុយោគ ទុកជាមានសេចក្ដីប្រាថ្នាកើតឡើងយ៉ាងនេះថា ឱហ្ន៎ ចិត្តរបស់អាត្មាអញគប្បីរួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនបានប្រកាន់មាំ ដូច្នេះក៏ដោយ ចិត្តរបស់ភិក្ខុនោះក៏នៅតែមិនរួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនបានប្រកាន់មាំឡើយ ។ សេចក្ដីនោះ ព្រោះហេតុអ្វី ។ គប្បីឆ្លើយថា ព្រោះភិក្ខុនោះមិនបានចម្រើន ។ មិនបានចម្រើនអ្វី ។ មិនបានចម្រើនសតិប្បដ្ឋានទាំង ៤ មិនបានចម្រើនសម្មប្បធានទាំង ៤ មិនបានចម្រើនឥទ្ធិបាទទាំង ៤ មិនបានចម្រើនឥន្ទ្រិយទាំង ៥ មិនបានចម្រើនពលៈទាំង ៥ មិនបានចម្រើនពោជ្ឈង្គទាំង ៧ មិនបានចម្រើនអរិយមគ្គប្រកបដោយអង្គ ៨ ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបរឿយ ៗ នូវភាវនានុយោគ ទុកជាមិនមានសេចក្ដីប្រាថ្នាកើតឡើងយ៉ាងនេះថា ឱហ្ន៎ ចិត្តរបស់អាត្មាអញគប្បីរួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនបានប្រកាន់មាំ ដូច្នេះក៏ដោយ ចិត្តរបស់ភិក្ខុនោះ រមែងរួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនបានប្រកាន់មាំដោយពិត ។

តំ កិស្ស ហេតុ ។ ភាវិតត្តាតិស្ស វចនីយំ ។ កិស្ស ភាវិតត្តា ។ ភាវិតត្តា ចតុន្នំ សតិបដ្ឋានានំ ភាវិតត្តា ចតុន្នំ សម្មប្បធានានំ ភាវិតត្តា ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា បញ្ចន្នំ ឥន្ទ្រិយានំ ភាវិតត្តា បញ្ចន្នំ ពលានំ ភាវិតត្តា សត្តន្នំ ពោជ្ឈង្គានំ ភាវិតត្តា អរិយស្ស អដ្ឋង្គិកស្ស មគ្គស្ស ។ សេយ្យថាបិ ភិក្ខវេ កុក្កុដិយា អណ្ឌានិ អដ្ឋ វា ទស វា ទ្វាទស វា តានស្សុ កុក្កុដិយា សម្មា អធិសយិតានិ សម្មា បរិសេទិតានិ សម្មា បរិភាវិតានិ កិញ្ចាបិ តស្សា កុក្កុដិយា ន ឯវំ ឥច្ឆា ឧប្បជ្ជេយ្យ អហោ វត មេ កុក្កុដបោតកា បាទនខសិខាយ វា មុខតុណ្ឌកេន វា អណ្ឌកោសំ បទាលេត្វា សោត្ថិនា អភិនិព្ភិជ្ជេយ្យុន្តិ អថខោ ភព្វា វ តេ កុក្កុដបោតកា បាទនខសិខាយ វា មុខតុណ្ឌកេន វា អណ្ឌកោសំ បទាលេត្វា សោត្ថិនា អភិនិព្ភិជ្ជិតុំ ។ តំ កិស្ស ហេតុ ។ តថា ហិ ភិក្ខវេ កុក្កុដិយា អណ្ឌានិ អដ្ឋ វា

សេចក្តីនោះ ព្រោះហេតុអ្វី ។ គប្បីឆ្លើយថា ព្រោះភិក្ខុនោះបានចម្រើន ។
បានចម្រើនអ្វី ។ បានចម្រើនសតិប្បដ្ឋានទាំង ៤ បានចម្រើនសម្មប្បធាន
ទាំង ៤ បានចម្រើនឥទ្ធិបាទទាំង ៤ បានចម្រើនឥន្ទ្រិយទាំង ៥ បានចម្រើន
ពលៈទាំង ៥ បានចម្រើនពោជ្ឈង្គទាំង ៧ បានចម្រើនអរិយមគ្គប្រកបដោយ
អង្គ ៨ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាមេមាន់មានស៊ុត ៨ ក្តី ១០ ក្តី
១២ ក្តី ឯស៊ុតទាំងនោះ មេមាន់ក៏បានក្រាបដោយប្រពៃ បានឲ្យចំហាយ
ដោយប្រពៃ បានអប់កំដៅដោយប្រពៃ ទុកជាមេមាន់នោះ មិនមាន
សេចក្តីប្រាថ្នាកើតឡើងយ៉ាងនេះថា ឱហ្ន៎ កូនមាន់របស់អាត្មាអញគប្បី
ទម្លាយនូវសម្បកស៊ុត ដោយចុងក្រចកជើង ឬដោយចុងចំពុះ ហើយ
ញាស់ចេញមកដោយសួស្តីដូច្នេះក៏ដោយ កូនមាន់ទាំងនោះក៏គួរដើម្បី
ទម្លាយនូវសម្បកស៊ុត ដោយចុងក្រចកជើង ឬដោយចុងចំពុះ ហើយ
ញាស់ចេញមកដោយសួស្តីបានដោយពិត ។ សេចក្តីនោះ ព្រោះ
ហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាមេមាន់ដែលមានស៊ុត ៨ ក្តី

ទស វា ទ្វាទស វា តានស្សុ កុក្កុដិយា សម្មា អធិសយិតានិ សម្មា បរិសេទិតានិ សម្មា បរិភាវិតានិ ។ ឯវមេវ ខោ ភិក្ខវេ ភាវនានុយោគំ អនុយុត្តស្ស ភិក្ខុនោ វិហរតោ កិញ្ចាបិ ន ឯវំ ឥច្ឆា ឧប្បជ្ជេយ្យ អហោ វត មេ អនុបាទាយ អាសវេហិ ចិត្តំ វិមុច្ចេយ្យាតិ អថខ្វស្ស អនុបាទាយ អាសវេហិ ចិត្តំ វិមុច្ចតិ ។ តំ កិស្ស ហេតុ ។ ភាវិតត្តាតិស្ស វចនីយំ ។ កិស្ស ភាវិតត្តា ។ ភាវិតត្តា ចតុន្នំ សតិបដ្ឋានានំ ភាវិតត្តា ចតុន្នំ សម្មប្បធានានំ ភាវិតត្តា ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា បញ្ចន្នំ ឥន្ទ្រិយានំ ភាវិតត្តា បញ្ចន្នំ ពលានំ ភាវិតត្តា សត្តន្នំ ពោជ្ឈង្គានំ ភាវិតត្តា អរិយស្ស អដ្ឋង្គិកស្ស មគ្គស្ស ។

(២៦២) សេយ្យថាបិ ភិក្ខវេ ផលគណ្ឌស្ស(១) វា ន ផលគណ្ឌន្តេវាសិស្ស វា វាសិជដេ ទិស្សន្តេ វា អង្គុលិបទានិ ទិស្សន្តិ អង្គុដ្ឋបទា នោ ច ខ្វស្ស ឯវមស្ស ញាណំ ហោតិ ឯត្តកំ វា(២) មេ អជ្ជ វាសិជដស្ស ខីណំ ឯត្តកំ ហិយ្យោ ឯត្តកំ បរេតិ អថខ្វស្ស

១ ឱ. ផលគណ្ឌស្ស វា ។ ២ ឯត្តកំ វត មេ ។

១០ក្តី ១២ក្តី ឯស៊ុតទាំងនោះ មេមាន់បានក្រាបដោយប្រពៃ បានឱ្យបំភាយដោយប្រពៃ បានអប់កំដៅដោយប្រពៃ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ឯភិក្ខុអ្នកប្រកបរឿយៗ នូវភាវនានុយោគ ទុកជាមិនមានសេចក្តីប្រាថ្នាកើតឡើងយ៉ាងនេះថា ឱហ្ន៎ ចិត្តរបស់អាត្មាអញគប្បីរួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ដូច្នេះក៏ដោយ ចិត្តរបស់ភិក្ខុនោះ រមែងរួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ បានដោយពិត ។ សេចក្តីនោះ ព្រោះហេតុអ្វី ។ គប្បីឆ្លើយថា ព្រោះភិក្ខុនោះបានចម្រើន ។ បានចម្រើនអ្វី ។ បានចម្រើនសតិប្បដ្ឋានទាំង ៤ បានចម្រើនសម្មប្បធានទាំង ៤ បានចម្រើនឥទ្ធិបាទទាំង ៤ បានចម្រើនឥន្ទ្រិយទាំង ៥ បានចម្រើនពលៈទាំង ៥ បានចម្រើនពោជ្ឈង្គទាំង ៧ បានចម្រើនអរិយមគ្គប្រកបដោយអង្គ ៨ ។

(២៦២) ម្នាលភិក្ខុទាំងឡាយ ដូចជាជាងឈើ ឬកូនសិស្សរបស់ជាងឈើ រមែងយកម្រាមដៃនិងមេដៃចាប់កាន់ត្រង់មៀនកាំបិតជាប្រាកដ ប៉ុន្តែជាងឈើនោះក៏មិនមានសេចក្តីដឹងយ៉ាងនេះថា ក្នុងថ្ងៃនេះ មៀនកាំបិតរបស់អាត្មាអញ សឹកអស់ទៅប៉ុណ្ណោះ ម្សិលមិញសឹកអស់ប៉ុណ្ណោះ ម្សិលម៉្ងៃសឹកអស់ប៉ុណ្ណោះ ដូច្នេះឡើយ ជាងឈើនោះគ្រាន់តែ

ខីណ ខីណន្តេវ(១) ញាណំ ហោតិ ។ ឯវមេវ ខោ ភិក្ខវេ ភាវនានុយោគមនុយុត្តស្ស ភិក្ខុនោ វិហរតោ កិញ្ចាបិ ន ឯវំ ញាណំ ហោតិ ឯត្តកំ វត មេ អជ្ជ អាសវានំ ខីណំ ឯត្តកំ ហិយ្យោ ឯត្តកំ បរេតិ អថខ្វស្ស ខីណេ ខីណន្តេវ ញាណំ ហោតិ ។ សេយ្យថាបិ ភិក្ខវេ សាមុទ្ទិកាយ នាវាយ វេត្តពន្ធនពទ្ធាយ ឆម្មាសានិ(២) ឧទកេ បរិយាទាយ ហេមន្តិកេន(៣) ថលំ ឧក្ខិត្តាយ វាតាតបបរេតានិ វេត្តពន្ធនានិ តានិ បាវុស្សកេន មេឃេន អភិប្បវុដ្ឋានិ អប្បកសិរេនេវ បដិប្បស្សម្ភន្តិ បូតិកានិ ភវន្តិ ។ ឯវមេវ ខោ ភិក្ខវេ ភាវនានុយោគមនុយុត្តស្ស ភិក្ខុនោ វិហរតោ អប្បកសិរេនេវ សញ្ញោជនានិ បដិប្បស្សម្ភន្តិ បូតិកានិ ភវន្តិ ។

---

១ ខីណំ ខិណន្តេវ ។ ២ ម. វស្សមាសានិ ។ ៣ ឱ. ហេមន្តិកេ ។

មានសេចក្តីដឹងថាអស់ទៅ ៗ តែប៉ុណ្ណោះ ដោយពិត យ៉ាងណាមិញ ៗ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបរឿយ ៗ នូវការនានុយោគ ក៏មិនមានសេចក្តីដឹងយ៉ាងនេះថា ក្នុងថ្ងៃនេះអាសវៈរបស់អាត្មាអញអស់ទៅប៉ុណ្ណោះ ម្សិលមិញអស់ទៅប៉ុណ្ណោះ ម្សិលម៉្ងៃអស់ទៅប៉ុណ្ណោះ ដូច្នេះដែរ ភិក្ខុនោះគ្រាន់តែមានសេចក្តីដឹងថាអស់ទៅ ៗ ប៉ុណ្ណោះ ក៏យ៉ាងនោះឯង ៗ ម្នាលភិក្ខុទាំងឡាយ មួយទៀត ដូចជាទូកនៅក្នុងសមុទ្រ ដែលគេចងដោយចំណងផ្តៅត្រាំនៅក្នុងទឹកអស់ ៦ ខែ ទើបគេស្រង់ឡើងដាក់លើគោកក្នុងហេមន្តរដូវ ឯចំណងផ្តៅទាំងនោះ ត្រូវខ្យល់និងកំដៅថ្ងៃគ្របសង្កត់ មេឃបង្អុរទឹកភ្លៀងគ្របសង្កត់ ក៏រមាសពុកផុយទៅ ដោយមិនយូរ យ៉ាងណាមិញ ៗ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបរឿយ ៗ នូវការនានុយោគ រមែងមានសញ្ញោជនៈស្ងប់រម្ងាប់ទៅ ពុកផុយទៅដោយមិនលំបាក ក៏យ៉ាងនោះឯង ៗ

[២៦៣] សាវត្ថិយំ ។ អនិច្ចសញ្ញា ភិក្ខវេ ភាវិតា ពហុលីកតា សព្វំ កាមរាគំ បរិយាទិយតិ សព្វំ រូបរាគំ បរិយាទិយតិ សព្វំ ភវរាគំ បរិយាទិយតិ សព្វំ អវិជ្ជំ បរិយាទិយតិ សព្វំ អស្មិមានំ(១) សមូហនតិ ។ សេយ្យថាបិ ភិក្ខវេ សរទសមយេ កស្សកោ មហានង្គលេន កសន្តោ សព្វានិ មូលសន្តានកានិ សម្បទាលេន្តោ កសតិ ។ ឯវមេវ ខោ ភិក្ខវេ អនិច្ចសញ្ញា ភាវិតា ពហុលីកតា សព្វំ កាមរាគំ បរិយាទិយតិ សព្វំ រូបរាគំ បរិយាទិយតិ សព្វំ ភវរាគំ បរិយាទិយតិ សព្វំ អវិជ្ជំ បរិយាទិយតិ សព្វំ អស្មិមានំ សមូហនតិ ។

[២៦៤] សេយ្យថាបិ ភិក្ខវេ បព្វជលាយកោ បព្វជំ លាយិត្វា អគ្គេ គហេត្វា ឱធុនាតិ និធុនាតិ និច្ឆោដេតិ(២) ។ ឯវមេវ ខោ ភិក្ខវេ អនិច្ចសញ្ញា ភាវិតា ។បេ។

---

១ បរិយាទិយតិ សមូហន្តិ ។ ២ ឱ. និច្ឆោទេតិ ម. និច្ឆោឌេតិ ។

[២៦៣] ជិតក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ អនិច្ចសញ្ញាដែលបុគ្គលបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ រមែងគ្របសង្កត់នូវកាមរាគ(១)ទាំងអស់ គ្របសង្កត់នូវរូបរាគ(២)ទាំងអស់ គ្របសង្កត់នូវភវរាគ(៣)ទាំងអស់ គ្របសង្កត់នូវអវិជ្ជាទាំងអស់ ដកឡើងនូវអស្មិមានះទាំងអស់ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសអ្នកភ្ជួរ កាលភ្ជួរដោយនង្គ័លធំក្នុងសរទសម័យ តែងភ្ជួរទម្លាយនូវបណ្ដាញនៃឫសទាំងពួង យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ឯអនិច្ចសញ្ញាដែលបុគ្គលបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ រមែងគ្របសង្កត់នូវកាមរាគទាំងអស់ គ្របសង្កត់នូវរូបរាគទាំងអស់ គ្របសង្កត់នូវភវរាគទាំងអស់ គ្របសង្កត់នូវអវិជ្ជាទាំងអស់ ដកឡើងនូវអស្មិមានះទាំងអស់បាន ក៏យ៉ាងនោះឯង ។

[២៦៤] ម្នាលភិក្ខុទាំងឡាយ មួយទៀត ដូចជាបុរសអ្នកច្រូតស្មៅជំណោកទន្សាយ បានច្រូតស្មៅជំណោកទន្សាយ ចាប់ចុងហើយ រលាស់គ្រវាត់បោក យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ អនិច្ចសញ្ញាដែលបុគ្គលបានចម្រើនហើយ ក៏យ៉ាងនោះឯង ។បេ។

---

១ សេចក្ដីត្រេកអរក្នុងកាមភព ។ ២ សេចក្ដីត្រេកអរក្នុងរូបភព ។ ៣ សេចក្ដីត្រេកអរក្នុងភព។

(២៦៥) សេយ្យថាបិ ភិក្ខវេ អម្ពបិណ្ឌិយា វណ្ដច្ឆិន្នាយ[១] យានិ តត្ថ អម្ពានិ វណ្ដូបនិពន្ធនានិ សព្វានិ តានិ តទន្វយានិ[២] ភវន្តិ ។ ឯវមេវ ខោ ភិក្ខវេ អនិច្ចសញ្ញា ភាវិតា ពហុលីកតា ។ បេ ។[៣]

(២៦៦) សេយ្យថាបិ ភិក្ខវេ កូដាគារស្ស យា កាចិ គោបានសិយោ សព្វា តា កូដង្គមា កូដនិន្នា កូដសមោសរណា កូដំ តាសំ អគ្គមក្ខាយតិ ។ ឯវមេវ ខោ ភិក្ខវេ អនិច្ចសញ្ញា ភាវិតា ។ បេ ។[៤]

(២៦៧) សេយ្យថាបិ ភិក្ខវេ យេ កេចិ មូលគន្ធា កាឡានុសារី តេសំ អគ្គមក្ខាយតិ ។ ឯវមេវ ខោ ភិក្ខវេ អនិច្ចសញ្ញា ភាវិតា ។ បេ ។

---

១ ឱ. វណ្ដច្ឆិន្នាយ ។ ២ ឱ. ម. តទន្វយានិ ។ ៣-៤ ម. សព្វំ អស្មិមានំ សមូហនតិ ។

[៦៦៥] ម្នាលភិក្ខុទាំងឡាយ មួយទៀត ដូចជាចង្កោមស្វាយដែលបុគ្គលកាត់ទងហើយ បណ្តាផ្លែស្វាយទាំងនោះ ផ្លែស្វាយទាំងឡាយណា ដែលជាប់នៅនឹងទង ផ្លែស្វាយទាំងអស់នោះ រមែងទៅតាមចង្កោមស្វាយនោះ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ អនិច្ចសញ្ញាដែលបុគ្គលបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ ។បេ។ ក៏យ៉ាងនោះឯង ។

[៦៦៦] ម្នាលភិក្ខុទាំងឡាយ មួយទៀត ដូចជាឈើបង្កង់ណានីមួយរបស់ផ្ទះមានកំពូល ឯបង្កង់ទាំងអស់នោះបាញ់ទៅរកកំពូល ផ្អាកទៅរកកំពូល ប្រជុំចុះត្រង់កំពូល ឯកំពូលប្រាកដជាប្រសើរ ជាងបង្កង់ទាំងនោះ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ អនិច្ចសញ្ញាដែលបុគ្គលបានចម្រើនហើយ ។បេ។ ក៏យ៉ាងនោះឯង ។

[៦៦៧] ម្នាលភិក្ខុទាំងឡាយ មួយទៀត ដូចជាវត្ថុមានក្លិនពីឫសណានីមួយ ស្មៅស្គា ប្រាកដជាប្រសើរ ជាងវត្ថុមានក្លិនពីឫសទាំងនោះ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ អនិច្ចសញ្ញាដែលបុគ្គលបានចម្រើនហើយ ។បេ។ ក៏យ៉ាងនោះឯង ។

[២៦៨] សេយ្យថាបិ ភិក្ខវេ យេ កេចិ សារគន្ធា លោហិតចន្ទនំ តេសំ អគ្គមក្ខាយតិ ។ ឯវមេវ ខោ ភិក្ខវេ អនិច្ចសញ្ញា ភាវិតា ។បេ។

[២៦៩] សេយ្យថាបិ ភិក្ខវេ យេ កេចិ បុប្ផគន្ធា វស្សិកំ តេសំ អគ្គមក្ខាយតិ ។ ឯវមេវ ខោ ភិក្ខវេ អនិច្ចសញ្ញា ភាវិតា ។បេ។

[២៧០] សេយ្យថាបិ ភិក្ខវេ យេ កេចិ កុដ្ឋរាជានោ(១) សព្វេ តេ រញ្ញោ ចក្កវត្តិស្ស អនុយន្តា(២) ភវន្តិ រាជា តេសំ ចក្កវត្តិ អគ្គមក្ខាយតិ ។ ឯវមេវ ខោ ភិក្ខវេ អនិច្ចសញ្ញា ភាវិតា ។បេ។

---

១ ឱ. ម. កុឌ្ឍរាជានោ ។ ២ អនុយុត្តាតិបិ បាឋោ ។

[២៦៨] ម្នាលភិក្ខុទាំងឡាយ មួយទៀត ដូចជាវត្ថុមានក្លិនពីខ្លឹមណាមួយ ចន្ទន៍ក្រហម ប្រាកដជាប្រសើរ ជាងវត្ថុមានក្លិនពីខ្លឹមទាំងនោះ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ អនិច្ចសញ្ញាដែលបុគ្គលបានចម្រើនហើយ ។ បេ ។ ក៏យ៉ាងនោះឯង ។

[២៦៩] ម្នាលភិក្ខុទាំងឡាយ មួយទៀត ដូចជាវត្ថុមានក្លិនពីផ្កាណាមួយ ម្លិះលា ប្រាកដជាប្រសើរ ជាងវត្ថុមានក្លិនពីផ្កាទាំងនោះ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ឯអនិច្ចសញ្ញាដែលបុគ្គលបានចម្រើនហើយ ។ បេ ។ ក៏យ៉ាងនោះឯង ។

[២៧០] ម្នាលភិក្ខុទាំងឡាយ មួយទៀត ដូចជាពួកស្ដេចខ្សោយអំណាចណាមួយ ស្ដេចទាំងអស់នោះ ជាបំណុះស្ដេចចក្រពត្តិ ឯស្ដេចចក្រពត្តិ ប្រាកដជាប្រសើរជាងស្ដេចទាំងនោះ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ អនិច្ចសញ្ញាដែលបុគ្គលបានចម្រើនហើយ ។ បេ ។ ក៏យ៉ាងនោះឯង ។

(២៧១) សេយ្យថាបិ ភិក្ខវេ យា កាចិ តារករូបានំ បភា សព្វា តា ចន្ទិមប្បភាយ កលំ នាគ្ឃន្តិ សោឡសឹ ចន្ទប្បភា តាសំ អគ្គមក្ខាយតិ ។ ឯវមេវ ខោ ភិក្ខវេ អនិច្ចសញ្ញា ភាវិតា ។ បេ ។

(២៧២) សេយ្យថាបិ ភិក្ខវេ សរទសមយេ វិសុទ្ធេ(១) វិគតវលាហកេ ទេវេ អាទិច្ចោ នភំ អព្ភុស្សក្កមានោ សព្វំ អាកាសគតំ តមគតំ អភិវិហច្ច ភាសតេ ច តបតេ ច វិរោចតេ ច ។ ឯវមេវ ខោ ភិក្ខវេ អនិច្ចសញ្ញា ភាវិតា ពហុលីកតា សព្វំ កាមរាគំ បរិយាទិយតិ សព្វំ រូបរាគំ បរិយាទិយតិ សព្វំ ភវរាគំ បរិយាទិយតិ សព្វំ អវិជ្ជំ បរិយាទិយតិ សព្វំ អស្មិមានំ សមូហនតិ ។

---

១ ឱ. ម. វិទ្ធេ ។

(២៧១) ម្នាលភិក្ខុទាំងឡាយ មួយទៀត ដូចជាពន្លឺនៃពួកផ្កាយណាមួយ ពន្លឺទាំងអស់នោះ រមែងមិនដល់នូវចំណែកដែលបុគ្គលចែកជាដប់ប្រាំមួយ ៗ លើកនៃពន្លឺព្រះចន្ទ ពន្លឺព្រះចន្ទ ប្រាកដជាប្រសើរជាងពន្លឺទាំងនោះ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ អនិច្ចសញ្ញាដែលបុគ្គលបានចម្រើនហើយ ។បេ។ ក៏យ៉ាងនោះឯង ។

(២៧២) ម្នាលភិក្ខុទាំងឡាយ មួយទៀត ដូចជាព្រះអាទិត្យ កាលបើមេឃដ៏ស្អាត ប្រាសចាកពពកហើយ ក្នុងសរទសម័យ ក៏ស្ទុះឡើងទៅកាន់អាកាស កំចាត់បង់នូវងងឹត ដែលតាំងនៅក្នុងអាកាសទាំងពួងហើយ ក៏រមែងភ្លឺផង ក្តៅផង រុងរឿងផង យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ អនិច្ចសញ្ញាដែលបុគ្គលបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ រមែងគ្របសង្កត់នូវកាមរាគទាំងអស់ គ្របសង្កត់នូវរូបរាគទាំងអស់ គ្របសង្កត់នូវភវរាគទាំងអស់ គ្របសង្កត់នូវអវិជ្ជាទាំងអស់ ដកឡើងនូវអស្មិមានះទាំងអស់បាន ក៏យ៉ាងនោះឯង ។

(២៧៣) កថំ ភាវិតា ច ភិក្ខវេ អនិច្ចសញ្ញា កថំ ពហុលីកតា សព្វំ កាមរាគំ បរិយាទិយតិ ។បេ។ សព្វំ អស្មិមានំ សមូហនតិ ។ ឥតិ រូបំ ឥតិ រូបស្ស សមុទយោ ឥតិ រូបស្ស អត្ថង្គមោ ។ ឥតិ វេទនា ។ ឥតិ សញ្ញា ។ ឥតិ សង្ខារា ។ ឥតិ វិញ្ញាណំ ឥតិ វិញ្ញាណស្ស សមុទយោ ឥតិ វិញ្ញាណស្ស អត្ថង្គមោតិ ។ ឯវំ ភាវិតា ខោ ភិក្ខវេ អនិច្ចសញ្ញា ឯវំ ពហុលីកតា សព្វំ កាមរាគំ បរិយាទិយតិ សព្វំ រូបរាគំ បរិយាទិយតិ សព្វំ ភវរាគំ បរិយាទិយតិ សព្វំ អវិជ្ជំ បរិយាទិយតិ សព្វំ អស្មិមានំ សមូហនតីតិ ។

បុប្ផវគ្គោ បញ្ចមោ ។

[២៧៣] ម្នាលភិក្ខុទាំងឡាយ ចុះអនិច្ចសញ្ញា ដែលបុគ្គលបាន ចម្រើនហើយ ដូចម្តេច ដែលបុគ្គលបានធ្វើឲ្យច្រើនហើយ ដូចម្តេច ទើបគ្របសង្កត់នូវកាមរាគទាំងអស់ ។បេ។ ដកឡើងនូវអស្មិមានះទាំងអស់បាន ។ បានចម្រើនថា រូបដូច្នេះ ហេតុឲ្យកើតឡើងនៃរូបដូច្នេះ សេចក្តីអស់ទៅនៃរូបដូច្នេះ ។ វេទនាដូច្នេះ ។ សញ្ញាដូច្នេះ ។ សង្ខារដូច្នេះ ។ វិញ្ញាណដូច្នេះ ហេតុឲ្យកើតឡើងនៃវិញ្ញាណដូច្នេះ សេចក្តីអស់ទៅនៃវិញ្ញាណដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ អនិច្ចសញ្ញាដែលបុគ្គលបានធ្វើឲ្យច្រើនហើយ យ៉ាងនេះឯង រមែងគ្របសង្កត់ នូវកាមរាគទាំងអស់ គ្របសង្កត់នូវរូបរាគទាំងអស់ គ្របសង្កត់នូវភវរាគទាំងអស់ គ្របសង្កត់នូវអវិជ្ជាទាំងអស់ ដកឡើងនូវអស្មិមានះទាំងអស់បាន ។

ចប់ បុប្ផវគ្គទី ៥ ។

## តស្សុទ្ទានំ

នទី បុប្ផញ្ច ផេណញ្ច

គោមយញ្ច នខាសិខំ

សាមុទ្ទកំ(១) ទ្វេ ច គទ្ទុលា

វាសិញ្ញាយ តេ នសាតិ(២) ។

មជ្ឈិមបណ្ណាសកោ សមត្តោ ។

## តស្ស មជ្ឈិមបណ្ណាសកស្ស វគ្គុទ្ទានំ

ឧបាយោ អរហន្តោ ច

ខជ្ជនិថេរសវ្ហយំ(៣)

បុប្ផវគ្គេន បណ្ណាស

ទុតិយោ តេន បវុច្ចតិ ។

---

១ ឱ. ម. សុទ្ធកំ ។ ២ ភាសិជដំ អនិច្ចតាតិ ។ ៣ ខជ្ជនីថេរសម្ពយំ ។

## ឧទ្ទាននៃបុប្ផវគ្គនោះគឺ

និយាយអំពីស្ទឹង ១ ផ្កាផលជាតិ ១ ពពុះទឹក ១ អាចម៍គោ ១ ចុងព្រះនខា ១ សមុទ្រ ១ ដងដោយសម្រាប់ចងឆ្កែពីរលើក ទូក ១ សញ្ញា ១ ត្រូវជា ១០ ។

ចប់ មជ្ឈិមបណ្ណាសកៈ ។

## ឧទ្ទាននៃវគ្គរបស់មជ្ឈិមបណ្ណាសកៈនោះគឺ

ឧបាយវគ្គ ១ អរហន្តវគ្គ ១ ខជ្ជនីយវគ្គ ១ ថេរវគ្គ ១ បុប្ផវគ្គ ១ លោកឲ្យឈ្មោះថា ទុតិយបណ្ណាសកៈ ។

# សុត្តន្តបិដកេ

# សំយុត្តនិកាយស្ស ខន្ធវារវគ្គោ

# បញ្ចមោ ភាគោ

---

## មាតិកា

អង្កេ


ខន្ធសំយុត្តស្ស មូលបណ្ណាសកេ នកុលបិតុវគ្គោ បឋមោ . . . ៣

អនិច្ចវគ្គោ ទុតិយោ . . . . . ៤៩

ភារវគ្គោ តតិយោ . . . . . ៥៧

នតុម្ហាកវគ្គោ ចតុត្ថោ . . . . ៧៥

អត្តទីបវគ្គោ បញ្ចមោ . . . . ៩៦

ខន្ធសំយុត្តស្ស មជ្ឈិមបណ្ណាសកេ ឧបាយវគ្គោ បឋមោ . . . . . ១២២

អរហន្តវគ្គោ ទុតិយោ . . . . ១៧៣

ខជ្ជនីយវគ្គោ តតិយោ . . . . ១៩១

ថេរវគ្គោ ចតុត្ថោ . . . . . . ២៤២

បុប្ផវគ្គោ បញ្ចមោ . . . . . ៣១៤


---

# សុត្តន្តបិដក

## សំយុត្តនិកាយ ខន្ធវារវគ្គ

## បញ្ចមភាគ

---

## មាតិកា

លេខទំព័រ


ខន្ធសំយុត្ត មូលបណ្ណាសកៈ នកុលបិតវគ្គ ទី ១ . . . . . . . . . . . . . . ៣

អនិច្ចវគ្គ ទី ២ . . . . . . . . . . . . . . . . ៤៩

ភារវគ្គ ទី ៣ . . . . . . . . . . . . . . . . ៥៧

នតុម្ហាកវគ្គ ទី ៤ . . . . . . . . . . . . . . . ៧៥

អត្តទីបវគ្គ ទី ៥ . . . . . . . . . . . . . . . ៩៦

ខន្ធសំយុត្ត មជ្ឈិមបណ្ណាសកៈ ឧបាយវគ្គ ទី ១ . . . . . . . . . . . . . ១២២

អរហន្តវគ្គ ទី ២ . . . . . . . . . . . . . . ១៧៣

ខជ្ជនីយវគ្គ ទី ៣ . . . . . . . . . . . . . . ១៩១

ថេរវគ្គ ទី ៤ . . . . . . . . . . . . . . . ២៤២

បុប្ផវគ្គ ទី ៥ . . . . . . . . . . . . . . . . ៣១៤


---

# វិរុទ្ធាវិរុទ្ធបត្តំ

| វិរុទ្ធបាឋោ | អវិរុទ្ធបាឋោ | អង្កេ | បន្តិលេខាយំ |
|---|---|---|---|
| អវេដ្ឍា សាយ | អវេដ្ឍាសាយ | ៣៦ | ៧ |
| នាវេដ្ឍា សាយ | នាវេដ្ឍាសាយ | ៣៨ | ៨ |
| កត្ថចិ ពោបកេ | កត្ថចិ ពោត្ថកេ | ៤៧ | ១២ |
| បញ្ចក្កន្ធា | បញ្ចក្ខន្ធា | ៥៩ | ២ |
| ឧត្តិ ឋានិ | ឧត្តិឋានិ | ៦៧ | ៩ |
| វិហ យេ្យ | វិហរេយ្យ | ៩៣ | ១៥ |
| វុច្ចតិ | វុច្ចតិ | ១០១ | ៤ |
| របំ | រូបំ | ១១៣ | ៥ |
| មជ្ឈមបណ្ណាសកេ | មជ្ឈិមបណ្ណាសកេ | ១៣៣ | ១ |
| វិញ្ញាណស្ស | វិញ្ញាណស្ស | ១៤៣ | ៨ |
| ផស ទិកោធា | ផស្សទិកោធា | ១៤៥ | ៩ |
| ឯវំ | ឯវំ | ១៥០ | ១៤ |
| មជមឈិបណ្ណាសកេ | មជ្ឈិមបណ្ណាសកេ | ១៥៧ | ១ |

# វិរុទ្ធាវិរុទ្ធបត្តំ

| វិរុទ្ធបាឋោ | អវិរុទ្ធបាឋោ | អង្កេ | បន្តិលេខាយំ |
|---|---|---|---|
| ឯវំ បស | ឯវំ បស្សំ | ១៦៦ | ៤ |
| មជ មបណ្ណាសកេ | មជ្ឈិមបណ្ណាសកេ | ១៦៧ | ១ |
| មជ មបណ្ណាសកេ | មជ្ឈិមបណ្ណាសកេ | ១៦៩ | ,, |
| វិញ្ញាណញ្ញោ | វិញ្ញាណញ្ញោ | ២០១ | ១៧ |
| សុខំ វាតិ ទុក្ខំ ភន្តេ ។ | សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ | ២០៧ | ៥ |
| ភិក្ខូហិ សទ្ធិ | ភិក្ខូហិ សទ្ធឹ | ២២០ | ១៦ |
| វិបរិណាមញ្ញថាភាព | វិបរិណាមញ្ញថាភាវ | ២៤៧ | ៤ |
| តេនុបសង្គមឹសុ | តេនុបសង្កមឹសុ | ២៧៧ | ៩ |
| កេវលកប្ប | កេវលកប្បំ | ២៧៨ | ១៣ |
| វិញ្ញាណំ | វិញ្ញាណំ | ៣១៥ | ១២ |
| វិញ្ញាណំ | វិញ្ញាណំ | ៣១៧ | ១១ |
| អភិសម្ពុជ ិតា | អភិសម្ពុជ្ឈិត្វា | ៣១៩ | ៣ |
| បដ្ឋបេត | បដ្ឋបេតិ | ,, | ៤ |

# សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| អាលបើ | កាលបើ | ៤ | ១៥ |
| តែមានចិត្តសោប់សល់ | តែមានចិត្តមិនសោប់សល់ | ៥ | ៥ |
| មនឃើញ | មិនឃើញ | ១០ | ១៦ |
| សូនឲ្យមាន | សូមឲ្យមាន | ២៧ | ១៤ |
| ការកើតឡើង | ការកើតឡើង | ៣៣ | ១០ |
| (៥២) | (៤២) | ៥១ | ២ |
| ជាអនត្តា | ជាអត្តា | ៥៥ | ៥ |
| សេបក្តីលេត់ | សេចក្តីលេត់ | ៧៣ | ១៧ |
| ធមិទាងនេះ | ធមិទាំងនេះ | ៨៩ | ១៥ |
| នូវបាឧទានក្ខន្ធ | នូវឧបាទានក្ខន្ធ | ១០៥ | ១៣ |
| ៣យ៉ាងគឹ | ៣ យ៉ាងគឺ | ១០៦ | ១៥ |
| ប្រសេរ | ប្រសើរ | ១១១ | ៥ |
| ជា ទោស | ជាទោស | ១៤៨ | ១១ |
| នវិញ្ញាណ | នៃវិញ្ញាណ | ១៥០ | ៥ |
| សដែងហើយ | សម្តែងហើយ | ១៨៥ | ១៣ |

# សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| (១៨៥) | (១៨៦) | ១៨៦ | ២ |
| រូបហ្នឹងឯង | រូបហ្នឹងឯង | ,, | ១១ |
| បានបាក់ធ្ងុះ | បានបាក់ធ្ងុះ | ១៩៦ | ៧ |
| សៅផ្អែម | សៅផ្អែម | ២០៤ | ២ |
| មិនសន្យ | មិនសន្យំ | ២១០ | ,, |
| ម្ចាលកិច្ចទាំងឡាយ | ម្ចាលកិច្ចទាំងឡាយ | ២២២ | ១២ |
| មជ្ឈិមបណ្ណាស : | មជ្ឈិមបណ្ណាសក: | ២៤៧ | ១ |
| ទើបឈ្មោះថាពោល | ទើបឈ្មោះថាមិនពោល | ២៦៧ | ៥-៦ |
| ទើបឈ្មោះថាពោល | ទើបឈ្មោះថាមិនពោល | ២៦៩ | ១០ |
| មិនសង័ យ | មិនសង្ស័យ | ២៨១ | ២ |
| ហើយនរណាឡើយ | ហើយ នរណាឡើយ | ៣០៥ | ,, |
| កង្ខ | កង្ទ | ៣១៣ | ៦ |
| ព្រាះដំណើរនោះ | ព្រោះដំណើរនោះ | ៣១៥ | ១៥ |
| ឱបាទានក្ខន្ធ | ឧបាទានក្ខន្ធ | ៣៤៣ | ៧ |

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE